គ្រប់គ្រងដោយគណៈកម្មការជាតិ
COMMISSION DES MŒURS & COUTUMES

ធម្មសន្ទិយា

ទស្សនាវដ្តី ផ្សាយចំណាំងពាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣១ លេខ ៣ ខែកក្កដា

ព. ស. ២៥០២ គ. ស. ១៩៥៩

ភ្នំពេញ

LIBRARY
BUDDHIST INS

អង្គុលិសន្ទេស

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	មតិយោបល់	ទំព័រ
- អំពីការត្រួតប៉ិនខ្លួន	លោក ស៊ីន-ហ៊ិន រៀបរៀង	៧២៩
- ឥសូម្ចឹងដាតក	ព្រះញាណកោសល ញាណ-ឈីន រៀបរៀង	៧៣៤
- សុវត្ថិដាតក (តមក)	លោក ជិង-រឹង បម្លែងពីសាស្ត្រស្លឹកឥវ៉ែន	៧៥៣
ផ្នែកអក្សរសាស្ត្រ		
- រឿងព្រៃងនឹងរឿងប្រភពប្រទេសដ៏ច្នៃន	លោក ភ័យ-ប៊ុក រៀបរៀង	៧៧៣
- រឿងមរណមាន	លោក ប៊ី-សុវណ្ណ បម្លែងពីសាស្ត្រស្លឹកឥវ៉ែ	៧៨៤
-រឿងព្រៃង ចែងអំពីអ្នកប្រើគំនិតខ្មែរសាំឡូមានពុក្នុងដៃខ្លួន	លោក ម៉ុន-អេង រៀបរៀង	៧៩៣
- រឿងហង្សិយន្ត (តមរ)	លោក អឹម-ភន បម្លែងពីសាស្ត្រស្លឹកឥវ៉ែ	៨០១
- ទំនៀមកាន់ទុក្ខសពនៃសាមញ្ញជនជាតិខ្មែរ	លោក ប៊ូ-ប៉ូ រៀបរៀង	៨១៩
- រឿងសាមកុក (តមក)	តាញ៉ី ទូ-ភន ប្រែ	៨២៣
ផ្នែកកំណាត់ទំនឹងប្រវត្តិសាស្ត្រ		
- ពត៌មានផ្សេងៗរបស់ក្រសួងធម្មការ		៨៣៥
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក)	ព្រះមហាជាង-ទាត់ រៀបរៀង	៨៣៨

* មួយឆ្នាំ មាន ១២ លេខ តម្លៃលក់ ដុល្លារ ២,៣០។០០

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

sommaire

Partie religieuse :

— La manière de se tourner par M. SIN-HEAN 725
— Tilamuthijâtaka par Preah Nhcan Kosal NHEAN-CHHŒUN 734
— Surabajataka (suite) recueilli du manuscrit sur feuilles de latanier par M. THANG-VONG 753

Partie littéraire :

— Contes et Légendes du Japon par M. RAY-BUC. 773
— Histoire de Marana Mâtâ recueillie du manuscrit sur feuilles de latanier par M. By-Suvann. 784
— La pensée fausse conduit l'homme à la misère par M. MAN-ENG. 793
— Histoire de Hang-Yon (suite) recueillie du manuscrit sur feuilles de latanier par M. IM-PHON 800
— Le deuil selon la coutume cambodgienne par M. BOU-PO . 819
— Histoire de Sam-Kok (suite) traduite par l'Okñha NOU-KAN. 823

Notes et Chroniques :

— Nouvelles diverses du Ministère des Cultes 835
—Dictionnaire Sanskrit-Khmer (suite) par vén. PANG-KHAT 838

Prix d'abonnement annuel (comprenant 12 numéros) : 230$00

ផ្នែកសាសនា

វិចារណកថា

អំពីការត្រឡប់ខ្លួន

លោក សុខ - ហ៊ាន រៀបរៀង

បុគ្គលណាធ្វើអំពើបាបហើយ មិនប្តូរអំពើបាបនោះ ដោយអកុសលគឺអរហត្តមគ្គមិនបាន បុគ្គលនោះឈ្មោះថា ញុំាងទុក្ខក្នុងលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រចេញផុតចាកគ្រាគ ។

(អង្គុលិមាលត្ថេរវត្ថុ គាថាធម្មបទ)

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយមិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញុំាងទុក្ខក្នុងលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រចេញផុតចាកគ្រាគ ។

(សម្ពហុលភិក្ខុវត្ថុ គាថាធម្មបទ)

អធិប្បាយ: កាលបើយើងពិចារណាដោយម៉ត់ចត់ចំពោះភាពប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា តាមទំនៀមទុក្ខរបស់ភាវលើនេះ តែងមានដួចប្រទេសនូវគោលវិញ្ញាណនៃការត្រឡប់ខ្លួននេះ មានទៅប្រើនកន្លែង ត្រូវតាំងមានសេចក្តីប្រាថ្នាដ្បៅគួរដើម្បីទុកក្នុងចិត្តរាល់គ្រា ។ ពុទ្ធសាសនាបានបោលតម្លឹមតំលើផែនដីកម្ពុជាតាំងពីបុរាណកាល, ប្រជារាស្ត្រខ្មែរក៏បាន

ខ្លួនខ្ញុំវិញ្ញាធម៌តុន្តសាសនា ទុកជាសរណៈដ៏ទុតម តាំងពីកាលខាងមុខមក ដើម្បីបង្ក្រាបសេចក្តីភ័តភ័យ ខ្លាំងដើម្បីសម្រេចសេចក្តីប្រាថ្នាព្រមទាំងបញ្ជាក់ខ្ញុំវិញសេចក្តីខ្ញុំកចិត្តរបស់ខ្ញុំនៅអនាគត មិនគួរបំភ្លេចចោលខ្ញុំវិញគោលធម៌ការត្រឡប់ខ្លួនដ៏សំខាន់នេះ ហើយបណ្តាយខ្លួនឲ្យលិចលង់ក្នុងសេចក្តីសោមស្ងួត ប្តូរតែធ្លើសេចក្តីអាក្រក់តែម្តាំងទៀតដោយគិតខ្លីថា "ជាន់ដាក់ចូរជ្រុលទៅហើយ ត្រូវខ្លួចឲ្យពេញទី" ប្រហែលគ្នាខឹងថា "ប្រឡាក់កក់ហើយ ខ្លាចអ្វីនឹងចុះកក់ទៀត" នោះឡើយ ។

មែនតែតគឺលោកនេះ មនុស្សយើងត្រូវតែគ្នាដែលធ្លើតិច្ចការអ្វីមួយតែងមានការខុសខ្លះជាធម្មតា បើមិនព្រើនក៏តិច ដូចសុភាសិតលោកចង់ទុកថា "មនុស្សដែលមិនខុស គឺមនុស្សមិនធ្លាប់ធ្លើរ៉ូវឡើយ, ការខុសជារបស់អ្នកធ្លើ ការឲ្យអត់ឱនជារបស់ខ្លាំង" ។ មានសុភាសិតមួយបទទៀតបញ្ជាក់សេចក្តីនេះថា "កំហុសជារបស់មនុស្ស តែមនុស្សដែលល្អគ្រូវបែរត្រឡប់តែខ្លួន" ។

ទាងត្រពុទ្ធសាសនាបានអនុមតិយល់ព្រមថា បុគ្គលក្នុងលោកមានឧកាសនឹងប្រព្រឹត្តអាក្រក់ ឬធ្លើខុស ដែលទាំងឲ្យវិនាសបានដោយដាច់ឈាស់ ព្រោះមានវត្ថុជាមរភេមដែលដឹកនាំឲ្យកើតតិរេសជាហេតុឲ្យធ្លើអាក្រក់ជាច្រើន ទើបលោកប្រៀនប្រដៅឲ្យមានសតិស្មារតីនឹកការពិចារណាជាមុន អំពីដំណើរធ្លើកិច្ចការអ្វីៗតទៅ តែថា ចើជាអ្នក

ធ្វើខុសរួចហើយ ទើបត្រឡប់ធ្វើឲ្យត្រូវវិញមិនបាន តើគួរទើបបណ្តាយ
ខុសឲ្យនៅខុសដូច្នោះហួតទៅ ឬថាទើបធ្វើឲ្យកន្លះខុសនោះ ឲ្យតែតែ
ខុសខ្លាំងឡើង ដោយប្រកាន់គោលដ៏ាយ។ថា កាលបើបានជារួច
ជ្រុលទៅហើយ ត្រូវខួចឲ្យតែញើ, ន័យនេះគប្បីជ្រាបដោយឧបមា:

សិពត់ស្បែកដណ្តប់ដែលជាប់ជាចង្កុះឆ្កួយ។ ដោយហេតុណា
មួយ បុគ្គលគួរទើបដំរះដូលឲ្យល្អ ឬគួរទើបស្បែកដណ្តប់នៅតាំងជាចយ៉ាង
នេះ ឬថាគួរទើបហែកឲ្យតែតែជាប់ ហើយស្បែកដណ្តប់? ន័យនេះត្រូវ
តបថា គួរតែដំរះដូលឲ្យល្អ ។

- មួយទៀត បុគ្គលមានទាយប្រឡាក់របស់ស្មោកគ្រោកមានក្លិនស្អុយ
ជាដើម, តើគួរទើលាងឲ្យជ្រះមិន ឬបណ្តាយខុសឲ្យនោះ ឬថាគួរ
ទើរយកបង់ស្មោកគ្រោកនោះ មកលាបខួនឲ្យតែតែប្រឡាក់ច្រើនថែម
ទៀត? ន័យនេះត្រូវតបថា គួរលាងឲ្យស្អាត ។

-មួយវិញទៀត បុគ្គលដើរទៅកាន់ទីបំណងណាមួយ លុះដល់
ផ្លូវបែកជា២ គំរ្រមុំស្រាលស្រពិលចាំមិនបានថា ផ្លូវណាត្រូវ-ខុស លុះ
ឃើលជ្រើសរើសដើរទៅតាមផ្លូវណាមួយអស់រៀងជាយូរ ទើបដឹងថា
ដើរខុសផ្លូវ, តើគួរទើត្រឡប់ក្រោយមកកាន់ផ្លូវបែកចាស់ ហើយដើរ
ផ្លូវដែលត្រូវតែទៅដាច់ ឬថាដើរទៅតាមផ្លូវណាមួយ ដែលខុសហើយនោះ ឬគួរឈប់
ស្ងៀមនៅត្រឹមនោះ ឬថាគួរដើរតទៅទៀត? សូម្បីន័យនេះក៏ត្រូវ

តបថា គួរត្រឡប់ក្រោយមកដើរផ្លូវដែលត្រូវតទៅជាថ្មី ។

ការងារឬសេចក្តីប្រព្រឹត្តកំដូចគ្នា អ្នកណាធ្លាប់ធុសមកហើយ មិនគួរបណ្តោះឱ្យនៅយ៉ាំដំនោះ ឬបួលចិត្តធ្វើឱ្យតែតែធុសខ្ទាំដរទេ គួរតែតស៊ូកែទ្រឡប់ខ្លួនធ្វើតាមផ្លូវដែលល្អត្រូវ ទើបប្រពៃ ។

អ្នកដែលធ្លាប់ធ្វើធុសមកហើយ ជាកាលំបាកក្នុងដំរែកពុំបាន ឬកើតពាសៈធ្វើសេចក្តីធុសពាំងំបំពាន ឈ្មោះថាប្រតល់ខ្លួនឯងឱ្យដល់ខ្លួវសេចក្តីអាក្រក់ធំដំសេចក្តីធុសជាច្រើនកង ឈ្មោះថាមិនមែនជាម្ចាស់របស់ខ្លួនឯង ទាំងឈ្មោះថា មិនបានធ្វើតាមពាក្យប្រៀនប្រដៅខាងព្រះពុទ្ធសាសនា ដែលប្រដៅឱ្យផ្គត់ផ្គង់ដំរែកបស់ខ្លួនឱ្យប្រព្រឹត្តទៅក្នុងផ្លូវល្អដោយការធ្វើសេចក្តីល្អខៀតផង ។ ឬគួលគួរបណ្តោះសត្តអាម្មេណ៍ចំពោះការប្រព្រឹត្តិរបស់ខ្លួនកន្លងបច្ចប្បន្នដំនាគតទៅជាថ្មី ឱ្យត្រូវតាមគន្ថដំធម៌ ព្រមទាំងគួរប្រកបហេតុនៃសេចក្តីចំរើន តាមសមគួរដល់ផ្លូវលោកឬផ្លូវធម៌ទើបអាចដួយខ្លួនឯងដែលជាអ្នកដំនឹងមកហើយ ឱ្យរួចអឿនក្តីស្វាដំនៅ, ឧបមាដូចជាឈ្លួកកើតក្នុងគំនរសម្រាម គាលដុះលូតលាស់ខ្ពស់ខ្លីដំ តដំមានក្លិនក្រអូបចេញទៅបាន ។ ខាងព្រះពុទ្ធសាសនាសរសើរចំពោះបុគ្គលនេះថាជាអ្នកមិនត្រមមបណ្តាយខ្លួន ឱ្យទៅកដំអំណាចនៃសេចក្តីអាក្រក់ដំនៃសេចក្តីធុស ។ កាលបើគោលបញ្ញត្តិពាក្យថា «កំហុសជារបស់មនុស្ស តែមនុស្សដែលល្អត្រូវចេះត្រឡប់កែខ្លួន» កំគួរ

តិចារណាដល់គោលវិប្បដិបត្តិទាំងព្រះពុទ្ធសាសនា ដែលប្រៀនប្រដៅចំពោះការត្រឡប់កែខ្លួននេះតទៅទៀត ។

១- ក្នុងព្រះត្រៃបិដក មានរឿងថ្លែងថា តថាគតទ្រង់ព្រាហ្មណ៍ខ្លះប្រទ្រឹត្តល្មើសចំពោះព្រះពុទ្ធ ព្រោះបួងបួលចិត្តទុស តាលបើដឹងខ្លួនថាទុសខួលសួមខ្លាចគេស, ព្រះអង្គក៏ទ្រង់ប្រទានអត័ឃះហើយត្រាស់ថា "ការដែលបុគ្គលយើញគេសប្រទ្រឹត្តល្មើសហើយ ត្រឡប់ដូទ្បីត្រូវតាមគន្លងធម៌ សង្រួមប្រយ័ត្នទៅវិញនោះ ជាសេចក្តីចំរើនក្នុងវិន័យព្រះអរិយៈ" នេះសំដែងឲ្យយើញថា ក្នុងអរិយវិន័យមនុស្សយើញកំហុសរបស់ខ្លួនហើយ ប្តូរធ្វើយកន្លែយក្នុងកាលដឹងខ្លួនថា ប្រទ្រឹត្តទុសល្មើសចំពោះអ្នកដទៃ ។

២- ក្នុងផ្លូវវិន័យ តថាគតប្រទ្រឹត្តទុស ជាហេតុឲ្យសង្ឃដាក់គេសដូចមិនឲ្យមានអ្នកណាគប់រក នៃយោបាយជាមួយ ឬត្រូវាស្តីណាប្រទ្រឹត្តបង្កើរឿងឲ្យកើតសេចក្តីវិនាសដល់តថាគតក្នុងសាសនា, សង្ឃត្រូវសួរត្រួតប្រកាសផ្តាច់ចោត្រ មិនឲ្យលួចខ្លួយធម៌របស់អ្នកនោះ ។ តាលបើតថាគតត្រូវាស្តីទាំងនោះត្រឡប់កែខ្លួនបាន, សង្ឃក៏បួត្រប្រកាសលើកគេសនោះចាលចេញ ឲ្យជាអ្នកមានសិទ្ធិសិរីភាពតាមធម្មតាដូចដើម នេះសំដែងឲ្យយើញថា ការដាក់គេសនោះ ពិតជាមានចំណងល្អចំពោះអ្នកប្រទ្រឹត្តទុសឲ្យបានត្រឡប់កែខ្លួនត្រូវាញ៉ាងប្រាកដ ។

៣- ក្នុងការប្រៀនប្រដៅអំពីសេចក្តីមិនប្រមាទ ព្រះអង្គទ្រង់ប្រដៅ

មិនឲ្យប្រមាទក្នុងការលះបង់នូវការយើញខុស ធ្វើសេចក្តីយើញឲ្យត្រូវ ។
រីឯការយើញនេះ នឹងធ្វើឲ្យយើញត្រូវហួតៗទៅត្រង់រឿងនោះ។ ជាការ
កម្រណាស់ ព្រោះរឿងដែលខ្លួនមិនធ្លាប់សិក្សាស្រាវជ្រាវ ឬរឿងដែលខ្លួន
ដឹងមិនពិត ក៏ជាការចាំបាច់ត្រូវតែមានសេចក្តីយើញខុស ចូលចិត្តខុសខ្លះ
តុំខាន ។ តាំសេសចំពុតក្នុងធម្មដ្ឋដិបត្តិ មានគណាចារ្យមេលំដាប្រៀនប្រ-
ដៅដាច្រើន ដែលច្រាកដថា សូម្បីតែព្រះពុទ្ធជាម្ចាស់នៃយើង ក៏ផ្ទាប់ថាន
សិក្សានឹងប្រតិបត្តិតាម តាក្យប្រៀនប្រដៅរបស់គណាចារ្យទាំងនោះដែរ
តែការសិក្សាត្រង់ត្រាន់ហើយ ឃើញថាទៅមិនមែនជាផ្លូវត្រូវពិតច្រាកដ
ទើបត្រង់ស្រាវជ្រាវរកវែកដោយព្រះអង្គឯងជាច្បាស់ទៀត នេះឯងសំដែងឲ្យ
យើញថាព្រះអង្គត្រង់ប្រកាន់ហេតុផលដែលត្រូវ ចេះត្រឡប់ព្រះអង្គមិន
ព្រមលះបង់នៅក្នុងសេចក្តីខុស ; មនុស្សខ្លះមានសេចក្តីយើញយ៉ាងណា
ក៏ត្រាញ់រឹតជំហរនៅយ៉ាងនោះ សូម្បីដឹងថាសេចក្តីយើញរបស់ខ្លួននោះ
ខុស ក៏មិនព្រមលះបង់ផ្លាស់ប្តូរឡើយ ។ ព្រះកុមារកស្សបៈជាសាវ័កបស់
ព្រះពុទ្ធបានប្រៀបប្តូលថែដូនេះ ៗ ទៅនឹងអ្នកដែលមិនព្រមលះបង់ចោល
នូវសម្ពាយសម្បកព្រលឹងជាដើម ដោយបំណងនឹងធ្វើប្រយោជន៍ខ្លះដើម្បី
ខ្លួន សូម្បីបានជួបប្រទះនូវតុមានដំណែរផ្សងៗក្នុងរយៈផ្លូវមានអាបត្តិក៏
ជាដើម ក៏មិនព្រមលះបង់ចោលនូវសម្ពាយនោះដែរ ដោយនឹកស្មានយ៉ា
សម្ពាយនេះ ខ្លួនបានរៀបស្ងាយមកយូរយារណាស់ហើយ ។ មួយទៀតក្នុង

ការសន្ទនាធម៌ ឬសន្ទនារឿងព័ន្ធនឹងអ្នកដទៃ ចើក្រែងថ្នាំប្រយោជន៍ពិតៗ គឺគួរតែត្រមះឲ្យល្អសិនចំពោះអ្នកដទៃ កុងពេលដែលយើញថាភាពរបស់ខ្លួនមិនត្រឹមត្រូវ ហើយយកតាមហេតុផលរបស់អ្នកដទៃដែលត្រឹមត្រូវល្អជាង ។ ឧទាហរណ៍ដូចព្រះនោនៈសន្ទនាត្បូ ការសន្ទនានឹងព្រះបាទមិលិន្ទក៏បានថ្វាយសេចក្តីបូលចិត្តជាមុនថា ត្រូវសន្ទនាគ្នាតាមបណ្ឌិតវិភាគប្រកាន់ហេតុផល ដែលត្រូវជាប្រមាណ, នេះឈ្មោះថាសំដែងនូវការត្រឡប់កែខ្លួនចាកភាពជាអ្នកឃើញខុសហើយ ត្រូវព្យាយាមសិក្សាស្រាវជ្រាវកែឱ្យដឹងពិតក្នុងលេស់នោះជាយ៉ាងឯង ។ មួយវិញទៀត ការសន្ទនាជ្រាស្រ័យនឹងអ្នកដទៃ ក៏គួរយល់ព្រមតាមសេចក្តីឃើញណាដែលត្រឹមត្រូវដោយហេតុផល មិនគួរប្រកាន់ខុសពីជំហរតាមមតិរបស់ខ្លួន ពាំជដឹងថាខុសការចេះត្រឡប់កែខ្លួនបានដូច្នេះ រមែងប្រព្រឹត្តដើម្បីប្រយោជន៍ខ្លួនយ៉ាងច្រើន ។

៤- អ្នកណាក៏ដោយ សូម្បីតែកាន់នូវជាមនុស្សគ្រាក់ប្រព្រឹត្តអាក្រក់មកពីមុនយូរហើយ ដោយមានវិតុចាមកពេមដឹកនាំក្តី ដោយសេចក្តីល្ងង់ខ្លៅអាប់ឥតបញ្ញា ឬដោយហេតុណាៗក្តី កាលបើដឹងថាខ្លួនប្រព្រឹត្តខុសហើយ គួរលះបង់ចោលនូវសេចក្តីប្រព្រឹត្តខុសនោះចេញ ត្រឡប់កែខ្លួនឲ្យជាមនុស្សល្អត្រឹមត្រូវឡើង ផ្តើមប្រព្រឹត្តសេចក្តីល្អតទៅ, គួយ៉ាងដូចព្រះអង្គុលិមាល ធ្វើបាបធ្វើជាចោរកាប់សម្លាប់មនុស្សមកជាច្រើន

តែចេះត្រឡប់កែខ្លួនបានមកតាំងនៅក្នុងសីលធម៌ គាល់តែបានសម្រេច
ព្រះអរហត្តផល ហើយបន្ទឹមពន្យារពាសំដែងពីសេចក្តីយើញចំពោះរឿង
ការត្រឡប់កែខ្លួននេះ ដោយជ្រះថ្លាក្នុងចិត្តពិតប្រាកដតាមពុទ្ធភាសិតដែល
បានតាំងទុកជាគោលទាន់ដើមនោះ ។

៥- គាលបើពិចារណា អំពីរឿងពុទ្ធប្រវត្តិ ខ្ញុំសាកប្រវត្តិហើយ
អាចយល់យើញថា ព្រះពុទ្ធជាម្ចាស់ក្តី សាវកទាំងឡាយក្តី សុទ្ធតែធ្លាប់
បានធ្វើនាត់ខ្លះគាលវប្បធម៌ ការត្រឡប់កែខ្លួនដូច្នោះតាំងអស់អង្គ ។
ក្នុងអដ្ឋកថាសំដែងពីបុព្វកម្មរបស់ព្រះអង្គថា ព្រះពុទ្ធជាម្ចាស់ ព្រះអង្គធ្លាប់
ជាអ្នកលេងល្បែង បុនាល់ បានគាលមើលឃើយព្រះបច្ចេកពុទ្ធក្នុងជាតិ
ដែលកន្លងមកហើយ ខ្ញុំងប្រព្រឹត្តអាក្រក់ក្នុងជាតិ ជាលំដាប់តទៅទៀត
ក្នុងទីបំផុតកំព្យាយាមត្រឡប់កែខ្លួន រៃងប្រព្រឹត្តអាក្រក់បានត្រាស់ជាព្រះ
ពុទ្ធនៅអង្គក្នុងលោក ។ សាវកទាំងឡាយដូចព្រះសារីបុត្តខ្ញុំងព្រះមោគ្គល្លាន
ជាដើម ធ្លាប់តប់អានសាសនាដទៃមកតាំងមុន តែគាលបានស្តាប់គាលវប្ប-
ធម៌ដ៏ប្រសើរដោយហេតុផល ក្នុងសាសនារបស់ព្រះមានព្រះភាគ កំត្រឡប់
ខ្លួន ត្រឡប់ចិត្ត ត្រឡប់សេចក្តីយើញ ប្រព្រឹត្តត្រឹមត្រាចារក្នុងព្រះពុទ្ធ
សាសនាវិញ ។ ជាដើម ១ ពាន់រូប គឺទរុវាលកស្សបៈ ទី១កស្សបៈ ខ្ញុំង
គយាកស្សបៈ ៣ នាត់បងប្អូនជាប្រធាន កំធ្លាប់ប្រកាន់តឹងរ៉ឹងក្នុងលទ្ធិដទៃ
មកតាំងមុនដែរ គាលបើបានស្តាប់តាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់

ហើយ កំពុងរណាយើញដោយចិត្តរបស់ខ្លួនឯងថា លទ្ធដើមរបស់ខ្លួនពុំមានខ្វះសារ ទើបត្រឡប់មកសូមទោសសម្បាកក្នុងសំណាក់ព្រះពុទ្ធជាម្ចាស់វិញ ។ តាំសេសចំផុត ព្រះទ្រង់លែកស្បែបបានភោលប្រកាសហេតុផលអំពីការដែលលើកលែងលទ្ធដើម មកពាក់ពាន់ព្រះពុទ្ធសាសនាវិញ ដល់ប្រជាជនក្នុងដែនមគធៈ ។

ព្រោះហេតុនេះ យើងជាពុទ្ធបរិស័ទកល់គ្នាគប្បីប្រុងប្រយ័ត្នខ្លួនតែការត្រឡប់កែអង្គបស់ព្រះមានព្រះភាគ ទំនឹងការកែខ្លួនបស់ព្រះសង្ឃបុពណាដដែលនាដើមនោះ យកមកជាគារម្មណ៍ ហើយត្រូវត្រួតពិនិត្យម៉ែលខ្លួនរាសេចក្តីប្រព្រឹត្តិរបស់ខ្លួនថែមទៀត ។ បើមធ្យាស្រ័យរបស់យើងនៅមានយោរយៅគំនួរកែទៀងឱ្យស្លូតបូតខ្ជាប់ បើទោះជាអ្នកឆ្លៀវប្រសើរ គំនួរប្រុងប្រយ័ត្នតាំងសេចក្តីត្បាយាមទៀត, ៖សេចក្តីទុស្សណា។ ដែលខ្លួនធ្លាប់ប្រកាន់ពីដំបូងមក, គាលដឹងថាទុស៖ហើយ ចូរត្រឡប់កែសេចក្តីយើញទុសនោះចោលទៅ ហើយធ្វើឱ្យត្រូវត្រង់ជាប្តឹងទៅ ។

ថ្ងៃណាដែលធ្វើដូច្នោះ ថ្ងៃនោះឧកជាថ្ងៃសុភមង្គលនៃភ្លូករយើងជាពុទ្ធបរិស័ទពិតមែន ព្រោះបានគំពាត់ចង់ខ្លួនសេចក្តីទុសកន្លងមកដោយការត្រឡប់កែខ្លួនឱ្យជាមនុស្សល្អតទៅ ។ ប្តូរលុបបានក្រែបរសបិតដែលកើតអំពីការធ្វើសេចក្តីល្អមានសីលជាដើម ដោយការត្រឡប់កែខ្លួនហើយឈ្មោះថាញ៉ាំងជីវិតរបស់ខ្លួនឱ្យស្រស់ថ្លែកយជាទីបំផុត ។

តិលម្ពដ្ឋិជាតក(១)

ព្រះញាណកោសល ញាណ-ឈឹង រៀបរៀង

ឯមេ ៣ ដង ។

សូមនមស្ការ ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់អង្គនោះ ព្រម
ទាំងព្រះធម៌នឹងព្រះអរិយសង្ឃ ដោយសេចក្តីគោរព ។

លំដាប់នេះ នឹងពណ៌នាអំពីបុគ្គលជាអរិយៈ ៤ ប្រភេទគឺ :

១- អាចារអរិយ,

២- ទស្សនអរិយ,

៣- លិង្គអរិយ,

៤- បដិវេធអរិយ ។

មានសេចក្តីប្រែ នឹងអធិប្បាយដូចតទៅនេះ :

១-អាចារអរិយៈ ប្រែថា បុគ្គលអ្នកមានការប្រព្រឹត្តត្រឹមត្រូវ
មានកិរិយាមារយាទល្អ អាចប្រកិរិយាថ្លៃថ្នូរ ប្តូរពាសមមៀ ចរិយាខ្ពង់ខ្ពស់
ជាបរិនាយកអ្នកដឹកនាំគេ ឬសត្វតាហនៈ ដូចដំរីសេះជាអាទិ៍ ដែលគេ
ហ្វឹកហ្វឺនបានបាន ដូចមានទេវតាបារណ៍ថា "អ្នកនេះមានអាចប្រកិរិយាល្អ

១-ដីអាចារ្យថា ចតុក្កោ ភាគោ ទំព័រ ៨-១៤ ។

ណាស់ ដំរីសេះទេះ បានបទល្អណាស់ ប៉ុណ្ណោះជាដើម ទេះជា អាថារអាយៈ ។

๒-ឧស្សន្ទអាយៈ ប្រែថា បុគ្គលជាមនុស្សជាតិនិងសត្វតិរច្ឆាន ដែលមានរូបល្អ មានវណ្ណៈបឋស្រគត់ស្រគម គួរជ្រះថ្លា គួរក្រេវក្រែក មើល ដូចទេពាវណ៌ទាងលើដែរ ទេះជាឧស្សន្ទអាយៈ ។

ន័យដដែលទៀត ជនប្រុសស្រីណា បានឃើញព្រះសម្ពុទ្ធ ព្រះនាមចក្ខុភូតុទ្ធ ឬបានឃើញភូតុទ្ធសាវកទាំយ កើតសទ្ធាជ្រះថ្លា ចំពោះអាយៈ តំនាងនោះ ការឃើញនោះឈ្មោះថា ឧស្សន្ទនទុត្តិយៈ ការឃើញវិសេស(๑) ការឃើញឥតទោស ។

๓-លិង្គអាយៈ ប្រែថា បុគ្គលដែលមានហេតុត្រឹមណាក៏ដោយ ទោះជាត្រូវាស្ត្រ ឬបព្វជិត មានសីលបរិសុទ្ធ ល្អ សោភាគ្រប់ គ្រាន់តែមានសំលៀកបំពាក់ពណ៌លឿង-ស តាំងយកនេះជាសមណៈគួរជ្រះថ្លា គួរក្រេវក្រែកមើល ដូចភូតុបរិស័ទបំព្រួញទុនគាន់សីល ๘-๑๐ ស្លៀកពាក់សំពត់ពណ៌លឿង-ស គោរសក់ គោរភ្នែកមាត់ ពុកចង្កា ស្អាតបាត ទេះជាលិង្គអាយៈ ។

๔ បដិវេធអាយៈ ប្រែថា ព្រះអរហន្តទាំង៦ព្រះអង្គ មានព្រះសម្ពុទ្ធជាដើម ដូចមានពាក្យថា អាយស្មា ញាតិ ពុទ្ធោ ច ភគវន្តោ-

---

๑-អនុត្តរិយសូត្រ. ភាណវារៈ ទំព័រ ๓๒๑, ឆក្កនិបាតៈ ភាគ ๒๒- ទំព័រ ๑๐ ។

ตุฏฺฐา ๑ ตุฏฺฐสฺสาวกา ๑ "ព្រះសព្វញ្ញុពុទ្ធក្តី ព្រះបច្ចេកពុទ្ធក្តី ពុទ្ធសាវកក្តី សុទ្ធតែជាអរិយៈទាំងអស់" នេះជាបដិវេធអរិយៈ ។

ប៉ុន្តែ កន្លងខ្លះ អ្នកនិពន្ធមានបំណងនឹងដកស្រង់ចំពោះតែអាចារៈអរិយៈខ្លះ ទាន់ដើមមកសំដែងឲ្យពិស្តារ, ដូចមានបទសុភាសិតថា :

អរិយោ អនរិយំ ភាវំ
យោ ទស្សន ឯសេតិ
សាសនំ តំ ន តំ ហេតំ
ឥតិ នំ បណ្ឌិតា វិទុ ។

ប្រែថា នរជនណាជាឧប្រហារគេ គឺដាល់តប់ខ្លះ ថ្នាំជាដោយរំពាត់ហើយហាមប្រាម ចំពោះជនម្នាក់ដែលប្រព្រឹត្តអំពើអាក្រក់ពុំគាប់ប្រសើរនរជនអ្នកហាមប្រាមនោះ ជានឈ្មោះថា អាចារអរិយៈ តាក្យប្រដៅរបស់ណាក៏ដោយចាត់ជាឧបាទេ តាក្យនោះមិនមែនជារំពាត់ឡើយ អ្នកប្រាជ្ញតែងស្គាល់ច្បាស់ខ្លួនឯងជនដោះ ដូច្នេះឯង ។

មិនតែប៉ុណ្ណោះសោត ពោះពាំងវាចារបស់មាតាបិតាគ្រូអាចារ្យដែលគោលថ្កោលថ្នោះបញ្ជោះបញ្ជៀ ដូចតាក្យថា អ្នកឯងត្រូវក្រេបវែង, អ្នកឯងត្រូវរំពាត់ដាដើម ដៅទៅរកបុគ្គលិតា ឬ ភូនសិស្ស ដែលមានកំហុសប៉ុន្តែ ចិត្តរបស់លោកនៅមានមេត្តាខន់ភូនចំពោះពីជីវិតាភ នឹងប្រយោជន៍

ដែលផ្តល់ខ្លួនសេចក្តីចំរើនតទៅមុខ រៀងប្តូតដ៏តាប្តកូនសិស្សនោះ។ ជាដរាប ។ ពាក្យដែលបានចែកចាយនោះមិនលោភ ថា "ផ្ទុះសក់ចាស់ឡើយ(១) ហើយមានតាបិតា ទើបត្រូតាំងនោះ គង់បានឈ្មោះថា អាចាអរិយៈ ដោយពិត ។ ឧទាហរណ៍ ដែលនាំមកប្រៀបធៀបនេះ ស្រដៀងនឹងបទសុភាសិតខាងដើមនោះដែរ ។

ចប្បាប់អំពីនេះ សូមសំដែងជាគតដែលជាបុព្វហេតុនៃអរិយបុគ្គលទាំង ៤ ដូចមានសេចក្តីថា :

កាលសម្តេចព្រះសុគតជាម្ចាស់ទ្រង់ធរមានទៅឡើយ ព្រះអង្គទ្រង់ប្រថាប់នៅវត្តជេតវន ជាឧទ្យានរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ទ្រង់ត្រាស់នឹងភិក្ខុទូប ដែលជាអ្នកធាប់ក្រោធ ។

សេចក្តីថា មានភិក្ខុទូបជាអ្នកធាប់ក្រោធ ជាអ្នកមានចិត្តក្រៀមក្រំគ្រាន់តែនេះយ៉ាងលើសលោះបង្គិចបង្គួច តំណប្រទេចគេ តែក៏តែប្រមូលទោសក្រោធមិនសមហេតុផល ធ្វើឲ្យជាក់ស្តែង ដូចបុរាណថាចាបដែរ្យតែពូតជាដុំ ។ ក្នុងមួយ ភិក្ខុទ្រជិនទូប អង្គុយប្រជុំគ្នា សន្ទនាថា សាវុសោទាំងឡាយ ! ភិក្ខុជាអ្នកក្រោធខ្លួបនោះ មានចិត្តក្រៀមក្រំតែងតែលាក់ក្បរមើកមុំនឹង ដេរប្រទេចគេ ឮសូរប្រេះ ដូចអំបិលដុះក្នុងដើងក្រោន, ភិក្ខុនេះ បួសក្នុងធម៌វិន័យដែលប្រដៅឲ្យអត់សង្កត់សេចក្តីក្រោធ, ឯខ្លួនលោកបែរជាធាប់ក្រោធ មិនអាចខំឆន់អត់សង្កត់ខប់ខល់

១- អង្គុត្តរមគ្គលស្សូត្រ, វិមលកថា ទំព័រ ៣៤-៤៣ ។

សេចក្តីក្រែធសោះ ។ ព្រះបរមសាស្តា ទ្រង់ជ្ញានស្តាប់ពាក្យតំកុំចាំង
នោះហើយ ទើបទ្រង់ឲ្យហៅតំកុនោះមកត្រាស់សួរថា នែតំកុ ! ឮថា
អ្នកឯងជាអ្នកធាប់ក្រោធមែនឬ ? ។ តំកុនោះទទួលស្រេចថា ក្រាបទូល
មែន ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា " ម្នាលតំកុចាំងឡាយ តំកុនេះ
មិនមែនជាអ្នកធាប់ក្រោធតែក្នុងជាតិបច្ចុប្បន្ននេះទេ ពីមុនមក តំកុនេះ ក្តាប់
ជាអ្នកធាប់ក្រោធដូច្នេះដែរ " លុះទ្រង់ត្រាស់ហើយ ក៏នាំអតីតនិទានថា :

អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ .

ក្នុងអតីតកាល មានព្រះមហាក្សត្រមួយអង្គទ្រង់ព្រះនាមព្រះបាទ
ព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី ទ្រង់មានព្រះរាជបុត្តមួយអង្គ
ព្រះនាម ព្រហ្មទត្តកុមារ ។

ខំនៀមក្សត្រតាំបុរាណត្រង់ៗ ព្រះអង្គសឹងជ្រាបច្បាស់ថា ពាជកុមារ
សុទ្ធតែមានមានះរឹងក្តឹងឆឹង ប៉ុន្តែជាអ្នកចេះអត់សង្កត់ត្រជាក់ក្តៅស្រេកឃ្លានខ
ជ្ញាន ត្រូវតែឲ្យចេះដឹងចេះយោសាស្ត្រ ចំណែរាំដាំនឹងតិរោនោះយោ
សម្រាប់លោក ទ្រង់តែងបញ្ជូនពាជបុត្រទៅបម៉ន់ខ្លួន ។ ឲ្យទៅរៀនក្នុង
សំណាក់អាចារ្យនិសាជ្ញាមោក្ខ ដែលមានក្នុងប្រទេស បើមិនមានទេ
តំបញ្ជូនឲ្យទៅប្រទេសក្រៅ ។ ព្រោះហេតុនោះ ព្រះជ្ញាទព្រហ្មទត្ត
ទ្រង់ត្រាស់ហៅព្រះពាជបុត្រ ដែលមានអាយុ ១៦ ឆ្នាំ មក ទ្រង់ប្រទាន
សែ្បកជើងសង្រែក ១ គូ ធ្នូត្រស្នឹក ១ ប្រាក់ខ្ចី តាន់កហាបណៈ ហើយឲ្យ

ថា "នែកូន! អ្នកត្រូវទៅគាន់ក្រុងតក្កសិលា ដើម្បីរៀនសិល្បសាស្ត្រចុះ។ ព្រះពដកុមារក៏ទទួលព្រះពដន្លាថា "សាធុ" ហើយសំពះលាមាតាបិតា ដើរចេញទៅតាមលំដាប់ ក៏ឈានដល់ទ្រនំស្ថានអាចារ្យនៅក្រុងតក្កសិលានោះ។ កាលនោះអាចារ្យទិសាបាមោក្ខ ទើបនឹងបង្រៀនពួកមាណពជាសិស្សរួចហើយ ក្រោកទៅឥដ្ឋិយនៅមាត់ភ្នំ។ រីឯព្រះពដកុមារ ឈានឡើងឥដ្ឋិយទៅមាត់ភ្នំរហើយ ក៏ដោះស្បែកជើង ដំរឡុះធំត្រង សំពះអាចារ្យ ហើយឈរនៅស្ងៀម។ អាចារ្យ ឈានជ្រាបថ្វាយគាលំឈានតាមផ្លូវ ក៏សង្គ្រោះព្រះពដកុមារដោយអាតន្តិកកិច្ច។ លុះព្រះពដកុមារសោយរួចហើយ សម្រាកកាយបន្តិច ទើបចូលទៅកាន់អាចារ្យ សំពះតាមកិច្ចគួរសម។ អាចារ្យឈានសួរថា: អ្នកមកពីទីនណា? - ខ្ញុំមកពីទីនរភាកណាស៊ី។ - អ្នកឯងឈ្មោះជាបុត្រលោកណា? ខ្ញុំជាព្រះពដបុត្រមេសព្រះបាទតាកណាស៊ី។ - អ្នកឯងមកដើម្បីអ្វី? - ខ្ញុំមកដើម្បីទីនរៀនសិល្បសាស្ត្រ។ - អ្នកត្រូវការរៀនឈ្នួលឬរៀនតាមធម្មតា? ខ្ញុំត្រូវការរៀនឈ្នួល។ លុះដំណឹងហើយ ក៏យកគ្រាប់ទាន់កហាបណៈ ដំកល់ទុកមុខនែលោកអាចារ្យ។

មានសេចក្តីថា កូនដំនាន់នោះ កូនសិស្សធម្មតាដែលឥតថ្លៃឈ្នួល រៀនបានតែរៀលាយប៉ាយ ឯរៀលាថ្លៃធ្វើការជូនលោកអាចារ្យ។

ចំណែកកូនសិស្សឈ្មួល រៀនចាប់តាំងយប់ព្រឹកថ្ងៃ ដូចជាបុត្រឆ្នងកូន
គេហដ្ឋានដូច្នោះ ហេតុនោះ អាចារ្យទិសាចារ្យមានបុត្រ បង្រៀនព្រះពុទ្ធកុមារ
ដោយសុភនក្ខត្តពេលវេលាល្អ ព្រះពុទ្ធកុមារក៏ភ្ញាខរចេះដឹងឆាប់រហ័សជាន់
ចិត្ត ។ មានថ្ងៃមួយ ក្រៅពីពេលរៀន ព្រះពុទ្ធកុមារ នាំរត់លេងក្នុងសួនជាមួយ
នឹងអាចារ្យ ។ គាលៈនោះមានស្ត្រីជាស្មាត់ឃ្លាសម្លាញ់ឈ្មោះ
ដើម្បីឲ្យស្កូតសម្លាញ់ រួចអង្គុយឃ្លាំចាំមើល ។ ព្រះពុទ្ធកុមារឃើញល្ងង
ខោះ គិតចង់លេងសើច ទើបទៅតើបយកល្ង ១ ក្តាប់មកសើច ។ ស្ត្រី
ជាស់ឃើញហើយគិតថា កុមារនេះឥតរបបណាស់ ប៉ុន្តែគាត់មិន
និយាយថាអ្វីឡើយ តាត់នៅស្ងៀម ។ លុះដល់ថ្ងៃជាតម្រង់ពីរតម្រង់បី
ព្រះពុទ្ធកុមារភ្ញើដួចមុនគេ ស្ត្រីជាស់ឃើញហើយ លើកដៃគក់ទ្រូង
ទ្រេហាយំថា "អាចារ្យទិសាចារ្យ នាំកូនសិស្សឲ្យមកបួនខ្ញុំ" ។ អាចារ្យ
ទិសាចារ្យសួរថា " នែយាយ ! ដំណើរអ្វី ? ស្ត្រីជាស់ដាក់ថា
ម្ចាស់ កូនសិស្សរបស់លោកវាយកល្ង ដែលខ្ញុំកំពុងនិយាយមក
ខ្ញុំឃើញគាន ក្នុងថ្ងៃនេះ ១ ក្តាប់ ពីរយ៉ាលម្ហែ ១ ក្តាប់
ទៀបើខ្ញុំឃើញគាតែយ៉ាងនេះ ល្ងរបស់ខ្ញុំនឹងវិនាសអស់ទៅខេ ។ ហើយ ! ។
អាចារ្យឃាត់ថា នែយាយ ! កុំយំសោកឡើយចាំខ្ញុំសងថ្ងៃជួន ។ ស្ត្រីជាស់
ជំពប់ថា ខ្ញុំពុំត្រូវការឲ្យសងថ្ងៃទេ សុំឲ្យតែលោកគ្រូប្រដៅកូនសិស្សកុំ
ឲ្យភ្ញើដួចមុនគេតែម្តុំណ្ណោះ ។

អាចារ្យទិសាបាមោក្ខធិយាយថា បើដូច្នោះ ហេយឯងចាំមើលចុះ លុះ
ជាហើយ កំប្រើមាណពតាវ្លែបឲ្យចាប់ព្រះកុមារត្រង់ដៃទាំងសងខាង
រួចហើយ យកបន្ទះថ្មស្បែរាយគាត់ចំតណ្ដាលទ្រូងហាមប្រាមថា "នែ
កុមារ! អ្នកកុំធ្វើដូចមុនទៀត" ។ ឯព្រះកុមារនោះភ្ញាល់ណាស់ ធ្វើព្រះ
នេត្រក្រហឡើងសំឡក់មើលអាចារ្យ តាំងតែជាខឹងដកបដល់ក្បាល (បង
តំនុំទុក) ។ អាចារ្យក៏ហាមគ្រាបថា ព្រះកុមារនេះភ្ញាល់ចំពោះខ្លួនណែ ។
លុះព្រះកុមារបានរៀនចេះចប់ជ្រាះហើយ ក៏ចងចិត្តថា ទៅអនាគត
ដ៏ខ្លី អញត្រូវតែសម្លាប់អាចារ្យនេះឲ្យបាន លុះគិតហើយដំកបថា "បពិត្រ
លោកអាចារ្យ បើកាលណាខ្ញុំបានទៅដល់មាតុភូមិហើយ បាន
សោយរាជ្យ ក្នុងក្រុងពារាណសី ខ្ញុំនឹងផ្ញើលិខិតមកសូមអញ្ជើញលោក
ទៅជួបនឹងខ្ញុំ, ក្នុងកាលនោះ លោកត្រូវតែអញ្ជើញទៅ" ព្រះកុមារធ្វើ
ការពាត់ពាក់ហាក់ដូចជាស្រឡាញ់អាចារ្យណាស់ រួចហើយសំពះដើរ
ចេញទៅ ។ ក្រោយពីនោះមក ព្រះកុមារបានរៀនត្រឡប់មកដល់
ក្រុងពារាណសី បានថ្វាយបង្គំមាតាបិតា សំដែងសិប្បៈដែលខ្លួនបាន
ចេះចាំថ្វាយព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យ ដោយទ្រង់ឈ្លេងយល់ថា
អញនឹងបានយើញរាជកុមារនេះសោយរាជ្យ នៅវេលាដែលអញមាន
ជីវិតរស់នៅ លុះទ្រង់ឈ្លេងយល់ហើយ ទ្រង់ព្រះរាជទានរាជសម្បត្តិ
ចំពោះព្រះរាជកុមារក្នុងកាលនោះឯង។ តាំងពីព្រះរាជកុមារបានសោយរាជ្យ

ក៏លើកខ្លួនឡើងសែនដល់អាចារ្យវាយយកទៅ, ទ្រង់ត្រេកអរ ពន្លត់ថា "យើងនឹងសំឡាប់អាចារ្យសង្ឃនៅវិញ ទ្រង់បញ្ជាឲ្យទៅអញ្ជើញអាចារ្យមក ។ ឯអាចារ្យទាំងបាមោក្ខគិតថា ព្រះពុទ្ធមានបឋមកាលដ៏ក្រៃលែងណាស់ នៅឡើយ យើងពុំអាចពន្យល់ឲ្យយល់ភ្លេចបានទេ; គាត់ក៏មិនអញ្ជើញមក លុះព្រះពុទ្ធមានបានបរិនិព្វានជាច្រើនឆ្នាំមកហើយ ទើបគិតថា ឥឡូវនេះ យើងអាចនឹងពន្យល់ព្រះពុទ្ធមានឲ្យយល់បាន គាត់ក៏អញ្ជើញមក ហើយឈរនៅទៀបទ្វារព្រះពុទ្ធនិវេសន៍ រួចហើយឲ្យយកសេចក្តីក្រាបបង្គំទូលថ្វាយបង្គំ ឥឡូវនេះ អាចារ្យអញ្ជើញមកដល់ហើយ ។ ព្រះពុទ្ធមានសេចក្តីត្រេកអរ ឲ្យអញ្ជើញព្រាហ្មណ៍ចូលមក គ្រាន់តែទ្រង់ទតឃើញព្រាហ្មណ៍មកដល់ ក៏កើតព្រះពោធមួយរំពេច ធ្លើព្រះនេត្រក្រឡៃ ទ្រង់ត្រាស់ហៅអាមាត្យមកប្រាប់ថា នែអ្នកទាំងឡាយ! ក្នុងថ្ងៃនេះ ត្រង់កន្លែងស្មាមដែលលោកអាចារ្យវាយខ្ញុំពីមុននោះ ឥឡូវនេះ កន្លែងនោះ វាចាប់ពោតឡើងវិញ, ប្រហែលជាលោកអាចារ្យ គាត់នាំយកសេចក្តីស្លាប់មកជាមួយនឹងដួងព្រលឹងផងហើយមើលទៅ; គាត់នឹកថា អញមុខជានឹងស្លាប់ ជីវិតរបស់អញនឹងមិនមានតទៅទៀតទេ; លុះទ្រង់ត្រាស់ហើយក៏សោលគាថាជាគាថាគ្រាមដូច្នេះថា

អដ្ឋានេ មេ តំ មនសិ

យំ មំ ភូំ តិលមុដ្ឋិយា

តាមកាយំ មំ តមោត្វាន

លដ្ឋិយា អនុតាលយិ

ននុ ជីវិតេ ន រមសិ

យេនាសិ ព្រាហ្មណាតតោ

យំ មំ តាយោ តមោត្វាន

តិក្ខត្តុំ អនុតាលយិ

ប្រែថា ម្នាលព្រាហ្មណ៍ លោកចាប់ខ្ញុំត្រង់ដើមដៃ លុះចាប់ហើយ ក៏យកខ្ញុំដាក់ក្នុងទូកស្បៃ ព្រោះតែស្ទឹកភ្លាប់ តាក់យោងៗ ដក់ខោកក្នុងចិត្តរបស់ខ្ញុំ ដកបដល់សព្វថ្ងៃនេះ ។ ម្នាលព្រាហ្មណ៍ លោកមិនស្តាយជីវិតរបស់លោកទេឬ ? ។

តាមុនមិញ លោកចាប់ខ្ញុំត្រង់ដើមដៃ ហើយក៏យកភ្ជាប់ ឥឡូវនេះ លោកទៅញ៉ាំមាន់សំណាកខ្ញុំ សូមលោកចូលខ្ញុំផលនៃការប៉ុនប៉ងរៀត ។

លំដាប់នោះ គាថាប្រកបសាធារណៈក្នុងសាច់ត្រូវសួរសៀងនៃព្រះបច្ចេកព្រហ្មទត្តដែលត្រង់ត្រតៀកធម៌ដ៏ជាន់ខ្ពស់ក្នុងកម្មដ៏ពេញខ្លួនហើយ ទើបពោលគាថាជាគាថាគប្បី :

អវិយោ អនវិយំ កុព្ភំ ។

។ ល ។

-សេចក្តីប្រែដូចខាងដើម ។

លុះចប់គាថាហើយ កំពង្សលំហេតុផលថា :

បពិត្រមហាពាជ ! សូមព្រះអង្គទ្រង់ជ្រាប ដូចខ្ញុំព្រះបង្គំបានក្រាបទូលនេះចុះ ព្រះអង្គពុំគួរជេនតៀកនដំណើរវែងប្រដៀងភ្ញាប់នោះទេ ប្រសិនបើ ខ្ញុំព្រះបង្គំពុំបានប្រដាព្រះអង្គ តុំបានថ្វាយការបំភ្លឺ តុំបានហាមឃាត់អំពើអាក្រក់របស់ព្រះអង្គទេ នោះឃ្លាតៅ ព្រះអង្គគង់ហាននលួចនំចំណិតនំងាយមានន្ទែះឈើជាដើម តិរបស់តូច ដល់របស់ធំ, តិរបស់តាប ដល់របស់ខ្ពស់, តិរបស់ជាក ដល់របស់ថ្លៃ ហើយព្រះអង្គជាប់ព្រះកជហប្លន់យកតង្វាយតោះកម្មសឡឹម ។ ឡើងតាមលំជាប់ ដល់ហានគាត់ជញ្ជាំងរបងឃ្លាំង លួចយកវេរបស់មានវិញ្ញាណ ឥតវិញ្ញាណទ្រង់នឹងតៅជាអ្នកមានកំហុសព្រោះតោសលួច ហើយកជបុរសគេនឹងចាប់ព្រះអង្គថាជាចោរនាំតៅថ្វាយព្រះមហាក្សត្រ ។ នឹងទ្រង់ត្រាស់បង្គាប់ឲ្យធ្វើខណ្ឌកម្មសមគួរតាមតោសនោះ, តាលបើដូច្នោះ ធ្វើម្តេចឡើយព្រះអង្គនឹងបាននាយកជសម្បត្តិនេះ ឥឡូវ តែជាទ្រង់បានទទួលព្រះកជឥស្សរិយយសជាម្ចាស់ផែនដីនេះ មិនគឺបានដោយអាស្រ័យខ្ញុំព្រះអង្គទេឬ ? ។ ឯអាមាត្យកជបរិពារដែលតៅតាល់ជុំវិញ ក្រោយពីបានស្តាប់សេចក្តីដែលអាចារ្យទំនាបានមានក្តីរោះស្រាយហើយក៏បានក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ! ព្រះកជឥស្សរិយយសរបស់ព្រះអង្គនេះ គឺជាសម្បត្តិរបស់

លោកអាចារ្យពិតមែន ។ ព្រះពាជាក៏ទ្រង់កត់ចំណាំនូវគុណវិបស់អាចារ្យ
ថាពិតមែន ទើបទ្រង់ត្រាស់ថា បពិត្រលោកអ្នកមានគុណ ! យើងសូមដូន
ឥសីយ៉ាយសតាំងអស់នេះ ចំពោះលោក សូមលោកខន្តីលាជឥសីម្នាក់នេះ
ចុះ ។ អាចារ្យប្រកែកថា បពិត្រមហាពាជ ! ខ្ញុំព្រះអង្គ ពុំត្រូវការដោយពាជ
សម្បត្តិនេះទេ ខ្ញុំព្រះអង្គត្រាន់តែខ្វល់សារសិទ្ធ សូមទ្រង់ជ្រាបតែប៉ុណ្ណោះ ។
ព្រះពាជាទ្រង់បញ្ជូនពាជទូតទៅទាំងគ្រឹងតក្កសិលា ឲ្យនាំគ្រួសារបស់
លោកអាចារ្យមកផ្ទះដុំ ទ្រង់ទឹងព្រះពាជទានឥសីយ៉ាយសដ៏ធំតែងតាំង
លោកអាចារ្យក្នុងឋានន្តរសាក្តិបុរោហិត ។ លើកដំកើងបុរោហិតនោះ
ទុកដូចជាបិតាបង្កើតព្រះអង្គ។ ទ្រង់បិតនៅក្នុងឋានៈនៃបុរោហិតសព្វ ។ កាល
ទ្រង់សន្សំបុណ្យមានធ្វើទានជាដើម លុះអាសាននៃព្រះជន្ម ទ្រង់បាន
ទៅកើតក្នុងស្ថានទេវតា ។

លុះព្រះបរមសាស្តា ទ្រង់សំដែងធម៌ទេសនាប្រកាសសច្ចធម៌ទាំង ៤
ប្រការចប់ហើយ តិត្ថិយកក្រោធនោះ បានប្រតិស្ថាននៅក្នុងអនាគាមិផល
តុទ្ធបរិស័ទដ៏សេសបានដល់ន្លាស្រាតាបត្តិផលខ្លះ សកទាគាមិផលខ្លះ
តាមសមគួរដល់ពាសនាបារមីរៀងៗខ្លួន ។ ឯព្រហ្មទត្តពាជវិញមារ ក្នុង
កាលនោះ គឺតិត្ថិយកក្រោធក្នុងកាលឥឡូវនេះ ។ អាចារ្យទិសាបាមោក្ខ
គឺអង្គតថាគតនេះឯង ។

មុខនឹងបញ្ចប់ជាតកនេះ សូមសំដែងពីអរិយសច្ចដែលប្រៀបថា ប្រសើរ

ប្រពៃ ត្រឹមត្រូវ វិសេសវិសាល ដើម្បីពន្លឹកសេចក្តីឲ្យកែចំណាយឡើង
ត្បិតអរិយសច្ចជាបច្ចត្តផ្ទុយនឹងអនរិយសច្ច ប្រែថា មិនប្រសើរ មិនប្រពៃ
មិនត្រឹមត្រូវ មិនវិសេសវិសាល បន្ថែមសិន ទើបបញ្ចប់ជាតតជាងក្រោយ
ព្រោះអរិយសច្ចនឹងអនរិយសច្ចនេះ គ្រាន់តែជាបទ វិសេសគុណជាឃនាមសច្ច ឬពាក្យនាមសច្ចនោះ ជាធម្មតាចង្អុលជាបុគ្គលតំណាងដូចន័យកថាប្រយោគថា :

ទ្វេ មេ ភិក្ខវេ អន្តា បព្វជិតេន
ន សេវិតព្វា កតមេ ទ្វេ យោ ចាយំ
កាមេសុ កាមសុខល្លិកានុយោគោ
ហីនោ គម្មោ បោថុជ្ជនិកោ
អនរិយោ អនត្ថសញ្ហិតោ(១) ។
យោ ចាយំ អត្តកិលមថានុយោគោ ទុក្ខោ
អនរិយោ អនត្ថសញ្ហិតោ ។

ប្រែថា ម្នាលភិក្ខុទាំងឡាយ លាមកធម្មទាំងពីរប្រការនេះ បព្វជិតមិនគួរសេពគប់ឡើយ ។ លាមកធម្មទាំងពីរប្រការ តើអ្វីខ្លះ ? គឺការប្រព្រឹត្តរឿយៗនូវកាមសុខ ក្នុងវត្ថុកាមមានរូបជាដើម ជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់ថោកប្រដុង មិនមែនជារបស់

១- ធម្មចក្កប្បវត្តនសូត្រ ភាណវារៈ ទំព័រ ៦៨ ។

ត្រង់អ្វីៗ: មិនមានប្រយោជន៍ ១ ការប្រព្រឹត្តិរឿយៗនូវអំពើថោកទាប ធ្វើខ្លួនឲ្យលំបាកមានប្រក្រតីសុខវិត្តដាដើម ជាបច្ច័យនាំមកនូវទុក្ខ មិនប្រសើរ មិនមានប្រយោជន៍ ១ ។ ទេះអនរិយសច្ច ពិសេសដោយបរ ភាមសុខល្អីភាទុយោគ: មិនឥត្តតិលមថាទុយោគ:

មួយទៀត មានប្រយោគថា អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ(*), ប្រែថា មគ្គមានអង្គ៨ប្រការ មានសម្មាទិដ្ឋិដាដើម ជាបច្ច័យប្រសើរ ជាអរិយធម៌ ទេះអរិយសច្ចពិសេសដោយមគ្គមានអង្គ៨ប្រការដូច្នេះ ។ ប្រយោគទាំងពីរនេះបង្ហាញឲ្យឃើញថា អរិយសច្ច ជាបច្ច័យពិសេសដោយជនមិនច្រើន ។

ឯអរិយសច្ចពិសេសដោយបុគ្គលដូចមានបទសុភាសិតថា:

ពុទ្ធា បច្ចេកពុទ្ធា
អរហន្តោ ពុទ្ធសាវកា
ត្រៃសារីមា អរេតត្តា
សត្ថៃ អរិយសង្ឃា(២)។

ប្រែថា ព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធ ទ្រង់ឥតទុក្ខសោកទាំងពួង ឈ្មោះថា អរិយៈ ក្រៅអំពីតថាគតសាវក គឺកិលេស ។

១- ធម្មចក្កប្បវត្តនសូត្រ ភាណវារៈទំព័រ ៦៤ ។

២- អរិយវំសសូត្រ ភាណវារៈទំព័រ ៣៤០ ។

នេះចង្អុលឲ្យឃើញថា អរិយសច្ចជាបច្ចត្តវិសេសដោយបុគ្គល នៅមានឧទាហរណ៍ដទៃទៀតថា:

ទ្វេមា ភិក្ខវេ បរិយេសនា

អនរិយា ច បរិយេសនា

អរិយា ច បរិយេសនា(១)

ប្រែថា ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមានប្រការតិ អនរិយបរិយេសនា ការស្វែងរកខុសចំនងមិនប្រសើរ មានការស្វែងរកជាតិ ជរា ព្យាធិ មរណៈជាអាទិ, អរិយបរិយេសនា ការស្វែងរកត្រូវចំនង ស្វែងរកប្រសើរ មានការស្វែងរកមានកូនមិត្រនិព្វានជាទីបំផុតនៃជាតិ ជរា ព្យាធិ មរណៈ ។ ។

នេះចង្អុលឲ្យឃើញថា អនរិយសច្ចនិងអរិយសច្ចទាំងពីរនេះជាបច្ចត្តវិសេសដោយធម្មាភិ ។ ព្រោះមានន័យជាគោលអធិប្បាយបែបយ៉ាងនេះ ទើបពួកបណ្ឌិតដទាំងឡាយគួរនិយមប្រើអរិយសច្ចនេះ, ស្មើរតែត្រង់ប្រយោគ ត្រង់ការសាជាតិនៃប្រទេសនោះ ។ ដូចមានពាក្យថា ឬលោកអ្នកនោះជាអរិយបុគ្គល អរិយសាវក អរិយជនអរិយធម្ម អរិយសីល អរិយវោហារ អនរិយវោហារ អរិយប្រត្យ ការប្រទេស ការត្រូមៗលៗ ជាគុណបទនិងនាមស័ព្ទ ដូចមានហើយនោះ ។

១- ជាសរាសិសូត្រ ភាគ. ២១ ទំព័ ៧២៨ ។

ពាក្យផ្ដើមរឿង

ក) បុគ្គលមានធម៌ខ្ពស់ប្រសើរលើសគេតើ ជាន់ដល់នូវសោតាបត្តិមគ្គជាដើម ដរាបដល់អរហត្តផល ឈ្មោះថា អរិយបុគ្គល ប្ដូរមួយអ្នកប្រព្រឹត្តល្អខ្លាចខ្លួនក្នុងទីបួនល្អ ១ចោសថល្អ មិនមានសៅហ្មង តាំងមានតំរិយា មានយោគ មិនគ្រាំគ្រងឆ្ងាស់ ទាស់នុស្សក្នុងភ្នែកប្រញាត្តិទីឯកជប្រញាត្តិក្នុងលោក ផ្លូវធម៌ តើភាន់ឈ្មោះថា អរិយបុគ្គលដែរ ។

ខ) អរិយសាវក អរិយជន សឹងមានគុណធម៌ដូចគ្នា មិនប្លែកគ្នាទេ ។

គ) អរិយធម៌ ធម៌ប្រសើរតើ អដ្ឋង្គិកមគ្គតាំង ៨ ប្រការ មានសម្មាទិដ្ឋិជាអាទិ៍ ឬធម៌របស់ព្រះអរិយៈ មានសុចរិតធម៌ជាដើម ។

ឃ) អរិយសីល សីលជាទីត្រេកអរនៃព្រះអរិយៈ គោះនិច្ចសីលតាំង ៥ ១ចោសថសីលតាំង ៨ អតិរេកសីលតាំង ១០ ចតុបារិសុទ្ធិសីលតាំង ៤ក្ដី សីលដែលមិនធ្លុះធ្លាយ មិនរាព្រះតណ្ហាលួស សីលដែលជិអ្នកប្រាជ្ញសរសើរ សីលមិនគ្រោកគ្រាតដោយតណ្ហាទីដិដ្ឋិ[1] មានសេចក្ដីពិស្ដារដូចអរិយធម៌ដែរ ។

ង) អរិយវោហារ[2] សំឡេងគោលចរចាផ្ទួមស្លួមពាក្យតិះដៀលរបស់អរិយជន ជាន់ដល់ពាក្យសុចរិតតាំង ៤ មានមិនគោលកុហកជាដើម ប្ដូ

---

១ ២-មើលភាគ១៩ ទំព័រ ១៦១ ព្រះត្រៃបិដក ។

សុភាសិតផ្សេងៗដែលមានសារៈខ្ពង់ខ្ពស់ប្រៀបដោយឃសល្យាណវាចា មិនមានទោសសព្វគ្រប់ ។

ច) អនរិយវោហារ[1] សំឡេងពោលចរចាមិនផ្គងផ្គើមហ្មង មិនពាក់ព័ន្ធ មិនមែនជារបស់អរិយជន ផ្ដុយនឹងវាចាសុចរិត ក្រមទាំងសុភាសិតផ្សេងៗ ។

ឆ) អរិយទ្រព្យ ទ្រព្យប្រសើរ ចោរលួចយកមិនបាន ភ្លើងឆេះមិនកើត ទឹកជន់ពន្លិចពុំបាន បញ្ចូមិត្តដណ្ដើមយកមិនបាន, បានដល់ទ្រព្យ៧ប្រការ មានសទ្ធាជាដើម ។

ជ) អារ្យប្រទេស ស្រុកតំណាក់ ទឹកដីទាំង ប្រទេសតូចធំដែលមានបែបបទរៀបរយល្អ មានផ្លូវគមនាគមន៍ល្អ មានមនុស្សច្រើនកុះករ សុទ្ធតែអ្នកមានទ្រព្យ អ្នកចេះដឹង ដូចប្រទេសវណ្ណៀជាដើម ពុទ្ធកាល នឹងគោះសំរែកឡើងជានាមសតវត្សទី៣ នៃពុទ្ធសករាជ គេតែងហៅថា អារ្យប្រទេស ។

ឈ) អារ្យជាតិ ជាតិអារ្យៈ ដូចព្រះបរមគ្រូជាម្ចាស់នៃយើង ព្រះអង្គជាអារ្យជាតិ ។

សេចក្ដីបំព្រួញថា ប្រទេសជាតិមាតុភូមិ ប្ដូបគ្គលដទៃគ្រាន់តែឱ្យ

១- មើលភាគ ១៩ ទំព័រ ១៣១ ព្រះត្រៃបិដក ។

ដូចអ្នកឯណេះ មិនមែនឈ្មោះថាអរិយទេ ។ ដូចរឿងព្រាន
ក្នុងក្រុងសាវត្ថី ព្រានៈនោះបានឃើញព្រះបរមសាស្តាទ្រង់គ្រាស់សួរព្រះ
សារីបុត្តថាលោកឈ្មោះអ្វី?, ខ្ញុំព្រះអង្គឈ្មោះសារីបុត្ត ហើយទ្រង់គ្រាស់
សួរព្រះមោគ្គល្លានថា លោកឈ្មោះអ្វី? ខ្ញុំព្រះអង្គឈ្មោះមោគ្គល្លាន ដូច្នេះ
ដាដែម លោកកាំងនោះ សុទ្ធតែជាព្រះអរិយៈសស ។ ព្រោះកំនឹតថា
ប្រហែលជាព្រះបរមសាស្តាទ្រង់ត្រាស់សួរអញដែរមើលៈភ ។ ព្រះ
សម្ពុទ្ធទ្រង់ជ្រាបពាក្យចិត្តរបស់ព្រាននោះហើយ ទ្រង់ត្រាស់សួរថានែ ឧបាសក!
អ្នកឯងនេះឈ្មោះអ្វី? ព្រាននោះទូលឆ្លើយតបថា ខ្ញុំព្រះអង្គឈ្មោះអរិយៈ ។
ព្រះសម្ពុទ្ធទ្រង់បន្ទរសេចថា នែឧបាសក! មិនមែនទេ មនុស្សប្រព្រឹត្ត
អំពើបាបណាតិចបាតជួបអ្នកឃាំងនេះ មិនមែនឈ្មោះថា អរិយៈទេ ប្លែ
ហើយទ្រង់សំដែងគុណព្រះអរិយៈជាវេនៈថាថា:

ន តេន អរិយោ ហោតិ
យេន បាណានិ ហឹសតិ
អហឹសា សព្វបាណានំ
អរិយោតិ បវុច្ចតិ(១) ។

១-ធម្មបទដ្ឋកថា អរិយវគ្គស័ព្ទវត្ថុ ភាគ ៧ ទំព័រ ៨៤ ។

ប្រែថា បុគ្គលបៀតបៀនធ្វើសត្វឲ្យវិនាស មិនមែនឈ្មោះថា អរិយ ព្រោះការបៀតបៀនខាងខេ ការមិនបៀតបៀនធ្វើសត្វឲ្យវិនាស ទើបហៅថា អរិយៈបាន ។

ពាក្យប្រៃ ត្រមាំងសេចក្តីអធិប្បាយអំពីអរិយសច្ច ខឹងទាហរណ៍ប្រៀបធៀប ដែលនាំមកត្រួសៗនេះ ក៏ល្មមសមគួរដល់វេលាតែប៉ុណ្ណេះ ។

បញ្ចប់គំពីរនេះ សូមផ្សាយកុសលពស់ ធម្មបណ្ណាការ ដ៏មានវិសេសនេះ ចែកជូនចំពោះទេវនិកាកុងស្តាន់សូតិ ខឹងទេវនិកាកុងស្តាន់មនុស្ស ត្រមាំងមនុស្សនិកាមានព្រះបរមសាស្ត្រជាប្រធាន ដរាបដល់សត្វនិកា សូមឲ្យបានសម្រេចតាមដួងមនុញ្ញផលសមតាមប្រាថ្នា មានសម្បត្តិព្រះនិព្វានជាអវសានកុំបីឃ្លាតឡើយ ។

សុរពជាតក

(តទៅ)

លោក ជឹង - វ៉ែង បម្លែងពីសាស្ត្រាសិង្ហាឡ

ភិក្ខុហ្មឹ វសតិ ព្រះអង្គ ឥតត្រង់ណា ? អញ្ជើមៅដែរទេតុំគួរឡើយ, តើ - តមោត្វា កុំ អញ្ជើគួរយកអ្វីមៅទ្វេះ ? សិម្ប៉ុ ខ្ញុំណ្ហិតុំ គួរអញ្ជើរៀនសិល្បសាស្ត្រហើយសឹមមៅ , តែតស្រេចតំចេញពីព្រះវត្តរួចលះមៅកន្លែងត្រៃ ដើម្បីរកៀនសិល្បសាស្ត្រ បានជួបនឹងលំមៅនៃតាបសម្នាក់ ។ តាបសនោះ ចេះសិល្បយ៉ាងពូកែ គេះបើយកបេះអ្វី ។ មកដាក់កន្លែងត្រាជូ (ផ្ទាំងឆ) បេះនោះក៏ក្លាយមៅជាមាស ដោយអានុភាពនៃត្រាជូនោះឯង ។ អាមាត្យនោះ កំបួលមៅសំណាក់សូមរៀន លុះរៀនបានហើយ លាព្រះតាបសត្រាច់កព្រះមហាក្សត្រ អាត់តាមជ្រោះជ្រលង ចូលមៅកន្លែងត្រៃធំ បានយើញស្រះមួយយ៉ាងធំ តំអង្គុយទៀបនេ្នស្រះនោះ ស្រាប់តែយើញកំន្ទុំមួយហែមកតាមអាកាស ។ កំន្ទុំនោះលុះដល់ស្រះហើយ ចុះងាះគ្រឿងអាភរណៈចេញពីខ្លួន ដើរមៅទៀបដើមឈើមួយ ស្មោះសម្បកយកមកស៊ី ស្រាប់តែប្រក្លាយខ្លួនមៅជាមេដំរី ។ មេដំរីនោះ ចុះលេងក្នុងទឹកស្រះទល់ល្ងាច ទើបះឡើងលើនេ្នស្រះដើរមៅទាំសម្បកឈើផ្សេងទៀតស៊ី តំក្លាយខ្លួនមៅជាកំន្ទុំវិញ តែ

ទៀយយាត់ចេញ ទើមដើរទៅរកសម្បកឈើមួយទៀតទាំស៊ុ, លុះនាងកំនូរ
នេះ ស្រដៀងគ្រឿងកំលេងជាន់ដូចដើមហើយ ស្ទុះហើរទៅតាមអាកាសជាត់
ទៅ ។ ឯអាមាត្យយើញដូច្នោះ កំដើរទៅស្ងោះសម្បកឈើទាំងនោះ
ក្រែកក្នុងថង់ឆាម ហើយគ្រាចតាមព្រះមហាក្សត្រតទៅទៀត ចូលក្នុងព្រៃ
តូចធំ ពុំខាន់ដួចប្រទះឡើយ, លុះដើរទៅអស់ផ្លូវគ្មាយជាច់ស្រយាលជួប
ទីឆ្ងកូម ១ ដែលព្រះមហាក្សត្រអាស្រ័យនៅ កាលបើឃើនយើញព្រះ
មហាក្សត្រហើយ កំក្រាបថ្វាយបង្គំទូលសួរថា «ឥឡូវនេះ ព្រះអង្គដឹង-
ស្គាល់សេចក្តីទុក្ខវេទនាក្រហាល់ក្រហាយហើយឬ ? » ។ ព្រះបរមក្សត្រ-
ឆើកដ្រាស់ថា «អញស្គាល់ហើយ» ។ – បើព្រះអង្គស្គាល់ហើយ សូម
ស្តេចយាងទៅនគរយើងវិញ ។ – ម្នាលអាមាត្យ! យើងទៅពុំខាន់ឃើនទេ
ដ្បិតនៅដំណាក់មានឆ្នាំងឆ្អាមសចំនួន១ឆាន់ដំឡឹងនៅឡើយ ។ ទើប
អាមាត្យឃកដុំថ្មមកថ្វាយ តើតជាមាសយ៉ាងច្រើនលើសលន ១ ឆាន់ដំឡឹង
មោះទៅទៀត រួចឲ្យទៅស្រ័ង្កាមាស ហើយយកខ្សែថមកជាក់ក្នុងភាន
ទឹក ។ លុះស្រ័ង្កាមាសឆឹកហើយ កំប្រែក្លាយទៅជាមេដំរីមកឈរ
នៅចំពោះត្រកែក្រៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រត្រាស់ថា ម្នាល
អាមាត្យ ចូរធ្វើឲ្យទៅជាមនុស្សដូចដើមវិញហោង ។ អាមាត្យកំយក
សម្បកឈើផ្សេងទៀតឲ្យស៊ុ តើតជាស្រដូចដើមវិញ តែស្រដៃពុំ
ជាន ។ ព្រះមហាក្សត្រប្រើឲ្យអាមាត្យធ្វើស្រីនោះ ឲ្យបានដូចយ

វិញ ។ អាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ! បើធ្វើឲ្យ
ស្រីនេះ ចេះស្រដីហើយ ក៏ខឹងចូលទៅក្រាបទូលព្រះមហាក្សត្រ
របស់ក្ប ខឹងចាប់យើងយកទៅសម្លាប់ពុំខាន, ដូច្នេះ គួរយើងរត់ទៅ
មុន ។ ស្តេចត្រាស់ថា ម្នាលអាមាត្យ ! យើងខឹងមានតែរវៃ ។
អាមាត្យក៏យកភ្នំមួយមុខទៀតទៅដាក់ចោលក្នុងតាជីតក ហើយនាំព្រះ
មហាក្សត្រវិលត្រឡប់ទៅចាំងយប់ តុំឈប់សម្រាកសោះ លុះត្រឹក
ទើបផុតទំណាស់មានតរនេះ ។ ឯស្រីឡាំមាស លុះត្រឹតឡើងទៅដឹក
ទឹកក្នុងតាជីនេះ ចេះនិយាយដូចដើមវិញ ទើបទូលទៅក្រាបទូលព្រះ
មហាក្សត្រខ្លួនថា ឥឡូវមានស្តេចមួយព្រះអង្គ ព្រាត់ឡាត់មកតាំនតរ
ដៃ ចេះសិល្បសាស្ត្រដូច្នេះ ។ ។ ព្រះមហាក្សត្រជ្រាបហើយ ក៏
គ្រាស់ប្រើសេនាមាត្យ រៀបគ្រឿងសស្ត្រាវុធ ដេញតាមស្តាត់រក ។
ពួកសេនាមាត្យដេញតាមរកសព្វត្រាត្រឹកក្បា ទីជិនិតមជនបទតូច ធំ តុំ
ឃើញ ក៏ត្រឡប់មកវិញ ។ ឯព្រះបាទវៃច្ចមាដើតក៏ជនទីឯអាមាត្យ ទំ
ស្រួតកាត់ព្រៃរកំណាយព្រៃទៅដល់ទតរមួយ ចូលទៅអាស្រ័យលើសា-
លាមួយ ។ តស្មិំ ខណេ ក្នុងទតរនោះ មានស្រីឡាមាសម្នាក់ មាន
រូបយ៉ាងស្អាត ឧស្សាហ៍ឆើយ ជាស្រីតីបុរសឯងតាំងភ្លួងគួរពិតពិលរមិល
មើល ហើយបង្កើតន្ធូរសេចក្តីស្នេហាចនឹងមិនត្រូវ ។ តែថា បើបុរសណា
ចូលទៅកាន់សំណាក់នាង ។ តាយកឈ្នួលជាប្រាក់ ១ ពាន់ដំឡឹងមុន

ហើយពុំបានដេកនៅតាស្រែយ៉ាងយូរសោះមុណាទេ , ឮតែនាងនោះ
ធ្វើគ្រែតែរ ធ្វើម្ខាងមានយន្ត, បើបុរសឡើងទៅអង្គុយលើគ្រែយន្តនោះ
រមែងភ្លាត់ធ្លាក់ទៅក្រោមដុះ ពួកទាសីរបស់នាងពាំងប៉ុន្មាន តាលបើ
ឃើញបុរសភ្លាត់ធ្លាក់មកដូច្នោះ ក៏ចាប់ចងដាក់គាត់បណ្តេញចេញក្នុង
មួយរំពេច ។ ជួនកាល មានបុរសខ្លះឡើងទៅលើគ្រែតានយន្ត ។
ឯស្រីភ្លាមាសនោះ ក៏ឡើងលើគ្រែមានយន្ត ហើយភ្លាត់ធ្លាក់ទៅក្រោម
ដុះ រត់ឡើងមកវិញឡើយ ។ ហេតុនេះ ទើបបុរសជាពាំងពួន ពុំ
ដែលសម្រេចសេចក្តីជ្រុងថ្នាំរបស់ខ្លួនឡើយ ។ កន្លងថ្ងៃដែលព្រះបាទ
វេទ្ធមារជិតភជ ឆ្នាំនៅលើសាលានោះ , មហាជនពាំងពួយ ពាំគ្នា
និយាយពីសំអាងរបស់ស្រីភ្លាមាសនោះ. ព្រះកង្សាទ្រង់សព្វព្រះភជហឫទ័យ
ចង់ទៅលេងតែក្បាលមួយស្រីនោះ ទើបយាងទៅជាមួយអាមាត្យ ហើយ
ត្រាស់ថា ម្នាលអាមាត្យ ! យើងចង់ទៅសំណាក់តាស្រែយន្តពាំងស្រីភ្លា-
មាសនោះដែរឬទ្រឹក ។ អាមាត្យទូលថា បពិត្រព្រះសម្មតិទេព ! សូម
ព្រះអង្គឈប់ទៅថ្ងៃនេះសិន ទូលព្រះបង្គំនឹងចូលទៅជាមុន ដើម្បីសង្កេត
មើលកិរិយារបស់វា រួចសឹមព្រះអង្គយាងទៅជាខាងក្រោយ, ទូលដូច្នោះ
ហើយ ក៏ក្រាបថ្វាយបង្គំលាទៅកាន់លំនៅរបស់ស្រីនោះ ។ ស្រីភ្លា-
មាស កាលបើឃើញអាមាត្យមកដូច្នោះ ស្ទុះទៅទទួលដោយរាក់ទាក់
ទាំឡើងទៅបរិភោគនូវខាទនីយភោជនីយាហារ, លុះអាមាត្យអង្គុយបាន

មួយស្របក់, នាងនេះមានប្រាក់ថ្លៃឈ្នួលភ្ញាម ។ អាមាត្យក៏ឲ្យ
ប្រាក់ពាន់តហាបណៈទៅនាង ហើយតឿនថា ម្នាលនាងអើយ !
មកយើងនឹងនាំគ្នាទៅលែងខាងក្នុង ។ នាងនោះទទួលថា សាធុ ។
ហើយនាំអាមាត្យចូលទៅក្នុងលែង នាងបានអង្គុយលើគ្រែឥតឃ្លាត ឲ្យ
អាមាត្យអង្គុយលើគ្រែមានយឺត, ឯគ្រែឃ្លាតភ្លាត់ឆ្ងាយអាមាត្យទៅក្រោម
ដួរ ។ រស្រែជាគស៊ីតាំងខ្លាម ពាក់បណ្តាញអាមាត្យចេញក្រៅមួយ
រំពេច ! ។ ទើបអាមាត្យទៅក្រាបទូលព្រះមហាក្សត្រថា បពិត្រព្រះ
សម្មតិទេព ! បើស្តេចយាងទៅកាន់សំណាក់នាង សូមគង់លើគ្រែខាង
ស្តាំ កុំគង់លើគ្រែខាងធ្វេងឡើយ, ដល់នាងមើងមកលើគ្រែខាងធ្វេង
ក្តាយខ្លួនទឹងភ្លាត់ឆ្ងាក់នាង, សូមព្រះអង្គចាប់ចុងកៀកកាន់នាងនោះឲ្យ
ខ្ជាប់ មនោរថំ ទាបុណ្ណាសុត្តន្ត ទីឯងានសម្រេចនូវសេចក្តីប្រាថ្នា
ហោង ។ ព្រះមហាក្សត្រស្តេចស្តាប់ពាក្យអាមាត្យហើយ ក្រេងចាន
ទៅកាន់សំណាក់នាងនោះហោង ។ ស្រីក្តាមាស កំពូលថ្វាយគោជ-
នាហារ លុះបានយកគ្រឿងបានហើយ អញ្ជើញព្រះអង្គចូលក្នុងលែងដួរ ។
ស្តេចគង់លើគ្រែខាងស្តាំ ។ នាងនោះអង្គុយលើគ្រែខាងធ្វេង ។
ក្តាយខ្លួនក៏ភ្លាត់ឆ្ងាក់នាងនោះទៅ ។ ប៉ុន្តែ ស្តេចចាប់ដាច់ពាញ ឡើងវិញ
ពុំឲ្យភ្លាក់ឡើយ ហើយព្រះអង្គបានសម្រេចកាមរស នឹងស្រីក្តាមាស
នោះ ។ ទើបនាងក្រាបទូលថា មហាភាគ បពិត្រមហារាជអើយ !

តាំងតែខ្ញុំម្ចាស់កើតមក ពុំដែលរួមសំវាសជាមួយបុរសណាឡើយ, ខ្ញុំម្ចាស់ទើបតែស្គាល់គូដណ្តឹងថ្ងៃនេះ ជាមួយព្រះអង្គ, ព្រះមហាក្សត្រស្តេចនាំនឹងស្រីផ្កាមាសនោះអស់រយៈ ៧ ខែគត់ រហូតដល់ស្រីនោះមានគភ៌ ទើបស្តេចព្រះកដតាន់ព្រះទំរង់ ១ នឹងមាស ១ សែនដំឡឹង ហើយផ្តាំថា «កន្លងម្ចាលនាឯងដំចំរនេ ! បើកូនយើងប្រុស ចូរនាំឲ្យព្រះទំរង់នេះ ហើយឲ្យទៅរកឪពុកវិញ, បើកូនស្រីវិញ ចូរនាំយកទៅក្សាតាមត្រកូលចុះ », លុះផ្តែផ្តាំរួចស្រេចហើយ ព្រះរាជាទ្រង់យាងចូលទៅកាន់ព្រះនគរព្រះអង្គវិញជាមួយអាមាត្យ សោយរាជសម្បត្តិដោយទសពិធរាជធម៌ ហើយទ្រង់ដំកល់អាមាត្យនោះ ក្នុងដំណែងជាសេនាបតី ។

នាងបណ្ឌិតទេវី ឮនាំទាហរណ៍មកក្រាបទូលព្រះបាទចន្ទកដ៏ជាមហោរាធ បពិត្រមហាកដ ! នាងហៅព្រះមហាក្សត្រនិងចាំមអាមាត្យនោះ សូមទ្រង់ពិចារណាគំនិតនាងទៅ ឲ្យបានទៀងត្រង់មានស្វាមីតក្តី ដូចព្រះបាទវិច្ចមារជិតរាជចិញ្ចឹមអាមាត្យដូច្នោះ ។

ព្រះបាទចន្ទកដ, លុះនាងនិទានថ្វាយដូច្នេះហើយ, ទ្រង់ត្រាស់ជណ្តឹងសួរថា ម្ចាលនាងបណ្ឌិតទេវី ! ចុះស្រីផ្កាមាសនេះ នាងបានកូនប្រុសឬស្រី ? ។ - បពិត្រព្រះសម្មតិទេព ! ស្រីផ្កាមាសនោះ បានកូនប្រុស ។ - កូនប្រុសនោះ មានប្រការដូចម្តេចខ្លះ ? ចូរនាងនិយាយតទៅទៀត យើងនឹងស្តាប់ផង ។ សា ច ទេវី

ទាងបណ្តើតទៅ នាំនិទានមកក្រាបទូលតទៀតថា :

បពិត្រក្សត្រថ្លៃប្រសើរអើយ ! រីស្រីផ្កាម៉ាសនោះ លុះមានគតិគ្រប់ទសមាសហើយក៏ប្រសូតកូន ១ ។ ព្រះពជកុមារនោះ កាលបើចំរើនធំឡើង បានអាយុ ១៧ ឆ្នាំ ទើបចូលទៅទៀបមាតាសួរថា អម្ពបតិត្រអ្នកម្តាយ ! តោ មយ្ហំ បិតា អ្នកណាជាបិតាខ្ញុំ ? ។ -ម្នាលកូនសំឡាញ់ ! រីបិតាអ្នកពុំនៅទីណាស្រុកនេះឡើយ គឺព្រះបាទវិទេហមហាជនក ស្តេចសោយរាជ្យនៅនគរឈ្មោះឯណោះ ។ ព្រះពជកុមារសួរថា បពិត្រអ្នកម្តាយ ! អ្នកម្តាយនៅស្រុកនេះ ម្តេចក៏បិតានៅស្រុកឯនាយ យល់ទុសប្រពៃណា ខ្ញុំពុំដឿឡើយ ។ តាតបិយបុត្ត ម្នាលកូនសំឡាញ់ម្តាយអើយ ! រីបិតានៃបាជាព្រះមហាក្សត្រសោយរាជ្យនៅនគរមួយ ស្តេចគ្រាប់ប្រភពព្រៃជាមួយនឹងអាមាត្យម្នាក់ ហើយចូលក្នុងព្រៃធំ-តូច តុះតារំលាយរកបមកដល់នគរោពណាសី ស្តេចចូលមកជាស្វាមីនៃម្តាយ, កាលបើម្តាយមានគតិ ស្តេចទ្រង់លាទៅ ទ្រង់ទុកចិញ្ចៀនព្រះទំរង់មួយនៅទីនេះ ហើយទ្រង់ផ្តាំថា បើកូនប្រុសឲ្យយកចិញ្ចៀននេះទៅតាមព្រះអង្គ បើកូនស្រីឲ្យម្តាយចិញ្ចឹមរក្សាតាមប្រពៃណី ស្តេចឲ្យគាំងទ្រព្យ ១ សែនជំឡឹងផង ម្នាលកូន ! បើចាចង់ស្គាល់បិតា ចូរចាយកព្រះទំរង់នេះទៅជាសំគាល់ហោង ។ ព្រះពជកុមារ ស្តាប់ហើយមានចិត្តត្រេកអរ

ខ្ញុំលួយយកព្រះទំរង់ដ៏ធំទ្រព្យ ១ សែនដំឡឹង ក្រាបថ្វាយបង្គំលា ធ្វើ
ប្រទក្សិណ ៣ ដង ឯកគោះ ចុះចាកគ្រឹះតែម្នាក់ឯង រំលងវាំង
ទីបរន្តោ សព្វារៀកដ៏ព្រៃតូច-ធំ លុះដល់ស្រុកមួយ ចូលទៅ
សំណាក់នឹងមេស្រុកនោះ ។ រីមេស្រុកនោះជាអាចារ្យនៃមហាចោរ
ពាំនាំដួង លុះ ឃើញព្រះកុមារមានមាស ១ សែនដំឡឹង មានចំណូចដ៏ថាន
ក៏ស្រដីថា· ម្នាលមាណព! ចៅចាំនរៀនសិល្បសាស្ត្រចោរឬទេ? ។
ព្រះរាជកុមារក្រាបថា ខ្ញុំពុំចាំនរៀនទេ ។ មហាចោរក៏និយាយថា
យោ យោ ចោរសិប្បំ ន ជានាតិ អ្នកណាមួយពុំចេះ
សិល្បសាស្ត្រចោរហើយ សោ សោ យន្តុ · កុដ្ឋតិ
អ្នកនោះ តោះនឹងចៅក្នុងទីណា ។ មានទ្រព្យដល់ ១ សែនដំឡឹងក្តី
ក៏ទីធ្លាត់ឥស់ហោង, ហេតុនោះ ចូរចាំរៀនសិល្បសាស្ត្រសិន ។
ព្រះរាជកុមារទូលថាទីងរៀន ។ ឯមហាចោរថា បើះចាំរៀនចូរ
ចៅឲ្យមាស ១ សែនដំឡឹងនេះមកយើងចុះ ។ ទើបព្រះរាជកុមារលើក
មាស ១ សែនដំឡឹងជូនមហាចោរជាស្រេច ហើយរៀនសិល្បសាស្ត្រនោះ
លុះរៀនចេះហើយ ទើបលាអាចារ្យចេញអំពីស្រុកមហាចោរ ទៅ
ដល់ទីតាំនៃព្រះវរបិតា ចូរទៅសំណាក់អាស្រ័យនឹងផ្ទះជូនថាសម្ចាស់ជា
អ្នកឥតភ្លេច ។ រីព្រះរាជកុមារនោះនៅតែតែលថ្ងៃ តែលយប់ ចុះ
ពីផ្ទះដើរគ្រាច់រន្ធត់សព្វប្រកល្អក រកលួចមាសប្រាក់នូវគ្រឿងប្រដាប់

សំពាត់ឆកវែនអ្នកស្រុកមកលាក់ទុកក្នុងទីទ្រ លុះព្រឹកឡើងចូលមកគាស្រ័យ
នឹងផ្ទះដូនចាស់វិញ ។ កាលបាច ដូនតាលត្រាកដល់ការឡើងលួច
លើផ្ទះពដប្រុស ទូរផ្ទះគាមាត្យមន្ត្រីសេដ្ឋីតូច ធំ ចាន់ប្រគ្រាប្លែកៗ
យកទៅទុកនៅទីដដែល ។ រីឯអ្នកស្រុកទាំងអស់ គស្ចារ្យក្នុងចិត្តថា
តាំងតាមុនមក ភ្នំដែលមានចោរកំណាច ឥឡូវនេះ មានចោរមកពីឯណា
គិតពិចារណាគ្មានកន្លែងចោរពុំឃើញឡើយ ទេមនាំសេចក្តីទុក្ខ
ទៅក្រាបបង្គំទូលព្រះរាជាថា បពិត្រមហាពដរាជ ! តាំងតាដើម
រៀងពដរាជមក ភ្នំដែលមានចោរក្នុងព្រះនគរឡើយ ឥឡូវមាន
ចោរកំណាច ឡើងលួចមាសប្រាក់អ្នកស្រុកអស់លើងជាម្តង ។ ព្រះ
មហាក្សត្រទ្រង់ព្រះសណ្តាប់ហើយ ក៏ស្ងៀមនៅ ។ លំដាប់តមក
ក្នុកនគរទាំងអស់ ទៅប្តឹងមហាមាត្យសព្វ ។ ថៃ ។ មហាមាត្យ
បាននាំសេចក្តីទុក្ខទៅក្រាបទូលព្រះមហាក្សត្រាធិរាជ ។ ព្រះអង្គទ្រង់ឲ្យ
មហាមាត្យគេចាប់ចោរនោះឲ្យបាន ។ មហាមាត្យក្រាបទូលថា ចាប់
ពុំបានឡើយ តែងតាចោរនោះចេះសិល្បសាស្ត្រពូកែណាស់ ។ ទើប
ស្តេចឲ្យហៅអស់ពដរាជយោធាមកហើយ មានព្រះបន្ទូលថា ចូរប្រុងស្តេច
កាលគ្នាចាំតាក្តីក្បាលភ្នំច្រកហ្លួកក្នុងភូមិតូច ធំ ព្រមទាំងរក្សាផ្លូវដ៏ជង
អូរឱ្យបានត្រួតូច ធំ ស្កាត់ចាប់ចោរនោះឲ្យបាន ។ រីពដរាជាទទួល
ព្រះបន្ទូលហើយ ក៏ផ្ញាស់គ្នាចាំតយឃ្លាំមើល ដួចព្រះបន្ទូលនោះ ។

រីឯជូនចាស់ព្នាត់ថា ព្រះមហាសត្វត្រូវចាប់ចោរជូនហ្នោះ កំស្រដីទៅកាន់ព្រះពុទ្ធមានថា ម្នាលភិក្ខុទាំង ! អ្នកកុំដើរលេងយប់ព្រលប់ឡើយ ត្បិតព្រះមហាសត្វត្រូវស្តេចឲ្យគេចាប់ចោរ រីត្រង់ពាក្យយោគចាប់ចៅថាដាំចោរនឹងធ្វើទោសដោយទូរអំណាចពុទ្ធអាជ្ញា ។ ព្រះពុទ្ធមានតិថា យោយនេះគាត់ពុំដឹងគំនិតអញឡើយ ហើយគិះស្មានទៅហាន ។ ឮដំណាលណោះ មានអាមាត្យម្នាក់ចេញទៅយ៉ាំមើល លុះដើរទៅដល់ផ្ទះជាងគាត់សក់ ឮជាងគាត់សក់ពីរនាក់និយាយគ្នាថា មានក្មេងម្នាក់មកនិញស្លាមួយើងវាជាចោរដឹង ? ។ អាមាត្យឮហើយ ក៏ចាប់យកជាងគាត់សក់ទាំងពីរនាក់មកតិចារណាសួរថា ប្រុះស្តេងស្គាល់ក្មេងនោះទៅផ្ទះនរណា ? ម្តាយឪពុកឈ្មោះអ្វី ? ។ ឯជាងគាត់សក់គិតឆ្លើយថា ខ្ញុំពុំស្គាល់ចំហាងផ្ទះសំបែងមាតាបិតាក្មេងនោះទេ ។ ទើបអាមាត្យនិយាយថា "បើដូច្នោះ ខ្លួនអ្នកឯងហ្នឹងហើយជាចោរ ហើយទាំងអ្នកទាំងពីរឡើងទៅតាល់ព្រះមហាសត្វត្រាប់ទូលតាមដំណើរ ។ ឯសម្តេចព្រះមហាសត្វត្រាស់ដូច្នេះមានព្រះបន្ទូលថា ហៃហោកអាមាត្យ ! រីជាងគាត់សក់ទាំងពីរនេះប៉ុន្មានចោរគឺកុសស្មើចោរតែម្តាក ចាវពុំជាន, ហៃហោកអាមាត្យ ! មិនដឹងទេឬ ? យំ យំ ចោរនេះ តស្លើតតែ រត់ស្ទុះដែលចោរលួចយកទៅ, ឯម្ចាស់ឥវ៉ាន់ដែលគេមកទៅ, រីចោរគេតទាំងខ្លាក់ចាលរបស់នៅភូមិណាក្តី ឃុំណាក្តី, ម្ចាស់របស់ឃើញតែត្រូវ ចាប់ចោរមិនជាន

ត្រូវម្ចាស់ភូមិនោះកេចោរឲ្យ បើកេមិនបានម្ចាស់ភូមិនោះជាចោរហាន; ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ទើបផ្តាំអស់សេនាគហានថា ម្នៃសេនាតាំងពួន! ចូរអ្នកកល់គ្នា រៀបអស់គ្រឿងសស្ត្រាវុធចេញទៅកេឲ្យឃើញ បើប្រទះវាហើយ វាតតាំងច្បាំង ត្រូវសម្លាប់វាចោលចេញ ។ តែ ៦ ឯអស់សេនាគហានតាំងភ្លាមខ្លួលព្រះពាជនន្លឹះហើយ ចេញទៅដោយទ្វារថៃ្មខ ។ ក្នុងកត្រីនោះ ។ រីឯភូមិសេនាបតីតេញទៅដោយមនុស្សម្នាកាន់គ្រឿងសស្ត្រាវុធត្រប់ដៃ ។ ហើយដុតភ្លើងភ្លឺនាលប្រាសផ្លេ ។ ព្រះពាជកុមារ លុះឃើញមហាជនអគ្គិយយាមដុតភ្លើងដូច្នោះ ទើបចូលទៅដឹតមហាជន ហើយដណ្តឹងសួរថា ម្នៃបងប្អូនភាំងពួនអើយ! ហេតុដូចម្តេចក៏អ្នកភាំងពួនប្រឆឹងប្រឡែបរឿងការុងច្រើនដូច្នេះ ។ រីអស់សេនាគហានភាំងអស់ប្រាប់ថា យើងនឹងចាប់ចោរ ។ ព្រះពាជកុមារសួរថា ចោរច្រើនឬចោរតែម្នាក់? ។ - ចោរតែម្នាក់ទេ, ប៉ុន្តែចោរនោះ វាជាអ្នកមានដំរេះប្រជ្ញា ។ ឯព្រះពាជកុមារនោះប្រាប់ថា តានា ម្នៃអ្នកភាំងឲ្យអើយ! កាលខ្ញុំដើរមក ខ្ញុំឃើញចោរម្នាក់ពាំនួចខ្ពស់ ប្រមាណប៉ុនខ្ញុំនេះឯង លុះវាឃើញខ្ញុំ វាដេញមក ទើបខ្ញុំតំបូលមកពីនេះ ។ ឯអស់សេនាគហានភាំងពួនសួរថា វាទៅឯណា?។ - ទៅឯណោះ ។ លុះឮដូច្នោះ, មហាជនភាំងឲ្យតស៊ុះតត់ទៅចាប់ចោរនោះ ។ រីព្រះពាជកុមារកំលូចទ្រព្យរបស់មហាជនភាំងនោះ ហើយវិលមកផ្ទះវិញ ។ មហាជន

តាំងឡាយវិលមកមើលឃើញទ្រព្យរបស់ កំពោលច្រាប់គ្នាទៀត ។ ថា
សំពត់អញចាត់ហើយ, ខ្នះថា អាវអញចាត់ហើយ ច្រាកដជាកុមារកេម្ញះ
នេះឯងជាចោរ ទើបបបួលគ្នាដើរទៅរក តំពុំឃើញ ។ បុន ដំរាំស
ក្នុងថ្ងៃព្រឹកឡើង អស់សេនាពាហនតាំងនោះ ឡើងទៅគាល់ព្រះមហា-
ក្សត្រាធិរាជខួលតាមដំណើរ ។ ព្រះមហាក្សត្រទ្រង់ត្រាស់ថា យើងច្រាប់
ថា ឲ្យចាប់ឲ្យបាន ហេតុអ្វីក៏មិនចាប់វាមក ទើបហៅហោរាមកដល្អីង
សួរថា ថ្ងៃនេះ តើចោរវានៅទិសឯណា ? ។ ហោរក្រាបខួលថា បពិត្រ
ព្រះសម្មតិទេព ! ថ្ងៃនេះ វានឹងមកនៅខាងទិសខ្ពង្គ ហើយទៅកេនឹងជួបវា
នៅខាងស្រែធំ ។ លំដាប់នោះព្រះមហាក្សត្រទ្រង់បង្គាប់ឲ្យសេនាយោធា
ទៅចាំឃ្លាំមើលនៅមាត់ស្រែធំ ។ រីសេនាពាហនតាន់ត្រឿងសស្ត្រាវុធ
ដោយខ្លួនទៀត ។ ហើយបបួលគ្នាទៅចាំឃ្លាំមើល នៅមាត់ស្រែនោះ
ឯង ឯព្រះកដកុមារពុំដឹងដំរមហាជនទៅឃ្លាំមើលនៅមាត់ស្រែនោះទេ
តាន់ផ្ទៃកន្ទុតព្រៃដើរទៅអង្គុយក្បែរមាត់ស្រែ រួចដាក់ត្រឿងប្រដាប់
ក្បែរខ្លួន ។ ឯសេនាយោធាតាំងឡាយឃើញព្រះកដកុមារអង្គុយក្បែ
ដូច្នោះ បបួលគ្នាតាន់ត្រឿងសស្ត្រាវុធចុះទៅ ធ្វើគ្នាចោមរោមដុំដិតច្រាំ
ខ្នើចាប់ព្រះកដកុមារ ។ ឯព្រះកដកុមារ លុះឃើញមហាជនតាំងភ្លឺ
ចោមរោមដូច្នោះសួរថា ហៃសេនាតាំងឡាយអើយ ! ហេតុអ្វីអ្នកតាំង
ឡាយតាន់ត្រឿងសស្ត្រាវុធមកដូច្នេះ ? ។ យើងតាំងឡាយមកចាប់អ្នក

ឯងជាចោរ ។ អ្នកណាទៅប្រាប់អ្នកតាំងឡាយថា ខ្ញុំជាចោរ ? ។ – ពុំមានអ្នកណាមកប្រាប់យើងទេ ។ – ចើគ្មានអ្នកណាមកប្រាប់ ហេតុអ្វីគំមកចាប់ខ្ញុំថាជាចោរវិញ, ហៃអ្នកតាំងឡាយ! ធម្មតាចោរ យើញមនុស្សកាន់គ្រឿងសស្ត្រាវុធច្រើនយ៉ាងនេះ ក៏មិនដែលចូលមកនៅកណ្តាលគ្រឿងអាវុធដូច្នេះទេ ។ តែពួកមហាជនវិញតាម ពុំបានចាប់ព្រះរាជកុមារនោះឡើយ ហើយដោះសំពត់ ខ្លួនគ្រឿងប្រដាប់ចេញពីខ្លួនអស់លើង ។ ឯព្រះរាជកុមារ លុះដើរចេញពីមហាជនបានបន្តិច ក៏ត្រឡប់ចូលមកស្រែកប្រាប់ថា ហៃអ្នកតាំងឡាយ! ខ្ញុំដើរចេញទៅពីនេះប្រហែនមិនចោរ វាដេញខ្ញុំ ។ សូរតាមក ។ ឯមហាជនជឿថា ពិតមែន ទំសូរតដេញ ចោលគាំងសំពត់ពោ-អាវខ្លួនគ្រឿងសស្ត្រាវុធនានា ខ្លះបានកាន់យកទៅ ខ្លះយកទៅមិនបាន់ ។ ឯព្រះរាជកុមារ ក៏រើសយកទ្រព្យរបស់ដែលគេចោលនោះ ហើយរត់ទៅ ។ រីមហាជនរត់ចាំតុំយើញ បបួលគ្នាវិលមកវិញ ឃាត់ទ្រព្យរបស់អស់លើង ទើបស្គាល់ជាក់ថា មាណពនេះជាចោរ ហើយទៅនើងទៅក្រាបទូលព្រះមហាក្សត្រាធិរាជតាមដំណើរ ។ ព្រះអង្គទ្រង់ត្រាស់ឲ្យហៅហោរមកដណ្តើងសួរថា កាលនំ ឯសំ តច្ចតិ ថៃ្ងនេះ តើចោរវាទៅទីណា? ។ ហោរក្រាបទូលថា ថៃ្ងនេះ ចោរវាទៅទិសបូព៌ ។ សម្តេចព្រះមហាក្សត្រាធិរាជ ទ្រង់ត្រាស់បង្គាប់ជាងប្រមោកឲ្យយកសំពត់

យ៉ាងក្រៃនៅចុងឯទ្វេ ហើយហាលចោលទូវគាត់ទន្ទេនោះឲ្យសេនាគហានឃ្លាំមើល ។ រីឯងប្រមោកទាំងឡាយ ខ្លួលព្រះពន្ធុង្ការហើយវិលមកផ្ទះ; លុះព្រឹកឡើង នាំគ្នាយកសំពត់ទៅប្រមោកឯទ្វេទំនួបពួកព្រះនេតរ លុះចុកវួចហើយ ទើបហាលដៃឲ្យគហានចាំរក្សា សាយណ្ណា គេសណ្ឋិតត្រជាក់ ពួកគហានទាំងនោះក៏សាសំពត់បត់វេចពុកជាតំនរ ហើយដំនុំគ្នាជាមួយមហាជនថា អតិសាយណ្ណា គេសនេះ ស្លាចណាស់ហើយ ហោរាតុំមកឡើយ មកយើងនាំគ្នាទៅផ្ទះវិញ។ កាលនោះ ព្រះពន្ធុគ្នាមេតដល់ ចូលទៅតណ្ណាលដំនុំមហាជនសួរថា ហៃអ្នកទាំងឡាយ! ឯមេ ពហុកណ្ហាតោ រំបង្វែចសំពត់អ៊ីព្រែនម្ល៉ះ! ខ្ញុំសូមលើកមើលទ្វន់ឬស្រាល ថាតែប៉ុណ្ណោះ ក៏ចាប់សំពត់លើស្មាដើរទៅ ។ ឯមហាជនដេញចាប់មិនបាន សឹងទ្វេរអស់កម្លាំងរឿងៗខ្លួន ត្រឡប់មកដំនុំគ្នាដោយប្រការផ្សេងៗ ។ ព្រះពន្ធុមារយកសំពត់ទៅលាក់ពុកមួយកន្លែង ហើយធ្វាសសំពត់ស្លៀកដាទៃទៀត រួចចូលមកតណ្ណាលដំនុំមហាជនោះ ។ ចំណែកខាងសេនាយោធាដែលកុំភ្លេចអង្គុយដំនុំគ្នានោះ ជាក់ត្រឿងអាវុធទៅឆ្ងាយតិចទ្វេង ។ ព្រះពន្ធុមារបានឧបាសក៏រើសយកត្រឿងអាវុធហើយរត់ទៅ ។ ជួនជាគេសនោះត្រលប់ទៅហើយ ពួកយោធាពុំអាចតាមទៅបាន នាំគ្នាចូលទៅគាល់សម្តេចព្រះមហាក្សត្រាធិរាជ ទូលតាមដំណើរ ។ កាលនោះ ព្រះពន្ធុទ្រង់មានព្រះបន្ទូលថា ម៉ឺមេ តាលា ឧទ្ធា ពួកសេនាគហានគាំង

នេះនោតលួងទៀណាស់ ទើបព្រះអង្គត្រាស់បង្គាប់សេនាតាហានឯទៀត ឲ្យហៅហោកចូលមកគាល់ ហើយដណ្តឹងសួរថា តតនំ ថ្ងៃស្អែកនេះ តើចោរពេះនៅទិសណា ? ។ ហោរក្រាបទូលថា ស្អែកនេះ ចោរពេះនៅទិសឯត្បូង ។ ទើបព្រះអង្គត្រាស់ប្រើសេនាបតីថា ស្អែកនេះ ត្រូវចេញទៅចាប់ចោរឲ្យបាន ។ ទើបសេនាបតី ក្តុំអស់សេនាយោធា ទាំងគ្នាចូលទៅកន្លែងដែលត្រៃចាំឃ្លាំមើលតាំងតែព្រឹកដរាបដល់ថ្ងៃត្រង់ ពុំឃើញចោរមកហើយ សេនាបតីនោះនៅតែលើទឹក, សេនាយោធានៅក្រោមទឹក ។ លុះដល់ល្ងាចវាំងឆ សេនាបតីក៏ដេរអស់ត្រឿងប្រដាប់ចេញតែខ្លួនចុះទៅដួតទឹកដុំរកាយ ។ គាល់នោះ ព្រះពជកុមារយល់ដំណឹងថាសេនាបតីដេរអស់ត្រឿងប្រដាប់ហើយ ក៏រើសយកដាវសំពាំងអស់តែទៅតាមជាំចំនួន ។ លុះជួបនឹងពួកយោធានៅខាងក្រោម ស្រែកប្រាប់ថា គោះឮ្ញា ភៃម្នុតតាំងឡាយដ៏ចំរើន ! ឥឡូវ សេនាបតីជាម្ចាស់ខ្មែរកាល់គ្នា កំពុងចំបាប់ទីឯចោរចូរអ្នកតាំងអស់ស្ទុះទៅជួយ ឆាប់ ! ឆាប់ ! ។ ពួកយោធាស្តាប់ហើយ គិតថាពិតមែន ។ ស្ទុះតេតៅចោលអស់ដាវលំពែងនូវគ្រឿងអាវុធនានា ។ ព្រះពជកុមាររើសយកគ្រឿងនោះតេតៅ ។ រីសេនាបតី ឃើញយោធាតេមកដូច្នោះ សួរថា ហេតុអ្វីក៏នាំគ្នាតេមកដូច្នេះ ? ។ - មានមាណពម្នាក់ប្រាប់យើងតាំងអស់គ្នាថា លោកកំពុងចំបាប់ទីឯចោរ ។ ទើបសេនាបតី វិលមកកេះគ្រឿងប្រដាប់តុំយើញក៏ប្រាប់គ្នាថា, បុរសពែលៅប្រាប់យើងនោះ

ច្រកតដាៈចារៈហាន៑ ។ ពាលួចរមស់ត្រីឮអស់ទៅហើយ បបួលគ្នាទៅរក
តំពុំយើញចោរ, លុះល្ងាចត្រជាក់ ចូលទៅគាល់ព្រះមហាក្សត្រាធិរាជ
ទូលតាមដំណើរ ។ សម្តេចព្រះមហាក្សត្រាធិរាជ ទ្រង់មានព្រះបន្ទូលថា
តុំមានអ្នកណាអាចចាប់ចោរបានសោះ ម៉ែដូច្នោះ អញនឹងចាប់ខ្លួនឯង
ទើបត្រាស់ដល្លឹងហៅភថ ម្នាលហោភ ! ភត្រីនេះ តើចោរវាទៅទិស
ណា ? ។ ហោភទូលថា យប់នេះវាទៅទិសបស្ចិម ។ កាលនោះ ព្រះ
មហាក្សត្រទ្រង់ព្រះតម្រិះឃើញ១ជាយកលមួយ ទើបហៅស្រីតេស្សា
ម្នាក់មកថ្លែងថា ម៉ៃនាងតេស្សាថ្លៃមាស ! ចូរនាងទៅកុះសាចារៈនោះ
លួងលោមដោយខ្លាំងគុណកុំឲ្យវាចេញពីផ្ទះបាន អញនឹងឲ្យសេនា
យោធាទៅចាប់រកមកចាប់ ។ ស្រីតេស្សា ទទួលព្រះពាជអង្គារហើយ
ទៅរៀបចំផ្ទះ ច្រដាប់ខ្លួនចេញទៅកចោរ លុះឃើញហើយ ក៏នាំមកផ្ទះ
បបួលគ្នាត្រេកអរដោយគាមគុណ តាំងតែបរមយោម រហូតដល់មធ្យម-
យោម លុះទៀបភ្លឺស្រាង ។ ព្រះពាជកុមារនោះ ប្រុងក្រោកចេញទៅ។
នាងតេស្សាឃើញដូច្នោះ ក៏ស្ទុះទៅឱបរឹតឃាត់ថា សូមអ្នកឈប់សិន ។
ព្រះពាជកុមារឆ្លើយថា ម៉ៃនាងតេស្សា ! អញត្រូវលាត្រហាយតុំសប្បាយ
តង់ខ្លួនសោះ ខ្ញុំនឹងទៅដំរះកាយ រួចហើយវិលមកវិញ ថាដូច្នោះក៏
ក្រោកឡើង ។ នាងដើរតាមទៅ ។ កាលបើព្រះពាជកុមារដើរទៅ
ដល់មាត់អណ្តូងហើយ, នាងក៏ទៅដល់ដែរ ។ រួចដងខ្លួនសម្រាប់

យោនិចំកកំជាប់ចំពុះក់ទៅ ដូច្នោះទើបព្រះពជកុមារនិយាយទៅនឹងស្រីពេស្យាថា ម្នែមានាង ! អញតុំមានអ្វីនឹងយោនិចំកឡើយ បើនាងឧស្សាហ៍យកក្នុងសង្រែកខាងដងយោនិនេះ ។ ស្រីពេស្យាក៏ធ្វើតាមបង្គាប់ ។ ព្រះពជកុមារក៏យកលេខ្មាស់ចុងយោនិទាំងមានត់អណ្តូងជាប់ ។ ឯស្រីពេស្យានោះ ដូចជាគេចងឆ្កែតន៏តោង ។ ទៅនឹងដងយោនិ ។ ព្រះពជកុមារក៏ដើរចាត់ទៅ ។ ទើបនាងស្រែកហៅឲ្យអ្នកភូមិជួយ ។ អ្នកភូមិចេញមកកេចោរពុំឃើញសោះ ទើបនាំគ្នាទៅដោះនាងពីដងយោនិនោះ។ ត្រឹកខ្លះ ពួកសេនាគហានដែលចោមរោមមកជួយស្រីពេស្យានោះ រកចោរនិងស្រីពេស្យាពុំឃើញឡើយ បបួលគ្នាលៃទៅវិញ ។ កាលនោះ ស្រីពេស្យា ចូលទៅគាល់សម្តេចព្រះមហាក្សត្រាធិពជ ក្រាបទូលតាមដំណើរ ។ រីព្រះពជាជាន់ជ្រាបដំណើរ ត្រាស់ថា បើអ្នកឯណាពុំអាចចាប់ចោរបាន បើដូច្នោះ មានតែអញចេញទៅចាប់វាម្តងដោយផ្ទាល់ដៃ ត្រាស់ដូច្នោះហើយ ទ្រង់ហៅហោរាមកដល់ក្នុងសួរថា : ម្នាលហោរា យប់នេះតើចោរវាក់ទៅទិសណា ? ។ ហោរាក្រាបទូលថា បពិត្រព្រះសម្មតិទេព ! យប់នេះ ចោរវាក់ទៅគណ្ឌាលទន្លេ ។ សម្តេចព្រះមហាក្សត្រាធិពជទ្រង់ត្រាស់បង្គាប់ហើយក៏ស្ងៀមទៅ, លុះគេសព្វាលាប់ ទ្រង់សោយព្រះក្រយាស្ងោយរួចហើយ គប្រដាប់ព្រះអង្គទ្រង់ព្រះខ័ន លីលាយាត្រាកន្លងក្រឹតែមួយព្រះអង្គឯង ក្រវែលឃ្លាំមើល រីព្រះពជកុមារនោះ កែនំលត់ក្តី

ក្តី ត្រាយនាយដោយផ្លូវថា ម ម ប្អូ រំលងយ្យា ៥ អ្នកតាំង
ឡាយ ចូរទៅញុំខ្ញុំ ។ កាលនោះព្រះពជា ស្តេចឃើញហើយត្រាស
ស្តីថា ហៃចៅមាណព ! ហេតុអ្វីបានជាចៅកែទំលត់តាំងពក្តី ? ។
ទើបព្រះពជកុមារថា ហៃអ្នកដំណើយ ! ខ្ញុំលត់ទំតាំងពក្តីនេះ ស្ងាត់មនុស្ស
តាំងឡាយទៅញុំជាមាសខ្លះ ជាប្រាក់ខ្លះ ដាំចិញ្ចៀនខ្លះ ។ ព្រះពជា
ត្រាស់ថា អញ្ជើជនឯបានឬទេ ? ។ ព្រះពជកុមារទ្វើយថា បើអ្នកដំណើ
ជាមួយនឹងខ្ញុំ បានជា២នាក់ដូច្នេះ មនុស្សតាំងឡាយ គេមិនទៅញុំជាមាស
ជាប្រាក់ឡើយ គេដូរជាស្រូវអង្កាមវិញ ដូច្នេះអ្នកដំកុំទៅឡើយ ។ ភ្លើ
ភ្លើមិនស្លាប់ ម្ចាលមាណព ! ធ្វើម្តេចអញ្ជើនឹងបានទៅផង ។ ទើបព្រះ
ពជកុមារទ្វើយថា បើអ្នកធំចង់ទៅ សូមអ្នកធំចូលក្នុងស្បាងស្បែកនេះ
ចុះ ខ្ញុំវែកទៅ មហាជនគេមិនដឹងជា២នាក់ទេ ហើយគេអាចទៅញុំជា
មាសជាប្រាក់បាន ។ ព្រះពជាទ្រង់ព្រះតម្រិះថា អញ្ជើនឹងទៅលេីមាស
មានមនុស្សទៅញុំមែនឬទេ ? ហើយព្រះអង្គស្តាប់ជាក់ថា បុរសនេះគ្រោ-
កដជាចោរហោង ទើបព្រះអង្គជាប់ព្រះទ័យចូលក្នុងស្បាងនោះ ។ ឯព្រះ
ពជកុមារ លុះព្រះមហាសត្វចូលក្នុងស្បាងហើយ, ក៏គិតថាអ្នកនេះ
មិនមែនពស្តេចឡើយ គិតដូច្នោះហើយ ចងរួបមាត់ស្បាងយ៉ាងណែន
ព្យួរទុកទៅកន្លែងមួយ ហើយវត់ទៅ ។ ឯសម្តេចព្រះមហាសត្វត្រាជពជ
ព្រះអង្គទៅក្នុងស្បាងនោះ លុះដល់ព្រឹកឡើង មហាជនតាំងឡាយ

យើញស្បៀងក្បុរនេះនឹងរបងដូច្នោះ ក៏ទឹកសង្ឃឹថា ស្បៀងនេះប្រាកដជា
ចោរយកមកបង់ក្បុរខុកតុំបានដោះយកទៅ ។ កាលនោះមេស៊ីតួកសេនា
យោធា និយាយគ្នាថា ឥឡូវព្រោះមហាក្សត្រចុត់ទៅហើយ ទើបនាំគ្នា
ចេញទៅកសាងក្រុងស្ថាបនាតាំងតួជំពុំយើញឡើយ យើញតែស្បៀងក្បុរ
នៅនឹងរបង ក៏គិតគ្នាថា ព្រោះមហាក្សត្រប្រហែលជាចោរកំបាញ្ជោតឲ្យ
ចូលក្នុងស្បៀងនេះប្រាកដហោង, ទើបសេនាបតីដើរទៅដឹតសួរថា
ខណោនៅក្នុងស្បៀងនេះ ? ។ ព្រះមហាក្សត្រឆ្លើយថា អញ ។
សេនាបតីដឹងថា ព្រះមហាក្សត្រខ្លួនភិតហើយ ក៏ឲ្យនាំដំរីមក លើក
ស្បៀងជាក់លើខ្នងដំរីនាំចូលទៅកង់ព្រះរាជវាំង ហើយស្រាយស្បៀង
ខោះ ។ ព្រះរាជាបានយល់មុខសេនាបតីហើយ មានព្រះបន្ទូល
ថា ម្នាលអ្នកតាំងខ្លាយ ! ចោរខោះ តក្កុណោ ចេះ នៅ
ក្នុងនៅឡើយ ដំណាក់ថ្ពាល មានរូបទោមល្អ តំ ជាឯសព្វមិ
អញស្គាល់ខ្លួនក់ហើយ មជ្ឈន្តិកសមយេ ក្នុងពេលថ្ងៃត្រង់ អញ
នឹងទៅតាត់ក្បាលកឲ្យបាន លុះមានព្រះបន្ទូលដូច្នោះរួចហើយ ស្តេច
ឡើងទៅលើប្រាសាទដំរើអាសនា; លុះតែនឡើងចេញទៅប្រថាប់នៅ
ព្រះដំណាក់ ត្រាស់ហៅហោរាថា អញនឹងទៅចាំទិសណាទើបប្រទះចោរ?
ហោរាក្រាបបង្គំទូលថា ថ្ងៃនេះ ចោរកំនឹងមកនៅទិសទក្ខិណ ។ ក៏ សុត្តា
ព្រះរាជា លុះជ្រមហើយ លុះលាចុះចាកព្រះរាជវាំង ឡើងប្រថាប់លើ

សេះឆ្ពោះទៅទិសឧត្តរ ដោយជវល់មហាខឺ ទ្រង់បរសេះទៅតាមទាន់ខ្នែ
តំខតឃើញព្រះរាជកុមារនោះ ស្ទុះកន្ត្រៀ ដណ្តប់ខ្នៃ អង្គុយស្ងួចត្រែ
ទើបចុះពីខ្នងសេះទៅតង់ក្រោយខ្នងព្រះរាជកុមារ ។ ឯព្រះរាជកុមារ កាល
បើឃើញព្រះមហាសត្វត្រាតតថា អយំ បុរិសោ បុរសនេះ ប្រាកដជា
បិតាអញហោង ។ កាលនោះ ព្រះមហាសត្វត្រាដ៏រាជ ទ្រង់មានព្រះ
បន្ទូលថា ម្នៃកុមារ ! អ្នកចូរឲ្យសន្ធូចមកអញនឹងស្ងួចលមើល ។ ព្រះរាជ
កុមារ ក៏ថ្វាយសន្ធូចទៅព្រះរាជា ។ ព្រះអង្គស្ងួច, ត្រកំពុំស៊ីសន្ធូចឡើយ ។
ទើបត្រាស់ថា ម្នាលកុមារ ! អញស្ងួចត្រែ ពុំស៊ីសន្ធូចសោះ ។ ព្រះរាជ
កុមារក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ! សូមព្រះអង្គដោះគ្រឿង
ច្រដាប់ចេញពីព្រះអង្គ ហើយទ្រង់ព្រះពស្ត្រខ្មៅនៃទូលព្រះបង្គំវិញ ទើប
ត្រកំស៊ីសន្ធូច ព្រោះព្រះអង្គទ្រង់ធ្វើមអម្ពរដូច្នេះ ត្រកំពុំហ៊ានស៊ីសន្ធូចទេ ។
ឯសម្តេចព្រះមហាសត្វត្រាដ៏រាជ ព្រះអង្គជ្រាបហើយតតថាមែន ទើបដោះ
គ្រឿងច្រដាប់ចេញពីព្រះអង្គ ហើយហុចឲ្យទៅព្រះរាជកុមារនោះ ។ ព្រះ-
រាជកុមារ កំដោះខោ-អាវខ្មៅថ្វាយទៅព្រះមហាសត្វ ។ ព្រះរាជាព្រះអង្គ
ទ្រង់ព្រះពស្ត្រខ្មៅគង់ស្ងួចត្រែ ឯត្រកំស៊ីសន្ធូច ។ កាលនោះ ព្រះរាជ
កុមារទ្រង់ធ្វើមអម្ពរព្រះមហាសត្វត្រា ទ្រង់ព្រះទ័ទ ឡើងគង់លើខ្នងសេះ
ហើយញាក់សេះ ឲ្យចូលទៅក្នុងព្រៃបរមរាជវាំង លុះដល់ហើយ

(នៅមានត)

ផ្នែកអក្សរសាស្ត្រ

រឿងព្រេងនឹងរឿងបុរាណប្រទេសជប៉ុន

លោក ភ័ឃ-ប៊ុក ប្រែរៀបរៀង

រឿងព្រះនាងបែនតែន និងនាគអេណ្ហាស៊ុម៉ា

អេណ្ហាស៊ុម៉ា ជាដីមួយកន្លែង ឯតនៅជិតទីក្រុងយូកូហាម៉ា ជាទីមានទេសភាពគួរចង់ដើរលេងកំសាន្តតាន់ភាក ។ ដីនេះ តាំដើមជាកោះមួយ, តែឥឡូវនេះ ទៅជាជ្រោយមួយ ដោយទឹកសមុទ្រស្រកស្រុតទៅទៅតែផុតឡាច់ ។ បើគេមើលពីចម្ងាយ, អេណ្ហាស៊ុម៉ា ដូចជាសុទ្ធមួយធំកំពុងដេក ប្រមុះវាបែរចំមកដី ។ កោះនោះ មានតណ្ហៅខៀវខ្ចីឯតនៅកណ្តាលសមុទ្រដែលមានតណ្ហៃផ្ទៃមួយ, មានព្រៃស្រោងស្រោងជុះនៅលើកោះ ហើយមានផ្លូវដើងខ្ចាត់ខ្ចាយ ។ នៅទីខ្ពស់ ត្រង់តន្លៃងដែលគួរពិតពិលមើលមើល គេយើញគេហដ្ឋានមានដាំដើមតែជាច្រើន ដែលពួកអ្នកទៅទស្សនាតង្ហិយៈទៅលើកនេះ ក្រឡេកមើលសំអនៃទេសភាពជាប្រសើរភ្ញាំងនោះ ។

នៅលើកោះនោះ មានគោជនាតាវជាច្រើន ដែលមានគោជនាតាប្រសប់ខាងធ្វើម្ហូបអាហារមានឈ្មោះសព្វញ្ញាតិសាប្បែក ។ តីមានលៀសសមុទ្រ ក្តាម ឫស្សីឆ្ងាជាដើម, មានភាណាដ្ឋាន ដែលលក់តែសម្រាប់

លំអជ្រុង ។ ដាំសុទ្ធតែខ្សែ សម្រាប់ជាអនុស្សាវរីយ៍នៃអ្នកធ្វើដំណើរ
ទស្សនា ។

គេមិនអាចទៅអណ្តូស៊ុមាំ ហើយចៀសវាងមិនទៅគោរពព្រះនាង
ទេវតីតាបែនតែន ដែលបិតានៅក្នុងគុហាមួយជាប្រជន័យដ្ឋាននោះទេ ។

ក្នុងចំណោមអាទិទេព៧ អង្គ, ព្រះនាងបែនតែនជាទេវតីតាមួយ
អង្គ, ឯអាទិទេព៦ អង្គក្រៅពីនេះ ជាបុរស ។

ហេតុដូចម្តេច ទើបជាតួតាទេសចរតាមគោរអណ្តូស៊ុមាំ ទើប
សំដែងកតញ្ញូតាធម៌ចំពោះព្រះនាងបែនតែន ? ។

កាលពីសតវត្សរ៍ ទី ១៩ គោរនេះមិនទាន់ផុសចេញពីទឹកសមុទ្រទេ
មានតែគុហាមួយដែលទឹកសមុទ្រមិនដុំជុំវិញ ។ ទៅទីនេះ មានរូងខាត
មួយដែលមានខាតតាចសាហាវគ្មុះឱ្យស្រមៃស្រមើអាស្រ័យទៅ ។ នាត
នោះមានរូបចំសម្លឹមអស្ចារ្យ ប៉ុន្តែប្រសប់ តំងវែលទឹក តំងលូនក៏
លឿនផង មានមាត់ធំ ប្រកបដោយធ្មេញស្រួចជាច្រើន ហើយពេញ
ចិត្តខាងស៊ីកូនក្មេងណាស់ ។ នាតនោះ តែងវែលតាមមាត់សមុទ្រ
កាលណាឃើញកូនក្មេងចុះទៅអុជទឹក ឬត្រៀលតាមមាត់សមុទ្រ វា
វែលទៅចាប់ពាក្យកូនក្មេងនោះមកត្រជាក់ស៊ីតែម្តង ។

ម្ល៉ោះហើយ នៅតាមភូមិនោះ មានតែមនុស្សតាន់តូចដោយ
ជាត់ក្មេង មានតែមាតាយំខ្លួញ . បិតាស្រែកសង្រ្តែងដោយជាត់កូន.

ហើយតែងមានមុខសួរគ្នាយ៉ាងនេះ ចំពោះកូនក្មេងឯទៀត ដែលត្រូវជាចំណែកនៃពស់នាគពាន់នេះ ទៅអនាគត ។

ព្រះទាន់ឆែងតែង ទ្រង់មានព្រះពុទ្ធចំណង់ចង់ប្រាប់ទូរស្តេបត្តិក្តីភ្ញាក់ផ្អើលនៃប្រជាពលរដ្ឋក្នុងភូមិនោះ ទ្រង់ជាទេវតានៃសុភមង្គល ទ្រង់មានព្រះបំណងចង់ឲ្យសត្វទាំងអស់បានសុខស្រួលគ្រប់ៗគ្នា, អំពើនេះមិនត្រឹមតែអ្នកសូត្រត្រង់ទេ សូម្បីអ្នកកាចសាហាវដូចយ៉ាងពស់នាគពាន់ដែលស៊ីសាច់មនុស្ស ក៏ព្រះទាន់មានព្រះបំណងដូច្នោះដែរ ។

ថ្ងៃមួយ នៅលើភ្នំហាដែលពស់នាគពាន់នោះស្ថិតនៅ មានភាពអណ្តែតត្រសែតពីលើ, ព្រះទាន់ទ្រង់គន់គាំនៅលើពពកមួយដុំ ហើយទន្ទ្រេរិះរកដែលមានទ្រង់ព្រួយមួលក្តុំ មានព្រះនេត្រគួចល្អ មានព្រះទស្សគួច ផ្ទៀងសង្ឃឹងចាញ់ទៅលើ ។

ភាមធន្ធូនៃព្រះទាន់ទេវធីតា ដ៏ឯកម្រើកខ្លាំង, គុហានៃពស់នាគពាន់ផុសចេញភ្លឺចិចសមុទ្រ ។ នៅជុំវិញគុហានោះ មានដីតំបូជុំវិញមានព្រៃឈើដុះស្រោងស្រោង ខេះតឹងតោរអណ្តូស៊ីមា៉ ដែលផុសចេញពីរឹងសមុទ្រ ។

ពស់នាគពាន់ស្ថិតនៅចំពីមុខគុហា ចាន់ខស្សនាដោយចាប់អារម្មណ៍យ៉ាងអស្ចារ្យ ខ្លះដោតុដែលគួរឲ្យស្រប់ស្រួល ។

ព្រះទាន់ទ្រង់មានព្រះតន្ត្រីស្រស់ញាញឹម យាងទៅកាន់គុហាមាន

ព្រះសង្ខ័យទៅកាន់ពស់នាគរាជនោះថា «អ្នកឯងនិស្ចិតនៅក្នុងទីនេះតែម្នាក់ឯងមិនអផ្សុកទេឬ ? គ្មានដើរសេពគួរណាមួយ រស់នៅដោយឥតមានសេចក្តីស្នេហានោះទេ ! តើអ្នកឯងចង់ធ្វើសមរសជាមួយនឹងខ្ញុំឬ? យើងនឹងរស់នៅសុខសប្បាយជាមួយគ្នា បើយើងមានកូន អ្នកឯងមុខជាស្រឡាញ់កូននោះក្រៃលែង . . . អ្នកឯងលែងអញ្ជើញទៅបរិភោគសាច់កូនក្មេងទៀតហើយ ។

ពស់នាគរាជឮហើយ ក៏ព្រមធ្វើសមរសជាមួយព្រះនាងវែនតែនតាំងតាំងថ្ងៃនោះមក ដើរតាមអ្នកតាំងពីបានបិតនៅសុខសប្បាយ ដូចព្រះនាងវែនតែនមានព្រះសង្ខ័យទៅកាន់ពស់នាគរាជដូច្នោះ ។

តាំងតាំនោះមក ជនជាតិដប៉ុនតែងតែរាប់ជាព្រះនាងវែនតែនជាន់ខ្ពស់ព្រោះយល់ថា ព្រះនាងមានព្រះរាជបិតាយ៉ាងប្រសើរដោយសេចក្តីករុណាប្រទានឲ្យវាសេចក្តីសុខសប្បាយដល់ប្រជារាស្ត្រតាំងប្រុសតាំងស្រីនៅទីនោះ ។

រឿងព្រះនាងវែនតែន នឹងពស់នាគរាជចប់តែប៉ុណ្ណោះ ។

រឿងដែលបានតណិនាមកហើយនេះ រឿងស្តាបនាតិតរាលាក ១, រឿងចុះទៅហាននរក ១, រឿងព្រះនាងសុវិយាទេវីទ្រង់ព្រះតាំរោង ១, រឿងអាទិទេពសុសាណូ នឹងពស់នាគរាជក្បាលច្រាំបី ១ រឿងអ្នកនេសាទអ៊ីសូរីមាំតារ៉ូ ១ រឿងព្រះនាងវែនតែន នឹងពស់នាគរាជអេណូស៊ីមាំ ១;

រឿងតាំង ៦[១] នេះ តីម្នាក់ទៀតបានដកស្រង់យកពីសាសនាស៊ីនតូ ។

អ្វីជាសាសនាស៊ីនតូ ?

សាសនាស៊ីនតូ បើតាមនៃសួរជនជាតិដទៃថាជាការគោរពជីដូនដូតា ឬ ថាជាតិធម្មានុះបម្រើបច្រែនបែបច្រែនយ៉ាង សម្រាប់តែការពេលថាជីដូនជីតាដែលធ្វើមរណកាលទៅហើយ ។

ចំពោះការឲ្យន័យខាងលើ សាសនាស៊ីនតូជាសាសនានៃប្រជាជាតិឬថាជាលទ្ធិនិយម ដូចអ្នកទស្សនវិទូម្នាក់បានពោលថា ៖

"មនុស្សនៃមិមានអ្នកស្លាប់ ត្រូវជាងអ្នកនៅរស់"

ព្រោះហេតុដូច្នេះ ប្រជាជាតិដែលមានចំណងចង់រក្សាទុកនូវឯកភាពរបស់ខ្លួន នឹងត្រូវរស់នៅជាសម្ព័ន្ធភាពជានិច្ចនិរន្តរ៍ ជាមួយនឹងមនុស្សពីអតីតកាលដែលបានជួយចលនាឲ្យមានប្រវត្តិបានថ្កុំថ្កើងរុងរឿង ។

តែបើតាមតិនិត្យឲ្យជាក់លាក់ទៅ សាសនាស៊ីនតូ មិនមែនត្រឹមតែការគោរពបូជាជីដូនជីតាប៉ុណ្ណោះទេ គឺជាលទ្ធិភាពកំពាំងមួយ លំបាកនឹងយល់តាំងពីដើម ដែលកម្ចាត់ជាតិបញ្ចូលបូកាយជាអាទិទេព ហើយបញ្ជាក់ថា មានពង្សាវតារពីបុរាណកាលមក ដែលស្ថាបនាឲ្យសត្វតិរច្ឆាន

---

១ រឿងទី១ ដល់ទី ៥ ក្នុងសាសនបណ្ឌិតបានចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយាក្នុងឆ្នាំ ១៩៥៨ រួចហើយ ។

មួយ ជាអ្នកបង្កើតជនជាតិជប៉ុនតមកទៀត ។ ចំពោះទេវតានៃសាសនាសិន្តូដែលមានជាច្រើនហ្មឺនរូប គេបានយើញទេវធីតាព្រះធរណី ១ សុរិយាទេវី ១ ជាដើម ។ តីព្រះនាងសុរិយាទេវីនេះឯង ដែលជាបុព្វហេតុឲ្យស្ថាបនាទូព្រះពជសន្ដតំរង់ "មិកាដូ" ដែលតំណែងសុទ្ធតែព្រះពជជនីសោយពជសម្បត្តិនៅប្រទេសជប៉ុន ។

នៅមានការគោរពសត្វតំរាច្នៃដូចជា សេះ ស្ពារ ខ្លែ កណ្ដុរ មាន់គក ដែលជាគេតនតណ្ដាំនៃទេវតានីដែរទេវធីតានៃសាសនាសិន្តូ ។ ក្រៅពីនេះនៅមានការគោរពរុក្ខជាតិ តាសាជប៉ុនហៅថា "តូរេអ៊ី" ជាច្បាប់ចងនៃព្រះសង្ឃសិន្តូ តីជំហរដែលមានចុងមានរំយោលក្រដាសជាច្រើន ។ រំយោលក្រដាសនេះ គំហៅថា "តូរេអ៊ី" ខ្លះហៅថា "សាតាន៏" ដែលដុះនៅពីលើខ្នងភ្នំតុហានៃព្រះនាងអមាតេរ៉ាស៊ូ ។

ពាក្យថា សិង្គបានសេចក្ដីដូចម្ដេច ?

បើតាមភាសាចិន ពាក្យថា សិន ឬ ស៊ិន ប្រែថា ខ្មោច វិញ្ញាណក្ខន្ធ ផលញាណនៃខន្ធ ពលភាពធម្មជាតិ ។ ពាក្យថាតូ ឬ តាវ ប្រែថា ផ្លូវ មគ្គ លទ្ធិ ព្រោះហេតុនោះ សិន្តូ ឬស៊ិនតាវ ប្រែថា ផ្លូវទៅកាន់ទេវតា ឬផ្លូវទៅកាន់ស្ថានសួគ៌ ។

បើតាមប្រវត្តិនៃសាសនាសិន្តូបានសង្កេតថា សាសនាសិន្តូនឹង

ព្រះពុទ្ធសាសនាមានបញ្ហាស័ីលដូចគ្នា តែតែមានសភាពទុស្សន្ទស្រឡះជាច្រើនកន្លែង ។

បញ្ហាសីលនៃកាមី ឬសាសនាស័ិងតូនោះគឺ:

១-បើកាលណាគេចង់គោរពកាមី (ដាវៀតប្រទេសជប៉ុន គឺជាព្រះមហាក្សត្រវ័ណ ឬ វ៉ាដេ ដែលបានរស់នៅក្នុងប្រទេសជប៉ុនពីអតីតកាល) គេត្រូវតែមិនបរិភោគសាច់គោ សាច់ជ្រូក សាច់សត្វសាហាវដូចជាសិង្ហ ខ្លាជាដើម ។

២-ស្ត្រីមិនត្រូវអនុញ្ញាតឱ្យបង្ហាញកន្ត្រាំចំពោះកាមី ក្នុងពេលដែលខ្លួនត្បាយមធ្លើសេចក្តីបរិសុទ្ធិខាងកាយ វាចា ចិត្ត, នាំត្រូវតែមិនឱ្យនិយ្រាប្តូបរិភោគអាហារជាមួយស្វាមី, ម្ហូបអាហារត្រូវយកទៅចំអិនទៅដើងក្រោនតំសេស មិនត្រូវយកទៅចំអិនទៅដើងក្រោន ដែលសម្រាប់ចំអិនម្ហូបអាហារស្វាមីឬញ្ញាតិសន្តានរបស់ខាងដាច់ខាត, ខាងត្រូវមិញ្រាទីងបរិភោគអាហារទៅគេហដ្ឋានមួយដោយឡែក ពាលតែសេចក្តីបរិសុទ្ធិបានសម្រេចជាអវសាន ។ នេះជាការតឹងរ៉ឹង ជាការចាំបាច់ ត្រូវតែស្រុំបំពេញទៅថ្ងៃដែលធ្វើខ្លួនឱ្យបរិសុទ្ធស្អាត ចៀសវាងមិនបានសោះឡើយ, ព្រោះថា ថ្ងៃនេះគេចុកជាថ្ងៃមិនបរិសុទ្ធនៃជីវភាព ជាថ្ងៃដែលពួកកាមីមិនពេញចិត្ត ។

- ៣-កាលណាស្រីប្រសូតកូន ត្រូវធ្វើត្រណមដូចខាងលើតាលតែដល់កំណត់នៃការធ្វើសេចក្តីបរិសុទ្ធស្អាតជ្រះស្រឡះ ទើបចេញពីត្រណមនេះបាន ។

៤-ប៉ៃពិតា បុត្រា ប្តីភ្ញាតិសន្តានៃបុគ្គលណាខូលអនិច្ចកម្មបុគ្គលដែលកាន់ទុកនោះ មិនត្រូវមកជប់ភ្ញាក្ខួនចំពោះមុខកាម ឬមហាមន្ត្រី ដែលខ្លួនមៅក្រោមអំណាចអស់រយៈវេលា ៤០ថ្ងៃ ។

៥-បើមានអ្នកណាប្រមាថមើលងាយខ្លួន ឬគ្រាន់តែមានបំណងចង់ប្រមាថខ្លួន, ខ្លួនត្រូវតាន់លោភកាម ហើយសូមអនុញ្ញាតសម្លាប់ឬធ្វើទណ្ឌកម្ម អ្នកដែលប្រមាថ ឬបំណងនឹងប្រមាថនោះ ។

បញ្ជីសីលនេះ មានសភាពខុសស្រឡះពីបញ្ជីសីលនៃព្រះពុទ្ធសាសនា ។

បញ្ជីសីលនៃព្រះពុទ្ធសាសនាមានដូចតទៅនេះ

១-វៀរចាកមិនសម្លាប់សត្វដោយខ្លួនឯង ឬប្រើគេឲ្យសម្លាប់ ។

២-វៀរចាកមិនលួចយកទ្រព្យសម្បត្តិអ្នកដទៃ ដែលគេមិនបានឲ្យដោយកាយឬដោយវាចា ។

៣-វៀរចាកមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

៤- រឿងចាក់មិនសោលពាក្យកុហក ។

៥ រឿងចាក់មិនសេតសុកនិដ្ឋមេរ័យ ។

លទ្ធិសិង្ហឡនិងព្រះពុទ្ធសាសនា តែតមែនតែមានសំគាល់ខុសគ្នា, ប៉ុន្តែ ក្នុងសតវត្សរ៍ទី ៩ មានបណ្ដិតភាងសាសនាសិង្ហឡម្នាក់នាម ជិនស៊ូ-អូដៃស៊ុ និងគូប៊ូដៃស៊ុ បានប្រមូលបង្កើតឱ្យទៅជាសាសនាតែមួយ ហៅថា "សណ្ឋាសិង្ហឡ ឬយ៉ូបូសិង្ហឡ", ទៅតាមនៃសាសនាថ្មីពីរទៅជាអរិយសច្ចៈ ។

នៅក្នុងព្រះវិហារសិង្ហឡនិងវត្តព្រះពុទ្ធសាសនា លោកគាមិនីនិងព្រះសង្ឃព្រះពុទ្ធសាសនា ចេញចូលបានតាមចិត្តដូចគ្នាឥតប្រកាន់ ។

លុះដល់សតវត្សរ៍ទី ១៨ មានការចាប់កំណើតឡើងជាថ្មីនូវសាសនាសិង្ហឡដ៏បរិសុទ្ធដោយអំណាចពួកជាតិនិយម និងអ្នកស្នេហាមាតុប្រទេស ដែលនាំឱ្យកើតការបដិវត្តន៍ក្នុងឆ្នាំ ១៨៦៨ ។ ក្នុងពេលនោះ សន្តតិវង្សមិគាដូ ក៏បានទទួលឡើងនៅប្រទេសជប៉ុន, ដោះបង់ចោលព្រះពុទ្ធសាសនា យកសាសនាសិង្ហឡជាសាសនារបស់ជ្រុង ។ ការបដិវត្តន៍នេះ បានយកសាសនាសិង្ហឡពីបុកណា និងសម័យបច្ចុប្បន្នមកចម្រាញ់បញ្ចូលគ្នា ។

អ្វីហៅថាកាមី ?

កាមីគឺជាទេវតានៃប្រទេសជប៉ុន, ទេវតាទាំងអស់មាន ៧ រូប មាន ទេវតា កុនិ-កូតូ-តាជី ជាដើម ទើបទេវតា អ៊ីសាណាគី ទើបអ៊ីសាណាមី ជាដើមដូនដីតានៃជាតិជប៉ុនជាខាងចុង ។

ទេវតាទាំងពីរ យើងបានពណ៌នាក្នុងរឿង "ចុះទៅស្ថានខេត ទើបរឿងស្តេចនាគិតពាលោក" រួចហើយ ។ ទៅខែនេះ យើងសូមពណ៌នាដោយសង្ខេប ។ ក្រោយដែលព្រះនាង អម៉ាតេរ៉ាស៊ូ មានជំងឺតូចមនស្សទើបព្រះរៀមស៊ូសាណូ គំបូលទៅលាក់ខ្លួនក្នុងអាគារទៅក្នុងគុហា ដោយទប់ទាយនៃទេវតាឯទៀត គំទ្រង់បានចេញពីគុហាមក, ទេវតាស៊ូសាណូគំបានទៅជួយសង្គ្រោះនាងកញ្ញាឱ្យរួចពីទំណាស់នាគពស ។ តាមរយៈទេវតាស៊ូសាណូទើបនាងកញ្ញា គំបានដឹងនូវទេវតា អូណាមូស៊ូ ជាស្តេចគ្រាញ់សោយរាជ្យនៅទន្លេអ៊ីដស៊ូម៉ូ ។

គេលនោះ ទេវីសកាបានដំទុំសម្រេចថា រាជសម្បត្តិនៃប្រទេសជប៉ុនត្រូវថ្វាយទៅព្រះរាជនត្តា (ចៅ) នៃព្រះនាង អម៉ាតេរ៉ាស៊ូ ជាទេវតាខាងព្រះអាទិត្យមានន័យថា ទិទីតី ។ ទិទីតីនេះ ជាដូនព្រះបានព្រះរាជតានូវនៃតិ ពិសិដ្ឋចំយ៉ាងតិះ សិលាពិសិដ្ឋ ១ ព្រះខន័កផ្យ ១ កញ្ចក់ ១, ដោយមានទេវតា អាមីណូកូយ៉ាន ជាអ្នកដង្ហែចុះពីមហាមេឃមកប្រគល់ស្តេចនៅ

កំពូលភ្នំ តាកាដ៊ីហ្វូ នៅដីតវ៉ីក្រុង ហ៊ាយូតា មកសោយពដសម្បត្តិកន្លង
ប្រទេសជប៉ុន, ទ្រង់ឆ្លៀតធ្វើព្រះពដសមរសទឹងនាងតញ្ញាមួយរួម នៅវ
ក្រុងសាត់ស៊ូម៉ា ។

ព្រះពដនត្តោនៃព្រះភ្លេងនីវ៉ីតីទ្រង់ព្រះនាម ភីម៉ីតេណ្ណូ ទ្រង់ភ្លេង
ចេញពីទីក្រុងសាត់ស៊ូម៉ា ធ្វើព្រះពដដំណើរទៅតាន់ទាងដើនប្រទេស ភ្លេង
ស្តាបទាព្រះពដអាណាចក្រមួយ ដែលមានពដជាន៉ៃនៅវ៉ីក្រុង យ៉ាម៉ាគូ ។
ព្រះពដនត្តោនៃព្រះភ្លេងនីតីនេះ ជាព្រះពុទ្ធពដប្រទេសជប៉ុនដាបឋម
សោយពដសម្បត្តិ ពីឆ្នាំ ៩៨៩ ទៅ ១៦០ឆ្នាំ មុនគ្រិស្តសកពដ ។

រឿងមរណមាតា

លោក ប៉ី-សុវណ្ណ បកប្រែពីសាស្ត្រាស្ក្រឹតជាខ្មែរ

បឋមោភាគត

ឯវមាមិហំ អតិវិទ្ធំ សុសម្ភន្ទោ លោកនាថ
វរញ្ញោណោ ញាណុត្តមោ តមត្ថុទ្ធំ ។ ឯមក្ខារធម្ម
ក្ខុណាតិយុត្តា យថាធិបំ ធនោលោក វិយយានំ
សុគន្ធីវំ វិយនាថ ។ ឯមក្ខារំ សង្ឃក្ខុណាំ សន្តិន្ទ្រិយា
អនុត្តរំ ខេត្តំជនា លោកបុញ្ញា សនាសោត្តំ ។
ខ្ញុំលុតលើកករ តំបន់ខនអ ខនអញ្ជលិ ខមក្តាក តាយា
វិន្ទិ បង្គិជនស្រែ ខនោថតតា ។ ព្រះអង្គជាមកុដ ក្រែតព
បំផុត ផ្លាលផ្លាញ់មាព ជាតំបង្ខូបង្ខាច អំណាចមហិមា ទ្រង់
ត្រាស់ធម្ម ព្រោសប្រាណសត្វសត្វ ។ វិចិវិត្ត សត្វពៅ ទឹក
គុណពុទ្ធក្តែ មនោវិត្ត ចិត្តាតិតក្តាត់ តោរតប្រណិប័តន៍ ប្រ-
ណមវិត្ត ។ រំលឹកព្រះគុណ ព្រះត្រាស់ពីមុន អមរាលទ្ធ៍ត-
សុធា បួនសម្បុទ្ធំ ហើយខ្ញុំវិត្ត ទឹកគុណពុទ្ធ ក្នុងបច្ចុប្បន្ន ។
កាលបានត្រាស់ត្រាច់ ព្រោជ្ញាសត៌ដ្ឋ ព្រោសសត្វអនន្ត អនេក
សង្ខ្យា ដែលជាបុថុជ្ជន សឹងលុះបានបុណ្យ អរហន្តសោតា ។

បង្គំពង្សពុទ្ធ ឯអនាគត សាធីជាមែន ទីឆត្រាស់ឯកែក អនេកសង្ខ្យេយ្យ ហើយខ្ញុំម្ចាស ព្រះធម៌បវរមត្ត ។ ក្រុំប៉ម៉ឺនបួន ពាន់ពេញធារបួន ជាយោន តាំសត្វ ដូចការកេត្រា សុរិណ្ណាយន្តែ ចេកជាន្តធ្នង់គាត់ រំដួសង្ឃរាក ។ បង្គំសង្ឃសុទ្ធ សាធីសីលស្រគត់ សង្រ្គមកាយា ជាស្រែបុណ្យជាន តាំក្រាណលោកា ជាក់ដល់ថ្នល់មហា អម្រឹតនិព្វាន ។ ដោយតេជៈខ្ញុំ ជាន់ថ្វាយបង្គំ រៃត្រែត្តេជ្ញីធ្លាន ប្រកបដោយអង្គ បញ្ចង្គប្រតិស្ឋាន ប្រសើរសូមមាន មង្គលសួស្តី ។ សូមឈ្នះខ្មក់ក័យ ។បច្រូតចង្រៃ អន្តរាយ អប្រិយ សូមឈ្នះលោកោ គោសោតីយ៍ មោហាកុំប៉ មានមកដល់ជិត ។ បង្គំគុណគ្រូ គុណតាប់តំរូវ្យ(១) ប្រដៅប្រៀនប្រែត ប្រៀបប្រើ ក្រាជ្រាយ សុះសាយប្រសិទ្ធិ ធម៌តាចំបួលចិត្ត ចាកជាបនានា ។ ហេតុនោះខ្ញុំនឹក ព្រះគុណល្ងាចព្រឹក សត្វទិនទិវ៉ា នឹកគុណប្រធាន មែនមានកុំណា មាតាបិតា ឪធីមានគុណតាប់ ។ គុណមហាក្សត្រា នោះខ្ញុំពណិនា សរសើរឈៀងចាប់ គុណញាតិសន្តាន ត្រៀងលានគួរតាប់ មានគុណតំនាប់ ធ្ងន់ក្រៃមថាមា ។ កាលក្នេរ៍សេចក្តី លោកត្រៃតាបី ចិញ្ចឹមរក្សា ចំណីចំណុក បញ្ចុកកោក្តា ថែទាំរក្សា លាងមូត្រលាងលាមក ។ ឈឺថ្កាត់កាលណា លោកមើលរក្សា ត្រួយក្រាណកើតខ្មុក អត់ពាំនឹកគោជនា កោក្តាពុំសុខ អង្គុយមើលមុខ មើលមិនឃ្លាតឃ្លា ។ ព្រះគុណធ្ងន់ក្រៃ ធ្ងន់ក្រកក្រៃ កម្រៃបមា ធ្ងន់ក្រៃធារធំ ទើបខ្ញុំពណិ-

---

១ គុណសព្ទភាសាទេសនៈ ប្រែថា ដែលធំខ្លាយ ។ អានថា តំរូ ។

ទា សរសើរសូត្រសា សូត្រសព្វល្ងាចព្រឹក ។ ព្រះគុណច្រាំបី ប្រ-
ការពិសី ពិសេសអធិក មានាវាចា ចិន្តាខ្ញុំទឹក ខ្ញុំគិតរលើក មិនលោះ
ទំាង ។ ពុទ្ធសាសនំ ខ្មែរសហស្សំ ចតុស្សតា - ធិតាទាវី - សតវស្សា
មាសឯកា អតិក្កន្តំ ។ អដ្ឋរសេ ទិនភាវេ សុក្របញ្ចំ សុក្កបក្ខេ អា-
សាឡ្ហមាសំ តិម្ហឡាទុំ ចទសិកា ។ បច្ចុប្បន្នំ អនាគតំ គតកាលា
ខ្មែរសហស្ស បញ្ចសតា សំវច្ឆរា សត្តតិនព្វំ ។ ឯតាទរេសា មាសទិ-
នោ ទសទិនំ ពុទ្ធសាសនា អវិរេសសំ បរិបុណ្ណំ តវស្សន្តា ។
អហំនាម ខាមេឥន្ទ- បញ្ញាតិកា មនោរមំ ចិត្តកព្យា សោម-
នស្សា ជាទិច្ចទិនន្តរំ ។ គិតតែឆកាព្យា កាលពុទ្ធសាសនា កន្ទដ៏ត
ពាន់ ប្លុនរយម្ភៃ(១) ឆ្នាំខែខាន់ ជានមួយខែស្បាន់ ថ្ងៃកន្ទឆត្រូវ ។
ជានច្រាំបីដន់-ដប់បច្ចុប្បន្ន ប្លូសក្នុងឆ្នាំឆ្លូវ ខែអាសាឡ្ហមុន គិម្ហន្តរដូវ
លើកខែនោះគូវ អាសាឡ្ហពីរដង ។ ក្នុងថ្ងៃ៩កើត កបកាលឯខ្ចិត
ថ្ងៃសុក្រសោតៈហាង សាសនាចាំងខាន់ ពុំខាន់កន្ទឆ ពីរពាន់ប្លាយឆង
ច្រាំរយសែស្បា ។ ជិតសឹបច្រាំប្លុន ឯខែខានឆ្លួន ដប់មួយមាសា ថ្ងៃ
ខាន់ដប់ថ្ងៃ គិតតែគណនា ឆ្នាំគ្នាត្រូវជា វស្សាច្រាំពាន់ ។ មហា-
សកពជគ្រប់ ឯកសប្តន្តព្វន្តព្វ(២) កំណាត់កំណាន់ ចុលសកពជ ឯងគាច
គ្រប់គ្រាន់ ឯកាទ(៣)ដកស្បាន់ ត្រឹនព្វគណនា ។ រីដើមនាមនោះ

១- ក. ស. ២៤២០ ។ ២- ម. ស. ១៧៩៩ ។ ៣- ប. ស. ១២៣៩ ។

ឈ្មោះអ៊ុកចំពោះ(១) មាតាបិតា សន្ធតនាមទ្វ័ តាមដោយរមេត្តា លុះ
ជន់ជន្មា បានតីរដណ្តប់ ។ ឆ្នើកាមេន្ទ្រិល ប្រសើរនិមិល កោរសក់
គ្រាន់ត្រប់ នាំមកបួសរៀន ប្រែតប្រឿនលុះចប់ ជួបចូលតម្រប់ ម្ភៃពីរ
វស្សា ។ បានទបសម្ព័ទ លោកគ្រូតិតកាត់ តិតគួរនាមា ឲ្យត្រូវដោយ
ខ្លាត មានយោកតិយោ ឥន្ទបញ្ញា(២) តិក្ខប្រពៃ ។ សំណាក់សាសនា
ជួបចូលវស្សា តំរេម្ភៃ ប្លាយពីរវស្សា ចិន្តាតិតតៃ តិតរលឹកដោយន័យ
ដោយទូវតាថា ។ ក្រែនខ្ញុំលើកលោះ ពាក្យតុំចំពោះ ទានខុសត្រង់ណា
សូមលោកដ៏មាន ភ្លាយរឿាណប្រាជ្ញា មេត្តាករុណា តម្រង់ឲ្យផង ។
កុំលោកតិះដៀល គួសគៀងដំខៀល កុំសើចឡើយមោង ដ្បិតទើប
រៀនរិះ ត្រែកត្រិះដូច្នឹង ដៃលកលើកម្ខង ពាបតិចប្រាជ្ញា ។ ត្រោះ
ដ្បិតចិត្តចង់ យកអាទិសង្ឃ ទើបខំចម្បាច់ ជាគ្រឹះកំណាន់ ប្រាំពាន់
វស្សា ក្នុងព្រះសាសនា សម្តេចជិនស្រី ។ ទីដ៏ពណិនាទិ- ពានកន្ទ
តម្ពីរ សារសេភូបាលី ឈ្មោះចេតនា- ពុទ្ធសេចក្តី សម្តេចជិនស្រី
ត្រាស់ទ្រង់ទេសនា ។

១-២ លោកអ្នកនិពន្ធរឿងនេះ ដាក់ពុទ្ធនាមតាមដើមឈ្មោះ អ៊ុក តាមដាយោ ឥន្ទបញ្ញា បួស
ពាន ២២ វស្សា ។

ថ្ងៃនិពាក្យត្រី ព្រះនាមនាងស្រី មរណមាត នាងសាងជាទី
ជនទីតតាំ សពេជ្ឈសាស្តា ចមរថៅលោកនាថ ។ កាលនាងរង្គាត់
អន្លាលកន្លងវង្ស សង្ឃរយកជាតិ មានតម្កុលកណ តាមត្រូណាពុំឃ្លាត
កើតកុកកន្លងជាតិ នោះគួរអនិច្ច ។ ថ្ងៃជនសែងស្តាច់ យកពុកជាចម្បាច់
ខ្លួនអាត្ម តិតកើតកម្មពៀរ វេរវៀរបាណា គួរតិតអនិច្ច សម្តេចក្សត្រីរ
នាងមានបាបជូន បាបត្រាស់តេកពន់ តេកពុំប្រណី នាងយកជាតិជា
កូនមហាសេដ្ឋី នោះនាងតាលី សម្លាប់មាត ។ ឯអគ្គក្សត្រី នោះនាង
តាលី តាចកំនហិង្សា ស្មោះធំនប្រែងក្តៅ នាងសៅវេទនា លុះស្លាប់
ជន្ម ដោយតៀរបុកណ ។ ហេតុនេះសម្តេច សាស្តាសពេជ្ឈ
សម្ពោធញ្ញាណ សំដែងជាតក តទុកឲ្យបាន ស្តាប់ហើយឲ្យមាន
សង្វេគអនិច្ច ។ តាលត្រះត្រទំញ្ញាណ ស្តេចគង់សម្រាន្ត ទៅ
ត្រះវិហារ នាមឈ្មោះវេឡុវ័ន សោភ័ណជាតិជា ទីមៀបនគរ
ពជត្រឹះបូរី ។ ស្តេចតែងបិណ្ឌបាត ត្រាស់សត្វសង្ឃាត សព្វថ្ងៃប្រក្រតី
តែងទេសន៍ខ្លួនាន ត្រាស់ត្រាណាប្រុសស្រី សព្វទិនភត្រ ឆុំលោះទំវ ។
មានតាលមួយថ្ងៃ មហាថេរប្រពៃ ត្រទំត្រះនាម ឈ្មោះអនុរុទ្ធ
វិសុទ្ធបញ្ញា លោកចូលសមា- បត្តិបានសុខុម ។ ទៅតន្លឹតុហា ឈ្មោះ
នន្ទមូលា បពិតជេនឹង លុះចេញសមា- បត្តិជាសុខុម ហើយត្រះអគ្គ-
ពីនដោយទិព្វញ្ញាណ ។ មៀនមើលកំណើត សព្វសត្វតាលកើត

ក្នុងសង្ឃាស្ថាន ខ្លះសោតឮត ស្រែចស្រែតឡើងជាន សូតិសុខចាក
ស្ថាន ជាតិជាមនុស្ស ។ ខ្លះសោតំលាន រំលងខន្ធាន ជាមនុស្ស
លោក អន្លោសជាតិទៅ ស្ថិតនៅចតុក- ជាយជាបវេទា ជាទុក្ខពេក
ពន់ ។ ចាប់ប្រដិសន្ធិ ជាមនុស្សប្រុសស្រី ពស់ប្រែជាតិជន យល់
ថ្នូរពីគ្នា ហាក់មហាទ្រល់លន់ មហាវេរគេយគន់ ហើយតិតសង្ឃឹយ ។
ជាប្រុសត្វសត្វ តាំងតួនខៀងខាត់ ថេរបិតសត្វថ្លៃ ហើយតុំខៀងវិញ
នុតញ្ញូទ្រល់ក្រៃ ព្រះមហាថេរថ្លៃ ព្រួយទ្រនំចន្ទា ។ រីតក្តដ្ឋញ្ញោះ ហើយ
ទើបក្រោកដោះ ឡើងចាកអាសនា លីលាទៅស្រេច ជ្រះអង្គអាត្ម
ប្តេចរលីលា ឆ្ពោះទៅវេឡុវ័ន ។ លុះដល់មត់ចាន ទូនអង្គអតិវាន
ព្រះមកុដសោភ័ណ ហើយមកអង្គុយ តន់ដោយខៃត្រចំណូ តំណាត់
តំណាន់ រួចចាកគោសា ។ ច្រាំមួយបទថ្លែក ពុំខ្ពស់ពេកពុំជិត
សោះសា ពុំឆ្ងាយលន់លាក លង់ចាកអាសនា ពុំក្រោយរុញរា ពុំចំ
ត័ក្តត្រង់(១) ។ ថ្វាយវន្ទនា ស្រែចហើយទូលថា បពិត្រព្រះអង្គ
អម្ចាស់ខ្ញុំលក្ខណ៍ ដួងត័ក្តវេរវែង ក្រាបទូលសូមទ្រង់ ប្រោសប្រាណ

១- ទំនៀមការអង្គុយចាស់ព្រះពុទ្ធ ត្រូវឲ្យរួចចាកទោស ៦បទ គឺ ១ មិនខ្ពស់ពេក, ២-មិន
ទាបពេក, ៣- មិនជិតពេក, ៤-មិនឆ្ងាយពេក, ៥-មិនក្រោយពេក, ៦មិនចំព្រះភ័ក្ត្រពេក ។

ករុណា ។ ខ្ញុំទូលព្រះគុណ ធួលទឹងមហាដន ប្អែកផ្សែងពីគ្នា ខ្វះកេតមកមាន រូបច្រណាសោភា ប្រកបច្រាជ្ញា ឆុះឆ្ងាស់យល់ឈ្វេង ។ ប្រកបស័ក្តិយស បុណ្យថ្កើងខ្ពង់ខ្ពស់ ចិញ្ចាចចាំញែង ទំយោយុគាជន្មាតផ្នែង កម្ទាំងលើសលែង លើសរោភតាំងឡាយ ។ មានតេជតេជៈ តេជាតបៈ ជាសុខសប្បាយ មិនមានរោគា ជាពៀតតាយ ចាន់ត្រឡាភ័ណ្ឌឡាយ មិនដែលបង់ចាត់ ។ ខ្វះកេតមកមាន ពេតរួបរឹតច្រាណ កំព្រាកំព្រាត់ ត្រមោចត្រមង់ ឯកម្ន៏ឯកាត់ក្តាត់ ក្រៃក្រសម្បត្តិសម្បូរមិនល្អ ។ តគ្រាតតគ្រិះ ភ្លិនក្លាយឆ្អាបន្តុះ សំរុងឡងឡ។ អាក្រក់តាំងពង ដូចតាន់ក្រឡ មាត់ធំច្រហ ច្រហាមស្រេញស្រាញ ។ អ្នកដឹងមើលយល់ រូបពងពុតិល ស្អុះស្អាប់គាន់ក្តាញ់ មិនមានមេត្តា ករុណាស្រឡាញ់ ពុំតិតពុំតេញ ពង់ពោះស្នេហ៍ស្មាល ។ បើហាតោលស្តីទៅកាន់ប្រុសស្រី តេពងតេចាល តេដំនេតេរ៉ះ តេរ៉ះមិនស្មាល មើលមកមមាល មរមែតតែយ ។ ជនពីរនោះណា លុះអស់ជន្ម ជីវិតក្សីណក្សយ ហើយចាប់ផាតិជា មនុស្សវិស័យ ត្រកូលអស្រ័យ ពុំដូចគ្នាទេ ។ សម្តេចតតាវ ទ្រង់ស្តាប់ក្រមហា អនុវត្តទូលថ្វៃ ស្តេចបើតព្រះនេត្ត ទ្រង់ត្រាស់ប្រាប់ប្រៃ ទេសនាថាឯ ជនពីរពួកនោះ ។ លុះកាលក្សីយដល់ បើចុតសាឝិផល ពីមុនមកស្មោះ ផលានិសង្ស ទ្រង់ចំពោះ កាលក្សីយទៅនោះ បុណ្យតាំចត្តារី ។ ចាប់ចដិសន្ធិ

សោយសុខនៅឯ សួគ៌ឋានឥន្ទ្រនៅ បើបានធ្វើបុណ្យ ដោយរឿងនៅ
ជាបុគ្គលនោះនៅ ទាំងត្រេកអរស្កប់ ។ ក្នុងកាលគ្មាន ចូរកន្ធពុតុក- ជាយ
ជាបត្នឹក រងទុក្ខវេទ័ណ្យ សង្ខ្មែរស្ទឹក សព្វថ្ងៃស៊ីផឹក តែងនឹងឈាម ។
ហៃជាអនុវ្ជ្ជ បុគ្គលលែង ជីវិតៈឥតាម តវតណ្ហា ក្រោថ្នាមែរម៉ម
រៃលៃរូបនាម ដោយក្តីក្រោថ្នា ។ ហេតុនោះកំណើត កំណាត់សត្វកើត
ក្នុងសង្សារ ប្រែប្រួលរូបប្លែក ចម្លែកពីគ្នា តាមកម្មវេក នានាំ
ក្នុងកាល ។ ជាមនុស្សជាតិមុន លុះលាញជីពជន្ម កើតជាតិរច្ឆាន
ជាតិមុនរួតទ្រព្យ ត្រូវប៉ះជាបាន ចាប់ជាតិនេរៀតមាន សម្បត្តិមហិមា ។
សម្តេចសត្វញ្ញូ ជាព្រះបរមគ្រូ លើសលើលោកា ព្រះអង្គសំដែង
ធម៌ថ្លែងទេសនា ត្រាស់ថាហៃជា អនុវ្ជ្ជេត្តេតើយ ។ បើបុគ្គលណា
តាំងខ្លួនឆ្លាត- ការកម្មជ្ញានហើយ ដម្កល់កន្លងចិត្ត ប្រព្រឹត្តរឿយ។ ពុំតែត-
ហត់នឿយ ដោយចិត្តមោហា ។ ដើមថាកេសា លោមានខា ខន្ធាតនៈចា
ដម្កល់ចិត្តថ្នាត់ កើតតាត់មោហា អាចនាំរូបា ចៀសបាបទុក្ខា ។
ដូចនាងមណៈ មាតាៈសាកៈ នាងកាមាថា ហតយំ ។ តាំងកន្លងចិត្តា
កើតឡើងបានជា មានចិត្តចិញ្ចល ។ គោះមនុស្សយោរយោដ ចិត្តចង់
ប្រមាថ អង្គនាងកម្រ តេជៈតមិថ្ងៃ ប្រពៃបវរ មានចិត្តចិញ្ចល ដូចបាន
ពណ៌នា ។ សម្តេចភគន្ត ទ្រង់មានព្រះបន្ទ- ខូលទៀងទេសនា

ប៉ុណ្ណោះស្មើមសូម្បី បញ្ឈប់ពុទ្ធដីកា ព្រះអនុរុទ្ធ ទទួលក្រាបក្រសួញថ្វាយ ។
បង្គំទូលថា បពិត្រព្រះមហា ករុណាសូមទាន សំដែងជាតក ខ្ញុំនឹងទុក្ខ
ក្រោសក្រាល យើងខ្ញុំរីឯចូន វិត្តតេស្តារ ។ ព្រះដ៏មានបុណ្យ ទទួល
និមន្ត ទ្រង់មានពុទ្ធដីកា នាំអតីតនិ- ទានពីរាសនា មរណមាត
ជាតកទុន ។ ហៃចូរអនុរុទ្ធ- ត្តេរអើយចូរផ្តត់ សោតាចាំបង
តេរតស្បាន់ខាំង កំប៉ាំងរំលង មានក្សត្រជាប្រាង ចមរចាកាត ។

បទព្រហ្មគីតិ

ខ័ណ្ឌថ្ងៃណែនដោយជាន កាលនោះមានក្សត្រសោភា ស្តេចទ្រង់
ព្រះនាម ព្រះចុតវិមលធម្មាជ ។ ឯកអគ្គឥតមហេសី ព្រះចក្រីទ្រង់
អំណាច អស់ក្សត្រងឹខ្ចាច សឹងចូលមកថ្វាយបង្គំ ។ ឯនាមនគរ
ឈ្មោះវិទេហ៍ដ្ឋាជរម្យ ជាស្តេចឯកជ័យជំ លើសខាំងស្តេចរយឯកា ។
ស្តេចតង់លើគ្រែសាទ តែរស្មីឆ្លាតចែងជ្រះថ្លា តាំងក្រាំសុវណ្ណ រឿង
ឯងគ្នាយាំងប្រណិត ។ សឹងស្រស់ខ្ពស់ត្រដួច ស្រោងស្រៀវស្រួច
ស្រៀបតិចត្រ ងាំតួងសព្វបូជនៃ ក្តីរំលេចមានរស្មី ។ ភ្នំឯកា ត្រចះ
ល្អិតាអ្នកអ្នះរឿងរ៉ាវ៉ី មានក្តីតួរត្រន្តី ដំប្រគំសព្វវាលា ។ មន្ត្រីចតុស្តម្ភ
ឈើតាល់ដុំប្រែនត្រៀបត្រា ស្រីស្នំបំរើវាក ប្រែនអនេកអនន្តរៃក្រ ។

(នៅមានត)

រឿងព្រៃង

ចែងអំពីអ្នកប្រើកំណិតខុសជាំឲ្យមានទុក្ខដល់ខ្លួន

លោក អ៊ុន-អេង លេខាធិការ នៃក្រុមព្រឹក្សាព្រះរាជអាណាចក្រ រៀបរៀង

ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់ ជាអ្នមរកស៊ីលក់ដូរមានធនធានគ្រាន់បើ, គាត់មានកូនប្រុស៤នាក់ មានអាយុគ្រប់ការទាំងអស់ ។

ក្រោយតំពេលដែលប្រពន្ធអនិច្ចកម្មទៅ គាត់ត្រាំនៅជាន៏ោះម៉ាយពុំយកប្រពន្ធទៀតទេ នៅជាមួយនឹងកូនប្រុសអស់១ទ្វាំ មានការលំបាកដោយខ្វះស្រីមេផ្ទះជាអ្នកចំអិនអាហារ និងជួយមើលថែទាំរបស់ទ្រព្យកំប៉ុកកំប៉ុកក្នុងផ្ទះ, គាត់ក៏រៀបការប្រពន្ធឲ្យកូនឲ្យធំ ហើយយកកូនប្រសារស្រីមកនៅជាមួយ ខែកទ្រព្យអស់ ។ ចំណែកឲ្យជាចំស្រឡះទៅកូនឲ្យធំរួចទៅ ។

លុះរំលងឆ្នាំ ១ ឆ្នាំក្រោយមកទៀត ក៏រកប្រពន្ធឲ្យកូនទី ២ ខែកទ្រព្យ ១ ចំណែកឲ្យដូចគ្នា ។

តមក គាត់រៀបការកូនទី៣ ខែកទ្រព្យ ១ ចំណែកឲ្យទៀត ។ ដល់ឆ្នាំជាគំរប់ ៤ ក៏រៀបការឲ្យកូនទី ៤ ខែកទ្រព្យ ១ ចំណែកទៀតដែរ ។ នៅសល់តែផ្ទះ ១ ខ្នងពុំបានខែក គាត់ទុកនៅជាំនឹងអស់គ្នា ។

ដែលគាត់បែកទ្រព្យរបស់ឲ្យអស់រលីងតាំងខ្លួនដូច្នោះមកពីគិតថា ឲ្យស្រេរឡះខ្លួនគាត់, ហើយនៅទំនេរស្ងៀម, ចាំឲ្យកូនរកស៊ីចញ្ចឹមវិញ រហូតដល់ស្លាប់ ប៉ុន្តែ គំនិតគាត់តុស្រឡះ ។

កាលដែលគាត់នៅជាមួយកូនប្រុស៤នាក់ កូនទាំងនោះស្រឡាញ់បងប្អូនណាស់ តុំចាន់បែកចិត្តគំនិតពីគ្នាបងប្អូនឡើយ ។

លុះចាន់ប្រពន្ធមកវៀងខ្លួនហើយ ក៏បែកចិត្តគំនិតផ្សេងៗពីគ្នានៅរួមជាមួយគ្នាតុំស្ងួរចាន់សុខ ចេះតែស្ងៀបរមាស់, បន្តិចម៉ាស់នេះ បន្តិចម៉ាស់នោះ, ក៏នាំគ្នាចុះចេញពីផ្ទះកំណើត ទៅរកសង់ផ្ទះនៅពីចៃពីគ្នាទាំងអស់ ដោយតាឥតុកពោះម៉ាយ ឲ្យនៅតែឯកោអនាថា ។

ឥតាលកូនទាំង ៤ នាក់ ទើបនឹងចុះចេញពីផ្ទះឥតុកថ្មីៗ នៅហុចចាយ ហុចចំណីតាឥតុកបន្តិចបន្តួចតាំងពីថ្ងៃ, លុះមានកូនខ្ចីត្រង់គ្នាដូនតេលប្តីវិលដើរជួញទៅស្រុកឆ្ងាយ តាយោនៅផ្ទះអាងតែប្តីមិនទៅអាងមានកូនខ្ចីផង, ក៏បង្អត់ដូនចាយទឹកឥតុកក្រក ដោយមេខ្លះគិតថាប្រហែលប្អូនគេឲ្យហើយ, មេខ្លះគិតថា បងឯណោះគេឲ្យហើយកូនប្រសា នាំគ្នាគិតដូច្នេះតែរៀងខ្លួន យូរ ១ ថ្ងៃ៧ តានោះអត់ចាយ ១ តេលក៏មាន, ២ តេលក៏មាន ។

លុះដល់វេលាប្តីមកពីរកស៊ីវិញដំណរឿងនេះ ចានស្តីបន្ទោសប្រពន្ធនាងតាយោដោះសាថា កូនឈឺ ខ្លះថា ខ្លួនពុំនៅ វេលាតែជួយញាតិ

ជីតាដ៏ ស្រេចតែមេប្រពន្ធវាជីកមុខ ; ប្តីតាមវាតាំងអស់ ។

ចំណែកតាគោះមាំយ អត់ជាយគ្មានសំពត់អាវស្លៀកពាក់ ដល់ថ្នាក់ដើរសុំទានគេបរិភោគ រង៉ាំក្តៅរំខានតន់ពេក បើនឹងលក់ផ្ទះ។ចាស់គ្រាំគ្រា តុំជាន់ថ្លៃចុំខ្លាន់ផង ហើយគ្មានជ្រកនៅផង ។

តាលណោះ មានបុរសម្នាក់ នៅកំខ្លោះ មានចិត្តសប្បុរស ហើយជាអ្នករៀនសូត្រចេះដឹងច្បាប់ចំលាប់ស្គាល់គុណទោសច្រើន , ផ្ទះនៅភូមិជិតគ្នា ដើរមកឃើញតានោះវេទនាដូច្នោះ មានចិត្តអាណិតក្រៃពេក ក៏សាកសួរថា «លោកតា ! ខ្ញុំច្បាប់ឃើញលោកតាពីដើម ជាអ្នកមានគ្រាន់បើ ឥតុកម្តាយខ្ញុំក៏ច្បាប់ពីឪពុកលោកតាខ្លះដែរ ម៉េចក៏ឥឡូវនេះលោកតាវេទនាភ្លាំងម្លឹះ , ក្រែងលោកតាមានកូនប្រុស ។ ដល់ទៅ ៤ នាក់ដែរ ម៉េចក៏កូននោះ ពាមើលចំណាំមិនថែតាំលោកតាសោះ ក្រែងទ្រព្យរបស់លោកតាមានសល់ខ្លះដែរឬ ? ឬបានជាលោកតាមិនយកទៅចិញ្ចឹមគ្រឿងបរិភោគប្រើប្រាស់ ? » ។

តាចាស់នោះឆ្លើយទៅវិញថា «ឧ ហ្ន៎ ! លោកចៅអើយ ! លាក់បាំងអីពីដើមតាមានទ្រព្យគ្រាន់បើពិតមែន , ប៉ុន្តែតាអាណិតស្រឡាញ់កូនភ្លាំងពេក ក៏បែកឲ្យវាគ្រប់គ្នាអស់លើងពីខ្លួនទៅ តែតាចាំឲ្យវាចិញ្ចឹមតាវិញ , ឥឡូវពួកវា មានប្រពន្ធហើយថែមតាំងមានកូនទៀត ពាយើញឯងអស់ទ្រព្យលើងពីខ្លួន ពាឥតនឹកនារកតាសោះ ពាតាមតែប្រពន្ធៗញុះញង់ក្នុងខ្នើតាម ក៏ពាចូលដែរ , ខ្លួនតាសព្វថ្ងៃឈឺផង នៅតែម្នាក់

ឯងមិនដឹង រវែងនាងចាំផុត ដេកសម្រក់តែទឹកភ្នែកជោកខ្នើយអស់ ហើយ ចុយព្រឹកជាចុយល្ងាច ខ្ញុំធ្វើការរកស៊ុកមិនកើតព្រោះចាស់ ជរា គ្រាន់តែដើរស្ទើរតែមិនរួចទៅហើយ ដូចលោកចៅឃើញស្រាប់ តាដេកចាំតែដល់ថ្ងៃស្លាប់ទេ " ។

ចៅតំរង្គោះលាន់មាត់ថា "យីអើ! កូនតាមានចិត្តអាក្រក់ដល់ម្ល៉ឹងហ៎ះ ដើម្បីចំណែលោកតាកុំភ័យ, ខ្ញុំមានទុយ្យមួយ ធ្វើឲ្យលោកតាបានសុខកាយ សប្បាយចិត្តដូចពីដើមវិញ, លោកតាធ្វើតាមខ្ញុំ ឲ្យលោកតារកគាំងមាន មាត់គូចល្មម។ ដុះអាចម៍ខ្ញីនោមដាក់ឲ្យតេញហើយរកកំណាត់សំពត់ចាស់ រុំបិទមាត់ឲ្យជិត, ជីកកប់ក្នុងដីដិតដើងសសរទ្រូងផ្ទះ, ហើយមើមាន អ្នកណាដើរមក ឲ្យលោកតានិយាយប្រាប់គេថា "ខ្ញុំនៅសល់កំណប់ ប្រាក់.មាស១ពាងកប់ទុក តុំពាន់បែកឲ្យកូនណានៅឡើយ ចាំមើលកូន ណាចិត្តបាន ដីនឹងដល់, បើខ្ញុំរៀបស្លាប់នឹងប្រគល់ឲ្យទៅកូននោះ" លោកតានិយាយប្រាប់មនុស្សដែលជួបតុំមាន, ក្នុងរវាងប៉ុន្មានថ្ងៃ-ខែខាងមុខនេះ កុំឲ្យលោកតាដើរទៅសុំបាននេះទៀត, ចាំខ្ញុំយកបាយ ទឹកមកជូនតាសិនកុំឲ្យត្រួយ " ។

តាចាស់ ក៏តាំងធ្វើតាមចៅចិត្តសប្បុរសពាំនអស់ ។ លុះបាន ប្រហែល ៥ ថ្ងៃ សំដីតានោះ បានដឹងដល់កូនប្រុសនឹងកូនប្រសា ចាំង ៤ នាក់, វាមានចិត្តលោភចង់បានកំណប់តែរៀងខ្លួន, ក៏ចាំគ្នា

យកបាយ ទឹកម្ហូបចំណីផ្លែឈើទុំៗគ្រប់មុខ ធំដ៏សារុនអាវ ក្រមាយកមកផ្តាប់ផ្តង់ជូនតាឥតរៀនកល់ថ្ងៃ តុំមានខ្វះថ្ងៃណាមួយឡើយ, តាចាស់បានសុះជាកេត មានសាច់ឈាមស្រស់បស់ មានកម្លាំងពលំ, សប្បាយកាយសប្បាយចិត្ត តាំងពីថ្ងៃនោះមករហូតដល់អស់តាយុ ។ លុះតាស្លាប់ហើយ កូនកំនាំគ្នាធ្វើបុណ្យអធិកអធមតាមទំនៀមរួចស្រេច ។

ចៅកូនចាំង ៤ នាក់ ទឹងកាយោគិតនាំគ្នា តាស់តាងកំណប់ចែកគ្នា, ប៉ុន្តែក្រែងចែកមិនស្មើគាគនាំឈ្មោះប្រកែកគ្នា ក៏ចៅអញ្ជើញគ្រូហ្មាក់ឲ្យមកជួយចែក, លោកនោះខ្លួលត្រម, ប៉ុន្តែគាត់ភ្ញាក់ថា កំណប់មាសច្រាក់ ច្រើនដល់ចៅ១តាង, គាត់ចង់បាន១ចំណែកដែរ, ហើយគាត់គិតក្នុងចិត្តថា គាត់ធ្វើមេចំណែកត្រូវបានៈច្រើនជាងកូនចំណែកផង, គាត់ក៏ដើរត្រឡែះមកដល់ផ្ទះកំណប់ភ្លាម, តាំងយកកូយធំមួយមកពុំជួតក្បាលធំដើងមើង ធ្វើឲ្យខូងកណ្តាល ដូចគេខួលជើងឆ្នាំងជ្រាវ, ក៏តាំងអង្គុយពែនក្នែនលើផ្លែដីកបរលើង ឆ្លេចភ្នែកសង្រ្កមស្ងើងស្ងាត់ ឈមមុខត្រង់ទៅទិសខាងកើត, ហើយគាត់ប្រាប់ចៅតាំង ៤ នាក់ ឲ្យចៅគាស់យកតាងកំណប់មក ប៉ុន្តែ គាត់ហាមកុំឲ្យខាន់អាលស្រាយមាត់តាងក្រែងខុសត្រណម ចាំគាត់បង្គាប់ លុះយកតាងមកដល់ហើយគាត់ឲ្យចៅតាំង ៤ នាក់ ឈរគ្រប់ទិសតាំង ៤ ឆ្លេចភ្នែកយកដៃតាំងអស់គ្នាចាប់លើកតាងខ្សួយប្រឡូលលើក្បាល ហើយសឹមស្រាយចំណងមាត់តាង, នាំគ្នាផ្អៀងមាត់តាងស្រោចកំណប់មកលើក្បាលគាត់

ចេញកំណាប់ផ្ទះសង្កត់ទៅទិសណាមុំខ្នាន ១ ត្រូវបានទៅអ្នកឈរកំណាន់ទិសនោះ ១ កំណាប់ណាទៅសល់ទើបលើឆ្នូតក្បាលគាត់ ត្រូវបានជារង្វាន់លោកគ្រូទាំងអស់ ។

ចៅទាំង ៤ នាក់ កំចាច់ធ្វើតាមបង្គាប់លោកគ្រូមិនហ៊ានឲ្យស្លៀងខាងការយោគទាំង ៤ នាក់ ឈរកាន់តែភ្ញើរឿងខ្លួនចាំកើប ។

ក្នុងពេលដែលចែកកំណាប់នោះ, មានអ្នកស្រុកដិតខាងទៅចាំមើលដែរ ។

ខិមិត្តតែគេលើកតាងប្រចួលរួច ស្រាយមាត់តាងផ្ទៀងចាក់ឈូរមក "ពីតម៉ាត្រាំលាមកច្រែខ្លួច" ហូរនៃស្រោចលើក្បាលលោកគ្រូពេញកំពុងហើយខ្លួនជាចសាចចេញទៅគ្រប់ទិស ប្រឡាក់ប្រឡែសតាសពេញមុខមាត់ខ្មីសាវ៉ុង អាវ រហូតដល់ខាងប្រតន្ធទាំង ៤ នាក់ លោកគ្រូបានចំណែកច្រែខជាងគេ, ជំនួនខ្មោះខ្លួ កំថាមិនត្រូវ គេឃើញលោកគ្រូស្រមុំវ៉ៅ ចាត់មុខចាត់រូបពាងអស់ ទំក្រោកឡើងសោះកក្រោះ ខ្មាស់អស់ភ្នែកបរិសទ័ដែលឈរចាំមើល ពួកបរិសទ័ក៏ផ្តើលទំរត់ចេញប្រជេញគ្នាទៅផ្ទះរៀងខ្លួន; ទើបលោកគ្រូស្រែកដេរតែសំខ្លួនទៅចៅទាំង ៤ នាក់ខ្មីងខាងការយោថា "ខ្មោចមេដែង អាដែងទាំងអស់គ្នា អា-មេបានធ្វើបាបខ្មោចឥតការច្រើនណាស់ហើយមើល.ៗ ចានជាកំណាប់មាស-ប្រាក់

អន្តរាយក្នុងទៅជាអាថម៌-នោមប្រាប់ខ្ញុំឧទាហរណ៍ដូច្នេះ យើ ! ភ្លេច
អាវេះ មេវេះ ។

លោកគ្រូធំឯកូនសិស្សទាំងគ្នាតក់ហើស លោតចំលាក់ខ្ទះទៅខ្ទេ
ប្រូង ចំណងជាបអស់ ១មោងឯម្នាក់ ។ រួចទាំងគ្នាឡើងទៅផ្ទះរៀងខ្លួន;
ចាន់សេចក្តីក្តៅក្រហាយស្តាយក្រោយ ខ្មាសគេតកូន-ចៅ ។

ឆ្លើយអំណោយបានទុក្ខ
ភ្លើបង្កំពុកបានសួយ
គ្រូណែនបានរុយ
រោមសំអុយពេញខ្លួន ។

រឿងនេះ ចាន់ផលល្អ អាក្រក់យ៉ាងណា ។ សូមជនប្រុស-ស្រី
ទាំងក្មេង តប្បីសំគាល់ទុកជាគតិតទៅ ។

រឿងហង្សវិយគ្គ

(តទៅ)

លោក អឹម-ភាន បម្លែងពីសាស្ត្រស្លឹករឹត

បទ ភាគកត

នាងធ្វើជាក្សត់ ដឹងស្មារតីជាក់ ស្តុះចេញម្ដង នាងធ្វើដំណាស់ ទឹងព្រះពជ្ឈ នាងនាថចរោ ហាក់មិនមេត្រី ។ ថាអង្គីកល អញមិនដែលយល់ ដូច្នេះតើអ្វី ប្រុសម្ដេចចិត្តធំ យល់ពុំដួតិ្ត មកចាំឯពត្រ ទឹងដេកពុំបាន ។ អញ្ជើញស្តេចទៅ ស្រុកខេសលំទៅ នគរក្សត្រក្សាន្ត កុំបីព្រះអង្គ ផ្សះផ្សងទៅស្ថាន នេះនាំរំខាន ពុំបានខេណ្ឌ ។

បទ ត្រឡប្បកិតិ

ស្តេចត្រាស់ស្នងរំលងវិន ថាត្រូវចិត្តមាសស្នេហា កុំអាលពៅតុំងារ ទឹងទឹងបង្គណា នាងអើយ ។ ចូរប្អូនមាសស្តែងស្តាប់ បងទឹងត្រូវបំដៅណើរឡើយ ឲ្យប្អូនមាសត្រាណត្រើយ ដឹងដោយដានដើមបងមក ។ កាលបងនៅនាយណា ព្រះបិតាអ្នកឲ្យឃក អស់ចុត្រីតន្ទុក ស្តេចមួយរយទឹងមួយណ្ឌ ។ សំដីមានរូបតិសិ ហាក់ដូចស្រីទេវសួគ៌ា ទឹងឲ្យជាតន់តាបងតុំយកដល់មួយឡើយ ។ បងឮនាមប្អូនពៅ ល្បីឮពៅដល់បងហើយ ត្រលឹងមាសបងអើយ បងជាទុក្ខតិថ្ងៃនោះ ។ បងអត់ពាំងអាហារ តិថ្ងៃកាលបងឮឈ្មោះ ប្អូនពៅដល់បងនោះ បងជាទុក្ខតន់ពេកក្រៃ ។

បងផ្អូតខន្ធិះចិត្ត ពុំក្រេចគិតដល់មួយថ្ងៃ ដរាតបងស្ទើរក្ស័យ ដ្បិតតែបងឮឈ្មោះប្អូន ។ ពីព្រះអង្គក្សត្រថ្ងៃ ព្រួយព្រះទ័យជាខ្លាំងពន់ ទើបស្តេចឲ្យធ្វើយន្ត ហង្សមាសមួយឲ្យបង ។ បងបានហង្សយន្តនោះ បងតើចហោះមកអាយហោង រកប្អូនសន្ធនស្នេហ៍ស្និទ្ធ ឲ្យបានដូចចិត្តចំណង្គ ។ ឥឡូវបងមកដល់ ប្អូនឱមិលមាសពុំដាំ ម្តេចឡើយនាងមកថា ឲ្យបងរៀងវែងៗហោង ។ គួរតែប្អូនស្នេហ៍ស្និទ្ធ នាងអាណិតអាសូរបង អាសូរដ្បិតប៉ុនប៉ង ស្រុះស្រួងមករកប្អូនៗ ។ គួរតែប្អូនស្រីស្រួល នាងទទួលយកបងៗ ជាប្តីនាងប្អូនៗ សឹងអម្បាលស្តេចដូចគ្នា ។ បើប្អូនអាសូរបង កាលនេះម្តងដូចច្រាំថ្ម គុណប្អូនមាសស្នេហា ធ្ងន់អនេកពេកក្តាត់ហោង ។ បងផ្ញើចកលតស់ទាំ ប្អូនជាថ្មាំលាយលាបបង ស្រោកស្រោនជម្ងឺផង មានប្រការនោះម្តេចមិញ ។ បងនឹងសងគុណធ្ងន់ នាងស្រីតន់ប្អូនសំឡាញ់ ឲ្យថៃឲ្យថ្លូនវិញ ព្រោះនាងមានគុណនឹងបង ។ នាងស្តាប់ព្រះនង្ការ ហើយនាងនាថទូលវិនស្និទ្ធ ខ្ញុំអព្រះអង្គហោង សង្ឃឹតមកតាមតែខ្ញុំ ។ ខ្លួនប្អូនដូចត្រីក្ស ទ្រង់ផលបរិបូណ៌ពុំមានម្ចាស់ក្សេមសម ស្តេចនឹងបេះឯងពុំបាន ។ បើទ្រង់សព្វព្រះទ័យ សូមមាសថ្ងៃទ្រង់ទៅថ្ងាន ក្រាបទូលមហាក្សត្រក្សន្ត ជាព្រះបិតាមាតា ។ បើពីរអង្គក្សត្រថ្ងៃ សព្វព្រះទ័យទ្រង់ករុណា ខ្លួនប្អូនឥតបើថា ពុំប្រកែកប្រកួតឡើយ ។ ស្តេចធ្វើយស្នងវិញថា

ហៅប្អូនភ្លាមៗសមដែរអើយ កុំថាដូច្នេះឡើយ សូនតែខ្លួនឯងភ្លាតល ។
ខ្ញុំប្អូនឯងដូចផ្កា ចង្ខូចក្រឹស្មារិសសល់ ដើមដុះឥតគេយល់ ព័ដារ
តែផ្កាស្លេងស្លើយ ។ បើបងបានភ្ញៀងផ្កា ស្រែចហើយណាមាសបង
អើយ ឯដើមតុំក្រឡើយ បងរកយើញខេណាចៅ ។ បើយើងតាំង
ពីនាក់ ជាន់ដែរស័ក្សមួយលំនៅ សំនឹងនឹងប្អូនភៅ យើងត្រូវរៀតគ
ងឯគ្នា ។ តាំងនេះខុតងារបង បងនៅរង់-ចើងនា លែងតែភៅតុំងា
នាងចូលចិត្តព្រមនឹងបង ។ ខើបនាងសងស្រមៃ ថាតាប់ចៃត្រូវអង្គ
ហោង ឃកខ្ញុំនឆានាង អស់ប្រការតាំងនេះណា ។ តឹមេះខ្ញុំមិន
ឆ្លើយ ខ្ញុំមិនដោយត្រូវពាក្យ ពាក្យប្រុសរៃងមាយា តុំសត្យាខៀនដល់
ក្តីង ។ ខ្ញុំប្អូនដូចត្រីក្សា មានសាវាជាបង្គន់ ត្រូវអន្តីដូចឃ្មុំឆង ខំ
ផ្ទើហើយ។ ហើរៅ ។ ឯឈើមិញឥតការ ខ្ញុចរសារខំនេរនៅ ប្រ-
ដូចខ្ញុំប្អូនភៅ ជាមេម៉ាយក្រុកដហើយ ។ ក្រែងបងចោះចេរៅ ឲ្យ
នាងនៅឯនឥតត្រើយ ត្រលឹងមាសៈងអើយ បងនាងនឹងរស់ម្តេចបាន។
ហេតុត្បិតបងស្នេហា ប្អូនណាស់ណាតន់ត្រមាណា ខើបបងចោះបងិ៍ហាន
សង្ឃឹតដកឲ្យបានដល់ ។ ចិត្តបងស្រឡាញ់ចៅ ដូចសំពៅស្រឡាញ់
ខ្សាល់ ស្លាប់សៅតំគាប់តល បងពុំតិតស្តាយឥក្ខ ។ ខ្ញុំបងនេះដូច
ត្រុង ប្អូនក្រោកដូចនាគា ឃានដៃត្រុងហើយណា តុំដែលវាលនាគ
នេះរហោង ។ ទុក្ខបងដូចខ្ញុំខ្ញែង នាងប្អូនឯងដូចមានដង ខ្ញែងនាប

ចាន់ហើយហោង តុំដែលបងំចោលម្សៀតសល់ ។ ខ្ញុំបងំដូចគល្មា ខ្ញុំនឹ
ប្អូនភ្ញាដូចគណ្តុរ គាលបើចាន់គាប់គល ក្នុងមាត់ឆ្នោះមែនមិញ ។
ឯឆ្នាតុំដែលខ្ចើម តុំដែលឆ្អែមនឹងលែងចេញ ប្អូនអើយឯអង្គរញ បង
បមាដូច្នោះហោង ។ សូមប្អូនមាសបណ្តុល នាងអាសូរប្រណីបង
ស្រួចក្តីបំណង ណា+ព្រលឹងមាសបងអើយ ។ ត្បិតបងកំព្រាសល់
ឥតឯយល់អ្នកណាឡើយ មានតែប្អូនឯងហើយ សូមប្អូនមាសមេប្រ-
ណី ។ កាលបងនៅស្រុកនាយ មានម្នាក់ឈ្មោយស្ងួនបេតី មកអាយ-
មានប្អូនស្រី បងនឹងផ្ញើនូនលើចៅ ។ តោះបើបងគាប់ទុស ដើរស្វាប់
រស់លើប្អូនតៅ ត្បិតបងស្រឡាញ់ចៅ ស្មើខ្ញុំនមួយរួមជីវ ។ បើសិន
បងលេបថ្នាំ ដោយចិត្តក្បាន្តដូចចំណី បងនឹងលេបប្អូនស្រី សោះ
ប្អូនមាសមានសង្ស័យ ។ នាងស្តាប់ព្រះភូមី នាងនារីតេញព្រះទ័យ
ទើបនាងសងស្រមៃ ថាគាប់ចៃត្រកោក ។ ចេះបន្តូលពីកេះ តែតង់តោះ
តុំដូចឆា ឯអង្គប្អូនឆោះណា+ មិនស្រើបស្រួលដោយព្រះអង្គ ។ ពាក្យ
ប្រសៃនៃប្រក្បាយ អកប្រុាយលួងលោមចង់ ចាន់ហើយចោលចោះ-
ប្តូរ ឲ្យតែស្រីអសារសល់ ។ ប្អូនតិតប្អូនជញ្ជឹង ប្អូនតើងហើយប្អូន
យល់ ចំណោរសៅនឹងលល់ ខ្ទុកខ្ទាកឯងឃើងស្រាក្រៃ ។ កុំព្រះអង្គចាំខ្ញុំ
ខ្លើយខ្ញុំតុំដោយក្សត្រៃថ្ងៃ អញ្ជើញសៅគ្រងថ្ងៃ ក្រោមព្រះអង្គឯងាយ
ណា+ ។ ក្សត្រិណានោះព្រះបមចក្រ ធ្លើជាអាត់អន្ទង់ចិត្ត ខ្ញាល់នឹងរវាំងយ

បន្ទូលបកគំពុំមេត្រី ។ ថាអញអន្តឺកល អស្ចារ្យសល់ពុំដួងក្តី ស្រឡាញ់តែ
ប្អូនស្រី ពុំគិតគេរ៉ែនន័ន្ធា ។ គេនឹងគេបណ្តេញ មិនស្រឡាញ់ខ្លួនឡើយ
ណា គិតតាប់គួរយោគ្រា ក្រឡាប់ទៅក្តូរតាប់ក្រែ ។ ស្តេចទិតចូលដំគាង
ដិតជល់នាងនាថថ្ងាថ្លៃ ទើបស្តេចត្រាស់ថាមៃ ប្អូនព្រលឹងមាសរស្នេហា
បងនឹងសូមថើបថៅ បងនឹងទៅឥឡូវណា សោះតែស្រណោះគ្នា ឥត
បុកណាគូនាងឡើយ ។ ស្តេចកៀកក្រសោងសេង រំពេចឥងពុំលង់ឡើយ
ឯនាងនាថឱ្យសហើយ ផាត់ព្រះហស្តចេញវិញណា ។ ស្តេចថាមៃ
ប្អូនតន់ កុំខុងនឹងបងពាំ ដៃដិតប៉ុណ្ណោះណា តើនឹងក្តៅក្រហាយអ្វី ។
នាងស្តាប់ព្រះរៀមហ៊ាយ នាងពុំធ្វើយស្នងវាចី នាងឱ្យសព្រះភូមិ ទន
សញ្ជ័យពុំចរចា ។ ព្រះអង្គថាមៃគៅ បងនឹងទៅឥឡូវណា កោតតែនាង
ប្អូនភ្លា មិនអាស្ទូរបងជាស្តេច ។ បងសាប្អូនទៅហោង ឱដ៏ទៅត្រង់បុត្រី
ស្តេច សឹងមានរូបស្រស់ស្រេច តាំងរាយឯកអង្គនារី ។ អង្គបងអត់ព្រហ៊ាយ
មាសបងតើយបងនៅថ្ម ទៅនេះឱ្យសប្អូនស្រី ឥឡូវបងទៅតាប់ក្រែ ។ ខ្លួន
បងឥតទ្រព្យា ប្រសើរជាឱ្យប្អូនថ្លៃ មានតែពាក្យនេះនៃ បងផ្តាំព្រះ
ប្អូនស្រី ។ ចាំតិថ្ងៃនេះទៅ កុំប្អូនទៅមាសមានប្តី ស្ងួនបួសជានាងដី នោះ
ប្រសើរពេកក្តាត់ណា ។ អម្បាលបងជាក្សត្រ កំប្អូនឥន៍មិនស្នេហា ហើយ
ប្អូនរកឯណា ឱ្យសមគួរនឹងប្អូនស្រី ។ បងនឹងសាប្អូនទៅ សូមនាងនៅឯក
អង្គ្រឹយ សោះព្រួយចិត្តប្អូនស្រី នាងកណ្តែងតាំងតែបង ។ ប្អូនទៅឯង

ឯអាយ ឲ្យសប្បាយចិត្តចៅហោង កុំមានសេចក្តីសង្ស័យ បងមិនបានមកវិញ
ឡើយ ។ ទៅណាទាន់ប្អូនណា បងនឹងលាប្អូនទៅហើយ ស្តេចនោះព្រះ
គ្រាណាត្រើយ ស្តេចដាក់ឧបាយឆ្លៀងយកត្រា ។ ឯនាងនាថនិមិល នាង
ឧតុយល់ព្រះពន្ធ ស្តេចចាកនាងណា នាងចាប់ដាយព្រះតស្តែថ្លៃ ។
រីឯព្រះពន្ធ ឆ្មៀងនត្រានទ័រពៃ ឧតុយល់នាងប្អូនថ្លៃ ចាប់ព្រះតស្តែត្រុះ
ពន្ធ ។ ស្តេចធ្វើដាក្សាំ ប្រែព្រះតត្រូមកម៉ូម ឧតុយល់នាង
ធីតា ចាប់ព្រះតស្តែដុះភ្នែរពោង ។ ទើបស្តេចបន្ទូលថា ពៃប្អូនក្សា
មាសស្នេហ៍ស្នង ប្អូនទ័ន្ធប្អូនស្អប់បង នាងបណ្តេញឲ្យបងទៅ ។ ឥឡូវ
នេះតើមាន បើទុសខានតាក្សាអ្វីទៅ កាលបងលាប្អូនទៅ កំសួនស្ងៀម
តុំស្រដី ។ ឥឡូវស្រាប់តែមក តើចអូសយកសំពត់ពី បង្កើះបងវិញទ្វី
នាងអាសូរបងសិនពុំ ។ សំពត់នេះថ្លៃខ្លាំ ដែលព្រះហស្តព្រះមាតា អ្នក
ក្សាញឲ្យបងណា កុំឲ្យបាត់ណានាងអើយ ។ នាងស្តាប់ព្រះពន្ធ រវៃជាយ
ឥតចម្លើយ នាងក្មាសត្រះត្រាណាត្រើយ ថ្វាយបង្គំព្រះពន្ធ ។ ក្សត្រីណានោះ
ព្រះភូមី យល់ប្អូនស្រីរវៃគ្នា ស្តេចឧតន៍ចុះម៉ូម្ចា ប៊ីថ្នាក់ជួមត្រះប្អូនស្រី ។
ជាក់លើចពាតន៍ តាអង្គក្សត្រមួមមេត្រី ទើបនាងនាថទៅ បង្គំខ្លួលព្រះ
ពន្ធ ។ បតិត្រូមត្រាអង្គ បន្ទាបន់លែងក្រោធ អាសូរខ្លួនប្អូនជា
ខ្ញុំបាទព្រះជាទបង ។ ក្សត្រីទូរក្សត្រា ស្តីទ្វេស្នេហាឥតឯហ្មង តាវ
ពន្ធព្រះដង្គហោង រួមបង្ខំសុខសួស្តី ។ ស្តេចលោមរវៃជាយ

ភាជធ័តាអគ្គមហេសី ប្អូនអើយបងមកផ- ឡូវនេះយូរណាស់ហើយណា ។
បងចង់បបួលទៅ ក្រឡាប់ទៅថ្ពាន់តាក ស្រុកបងឯនាយណា ចូរប្អូនទៅ
ទៅទឹងបង ។ នាងស្តាប់ព្រះឧទ្ទារ ទើបនាងនាចំពូលវឹងស្នង បពិត្រខ្ញុំ
នេះហោង មានព្រះអង្គជាអម្ចាស់ ។ គឺមោះព្រះបិតា ខ្ញុំមាតាមានគុណ
ណាស់ សោតសឹងជពាស់ តាមតែខ្ញុំព្រះអនុណា ។ ស្តេចស្តាប់
នាងនាថពូល ព្រះអាសូរវរជយា ក្សត្រីខ្ញុំក្សត្រា ធ្វើក្រសាល
ព្រះហ្ឫទ័យ ។ លុះមានរាត្រីណា ស្តេចលោមលាព្រះប្អូនថ្ងៃ មាស
អើយឥឡូវនៃ ហៀបនឹងត្រឡប់ហើយណាទៅ ។ ខ្ញុំខមាសស្នេហ ឥ-
ឡូវណាចូរនាងនៅ បងនឹងលាប្អូនទៅ ហើយបងនឹងរំលែកញ្ញាណ ។
សម្តេចព្រះភូមី ថ្នមប្អូនស្រីឥន្ទ័តុំដាំ មហេសីសុគន្ធសោភា ស្តេចជាក់
លើទកវ័តន់ ។ ស្តេចថើបក្រនេក្រា ព្រះពាក្យផ្តែផ្តាំឆ្លិត រេស្តេចហើប
ស្តេចឡើងបិត លើហង្សមន្ត្តីចហៀរហោះ ។ លុះដល់ដើមត្រឹកក្សា
ព្រះរាជាចង់ឃ្លាំងនោះ ហើយត្រេះឯងចុះ លីលាទៅទ្រព្រាហ្មណ៍ណា ។
ព្រាហ្មណ៍ឃើញព្រះភូមី ព្រាហ្មណ៍ត្រឹទ្ធិសោមនស្សា ស្រែឡាតាត្រេះរាជា
ស្នើកសួនបេះត្តីតនៃ ។ ហើយស្តេចតែងឡើងទៅ តាមព្រះរថចម
ក្សត្រថ្ងៃ ប្រក្រតីសព្វ ។ ថ្ងៃ ភ្លុំដែលជាចំនួនមួយណា ។ លុះដួល
ចូលរាត្រី ត្រេះភូមីទៅនិទ្រា ទឹងនាងនាថជាយា ជាប្រក្រតីដូច្នោះ
ហោង ។ ស្តេចទៅលង់ទៅណា នាងជីតាត្រូវតិផង ទំនងនាងនាថ

ហើយហោង ឱងប្រសូតកាន់បុត្រា ។ ពុំលន់ឡើយជ្រាបទៅ ដល់ព្រះ
ភៀព្រះបិតា ក្សត្រិណោះព្រះពជ្ឈ ឲ្យអញ្ជើញបុត្រិតន ។ ទើបនាងនាថ
នារី ចុះចាកតាក្រាសាទថ្នាត់ ទៅតាលតីរតេឡក្សត្រ ព្រះបិតាខ្លួមាតា ។
ឯព្រះបិតាតន យលសុបិនទាងទៀណា ស្តេចជ្រាបដឿងជាកដា កាន-
បុត្រីនាងខ្លួនតតិ ។ ស្តេចក្រោធក្រៃក្រាកដ ហើយទំអតិធ្លេក្រសាល
មាក់ហើយជាភ្លុំខ្ញាល់ ស្តេចតុំឲ្យនាងដំនន់ឡើយ ។ ក្សត្រិណោះនាងទៅ
លាជនទីជនកហើយ ទើបនាងនាថត្រាណត្រើយ រៀលទៅភ្លាន
ក្រាសាទណា ។

បទនំនោល

កាលនោះព្រះចៅបញ្ជាល់ ត្រាបក្លួច្នោះណា ស្តេចខ្ញាល់តន្ធឹក
តេកក្រៃ ។ ហាក់ដូចអគ្គីវិសម័យ នេះក្នុងព្រះទ័យ ខ្នេត់ចំប្រុងអគ្គិ ។
ទើបត្រង់ព្រះចិត្តាថា កូនអញានេះណា អគ្គីនឹងអ្នកដទៃ ។
សមនឹងកូនព្រាហ្មណ៍នោះទៃ មានរូបប្រពៃ ប្រសើរលើសលែងអ្នក
ផង ។ បើច្នោះគួរអញនឹងស្លាប់ យកចំណេះលង លួងចាប់ឲ្យ
បានហោងណា ។ ទើបស្តេចឃាត់ត្រឿងមាលា ចួងចន្ទន៍ក្រឹស្នា
ហើយលាងនឹងជាតិហិង្គុល ។ មានសេតីរោមសាតសប់ ពុំភាំង
ដណ្តប់ កំណើងក្រអូបស្មើងល្វើយ ។ ដាក់ក្នុងប្រអប់មាសហើយ
ទើបក្សត្រិត្រាណត្រើយ ត្រាស់ប្រើសារថីជាមួយណា ។ យកទៅថ្វាយ
ពជធីតា សៅដៃជាមិនមា ខ្លួលប្រអប់មាសនៃ ។ យកតីព្រះហស្ត

ក្សត្រថ្ងៃ ស្រាប់ស្រេចហើយនៃ សារវៃជបង្គិក្រាបលា ។ ទៅទូល
វរពជធីតា សារវៃជទូលថា បពិត្រព្រះពជក្សត្រី ។ សម្តេចព្រះវរជនន៏
ស្តែងស្តេចជាគ សូវប្រើខ្ញុំមកនេះណា ។ ឲ្យយកគ្រឿងព្រះមាលា
ប្រសើរថ្ងៃថ្វា មកថ្វាយព្រះអគ្គ្គមហេសី ។ ព្រះពជបុត្រីតន៏ថ្ងៃ នាង
ស្តាប់សារវៃជ ស្រេចនាងទូលយកហោង ។ សារវៃជក្រាបលាវិលផ្តង
ភ្លាតព្រះបាទសង្ខ ជាំជាព្រះវរបិតា ។ បពិត្រសម្តេចពជា វរពជធីតា
តំថ្វាយបង្គំរំខ្ញុំយ ។ មកព្រះនរនាថនរបតី ស្តែងស្តេចជាគ សូវអស
ចាំងពស្តេចនណា ។ ស្តេចស្តាប់សារវៃជទូលថា ហើយព្រះពជា
ស្តេចត្រេកន្ធរសាមនស្សក្រៃ ។

រីកាលពត្រីនោះនៃ ព្រះបាទដៀស្តជ័យ ស្តេចនឹកដល់វរជាយា ។
ស្រេចខែមព្រះបាទក្សត្រា ស្តែងស្តេចលីលា ព្រះបាទក្សត្រថ្ងៃដើរទៅ ។
ដល់ដើមឈើធំនិត្យទៅ ខែមព្រះចមទៅ ស្តេចឡើងដល់ហង្សយន្ត
ណា ។ ស្រេចហើយព្រះបាទក្សត្រា ស្រាយយន្តម៉ូម្ម ស្តេចតង់
ហង្សយន្តហោះដល់ ។ ត្រាសាទប្រសើរសួស្តីសល់ ហើយព្រះទស
ពល ស្តេចចុះពីហង្សយន្តណា ។ ខែមស្តេចយោងយាសយាត្រា ចូល
ទៅដល់នាក្រឡាបន្ទំក្សត្រី ។ ក្សត្រីណានោះព្រះពជទេពី វរតន៏ទមហេសី
នាងយកគ្រឿងព្រះមាលា ។ លាយលាបឲ្យព្រះពជា រីកជធីតា
តុំជំនិងជាតេឡែកល ។ ស្រេចស្តេចធ្វើលក់សួស្តីសល់ ទីងហៀបលុះដល់
ទៅមាន់រងាវហើយណា ។ ស្រេចខែមព្រះបាទក្សត្រា ថ្ងៃត្តាំជាយា

ប្អូនអើយនឹងត្រឹកហើយហោង ។ បងនឹងលីលាទៅផ្ដង ចាំយប់ឯង
ហោង បងមកកាន់ព្រះប្អូនស្រី ស្ដេចលោមនាងអគ្គមហេសី ស្រេច
ព្រះចក្រី ស្ដេចថ្នមព្រះប្អូនស្នេហា ។ ថើបថែអស់ព្រះអង្គា ស្រេច
ស្ដេចលីលា ដើរចេញមកដល់យន្តហោង ។ ស្រាប់ស្រេចស្ដេង
ស្ដេចឡើងគង់ លើហង្សហោះផ្សង កំលុះដល់ដើមត្រឹកក្បា ។ ស្ដេច
បងហង្សយន្តម៉ម្ចា ហើយមហាក្សត្រា· ធាតដស្ដេចមកដល់ហោង ។
ស្ដេងស្ដេចចត្រាច់រើងផ្ដង ត្រាច់ដោយគន្ធង ទៅដល់ផ្ទះព្រាហ្មណ៍
ត្រឹខ្ញី ។ ព្រះអង្គយកព្រះតស្រ្ដថ្ម មកខ្ទូរតែ ព្រះសិរ្សដល់ព្រះបាទ ។
ហើយផ្ទុំតែឯកអង្គា លក់សូន្យក្ដាត់ណា លុះព្រះអាទិត្យទ្រង់យ ។
រះតែបូតាប្រពៃ រឿនរះខ្ពស់ក្រៃ ព្រះអង្គពុំភ្ញាក់ឡើយណា ។ ក្សិណ
នោះព្រះចៅបញ្ចាល់ តើនចាកនិគ្រោ ស្ដេចចេញពីពាធវ័តន៍ ។
មន្ត្រីតង់តាល់ច្រើនក្ដាត់ ទើបព្រះមហាក្សត្រ ត្រាស់ប្រើអាមាត្យមួយ
ណា ។ ទោហៅកូនព្រាហ្មណ៍ហោង ក្សិណនោះអមច្ចា ក្រាបលា
សម្ដេចដៀស្ដង់ជ័យ ។ ខ្នើយតសង្ហាតវ៉ៅ រត់ធាប់ៗក្រៃ ទៅដល់
ផ្ទះព្រាហ្មណ៍ហោង ។ ថ្ងៃដឹងព្រះពាធអាថ្ងា ព្រាហ្មណ៍ប្រាជ្ញតតថា
កូនអញ្ជានេះតើធ្វើអ្វី ។ ឲ្យហៅយល់អង្គឹក្ដី ទើបព្រាហ្មណ៍ត្រឹខ្ញី
ខចូលទៅជាស់បុត្រា ។ ព្រះអង្គតើនចាកនិគ្រោ ព្រាហ្មណ៍យល់អង្គា ដំ
ប្រាលន្ទាលធ្លុនផ្ដៅ ។ ទើបព្រាហ្មណ៍ឲ្យព្រះបមចៅ ស្ដេចលីលា

ទៅ ស្រេះស្រេងដំរេះអាត្មា ។ ព្រះអង្គស្រេងព្រះគង្គា ដុសសព្វកាយា
ស្រេចបរិបូណ៌ហើយនៃ ។ នៅខាងព្រះកាមាថ្ងៃ សម្តេចជៀស្នងជ័យ
ស្តេចដុសតុំសព្វឡើយណា ។ ទើបស្តេចទ្រង់ព្រះតស្រ្តា ស្រេចស្រាប់
ម្ចាស់ លេះលាំងទៅថ្ងាត់ ។ លុះដល់មណ្ឌលភេទរតន៍ ថ្វាយ
បង្គំក្សត្រ ព្រះចាប់ញាលន់របត ។ ទើបស្តេចត្រាស់ប្រើមន្ត្រី មើល
សព្វតន្ត្រីយ ក្រែងមានដិតជាតិហិង្គុល ។ អាមាត្យមើលព្រះខសតល
តន់សព្វក្សិណាយល់ បន្តិចខាងព្រះកាមា ។ អាមាត្យក្រាបទូលភជា
សម្តេចចេស្តា ជ្រាបជាក់ដូច្នោះហើយនៃ ។ ស្តេចទ្រង់ក្រោធតន់តេក
ក្រៃ បន្ទូលថាវៃហ តេជ្ឈាជតាំងអស់គ្នា ។ គ្នាយើងរួសធាប់ម្ចាស់
ចោមភេមចាប់ភ្ញ កំណាចនេះចន្ទឲ្យខ្លាប់ ។ ហើយទាំងៅតិឃាត
ធាប់ យកវាសម្លាប់ ឥឡូវកុំយូរឡើយណា ។ តេជ្ឈាជតិ
សោតម្ចាស់ ចោមចាប់ពួជា ឃាតហើយរុំចង់ខ្លាប់ក្រៃ ។ ស្រេចហើយ
នាំចេញវៃ ។ ខ្ពោះសំរែងព្រៃ ប៉ុនប៉ងតិឃាជក្រែងជ ។ រីឯសម្តេច
តង្ឃព្រុ- ខ្លួរបរិសុទ្ធ ឃាតលុះនៃដៃតេជ្ឈាជ ។ ស្តេចសែនសោយ
សោតសង្វាត អាណិតអនាថ តែព្រះអង្គឯងឯកា ។

បទកាកគតិ

កាលនោះពោធី - សត្វសាងចារមី វត្តមោ ខឿនលំពុក្ខា
ឯកាខាថា ពុតិលឯកា ថ្ងៃនថ្ងៃនតុំចុន ។ ព្រះទេស្នាថ្ងៃន ទ្រង់ព្រះ

កន្សែង ពិលាបប្រះក្រាណាំ ជាតុអញ្ជើយ ម្ដេះហើយពុំបាន រីលវិនវៅថ្ងាន មាតាបិតា ។ តុអ្នកមានគុណ គុណគប់មហាធ្ងន់ ធ្ងន់ពេកក្ដាត់ណា ម្ដេះសមកូនក្ស័យ ជីវិតដន្ទា ឯកអង្គឯងអា. សារសោះសូន្យសល់ ។ កូនមកស្រុកគាយ ខោលអ្នកជាម្ដាយ កំព្រាពុំតិល មកស្ងាប់អសារ ឥតកាវេតកល នៅទាមណ្ដុល ដែនដីស្រុកគាយ ។ តុអញ្ជើអក៏ឮ ម្ដេចក៏មកស្ងាប់ ស្ងាប់បង់អ្នកម្ដាយ បង់អ្នកអាពុក បង់ស្រុកឯទាយ ដូរតចិត្តឈឺមាយ ស្រើបដោយតណ្ហា ។ មកស្មែងប្រពន្ធ បង់អ្នកមានគុណ ទាំងពីរអង្គា មកជល់នគរ បរិវេបញ្ចាល់ ចាន់បុត្រក្សត្រា ជាតួសម្ពន្ធ ។ តុទ្រង់អញ្ជើអើយ ឥឡូវម្ដេចឡើយ មុខរងើកុក្ខធ្ងន់ តែគួរគាក់យាក លំបាករពេកពន់ តែធ្វើទ័ងបុណ្យ អំណាចណាស់នៃ ។ តុអ្នកម្ដាយឆ្នាំ នោះម៉ាកូនចាំ ជាអចិន្ត្រៃយ ឥឡូវនេះណា រៀកពៀកើយ មកជល់នាថៃ្ង នេះឯងហោងណា ។ សមអ្នកទាំងពីរ តែងតរមិល ម៉ើលផ្លូវបុត្រា គិតស្នានកូនប្រុស រូបរៃសុខស. ប្បាយចាន់លាណ ក្រឡាប់រលៅ ។ មិនដឹងជាកូន ក្ស័យសោះសូន្យ ច្រាសព្រះបមចៅ ម្ដេះព្រះមាតា បិតាអ្នកនៅ សង្រែងក្ដាត់ចៅ ខន្ធីបុត្រចាត់ ។ តុអនិច្ចា ខ្ញុំនេះអើយកំព្រា ត្រូវមាចច្រាសត្រាត់ មកស្ងាប់អសារ កណ្ដាលព្រៃស្ងាត់ ស្ងាប់ម្ដេចដូចសត្វ ដោយដីច្នេះណា ។ ចៅម៉ែទ្ធឆ្ងាស់ ឲ្យ

មានគំនាប់ នៅស្រុកតិចណា ព្រះជនកព្រងើនខ្លី ក្សត្រីក្សត្រា ប្រ-
ជាប់ប្រជា លើកសពក្សត្រថ្ងៃ ។ ឥឡូវកូនស្ងាប់ ឯកអង្គអភ័ព្វ
កណ្តាលទ្រូងព្រៃ កូនយកប្រឹថព៌ ដែនដីនេះនៃ ជាមឈូសមាសមៃ
និព្រាវៅហោង ។ កូនយកអាកាស ជាពិតានមាស ថ្ងាថ្ងៃកន្ទុង
លើកសពអាត្មា គាលគ្រានេះម្តង តាមវៀរវង ចៀសតុំបានណា ។
កូនខ្លីឯយកព្រះ សុរិយោរៃនរះ ពីបូពិទិសា អាស្រ័យរស្មី ជាក្តីខ្លួ
លើកសពសង្ឃឹរ កូនគាលនេះម្តង ។ កូនយកប្រឹក្សា ជាកំឯនណា
ចិត្តជាំនប្រពៃ កូនយកសត្វសត្វ ស្រែជាតំក្នុងព្រៃ កូនខ្លីឯអាស្រ័យ
ពុកជាភ្លើងផង ។ ជាតួរឫតន្ត្រី ប្រគំប្រក្រតី លើកសពកូនហោង
តាមកម្មវៀរ គាលគ្រានេះម្តង កូវកូនខ្លីនវង តាមវិជាកជាន ។
ឧតតអ្នកណា ខ្លីឯអាចយាត្រា រៃលវិនវៅថ្ងាន ទូលព្រះបិតា មាតា-
ឲ្យជាន ជ្រាបថាកូនមាន ពុក្តពោសដល់ស្ងាប់ ។ ជាន់អ្នកខ្លីឯមក
ប្រយោជន៍ខ្លួវក រៀបចំប្រជាប់ លើកសពកូនជា បុត្រាធាប់ ។
ចរិបូណ៌ដោយច្បាប់ ដូចអស់ក្សត្រផង ។ ឧអម្ចាស់ថ្ងៃ ចាប់ដើមពី
ថ្ងៃ នេះឯងហើយហោង តុំបានឃើញកូន សោះសូន្យនេះម្តង សម
អ្នកខ្លីនវង ពុក្តពោមនស្ស ។ សម្តេចតូម៉ា ថ្ងាថ្ងៃឯទូញពី មាតា-
បិតា គាណិតអនេក ពន់ពេកណាស់ណា ហើយព្រះពាជា ទូញៅ
ប្អូនស្រី ។ ឧខាងបុម កេសរទត្តម រៃរាជក្សត្រី ម្ចុះសមបងប្អូ

ប្អូនសង្ឃរតី ថ្ងៃនេះឯងឥ ឡូវណាប្អូនអើយ ។ ខុមាសស្នេហ៍ស្និទ្ធ
បងបានដូចចិត្ត ចិត្តចិន្តាហើយ ល្ងីកអ្វីប្រែប្រាស ប្អូនមាសត្រាណ-
ត្រើយ ព្រលឹងចង់អើយ បងប្រណីណា ។ ខប្អូនបណ្តាច់
បណ្តូលសួតសាច់ សាច់សង្ឃរាក ស្រីតន់តែមួយ ជាត្រួយខយា បង
ចំនិយកជា អឃិអគ្គមហេសី ។ ម្តេចឡើយមកប្រាស ត្រាត់ព្រលឹង
មាស នាគ្រានេះឮ ហតុបាបបងឯង តែត្រូងជាតិ តាមទាន់ឯងឥ-
ឡូវនេះហោងណា ។ អញ្ជាថាក្សីណាក្សីយ ជីវិតប្រលំឃ ប្រាសព្រះ
ប្អូនកូ ខអាសូរខៅ នានទៅកំព្រា សមនានឧនិជា មេម៉ាយឯង-
ហោង ។ បងមហាប្រណី អាសូរប្អូនស្រី មាសមិត្តឥតគ្នន សមខៅ
សោយសោក អរោគក្សត្តាត់ហោង ចាំតែឈ្មោះបង ខ្ញុំនមិញមិន
យល់ ។ ខុយើងចាំងតាវ ឆ្ងាប់រៃបិតរថ មូលមួយមណ្ឌល ស្រ-
ឡាញ់ស្នេហ៍ស្និទ្ធ អប់ចិត្តអស់កល ជាបម្រុងកផ្តល់ ឲ្យបងបង់មេ ។
ខអង្គប្អូនមាស ថ្ងៃបងនឹងប្រាស លែងបានឆ្លាំផ្តែ ប្រាសម្តេចសោះសូន្យ
បងប្អូនមាសស្នេហ៍ ពុំបានឆ្លាំមេ មកមរណ៍អសារ ។ បងតិតខៅគ្រប់
គ្រប់ហើយរៃងឋប់ ឋប់ប៉ប្រការ ឋប់មួយជ្ឈិតប្រាស ប្អូនមាសត្រកាល
អាសូរអសារ ខៅឯងតំព្រា ។ បងឋប់មួយក្តី តិតព្រះជនន៍ ជនកជក
ចាស់ហើយរៃងប្រាស ទិកសប្បុត្រ សមអ្នកនឹងជា ខុក្នុងឯងច្នន់ក្រៃ ។ ឋប់
មួយសោតហោង ឯកឯងអគ្គបងឯ នេះណានឹងក្សីយ ជីវិតប្រែប្រាស ប្អូន

មាសារថ្មីមថ្ងៃ ក្រោកដនាថ្ងៃ ខេះឯងរហោងណា ។ ស្តេចទ្រង់ព្រះក- ខ្សែន
សោកស្រីតន់ រំពេជជាយា អាណិតអនាថ សល់ខ្លួតសោក
ជោរជលនេត្រា តុំស្បើយខ្សើយហោង ។ ក្សីណានោះក្សត្រី រំពេជ-
ខេវី អនុជស្នេហ៍ស្នង នាងឮថាតា ក្រោធាកន្ធង ព្រះអង្គខ្ញាល់ផង
ព្រះរៀមរាជ ។ ព្រះអង្គឱ្យចាប់ យកទៅសម្លាប់ បំបាត់ជន្ម នាងឮ
ស្ងាមី ត្រូវក្តីហើយណា នាងសោយសោក ពន់ពិលាបលន់ ។
នាងយកព្រះករ តាំងពីនោងគរ ទុកស្រីតន់ ហាក់ខ្លីងក្សីណាក្សយ
ប្រលែងដីពជន្ម នាងទ្រង់ព្រះក- ខ្សែនសោកខ្លួញថា ។ ទុអម្ចាស់ថ្ងៃ
បើព្រះអង្គក្សយ ខ្ញុំស្លាប់មរណា ស្ងាប់ផងជៀស្តជ័យ នាថ្ងៃនេះណា
ព្រមព្រះរាជា ស្មើឯកជីវី ។ នាងខ្លួញបណ្តើរ ស្រីរតន៍ប្រសើរ លី-
លាចុះតី ក្រាសាខមកទល់ មណ្ឌលជនទី ខើចនាងខើ ខ្លួលព្រះមាតា ។
បតិត្រព្រះមេ ជាមកុដសីរ គុណតម្លឹក សូមទានព្រះអង្គ ស្តេច
ទ្រង់ករុណា អាសូរខ្ញុំជា កូនកាលខេះម្តង ។ ឥឡូវកូនស្លូន មាន
ខ្លួកកន្ធខ្លួន ឆ្នូនក្រែកន្ធង ជ្បាតព្រះបិតា ក្រោធាខ្ញាល់ផង ប្តីខ្ញុំឯងរហោង
ពន្ធុកមហិមា ។ សូមអ្នកមេរៀ ក្រាបខ្លួលព្រះបៀ ព្រះរ៉ះបិតា ខ្លួល
សូមជីវិត ស្ងាមីខ្ញុំណា កុំឱ្យរាជា ពិឃាដបង់ជាត់ ។ ជ្បាតបុត្រព្រលឹង
ជាខ្ញុំមកនឹង ប្រុសមានរូបរតន៍ បើព្រះបិតា ក្រោធាពេកក្តាត់ មិនអ-
សូរសត្វ ដល់តិចឡើយណា ។ សូមប្បីខ្ញុំក្សយ ជីវិតប្រលែយ មួលមួយ

ផងគ្នា សឹមទៅយកប្តី ស្វាមីស្នេហា រួមហ៊ានទៅនា ស្រុកភ្នោចខោះ
នៃ ។ ព្រះមាតាស្តាប់ បុត្រទូញទូលទ្រាប់ ទ្រាបព្រះហឫទ័យ អាសូរ
ពដបុត្រ ទ្រហឹកដដេកក្រៃ បន្ទូលថាកៃហា កូនស្ងួនតុំណា ។ កុំលស់ទុក
ខ្លៅ ៤ ព្រលឹងម្តាយអើយ ម្តាយនឹងទៅណា ទៅទូលអង្វរ ព្រះវេចិតា
ឲ្យទានឯកាលគ្រា នេះឯងកូនអើយ ។ ទើបទានឯនាថទៅ ទូលតាស់ព្រះ
ទៅ តិតភ្លុលដំខ្លើយ បពិត្រព្រះមហា ក្សត្រាក្រាណាត្រើយ សូមស្តេច
លំហើយ លះបង់ក្រោធា ។ អាសូរកូនស្ងួន តាទុកឱ្យមួយខួន ឥឡូវ-
នេះកំ ចានជាអាល័យ នឹងក្តីយផងគ្នា សូមស្តេចករុណា អត់ទោស
ទៅហោង ។ មិនតែកូនយើង នេះនឹងចេះឯង ក្រៅប្លាប់តទួង និយាយ
ចុកណា សឹងមានច្នេះហោង សូមទានកុំចង ព្រះទ័យក្រោធា ។
ក្សត្រិណានាងភូមី ស្តាប់ពដទេវី ទូលដូច្នោះណា ស្តេចទ្រង់ព្រះក្រោធ
តិរេធមហិមា បន្ទូលត្រាស់ថា មិនកុំធ្វើច្នេះ ។ កូនតាចតាច់ខ្លាស
ឲ្យអស្រូវតោស មុខតញ៉ាំងម៉្លេះ ដ្បិតតំនិតហោង · សមផងពាក្យនេះ
ខ្លីបខ្លៀវបៃតោះ លុកលៅមក ។ បើពាចនាស្តាប់ អញសោតតុំ
ពាប់ ទុកស្មើឈាមតក បងមេ្លៀតដោយដី កុំបីមឹងមក ស្រងឹរ-
រក អង្វរអញឡើយ ។ ឯព្រះមាតា ស្តាប់ព្រះពាក្យ បន្ទូលច្នោះ
ហើយ នាងភ្ញាចភូមី ឥតបីហ៊ានឆ្លើយ សាសងខ្មៀតហើយ
នាងនាថក្រាបលា ។ មកដល់បុត្រី ទើបនាងជនទី ទុនទុបបុត្រ

ក្តី ទ្រង់ត្រេកអែន ថ្វាយថ្វៃទ្រាប់ថា នាងអើយបិតា ក្រោធពន់ពេក
ក្រៃ ។ ដេរដាលដល់ម្តាយ ខ្ញាល់ណាស់នាងអាយ ក្រោធក្រៃវិស័យ
កំម្តាយកំតុខ្លាច ព្រះពជហ្ចឹយ ដូចកូនមាសមៃ ដំនរហើយណានាង ។
នាងនាថទេវី ស្តាប់ព្រះជនន៏ ទ្រាប់ដូច្នោះណា នាងយតព្រះករុតត់តរុក
សែនសោយសោកា ពន់ពាំលាបលន់ ។ នាងពូលមាតា ខ្ញុំសូមក្រាបលា
អ្នកមានគុណធ្ងន់ ដ្បិតខ្ញុំធំងក្សយ ប្រល័យជីពជន្ម ថ្ងៃនេះឯងអ-ន្តរាយ
តាមប្តី ។ ព្រះវរមាតា ស្តាប់បុត្រពូលា ទំនឹងយោងខ្លី នាងនុចកូន
រតន៏ លេមយាត់បុត្រី នាងអើយកុំប៉ី កូនតិតច្នោះណា ។ ម្តាយសោត
ចាស់ហើយ ព្រលឹងម្តាយអើយ ម្តាយមានឱនាងជា កូនស្រីតែមួយ ជា
ត្រួយខយា ភ្នែកម្តាយនេះណា ផ្ទើលើនាងហោង ។ ពីរពង្សត្រកូត្រី សែន
សោយសោកតិ· លាបលន់កន្ទួង សឹងសន្ធប់លង់ ពីរពង្សជាម្តង ហេតុដូចតែរឯ
ទុក្ខពៀងសោតសោះ ។ នេះទំនឹងស្រដី ដំណើរអំពី អស់ពេជ្ជ·
ឃាដនោះ នាំព្រះអង្គដល់ មណ្ឌលព្រៃស្មោះ ដោយចិត្តចំពោះ បំនិទីន
តិយាម ។ កាលនោះពោធិ· សត្វសាធជាមិ ប្រសើរសល់ខ្លាត ការនាព្រះ
ធម៌ សម្មាជាអាទិ៏ សម្តែចនានាថ ពុំភ្លេចធម៌ថ្ងៃ ។ ទើបស្តេចត្រាស់ថា
ថៃអស់តំនិត្តា បងថ្លូននេះនៃ សំណើកអាត្មា អញណានឹងស្ងួយ
ប្រាកដនាថ្ងៃ នេះឯងហោងណា ។ អញមានព្រួញថ្ងៃ មួយមានដំឡៃ
ប្រពៃមហិមា រូបកដហង្សមាស ឆ្នុះឆ្លុះថ្ងៃថ្លា អញទុកនៅនា ចុង

រឿមមុខហោះឆ ។ អញនឹងឲ្យជា វង្វាន់អស់គ្នា កាលត្រានេះម្តង ចៃគ្នា
ស្រួលៗគ្រាន់ នាំអញទៅផង ដល់ឈើហើយហោង អ្នកឡើងយកណា ។
អស់ពេជ្យឃាដស្តាប់ ព្រះអង្គថ្លែងប្រាប់ ត្រេកអរណាស់ណា ត្រៀបគ្នាក៏ទៅ
សំដៅត្រីក្បា ទើបត្រូវពាជា ទ្រង់នាំទៅដល់ ។ ក្រោមដើមត្រីក្បា ទើប
ត្រូវពាជា បង្ហាញឲ្យឃើញ រួមហាឫទ្ធាសមែ ថ្វាយថ្វៃសួស្តីសព្ទ នៅ
នាមណ្ឌល បមបុនត្រីក្បា ។ ឯអស់ពេជ្យឃាដ យល់ហាឫទ្ធាសស្អាត
ត្រេកអរមេហ៊ាមា ដល់ណើមគ្នាពាន បន់ប្រាន់សុំណា គ្នាទូរស្រែកថា
ឲ្យអញឯងពាន ។ ទូរសោតថាទៅ ចំណោះអ្នកថា ថៅនឹងឡើងបាន ឈើ
សោតធំលន់ ខ្ពស់ពាន់ប្រមាណ អត់ឲ្យអញភាន ម្នាក់ឯកុំណាកំ ។
គ្នាទូរពាន់ឡើង គ្នាទូរចាប់ជើង កើចចុះវិញណា ដល់ណើមគ្នាឯង កោង
ក្រែងអាត្មា រួមតហត្ថា ជ្លាក់ចុះដល់ដី ។ យើងយល់គ្នាជ្លាក់ ស្ទុះទៅ
កន្ត្រាក់ ដៃជោះឡើងខ្ទី មិនឈប់មើលអញ ឡើងវិញភ្លាចអ្វី យក
ទ្បាន៥ ឡូវនេះហោងណា ។ កុំណាស្ទុះទៅភាន ប៉ុនបំងឲ្យបាន
ដួចចិត្តចិន្តា ធ្វើហាក់ឯងស្អាត កុំណាក្លាត់បាត រួមតហត្ថា ជ្លាក់
ចុះវិញហោង ។ ឯពេជ្យឃាដណា ទំឡើងត្រីក្បា ច្រើនគ្រាច្រើនជង
តុំបាន់ដួចចិត្ត តំនិតប៉ុនប៉ង ស្រេចដៃហោង ឈរមើលខណា ។
តេជៈបារមី សម្តេចជិនស្រី សាពិជ្ញាស្តា តុំឲ្យពេជ្យឃាដ នេសាទនោះក់

ទ្បើងដើមត្រីក្ស រួចដល់មួយនៃ ។ ក្សីណាខោះព្រះបាទ សម្តេចនរេន្ទ
ធិរាជរៀស្តេជ័យ ទ្រង់ព្រះចិត្តា ប្រាជ្ញាចំពូថ្ងៃ ចន្លូលថាហៃ បងប្អូន
តាំងឡាយ ។ ចូរបបួលគ្នា ទោមដើមត្រីក្ស ស្រែចហើយគ្នាស្រាយ
អញនឹងទ្បើងយក ចុះមកតាំងវាយ ឲ្យអ្នកតាំងឡាយ ជារង្វាន់
ណា ។ តេជ្ឈឃាដស្តែងស្តាប់ ស្តេចបន្ទូលប្រាប់ ត្រេកអរគ្រប់គ្នា
មកស្រាយតោធ- សត្វវិសេសា ប្រាកដហើយណា ទោមជុំវិញ
រហាង ។ កាលខោះតោធ- សត្វរួចអំពី ចរបូណាឥតឆ្ងល ស្រែច
ហើយក្សត្រៃថ្ងៃ ប្រតៃច្បាស់ច្បង ទ្បើងឈើដូចបង ពុំលង់ទ្បើយ
ណា ។ សម្តេចនរសពល ស្តេចទ្បើងតៅដល់ លុះលើរុក្ខា ខ្ពស់
តន់តេកក្រៃ ក្សត្រៃថ្ងៃធ្វើជា តិតភ័យមហិមា ស្ទើរទ្បើងពុំបាន ។
ឯអស់តេជ្ឈឃាដ យងំយល់ព្រះបាទ តកត្រូងតក់ប្រាណ គ្នាទ្រុះ
ស្រែតថា អាចោរសាមាន្យ បើទ្បើងពុំបាន ចុះមកវិញណា ។ ទើប
ព្រះអង្គត្រើច ថាអស់គ្នាហើយ កុំតិតអញ្ជាំ សំណឹកនឹងក្ស័យ នា
ថ្ងៃទោះណា កុំបីអស់គ្នា តិតអញ្ជាទ្បើយ ហាន ។ សែងតែតិតអញ្ជា
បាន រួបហាងរួមាសមាន ដំរៀកខ្នួន ឲ្យជារង្វាន់ ត្រប់ត្រាន់អស់
បង ប្អូនតាំងនេះហាន ដូចចិត្តប្រាថ្នា ។ ស្តេចទ្បើងតៅដល់ ហ៊ន្ស
យន្តនិមល ហើយទ្រង់ចិត្តា អញ្ជាចង់ខ្មាក់ មាសប្រាក់ស្បែរ តិតខ្លួន
កុំគ្រា ដល់តិចទ្បើយនៃ ។ (នៅមានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមកាន់ទុក្ខសពនៃសាមញ្ញជនជាតិខ្មែរ

ហោ ង៉ូ–ង៉ូ រៀបរៀង

សំណួរ– គួរឲ្យនឹកឆ្ងល់ថា នៅវេលាមានបុណ្យសពនៃសាមញ្ញជនទីមួយៗ គេតែងឃើញក្រុមគ្រួសាររបស់សព អ្នកខ្លះគោរសក់, អ្នកខ្លះមិនគោរសក់, អ្នកខ្លះស្លៀកពាក់សំពត់គាវស, អ្នកខ្លះស្លៀកពាក់សំពត់គាវភ្លៅ ឬក៏គ្រាន់តែយកកំណាត់សំពត់ភ្លៅមួយបន្ទះភ្ជួចខ្ទាស់ក្បាលនឹងគាវក៏មាន, ការដែលគេធ្វើយ៉ាងនេះ តើជាខុសឬត្រូវ, ហើយគេប្រកាន់យកអ្វីជាគោលការណ៍ ?

ចម្លើយ - សូមដោះស្រាយប្រស្នានេះថា បណ្តាជនជាតិខ្មែរនៅស្រុកស្រែចម្ការ ច្រើនតែគោរសក់ ហើយស្លៀកពាក់សំពត់គាវសកាន់ទុក្ខសព តាមទម្លាប់ដែលបានសុំគ្នាប់ធ្វើតៗគ្នា តាំងពីព្រេងនាយជាប់ជាទំនៀមរៀងរហូតមកដល់សម័យនេះ ។

តាមយោបល់នៃលោកអ្នកប្រាជ្ញជាតិខ្មែរខ្លះយល់ថា ការដែលបណ្តាជនជាតិខ្មែរគោរសក់ ហើយស្លៀកពាក់សំពត់គាវសកាន់ទុក្ខសពនោះ ដោយប្រកាន់តាមក្បួនច្បាប់ក្នុងព្រះពុទ្ធ ឬសនាជាគោល ដូចជាការគោរសក់ជាប្រស្នាសម្រាប់តិចារណាឲ្យយើញថា សក់ដែលគោរ

អស់រលើនហើយ តែងតែដុះឡើងវិញជាមិនខាន ប្រៀបដូចធម៌មនុស្ស ស្លាប់ទៅហើយ ទៀងតែកើតឡើងទៀត ហើយសោយសុខទុក្ខទៅ តាមផលបុណ្យ-បាបរបស់ខ្លួន ។

ចំណែកសំពត់អាវមានពណ៌ផ្សេងៗជាច្រើន ប៉ុន្តែ ពណ៌ស ជា ពណ៌អាចផ្លាស់ប្តូរប្រែប្រួលទៅជាពណ៌អ្វីៗ ដទៃទៀតបាន គឺជាដើម តាល់ប្រឡាក់ខ្មៅវត្ថុមិនស្អាតណាមួយ មានឆ្ងល់ជាដើម តែងក្លាយទៅ ជាសំពត់ក្រខ្វក់អាក្រក់ដោយឆ្ងល់ប្រឡាក់ មិនទៅជាពណ៌ស ស្អាតតាម ភាពដើមវិញទេ ។ ពណ៌សនេះ ទុកជាប្រស្នាមួយ សម្រាប់ឲ្យគិតពិចារ-ណាប្រៀបធៀបទៅនឹងរូបមនុស្ស ដែលតែងផ្លាស់ប្តូរប្រែប្រួលពីក្មេងទៅ ជាចាស់, ពីជាទៅជាឈឺ, ពីរស់ទៅជាស្លាប់ ។

ពួកអ្នកតុខ្លះសន្និដ្ឋានយល់ឃើញថា សំពត់ពណ៌សមានប្រយោជន៍ដ៏ សំខាន់យ៉ាងនេះហើយ ជាដាក់ទិយមស្លៀកពាក់សំពត់អាវសកាន់ទុក្ខ សព ។

ម្យ៉ាងវិញទៀត ការប្រើសំពត់ស ជាការចាំបាច់ក្នុងន័យវិជាវណា ធម៌ ដ៏មានអតីតនិទានក្នុងគម្ពីរពុទ្ធសាសនាថា :

"កាលព្រះបរមសាស្តានៃយើងគង់ព្រះដន្ទៅទៀយ, មានព្រះថេរៈ មួយរូបព្រះនាមចូឡបន្ថកៈ ចូលទៅគាល់ព្រះសាស្តាក្រាបថ្វាយបង្គំលា សឹក, ព្រះពុទ្ធអង្គទ្រង់ប្រទានកំណាត់សំពត់សមួយផ្ទាំងតូច ឲ្យ

យកទៅអង្គុយឈ្លីកណ្តាលវាលហាលថ្ងៃ ហើយឲ្យសំឡឹងមើលសំពត់ស
ដែលខ្លួនឈ្លីនឹងឲ្យខ្នេញថា " សំពត់សនេះមិនស្អាតទេ, សំពត់នេះមិន
ស្អាតទេ" ។

ព្រះថេរៈ ខលួនព្រះពុទ្ធដីកាយកសំពត់សព្រះហស្តចេញទៅអាង
ក្រៅអង្គុយកណ្តាលវាលហាលថ្ងៃ ដៃឈ្លីសំពត់ស ភ្នែកសំឡឹងសំពត់ស
មាត់ខ្នេញអ្វើថា "សំពត់សនេះមិនស្អាតទេ, សំពត់សនេះមិនស្អាតទេ"
មិនយូរប៉ុន្មាន សំពត់សដែលសោកឈ្លីនោះ ប្រឡាក់ភ្លើសក្អែលដៃ
ទៅជាបៃស់ភ្នៅក្រខ្វក់ លែងសស្អាតដូចពីដើម ។ ព្រះថេរៈឃើញដូច្នោះ
កំកើតព្រះវិយសង្វេគតក់ស្លុតតិចារណាឃើញថ្លង់ដែលមិថា "រាត្តិនឹងអស់
ជាបៃស់មិនខ្វៀងខាត់ទេ, ជាបៃស់នាំឲ្យកើតទុក្ខទោស, មិនមែនជា
បៃស់ខ្លួនសោះឡើយ" ទៅទីបំផុតនៃការពិចារណាធម៌ ព្រះថេរៈបាន
សម្រេចព្រះអរហត្តផលនៅពេលនោះឯង ។

អាស្រ័យរឿងព្រះចូឡបន្ថកថេរនេះជាគោលអាង បានជាបណ្តាជន
ជាតិខ្មែរអ្នកគាន់ធម៌ក្បាស័លក្តី អ្នកគាន់ទុក្ខសត្តិ ច្រើនតែស្ទុះតាក់
សំពត់អាសៈ ឱនច្រើនតែគោរសក់ផង ។

សូម្បីក្នុងច្បាប់ព្រះពុទ្ធសាសនាក្រុងកម្ពុជា កំរើញមានសេចក្តី
ប្រកាសឲ្យប្រជាពស្ត្រខ្មែរប្រដាប់គ្នាគោរសក់ , ស្ទុះតាក់សំពត់អាសៈ
គាន់ទុក្ខព្រះបរមសព្តនៃព្រះមហាក្សត្រៃបៃស់ខ្លួនដែរ ។

ប៉ុន្តែ សព្វថ្ងៃនេះ ឃើញមានបណ្តាជនជាតិខ្មែរខ្លះ ស្លៀកពាក់សំពត់អាវខ្មៅ ឬក៏គ្រាន់តែខ្លាស់បន្ទះសំពត់ខ្មៅបន្តិចក្បាច់នៅអាវស ជាគ្រឿងសំគាល់ថា ខ្លួនកាន់ទុក្ខសព ។ ការដែលធ្វើយ៉ាងនេះ មិនមែនធ្វើតាមទំនៀមទម្លាប់របស់ជាតិខ្មែរតាំពីបុពណ្ណកាលមកទេ គឺគេធ្វើតាមតួកអឺរ៉ុបដែលចូលមកនៅក្នុងប្រទេសខ្មែរ ។

នៅចំបំផុតនេះ សូមដោះស្រាយបញ្ហាប្រស្នាខាងដើមនេះថា អ្នកកាន់ទុក្ខសព គេរកាសក់ក្តី មិនរកាសក់ក្តី ស្លៀកពាក់សក្តី ឡើងក្តីឬពណ៌អ្វីឯទៀតក្តី ទីដ៏អាចាត់ថា អ្នកណាធ្វើខុស អ្នកណាធ្វើត្រូវ ក៏មិនបាន ព្រោះព្រះពុទ្ធអង្គមិនបានបញ្ញត្តពីរឿងកាន់ទុក្ខសពនេះទេ ស្រេចតែគេធ្វើតាមទំនៀមទម្លាប់របស់ជាតិគេ រឿងណាដែលមានព្រះពុទ្ធប្រកាសជាការចាំបាច់ ខានមិនបាន ។

បរិយាយអំពីរបៀបកាន់ទុក្ខសពនៃប្រជាពលរដ្ឋខ្មែរ ចប់តែប៉ុណ្ណេះ ។

កណ្ដាទី ៣៦

នាយវីរុលាជសេនា ស្វ-ភិន ប្រមៀបរៀង

(តមក)

រឿងសាមតុកកុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
នឹងបេះខុបាយកលចំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ស្រួតទៅចាំចំឡងតាំងអស់គ្នា លុះអ្នកស្រុកធ្វងអស់ហើយ ទ្បៅតាកំនាំតាំងស្រី តាំងប្រុស ចាស់ក្មេង លើកទៅដល់ស្រុកសុងយ៉ុង ទីនិចូលទៅក្នុងស្រុកគឺមិនបាន ទ្បៅតាកិជិរសេះត្រឡប់ទៅតាមដើងកំពង់ ហើយស្រែកហៅទ្បៅចងថា ក្មួយអើយអ្នកកុំមានសេចក្តីសង្ស័យ យើងលើកមកនេះមិនមែននឹងធ្វើប្រទូសកំងអ្នកទេ យើងមកដោយសេចក្តីអាណិតអាសូរអ្នកស្រុកតាំងអស់គ្នា ចូរក្មួយបើកទ្វារឲ្យយើងចូលទៅចុះ ។ ឯឈ្មួញនឹងទៀតអ៊ុន យើញទ្បៅតាំងវាងឆ្ងាយមកស្រែកហៅឲ្យបើកទ្វារដូច្នោះក៏ឡើងទៅលើសើន ឲ្យតាហានបាញ់ដួចម្រុះចេញមក ។

ខណៈនោះ អ៊ុយអៀនជាពួកស្រុកងីយ៉ុង ខ្ពស់ ៦ ហត្ថ មុខក្រហម

ពណិជ្ជបង្ហែតុត្រាទុំ នៅក្នុងស្រុកខោះ ស៊ុះឃើញឈ្មួញម៉ែនឆែវៀតអ៊ុនធ្វើដូច្នោះ ក៏លើកពួកម៉ាកប្រវែលទ៥០០នាក់ទៅត្រង់ច្រាំងស្រុក ស្រែកដេរឈ្មួញម៉ែនឆែវៀតអ៊ុនថា ឯងនេះជាសត្រូវលក់ម្ចាស់ មកធ្វើដូច្នេះ គួរហើយឬ ? ។ ឡៅពីនេះ ជាមនុស្សចិត្តល្អនឹងអាណាប្រជាពុកស្តេចតំណាងស់ ដែលលើកមកនេះ ព្រោះសង្គ្រោះដោះពុកស្តេច មួយទៀតបិតាអ្នកស្នាប់តំបន់ឆ្នាំឆើកចុងការសុំទ្រុងនឹងឡៅពី ហេតុម្តេចឯងមិនឲ្យឡៅពីចូលមក ជាដូច្នោះហើយ ក៏យកជាវដេញតាប់តាហានដែលនៅរក្សាច្រាស្នាប់ខ្លាត់ខ្លាយអស់ទៅ ទើបច្រានបើកច្រាស្រុកចេញទៅទួលឡៅតស្រែកថា អញ្ជើញលោកនាំបណ្តាអ្នកស្រុកតាំងអស់គ្នាចូលមកចុះ ចូរជួយកំចាត់សត្រូវលក់ម្ចាស់ចេញ ។

ឡៅតឮដូច្នោះ ក៏អរណាស់ ទើរនាំតាហានទាំងបណ្តាអ្នកស្រុកចូលទៅ ទួលជួបទាំងប៊ុនផង លើកតាហានមក ឃើញ អ៊ុយអៀនបើកច្រាទួលឡៅតដូច្នោះ ក៏ស្រែកដេរថា ឯងគ្រាន់តែជាកូនតាហានគ្មានន័យណាកប់អាន័សោះ ហេតុម្តេច ក៏មកបើកច្រាទួលឡៅតឲ្យចូលមកដូច្នេះ ឯងនឹងចង់ឲ្យស្រុកនេះកើតចលាចលឬ ? ។ អ៊ុយអៀនឮ ប៊ុនផង ដេរប្រមាថដូច្នោះ ក៏ខឹងណាស់ បន្ទរសេះចូលទៅតយុទ្ធគ្នាទាំងប៊ុនផង ជាតន្ទឹក តាហានតាំងសងខាងក៏ចូលតដៃគ្នាជាច្រួលច្របល់រឹតវែឡើង ។

ខ្ញុំតាយើញដូច្នោះក៏ថា យើងមកគ្រានេះតាំងចិត្តនឹងអនុគ្រោះបណ្តាកស្ត្រីតាំងពួនឲ្យបាននេះចក្តីសុខត្រមមួលគ្នា យើងមិនខានន្តឹងចូលទៅដល់ស្រុក ម្តេចក៏មកបណ្តាលខាសខែងគ្នាឲ្យតាំងតាប់សម្ងាប់តែរដូច្នេះ ត្រឡប់ឲ្យបណ្តាកស្ត្រីកន្លែងស្រុកនឹងខាងក្រៅស្តែកក្រហាយទៅវិញ បើយើងចូលទៅហើយនឹងមិនកើតរឹតរដាងនេះទៅទៀតឬ ? ដែលយើងតាំងចិត្តជួយឲ្យជាប្រយោជន៍នោះ ក៏នឹងអសារឥតការទេទៅ ដូចយើងចូលទៅធ្វើឲ្យបណ្តាកស្ត្រី ជាន់ខ្លួនក្តៅឡើងទៀត យើងក៏មិនចូលទៅទេីយ ។ ពុងបង្ហាញ ថា: ចើដូច្នោះស្រុកតាំងឡើងក៏ជាទីដែនចំណុះស្រុកគេដដែរ សុំឲ្យលោកលើកលែងទៅស្រុកនោះចុះ ដើម្បីនឹងជាន់ការតារក្សាខ្លួនដោយស្រួល ។ ខ្ញុំតាយល់យើញត្រូវ ក៏នាំគាហាន់នឹងបណ្តាកស្ត្រីតាំងនោះ លើកទៅស្រុកតាំងឡើង ។

ឯពួកអ្នកស្រុក សុងយ៉ុង យើញកើតចលាចលរឹតរដូច្នោះ ក៏នាំគ្នាលើកគ្រប់គ្រួតាមទៅជាច្រើនណាស់ ។ អ៊ុយអៀន ទើបចុះដេងច្បាំងគ្នាតាំងពីព្រឹកដល់ថ្ងៃត្រង់គាហាន់តាំងសងខាង របួសតិការស្លាប់ជាច្រើន អ៊ុយអៀន គស្ងើនឯកម្លាំងចុះដេងមិនបាន ក៏ញាក់សេះរះរេះចេញទៅក្រៅស្រុក នឹងទៅពេទ្យតាមប្រទះ ក៏តប្រះទៅទៅនឹងហាន់ហៀន ចៅហ្វាយស្រុកខៀនសា ។ ឯទ្យតាលើកគ្រប់គ្រួជួលប្រជល់ទៅគ្រានោះ មនុស្សប្រហែល ៩ ម៉ឺន លុះទៅដល់ទន្លេទ្យតាបៀរ

កំឲ្យឈប់ខ័ត្តសំពាក ខ្ញុំតាកំពុងតែលើសេះចូលទៅតំនាក់សពរឿងរៀវ
ហើយយំសោកថា លោកជាបងបានផ្តែផ្តាំខ្ញុំគ្រប់ខ្ញីពីដើម ឲ្យខ្ញុំខំខ្នុក
បំរុងក្មួយថៅ ខ្ញុំតែងខ្ចាំពាក្យលោកទាំងអស់ តែឥឡូវនេះ ខ្ញុំតែធ្វើមិន
រហូត ទោសកំមានដល់ខ្ញុំច្រើនណាស់ សូមឲ្យលោកអត់ឧនខ្ញុំ
ទោសនោះដល់ខ្ញុំផងចុះ ប៉ាជូចលោកបានសង្គ្រោះជោះខ្ញុំ អាណា-
ប្រជានុកស្តេចាំងពួង ជួយឃុំគ្រងរក្សាឲ្យបានសេចក្តីសុខតទៅ ។

កាលខ្ញុំតាចូលទៅតំនាក់សពយំសោកអាល័យខ្ញុំរៀវ
ដូច្នោះ មានចំរើសេះមកប្រាប់ថា ឥឡូវចូរឆ្លៀតកងខ័ពកខ្លួនចូលមកដល់
ស្រុកអ្នកសិនៅ ហើយកំពុងចាត់ចែងខ្លួនធ្វើតាមមកខ្លាំង ។ តាហានតាំង
ពួងឮដូច្នោះ ក៏នាំគ្នាទៅដំរាបខ្ញុំតាថា លោកនឹងមកប្រកួតប្រកាន់កំណាន់
ចិត្តតិតដល់គ្រប់គ្រងតាំងអស់ខេះ មិនបង់លើកទៅឲ្យនាប ដើរខ្លាត ១ ថ្ងៃ
ត្រូវ ។ ដូច្នេះឃើញថា រត់មិនផុតទេ បើបួងតាមមកចាន់ នឹងមិនបង់តា
ថ្លង់ឆ្ងាយទៅទេឬ? សូមឲ្យលោកចាលគ្រប់គ្រងតាំងខេះទៅចុះ ខំស្រួតត្រង
ទៅខាងមុខឲ្យដល់ស្រុកតាំងឡងសិន ព្រោះស្រុកតាំងឡងជាទីសំខាន់
នឹងការពារគេស្ទឹងបានច្បាស់ ។ ខ្ញុំតាយំបណ្តោះនិយាយបណ្តោះថា
ប្រពៃណីអ្នកមានប្រាជ្ញាប្រាថ្នានឹងគិតធ្វើការធំមាំមួនខោះ រមែងនឹងតាំងចិត្ត
គ្រប់គ្រងការពារអាណាប្រជានុកស្ត្រី ឲ្យមានសេចក្តីមេត្រីស្រឡាញ់ ឲ្យ
អស់អញ្ជលីគេញាអាត្មា គំនិតខោះជាប្រសិនលើ ទើបមិនសំរេចផល

ប្រយោជន៍ចាន ឥឡូវបណ្តាកស្តេចាំងអស់នេះ មានចិត្តអាណិតយើង ស៊ូជំនះដោយតាមដេយ មកដោយលំបាកជាទីបំផុត យើងនឹងដោះរត់យកតែខ្លួនទៅមុនចាលឲ្យទៅកំព្រាខ្លួនឯង កំជាការមិនគួរសមសោះ ។ បណ្តាកស្តេចាំងអស់ ឮខ្មៅតិនិយាយដូច្នោះ កំយំសោកចាំងអស់គ្នា រឹតតែមានចិត្តស្នេហាស្រឡាញ់ខ្មៅតិជាច្រើនណាស់ ។

សាមកុកខ្មែរ ៣៧

តាំងតាំងពីពុងបេង, ខ្មៅតិ ប្រើតួនអ្នកទៅសុំទឹកខ្មៅតិមកជួយ ក្នុងលើកចួលទៅស្រុកសុងប៉ុងបញ្ជោតស្តម្ងាប់ខ្មៅបងនឹងម្តាយស្លាប់ ហើយលើកតាមខ្មៅតិ, ពុងបេងចុះទូកទៅនៅបន្ទាយហែទៅ ។

ពុងបេងនិយាយទីនឹងខ្មៅតិថា ឥឡូវបងធ្លុលើកទ័ពជាប់តាមមកជិតតាន់ហើយ សុំលោកប្រើតួនអ្នកស្រុកទៅប្រាប់ខ្មៅតិឯស្រុកកាំងហែឲ្យលើកទ័ពទូកមកជួយបញ្ចូលគ្នានឹងកងទ័ពស្រុកកាំង ឡង ។ ខ្មៅតិកំយល់ឃើញត្រូវ ទើបប្រើតួនអ្នកទីនឹងស៊ុនខៀនកាន់សំបុត្រទៅ ឲ្យខ្មៅតិលើកកងទ័ពទូកមកជួយ ហើយឲ្យជូឡុងនាំត្រប់ត្រួតាំងពួង ឲ្យខៀវហ៊ុយនាំតាហានលើកទៅជាកងទ័ពក្រោយសម្រាប់ការពារ ខ្មៅតិកំដើរតៀរប្រមូលត្រប់ត្រួទៅតាមផ្លូវ ១ ថ្ងៃបាន ១០០សិន (៤ គ.ម.) ។

ឯបច្ចូគាលលើកទ័ព ៣ដល់ស្រុកអ្នខសៀហើយ កំស្រុតរួតនាំពាហានតាំងតួងឆ្នងទៅស្រុកសុនយ៉ុង លុះទៅដល់ហើយ កំឲ្យបំរើទៅហៅខ្លៅចង់ឲ្យចេញមក ។ ឈួម៉ុងឆីរៀបអ៊ុន កំនិយាយនឹងខ្លៅចង់ថា មហាឧបកជលើកមកដល់ស្រុកហើយ ឲ្យចំរើមកហៅលោកចេញទៅគាប់ កំគួរនឹងចេញទៅគាប់តាមទម្លាប់ប្រពៃណី ។ អង្គអ៊ុយឌីប្រឹក្សាបច្ចូលទៅទូលប្រាប់ខ្លៅចង់ថា ពីដើមលោកនឹងទៅចំណុះចុះបច្ចូលបច្ចូគ៌ពិតមែន ឥឡូវនេះឮតែតត់ព័ចូដូទៅមិនបានតស៊ូទេ ឃើញថាបច្ចូគ្រានេះ មានចិត្តទ្រើសទ្រនង់អង់អាចណាស់ មិនបានចាត់ចែងនឹងក្បាច្ចូនឲ្យមាំមួនដូចពីដើមទេ មុខជាធ្វេសប្រហែសណាស់ហើយ នាំឲ្យណាមនុស្សពាំងតួងកំនឹងដឹងឮប្រាកដ ថាលោកមានដម្រេះប្រាជ្ញាចេះរិះគិតតែតែគោតខ្ចាចដែលនឹងគិតការធំតៈទៅទៀត កំគង់នឹងមានអំណាចសម្រេចតាមប្រាថ្នា ។ ខ្លៅចង់កំយកសំដីដែលអង្គអ៊ុយនិយាយនោះទៅប្រាប់ឈួម៉ុ ។

ឈួម៉ុឮដូច្នោះ កំឲ្យហៅអង្គអ៊ុយចូលទៅហើយនិយាយថា ខ្ញុំឯងនេះ មិនបានដឹងប្បាស់លក្ខណៈដែនដីដែលនឹងវិនាសនឹងចំរើន ហេតុម្តេចឯងព្រហើនអាចហានចរចាដូច្នេះ ។ អង្គអ៊ុយបានឮឈួម៉ុនិយាយដូច្នោះខឹងណាស់ ទ្រើយថា អាសត្រូវលក់ខ្លួនស់ គាស់ណាអញនឹងបានស៊ីសាច់អាឯងទើបអញអស់ខឹង ។ ឈួម៉ុឮដូច្នោះ កំបង្គាប់ពាហានឲ្យចាប់អង្គអ៊ុយយកទៅសម្លាប់ ។ គេនិងអ្នតកំយាត់ហាមសួមទោស

អង្គអ៊ុយ ។ ឈួម៉ក៏នាំខៀវអ៊ុនចេញទៅគំនាប់ចូលឆ្ពោះក្បែរប្រាំងស្ទឹងនិងធ្វើ ។ ចូលសួរថា តើឯងជែនជែលឡើងស្រុកកេងដីវនេះ មានស្បៀងអាហារនិងពស្ត្រចំណុះស្រុកតាំងអស់ប៉ុន្មាន ? ។ ឈួម៉ឆ្លើយថា មានភាហានសេះ៥ម៉ឺន, ភាហានថ្មើរជើង ១៥ ម៉ឺន, ភាហានខ្លួក ៨ ម៉ឺន, រួមផងគ្នាត្រូវជា ២៨ ម៉ឺន, ឯស្បៀងអាហារនោះបានប្រមូលពុកជាក់ក្នុងស្រុកតាំងខ្លួនជាច្រើន បើប្រមូលផ្សំគ្នាត្រប់ខែត្រតាំងអស់និងស៊ីបានប្រហែល ១ ឆ្នាំ ។

ចូលសួរថា ខ្លួកបម្បាំងមានចំនួនប៉ុន្មាន ? នរណាជាអ្នកបង្គាប់បញ្ជាត្រួតត្រា ? ។ ឈួម៉ឆ្លើយថា ខ្លួកបម្បាំងតាំងធំតាំងតូចមាន ៧ តាន់ជាយ នៅក្នុងបង្គាប់បញ្ជាខ្ញុំជា ២ នាក់នេះតាំងអស់ ។ ចូលឮដូច្នោះត្រេកអរណាស់ ទើបតាំងឲ្យឈួម៉និងខៀវអ៊ុនជានាយកងំពដើងទ័ព ហើយថាឥឡូវនេះ ខ្មៅបៀវក៏ស្លាប់ជាតិហើយ ឯខ្មៅចងជាកូន ក៏មកចំណុះចុះចូលយើង។ និងក្រាបទូលព្រះចៅហ្លួនតេ ឲ្យតាំងជានាម៉ឺនធំ សម្រេចការពារជាការក្នុងស្រុកកេងដីវតៅ ។ ឈួម៉, ខៀវអ៊ុនបានស្តាប់ដូច្នោះ ក៏មានចិត្តជឿតាំប្រាមោជឆ្ពោះត្រេកអរណាស់ គំនាប់លាចូលមកវិញ ។

ស៊ុនហ៊ុវដំណរចូលថា ឈួម៉ និងខៀវអ៊ុន២នាក់នេះ ជាមនុស្សប្រចុបប្រចែងនិងឡបឡប ហេតុម្តេចលោកម៉ានស្គាល់ចិត្តគំនិត ក៏តែងតាំងឲ្យ

ធ្វើជានាយទាហានដ៏ធំកំណែតម្ដងនោះម្ដេចទៅ ! ។ ចូរឆ្លងសំណើច
ហើយថា បើយើងមិនដឹងមិនស្គាល់ចិត្តមនុស្សទេ នឹងធ្វើការធំម្ដេចបាន
ប្រការទៀត ទាហានរបស់យើងប៉ុន្មានប្រសប់តែផ្លូវគេត ដែលនឹងរកឲ្យ
ស្មើគំនាញាខាងដើងធំកំណែនោះមិនមាន យើងធ្វើតាមឧម្បាលនេះ ច្រើន
នឹងយកចិត្តទុកដាក់ហ្មឹកហាត់ទាហានយើងឲ្យប្រសប់ រួចសឹមកំចាត់វា
ចេញទៅចុងដៃ នឹងក្រែងយូអ្វី ។

ឯឈ្មួញ នឹងឿអ៊ុន កំនាំយកសេចក្ដីទៅសំដែងច្រាប់ឡៅចន
តាមពាក្យចូរឆ្លងត្រូវគ្រប់ប្រការ ។ ឡៅចន៍ឮហើយមានអំណរណាស់
នាំយកសេចក្ដីនោះទៅសំដែងច្រាប់នាងឈួហ៊ូយ៉ាងជាម្ដាយ លុះវេលា
ព្រឹក កំរៀបតាក់តែងរបស់ទ្រព្យដែលនឹងនាំទៅគំនាប់ចូរឆ្លង , លុះរៀបចំ
ស្រេចហើយ ឡៅចន៍ នឹងនាងឈួហ៊ូយ៉ាង កំនាំចូលទៅគំនាប់ចូរឆ្លង, យក
គ្រាស់ទ្រាប់ដារដួងទៅផង រួចកំលើករបស់ទឹងគ្រានោះដួងទៅចូរឆ្លង ។
គ្រែកអរណាស់ កំលើកកងទ័ពទៅតាំងទៅប្រុបស្រុកសុងយ៉ុង ។

ឯឈ្មួញ , ឿអ៊ុន កំអុជឆ្លងទៀនគំនាប់ចូរឆ្លង អាញ្ជើញឲ្យចូរឆ្លង
ចូលទៅកងស្រុក ។ ចូរឆ្លងឲ្យគេហៅកេងអ៊ូតមកហើយ កំនំយោយថា
ខ្លួនយើងមកយកស្រុកកេងដីវគ្រានេះ មិនមែនឲ្យមានអំណារប៉ុន្មាន
ទេ ដែលយើងបានខ្លួនអ្នកតែមួយកំមានចិត្តត្រេកអរ លើសជាងបាន
ស្រុកកេងដីវពាំនមួលទៅទៀត ហើយកំតាំងកេងអ៊ូតជាទៅហ្វាយស្រុក

កាំងឡើង តាំងហ៊ូសួន , អង្គសាន់ជាមន្ត្រីធំ តាំងឡៅចង់ជាចៅហ្វាយ
ស្រុកកេងដ៏រៀ ហើយកំឡៃរៀបខ្លួនចេញទៅ ។

ឡៅចង់ឮដូច្នោះ កំសត់ស្មុគស្មាញក្នុងចិត្ត ទើបអង្វរសុំខ្លួនថា ដែលមហា
ឧបាជតាំងឲ្យខ្ញុំបានជាចៅហ្វាយស្រុកកេងដ៏រៀនោះ ជាព្រះគុណធ្ងន់ក្នុង
ទីបំផុត ដែលខ្ញុំបាទ ឃ្លាហ៍ចេញមកគំនាប់លោកតាំងម្ល៉ះ មិនមែនធំណ
មានសេចក្តីប្រថ្នាចង់ធ្វើចៅហ្វាយស្រុកនោះណាស់ណាទេ ខ្ញុំបាទសុំ
ឲ្យបានតែវាសនាស្តាសៅក្នុងស្រុកកេងដ៏រៀនេះ ដើម្បីធំណបានថែរក្សា
សពបិតាប៉ុណ្ណោះ ក្រៅពីនោះប្រថ្នាធំណរកាញ្ញាតិសាលោកិតតាមប្រវៃ-
ណីតទៅ ឥឡូវសូមឲ្យលោកទានកុណាជល់ខ្ញុំបាទចុះ ។ ចូរដឹងថា
ដែលយើងធំណឲ្យអ្នកទៅទៅស្រុកកេងដ៏រៀនោះ ដោយសេចក្តីប្រណីតា-
ណិតអ្នក ព្រោះយើញថាស្រុកកេងដ៏រៀធំណក្រុងហ៊ូតៅមៅដិតគ្នា អ្នកធំណ
បានចូលចេញតាស់ហ្គាត្រះចៅហៀនតេដោយស្រួល , ប្រការ១ទៀត
ម៉ែអ្នកធំណចង់ទៅកន្លែងស្រុកកេងដ៏រៀនេះ ឆ្ងាយពីយើងធំណត្រះចៅហៀនតេ
តង់ងាពីបៀតបៀនទៃមនុស្សដែលជាសត្រូវកុំណួច ធំណមិនសប្បាយទៅ
ចុងរៀ ។ ឡៅចង់ឮហើយ កំតាស់គំនិតត្រេះតិតភ្លាចចូរ ធំណរីឯធំណ
មិនបានតំត្រមខ្លួល ហើយតំនាប់លាទាំមាតាចេញទៅស្រុកកេងដ៏រៀ លុះ
ទៅដល់មាត់កំពង់ធំណធ្លងស្ទឹង នាម៉ឺនទាំងអស់ក៏លាចូរទៅតាន់ឯកន្លែង
រៀងខ្លួន ។ ឯអង្គអ៊ុយក៏ជាប់តាមឡៅចង់ទៅផង ។

កាលដែលខ្លាឃនឹងចេញផុតព្រំស្រុកនោះហើយ, ចចូកចង្កាប់អ៊ុតឹមថា អ្នកចូរលើកតាហានស្រូតតាមទៅស្កាត់ចាប់សម្លាប់ខ្លាឃនឹងចេញ ។ អ៊ុតឹមក៏លើកតាហានស្រូតតាមទៅ លុះទៅទាន់ខ្លាឃនឹងហើយ ក៏ស្រែកថា ឥឡូវមហាទេពជប្រើឲ្យយើង តាមមកសម្លាប់អ្នកឯង ត្រូវចាំនឹងឆ្លាយចាំង ២ នាក់ចេញ អ្នកកុំរីរាត់ទៅឯណាឡើយ ចូរនៅស្មៀមឲ្យយើងកាត់ក្បាលនាំទៅឲ្យមហាទេពជចុះ ។ នាងឈូហ៊ូយិនឮដូច្នោះក៏តក់ស្លុតស្មារតី ម្ដាយនឹងកូនក៏ទេពកន្ធាខ្លួញយំដំនក ។ កងអ៊ុយឃើញដូច្នោះខឹងណាស់ ត្រឡប់មុខវិលមកនឹងតស៊ូ ។ អ៊ុតឹមឲ្យតាហានចាប់សម្លាប់ចេញហើយក៏កាត់ក្បាលនាងឈូហ៊ូយិនទឹងខ្លាឃនឹងត្រឡប់នាំទៅឲ្យចចូ ។ ក៏ឲ្យបំណាច់ឆ្អិនអ៊ុតឹមតាមសមគួរ ហើយមង្គាប់តាហានឲ្យទៅចាប់គ្រប់គ្រួនឹងបងមិនឃើញសោះ ហើយក៏វិលមកប្រាប់ចចូវិញ ។ ចចូក៏មានកំហឹងគុំគួនមិនរសាយ ។ ខណៈកាលនឹងបងនឹងលើកព្យហៈចាកចេញពីស្រុកសុំនអៀនោះ ក៏ទឹកភ្នែកក្រែងចចូនឹងធ្វើអន្តរាយដល់គ្រប់គ្រួ ក៏គេចចូលទៅនាំគ្រប់គ្រួយកទៅលាក់ចំពួនទៅដំបន់សាំងតាំង ឃានជាតាហានស្រាវជ្រាវរកមិនជួបប្រទះ ។

ចំណែកសុំនហ៊ាវដំកចចូថា ស្រុកតាំងឡើងនោះ ជាទីតាំមួនណាស់ តាំងស្បៀងអាហារ កំប្រមូលយកទៅពុកជារាច្រើន បើប្រសិនខ្លាឃតាំងនៅមុនឃាន យើងនឹងតាមទៅធ្វើការច្បាំងជាណ្ដើមក៏មិនជាយ

ទីឯយកដំរីដំនិះបានសោះ ។ ចូរធ្លុតបបថា អ្នកនិយាយនោះត្រូវហើយ យើងក្តេចទេ យើងកំនៅតែតយើញដកថ តែឥឡូវយើងត្រូវឲ្យតាហានស្រួតរួតរំលងទៅមុខ ចូរបេយកស្រុកតាំងឡើងឲ្យបានមុន, ចូរធ្លុកំឲ្យអន្លើញតាលតាហានរបស់ឡៅចងមកត្រួតមើល យើញថាតំម្លាក់ឈ្មោះប៊ុនផង, ចូរធ្លុកំឲ្យមនុស្សទៅហៅយកវិញ ខ្លួលដួចប្រទេងទីឯប៊ុនផងកំទាំចូលមកតំនាប់ចូរ ។ សួរថា តាំងពីយើងមកនៅក្នុងស្រុកសុងយ៉ុងនេះច្រើនពេល ហេតុម្តេចកំវិញទៅតួនមុខមិនមកតែដួចនឹងយើង ? ។ ប៊ុនផងគ្នើយថា ខ្ញុំបាទមិនបានមកតែលោកនោះ មិនមែនទីឯតួនមុខលាក់វិញទេ ព្រោះខ្ញុំបាទកើតមកជាតាហាន មិនបានធ្លើការយកអាសាចៅហ្វាយនាយឲ្យស្រុកភូមិទៅជាសុខ បានជាខ្ញុំបាទកើតទុក្ខអៀនខ្មាសណាស់ ទើបមិនបានមកតែលោក និយាយហើយកំយំ ។ ចូរធ្លុយើញដូច្នោះ កំតេញចិត្តណាស់ សំឡឹងមើលយើញថា ជាមនុស្សសុចរិតខ្លៀងត្រង់មែន ទើបតាំងឲ្យប៊ុនផងជាចៅហ្វាយស្រុកតាំងហៅ ហើយឲ្យលើកតាហានដែលមានកម្លាំងខ្លាំងតួកចាំង៥តាន់ស្រួតទៅតាមឡៅតិ, ចូរធ្លុកំលើកទ័តហួងជាជំនួយតាមទៅក្រោយ ។

ឯខុងជេងនិយាយនឹងឡៅតិថា បណ្តាត្រប់ត្រួដែលមកតាំងអម្បាលនេះ មានចំនួនដល់ ៣ ម៉ឺន ៤ ម៉ឺន មានតាហានចំបាំងប្រហែលតែ ៣ តាន់តិចតេចណាស់ ហើយខ្លួនលោកកំដើរកៀរប្រមូលត្រប់ត្រួយ៉ាងតាំងម៉ឺន តង់ទ័តចូរធ្លុកំលើកជាប់តាមមកភ្លាន់ ។ ជិតភាន់ហើយ តាលដែល

លោកប្រើគ្នានអ្វី ៗសុំកងទ័ពស្រុកកាំងហែមកជួយ តាំងពីថ្ងៃនោះ
មកដល់ថ្ងៃនេះ កំណត់ ១ ខែហើយ នឹងបានមិនបាន ក៏មិនឃើញវិលមក
វិញ មិនដឹងជាកាចជាយ៉ាងណាទៀយ នឹងតតួចម្តេច ? ។ ឡៅតីថា
បើដូច្នោះលោកកុំឃើញតែខ្លឹងហត់ឡើយ ចូរទៅស្បាហ៍ទៅខ្លួនឯងចុះ
ចុះ ព្រោះលោកមានគុណូបការៈ នឹងឡៅតីតាំងថ្ងៃនុន ។ ឡៅតីឃើញ
លោកទៅខ្លួនឯងហើយ ក៏នឹងបោះចង្កឹបុាន តស៊ូនឹងកេតសាហាន
ឲ្យលោកខ្លះ ៦ ទុនចេងខ្លួលពាក្យហើយក៏ចេញទៅ នាំឡៅហានទៅដង
ជា ២ នាយលើកទាហាន ៥០០ ស្រុតទៅស្រុកកាំងហែ ។

កាលឡៅតីនឹងប៊ីតុក ប៊ីហង កាន់ឃ៊ុង នាំគ្រប់គ្រួលើកប្រគាក់ប្រ-
ពួនទៅក្នុងថ្ងៃនោះ ក៏កើតឱ្យលំញ៉ះកំបុតស្បូងចោកបក់ក្តួចយកផងក្តួលី
ហុយត្រឡប់ទៀតទៅត្រង់មុខសេះ ឡៅតី ។ ស្មុតស្តិ ក៏ស្បែប៊ីតុក ប៊ីហង
កាន់ឃ៊ុងថា គេទេនេះនឹងល្អឬអត្រក់ឫការម្តេច ? ។ កាន់ឃ៊ុងចាប់ឃាម
មើល ហើយដំពាមឡៅតីថា គេទេនេះគាចណាស់ គេលួចប់នេះគ័យនឹង
មកដល់លោកដាក្រាកដហើយសុំឱ្យលោកចោលគ្រប់គ្រួចញាស់ន ស្រួត
រត់ទៅមុនឱ្យរួចខ្លួនសិនចុះ ។ ឡៅតីថា បន៍គ្លាំនដែលយើងបានការ
តារកម្មទុស្សាំងអស់នេះមកពីស្រុកស៊ុនអ៊ី រហូតដល់ខ្លានេះហើយ
ដែលនឹងបោះបង់ចោលគ្នារត់យកតែខ្លួននោះ យើងមិនដឹងនឹងធ្វើកើត
សោះឡើយ ។ កាន់ឃ៊ុងថា បើលោកនៅតែមិនដឿស្តាប់ពាក្យខ្ញុំបាទ

ផ្នែកកំណាត់ដំណឹងប្រវត្តិការណ៍

ពត៌មានដែលទាក់ទងសង្ឃនាយក

អំពីការតាំងមន្ត្រីសង្ឃទីរាជាគណៈពីរូប ទាំងគណៈធម្ម-
យុត្ត តាមព្រះរាជក្រឹត្យលេខ ២៨ រ.រ.ប៊ុះប៊ៀ ទី៦ មិថុនា ១៩៥៩

១-ព្រះអរិយកស្សប កែវ.អ៊ូច ជន្មាយុ៧៦ឆ្នាំ វស្សា៥០ ពជាគណៈ
សម្រាប់គោទៅវត្តបទុមវតី ក្រុងភ្នំពេញ ជាទីពជាគណៈសម្រាប់ឯក
មានគោរម្យងារជា "ព្រះមន្ត្តីលេខាភាវ្យ" ជំនួសសម្តេចព្រះមន្ត្តី-
ខេត្តាភាវ្យ កែម-ភួង ដែលខូលអនិច្ចធម្ម ។

២- ព្រះមហាវិរវង្សាភាវ្យ ហ៊ី-ជា ជន្មាយុ៤៦ឆ្នាំ វស្សា ៣១
ពជាគណៈសម្រាប់ត្រី នៅវត្តបទុមវតី ក្រុងភ្នំពេញ ជាទីពជាគណៈ
សម្រាប់គោ មានគោរម្យងារជា "ព្រះធម្មុត្តម" ជំនួសព្រះធម្មុត្តម
ឡុង-សន ដែលខូលអនិច្ចធម្ម ។

៣- ព្រះញាណវង្ស៊ី ចាន់-តង់ ជន្មាយុ៦៣ឆ្នាំ វស្សា ៣៤
ពជាគណៈសម្រាប់ត្រី នៅវត្តបទុមវតី ក្រុងភ្នំពេញ ទីពជាគណៈ
សម្រាប់គោមានគោរម្យងារជា "ព្រះអរិយកស្សប" ជំនួសព្រះអរិ-
យកស្សប កែវ.អ៊ូច ដែលខ្លើ៉ដាទីពជាគណៈសម្រាប់ឯក ។

៤- ព្រះអមរាភិរក្ខិត ឡុង-ណារ៉ ជន្មាយុ ៤៨ឆ្នាំ វស្សា ២៧ ពជ្ឈាគណៈសម្រាប់ចក្ខា នៅវត្តបឋុមវតី ក្រុងភ្នំពេញ ជាទីពជ្ឈាគណៈសម្រាប់ត្រី មានតារម្យងារជា "ព្រះញាណវង្ស" ជំនួសព្រះញាណវង្ស ចាន់-តន់ ដែលឡើងជាទីពជ្ឈាគណៈសម្រាប់ត្រី ។

៥- ព្រះញាណវិរិយៈ ភ័ន់-សាឌុម ជន្មាយុ ៥៤ ឆ្នាំ វស្សា ៣៤ ពជ្ឈាគណៈសម្រាប់ចក្ខា នៅវត្តនន្ទមណ្ឌាម ក្រុងភ្នំពេញ ជាទីពជ្ឈាគណៈសម្រាប់ត្រី មានតារម្យងារជា "ព្រះមហាវិរវង្សាចារ្យ" ជំនួសព្រះមហាវិរវង្សាចារ្យ ប៉ុជា ដែលឡើងជាទីពជ្ឈាគណៈសម្រាប់ពេ ។

៦- ព្រះគ្រូមហាបឋុម កែវ-ស៊ីមន ជន្មាយុ ៤១ឆ្នាំ វស្សា ២១ ទីហានានុក្រមនៅវត្តបឋុមវតី ក្រុងភ្នំពេញ ជាទីពជ្ឈាគណៈសម្រាប់ចក្ខា មានតារម្យងារជា "ព្រះអមរាភិរក្ខិត" ជំនួសព្រះអមរាភិរក្ខិត ឡុង-ណារ៉ ដែលឡើងជាទីពជ្ឈាគណៈសម្រាប់ត្រី ។

៧- ព្រះគ្រូធម្មធីរមុនី ខន-ចេង ជន្មាយុ ៥៨ឆ្នាំ វស្សា ៣៥ ទីហានានុក្រម នៅវត្តប្រជុំវង្សារាម ក្រុងភ្នំពេញ ជាទីពជ្ឈាគណៈសម្រាប់ចក្ខា មានតារម្យងារជា "ព្រះញាណវិរិយៈ" ជំនួសព្រះញាណវិរិយៈ ភ័ន់-សាឌុម ដែលឡើងជាទីពជ្ឈាគណៈសម្រាប់ត្រី ។

អំពីការតាំងមន្ត្រីសង្ឃទីហ៊ានពុក្រម

-ជានតាំងកិត្តិ ចិត អ៊ុន វត្តត្រែងធ្នក ឃុំស្វាយតាយាន ស្រុកស្វាយចាប ខែត្រស្វាយរៀង ឲ្យឡើងជាចៅអធិការ អនុគណកងស្រុកស្វាយចាប ។

-ជានតាំងកិត្តិ ម៉ម អាំ វត្តត្រែអង្គញ ឃុំច្រកមូស ស្រុកស្វាយចាប ខែត្រស្វាយរៀង ឲ្យឡើងជាចៅព្រះសមុហ៍អនុគណ ក្នុងស្រុកស្វាយចាប។

អំពីការតាំងចៅអធិការ

-ជានតាំងកិត្តិ ស្វាយ កុន នាមនាយចន្ទសារិគណៈធម្មយុត្តិកនិកាយ ឲ្យឡើងជាចៅអធិការ វត្តសាលា ឃុំភូមិធំ ស្រុកស្វាយជ្រុំ ខែត្រកណ្តាល។

-ជានតាំងកិត្តិ ចន្ទ ឡាច ឲ្យឡើងជាចៅអធិការ វត្តរោងវែង ឃុំចំការលើ ស្រុកស្អាង ខែត្រកណ្តាល ។

-ជានតាំងកិត្តិ ខៀង សំ ឲ្យឡើងជាចៅអធិការ វត្តវាលមាស ឃុំវាលចេញ ស្រុកត្រែងប់ ខែត្រកំពត ។

(តទៅ)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អញ្ជលិ ពុំ. អញ្ជលិ, ក្រពុំម្រាមដៃ ។ *អញ្ជលិ-ក្ឫ* ន. ន. *អញ្ជលិ តន្ឫ* ន. ន. ។ - **កម្ម** ន. ពុំ. ការីយាធ្វើអញ្ជលិ ។ - **ការិកា** ស្ត្រ. ទេវរូបដែលធ្វើពីដី ។ - **ចាត** ពុំ. ការីយាន. ន. ។ - **បុដ** ពុំ. ន. ពុំ កំពង់នៃអញ្ជលិ ។ - **ប្រគ្រហ** គុ. ដែលទ្ទឹងអញ្ជលិ ។

អញ្ជលិក ពុំ. ព្រួញមួយបែប ។ **អញ្ជលិកា** ស្ត្រ. កណ្តុរកន្ទើយ ។

អញ្ជសា ក្រ. វ. ដោយត្រឹមត្រូវ ដោយត្រង់; មួយរំពេច ។

អញ្ជីរ ពុំ. ដើម ឬ ផ្លែមៀ, ដើម ឬ ផ្លែត្របែក ។

អញ្ជោ-គតិ គុ. (សរ) ដែលហើរត្រង់ ។

អដ ឆាគុ. អដតិ. អនភ; អដិតុំ អដិត្វា ។ ដើរប្រាប .ស្ទះស្ទើង ។

អដន ន.ពុំ. ការីយាដើរប្រាប. ការីយាត្រាប់ឆ្ពាត់ ។

អដនិ ម អដនី ស្ត្រ. ជុងដំបូតនៃដងទ្ធ. ។

អដវិក ពុំ. អ្នកព្រៃ. អ្នកឆ្មើរព្រៃ ។

អដវី ស្ត្រ. ព្រៃ; ក្រុងសាវត្ថី ។ - **ក្រាយ-ក្រាន្ត** ឆា ស្ត្រ. ការនៃទីពំនាក់នៃ...ដែលត្រូវដុំរើចេញដោយព្រៃ ។ - **ភាស** ន.ពុំ. ..ពាលនៃព្រៃ" ឬ ភាសាសត ។

ភាវនាសុទ្ធិយា


ទស្សនាវដ្តី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣១ លេខ ៨ ខែសីហា

ព.ស. ២៥០២ គ.ស. ១៩៥៩

ភ្នំពេញ



ទង្គុលសន្តិភាព

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បន្ទាប់ទៀត	ទំព័រ
- ទីបធម្មកថា របស់ព្រះមហា ជា-សន	. . . . .	៨៤៥
- ទង្វើនធម្មណាភទេសនា របស់ព្រះមហា មៅ-ខាន់	. . . .	៨៥៣
- សុវត្ថិភាពក (តមក) លោក ជឹង-រឹង ចម្លងពីសាស្ត្រាស្ងឹកវិត	. . .	៨៦៦
ផ្នែកអក្សរសាស្ត្រ		
- រឿងហង្សជាតក (តមក) លោក អឹម-ភន ចម្លងពីសាស្ត្រាស្ងឹកវិត	. . . .	៨៧១
- រឿងមរណមាត (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្ងឹកវិត	. . .	៨៧៣
- រឿងព្រះធម្មសួស្តី លោក ប៊ូ-ប៊ូ រៀបរៀង	. . . . .	៨៨៥
- រឿងព្រះនឹងរឿងបុរាណប្រទេសជប៉ុន (តមក) លោក ភាយ-ប៊ុក រៀបរៀង	. .	៨៩០
- សុចរិតនឹងទុច្ចរិត រឿងព្រះអង្គស្រី អ្នកស្រី ស - សាវត្ថ ប្រែរៀបរៀង	. .	៩០៧
- រឿងស្រីគ្រប់ល័ក្ខណ៍ យុក-ដើរ រៀបរៀង លោក ផេង-ទ្រីវ ពិនិត្យ	.	៩២០
- រឿងសាមក្កុក (តមក) ឧកញ៉ា ឆ្ង-ភន ប្រែ	. . . . .	៩៣៨
ផ្នែកគំណាត់ទីធីប្រវត្តិការណ៍		
- សេចក្តីថ្លែងការណ៍សារតិមាន របស់ព្រះតេជគុណព្រះគោធិវង្ស ឃួត-ភាគ អគ្គាធិការនៃពុទ្ធិកសិក្សា	. . . .	៩៥០
- ពត៌មានផ្សេងៗ របស់ក្រសួងធម្មការ	. . . . .	៩៥៣
- វិធានានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ជាង-ខាត់ រៀបរៀង	. . .	៩៥៨

មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០០

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

sommaire

Partie religieuse :

— Dipadhammakatha par Preah moha CHEA-SAN 845
— Uthànadhana la bha desana par Preah moha MAU-KHAN 857
— Sarabajataka (suite) recueilli du manuscrit sur feuilles de latanier par M. THANG-VONG 866

Partie littéraire :

— Histoire de Hang-Yon (suite) recueillie du manuscrit sur feuilles de latanier par M. IM-PHON 871
— Histoire de Marana Mâtâ recueillie du manuscrit sur feuilles de latanier par M. By-Sovan 878
— Légende de Chey Sûos par M. BOU-PO 885
— Contes et Légendes du Japon par M. RAY-BUC. 890
— L'honnêteté et la malhonnêteté, conte populaire Russe traduit par Mme SA-SARA 907
— La femme vertueuse par Yok Vochir revue et corrigée par M. PHENG-CHRIV 920
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 938

Notes et Chroniques :

— Tournée du Vén. Preah Pothivong HUOT-TAT Inspecteur de l Enseignement du Bouddhisme 950
— Nouvelles diverses du Ministère des Cultes 957
—Dictionnaire Sanskrit-Khmer (suite) par Vén. PANG-KHAT . 958

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

ផ្ទៃកសាសនា

ទីបធម្មកថា

ព្រះមហា ជា-សន រៀបរៀង

និមោ ៣ ដង

សូមនមស្ការ ចំពោះព្រះគន្ថវន្តមុនី អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គ
នោះ (ត្រមាំងព្រះធម៌ដ៏ព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

លំដាប់នេះ សូមសម្តែងអំពី ទីបធម្មកថា ។

ទីបធម្មកថា នេះ , សម្តេចព្រះអនាវរណញាណ ទ្រង់
ប្រកបដោយប្រាជ្ញាដ៏មោះមុត ឥតមានអ្វីមួយជាគ្រឿងខ្វើសង្គត់គតិប្រៀបប្រា
បេះព្រះអង្គ ទ្រង់ត្រាស់ប្រកាសឡើងពុំឥតជាមួយបហេតុ សម្រាប់ញុំាង
សត្វដែលបានប្រតិបត្តិតាម ឲ្យមានសិទ្ធិចូលទៅត្រង់ដ៏យក ទូវផល
៣ ប្រការគឺ: បច្ចុប្បន្នផល , សម្បរាយកផល ទំនឹង បរមត្ថផលបាន
ព្រោះព្រះអង្គមានតុ្ណចំណង់ដ៏ល្អវិសេស បំផ្ងឲ្យពួកសត្វកាលខ្លះតាយបាន
តបប្រសព្វដោយសុខសម្បត្តិចំរើនពុំរឿង ដោយគុណប្រយោជន៍នានា
ទាំងបានយល់ឃ្លាស់លាស់ទូវលោកគតិ " ដំណើរបេះលោក " ធម្មតិ
" ដំណើរបេះធម៌ " ក្នុងលោកនេះ ទំនឹងលោកខាងមុខ ទៅវិលដែល
មិនខាន់បានជួបប្រទះទូវព្រះនិព្វាន ។

សត្វពាលឯទៀត ដែលមិនទាន់បានប្រតិបត្តិតាមធម៌ យកមកតាំងទុកជាទីគោរពប្រតិបត្តិតាមនៅឡើយ ចេះតែលង់លិចទៅក (គឺអត្តភាព) ក្នុងសមុទ្រ (គឺសំសារវដ្ត) ឈ្លក់ទឹក (គឺទំនាំរណ្ហូបក្តៅលេស) បានជាចំណីត្រី (គឺឥច្ចាជ) ត្រឡប់លេបញ៉ាំកញ្ជាប់ឆ្អើជាអាហារ ។ ចំណែកខាងអន្ធពាលសត្វដែលមិនបានប្រតិបត្តិតាមធម៌ ឥតបានដឹង បានយល់ដូច្នោះឡើយ ម្ល៉ោះហើយតែងតែជួបប្រទះទុក្ខវេទនាក្នុងសមុទ្រសំសារវដ្តនោះឯង; ឯកល្យាណសត្វ ដែលបានប្រតិបត្តិតាម ទើបអាចយល់ហេតុការណ៍នោះបានដោយសភាពពិត ។ ។

ធម៌បទម្ន នេះ ប្រែថា "ធម៌ជាទីពឹង, ធម៌ជាប្រទីប ឬថាធម៌ដូចជាកោះ" ។

ធម៌បទម្ន នេះចែកចេញជា ៤ ប្រភេទ គឺ:

១ - ឧដ្ឋាន ការម៉ឺងម្ាត់ព្រមើលព្រមើន ប្រកបការងារដែលត្រូវប្រកប ។

២- អប្បមាទ ការមិនធ្វេសប្រហែស មិនធ្វាយស្មារតី ។

៣- សញ្ញម ការសង្រួម-ប្រយ័ត្ន-រក់ងឥន្ទ្រិយទាំង ៦ ។

៤- ទម ការទូន្មានចិត្ត ប្រដៅចិត្ត ឲ្យមានបែបបទសណ្តាប់ធ្នាប់ល្អ ។

សូមលើកយកប្រភេទមួយម្តងៗ មកអធិប្បាយដូចតទៅ :-

១- ឧដ្ឋាន ការម៉ឺងម្ាត់ប្រកបការងារដែលត្រូវប្រកបនេះ ស្រួបគ្នា

ទានវិរិយៈ (សេចក្តីព្យាយាម) ដែលមានឧកាសដ្ឋៈ (សេចក្តីឯ្ងលប្រអូស) ជាទំនាស់ ។ សេចក្តីព្យាយាមប្រកបការងារ មិនមែនសុទ្ធតែត្រូវតាំនអស់នោះទេ មានការងារនៃបុគ្គលខ្លះប្រកបទុសកិច្ចដែរ គួយ៉ាងដូចជាជនពួកខ្លះ មានអត្តភាពជាមនុស្ស បែរជាទៅប្រកបការងារដែលជាតិច្ឆៈរបស់សត្វតិរច្ឆានទៅវិញ យ៉ាងនេះហៅថា ការងារទុសកិច្ច ។ ចំដ៏ឆាំខ្លួនជាមនុស្សហើយ ត្រូវតែព្យាយាមប្រកបការងារដែលជារបស់មនុស្ស គឺមនុស្សកម្ម (ការងារល្អដែលមនុស្សត្រូវធ្វើ) មនុស្សធម៌ (ធម៌ល្អមានសុចរិតធម៌ជាដើម ដែលមនុស្សត្រូវគាំ) វឌ្ឍនធម៌ (សេចក្តីចំរើនដែលមនុស្សត្រូវចំពេញ) ព្រោះមនុស្សមានសិទ្ធិ-សិរី-អធិបតេយ្យនីឯការណ៍ឃកិច្ចទាំនអស់ មិនមែនមានការងារប្តូធម៌ដូចសត្វតិរច្ឆានទោះទេ ។ ការប្រឹងប្រែងម៉ឺងម៉ាត់ ប្រកបខ្លួនឲ្យបរិបូណ៌ជាយសេចក្តីព្យាយាម បែរមុខទៅរកកុសលធម៌ ទើបហៅថាការងារត្រូវប្រកប ។ សេចក្តីព្យាយាមនេះ ជាគុណធម៌អាចឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាង តាមសមគួរដល់ទបនិស្ស័យរបស់ខ្លួនពិតប្រាកដ អាចលើកស្ទួយបុរស-ស្ត្រីឲ្យផុតអំពីសភាពជាកូនចាបក្រួតអត់ឃ្លានល្ងង់ខ្លៅបាន ហើយដាក់ទៅលើសភាពថ្កុំថ្កើងប្រសើរ ជាគុណធម៌មានអានិសង្សច្រើនជាអនេក ដូចជាក្នុងជាឧសូត្រ ដែលព្រះលោកនាថទ្រង់សម្តែងដាស់តឿនថា :

សំវរោ ច មហាឧឡ្ហ កាវិជា អនុរក្ខតា

ឯតេ ចត្តារោ បធានា នេសិតានិច្ច ពន្ធុនា
យេហិ កិក្ខុ ឥធាគាមី ខយំ ទុក្ខស្ស ទាបុណោ

ប្រែថា: បធាន: គឺធម៌ជាគ្រឿងដុតកំចាត់ ៤ យ៉ាងនេះ គឺ:

ក) សំវរោ រក្សាទប្រយ័ត្នមិនឲ្យបាបអកុសលកើតឡើងបាន ។

ខ) បហានំ លះបង់បាបអកុសលដែលកើតឡើងហើយ ។

គ) ភាវនា ចំរើនកុសលដែលមិនទាន់កើតឲ្យកើតឡើង ។

ឃ) អនុរក្ខនា រក្សាកុសលគឺសេចក្តីល្អ ដែលកើតឡើងហើយ មិនឲ្យវិនាសសាបសូន្យទៅវិញ ។

ធម៌ទាំង ៤ យ៉ាងនេះ ព្រះសម្ពុទ្ធមានព្រះភាគត្រាស់ដូចជា ព្រះអាទិត្យ ទ្រង់ស្រែងហើយ ។ តែក្នុងសាសនានេះ គួរតែប្រឹងព្យាយាមធ្វើតាមសេចក្តីដែលទ្រង់ត្រាស់ដោយបធានធម៌ ដែលបានលាមកហើយនេះ ទើបដល់នូវតំរិយាអស់ទៅនៃសេចក្តីទុក្ខព្រួយគ្រប់យ៉ាងបាន ។

៦ - អប្បមាទ: « ការមិនធ្វេសប្រហែស » នេះ ត្រូវគ្នានឹងសូត្រ "សេចក្តីតំរិះញាំញីចាំបាន" ។ អប្បមាទ: មាន បមាទ: « ការធ្វេសប្រហែស » ជាបដិបក្ខ, បមាទ: មានសតិវៀសវ្រួត: ជាលក្ខណ: ។

អប្បមាទ: ជាគូដង្ហាន:បស់កុសល ហើយជាសភាវធម៌មានឫទ្ធិយ៉ាងធំបំផុត ជាកំពូលនៃកុសលធម៌ទាំងពួង សមដូចព្រះពុទ្ធដីកាថា :យ កោចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា

អប្បមាណសមោសរណា អប្បមាណោ តេសំ អគ្គមក្ខា-
យតិ សេចក្តីថា: ពួកធម៌ជាកុសលណាមួយ, ពួកធម៌ជាកុសលទាំង
អស់នោះ មានសេចក្តីមិនប្រមាទជាមូល ប្រជុំចុះក្នុងសេចក្តីមិនប្រមាទ.
បណ្ឌិតតោលសរសើរសេចក្តីមិនប្រមាទថា ជាកំពូលនៃកុសលធម៌ទាំង
នោះ ។

សេចក្តីមិនប្រមាទនេះ ថាជាកំពូលនៃកុសលធម៌នោះ ព្រោះថា
បណ្តាកុសលធម៌ទាំងអស់ កុសលធម៌ណាមួយ ដែលនឹងកើតឡើងបាន
កំព្រោះតែសេចក្តីមិនប្រមាទកើតឡើងជាមុន ឬក៏មានសេចក្តីមិនប្រមាទ
នៅពីមុនទ្រទ្រង់មកហើយទើបកើតឡើងបាន, ដូចមេដំបូលប្រាសាទដែល
ជាទីប្រជុំចុះនៃគ្រឿងឥតសម្ភារៈទាំងឡាយ មានផ្ទាំង ផ្ទាន ជាដើម
ព្រោះហេតុនេះ បានជាព្រះមានព្រះភាគទ្រង់សំដែងសេចក្តីមិនប្រមាទ
ដោយបរិយាយផ្សេងៗ មានដើមថា: ជានាំ តិក្ខវេ អញ្ញំ
ឯតាទិសំ សមវុបសន្តិ ម្នាលភិក្ខុទាំងឡាយ! តថាគតមិន
ឃើញមានធម៌ដទៃណាមួយ ដែលជាហេតុញុំាងកុសលមិនទាន់កើតឲ្យ
កើតឡើង ញុំាងកុសលដែលកើតឡើងហើយ ឲ្យរឹងឹតតែចំរើន
ឡើង ដូចសេចក្តីមិនប្រមាទនេះឡើយ; សូម្បីតែព្រះអង្គជិតនឹង
បរិនិព្វានតន់ព្រះអង្គទ្រង់សំដែងជាស់តឿនថា ជានន្ទ តិក្ខវេ
អាមន្តយាមិ វោ ម្នាលភិក្ខុទាំងឡាយ តថាគតជាស់តឿនអ្នក

តាំងអស់គ្នា វយនម្មា សង្ខារតាំងឡាយមានសេចក្តី
សូន្យជាធម្មតា អប្បមាទេន សម្បាទេថ អ្នកតាំងឡាយ
ចូរញុំាងប្រយោជន៍ឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ ។

អប្បមាទៈ ការមិនធ្វេសប្រហែសនេះ បើបុគ្គលអាចនឹងបណ្តុះឲ្យ
ចាក់ឫសនៅក្នុងសន្តានបាន ចាត់ទុកថាជាគុណប្រសើរណាស់; ព្រោះ
ការអ្វីក៏ដោយ ដែលបែរជាភ្លាត់ខ្លួនបង់ទៅ, ចាក់បែកវិនាសទៅ ក៏
ព្រោះតែសេចក្តីធ្វេសប្រហែស, បើអប្បមាទៈ "សេចក្តីមិនធ្វេសប្រហែស"
មាននៅហើយ ការនោះៗ មិនអាចខ្លួចបង់ទៅបានឡើយ, មានតែសេចក្តី
ចំរើន សេចក្តីល្អតែងតែប៉ុណ្ណោះ ។ ក៏ឯការរៀនសូត្រគ្មានដំណឹងខ្លួន គ្មាន
ភ្លាត់គំនិត តែងតែស្រាវជ្រាវជ្រៅជ្រះថ្លៃក្នុងអំពើខុសត្រូវតែផុតហ៊ានឹងខ្ពស់ប្លែក
ក៏ព្រោះតែបមាទៈដឹកនាំ, បើពោលសំដៅទៅរកបុគ្គលវិញថា បុគ្គលដែល
ជំពាក់ដោយបមាទៈ ខុតជារស់នៅអស់អាយុ១០០ឆ្នាំ ក៏ពុំប្រសើរឡើយ
ព្រោះអស្សាសៈនឹងបស្សាសៈដែលបុគ្គលប្រមាទនោះដកចេញ-ចូលតែង
ប្រឡាក់ដោយសេចក្តីផ្តន្ទាឈ្នានន័សនិន្ទាឫស្យា; កាលណាដកចូលស្រូបយក
តែអកុសលធម៌ទៅមិនស្ប ថម្ពៈ នឹងសារម្ភៈទៅផង, ដល់បោះញាមកវិញ
ហុយផ្លោងដូចផ្សែង គឺអនិដ្ឋាពន ការមេសុមិច្ឆាចារ ព្យាបាទៈ វិហឹសា
មក្ខៈ នឹងបលាសៈ ។ ឯបុគ្គលមិនប្រមាទមិនដូច្នោះទេ គេតែងបង្កឹក
ខ្លួនឲ្យមានបញ្ញាគតិ ធ្វើដំណើរទៅតាមលក្ខណៈនៃសតិនឹងសម្បជញ្ញៈ

ញ្ញាំងវិចារណញ្ញាណ ឲ្យតាំងនិត្យតាំងយ៉ងខ្លាំងប្រវត្តន៍របស់បញ្ចក្ខន្ធ ដើម្បីបញ្ញាចក្ខុសំឡឹងមុតទៅក្នុងវិមោក្ខមុខ (ទ្វារបស់ព្រះនិព្វាន) ដំណាក់ត្រៃគារៈ តិខ្ណគារៈ តិលេសគារៈ អតិសង្ខារគារៈ ចោល លែងប្រកាន់ការៈដទៃ, ដើរទន្ទ្រានកាត់ព្រៃ គឺអស្មិ- មានៈ- តណ្ហា- ទិដ្ឋិ ខ្ពោះមុខសំដៅទៅកាន់និព្វានទិស ។

លក្ខណៈនៃបុគ្គលមិនប្រមាទមាន ៤ យ៉ាងគឺ :

ក) អត្តាបដ្ឋ ដំណើរមិនមានការព្យាបាទ ។

ខ) សទា សតិ មានសតិសព្វ ។ កាល ។

គ) អជ្ឈត្តំ សុសមាហិត មានចិត្តដំកល់មាំក្នុងខ្លួន ។

ឃ) អភិជ្ឈាវិនយេ សិក្ខា សិក្សាក្នុងការនាំចេញនូវអភិជ្ឈា ។

ឯអប្បមាទៈ ខ្ពោះកំណត់ដោយបរិបូណ៌ដោយសតិ, សតិនេះជាតហុបការធម៌ "ធម៌មានឧបការច្រើន" ហើយប្រព្រឹត្តទៅដោយជំរើយច្រើនជាអនេក ។

៣- សញ្ញមៈ "ការសង្រួម" បានដល់ការកំណត់ប្រុងប្រយ័ត្នទ្វារទាំង៦គឺ :

ក) ភ្នែក ទ្វារជាទីបញ្ចាក់រូប មានតិរិយាយើញជាការងារ,

ខ) ត្រចៀក ទ្វារជាទីស្រូបសម្លេង មានតិរិយាឮជាការងារ,

គ) ច្រមុះ ទ្វារជាទីស្រង់ក្លិន មានតិរិយាធុំជាការងារ,

ឃ) អណ្តាត ទ្វារជាទីដប់រស មានកិរិយាជ្រួតជ្រាបជាការងារ,

ង) កាយ ទ្វារជាទីបីពីរចុងឆ្អឹង ស្មៅតស្អួង មានកិរិយាបំរុងខ្ជិលជាការងារ,

ច) ចិត្ត ទ្វារជាទីកើតនៃធម្មារម្មណ៍ មានកិរិយាត្រិះរិះពិចារណាជាការងារ, មិនឲ្យពួកមហាចោរ គឺលោភៈ ទោសៈ មោហៈ ទាំងពួកចោរដែលជាបរិវារ គឺអកុសលា ទីងតាមខស្សៅ ដើរចូលមកតាមទ្វារទាំង ៦ នោះ ទោះទ្វារណាមួយ មកលបលួចយកទ្រព្យសម្បត្តិ គឺសីល-សមាធិ- បញ្ញា អំពីខ្លួ គឺហឥយតែបានឡើយ ។ ឯការប្រុងប្រយ័ត្នរក្សាទ្វារទាំងនោះ ជានដល់ការតាំងសតិជាឆ្នាំទ្វារចាំឆែករនេវ គាលបើនាយឆ្នាំទ្វារពិនិត្យមៅហើយដឹងថា នេះជាមហាចោរ នេះជាពួកចោរបរិវារ ដូច្នោះហើយនោះ ត្រូវឃាត់ដំណើរពួកនេះទុក ឬកំបរណ្តេញចំបរឲ្យចេញផុតទៅ ។ តែបើសន្លឹតពិនិត្យយ៉ាងម៉ត់ចត់មៅហើយដឹងថា នេះជាពួកពាណិជក្រុមសតិប្បដ្ឋាន ៤, នេះជាពួកកសិករក្រុមសម្មប្បធាន ៤, នេះជាពួកអាកាសចរក្រុមឥទ្ធិបាទ ៤, នេះជាពួកប្រជានក្រុមឥន្ទ្រិយ ៥, នេះជាពួកពិជ័យសង្គ្រាមក្រុមពលៈ ៥, នេះជាពួកបដិវេធប្បណ្ឌិត ក្រុមសម្ពោជ្ឈង្គៈ ៧, នេះជាពួកមេដំនើរក្រុមមគ្គប្រកបដោយអង្គ ៨ ដូច្នេះហើយ ត្រូវបើកឧកាសឲ្យធ្វើដំណើរចូលតាមទ្វារនោះ ។ ៧ ។ ការប្រុងប្រយ័ត្ន មិនឲ្យបាបធម៌ចាំងភ្លាយ មានឧកាសចូលមកដឹកនាំ

ជានយ៉ាងនេះ ទើបហៅថាសញ្ញមៈ ។

៤- ទមៈ "ការខ្នាតចិត្ត" ជានដល់ការសង្កត់សង្កិនចិត្ត ឲ្យមានរៀបរៃបែបបទល្អ ឬការយោគចិត្តឲ្យត្រូតត្រាមលើចំពោះអកុសលកម្មផ្សេង ។ ព្រោះថាចិត្តនេះ បើហ្វឹកហាត់ការខ្នាតប្រៀនប្រដៅហើយ ទៅជាចិត្តប្រើការមានកើតទេ តាំងពុំសមមៀងដល់ការណាមួយតួងខ្លួនឯង ។ ហេតុនោះ ការខ្នាតប្រៀនប្រដៅចិត្តជានជាគុណប្រសើរបំផុត ឥតមានអ្វីជាគ្រឿងប្រៀបផ្ទឹមជានឡើយ ។ ពុទ្ធភាសិតសំដែងមកក្នុង ចំពោះការខ្នាតប្រៀនប្រដៅចិត្តថា : ចិត្តស្ស ទមថោ សាធុ "ការខ្នាតចិត្តជាន ជាគុណញុំងប្រយោជន៍ឲ្យសម្រេច", ចិត្តំ ទន្តំ សុខាវហំ "ចិត្តដែលគេប្រៀនប្រដៅជាន ជាគ្រឿងនាំមកនូវសេចក្តីសុខ" ។

បុគ្គលមួយរូប ។ សុទ្ធតែមានចិត្តជាអធិបតី, មានចិត្តជាគ្រឿងសម្រេចការ ឬមានចិត្តជាមេការ សមដូចព្រះពុទ្ធភាសិតក្នុងគម្ពីរធម្មបទគាថាថា :

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទន្តំ ។

សេចក្តីថា: ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តជាធំ

សម្រេចតែគំនិតចិត្ត, បើបុគ្គលមានចិត្តអាក្រក់ទំយោយ ឬធ្វើការអ្វីអាក្រក់) ចិត្តអាក្រក់នោះឯង តែងកៀរគ្រងសេចក្តីទុក្ខលំបាកហើយជាប់តាមរៀង, ដូចជាកង់រទេះដែលវិលជាប់តាមស្នាមដង្កៀរគោ ។

បុគ្គលកាលរូបសុទ្ធតែមានចិត្តជាធំ- ជាគ្រឿងសម្រេចការឬជាមេការយ៉ាងនេះ បើគ្មានការហ្វឹកហ្វឺនចិត្ត គ្មានការបង្ហាត់ចិត្ត គ្មានបែបបទល្អសោះ តើនឹងអាចដឹកនាំអត្តភាពនោះឲ្យទទួលយកសម្បត្តិសួគ៌-និព្វានសុខក្សេមក្សាន្តដូចម្តេចបាន ។

ហេតុនេះ គួរជនពាំនឹងឡាយតំណត់ទុកថា: អាហារត្រូវបរិភោគរាល់ថ្ងៃ, ទឹកត្រូវផឹករាល់ថ្ងៃ បើដូច្នោះ ចិត្តក៏ត្រូវតែប្រដៅឲ្យរាល់ថ្ងៃផងដែរ ។ អ្នកប្រាជ្ញពាំនឹងឡាយ មានព្រះពុទ្ធដាដើម តែងសរសើរការប្រឹនប្រដៅចិត្តនោះរាល់កាលទាស់ ដូចជាព្រះគាថាដែលទ្រង់ដាស់តឿនថា:

សុទុទ្ទសំ សុនិបុណំ យត្ថកាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

សេចក្តីថា: បុគ្គលជាបណ្ឌិតមានប្រាជ្ញាគួរតែខំប្រឹងចិត្ត រក្សាចិត្តដែលឃើញបានដោយកម្រ ដែលស្អិតពន់ពេក ដែលលង់ទៅតាមអារម្មណ៍ណាមួយហើយ មិនងាយនឹងតាញ៉ែរាកចេញមកវិញបាន, ចិត្តដែលអ្នកមានប្រាជ្ញាបានខ្ចប់ខ្ចាន់ហើយ តែងនាំសុខមកឲ្យ ។

ធម៌ ការខ្ជាន់ចិត្តពិតនោះគឺ ការតម្រង់ចិត្តឲ្យស្គាល់ទោស ដែលហៀរហូរចេញពីកាយ៖ ទោស ទីឆ៌មោហ ហើយបង្វឹកវាឲ្យ ស្រឡាញ់គុណនិងឆ្ងល់បស់ត្រៃសិក្ខតី សីលសិក្ខា សមាធិសិក្ខា ទីឆ៌បញ្ញាសិក្ខា ; ឲ្យត្រាច់ទៅតាមផ្លូវនៃអរិយធម៌ ចូលសំដៅទៅ និព្វានបុរី ដើម្បីយកសន្តិសម្បត្តិ ឬកំយកបំពង់តីសមាធិភាវ ៤ ទៅ ស្រូបទឹក (ទុយ) ពាំង ៤ អន្ទង់ បង្ហូរចោលឲ្យអស់អំពីមហាសមុទ្រ គឺ តណ្ហា , ហើយយកវឹកតឹសីល ទៅសត់ក្តក់ក្តូរ គឺមាន , យក កែវទ្វេះ គឺបញ្ញា ទៅបញ្ចាំងស្ងាប់ងងឹត គឺមោហ ។ តាលុះបើយោគាវចរ ព្យាយាមខ្ជាន់ចិត្តដូចន័យដែលបានពណ៌នាមកខ្ទេះ មុខជាទីឆ៌ បានមហាមច្ចុតីសោតាបន្ន សកទាគាមិភាព, បានត្រជាក់កាយ សប្បាយចិត្តសះមុខរបួសជាដំណើ តីអនាគាមិភាព, បាត់ឫទ្ធិតមមឺង មមាំឆ៌តាំងតំនិត តីអរហន្តភាព ។ បុគ្គលដែលប្រតិបត្តិដល់មកថ្នាក់ ខ្ទេះហើយ បានឆាមថា " ព្រះខីណាស្រព, ព្រះអសេក្ខបុគ្គលឬ ព្រះអរហន្ត ", បុគ្គលនោះឈ្មោះថា ញ៉ាំងទិដ្ឋធម៌ព្រះពុទ្ធសាសនាឲ្យ ចប់ ព្រោះអស់តិច្ចដែលត្រូវបំពេញ ត្រូវប្រតិបត្តិដើម្បីអ្វីទៀតហើយ ; ធម៌ដែលលោកដល់ហើយនោះ ហៅថា អរហត្ត ដែលជាកំពូលនៃ សត្តសាសនធម៌បស់ព្រះបរមៈលោកនាថ, លុះដល់សត់បញ្ចក្ខន្ធទៅ

អាចបញ្ជូនផលញាណ ដែលកើតអំពីវិបស្សនាយោគៈ (ព្យាយាមដាក់ត្រឿងប្រកបក្នុងវិបស្សនាញាណ គាំង ១០ ណាមួយ) ទៅត្រង់រងយកបរមសុខដ៏ឱឡារិកតាត់ឥតប្រែប្រួល ដែលហៅថា ព្រះនិព្វានៈនោះឯង ។

ហេតុនេះ សាធុជនគួរម្ចាស់ណាដណ្តើមយកទម្លាប់នោះ មកទុកក្នុងខ្លួនឲ្យបានរួសរាន់ឡើង តាន់សម័យនៃដំរីតំពុងមានទៅ តែទុកឲ្យដំរីតរលត់ផុតទៅហើយ គ្មាននរណាអាចប្រតិបត្តិដំនួសខ្លួនយើងបានឡើយ ។

សម្តេចព្រះសក្យមុនីគោតមបរមសម្ពុទ្ធ ទ្រង់ត្រាស់បង្គាប់ឲ្យពួកពុទ្ធបរិសទ្យចំពោះតថាគតក្នុងប្រតិបត្តិចំពោះធម៌នេះ ដោយគាថាដ៏តាស៊ីតយ៉ាងនេះថា:

ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច
ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។

សេចក្តីថា: អ្នកប្រាជ្ញគប្បីធ្វើទ្វីបៈ គឺព្រះនិព្វានដែលតុយៈត្រៃបសន្តិត៍មិនជាន ដោយធម៌ ៤ ប្រការគឺ: ឧដ្ឋានៈ១, អប្បមាទៈ១, សញ្ញមៈ១ ទមៈ១ (តាមន័យដូចបានពណ៌នាមកហើយនេះឯង) ។

ធម្មទេសនា ដែលជាខ្លឹមដែលអំពីទីបធម្មកថា តំណាលមកត្រូវដល់ការបរិច្ចេទត្រឹមប៉ុណ្ណេះ ។

ទុដ្ឋានធម្មសាកច្ឆាសជា

ព្រះមហា មៅ-ខាន់

សមាជិកក្រុមជំទុំ ប្រៃព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

ឧទ្ទេស ៣ ជំពូក

សូមនមស្សការ ចំពោះព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រមទាំងព្រះធម៌ទាំងព្រះសង្ឃ ដោយសេចក្តីគោរព ។

បន្ទាប់ពីនេះ សូមសម្តែង ព្រះធម្មទេសនា ជាទង្វើនៃពុទ្ធសាសនៈ តាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ដើម្បីជាសារានុគ្គហៈដល់សង្ឃ ដល់អស់លោកសាធុជន អ្នកប្រាថ្នាប្រយោជន៍ក្នុងការស្តាប់ធម៌ទាំងឡាយ ដោយលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ យល់ឃើញអំណាចប្រយោជន៍នៃគម្ពីរព្រះត្រៃបិដក ដែលពុទ្ធសាសនបណ្ឌិត្យ បានចោះពុម្ពផ្សាយ ក្រោមការឧបត្ថម្ភរបស់ព្រះពាជរដ្ឋាភិបាល ហើយមានសេចក្តីជ្រះថ្លា ប្រាថ្នាឱ្យអត្ថន័យដ៏មានសារៈនៃគម្ពីរនេះ សាយភាយជ្រួតជ្រាបដល់សន្តានចិត្តនៃសាធុជនទូទៅ ទើបចាត់ទុកព្រះសង្ឃក្រុមជំទុំប្រៃព្រះត្រៃបិដក ឱ្យដកស្រង់អត្ថបទតាមគម្ពីរនេះទុក។ មកសំដែងផ្សាយតាមខ្សែជាតិ ។ ការប្រកាសផ្សាយគម្ពីរព្រះត្រៃបិដក ក៏ឈ្មោះថាប្រកាសផ្សាយនូវព្រះសទ្ធម្ម ឬព្រះពុទ្ធសាសនាទាំងមូល ព្រោះព្រះសទ្ធម្មដែលពាក់ព័ន្ធជាមួយនឹងធម៌ទាំងប៉ុន្មាន សុទ្ធតែមានមកកាន់គម្ពីរ

ព្រះត្រៃបិដកទាំងអស់ ។ មែនពិតគម្ពីរព្រះត្រៃបិដកនេះ ជាគោលលទ្ធិក
នៃព្រះពុទ្ធសាសនា ជាឃ្លាំងប្រដាប់ក្រឹត្យផ្តុតពេញដោយបញ្ញាដ៏ជ្រួចជ្រាន សីល.
ធម៌ ទស្សនវិជ្ជានដ៏បរមត្ថវិជ្ជា ដ៏ជាពុទ្ធោវាទ មានជាន់ មានថ្នាក់
ពីពាក់ភៅជ្រៅ តាមលំដាប់សម្រាប់ដឹកនាំមនុស្សលោកឲ្យរៀសសុទ្ធរឿង
នឹងសុខសន្តិភាព តឹងឲ្យបានសម្រេចសម្បត្តិមនុស្ស សម្បត្តិទេវតា
សម្បត្តិព្រះនិព្វាន ។ អ្នកណាមានគម្ពីរព្រះត្រៃបិដកនេះ ពុកដូច
ជាមានឃ្លាំងនៃត្រៃពិធសម្បត្តិ កាលបើទស្សាហ៍អាន ទស្សាហ៍សិក្សា
នឹងប្រតិបត្តិតាម កំអាចកាន់យកគុណប្រយោជន៍អំពីគម្ពីរនេះមិនមានខ
បំផុត ។ ពុំនោះសោត អ្នកដែលមានគម្ពីរព្រះត្រៃបិដកនេះ ដំកល់ពុកជា
ធម្មសម្បត្តិហើយ ពុកដូចជាបានតួអង្គព្រះសម្ពុទ្ធនឹងអរិយសាវក មកគង់
ក្នុងទីចំពោះមុខ កាលបានអាន បានសិក្សា ដូចជាបានព្រះអង្គមកសំដែង
ធម៌ប្រាសដូច្នោះដែរ ។ ម្យ៉ាងទៀតគម្ពីរព្រះត្រៃបិដកនៃយើងនេះ លោក
ចុងរៀបរៀងជាភាសាមគ្គ ជាសេចក្តីប្រែមគ្ងឹះប្រៀបដូចជាដួងប្រទីបពន្លឺរ
លោកជាក់ច្បាស់ណាស់ សម្រាប់ចំភ្លឺដល់មនុស្សលោកឲ្យដើរទៅកាន់សេចក្តីសុខ
សួស្តីតាមសេចក្តីប្រាថ្នា ឬតាមនិស្ស័យជាសនាវបស់ខ្លួន ។

ដូច្នេះ សូមលើកយកពុទ្ធភាសិតមួយអង្គ ដែលទ្រង់ត្បាក់ដោះ
បញ្ញាអស្ចារ្យយក សំដែងមកក្នុងគម្ពីរព្រះត្រៃបិដក ត្រង់សំយុត្ត-
និកាយ សគាថវគ្គមកសម្តែងដូចតទៅនេះ :

យក្ស ខ្ញុំសួរព្រះអង្គថា:

តើបុំសុ វិន្ធតេ ធនំ បុគ្គលធ្វើដូចម្តេចទើបបានទ្រព្យ ?

ព្រះអង្គត្រាស់តបថា បដិរូបការី ឆុរកា ឧដ្ឋានា វិន្ធតេ ធនំ បុគ្គលតប្រាណដោយធ្វើការងារតាមសមគួរ មិនលះធុរៈ រមែងបានទ្រព្យ ។

ព្រះតម្រាស់នេះទ្រង់សម្តែងបញ្ជាក់ថា ព្យាយាមជាហេតុ បានទ្រព្យជាផល ។ តែមុនទីសម្តែងពីសេចក្តីព្យាយាម សូមសម្តែងពីប្រភេទនៃទ្រព្យ ដើម្បីគុណគាថាបស់ទ្រព្យឲ្យឃើញជាមុនសិន ។

ទ្រព្យ គឺបស់បរប្តូរគ្រឿងប្រកបឲ្យសម្រេចផល គឺធ្វើអ្នកមានទ្រព្យ ឲ្យស្រួលកាយ ចូលយតំនិត ឲ្យបានសេចក្តីសុខសម្រាន្ត ច្រើនប្រភេទ ស្រេចហើយតែនឹងចំនួនឬកម្ចាត់នៃទ្រព្យដែលមាន ។ ទ្រព្យនោះមានច្រើនប្រភេទ តែលោកចែកដោយខ្ទីមាន ២ គឺ: ពាហិរទ្រព្យ ១ អជ្ឈត្តិកទ្រព្យ ១ ។

១- ពាហិរទ្រព្យ ទ្រព្យខាងក្រៅ ចែកចេញជា ២ គឺ សំហារិមទ្រព្យ ចុះដល់របស់ដែលគេចធ្វើឲ្យឃ្លាតចាកទីដើមក៏បាន ដូចយន្តយាន តាហាន: ស្រូវ៉ាក់ មាស គ្រឿងទបគោគ-បរិភោគជាដើម១, អសំហារិមទ្រព្យ បានដល់របស់ដែលមិនអាចឲ្យឃ្លាតចាកទីបាន ដូចដីធ្លី ទីភូមិ ស្រែចំការ ផ្ទះសំបែងជាដើម ១ ។ បណ្តាទ្រព្យទាំងពីរនេះ ចែកចេញជាពីរទៀតគឺ ទ្រព្យដែលចាំបាច់១ ទ្រព្យដែលមិនសូវចាំបាច់ ១ ។

របស់ណាមើលទុកជាមិនមាន ក៏មិនដល់ទៅជាកើតរសេចក្តីទុក្ខលំបាកក្តៅក្រហាយ ដូចគ្រឿងប្រដាប់សម្រាប់តែងកាយឲ្យហ៊ីហា ឬគ្រឿងតាំងគ្រឿងតែងគេហដ្ឋានខ្លះ ដែលសើសតែរសេចក្តីត្រូវការ នេះហៅថាទ្រព្យមិនសូវចាំបាច់ ។ របស់ណាដែលខ្វះមិនបាន ដូចគោជនាហារសំលៀកបំពាក់ទីនៅអាស្រ័យនឹងថ្នាំពែរពេត ព្រមទាំងគ្រឿងទបករណ៍ដែលជាជំនួយដល់ការរស់នៅ នឹងគ្រឿងការពារគ្រោះអន្តរាយ ដើម្បីឲ្យបានសុខសម្រាន្ត ទាំងនេះជាទ្រព្យចាំបាច់ ជារបស់គួរស្វែងរក ។

២- អដ្ឋង្គត្តិកទ្រព្យ ទ្រព្យមានអង្គ៨ មានពាក្យថា អដ្ឋង្គសមន្នាគតំ ទ្រព្យដែលឲ្យផលដល់ខ្លួនដរាបដល់អស់ជីវិត ឬទ្រព្យដែលអាស្រ័យប្រើក្នុងវេលាមានអាយុវែងតែប៉ុណ្ណោះ, អនុត្តរាមិសកនិធិ ទ្រព្យដែលផ្តល់ផលពិសេសដល់ខ្លួន ទាំងក្នុងបច្ចុប្បន្នទាំងក្នុងលោកខាងមុខ ។ ល ។

បណ្តាទ្រព្យទាំងក្នុងទាំងពីរយ៉ាងនេះ, ចំណែកវិជ្ជាផ្សេងៗ ដែលជាសម្បត្តិដ៏ឥតជាប់នឹងខ្លួន ធ្វើឲ្យអ្នកដែលបានហាត់រៀនមក មានរសេចក្តីចេះដឹង មានគំនិតគំនឹងមានរសេចក្តីឥតងឿងឆ្ងល់ដែលមិនទាន់បានហាត់រៀនជាដើម ចេះសរសេរ ចេះអាន ចេះចាត់ចែង ចេះគួរកិច្ចការទាំងពួង យ៉ាងនាឯបាប់តាំងពីកិច្ចការក្នុងគ្រួសារឡើងទៅ ត្រូវចាត់ចែង ត្រូវធ្វើយ៉ាងណាៗ ដើម្បីឲ្យបានរបៀប មិនខំនាស់ខឹងអន្ទាក់ឯ ឬតាមសម័យនិយម ចេះសិល្បៈប្រការខ្លះ ដូចការដាំង ការឈ្នួញ ខឹងហត្ថកម្ម ឬវិជ្ជាដ៏វិ-

ដទៃ ។ មានចេះរបៀបធ្វើស្រែចំការជាដើម ចេះទំនៀមទម្លាប់ប្រពៃណី ចេះប្រាស្រ័យសន្ទនា ក្នុងវេលាដែលខ្លួនត្រូវគាត់ធនធីនប្រជុំជន ក្នុងសម័យនោះ ។ ហួតដល់ចេះបញ្ជាប់ទម្លាប់ ឬរៀងជាន់ខ្ពស់ផ្សេងៗទៀត នេះហៅថា អន្តសមនិធិ ទ្រព្យដែលជិតជាប់នឹងខ្លួន ។

ចំណែកការប្រតិបត្តិល្អ ដែលហៅថា បុណ្យកុសលគ្រប់ប្រការ ដូចជា-ការបរិច្ចាគទ្រព្យបរិស័ទ្ធឲ្យដល់អ្នកដទៃ ដោយចេតនាអនុគ្រោះ ឬបូជាគុណ ឬក្នុងថ្នាសាធារណប្រយោជន៍ ដូចសាងសាលារៀន មន្ទីរពេទ្យតាំងបាលពេត សាងថ្នល់ សាងស្ពាន សម្រាប់ការចរាចរ ជីកអណ្តូងជីកស្រះ សម្រាប់ប្រជាជនអាស្រ័យ នឹងឧបត្ថម្ភព្រះពុទ្ធសាសនា មានសាងកុដិវិហារសាលាជាដើម សម្រាប់បណ្តុះផ្សាយសេចក្តីល្អ ដល់ពួកកុលបុត្តខ្លះៗ, ស័ល ការគាំងចិត្តសង្រ្គម ការពោរមិនឲ្យទោសខុសត្រូវតែតើតឡើងបាន មានការយកម្ន ចរិកម្ន មនោកម្ន ប្រកបដោយមេត្តាករុណាចំពោះសត្វភាំងតួង នឹងការទាំ គឺការអប់រំចិត្ត ដោយការនឹកគិតពិចារណាខ្លួរអំពើល្អដែលខ្លួនបានសាងសន្សំមកហើយ ដើម្បីធ្វើចិត្តឲ្យធ្ងន់ធ្ង ឲ្យគួរដល់ការទាកម្ន ឲ្យជាចិត្តរីកយក្លាហានក្នុងគុណធម៌នោះៗ ឲ្យជាចិត្តថ្លៃស្អាតក្រាស់ចាកមន្ទិលគ្រឿងសៅហ្មងផ្សេងៗ ជាទីបាយឲ្យកើតបញ្ញាគួរថ្លាសម្រាប់មើលឃើញសភាវៈពិត តោលដោយឈ្មោះថា

ពាន ស័ល ភាវនា នេះហៅថា អនុត្តរទានិធិ ទ្រព្យដែលជាប់តាមខ្លួន ដូចស្រមោលអនុលោមតាមប្រាណ ។

តាលប្រាជ្ញបប្រកែកនៃទ្រព្យផ្សេងៗ ដូចសម្តែងមកដោយសង្ខេបនេះ កំឃើញបានថា ទ្រព្យទាំងអស់នោះ សុទ្ធតែគួរប្រាថ្នាគួរស្វែងរក ព្រោះលោកពោលសរសើរទ្រព្យទុកថា :

ន រូបំ ន ច បញ្ញាំ ន ច ភោគា សម្ភវោ
កាលវិបត្តិសម្បត្តេ ន ន មេវ វិសេសកោ

តាលគ្រាវិបត្តិ គឺគ្រោះថ្នាក់មកដល់ហើយ ពន្លឺកាយក៏ជួយមិនបាន កេរ្តិ៍ឈ្មោះពីរោះល្អីល្អាញក៏ជួយមិនបាន ទាំងត្រកូលវង្សរៀងសន្ធាន ក៏ជួយមិនបាន មានតែទ្រព្យប៉ុណ្ណោះ ទើបជាបុរសវិសេសអាចជួយរំដោះគ្រោះវិបត្តិនោះបាន

ន ន ហិរំ ច ន ឥ មិត្តា បុត្តទារា សហោទរា
ន ន វត្តារ សោកស្មិំ ន ំ លោកេ មហាសខា ។

មនុស្សសូន្យទ្រព្យ មិត្តភិន្នាយ កំតង់លះបង់ចោល បុត្តភរិយាទីឆ្ងល់ប្លែកបង្កើត កំតង់លះបង់ចោលបាន មានតែអ្នកមានទ្រព្យទើបល្អរុងរឿង ព្រោះទ្រព្យជាប់ថាជាសំឡាញ់ធំក្នុងលោក ។

ប៉ុន្តែ បុគ្គលដែលទីឆ្ងល់ស្វែងរកទ្រព្យបាននោះ លោកពោលថាត្រូវអាស្រ័យសេចក្តីព្យាយាមជាបច្ច័យ ឬជាមូលហេតុ បានដល់ការខំឃុតចិត្ត

ពុកយាត់ ចំប្រឹងប្រែងស្វែងរក តែចំណេះ ចំប្រកបឲ្យពេញកម្លាំង ឲ្យសមគួរ តាមទាន តាមចំណង តាមសម័យកាល មិនធ្វើដោយឆ្នួលឆ្ងាយ មិនដំអក់ទម្រន់ ប្តូរដុះដោយអាងហេតុការណ៍ផ្សេង ។ បើរកចាយ ជំនះខ្លួនបស់គ្គ ចាំងពួង មិនអាងលេសថា ត្រជាក់ណាស់ ក្តៅណាស់ជាដើម ដែលជាហេតុឲ្យខ្ជិលប្រអូសមិនប្រកបការងារ ។ តែបើមានសេចក្តីខ្ជិលប្រអូសក្តី មិនស្គាល់ប្រកែរព្រមចាំងគុណប្រយោជន៍នៃទ្រព្យក្តី ជាអ្នកធ្វើទៅតាមរឿងអចាយមុខ ជាបជាប់ជំងាក់ចិត្តទៅក្នុងអចាយមុខៈនោះ ។ ក្តី កាលាយមានកេតាភាពបៀតបៀនកុំបៃក្តី ចាំងនេះក៏ជាខបស័ត្តពិឆក មិនឲ្យព្យាយាមស្វែងរកទ្រព្យកើត ។ ព្រោះហេតុនោះ ត្រូវជាអ្នកសម្បូណ៌ដោយខុចាយកំចាត់បង់ ឬការពារខ្លួន ឲ្យផុតចាកភ័យអន្តរាយនោះ ។ ត្រប់ប្រការ ចាំងត្រូវស្គាល់តម្លៃ ស្គាល់គុណប្រយោជន៍របស់ទ្រព្យ តាមចំណែកតាមប្រភេទ ដែលជាហេតុជាស់តឿនក្រើនរំលឹកចិត្តឲ្យប្រញាប់ចំប្រឹងស្វែងរក ។ ក្នុងការព្យាយាមស្វែងរកទ្រព្យនោះ គប្បីចាំហើយរលឹករឿយ ។ ដល់សុភាសិតថា

គោគេ សំមារមាឧសុ្ត កមរសេ្សវ ឥរ័យគោ

គោគា សង្ខិច្ចយំ យន្តិ វម្មិគោ វ្រូបចិយតិ

តាលស្វែងរកគោគទ្រព្យ គប្បីជាអ្នកយកតួយ៉ាងសត្វឃ្មុំ គោគទ្រព្យទើបដល់ខ្លួនការពេញពួន ដូចដំបូកដែលកណ្តៀកពួនឡើងជួញ្ជោះ ។

អប្បតោធម៌ មេធាវី ចាកតែង វិចក្ខណោ
សមុដ្ឋាបេតិ អត្តានំ អលាភំ អក្កំវ សន្ធិមំ

អ្នកមានប្រាជ្ញាចេះគិតលៃលក រមែងតាំងខ្លួនបានដោយទ្រព្យថា ដើមខ្នុន ពោះបន្តិចបន្តួច ដូចគេបង្កាត់ក្តីងដ៏តូច ឲ្យជាគំនរក្តីងដ៏ធំ ឡើងបានដូច្នោះ ។

សុភាសិតទាំងពីរបទនេះ ជាគ្រឿងសម្តែងវិធីសូងរក វិធីថែទាំរក្សា ត្រមាំងវិធីបរិភោគប្រើប្រាស់ទ្រព្យសម្បត្តិឲ្យល្មមប្រមាណ ។

ទ្រព្យជាមូលហេតុ ឬជាបច្ច័យនៃសេចក្តីរុងរឿងត្រចំយ៉ាង តប្បីតិនិត្យ ដល់ចេស់ដែលបានឃើញចំពោះមុខទាំងឡាយ ដូចគ្រឿងសំណាងនឹងរបស់ប្រើប្រាស់ សម្រាប់សេចក្តីស្រួលសប្បាយនៃខ្លួន ខឹងមនុស្សដទៃ ហួតដល់អ្នកដែលចំរើនស្តុកស្តម្ភកន្លងសម័យបច្ចុប្បន្ននេះ ក៏ឃើញបានថា ទាំងអស់នោះ សុទ្ធតែត្រូវអាស្រ័យទ្រព្យជាកម្ទាំងយ៉ាងខ្លាំងខ្លាស់ បើខ្វះទ្រព្យហើយ សូម្បីមានគំនិតត្រូវល្អយ៉ាងណាក៏ដោយ ក៏កម្រនឹងធ្វើឲ្យកិច្ចការនោះ។ សម្រេចបានល្អឡើយ ។ មនុស្សគ្មានទ្រព្យ ទើបជាមនុស្សខ្វះលំនិត ចូលកន្លងបទថា ខ្សត់ទ្រព្យអាប់បញ្ញា ។ ព្រោះហេតុនោះ សាធុជនគួរជាអ្នកខំប្រឹងប្រែងសូងរកទ្រព្យ

ទាំងខាងក្រៅ ទាំងខាងក្នុង ដែលជាគ្រឿងបំផ្លាត់សេចក្តីខ្វល់ក្រ ទំនងជាហេតុ ឲ្យបានសេចក្តីសុខចំរើន ក្នុងបច្ចុប្បន្នទំនងអនាគត ដល់ខ្លួនទីដ៏អ្នកដទៃ តាមទំយ ព្រះពុទ្ធកាសិត ដែលបានលំទិតទុកខាងដើមនោះ កុំបីអាក់ខានឡើយ ។

មុខទីបញ្ចប់នូវព្រះធម៌ទេសនានេះ សូមថ្វាយព្រះពរជ័យសួស្តីចំពោះព្រះករុណាជាអម្ចាស់ជីវិតទាំងឥព្រះអង្គ ទំនងសម្តេចព្រះទុបយុវរាជ សូមទ្រង់គង់នៅក្នុងសិរីពរជ័យសម្បត្តិ ប្រកបដោយព្រះបរមសុខជានិច្ចនិរន្តរ៍ ដើម្បីជាពំនាក់នៃជាតិ ទំនងជាគ្រឹះនៃព្រះពុទ្ធសាសនាអស់កាលជាអង្វែងតទៅ ។

សោត្តិ បច្ឆា ភុ សោត្តាភេ សាធវោ ពុទ្ធមាមកា

សូមសាធុជនពុទ្ធមាមកៈអ្នកតាំងចិត្តស្តាប់ទាំងឡាយ បានដល់នូវសិរីសួស្តី គឺសេចក្តីសុខ សេចក្តីចំរើន កុំបីឃ្លៀងឃ្លាតឡើយ ។

អយំ ធម្មទេសនា សង្ខេបេន សមត្តា ព្រះធម៌ទេសនាដែលបានសម្តែងមកនេះ សន្មតថាចប់ដោយសង្ខេប ត្រឹមប៉ុណ្ណេះឯង ។

សុរពជាតក

(តមក)

លោក ប៊ិង-រ៉ង បម្លែងពីសារាស្ត្រស្ងឹករឹត

ខើបផ្តាំអ្នកឃាមថ្មារថា បើឃើញបុរសស្លៀកខ្មៅ ដណ្តប់ខ្មៅចូលមក អ្នកកុំឃាត់ឡើយ ឲ្យចូលមកចុះ, លុះឆ្នាំស្រែចហើយ គឺចូលទៅកន្លែងព្រះរាជវេន ។ គាលនោះ ព្រះរាជាជាកំដរសន្ធូចត់ទៅពុំខាន់ ដល់ទៅព្រះរាជកំនើតជាខាងក្រោយ ស្តេចដេញតាមទៅកន្លែងព្រះរាជវេន ។ ឯពួកអមាត្យមានសេនាបតីជាដើមគិតថា អយំ ចោរោ អានេះជាចោរ ពាយកដ្ឋិមកម្ពុជព្រះមហាសុត្រ ប្រជាប់ខ្លួនវា ខើបត្រូវមហាសុត្រច្រឡំព្រះពស្ត្រខ្មៅ យាងចូលមកតាមក្រោយប្រុងចាប់អានេះ ។ គ្រានោះ ព្រះរាជកុមារស្ទុះចូលទៅក្រាបទៀបព្រះភូតានៃព្រះមហាសុត្រ ហើយក្រាបទូលថា អហន្តេ បុត្តោ តេ ជាតាមិ បតិត្រស្សក្រៃថ្ងៃប្រសើរអើយ! ខ្ញុំសូមព្រះបង្គំជាព្រះរាជបុត្រទ្រង់ព្រះអង្គ ។ សម្តេចព្រះមហាសុត្រជាតិរាជព្រះអង្គពុំជឿ ខើបត្រាស់ថា ម៉ៃហោរ! អ្នកជាខ្ញុំនអ្នកជាកូនអញ ។ ពុំជឿឡើយ ។ ព្រះរាជកុមារក្រាបបង្គំទូលថា ខ្ញុំសូមព្រះបង្គំនេះ ជាកូនតាំងនៅតរៈសាកិនី នៅខតរៈឈ្មោះឯណោះ ព្រះអង្គជាព្រះបិតានៃខ្ញុំសូមព្រះបង្គំតិតប្រាកដ បើព្រះអង្គពុំជឿ សូមព្រះអង្គខតចំរៀងព្រះទំរង់នេះចុះ មម មាតុយា ព្រះអង្គបានព្រះរាជទានដល់មាតារបស់ខ្ញុំ

ព្រះអង្គ ហើយមានព្រះបន្ទូលតបទៅនឹងព្រះបន្ទូលថា ព្រះវរបិតារបស់ចាឯវ៍ គឺព្រះជាម្ចាស់ដែរ ដូច្នោះ ទើបទូលព្រះបន្ទូលមានចិត្តគិតថា ធ្វើដូចម្តេចទើបឃើញព្រះអង្គជាព្រះវរបិតា, ទើបសោមានមក, មានបានឲ្យព្រះទំនើងនេះដាច់ខ្លួនឡើយ ។ ព្រះពាក់ព្រះឆ្នឹងតទៅព្រះទំនើងហើយស្គាល់ ទើបត្រាស់នឹងសេនាបតីថា ម្នាលសេនាបតី ! អ្នកចូរពិនិត្យមើលព្រះទំនើងទេវប្រាកដជារបស់អញ ឬមិនមែនទេ ? ។ សេនាបតីក៏យកព្រះទំនើងទាំងមកពិនិត្យមើលហើយដោយសព្វគ្រប់, ស្គាល់ជាក់ជាព្រះទំនើងនៃព្រះមហាក្សត្រខ្លួន ទើបក្រាបបង្គំទូលថា បពិត្រក្សត្រៃលោកប្រសើរអើយ ! ព្រះទំនើងនេះ ប្រាកដជាព្រះទំនើងរបស់ព្រះអង្គ. ឯព្រះកុមារបុត្រនេះ ក៏ប្រាកដជាព្រះកុមារបុត្ររបស់ព្រះអង្គដែរ ។ ទើបស្តេចត្រាស់ថា ម្នាលបុរោ ! ហេតុអ្វីក៏អ្នកមិនមកដោយត្រង់ អ្នកធ្វើជាចោរដូច្នោះ ? ។ បពិត្រព្រះវរបិតា អបរំ ខុដ្ឋកំ អាគតោ ថាបើទូលព្រះបង្គំមកដោយត្រង់ ធ្វើម្តេចនឹងបានចូលមកដល់ព្រះអង្គ, តួនទូលព្រះបង្គំជាអ្នកកំសត់ទុគ៌ត ខុទ្ធាវុតោ សំតត់ដណ្តប់ក៏ដាច់រយើករយោក ខុទ្ទិ-វត្ថោ សំតត់សម្លៀកក៏ដាច់ដាចច្រើនចំណែកណាស់ ព្រោះដើរដោយផ្លូវឆ្ងាយក្រនឹងមកដល់ ; ប្រការមួយទៀត អស់មនុស្សទាំងឡាយក៏គេមិនស្គាល់ថា ខ្ញុំទូលព្រះបង្គំជាព្រះកុមារបុត្រនៃព្រះអង្គដែរ ខ្ញុំទូលព្រះបង្គំស្ទុះស្ទីមកកៃព្រះអង្គដោយការលំបាកកន្តើតណាស់ ជាបើចំពោះ

ចូលមក អ្នកថ្មាំគ្រូនេះសេនាមាត្យពាំងពួង គេនឹងជាក់ចាត់ក្បាលខ្លួលព្រះបង្គំ តើខ្លះណាគេនឹងមកគ្រាបខ្លួលព្រះអង្គ, ខ្លួលព្រះបង្គំតែងដូច្នេះ ទើបខ្លួលព្រះបង្គំធ្វើជាចោរ, ការឧបាតសង្ឃាតពាំងម្ល៉ះនេះ ប្រាថ្នានឹងសំដែងអានុភាពតាមឧត្តុយជាតិតែម្យ៉ាង, ឯទ្រព្យសម្បត្តិដែលខ្លួលព្រះបង្គំយកទៅខុតកន្លងណា ។ សូមព្រះអង្គជ្រាបអស់អ្នកនគរថា របស់ទ្រព្យណា ។ ដែលចោរលួចយកទៅ ចូរអ្នកជាម្ចាស់ទ្រព្យទៅយកនៅទីឯណោះ ។ រីឯហោង ។ ព្រះកជាជ្រាបហើយមានព្រះពជហឫទ័យត្រេកអរឥតឧបមា ត្រាស់ប្រើអមាត្យឲ្យទៅរាយតង្រាបអស់អ្នកនគរជួបព្រះពជកុមារគ្រាបខ្លួល ។ អមាត្យក៏ចាំតែងជ្រាបអស់អ្នកនគរឲ្យទៅយកទ្រព្យរបស់ខ្លួន ។ ។ កាលនោះព្រះកុមារដ៏តពជស្តេចគាំងព្រះពជកុមារជាឧបពជ ។

ឥតិ សា បណ្ឌិតា ទេវី រីនាងបណ្ឌិតទេវី ជាស្ត្រីឈ្លាសវៃនាងនិពន្ធរឿងពាំងពួង តាំងពីបឋមយាមរហូតដល់យាម ៤ ភ្លឺ ទើបចប់ ។ រីព្រះបាទចន្ទពជដែលមានព្រះពជហឫទ័យកាចសាហាវ ម្ចុះ តោ ចិត្តោ ព្រះអង្គមានព្រះពជហឫទ័យខន់ ហើយអតិសេកនាងបណ្ឌិតទេវីនុ៎ះ ជាមហេសី ។ តតោ បច្ចាយ ចាប់ដើមតាំងពីថ្ងៃនោះមក ព្រះបាទចន្ទពជក៏បំពេញនៅក្នុងនគរនៃអគ្គមហេសី ទ្រង់រក្សាទសពិធរាជធម៌ តុំឲ្យអ្នកនគរមានចលាចលឡើយ មិនត្រឹមតែប៉ុណ្ណោះ

ព្រះអង្គទ្រង់សង្គ្រោះគាំពារប្រជាទុក្ខស្ត្រេដោយសង្គហធម៌៤យ៉ាង, ទ្រង់មានព្រះកដហឫទ័យជ្រះថ្លាឱ្យគាននក្សាសីល លុះសោយទិវង្គតទៅបានទៅកើតឯស្ថានសួគ៌ខេវរាលោកនាយហោង ។

ឥតិ សុវត្ថោ តោធិសត្តោ តាឯ វត្ថុឯ អាមាវត្តោ រីឯព្រះសុតោភោធិសត្វ ទ្រង់បានទាំទាហាណ៍ទីឆិនទិគាននផ្សេងៗដូច្នេះ ដើម្បីដោះសោកន្លឹព្រះគាថាថា អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា, ឫជា ច ឫជនីយានំ ធ-តម្មក្ខលមុត្តមន្តិ ប្រែជាសេចក្តីថា អសេវនា ច ពាលានំ ពុំបាននសេពគប់នឹងមនុស្សពាល១, បណ្ឌិតានញ្ច សេវនា ច សេពគប់នឹងអ្នកប្រាជ្ញ១, ឫជា ច ឫជនីយានំ គួរប្តូជាចំពោះបងប្អូនជាអ្នកដឹកសមណព្រាហ្មណ៍នឹងព្រះតេនៈតាំង ៣ ដែលគួរប្តូជា ១, ឯកំរិតមិត្តិនេះ ឧត្តមំ ជាមង្គលម្រេស៊ោ ពុំដឹងបើនឹងគណនាបាន ។

រីឯបុរសតាំងពី (បុរសតុនកុតនឹងបុរសល្មោកបង់បានកុត) លុះបាននស្តាប់ព្រះធម៌វិសេបទេសនានៃព្រះបរមគោធិសត្វហើយ មានចិត្តគោរពនិលះបង់ផ្ទុសភ្ញាក ថ្វាយបង្គំលាព្រះបរមគោធិសត្វទៅតាន់ផ្ទះអាត្មាទីខែ ។ ហោង ។

ឝាលនោះ ព្រះបរមគោធិសត្វ ទ្រង់លីលាបៀញពីសាលានោះ ឆ្ពោះទៅដល់ខនរមួយទៅវិសខក្សិណ ចេញពីនោះទៅដល់ស្រុកមួយទៀត

ឈ្មោះ តក្កសិក្រុម, មានអាចារ្យមួយឈ្មោះ អម្ពុលត្ថិរ័ន ។
នៅក្នុងស្រុកនោះ មានកុដុម្ពីកម្នាក់ឈ្មោះ សុចិ ជាអ្នកចាំថែទាំនិងជាមគ្គុទ្ទាយកក្នុងអាចារ្យនេះ ។ ឯអាចារ្យនោះមានសមណៈ ១ អង្គ ព្រះនាមសុធម្មសមណៈ ។

ឯកាស្មឹ កាលេ ពេលមួយ ព្រះសុធម្មសមណៈ ចង់ទៅសួរញាតិការនៅភូមិឆ្ងាយ ទើបហៅសុចិកុដុម្ពីកនោះមកឆ្ពោះថា អម្ពោ ឧបាសក ហៃ។ ចាសកដ៏ចំរើន ! ឥឡូវអាត្មាភាពចង់ទៅភូមិឆ្ងាយ ដើម្បីនឹងទៅសួរញាតិការនៃអាត្មា ចូរអ្នកយកហិបនេះទៅទុកក្នុងផ្ទះនៃអ្នកផងចុះ ខំរំអាត្មាវិលមកវិញ ។ កុដុម្ពីកនោះសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ចូនដាក់អ្វីខ្លះក្នុងហិបនេះ ។ អាត្មាដាក់ថ្នាំជូសឈើសម្បកនឹងខ្មៅឈើ ។ ទើបកុដុម្ពីកទទួលថាសាធុ។ ហើយពុំបានបើកមើលហិបនោះឡើយ លីយកទៅទុកក្នុងផ្ទះ ។ ប៉ុន្តែហិបនោះចៅអាវាសដាក់ថង់មាស ១ សែនដុល្លឹងខាងក្រោម យកសម្បក-ជូស-ខ្មៅឈើដាក់ខាងលើ ។ ឯសុចិកុដុម្ពីក លុះលើហិបទៅ ទឹកសង្ឃឹយថា ទ្រព្យអ្ហ៊ុ ! នៅក្នុងហិបនេះឆ្ងន់ណាម្ល៉ះ ! ទើបបើកហិបរំសម្បក - ជូស - ខ្មៅឈើចេញ ឃើញមាស ១ សែនដុល្លឹងគិតថា ព្រះភិក្ខុពុំបានប្រាប់អញ។ ឧបាយកមាសនេះទុកព្រះភិក្ខុនេះតរយកវិញឬទេ ។ គិតដូច្នោះហើយក៏យកមាសទុកទាន់ក្រៅដាក់ចន្លំដែងដំនួស រួចយកសម្បក-ជូស-ខ្មៅឈើមកដាក់ដូចដើមវិញ ។

(មានត)

រឿងហង្សជាតក

(តមក)

លោក អឹម-ភន បណ្ឌិតអក្សរសាស្ត្រសំស្ក្រឹត

ឯបដិបត្តិលះចិត្ត ព្រមនឹងមហាក្សត្រ ឥតធម៌ភេកវៃក្រ ទើបពុទ្ធដ៏រុ
បន្ទូលថាវៃហ អស់គ្នាចំរៀ រៀលៅម្ដីម្ដា ។ ទៅប្រាប់មហាក្សត្រ ឥត
ធម៌ក្រៅក្រៃត្ស ជាអម្ចាស់ក់ ថាអញនឹងផ្សាន ទៅជ្ដានភាព ស្រុក
អញទាយណា+ ថ្ងៃនេះជាមួន ។ ពេជ្ឈយាជស្ដែងស្ដាប់ ស្ដេចបន្ទូល
ប្រាប់ ហើយទ្វើយវិនស្ដន ថាអាកុំអួត ប្រកួតប្រឡង ចូរអាវិនផ្ដន
ចុះមកវៃញណា+ ។ បើយើងខឹងចំ យកគ្នាំលំ ខ្ទូរដើមព្រឹក្ស ជួល
ចុះដល់ដី សូម្បីអាត្ម មឹងក្ស័យឯងណា+ តុំលង់ខ្ទើងហោង ។ ទើប
ស្ដេចត្រស់ថា នែម្ចាលអស់អា ពេជ្ឈយាជទ្រីស្ដួយន ចូរមឹងក្រឡាប់
រៀលធាប់ទៅផ្ដល់ កុំព្រួយមឹងហោង ចាំអញឡើយណា+ ។ ក្ស័ណនោះ
ព្រះបាទ សម្ដេចនរោត្ត ធ្លាជចេស្ដា ស្ដែងស្ដេចឡើងតង់ លើ
ហង្សយន្តណា ហោះដោយវេហាស៍ ត្រាងត្រាយរស្មី ។ ឯអស់
ពេជ្ឈយាជ យង់យល់ព្រះបាទ ហោះដោយឧតា កំតក់យន្ធបន្ធាច

អំណាចថ្កុរម៉ៃ ក្រញ្ជក្រាបអតិ- ភ័ពវរវន្ទា ។ ស្រែកថ្វាយសតួសា-ធុការ
ព្រះថ្មោ សតិដ្ឋសាស្តា ថាឧត្រះអង្គ ខ្ញុំចាំមិតា សូមមានករុណា
ប្រោសយើងខ្ញុំផង ។ អស់តាំងពេជ្ឈឃាដ សឹងថ្វាយសតួសា-ធុការ
អ៊ីងកង ស្រេចហើយក្រឡាប់ វិលទាប់មកផ្គង ជល់ក្បត្រហើយហោង
ក្រញ្ជក្រាបខ្លួលថា ។ បពិត្រព្រះថ្មោ ត្រើយត្រៃក្តូវនាថ ឥសូរសៈ-
រសា សូមមានព្រះអង្គ ស្តេចខ្ញុំក្រោធា ប្រើខ្ញុំករុណា ខ្ញុំអស់
គ្នាផង ។ នាំអ្នកពេសពៅ បណ្តើរសំដៅ ជល់ត្រៃហើយហោង
ទើបអស់យើងខ្ញុំ ចោមជុំជាមួង ដោយចិត្តប្តុំនបំង មិនមានប្រណី ។
យើងខ្ញុំស្រេចស្រាប់ លើកងារនឹងគាប់ ឲ្យក្សត្រជាវី តាប់មានបក្ស
មហិមាវិន្ធ្យ តៀងតាបធក់ត័ យើងខ្ញុំពៅហោង ។ ក្សត្រាណានោះព្រះថ្មោ
លុះឮពេជ្ឈឃាដ ខ្លួលដូច្នោះហោង ត្រួយព្រះហ្ឫទ័យ តិតត័យ
កន្ធង់ នុអញ្ជានេះម្តង តតការខេណ្ឌ ។ ឲ្យពៅសម្លាប់ ឥឡូវមិនស្ងាប់
មកមានពេសា បក្សាទាថាំ ទានាំយាត្រា ហោះដោយវេហាស
ក្រោកជគ្គវិស្ថង ។ ម៉ែះហើយសមន៍ង ក្រឡាបវិលវង់ មកវិញមិនលែង
ដ្បិតថ្មានបក្ស មហិមាខ្លះខ្លែង ម៉ែះហើយគេតែង ខឹងធ្វើពេសា ។
អញ្ជាអើយថាបើ គេមតគេធ្វើ ដោយចិត្តក្រោធា ឯខ្ញុំនអញ្ជានេះ ចាស់
ម៉ែះហើយណា សមក្សត្រជន្ម ពិតពុំលង់ឡើយ ។ ព្រះពៅបញ្ជាល់
ទ្រង់ព្រះចិត្តា អម្បាលនោះហើយ តិតឯងគេកសល់ ខ្លួញខ្លាំងត

ស្បើយ ទើបក្សត្រគ្រាណត្រើយ ទំបន្ទូលថា ។ ក្រាប់ប្រើប្តូតើ
ប្រសើរស្រស់ស្រី ស្រីតែម៉ងធីតា ឲ្យរៀលទៅថ្ពាន ឋិតឋានក្រុងគ្រុ- សាទ
សួគ៌មហិមា ពិតពុំលង់ឡើយ ។ ឯនាងមនុម្ស· តេសាទត្តម ក្សត្រ
គ្រាណត្រើយ នាងឮស្ងាម៏ រួចពីក្តីហើយ នាងទាថថានស្បើយ ខុក្ខ
ភោមនស្ប ។ ទើបនាងកល្យាណ រៀលនែងទៅថ្ពាន ក្រុងសាទនាងណា
ហើយនាងតង់ទៅ នាព្រះសាវតា មើលផ្លូវព្រះមហា ពន្ធុកខ្លើមថ្ងៃ ។

បទព្រហ្មគីត

នេះទើងថ្ងៃស្រដី ដំណើរព្រះចមរៃត្រ ស្តេចតង់យន្តមាសមៃ
ហោះត្រសៃតអណ្តែតដល់ ។ ក្រុងសាទប្រសើរហ៊ានកដតិមានតេន៍មណ្ឌល
នាងទាថស្រីសួគ៌សល់ ខតយង់យល់ព្រះកថា ។ នាងមានត្រេហ៍ឲ្យ
ស្រុះតេន៍ថ្ងៃសោមនស្ប អវតតងគណនា ខ្ញុំងថ្ងៃថ្ងូងពុំថ្មានឡើយ ។
ក្សត្រាណោះឯព្រះថ្មាទ ដល់ក្រុងសាទប្រសើរហើយ ព្រះអង្គពុំលង់ឡើយ
ស្តេចចុះចាកហង្សមាសមៃ ។ ស្តេចថ្នមព្រះប្អូនស្រី អគ្គមហេសីងាកដល់ឮ
ទាកតេន៍ប្រពៃ ព័រពង្សក្សត្រតិលាចលង់ ។ ព្រះអង្គថ្នមបបត់ ព្រលឹងអ្នក
មាសស្ងួនតន់ ចឹងាត់លើហង្សយន្ត ស្រេចហើយហៀរហោះចាកហ៊ាន ។
ប្រទក្សិណក្រុងសាទ ប្រសើរស្អេតចឹដុំថាន បរិបូណ៌ហើយក្សត្រក្សត្ត
ហោះទៅត្រង់ទាមណ្ឌល ។ នៃព្រះថៅចក្កាល់ ជាចិតានាងនិមិល ទើបព្រះ

ថាទេវសតាល ចន្ទលតីអាកាសថា ។ ម្នាលស្តេចគំនៀលន់ ជាពុជនដូ
មោហោ ខ្ញុំឥតពិចារណា ពុំចេះដឹងឲ្យអស់ក្តី ។ ឥឡូវចូរស្តេចស្តាប់
អញនឹងថ្លែងដំណើរតើ អង្គអញឯងជាតិ មិនគឺកូនព្រាហ្មណ៍ហោក ។
អញឯងបុត្រព្រះអង្គ អាទិត្យវង្សពិតជា ត្រូវត្រូតក្រឹតភាព អស់ក្សត្រ
ទាំងពួងឯក ។ អញឯងចរយោត្រា បង់សំមាមកឆ្ងាយពេក តែអង្គអញ
សង្វេគ សំណាក់នៅព្រាហ្មណ៍ហោក ។ ព្រះចៅបញ្ជាល់ស្តាប់ ព្រះ
អង្គថ្លែងដូច្នោះណា តតញ្ជ័រអស់អង្គា ខំមើលទៅឯអាកាស ។
ឃើញជាក់ជាព្រះអង្គ ស្តេចស្នែងតង់លើហង្សមាស រស្មីភ្លឺឆ្ងាស់
ត្រចះចែងដោយវិហាស ។ ស្តេចឃើញហើយវែងគិត តំយ៉ងឯងឥតពិ-
ចារណា ខំទូលអង្វរថា អម្ចាស់អាពុកអ្នកមើយ ។ សូមពាន្ធអ្នក
សន្តោស កុំយកទោសអាពុកឡើយ ស្មើអាពុកស្លាប់ហើយ សូមអាណិត
អាពុកវិញ ។ ទោសអាពុកខ្នេះជ្រាប ធ្វើនគ្រាស់ស្រែប្រមាណមិញ
សូមអ្នកច្រោសចោលចេញ អត់ទោសទៅយកតែបុណ្យ ។ អា-
ពុកមានបុត្រី ឆោមពិស់តិរសសលន់ ថ្លាឃស្នងជាប្រពន្ធ ជាមហេសី
អ្នកហើយណា ។ រីព្រាហ្មណ៍ច្រោជបុ ពាមិត កុំអ្នកតិតទុក្ខឲ្យអា- ពុក
ខ្នេះនឹងរក្សា កុំឲ្យព្រួយព្រះទ័យឡើយ ។ បើអ្នកមានមេត្តា ច្រើន
ករុណាអត់ទោសហើយ ព្រះគុណអ្នកជាត្រើយ អាពុកពុំភ្លេចឡើយ
ណា ។ ក្សត្រាខ្នេះឯព្រះចុង បរមនាថធិពជា ឃើញព្រះចៅបញ្ជាល់

ចាស្បាទ្វបទ្វាចត្រាះជ្ញាមើ ។ តុំអាចហានប្រឡង ប្រកួតដងព្រះជ្ញាមើ
សម្តេចព្រះនាងស្រី ស្តេចតុំយកគោសឡើយណា ។ ឯនាងនាថខេមើ
អគ្គមហេសីសួតិសោភា នាងផ្តាំព្រះមាតា ថាបពិត្រអ្នកមេអើយ ។
ខ្ញុំសូមភានក្រាបលា ព្រះមាតាឥរួរហើយ អ្នកអម្ចាស់កូនអើយ កូន
នឹងនៅតុំបាទណា ។ កន្លែងនោះព្រះដនន៏ ឮមុត្រីនាងខូលសា នាង
បេញ្ញាស្រីម៏ម្នា ទតទៅឃលុំកដបុត្រី ។ នាងទ្រង់ព្រះកន្សែង សោក
ស្រាប់ស្រែងសួតស្មាតើ ពិលាបលោមយាត់ឱ្យ ថាកូនស្ងួនមាតា ។
មាសអើយកុំនាងនៅ ចូរទាងទៅនឹងម្តាយកំ ម្តាយមានមាសមេ
ជា ថ្មើមដង្កើមម្តាយសព្វថ្ងៃ ។ អ្នកនៅនេះតាំងពីរ ម្តាយបង្កើរអេស
តាំងថ្ងៃ ត្រាមក្រមឱ្យទាសថ្ងៃ តាំងពីរសោយកដសម្បត្តិ ។ ឧកូន
តាំងពីរអើយ កុំទៅឡើយម្តាយសូមយាត់ អញ្ជើញចុះមកជាត់ នៅនឹង
ម្តាយក៏មាសថ្ងៃ ។ ឱ្យម្តាយសោតចាស់ហើយ មាសម្តាយអើយបើ
ម្តាយក្សីយ ម្តាយផ្តើរឱ្យចនេះនៃ ឱ្យកូនប្អូនលើកភ្នែចម្តាយ ។
មាសអើយកុំនាងនៅ ចូរទាងទៅណានាងនាយ អាស្រូវត្រឹមតែម្តាយ
កុំយ៉ែកគោសព្រះបិតា ។ ថាបើនាងកូនៅ មាសមិនទៅនឹងយាត្រា
ទៅដងប្តីនាងណា សមម្តាយក្សីយឯងកូនអើយ ។ ដ្បិតម្តាយតំត្រាសល់
ឥតឯយល់អ្នកណាឡើយ ត្រលឹងមាសម្តាយអើយ សូមនាងនៅនឹងម្តាយកំ ។ កន្លែងនោះកដបុត្រី ស្តាប់ដនន៏នាងសោក ឋន្ធល

ដូច្នោះណា នាងសែនសោយសោកាណាស់ ។ អាណិតព្រះមាតា
នាងសោកាតន់ពតសស់ ព្រះនេត្រាជោរដល សស្រាក់ស្រោចព្រះ
កន្ត្រា ។ នាងសោកពុំអាចថ្លែង ចរចាចែងចេញឡើយណា តាន
តឹងអួលឧក ចង្អៀតអស់ព្រះហឫទ័យ ។ ក្សត្រាណោះគ្រះកូថាល
យល់ដាយោសាកនាតកក្រៃ ស្តេចតើចយន្តម៉ាសមៃ ហោះអណ្តែត
ដោយវេហាស៍ ។ ព្រះមន្ត្រីស្តេចតន៏ឃន្តី ហោះដោយបុណ្យព្រះ
ចេស្តា ខ្ពស់ផុតព្រះនេត្រា នៃអ្នកផងពុំយល់ឡើយ ។ ឯព្រះវរបិតា
សែនសោកាឥតឯស្បើយ ដ្បិតកូនស្ងួនត្រាណាត្រើយ ប្រែប្រាសព្រាត់ចម្ងៃឯចង ។ សម្តេចវរមាតា សោយសោកាសន្ធប់សុង នាងឈឺ
ដ្បិតបុត្រចង ប្រែប្រាសពីព្រះឧក ។ រីឯព្រះភូមី យល់ទេវីសន្ធប់ណា
ស្តេចយកព្រះង្គា ក្សិតព្រះកន្ត្រានាងទាថហើយ ។ ក្សត្រាណោះវរក្សត្រី
ភ្ញាក់ស្មារតីពុំលងឡើយ នាងសោយសោកឥតស្បើយ ពីលាបលន់
ពន់ពតណា ។ នាងទាថយកព្រះករ ពាំពីរតេតក់ឧក ព្រះទេស្តាថ្លែងប្តីញ្ញា
ឧក្ខូនស្ងួនមាសម្តាយអើយ ។ ពីដូចមាសទុក្ខ កើតមកធំ ។ ម្ល៉ះហើយ
កុំដែលដាច់ម្តាយឡើយ ដល់ពត្រីថ្ងៃមួយណា ។ នេះម្តងម្តេចកូនសៅ
ប្រែប្រាសសៅពីមាតា ពាំងនេះហេតុវេក ឯងមកផ្តល់កូនទីងម្តាយ ។
ឧក្ខូនស្ងួនប្រាសសៅ ទីលំនៅទាំងឆ្ងាយ ឧក្ខូនមាសមិត្តម្តាយ ម្តាយ

ថប់ច្រេនប្រកាន្តាត់ ។ ឧម្ពាយប្រណាំទាន ឆ្ងាប់ទៅប្រាន្ត្រប្រាសាទតេន
តឡ្ងះនេះនាងគ្រាត់ ទៅឯកាណាកូនអើយ ។ ម្ពាយថប់មួយគេកក្រៃ
តតាតញ្ជៃផ្ទៃបបែបូណាហើយ ក្រែងភ្លាត់ដល់ស្រុកឡើយ ជួនប្រសូតដោយ
មាតា ។ ថប់មួយក្រែងដល់ហាន ពាដតិមានព្រះអង្គជា មេកុកបាក្រុក
ណា ក្រែងលោកភ្លាសួរមេ ។ មិនអស់ចិត្តដូច្នេះ ឧកូនឆួន ។ មាស.
ស្នេហ៍ ម្ពាយតិតតិតទៅថៃ ថៃហើយថប់ថប់តេកតន់ ។ សម្តេចព្រះជនន៍
សោកបុត្រតិលាបលន់ ខល់ទុក្ខជាខ្លាំង តាន់ទុកវៀងទៅហោង ។

នេះនិងចាចែង និងនិងថ្ងៃងដោយតន្ទង ដំណាលទូរទំនង
ដំណើរព្រះពោធិសត្វ ។ ស្តេចហោះនឹងប្អូនភ្លា ដោយវេមាស៍ប្រសើរ
ភ្លាត ពីភេង្ស៍ព្រះអង្គក្សត្រ បន្ទោបង់លែងសោក ។ ស្តេចស្តែងដើរ
ដោយបុណ្យ កណ្តាលមណ្ឌលវេហាស៍ ឥតក្សត្រដទៃណា ទៅធ្វើមនិង
ព្រះអង្គបាន ។ ក្សត្រាទូរក្សត្រី ប្រសើរវិសេសប្តីនិងប្អូន ស្តេចហោះ
ពាពហាន តំរង់ជួនទិនទិក ។ នាងឈើព្រះទេវ គ្រប់ចាប្តូលាំទៅហើយ
ណា នឹងប្រសូតពាជបុត្រា នាងក្រាបទូលព្រះភូមិ ។ ស្តេចស្តាប់ព្រះប្អូន
តន់ ស្តេចកើតយន្តមាសមណី ធ្វើនាបន់តាបឱ្យ ចុះដល់ដំដើមត្រឹក្ស ។
ស្តេចចូលចតអាស្រ័យ ក្រោមព្រះជ្រៃព្រៃគ្រឹស្ម ខាងឆ្នេរព្រះគង្គា តីស្រះ
ចោក្ខណៈជ្រាប ។ ទៃត្រៃទេមចាមតាន្ត ស្តេចសម្រាន្តអាស្រ័យនៅ
រឹងព្រះប្អូនភៅ សែនសោកាស្មោតស្មុត ។ នាងន្ទាថនារីថ្ងៃ នាងឈើផ្ទៃ
ញ៉ាំរន្ធត់ អស់ឥន្ទ្រិយស្រយុត ពុំស្រួយាលជំលាំតិចឡើយ ។ (ឃនត)

រឿងមរណាមាតា

(តមក)

ឈ្មោក ប៉ ឈុំឈ្ណ ចងនិងកំសាន្តស្នាំរឹត

កំពែងដែនត្រដាប ថ្មសស្វាចខ្ពស់ត្រឈៃ ត្រឈឹងឆឹងស្ពឹងស្ពឹមស្ពៃ
តាំងច្រាំពីជាន់ដុំដិត ។ ខ្ពោងឮរទិសតាំងបួន សមធំធួនធំពាកពិត
ស្រោងស្រស់ខ្ពស់តិចត្រ ដើយរបូតឈ្នះកេសា ។ តាកតែងជាមណ្ឌប
កំពូលត្រប់ច្រាំសោភា ល្អល្អះឥតគណនា មានក្បូរក្បាច់ជាសដាំដិត ។
ដាំត្បូងដាំកញ្ចក់ ក្បាច់ក្នងក្នក់មានមាសបិទ ភ្លឺផ្លេក។ តិចត្រ មាន
ខណ្ឌខានត្រាលច្រុះ ។ គួរគេតះជ្រៅស្រឡង លឹងចំរូងដែកដាំដុះ ដាំដិត
ប្រភិតច្រុះ ជាសម្រាប់ការសង្គ្រាម ។ គួទ័ក។ ជ្រាលជ្រៅ មៀង-
មើលទៅលិចអន្ធាម អន្ធង់មានម្ពាត្រាម ត្រីក្រតើច្រែនយោរយៅ ។
ទឹកកក់ឈូកលឹងដុះ ច្រើនច្រងឹច្រុះឡាំច្រាលឡៅ មច្ឆាហែមហែលទៅ
ទឹអាស្រ័យតឹងពាក់ភួន ។ សេនាតួតាហាន ភង់ភេច្រាំណាំក្រអួន
ក្រអឹតស្លេតមាំមួន ចិត្តក្លៀវក្លាមំនួចសឹក ។ ចេះគុនតន់អាគម
ប្រែជាតំធំចិត្តឥតភ័ក តយល្បាតតាំងយប់ព្រឹក យាមប្រយ័ត្នសព្វទិវា ។
អស់ពស្ត្រសោភិន្ទ ដោយឫទ្ធិមុណ្យក្សត្រា ឥតខ្វះឥតខានសោះ ឥត
សត្រូវរៀតរៀនច្រណា ។

ខេះខំដឹងថ្លែងឥត ដំណាលដំណ ដំណើរនៃភាន បទដើមចំពោះ
គាលនោះមែនមាន បុរសម្នាក់ប្រាណ ឱត្សនៅតំបែរ ។ នាមនៃ
ឈ្មោះ កុល្លីយបុរស ប្រតិទ្ធនាមា នាដ៏តែវកេសី ជាស្រីសោភា
សុភាតភាយា គាយោលល្អះ ។ ល្អះល្អិតប្រមប្រិយ ខ្មៅដិបុណ្យស័ក្តិប្តី
ចំរើអម្ចាស់ ស្តេចទ្រង់ប្រណី កុល្លីយនោះណាស់ ព្រះអង្គទ្រង់ត្រាស
បើកបង្គំលថា ។ កុល្លីយបុរស អញឲ្យស័ក្តិយស ស្តីការពេជការ
ទ្វៃធ្វើមេស្រុក ដោះទុក្ខនានា របស់ប្រជា- ទុពស្ត្រស្រុកគ្រា ។ កុល្លីយ
បុរស ខ្ញុំលស័ក្តិយស រីឯមកលំនៅ ស្តីការពេជការ ប្រជាពស្ត្រគ្រា
ចំណោតចំពៅ រីឯតំបែរ ។ នាដ៏មានតតិត្រប់ ដប់ខែសម្ភព បុត្រី
សោភា មេស្រុកឲ្យនាម នោះតាមតន្ត្រា យកនាមមាតា បិតាមកផ្សំ ។
ឈ្មោះកុលកេសី កុមារប្រឹមប្រិយ រូបកដ៏ឧត្តម ល្អល្អះទ្រង់ទ្រាយ
ឆោមឆាយស័ក្តិសម ចង្កើះរៀកុំ ដូចខេតដ៏តា ។ ជនកជនី
ស្រីប្លាត្បាំប្តី បណ្តាលស្នេហា ដូរតបុត្រតែមួយ ត្រួយសង្ឃឹមក
កើតមកកាលណា ចំរើនយសស័ក្តិ ។ គាសាគាសី គោរសេះដំរី
របស់មាសប្រាក់ មេស្រុកកើតមាន ធនជាន់អន្ធឹត្ស គន្ធេកឥតអាក់
សាន្តសុខសព្វថ្ងៃ ។ ដូចប្តូចូលតំបៅ ប្រាំមួយដណ្តប់ រូបកដ៏
ល្អក្រៃ មានលក្ខណា សោភាប្រៃតែ ញាតិព្រៀងជវៃ ស្មែគ

សឹងស្រឡាញ់ ។ មកមើលកុមារ សឹងភាន់ព្រលឹង មកដូនតាស្ទុះតាម
តោះតេញចាំនឹង លួលរំលិចរំលិច ទៅទឹកស្រឡាញ់ មកក្រោយ
មហាមា ។ ឈប់ស្ទុះខាន់ខាន ខឿនខើបខាន់ខាន ខឿតតណាខា
មែនម្ចាស់បុរស មួយនោះជាតំណា អ្នកស្រែទៅនា ខឿបខំមេស្រុក ។
បុរសនោះមាន ភរិយារួមក្រុណា ក្រក្រពុំសុខ ពុំក្សាន្តសប្បាយ ក្នុង
កាយវិតក្ក ជ្រួតគ្នាខសម្បុក សម្បត្តិល្អជា ។ សន្ធឹងភូមួយ ខ្សែង
ដេករញ្ជួយ ស្ទើរចាក់សោះសា រក្សាស្រូវស្រែ គ្រាន់តែគោក្តា តិច
ខើបភរិយា មានតតិខែត្រចំ ។ ប្តីរសជាប្តី រវល់ឃ្លាតខ្លី មិនមានឈរ
ឈប់ រកទុសអាស្រ័យ ពីថ្ងៃរុះឃប់ មិនមានឈរឈប់ ទៅលក់
យកថ្ងៃ ។ ទិញត្រីគោជន ចំការមប្រពន្ធ ពុំខានមួយថ្ងៃ រីស្រូវក្នុងស្រែ
ពុំបែរបាំង ប្រពន្ធសត្វថ្ងៃ ទៅមើលទៅថ្ងៃ ។ មានកាលមួយថ្ងៃ
ប្រពន្ធវិលវៃ ទៅមើលស្រូវស្រែ ដេញចាបរំលៃ សត្វថ្ងៃសត្វខែ
តាមកាលនោះឯ- ងានឈឺតោះគេក ។ សម្លឹងបុត្រប្រុស ដួសភាន់
ស្ងាខស្ងោះ តែម្នាក់ឯងឯក ហេតុតែកំសត់ ខុតតអនេក កាណាតងានគេក
ងានពុំសប្បាយ ។ ដួចអស់ពីតោះ ខើបដឹងដល់អស់ ត្រឿនលាខចាំង
ខ្លាយ ដៃលេចាំចាបស្រូវ ស្រែទៅជិតខ្លាយ ដួចតែប្រញាយ មកមើល
ធ្លុនថ្ងៃ ។ ជុំញាតិកា ម្ចាស់ចិតា ឱ្យឈ្មោះគ្រោះតែ ហេតុកូនតោះកាល
សម្រាលកូនស្រែ ឱ្យ ឈ្មោះហៅតែ ភ្លើជម្លឹកកុមារ ។ លុះជន្មជន់ចប់

ចូលដួចតំបៅ សោឡសវស្សា មុខមាត់ប្រឹមប្រើយ ស្រស់ស្រីក្រៃ
ល្អលើសកុមារ ក្នុងស្រុកគាំងឡាយ ។ ចេះជួយធ្វើការ មាតាបិតា
គ្រាន់ធួរសប្បាយ មើលចាបមើលថែ ទឹកស្រែសម្បាយ ជួយកំលាំង
ម្តាយ ឥតុកគ្រាន់ល្អែ ។ មានមួយទៀត កេសីធីតា ចិត្តចង់លេង
ស្រែ តែលៀវមេនំ ចោមជុំដង្រែ ភៅគាល់ខៀវស្រែ កុដុម្ពីកកុមារ ។
កុដុម្ពីកមើលយល់ ធីតានិមិល ក្តួចកើតស្នេហា ចាប់ចិត្តស្រឡាញ់ ពោរ
ពេញចិត្តា ពុះលាន់មាត់ថា នុកូនមេស្រុក ។ អញមិនដែលយល់
រូបល្អនិមិល ឲ្យអញកើតទុក្ខ ធ្វើម្តេចនឹងបាន រួមហានរួមសុខ កុដុម្ពីក
ជាទុក្ខ ខ្វល់ខ្វាយចិត្តា ។ នាងកុលកេសី បានឃើញកុដុម្ពីក ក្តួចកើត
ស្នេហា ក្នុងចិត្តផ្អើលផ្អូរ ភៅមកកាន់គ្នា ហើយរៀបត្រីហា ជាស
សប្បាយ ។ រីឯកុដុម្ពីក កើតទុក្ខអំពី បានយល់រូបកាយ នាងកុលកេ-
សី ប្រឹមប្រើយនោមធាយ អត់ទឹកអត់បាយ ពុំបានគោក្តា ។ ឆ្កួត
ចិត្តវង្វែង រៃវៃលំដេរលេង លេលាលា លលុះឥតក្រែង ជាល្បែង
អួសារ មិនមានកាន់ការ កាន់តែកួចតែស្រើ ។ មាតាបិតា គន់គិតថែ
ថា នុកូនពិសី មិនដែលដូច្នេះ កូនឯងឈឺអ្វី តិត្តហើយស្រដី
ជណ្តើនភៅថា ។ រៃហកូនមាសម្តាយ ថ្ងូមិនហូបបាយ ឈឺអ្វីប្រាប់ព្រំ
កុដុម្ពីកប្រាប់ត្រង់ ប្រាប់សព្វទាំងការ ពីឃើញក្តួច នាងកុលកេសី ។
ម្តាយប្រាប់ហើយថា នុកូនពុំដឹង ខ្លួនយើងស្រស់ កូនណាក៏មេស្នេហ

ជាមុខមន្ត្រី ចេចនិរ្ទេសដ រកកស្ត្រីដូចគ្នា ។ ឯកុដុម្ពីកនោះ ឮម្ចាស់ស្រុកថ្នោះ តាំងចិត្តញាចរចា សញ្ជឹងសញ្ជប់ សួនសួចកត្តា ទៅចរកោតក្តាជាន់ពាក់ម៉ាត់ ។ ហើយដើរទៅស្រែ តន់តត់ទៅតែ កេសីមិនជាត់ ថ្ងៃនោះកែសី ប្រមប្រឃេរូបក្នុង ទៅឆ្ងាតចិត្តជាត់ តែពាក្យគ្នា ។ ឧដ៏កាលៀងម្ចាក់កុដុម្ពីកដើរស្រាក ទៅតាល់ដួចគ្នា ដួចកុលកេសី ទៅចិតគ្នា កុដុម្ពីកម៉ាមាចូលចាប់ដៃខ្លាច់ ។ ហើយសួរទៅថា ដោយពាក្យស្នេហ៍ សួរលោមរៀបរាប់ ខានសោតខេះខិន រត់រឹងពុំស្តាប់ កាលៀងប្រញាប់ ចូលជួយមេរដ្ឋ ។ កុដុម្ពីកប្រឹងក្តាប់ កដៃខានជាប់ កាលៀងសោតវៃ ជួយខ្លាក្រេចវៃស្រែកទៅខ្ញាំងវៃក្រ ហៅម្នាជាវៃ ឲ្យជួយធីតា ។ ឯកុលកេសី តាំងភិតភតថ្ម ឥតបើឧបមា ខានក្តិចខានខ្ញាំ ខានខាំខានខ្លារ កុដុម្ពីកមិនណា មិនលែងខានរសោះ ។ រំហែកអាវៃស្ប លុះបានដល់ដៃកុដុម្ពីកតាលនោះ កាលៀងម៉ាលយល់ កិច្ចកលចំពោះ កាលៀងចេញចុះ ចេញចោលធីតា ។ កុដុម្ពីកសោតបាន រួមសុខរួមទុក្ខាណ ទឹងកេសីណា ស្រេចហើយកាលៀង ខាំខានធីតា - រីលទៅត្រូហាជួចដើមប្រក្រតី ។ កាលៀងធីតា តុហានចរពា ពាក្យតេចន៍អ្វី ។ កុដុម្ពីកតងទៅ ស្ងួនទៅកេសី ពាល់ពាក្យ ពុំខានខំដ ។ យូរទៅកុដុម្ពីកប្រាប់កុលកេសី ថាប្អូនស្នេហ៍ យើងនៅពុំបាន ត្រូវធ្វើមានតេសាចេះយើងនាំគ្នា រតទៅជនបទ ។ កេសីឆ្លើយថា អ្នកតត់តនោះជា

តេញត្រូវប្រាកដ ស្រេចហើយកុដ្ឋម្ដាក់ តិតចំកំណាត់ វែលាទឹងត
ប្រាប់កុលកេសី ។ ឲ្យរៀបស្បៀងផ្លូវ ទៅតាកសតូវ តស្ដីតោជ្ឈ
ចំណី នាងលបលាក់ធ្វើ សរតើអ្វា ស្រេចហើយកេសី ប្រកាវខ
ពុកល្អ ។ ស្រេចយកសំពត់ ចាស់ស្បែកតំនួតំ តៀស ធ្វើជក្រ
ហើយយកសំពត់ ថ្មីបត់វែងល្អ យល់ស្ងាត់នាងបា នាងចាកគ្រឹហា ។
ទំដើរទាំងយប់ មនុយប់មិងក លុះគ្នីសុរិយា ទើបកៀត្រពួន ។
នាំគ្នាកោក្ដា ហើយរៀបនិត្រា លងលក់មាំមួន ដោយខឿយហត់តេក
ដេកតុំដងខ្លួន ពោះជាស់អង្ឃន ស្ទើរតុំភ្ញាក់ប្រាណ ។ លុះរាន់សុរិយា
ទើបភ្ញាក់និត្រា បរិភោគនៃ្ហតបាន ចាំលុះព្រលប់ តុំឈប់សម្រាន្ត
ដងដឹតរំបងបាន នាំគ្នា ដើរទៅ ។ សត្វថ្ងៃប្រក្រតី ពលរាកត្រី មិន
ឈប់ឈរទៅ ពោះបីខឿយហត់ ទំអត់ទុកទៅ ដើរកាត់សំរោ
ជនបទគ្រាមា ។

នេះនិទានទៅ ឯមេស្រុកទៅ លុះបានទិត្រា តិលៀងរំមិទ
ជួបជុំគ្រប់គ្នា យល់ឃាត់ធីតា តុំមានដំណឹង ។ ឡើងទៅដំកប មេស្រុក
ដកប សេចក្ដីដែលដឹង មេស្រុកឲ្យកេ ពោ ឡាទ្រហឹង ទ្រហោ
យំអឺង យំអាបពលគ្នា ។ អាតុកកុដ្ឋម្ដាក់ ទៅឆ្ងាយភ្ញាក់តឹ ដេកឃាតុំប្ដូត្រ
ក្ងា ដឹងហេតុនោះជាក់ តិតលាក់កំងឹក ឡើបឡៃប្រាប់គ្នា មិន
ឲ្យស្រដី ។ កូនយើងជាប្រុស យើងឡតវេស កូនលោកជាស្រី

វាតាំងចេន. ឲ្យយើងកើតក្តី យើងរកវាថ្វី ឲ្យខឿយអាត្មា ។ ចំរម្រស្រុក
ជាប្តីខ្ញុំ ខ្ញុំនៃកវៃកេសី តែតតិចារណា ហៅអស់មេទំ មកជុំពាល់គ្នា
រហ៊ឺយសួរទៅថា ហង្សស្តីឲ្យត្រង់ ។ ជ្រុតហង្សក្បាត ក្តួនអញ្ជាលគ្នា
មិនឲ្យលះបង់ បើមោះមិនគាប់ ហង្សច្រាបឲ្យត្រង់ អញ្ជាសោតអញ
ចង់ ដឹងហេតុឲ្យជាក់ ។ តាលៀងជំពប ថាសូមលោកជ្រាប យើង
ខ្ញុំនឹងលាក់ កាលលោកចៅហ្វាយ ឲ្យទៅរកអ្នក យើងខ្ញុំសឹងស្វាក់
សឹងស្វាបសព្វថ្ងៃ ។ ទៅរកដល់ស្រែ ប៉ាន់សួរផ្លូវមេ ជាម្ចាស់ក្តុដម្ពក
មិនម្ចាំនឮមាត់ សូន្យស្ងាត់ឥតឮ ត្រង់នោះតុំចេរ តែលោកមេគ្គា ។
មេស្រុកឮនស្តាប់ តាលៀងថ្លែងច្រាប់ តិតកងចិត្តខ្លា ទើបស្តីថាអើ
ថាបើខ្លួនវា ជាកូនតុំងា មិនចង់ដំមុខ ។ វាកាច់ស្លឹកខ្ចាស ឲ្យអាស្រូវ
ភ្លាស ខ្ចប់ណ្ហោះអាតុក អញ្ជាសោតកាត់សាច់ ឲ្យជាប់តុំពុក តិរនេះ
ទៅមុខ លែងនឹកលែងរក៏ ។ ឯម្ចាស់ក្តុដម្ពក អាតុកនោះក្តី ហេតុតែ
អ្នកច្រៀងឮថាមេស្រុក មិនរកមិនរក៏ មានចិត្តត្រេកអរ ឥតបីឧបមា ។

បន្ទព្រហ្មកិតិ

ន័យនេះស្មេះឈប់ខាន ន័ងនិងតតិចារថា ឯក្តុដម្ពក៏យាត្រា ន័ង
នាងតុលាកេសីនោះ ។ ដើរដោយដងមាគ៌ា ចូលព្រៃក្បាព្រៃរោះ ដើរ
យប់មិនឈប់សោះ មិនស្រម្ភខ្លាខន្ធិត្រា ។

(មានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

រៀនគ្រែនដ៏យស្ងួស្តី

លោក ប៊ូ.ប៊ូ រៀបរៀង

ឥលូវនេះ សូមបំភ្លឺយោងអំពីពាក្យថា «ជ័យហោង! សួស្តីហោង! មែនហោង! តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅតុលាសន-បណ្ឌិត្យ ភ្នំពេញ មានសេចក្តីដូចតទៅនេះ:

ជនាតុជនខ្មែរ កាលបើមានធ្វើពិធីមង្គលការ រៀបដែលកូនប្រុសស្រីកំពុងក្រោមទន្ទឹមគ្នា នាកណ្តាលទីប្រជុំពួកញាតិមិត្តមានមាតាចំតាងដើម ដើម្បីសំភះទួលស្វាគមន៍មេបានោះ លោកអាចារ្យតែងស្រែកសួរពួកញាតិមិត្តនៅទីនោះថា «ជ័យហោង?»

ពួកញាតិមិត្តធ្វើយព្រមគ្នាថា «ជ័យ!»

លោកអាចារ្យសួរទៀតថា «សួស្តីហោង?»

ពួកញាតិមិត្ត ថា «សួស្តី!»

លោកអាចារ្យ ថា «មែនហោង?»

ពួកញាតិមិត្ត ថា «មែន!»

លោកអាចារ្យ ថា «យកអ្វីជាបន្ទាល់?»

ពួកញាតិមិត្ត ថា «យកហាលជាបន្ទាល់!

រួចក៏តាំងនាំគ្នាស្រែកហៅកងរំពងគេញផ្លុះ ៣ ដង ឯលោកអាចារ្យក៏លើកឃ្មោះឡើងវាយយ៉ាងខ្លាំងឮសូរមួន ។ ខុកជាសញ្ញាថា កូនប្រុសស្រីគួស្នាមតិរយាថ្មី មានសំរីសួស្តីជ័យមង្គលហើយ ។

រៀបរៀបនេះ អ្នកផងនៅប្រទេសខ្មែរយើង គេតែងធ្វើត្រង់គ្នាពាលតែរឿងមង្គលការកូនប្រុសស្រី ។

សំនួរ - គួរឲ្យឆ្ងល់ណាស់ ចុះហេតុអ្វី ចាមជាជាតិខ្មែរប្រកាន់យកពាក្យ "ជ័យហោង ! សួស្តីហោង ! មែនហោង ! ច័បខនេះ មកធ្វើជាត្រម្មុះកងឯជ័មង្គលការ ? ។

ចម្លើយ - ព្រោះមានអត្ថន័យជារឿងត្រង់ ដែលចាស់ទុំដំណាលតៗ គ្នាមកថា :

កាលតាំត្រង់នាយ មានស្តេចក្រមុំម្នាក់ កំព្រាម្តាយ មានតែម្តាយមិនដឹងជាទៅស្រុកទេសណាៈ ។ ដួនជាគ្រានោះ ស្រុកទេសកើតអំណាត់មុតយ្ងានដោយភាំងភ្លៀងយូរពេក ។ ទាងក្រមុំកំព្រាតែងចូលទៅព្រៃរកដីកដំឡូងនឹងម៉ែមេឈឺឯទៀតជាមួយអ្នកស្រុក យកមកស្ងោរបរិភោគជួសបាយតែសព្វថ្ងៃរៀងមក ។

រំលោភត្រមួយ ទាងក្រមុំដកលក់ទៅយល់សប្តិឃើញថា ព្រះឥន្ទ្រយកតង ១ មានសម្បុរស្អាណាស់មកហុចឲ្យទាង ហើយប្រាប់ថា "ចេស់នេះ ជាតង៨ដំរែស ចូរទាងថែរក្សាទុកឲ្យល្អ ទ្បែតង៌ទៅយូរ

លង់ទៅ នាងនឹងបានជាធំភ្លុំលែងខ្លាយ " ។ ព្រះឥន្ទ្រាប់ប្រាប់កំតៀស
ខ្លួនចាត់មួយរំពេចទៅ ។

លុះព្រឹកឡើង នាងក្រមុំដណ្តើមបាយឆ្អិនដួសខ្ចប់ជាសំណុំនឹងទឹក
មួយចំតង់ រួចលើចបដក ចូលទៅព្រៃជាមួយអ្នកស្រុកដូចថ្ងៃមុន ។ ។
លុះនាងចូលទៅក្នុងព្រៃស្រោងស្ងាត់ ស្រាប់តែមេយម៉ាស្រែខំឆឹងតឈ្លប់
ផ្តួលនង្គ្រម ។ ហាក់ដូចជាភ្នាក់ភ្លឿងក្លាម ។ ។ ឯកូតាស់ ។ យើញ
មេយឆឹងដូច្នោះ កំនិយាយសើងថា " ហ៊ាំអីរាត យើងចាក់ទឹកចំតង់
ចោលទៅ ចាំត្រឆយកទឹកភ្លឿងឆឹកវិញ » ។ នាងក្រមុំ ហេតុតែខ្លួន
នៅក្មេងខ្ចីសេចក្តី ឮសំដីចាស់ៗ ដូច្នោះ កំចាក់ទឹកចំតង់ចេស់ខ្លួនចោល
អស់លើងទៅ ។ តមក មិនយូរប៉ុន្មាន ស្រាប់តែមេយប្រែខ្លួនជាក្តី
ស្វាងស្រឡះឆេងទៅវិញ ឥតស្រាក់ភ្លឿងមួយដំណាក់សោះ ។ បន្ទាប់ពី
នោះមក នាងក្រមុំស្រែកទឹកយ៉ាងខ្លាំង ត្រាំតុំបាន កំដើរមូរស្វែង
រកទឹកផឹក ទៅជាប់ឆ្ងាយភ្នំគ ដល់កន្លែងមួយ នាងឃើញទឹកដក់នា
កងជានដើងដំរី ដែលកំពុងដើរឆុតទៅថ្មី ។ នាងស្មានថាជាទឹកភ្លឿង
ដោយស្រែកខ្លាំងគោកកំនុងក្រមឆឹកតាល់តែឆ្អែត ទើបបានដឹងជាក្រោយ
ថាទឹកនោមដំរី ។ នាងវិលមកផ្ទះវិញ កំមានទម្ងន់ដោយសារតែឆឹកទឹក
នោមដំរីនោះ លុះត្រាប់ខែហ៊ាយសម្រាលមកជាកូនប្រុស នាងឲ្យឈ្មោះ
"ជ័យ" ។

ចំណែរក្រោយមកទៀត នាងក្រមុំនោះមានប្តី ឋានកូនប្រុសម្នាក់ទៀតឈ្មោះ «សួស្តី» ។ មិនយូរប៉ុន្មាន ប្តីនាងអនិច្ចកម្មៈ នាងនៅចិញ្ចឹមរក្សាកូនប្រុសតាំងពីរតែម្នាក់ឯង ។

ថ្ងៃនីព្រះមហាសត្វក្នុងនគរនោះ ស្តេចទ្រង់ព្រះនាមវិឡ្ហកៈគ្មានព្រះរាជបុត្រា-បុត្រីមួយព្រះអង្គ ទើងឡើងគ្រប់គ្រងនគរ តព្រះរាជវង្សសោះ ។ ទើបពួកអាមាត្យមុខមន្ត្រីធ្វើពិធីបួងសួងផ្សងដំរីមង្គល ដើម្បីស្វែងរកអ្នកមានបុណ្យវាសនា យកមកអភិសេកសោយរាជ្យក្នុងនគរនោះ ។

ឯដំរីមង្គលនោះ មានរេហ៍តលជាច្រើនដើរដង្ហែព័ក្រាយ ដើរៈៗដល់ផ្ទះចៅដំយនិងចៅសួស្តី ក៏លុតជើងមុខក្រោមក្រាបនៅមុខផ្ទះនោះ ។ អាមាត្យមុខមន្ត្រីអកតាមហែដំរី ឃើញអាការដូច្នោះហើយ ក៏សំគាល់ថា ចៅដំយនិងចៅសួស្តីជាអ្នកមានបុណ្យច្បាស់ជាច្រើន អាចសោយរាជ្យបាន ទើបយកគ្រឿងរាជ្យចូលទៅចំពាក់ចៅដំយ ហើយអញ្ជើញឡើងជិះដំរីមង្គលហែចូលក្នុងព្រះបរមរាជវាំង តាំងអភិសេកចៅដំយជាស្តេចសោយរាជ្យ, អភិសេកចៅសួស្តីជាព្រះឧបរាជ ក្នុងពេលជាមួយគ្នា ។ នៅវេលាអភិសេកនោះ សេវាអាមាត្យមុខមន្ត្រីទាំងពួងនាំគ្នាបន្ទូលថ្លែងថា "ជ័យហោង! សួស្តីហោង! មែនហោង! ជ័ជង់ស្រេចហើយ កំសោចទឹកភ្នែកទឹកសន្ធឹងអភិសេកសម្រេចកិច្ចសុភមង្គលក្នុងគ្រានោះឯង ។

ពាក្យ «ជ័យហោង, សួស្តីហោង» មានរឿងត្រង់ប្រាត្បមកដូច្នេះ។

ចំណែកពាក្យ "មែនហោង" តុំមានរឿងត្រង់ប្រាត្បចំពោះរូបអ្នកណាទេ ហើយតុំមានអត្ថាធិប្បាយឲ្យពិស្តារផង គ្រាន់តែជាពាក្យដែលលោកអាចារ្យសួរបញ្ជាក់យកសេចក្តីពិតប្រាកដ ជាលើកទី៣ បន្ទាប់ពីលើពាក្យ "ជ័យហោង" ទី១ « សួស្តីហោង" ទី២ ឲ្យយើញថា កូនប្រុសស្រីដែលត្រាបសំពះខ្នើមគ្នានោះ ជាអ្នកមានជ័យជំនះឈ្នះមារសេត្រូវមែន ជាអ្នកមានសិរីសួស្តីមែន។ ប្តុតុំមែនប៉ុណ្ណោះ ។

តួតញ្ជាតិមត្រង្វើយបញ្ជាក់ថា « មែនពិតណាស់ហោង ឥតក្លែងក្លាយទេ" ។

ហេតុតែមានទិភានរឿងត្រង់ដូចថ្ងៃនេះ ទើបជាមានពាក្យ«ជ័យហោង ! សួស្តីហោង ! មែនហោង ! ក្នុងពិធីមង្គលការដាប់ជាខ្មែរទាំងមូលតរមកដល់សព្វថ្ងៃនេះ ។

រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

(តទៅ)

លោក ភ័ក្ត្រ - ប៊ុត្ថា រៀបរៀង

គតិបណ្ឌិតកុង - ហ្វុងសឺ

-តួកណាដាបណ្ឌិតកុង ហ្វុងសឺ?

ប្រហែលជាឆ្នាំ២០០០ឆ្នាំមកហើយ មានបណ្ឌិតមួយរូបនាមកុង-ហ្វុងសឺ ជាមគ្គុទ្ទេសក៍យ៉ាងឆ្នើមនៃមនុស្សជាតិ ជាអ្នកទស្សនវិទូយ៉ាងឯក ទម្ងន់ឡើងទៅប្រទេសចិន ក្នុងគ.ស.៥៥២ គឺ ២០ ឆ្នាំ ក្រោយដែលព្រះអង្គជាជនលិខិត ក៏ និងនៃសន្តតិវង្ស ចៀវ សោយរាជសម្បត្តិ, ខ្លះថាលោកបដិសន្ធិក្នុងឆ្នាំ៥៥១ មុនគ្រិស្តសករាជ ដោយនឹងថា លោកមិនអាចបដិសន្ធិទៅឆ្នាំ៥៥២ ដែលមានសង្គ្រាមដល់ទៅបីលើក ។ លោកស៊ូលីយេដឺម៉ូរ៉ាឌ័ក ជាអ្នកប្រែភាសាចិនមកជាបារាំង បានកំណត់នាមលោកថា ក្រុងហ៊ូស្យ ប្រែថា បណ្ឌិតក្រុង, មានខ្លះថា លោកនាម ក្រុងស្យ ។

គេបានដំណាលថា ដីតារបស់លោកកុង ហ្វុងសឺ ពេលការបានតែងតាំងជាចៅហ្វាយក្រុងតូចមួយឈ្មោះ ហ្វុង នៅក្នុងរដ្ឋលូ ។ ចៅលោកចៅហ្វាយក្រុងនាម ជួ-លៀង-កាំ ដោយបានរៀបរៀបហ-

មន្ត្រីសាមួយទីឯស្រីម្នាក់ រស់នៅដល់អាយុ ៧០ ឆ្នាំ មានសុទ្ធតែកូនស្រី កំឡើរតែហាមន្ត្រីសទីស្រីម្នាក់ទៀតឈ្មោះនាង ត្នេង-ឆៃស្ង កំបានបុត្រមួយនាម កុង-ហ្វូឆឺ ។

ក្រោយដែលបានតាំងគ្រួសារមួយរយៈនោះ អស់រយៈពេល ២-៣ ខែ, នាង ត្នេង-ឆៃស្ង កំពុងឡើងទៅលើភ្នំនីកៀវ ដើម្បីធ្វើសុំព្រះជាម្ចាស់នូវបុត្រម្នាក់; ជួនដំណើរបែត្រឡប់មកវិញ, គេឃើញនាងយល់សប្តិឃើញព្រះអធិពលសម្រាំម្នាក់ព្រះកន្ត ទ្រង់មានព្រះពាក្យមកកាន់នាងថា នាងឯងនឹងមានកូនប្រុសមួយជាបណ្ឌិត រួចនាងឯងត្រូវប្រសូតបុត្រនោះ នៅក្នុងទ្វេដែលគេចាក្នុងដើមមន ។ ក្នុងមួយក្នុងកំឡុងដែលនាងមានតតិ នាងបានឱម៉ត្តឃើញ ខែតាំង ៩ រួបតែ អាកាស ភ្លើង ឃ្លាំ ទឹក ដី មានទាតិសាដ្ឋមួយហែហាមនាង មកលុតជង្គង់ចំពោះមុខនាង ហើយព្រួសខ្លួរតែមួយចេញពីមាត់ជាក់ដើនាង ។ ក្រេឡកមើលទៅ យើញប៉ណ្ណាធ្លើពីថ្នាយក(១) ហើយមានចារឹកអក្សរថា « បុត្រានៃគុណសម្បត្តិ នឹងសោយភក្ស ដំណើរពីសន្តតិវង្ស ត្នៀ ដែលនឹងភ្លាក់ចុះអាប់ទន្ទឹងក្នុងអនាគត, បុត្រានោះនឹងទៅជាព្រះមហាក្សត្រតតមកុជពក្ស ។ នាងត្នេង-ឆៃស្ង កំសួរ

(១) ថ្នាមានសាច់រឹងមិនខ្លៃ មានតណ្ហាទៀបែស ដាតិចនិងប្រើនយកថ្នាទេះមកបានទៀ ធ្វើជាគ្រឿងលំអផ្សេងៗ ។

យកកំណាត់សំពត់ចងសែ្នងនាគពិសិដ្ឋនោះ។ កំរត់ជាត់ទៅ ។ នាងកំ
ភ្លាត់ឡើង ។

នាងត្តេង-ភៃ្ស ហៅកុង-ហ្គុងសឺថា «កៀវ ប្ដ តួងន» ដោយទឹកដល់ភ្នែដែលនាងឡើងទៅបន់ ។ កុង-ហ្គុងសឺ តើតទៅកន្លែងមួយហៅថា "កុងទីវ" ប្រែថា តុហាកុំ ប្ដកុងសាង ប្រែថា ដើមមនមានប្រហោង នៅកងរដ្ឋកាលត្រះមហាក្សត្រទី ៦៣ នៃសន្ដតិវង្សភ្លៃ ។

កុង-ហ្គុងសឺ, នៅលើក្បាលមានសាច់ផតមួយកន្ទុង ប្រៀបដូចតុំតួចដែលរកឮពុកនៅទឹកតេលរដូវភ្លៀង, នៅចន្លោះកំមានសាច់ផតដូចលលាដ៍ក្បាលដែរ ។ កុង ហ្គុងសឺ មានសម្បារសែ្បកខ្មៅរលើយមានច្រមុជ ។

កុង-ហ្គុងសឺ កាលពីកុមារតេញចិត្តខាងការតាតខំសំដែងសេចក្ដីគួរសម ។ កុមារចេះបតេញអាកប្បកិរិយាធ្វើដំណើរទៅតាមវិធីបុណ្យមួយៗឲ្យបានសមរម្យ, ដូនកាលប៉ុនប្រុសបានការពួលភ្លៀងចេះរៀបចំទៅតាមហាន: តាមកិត្តិយស ក្មេង ជំទង់ ចាស់ ត្រឹមជាប្រុមន្ត្រីធំ-តូច ។

លុះកុង-ហ្គុងសឺអាយុបាន ១៩ឆ្នាំ, គេបានធ្វើសមរសនឹងស្រ្តីម្នាក់នៅកងរដ្ឋសុង ។ អាពាហមង្គលនេះ ទាំងបានបុត្រាម្នាក់ តមក

ចានបុត្រីម្នាក់ទៀត ។ បុត្រីរបស់លោកបានធ្វើអាពាហមង្គលនឹងសិស្ស
របស់លោកម្នាក់ឈ្មោះ កុង-ត្ចី-ត្ចាង ។ លោកមានប្រសាសន៍ថា
« ពិតមែនតែ កុង-ត្ចី-ត្ចាង ជាបព្វជ្ជាចារ្យ តែឈ្មោះនេះគ្មានបាន ប្រ-
ព្រឹត្តបទឧក្រិដ្ឋអ៊ីសោះឡើយ , បានជាខ្ញុំមានក្តីត្រេកអរទទួលកូនស្រីខ្ញុំ " ។

បណ្ឌិតកុង-ហ្ចឺសឺ ជាអ្នកកាចរឹងស្រួចចំពោះខ្លួនលោក ។ ចំពោះ
យោមតែចរិយាបស់លោក ហើយលោកច្រើនតែលាលថា « បើអ្នក
ស្រឡាញ់ខ្លួនមែនសួរមិ តែកុំភ្លេចថា ចៃអ្នកចង់កុំឲ្យគេប្រព្រឹត្តទាំងឆ្គង
មកលើអ្នក ។ ត្រូវកុំប្រព្រឹត្តទាំងឆ្គងនឹងអ្នកដទៃជាមុន " ។

ដល់លោកអាយុ ២០ឆ្នាំ , ពួកគេបានតាំងលោកឲ្យធ្វើដំណាងយក
ទ្រព្យបាលនៃដ្រកសាធារណៈ ។ ក្នុងគ្រានោះ លោកបានចុះបញ្ជី
គណនីត្រឹមត្រូវ ហើយលោកតាំងចិត្តពិតត្រង់ , ដល់ ២-៣
ខែក្រោយមក លោកធ្វើជាអ្នករក្សាកំលេស្មៅ , តាំងពីនេះ លោកបាន
ដែរក្សាបៀមឲ្យមានសាច់ដាត់ធំ ។

លុះដល់អាយុ ២៤ ឆ្នាំ , លោកគេជាអ្នកតស៊ូខាងសង្គមកិច្ច ជា
គ្រូបង្រៀនលើលំដាប់ណាឯយម, ដោយលោកលាលថា:

« ពួកបុណាមិនដែលបង្ហាញសំឡេងឥតប្រយោជន៍ទេ ។ ខ្លាចក្រែង
សកម្មភាពដែលខ្លួនធ្វើមិនបានការ, ចិត្តស្មូតត្រង់ជាការប្រសើរ ត្រូវ
ស្រឡាញ់អ្នកដទៃ ឲ្យដូចជាខ្លួនស្រឡាញ់ខ្លួនឯង " ។

កូនការបង្រៀនកូនសិស្ស លោកយកថ្លៃឈ្នួល ៣ក់តាមហាន:
កូនសិស្សមាន ប្លែក ។

លំដាប់តមក លោកបានសរសេរសៀវភៅឈ្មោះថា "ឯកសារ
នៃឯកាយៈវត្ថុនិងសារធាតុ" ដែលលោកបានឱ្យយោបល់អំពី
បញ្ហាសង្គមកិច្ចនិងសេដ្ឋកិច្ចវិញ ហើយបង្ហាញថា សង្គមនៃប្រទេសចិន
កន្លងមក មានសភាពយ៉ាងណាខ្លាំង ព្រោះគ្មានន័យខាងអត្ថ-
ប្រយោជន៍ នយោបាយសោះឡើយ ។ ការដែលចេញសៀវភៅ
នេះ នាំឱ្យលោកគុង-ហ្គុងសឺ មានបញ្ហាមត្រជាច្រើន ព្រោះមន្ត្រីធំៗតូច
ដែលប្រព្រឹត្តបទល្មើសកន្លងមក មានចិត្តភ័យតក់ស្លុតក្រែងគេដឹង
ចំណាប់ខ្លួន ។ តែមន្ត្រីទាំងនោះ ពុំបានមានពលភាពខ្លាំងឡើយ
ហើយព្រះមហាក្សត្រនៃរដ្ឋលូ (រដ្ឋដែលលោកគុង-ហ្គុងសឺស្ថិតនៅ)
តែងត្រូវការ លោកខាងមិនបាន ។ ព្រះមហាក្សត្រនៃរដ្ឋលូ មានព្រះភាព
ហ្មត់ចត់ខ្លាចព្រះមហាក្សត្រនៃរដ្ឋជូ (រដ្ឋនេះ ភាគធាតុមានមាឡូ) ។ នៅក្នុង
រដ្ឋជូនេះ មានចាស់ព្រឹទ្ធាចារ្យម្នាក់ឈ្មោះ ឡៅ-ស៊ឺ ជាអ្នកត្រួតត្រាឯក
សារនៃព្រះអធិរាជចិន ជាអ្នកមានប្រាជ្ញា ហើយចេះដឹងវិជ្ជាច្រើនឥតឆ្ងល់ ។
ព្រះមហាក្សត្រនៃរដ្ឋលូ បានចាត់លោកគុង - ហ្គុងសឺ ជាឯកអគ្គរាជទូត
ប្រចាំទីក្រុងនេះ ។

គេលនោះ លោកគុង-ហ្គុងសឺ មានអាយុ៦៧ឆ្នាំ លោកបានបង្រៀន

ឱសថ្មីតរបស់លោកថា "ធ្វើសកម្មភាពខ្លាចបានផល" ។ ចំណែកលោក ខ្លៅ-ស្តី បង្រៀនឱសថ្មីតរបស់លោកថា: "ត្រូវប្រព្រឹត្តមកម្មភាពខ្លាចបានផល" ។

គតិនៃលោកទាំងពីរ មានសភាពផ្ទុយគ្នាស្រឡះគឺថា បណ្ឌិតកុង-ហ្វូសឺយល់ថា "កិច្ចការទាំងឡាយត្រូវត្បាយាមធ្វើ ទើបបានសម្រេចប្រយោជន៍." បណ្ឌិតខ្លៅ-ស្តីយល់ថា "ត្រូវរង្គឹយឱ្យស្ងៀម ធ្វើសមាធិចិត្ត ហើយយកប្រាជ្ញាពិចារណាទើបបានសម្រេចប្រយោជន៍" ។

បណ្ឌិតខ្លៅ-ស្តីបានពោលថា: ដើម្បីធ្វើប្រទេសឱ្យបានសន្តិសុខ ត្រូវបំបាត់នូវការរំដើបំផ្លួល,អ្នកណាមិនបានធ្វើចិត្តឱ្យស្ងប់ស្ងៀមអ្នកនោះមិនអាចត្រួតត្រាប្រទេសបាន, តើអ្នកណាអាចធ្វើចិត្តឱ្យចាំស៊ុខបានដូចជាទឹកល្អក់ដែលគេដំកល់ទុកឱ្យរឿងថ្នា, គុណធម៌ដ៏ខ្ពង់ខ្ពស់មកប្រៀបដូចជាទឹកដូច្នោះ"។

បណ្ឌិតខ្លៅ-ស្តី បានសួរបណ្ឌិតកុង-ហ្វូសឺថា: «ឯងបានឃើញផ្លូវរៀបរយឬទេមា ? ឯងបានលះបង់ប្រកាយ កន្លងពេលដែលឯងធ្វើដំណើរទៅកន្លែងគួមិចិត្ត ចំពោះការរកបុព្វហេតុនៃធម៌ទាំងឡាយ" ។

លោកកុង-ហ្វូសឺតបថា: " ខ្ញុំបានបានរកអស់រយៈពេល ២៧ឆ្នាំហើយ មិនឃើញសោះផ្លូវនេះ " ។

បណ្ឌិតខ្លៅ-ស្តីពោលថា "បណ្ឌិតគេញចិត្តទាស្ងប់ការធំធឹត, ការស្ងប់ស្ងៀម មិនផ្តួលខ្ទេចដោយឥតពិចារណាទៅលើបុគ្គលណាមួយ តែងពិចារ-

ណាខ្លួនគាលវិលាជាមិច្ច. បើគេសមនិយាយទើបនិយាយ បើគេលមិន
ត្រូវនិយាយលោកនៅស្ងៀមស្ងាត់, ការលេងមានះតនវត្តមិនផ្សាយដំណឹង
ឲ្យអ្នកផងគាំងតួងដឹងឮច្បាស់ , បណ្តិតពិត ទេះពន្យល់ចំក្លីរឿងមិមួយ។
ចំពោះតែបុគ្គលណា. ដែលគាចសិក្សារឿនសូត្រថាន" ។

ក្រោយគេលដែលបណ្តិតកុង ហុងសឺ ត្រឡប់តាដ្ឋជូនកវិញ លោក
ថានចូលទៅក្រាបបង្គំទូលព្រះមហាក្សត្រេបសំលោកថា " សូមទ្រង់កុំ
ព្រួយបារម្ភក្តីឲ្យសោះ " ហើយលោកថានតណាអំពីគានុគាតប្រជារាស្ត្រ
នាឬ្នខត្តធំ ចរិយាព្រះមហាក្សត្រ ។ល។ ក្នុងរជ្ជនោះ ។

លំដាប់តមក លោកកុង ហុងសឺ ថានហានន្តះជាគាយក្លាចាលជង្រុក
ស្រូវសោធារណៈ ។ ក្នុងគេលនោះ លោកទំព្យាយាមបង្ការតពួជមនុស្ស
សត្វ ដោយការសរសេរផ្សាយតតាមន ធ្វើសន្ធិសីទ ព្រមទាំងពន្យល់
អំពីការអន្តរាយនៃការលំបាកឲ្យថានដារភ្លាំង ដល់អ្នកដែលប្រឹងប្រែង
ចំគេញការណ៍យកចិត្តទុកដាក់ទ្រព្យសម្បត្តិ ដើមបីជាប្រយោជន៍
ធនជារសព្វសារពើ មិនតែប៉ុណ្ណោះ លោកថានរៀបចំបទបញ្ញត្តិច្បាប់
ស្តីអំពីវិវាហមង្គលនៃបុរសអាយុ ៣០ឆ្នាំ នារីអាយុ ២០ ឆ្នាំ ស្រីមេម៉ាយ
ធំងប្រុសគោះម៉ាយឲ្យមានរបៀបរៀបរយ ។

ក្នុងការថានតែងតាំងលោកជាទាយចាត់ការទាងពីធីបុណ្យសាសនា
លោកថានរៀបចំខ្លួនវិជានការណ៍ទាងការគួរសម ការយុត្តិធម៌ ចំនៀម

ខម្ចាប់ ប្រពៃណី ការប្រាស្រ័យរវាងស្តេច និង ប្រជាកម្ពុជ ស្មោះទឹងត
រយៈ ចិត្តមានតែ ទឹង ប្តូរប្តាប្តូរត្រី មិត្ត ចាស់ ក្មេង ណែនាំកន្លះគួរ
ពួកភាពសាស្ត្រដាដើម ។

លំដាប់តមក ក៏ការបានតែងតាំងលោកជានាយកទាហានកងវិភ
ស្ថេរ មានការខាងត្រួតត្រាយ៉ាំងត្រឿងសស្ត្រាវុធទឹងប្រមាញ់ ហើយ
មានអំណាចដាក់ទណ្ឌកម្ម ចំពោះមន្ត្រីធំ - នាយទាហានឬនាយទាហាន
រងដែលប្រព្រឹត្តបទល្មើសផ្សេង ។

ក្រៅពីនេះ ក៏ការបានចាត់លោកឲ្យកាន់ដំណែងជានាយកចាត់
ការទាហានិកច្នៃសាន្តផ្សេង ។ ក្នុងគ្រានោះ លោកបានប្រគល់
ការឲ្យគេធ្វើកន្លងគ្រាដែលកិច្ចការកងសិកម្មបានធ្វើរួចហើយ តែកន្លង
ដែលប្រជាកម្ពុជិតនៅទំនេរ ត្រូវតាំងឲ្យធ្វើទាន់ដល់ផនណាដែលចេះធ្វើ
តិច្ចការល្អ ទឹងតឲ្យលំ ចំកុំឲ្យរមេរាភ្លាយផ្សេង ។ ដើម្បីវឌ្ឍនភាពនៃ
ទស្សាហកម្ម ទឹង សិល្បកម្ម ។

តមកទៀត លោកបានតាំងមុខងារទាហានជានាយកនៃក្រុមតំបាត់ពួក
ពាលទុច្ចរិត តែតាំងតាំងតុលាការ ធ្វើទណ្ឌកម្មដល់ពួកអ្នកប្រព្រឹត្ត
បទក្រិត្យ បទមជ្ឈិម បទលហុ ផ្តន្ទាទោសពួកនាំមុះបោរ ពួក
ផ្សាយដំណឹងអកុសល ។

លោកកុង ហ៊ុងសឺ បានពន្យល់ពួកនិស្សិតថា « បទបញ្ញត្តិនៃការសិក្សាដ៏ទុត្តមប្បទេសន្តនៃវិជ្ជា ជាកិច្ចប្រតិបត្តិដែលត្រូវយកគោលការណ៍ប្រកបដោយវិចារណញ្ញាណរបស់ខ្លួនមកចាត់ឲ្យបានចំរើន, វិចារណញ្ញាណនេះ ជាការកែប្រែមនុស្សឲ្យមានចរិយាល្អ ហើយនឹងដំកល់ជោគវាសនារបស់មនុស្សជាអវសានឲ្យបែរទៅជាសុក្រិតភាពក្នុងមហាកុសលតាំងពីមនុស្សខ្ពង់ខ្ពស់ ដែលមានចរិយាថ្លៃថ្នូរហួតដល់ជនសាមញ្ញអ្នកជោគជាប ត្រូវមានការណែនាំកិច្ចស្មើគ្នាតែមួយគឺ: កែប្រែបុគ្គលិកលក្ខណៈរបស់ខ្លួនឲ្យបានចំរើនជាតិយៅភាពតទៅ ។ ការធ្វើខ្លួនឲ្យបានប្រកបដោយសុក្រិតភាពគឺជាមូលដ្ឋានដ៏សំខាន់នៃការចំរើនពិតប្រាកដ » ។

ពេលក្រោយមក ឪតារបស់លោកខូលអនុញ្ញាតឲ្យ លោកមានចំណងជើងយកសព្ទថាតារលោក ទៅកាន់ដែនកន្លែង ដែលកាន់សេចក្តីតារលោក ទៅភូមិហ្វាងកួងរដ្ឋលូ ។ លោកគិតថាដំណើរការរបស់លោក មិនបានប្រែខ្លឹមយកន្លែងតែងត្រូវដំណើរពីស្រុកមួយទៅស្រុកមួយ ។ ហេតុនេះ ឪតារលោកមិនសាងទុក្ខសម្រាប់ដំកល់សពបិតាមាតាលោក គ្រាន់តែតួនដឹងឲ្យខ្លួនបន្តិចស្រួលចំណាត់ទៅអនាគត ។ លុះលោកតួនដឹងហើយ ស្រាប់តែខ្លះចាញ់ខ្លាយមួយធ្លាក់ទៅជាដីកបស្មៅទៅវិញ ។ លោកគិតថាការកែប្រែម្រេះអ្វីមួយ ឲ្យខុសពីមុនទៀមទាំមួយប្រភេទណាជាជួនដំតា មិន

មែនធ្វើបានដោយងាយទេ មិនមែនមកពីហេតុអ្វីទេ គឺមកពីព្រះជាម្ចាស់ជាហេតុនាំក្នុង ។

លោកបានតាំងនាក់ឯសៀវភៅរបស់លោកមួយឈ្មោះ «ការសិក្សាដ៏ធំទូលាយ» មានសេចក្តីថា «សិក្សាដោយគ្មានគិតពិចារណាមែនអាត្មាតែឯងវាគ្មានប្រយោជន៍, គិតពិចារណាដោយគ្មានការសិក្សាមែនឯងគាំទ្រខ្សោយជាខ្លាំង» ។ ក្នុងពេលនោះ លោកបានស្ថាបនាសាលារៀនមួយឈ្មោះថា «សាលាសិក្សាអាឯរះបៀប យុត្តិធម៌, សុចរិតនឹងការស្និទ្ធស្នាល» ។ ពេលនោះ មានសាក៏ខ្លះ ត្រមាំងនិស្សិត ៣០០ នាក់ ចូលមកសិក្សាក្នុងសាលានោះ ។ ក្មួនសិស្សដែលមកពីប្រទេសផ្សេងៗ ប្តូរក្នុងរៃនៃប្រទេសចំនួន តែងមកសុំគេហដ្ឋានរបស់លោកសំណាក់អាស្រ័យ ។

លោកកុង ហ្វូឆឺបានតាមរៀនក្មួនសិស្សនឹងសាក៏របស់លោក ខ្លះ ច្រើនជាច្រើនមែនច្រើនយ៉ាង ។ ក្រោយនោះ គឺលោកធ្វើអត្ថាធិប្បាយពាក្យសុភាសិតបណ្តាំតបុណដែលលោកបានរៀបចំតាមសភាពលក្ខណៈ បទមែនតាមថាំដែរ ។ ក្រោយនេះ លោកបានប្រមូលយកទៅធ្វើជាសៀវភៅបាន ៤ក្បាលគឺ :

១-យី-ឆឺង មៀវភាពណានាអំពីបទបញ្ញត្តិច្បាប់ផ្លូវសង្គមសិទ្ធិអំណាចមែន ។

២ - ជ្ញ-កឹង សៀវភៅប្រវត្តិសាស្ត្រ ។

៣ - ឆេ-កឹង សៀវភៅតែងកាព្យឃ្លោង ។

៤ - យ្ញ-កឹង សៀវភៅតណិនាអំពីទំនៀមទម្លាប់ប្រពៃណីនឹងក្នុង ។

គេលខោះ ប្រទេសចិន មានការចលាចលជាច្រើនកន្លែង រដ្ឋមន្ត្រីក្តៅយោគកម្ចាត់អង្គឌួង, កូនសំឡាប់ឪពុក ។ លោកកុង-ហ្វូ-ស៊ី មានចិត្តជំពួលជាខ្លាំង ហើយដើម្បីនឹងបំបាត់ នូវការចលាចលទាំងនេះ លោកបានសរសេរគម្ពីរមួយឈ្មោះថា "ជូរ៉ែង-ស៊ូវ" ឯកសារនិទាន-រដ្ឋរំនឹងសរទរដូវ ។ ក្រោយមកមានពួកគ្រូសោងស្តេចត្រាញ់ប៉ះប៉ូវបង្កើតការបះបោរឡើង (គ.ស. ៥១៣) ។ ព្រះមហាក្សត្រដួលទ្រង់ចាកចេញពីរដ្ឋតំ ៧ កន្លះទៅដល់ ។ មានពួកមួយក្រុមរួមគំនិតគ្នាតែងក្តៅយោគកម្ចាលោកកុង-ហ្វូ-ស៊ី ។ គឺរត់ចេញពីរដ្ឋលូ ទៅរដ្ឋស៊ូ, ទ្រង់ឈ្មោះដើម-ស៊ូវ ។ ខៅខំខោះ លោកបានជួបមន្ត្រីខ្លះជាន-ហ្មាន់ក្នុង ហើយបានចូលទៅតាល់ព្រះមហាក្សត្រដ្ឋស៊ូ ។ ព្រះមហាក្សត្រអង្គនេះ ទ្រង់សព្វព្រះហឫទ័យតាំងលោកធ្វើជាទីប្រឹក្សា ។

គេលខោះ លោកបានឮឃ្លាខ្លួវបុកណាសុភាសិត ហើយបានគំណត់កម្ចាត់ពីតែទម្រង់ទំនៀមទម្លាប់បុកណា ។ តែលោករដ្ឋមន្ត្រីទីមួយពុំក្រមតាម ហើយចោទប្រកាន់លោកថា "លោកយកបុកណាជាធំ ដើម្បីបន្តុះបង្អាប់បច្ចុប្បន្នសម័យ, គោលតាំសចក្តីល្អកន្លងអតីតកាល ដើម្បី

បះពាល់ឲ្យសេចក្តីអាក្រក់កើតឡើងបច្ចុប្បន្នកាល ។ ។

ព្រះមហាក្សត្រនៃជ្វាត្បូ ទ្រង់យល់ស្របតាមលោកដូច្នេះទើ ទ្រង់ត្រេះតែពេលនឹងលោក កុន-ហ្គុនស៊ី ជាភ្ញាំង ។ លោកកុន-ហ្គុនស៊ី បានចាកចេញពីជ្វាត្បូ រួចត្រឡប់មកកាន់ជ្វាលូវិញ ។ នោះជ្វាលូមានសង្គ្រាមតស៊ូនៅឡើយ ។ ពួកមន្ត្រីធ្វើបាបបង្ក្រូតូចតាច ។

លុះលោកអញ្ជើញមកដល់ជ្វាលូ, សាលាចាត់រៀបអប់រំយុត្តិធម៌ និងសុឆរិយធម៌ ត្រូវពេជ្ឈការលុបចោលជាអសារបង់ ។ លោកកុន-ហ្គុនស៊ីក៏បន្តនៅធ្វើតាមវិន័យសាលារៀន, តែប្រជារបស់លោក កំផ្សុយខ្លួនលាខឡើង, មានភ្លើងបះបោរ ក្រុមមន្ត្រីការពារត្រង់ក្រសួងបានប្រើឲ្យចាប់ដឹងនាំលោកឲ្យចូលបម្រើសេចក្តីខ្លួន តែលោកមិនព្រមចូល បើខ្លួនជាអ្នកណាពោលតាក្យតំពេរពីសាយ៉ាង៌ណាក៏ដោយ ក៏លោកមិនព្រមចូលជាដាច់ខាតអស់រយៈវេលា ១៥ ឆ្នាំ ។

មានថ្ងៃមួយ ជាទីសល្ងាតើជ្វាលូបិតនៅក្នុងសន្ធិសាតគ.ស.៩០០ ភាគការបានអញ្ជើញលោកឲ្យការដំណែងជាប៉ាហ្គុយក្រុង តួន-ក្ឌូ ។ លោកក៏ត្រូមទទួលធ្វើ, ពេលនោះលោកមានអាយុ ៥២ ឆ្នាំ, ដោយសារប្រជារបស់លោក, ក្រុងភូទិន ព្រះបៅជ្វាលូ ក៏តែងតាំងលោកកន្ទ្រាហានន្តរសក្តិកាន់តែខ្ពស់ឡើង ។ តាំងពីចាប់ហ្វាងកំសាន្ត ចាប់ហ្វាងពួកពាលទុច្ចរិត ទីបំផុតជាទីបកជនៃជ្វាលូ គ.ស. ៩៨៧ ។

ឋណ្ឌាគស្ត្រ មានសេចក្តីសរសើរបណ្ឌិតកុង-ហ្វូនសឺតន់តេក ។ រដ្ឋលួចជារដ្ឋមួយ ប្រកបដោយសម្បូណិភាព ទឹងតែជាទុភាគយ៉ាងអស្ចារ្យ ។

មានរដ្ឋដទៃ ប្រាថ្នាចូលមកលុកលុយរដ្ឋលួ, តែបណ្ឌិតកុង-ហ្វូនសឺ ឃាត់ចាត់ឱ្យកងទ័ពទៅបង្ក្រាបគាល់តែស្ងប់ស្ងាត់ ។

តាមក្បួនរណសាស្ត្រចិន ឃាតណិនាប្រវត្តិសាស្ត្រប្រទេសចិនរបស់លោកស៊ូលៀយដឺម៉ូរ៉ង់ត៍ មានក្បួនរណសាស្ត្រលោកមេទ័ពសុន-ស្តូជាដើមឃាតនោលថា ៖

" រក្សាថែទាំប្រទេសជាទី ១, បំផ្លាញប្រទេសដែលជាសត្រូវជាទីពីរ, ច្បាំង ១០០ ជង ជោគជ័យ ១០០ ជង តុំប្រសើរទេ ការដែលប្រសើរនោះគឺ ចេះធ្វើកងទ័ពរបស់សត្រូវឱ្យបាក់ទៅឃាតនឹងមួយកន្ទុងគ្មានច្បាំង, បើកងទ័ពបច្ចាមិត្រមានកម្លាំង ១០ ភាគលើសកងទ័ពខ្លួន ត្រូវចាត់កងទ័ពឱ្យទៅឡោមព័ទ្ធកងទ័ពមច្ចាមិត្រ, បើកងទ័ពបច្ចាមិត្រមានកម្លាំង ៥ ភាគលើសកងទ័ពខ្លួន ត្រូវនាំកងទ័ពទៅវាយតែមួយភាគ, បើកងទ័ពសត្រូវមានកម្លាំងតែពីរភាគ ត្រូវបំបែកកងទ័ពរបស់ខ្លួនជាពីរផ្នែកគឺ: មួយផ្នែកសម្រាប់ទប់កងទ័ពសត្រូវឱ្យទៅនឹងមួយកន្ទុងមួយផ្នែកទៀត សម្រាប់វាយលុកចូល ។ អ្នកណាស្គាល់គេលះវិលវៃដែលត្រូវនាំកងទ័ពទៅច្បាំងអ្នកនោះនឹងមានជ័យជំនះ, អ្នកណាប្រើរយៈ

រៀបជាច្រើនទ្នាំ ដើម្បីនឹងធ្វើសង្គ្រាម អ្នកនោះមិនស្រឡាញ់ប្រជាពស្ត្រ
ឈ្មោះថាជាសត្រូវនឹងប្រទេសរបស់ខ្លួន, ធ្វើសង្គ្រាមដោយងាយឆាប់ឆ្លាមព័ទ្ធ
នឹងការតែប៉ុណ្ណោះដើម្បីឱ្យបានជាគជ័យ ឈ្មោះថា មិនចេះធ្វើ
សង្គ្រាមទេ. អ្នកណាដែលគិតតែចំផ្លាញទ័ព្រកន្ធនឹងកងទ័ពសត្រូវ អ្នក
នោះហៅថាល្ងង់, ការប្រសើរគឺ ចេះលៃលកឱ្យបានទីព្រកន្ធនោះមកបិត
នៅក្នុងកណ្តាប់ដៃយើងឬកនឹងពលសត្រូវឱ្យបាត់បង់បង្ហិច ។ ព្រោះហេតុ
ដូច្នោះ យើងត្រូវប្រើមធ្យោបាយគ្រប់យ៉ាងប្រសើរជាងធ្វើសង្គ្រាម ។
ប្រឹងហ៊ានបានជាគជ័យ គឺបង្ខូចកម្លាំងរបស់ខ្លួន ដោយពាយតួក
ទាហានរបស់ខ្លួន, ត្រូវលៃលកឱ្យបានកម្លាំងទាំងស័ល្លធមិ ចំណែនភាន
ឬប្រើន ស្ងាត់ចំពោះនឹងគ្រឿងសស្ត្រាវុធឱ្យបានប្រកបទៅតាមកាលៈទេសៈ
ជាការប្រសើរតែន់តែក អ្នកណាហ៊ានមកធ្វើសង្គ្រាមចំពោះកងទ័ពបែប
នេះ ហៅថា ក្លិត" ។

ក្នុងគ្រានេះ ព្រះមហាក្សត្រនៃរដ្ឋក្រុងធំព្រះនាម តឺង ដោយ
មានរដ្ឋមន្ត្រីរបស់ព្រះអង្គចាត់ពុក កំលើកកងទ័ពមកវាយរដ្ឋលូមានជ័យ
ជំនះ តែពួកប្រជាពស្ត្រនៅរដ្ឋលូ បានយកលទ្ធិកុង - ហ្វូឈឺមកតតាំ ។
ព្រះចៅតឺង កំត្រមថ្វាយរដ្ឋលូមកព្រះមហាក្សត្ររដ្ឋនេះវិញ ។

តាំងពីនោះមក អាទុកាតរបស់បណ្ឌិត កុង-ហ្វូឈឺ កំផ្សាយពេញ
ប្រទេសចិនទាំងមូល ។ តែបច្ចាមិត្តនៃបណ្ឌិត កុង-ហ្វូឈឺ កំមិនលះបង់

ការគំនុំគុំគួនសោះ, ពួកវា មិនចង់ត្រឹមតែហួចដាវបណ្ដែត កុង-ហ្គុងសឺ ដំណែងជាទេបពជនៃរដ្ឋលូប៉ុណ្ណោះទេ ថែមទាំងចង់បំផ្លាញទូវសាវកបេស់លោកព័ខាក់ខ្លីតទៀត លោកត្សៃ-លូ និងលោកត្សៃ-ហូ ដែលបិតនៅក្នុងដំណែងជាន់ខ្ពស់ខ្លាំងផងដែរ ។ ហេតុនេះហើយបានជា ពួកបច្ចាមិត្តបេស់លោក ចានចូលទៅចងភ្ជាន់មន្ត្រីនិងព្រះចៅរដ្ឋត្សិ ។ មានទ័ព្រីក្សារបស់ព្រះចៅរដ្ឋត្សិ ទូលព្រះមហាក្សត្រឲ្យនាំស្រីរ៉ាំនិងក្រុមក្មេងចំនួន៨០នាក់ ដែលមានរូបឆោមល្អៗទៅតាំងថ្វាយព្រះចៅរដ្ឋលូ ។ ព្រះចៅរដ្ឋលូ ដោយត្រេកអរនឹងនាងនាដកាតាំងឡាយ កំភ្លេចកិច្ចការដែនដី ។ ក្នុងសម័យនោះ ពួកបច្ចាមិត្តបណ្ដែត កុង-ហ្គុងសឺ កំឡុតឧកាសក្រោបបង្ខំទូលព្រះមហាក្សត្រ ចឹង ។ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យជេជង ចានហូតដាវលោក កុង-ហ្គុងសឺ ចេញពីដំណែងជាមហាទេបាធ ។

បណ្ដែត កុង-ហ្គុងសឺ លុះខ្លួនចេញពីដំណែងទេបាធៃរដ្ឋលូហើយ កំឡុងដំណើរតាមផ្លូវមួយ ទៅដល់មួយ ត្រាច់ឆ្ពោះតាមខេត្តមជ្ឈិមប្រទេសលំភ្នំ អ្នកស្រុកថា: មនុស្សមាន ៦ ប្រភេទ:

ថ្នាក់ទី ១ - មុខនឹងតាំងខ្លួនជាបណ្ដែត, ត្រូវសិក្សាទូវវិជ្ជាតំងឡាយ ត្រមតាំងពីចារណាទូវវិជ្ជាតំងនេះ ឲ្យចានយល់សព្វត្រប់ ហើយធ្វើទូវបេសកកម្មបង្ហាញទូវសមត្ថភាពរបស់ខ្លួន ។

ថ្នាក់ទី ២- ត្រូវបង្ហាត់បង្ហាញទូវវិជ្ជាតំងឡាយដល់អ្នកដទៃឲ្យចាន

ចេះបាំស្ពាត់ តែហាមកុំឲ្យត្រួតត្រាបង្ក្រាបគ្នាឲ្យសោះ ។

ថ្នាក់ទី ៣ - ត្រូវគ្រាច់តាម "តាវ" គឺតាស់ទាតាវដែលចូលមកបំភ័ន ៣ ក្នុងខ្នងយើង ហើយបណ្តេញទាំងតាតាជាមិនក្រោយ (ថ្នាក់នេះ ប្រហែលជាចង់ថា បើមានវិជ្ជាគ្រប់គ្រាន់ហើយ ត្រូវប្រព្រឹត្តប្រតិបត្តិតាមវិជ្ជានោះ ឲ្យពាល់តែសម្រេចខ្លួនតែម្នាក់ឯងដាច់ប្រសើរ) ។ តាវនេះ បើតាមយល់ដេសខ្ញុំ គឺ "ផ្លូវ" ។

ថ្នាក់ទី ៤ - មនុស្ស - នាគ ត្រូវចេញខ្លួនឲ្យចំរើនសត្រូវជាឲ្យបានចុះសឹមមនុស្សធម្មតា ដើម្បីធ្វើការជាប្រយោជន៍មនុស្សជាតិនឹងដែនដី ។

ថ្នាក់ទី ៥ - មនុស្ស-នាគ ចេះគេចញ្ញលក្ខណៈប្រព្រឹត្តប្រតិបត្តិត្រឹមត្រូវតាមលទ្ធិកុង - ហ៊ុឺសឺហើយ ញ៉ាំងអ្នកដទៃឲ្យប្រតិបត្តិតាមៈហៅថា ទេវមនុស្ស ។

ថ្នាក់ទី ៦ - មនុស្ស - នាគ ហោះហើរ ចេញខ្លួនឲ្យមានលំអសច្ចធម៌ សុចរិតត្រង់យ៉ាំង លែងភ័យ លែងខ្លាច, គឺខ្លួនបានធម៌ហើយ ញ៉ាំងអ្នកដទៃឲ្យបានធម៌ផង ។

ចាប់តាំងពីនោះមក លោកកុង-ហ៊ុឺសឺ បានគ្រាច់ទៅកាន់រដ្ឋវ៉ៃ, រដ្ឋគ្នេន, រដ្ឋត្សូ, រដ្ឋត្ងួង; លោកនៅកាន់រដ្ឋត្ងួងអស់រយៈវេលា ៣ ឆ្នាំ ។ នៅក្នុងវដ្ឋណាក៏ដោយ លោកជួបប្រទះតែមានអំពើពាលខុសច្បាប់គ្រប់យ៉ាងគឺៈ មនុស្សប្រព្រឹត្តអបាយមុខ, ពួកអសប្បុរស, មនុស្ស

លែងប្រព្រឹត្តតាមច្បាប់ដូច, ទឹងមនុស្សមានតែចិត្តថ្លាបរិសុទ្ធ ។

លុះលោកអញ្ជើញទៅដល់រដ្ឋធូអាង, លោកត្រូវពលការនៃរដ្ឋនោះ ចាប់ខ្លួនលោកទៅដាក់គុក, តែមិនយូរប៉ុន្មាន លោកបានរួចពីការឃុំឃាំងធ្វើដំណើរទៅដល់រដ្ឋតួង ក្នុងវេលាត្រកៃ-ហ្វុង-ហ៊ូ, ក្រោយមកលោកបានអញ្ជើញទៅដល់រដ្ឋសុង ដែលជារដ្ឋរបស់ដីដូនដីតាលោក។ ទៅទីនេះ លោកត្រូវនាយពាហនជាន់ខ្ពស់ម្នាក់ ដែលជាបច្ចាមិត្តរបស់លោក ចង់ពិឃាតលោក តែមិនសម្រេចដូចបំណង ។ រួចលោកបានបន្តដំណើរមកដល់រដ្ឋកៃឡូ ។

ក្នុងពេលនោះ មានសង្គ្រាមកើតឡើងរវាងរដ្ឋវ៉ូ ទឹងរដ្ឋតួង ។ ព្រះមហាក្សត្រនៃរដ្ឋតួង ដែលចុះចង ស្គាល់មេត្រីទឹងមហាក្សត្ររដ្ឋតួង ទ្រង់បានជ្រាបថា បណ្ឌិតកុង-ហ្វូងសឺ បិតាខាងឯកូមិភាគរដ្ឋតួងទឹងកៃឡូ ទ្រង់ចាត់ឲ្យនាំបណ្ណាការទៅដូនបណ្ឌិតកុង-ហ្វូងសឺ ដើម្បីសង្កេតឲ្យមកធ្វើជាទីប្រឹក្សារបស់ព្រះអង្គ ។ បណ្ឌិតកុង-ហ្វូងសឺ កំពុងរៀបចំថាទឹងចេញដំណើរទៅ ប៉ុន្តែ ពួកសាវ័ករបស់លោកយល់ថា មានគន្លឹះសំខាន់ត្រូវចាំផ្គត់ផ្គង់ក្លាយទៅជាបំរុងទឹងពិឃាតលោក ។ គំនាក់នាងអញ្ជើញទៅ ។ លោកមានអាយុ ៦៣ឆ្នាំហើយ លោកបានលែងត្រឡប់មកកាន់ដួងវិញ ។

(មានត)

សុបរិតនឹងទុច្ចរិត-រឿងព្រេងរុស្ស៊ី

អ្នកស្រី ស-សាក ប្រែរៀបរៀង

លោក ប៊ូ-ប៉ូ ពិនិត្យតែសម្រួល

ថ្ងៃមួយ មានបុរសអ្នកស្រែតាំទោកន់និយាយជជែកគ្នាអំពីសុចរិតនឹងទុច្ចរិត ដូចមានរៈសេចក្តីតទៅនេះ ៖

បុរសម្នាក់ ជាមនុស្សវាសនាប្រព្រឹត្តតែអំពើទុច្ចរិត រកបានមួយថ្ងៃស៊ីតែមួយថ្ងៃ ដោយអំពើរឿចត្រង់យ៉ាងនេះ ទៅខ្វះតែអំពើលួចចូនតែមួយយ៉ាងប៉ុណ្ណោះ ។

បុរសម្នាក់ទៀត ជាបណ្ឌិតប្រព្រឹត្តតែអំពើសុចរិតជានិច្ច ។ អ្នកទាំងពីរដើរមកជួបប្រទះគ្នាទៅនាកណ្តាលផ្លូវ ក៏និយាយសាកសួរសុខទុក្ខគ្នាអំពីបេះចិញ្ចឹមជីវិតរៀងខ្លួន ។

បុរសពាល និយាយថា ខ្ញុំចូលចិត្តតែចិញ្ចឹមជីវិតដោយអំពើទុច្ចរិត ភូតតរកុហកបោកប្រាស់គេជានិច្ចកាល ។

បុរសបណ្ឌិតឆ្លើយថា មិនដែលមានអ្នកណាចេះតែភូតតរកុហកបោកប្រាស់គេបានពាល់ថ្ងៃទេ , ចំណែកខ្ញុំវិញ ខ្ញុំស៊ូត្រាំចិញ្ចឹមជីវិតដោយអំពើសុចរិត· ទោះបីលំបាកវេទនាយ៉ាងណាក៏ដោយចុះ ឲ្យតែធ្វើតាមរៈសេចក្តីពិតត្រង់ ។

ប៉ុន្តែតាំងពីខាត់ ជាដែកគ្នាដណ្តើមយកត្រូវតែរឿងខ្លួន មិនត្រូវ
ចាញ់គ្នាទៅវិញទៅមក មិនប៉ុន្តែសម្រុងគ្នាសោះ ទើបស្រុះចិត្តប្តេជ្ញាគ្នា
ថា "៖យើងត្រូវតែដើរស្វែងស្វែងរកមនុស្សដទៃទៀត ប្រាប់តែឲ្យជួយដោះ
ស្រាយរកមុខត្រូវរឿងយើងតាំងពីខាត់" ដូច្នេះហើយពួកគាត់ក៏ធ្វើដំណើរ
ទៅ ។

ប៉ុន្តែពីរខាត់បណ្តើរគ្នាទៅមិនយូរប៉ុន្មាន ក៏បានជួបប្រទះនឹងអ្នកស្រែ
ម្នាក់កំពុងភ្ជួរស្រែ ទើបដើរដម្រង់ទៅដល់ហើយសួរថា ៖

បពិត្រអ្នកដ៏ចំរើន ! សូមអ្នកមេត្តាកាត់សេចក្តីមនុស្សត្រូវឲ្យយើងខ្ញុំ
បន្តិចមើល នៅក្នុងសកលលោកនេះ តើគេតាំងមជ្ឈិមដីតដោយអំពើសុចរិត
ឬដោយអំពើទុច្ចរិត តើអំពើណាប្រសើរជាង ? យើងទុំដែកគ្នាមិន
ជាចប្រែចសោះ ។

អ្នកស្រែឆ្លើយថា ៖

-នែអ្នកតាំងពីរ ! អំពើសុចរិតឬក្តីអំពើមិនសឹងនឹងដូចគ្នាតាំងមជ្ឈិមដីត
យើងទេ យើងត្រូវតែប្រព្រឹត្តិតាំងមជ្ឈិមដីតដោយអំពើទុច្ចរិតអឬក្តីអំពើ
សុចរិត ទើបបានស្រួលរស់នៅក្នុងលោកនេះបានដោយងាយ ព្រោះអំពើ
សុចរិតឬក្តីអំពើមិនប្រៀបដូចអ្នកតាក់ស្បែកដើរសំពត់ស្តើងខ្លាំង ដើរមិនបាន
វែងឆ្ងាយទេ; ឯអំពើទុច្ចរិតឬក្តីអំពើមិនប្រៀបដូចអ្នកតាក់ស្បែកដើរជើងយ៉ាង
ក្រាស់ជាប់មាំ អាចដើរបានវែងឆ្ងាយណាស់ បើទុកជាដើរទៅជាន់លើ

ចំរើនបន្ទាប់ ក៏មិនមុតបាតដើងដែរ ចេះតែទៅរួចហូត ។ អ្នកគ្នាប់ដឹងឬទេ? ក្នុងប្រទេសយើងសព្វថ្ងៃនេះ ពួកគហបតីដែលជាម្ចាស់យើង គេគិតតែតឹងតែរយកផលប្រយោជន៍អំពីយើងឲ្យតែញ ។ ។ ក្នុងមួយថ្ងៃៗ ឥតឲ្យខ្លះកន្ទុះទេ? យើងកែតែពេលចំនេះនើបំពេញផលប្រយោជន៍បេស់ខ្លួនពុំបានសោះ, ដូច្នេះ យើងត្រូវតែពុតធ្វើជាឈឺ ដើម្បីទិនលួចបន្ទុចួលទៅរកគាប់ឈើកន្ធរព្រៃនៅពេលថ្ងៃ បើគេដឹងពុតយើងហើយ គេហាមប្រាមមិនឲ្យយើងធ្វើដូច្នោះទៀត យើងលួចទៅធ្វើនៅវេលាយប់វិញ ។

- ហ៎! មើចទៅ ឯងឮឬទេ? ឯងដឹងថាអញយល់ត្រូវមែនឬទេ? (ប៊ុសសាលសួរប៊ុសសបណ្ដិត) ។

ប៊ុសគាំងតិចនោក នៅមិនទាន់អស់ចិត្ត ក៏បបួលគ្នាដើរទៅមុខទៀត លុះដើរទៅបានបន្តិច ដួបនឹងឈ្មួញរេម្នាក់ ស្រែកហៅថា ៖

សូមអ្នកឈប់បន្តិចសិន ព្រោះយើងខ្ញុំចង់សួរប្រស្នានឹងអ្នកបន្តិច បើអ្នកអនុញ្ញាតឲ្យសួរបាន? យើងខ្ញុំនឹកសង្ស័យថា ក្នុងលោកនេះមនុស្សយើងត្រូវចិញ្ចឹមជីវិតដោយអំពើសុចរិត ឬ ទុច្ចរិត?

អ្នកដំណើរញញឹមថា នែអ្នកអើយ! អំពើសុចរិតធ្វើឲ្យយើងចិញ្ចឹមជីវិតដោយលំបាកណាស់ ត្រូវតែយើងគេស៊ុចិញ្ចឹមជីវិតដោយអំពើទុច្ចរិតវិញ ដ្បិតថា បើគេកុហកបញ្ឆោតបោកប្រាស់យើងហើយ យើងក៏ត្រូវបញ្ឆោតបោកប្រាស់គេវិញដែរ ។

បុរសពាល ម៉េចឯងវាងខ្លាំងម្ល៉េះ ? អញគិតត្រូវមែនឬទេ ? អ្នកទាំងពីរមិនពាន់ឃល់ស្រមគ្នាសោះ ទើបប្រឹក្សាគ្នាថាយើងត្រូវទៅសួរអ្នកណាម្នាក់ទៀត ឲ្យជាន់តំរង់បីនាក់ ដើម្បីឲ្យអស់ចិត្តអំពីប្រស្នារបស់យើង ទើបនាំគ្នាដើរទៅមុខទៀត ដេរតែដើរយូរ ។ ៧ ជាន់ជួបនឹងសេដ្ឋីម្នាក់ ហើយនិយាយថា ៖

-សូមលោកអាណិតមេត្តាឈប់បន្តិចសិន យើងខ្ញុំសុំសួរលោកអំពីប្រស្នាមួយថា " មនុស្សយើងសព្វថ្ងៃនេះ ត្រូវរកស៊ីចិញ្ចឹមជីវិតតាមអំពើសុចរិតស្រួលជាង ឬតាមអំពើទុច្ចរិតស្រួលជាង ?

សេដ្ឋី- ប្រស្នាអ្នកតាំងពីដើមណាស់ អ្នកកុំឆ្ងល់តឹ ការរកស៊ីចិញ្ចឹមជីវិតដោយអំពើទុច្ចរិតប្រសើរជាងអំពើសុចរិត។ ក្នុងលោកនេះ អ្នកទៅរកសុចរិតឯណាឃើញ បើអ្នកឯងនិយាយតាមត្រង់ មុខជាគេបញ្ជូនឲ្យទៅស្រុកស៊ីបេរី (Sibérie) ហើយ ហើយគេថាទៀតថាយើងកុហកគេថែមទៀតផង ។

បុរសពាល- ទំ ឯងវាងខ្លាំង ! អ្នកណាក៏គេថាដូច ។ គ្នាដែរ យើងសួរមនុស្សបីនាក់ហើយ គេឆ្លើយតែរបៀបមួយទៅលើទុច្ចរិតពាល់ម៉ាត់ថា ការរស់នៅដោយអំពើទុច្ចរិតគ្រាន់បើស្រួលជាងរស់នៅដោយអំពើសុចរិត ។

បុរសបណ្ឌិត- ខេ ! ខេ ! អញមិនយកទេ ! អញយកតែខាងសុចរិតទុកជាអញខ័ស្រក្រសំបាកសំបិនយ៉ាងណាក៏ដោយ . ក៏អញមិនត្រមះកស៊ីតាមអំពើទុច្ចរិតដែរ ។

បុរសទាំងពីរនាក់ និយាយគ្នាដូច្នោះហើយ ក៏នាំគ្នាដើរទៅស្វែងរកធ្វើការងារជារបរចិញ្ចឹមជីវិតទាំងពីរនាក់ ។ បុរសពាលចេះតែចំបែរចិត្តឲ្យរៀបចំតាមកាលៈទេសៈនិងតាមកិច្ចការ ហើយទៅរស់នៅណា ក៏ចេះតែមានមនុស្សឲ្យថ្លាយចំណីបរិភោគឥតខ្វះដែរ ហើយឥតគិតថ្លៃទៀតផង ។ ចំណែកបុរសបណ្ឌិត ក៏ចំធ្វើការងារយកថ្លាយចំណីមជីវិតខ្លួនពាល់ថ្ងៃដោយសេចក្តីពេញចិត្ត និងអំពើសុចរិតរបស់ខ្លួនជានិច្ចកាល ។

ថ្ងៃមួយ នៅគ្រាដែលបុរសបណ្ឌិតធ្វើដំណើរទៅតាមផ្លូវក៏និកម្មនថ្លាយជាភ្ញាំង ទើបនិយាយនឹងបុរសពាលជាសំឡាញ់ថា ៖

– ចូរឯងអាណិតអញ ឲ្យនំប៉័ងមួយដុំមកអញស៊ីផង ។

បុរសពាល – ចុះឯងឲ្យអ្វីជាសំណងមកអញវិញ ?

បុរសបណ្ឌិត – បើឯងចង់បានអ្វី ស្រេចនៅចិត្តឯងយកចុះ ។

បុរសពាល – អើ ! បើឯងថាអីចឹង អញត្រូវឆ្កៀលយកគ្រាប់ភ្នែកឯងម្ខាង ។

បុរសបណ្ឌិត – អើ ! មិនជាអ្វីទេ អញត្រូមឲ្យឆ្កៀលតាមចិត្តឯង ។

បុរសពាលក៏ឆ្កៀលយកគ្រាប់ភ្នែកម្ខាងរបស់បុរសបណ្ឌិត រួចឲ្យនំប៉័ងមួយដុំទៅបុរសបណ្ឌិត ហើយនាំគ្នាដើរទៅមុខទៀត ។

ថ្ងៃក្រោយមកទៀត បុរសបណ្ឌិតឃ្លានខ្លាំង ពាល់តែអត់គ្រាំពុំបាន ក៏ប៉ុនប៉ងពីបុរសពាលមួយដុំទៀត ។

បុរសតាល - ម៉េដូច្នោះ អញត្រូវតែឆ្កៀលយកគ្រាប់ភ្នែកឯងមួយទៀត ។

បុរសបណ្តើត ។ ! សំឡាញ់អើយ សូមអាណិតអាសូរអញឯង ម៉េឯងឆ្កៀលភ្នែកអញម្ខាងទៀត មុខជាអញខ្វាក់លែងឃើញអ្វីសោះហើយ ។

បុរសតាល - ឯងខ្វាក់ទៅជាអ្វីក៏ដោយ ម៉េឯងចូលចិត្តតែរស់នៅដោយសារអំពើសុចរិតដូច្នេះហើយ ឯងខ្វាចខ្វាក់អីទៀត ។

បុរសបណ្តើត- ដញ្ញឹងគិតថា ធ្វើម្តេចឥឡូវ ម៉េឯងឃ្លានបាយស្ទើរដាច់ខ្យល់ តាល់តែគ្រាំអត់មិនឃ្លានហើយ, គិតរួចប្រាប់ថា ល្អើយបុះសំឡាញ់ ! ម៉េឯងមិនខ្វាចកម្មតៀរវែងទេ ចុះឯងឆ្កៀលយកគ្រាប់ភ្នែកអញម្ខាងទៅទៀតចុះ ។

បុរសតាលក៏ឆ្កៀលភ្នែកបុរសបណ្តើតម្ខាងទៀត រួចឲ្យដំបុ័ងមួយដុំហើយប្រាប់ថា អញមិនដឹកដៃឯងនាំទៅទេ, ត្រូវឯងនៅទីនេះចុះ ចង់ទៅឯណាតាមចិត្តឯង អញលែងនៅជាមួយឯងទៀតហើយ អាមនុស្សខ្វាក់យ៉ាងនេះ ទីឯណាជាការអ្វី ជាប៉ុណ្ណោះក៏ដើរចោលបុរសបណ្តើតឲ្យទៅ ។

ចំណែកបុរសបណ្តើតខ្វាក់ភ្នែកដ៏ខ្លឹតឈឹងលែងឃើញអ្វីសោះ ឯងដំបុ័ងមួយដុំបរិភោគអស់ហើយ ក៏ពាំស្ទាបផ្លូវដើរតើមៗទៅមុខទៀត ដោយនឹកសង្ឃឹមថា ត្រែងឯងដល់ស្រុកភូមិណាមួយគ្រាន់ទិញនៅសំណាក់អាស្រ័យ, លុះចេះតែដើរតើមៗទៅក៏រំងើនផ្លូវ មិនដឹងជាតម្រង់

ទៅទិសទិដ្ឋចំណាះ ទើបបង្ខំចិត្តថាស្រែកអំពាវនាវបន្ទរទៅតាសុំឲ្យ
ជួយស្រោចស្រង់ជីវិតខ្លួនឲ្យផុតពីក្តីទុក្ខវេទនា ។

ក្រោយមកមិនយូរប៉ុន្មាន ស្រាប់តែបុរសបណ្ឌិតឆន់តឆន់ងុលឮសូរ
សំឡេងបែកថា, "ចូរឯងដើរផាកទៅខាងស្តាំដៃឯងទៅ ឯងនឹងទៅ
ដល់ត្រែមួយ ដែលមានប្រឡាយទឹកហូរគុក ។ ចូរឯងក្សន់យកទឹកនោះ
លុបលាងមុខទៅ មុខជាក្អែកឯងពាំងតូកូដូចដើមវិញមិនខាន ហើយឯងនឹង
ឃើញ ដើមត្រែធំមួយដើមនៅទីនោះ ដល់គេលកត្រែត្រូវឯងឡើងទៅភ្លាម
សម្ងំដេកលើដើមត្រែនោះទៅ កុំខាតកន្សែនណាឃើញដាច់ឮឡើយ" ។

បុរសបណ្ឌិតឮពាក្យខ្មេះហើយ ក៏ត្រេកអរទំាងស្មាបពាំដើរទៅទៀត
ហើយប្រកាន់តែស្តាំដៃហូតទៅ ដក ដល់ចូលក្នុងព្រៃទៅត្រូវត្រែធំ
ប្រឡាយទឹក ក៏ឮសូរទឹកហូរគុក ។ ទើបក្សន់ទឹកនោះលុបលាងមុខ
ស្រាប់តែក្អែកក្តីដូចដើមវិញ ហើយងាកមើលទៅឃើញត្រែមួយដើមធំ,
ឃើញស្មៅនៅតលត្រែនោះ រេចរឹលរក់ទីដូចជាមានអ្នកដំណើរដើរមក
ឈប់ជ្រកអង្គុយលេងនៅតលត្រែ លុះដល់យប់ក៏ឡើងទៅដេកតួនសម្ងំ
នៅប្រគាបត្រែខាងលើខ្ពស់ដាច់ដើម ដើម្បីកុំឲ្យអ្នកណាឃើញខ្លួន ។

នៅពេលអធ្រាត្រស្ងាត់ ពួកបិសាចដែលមានបុត្តីភ្នំឆ្ងាយមកប្រជុំគ្នា
ក្រោមដើមត្រែនោះ អួតអាងអំពីបុត្តីរបស់ខ្លួនដែលបានធ្វើឲ្យគេឈឺចាប់។
ពេលនោះ បិសាចម្នាក់និយាយថា ៖

សព្វថ្ងៃ អញអាស្រ័យនៅក្នុងវិទ្យាសាខកូនស្រីស្តេច រាងជា១០ឆ្នាំមក
ហើយ អញចេះតែធ្វើឲ្យខាងឈឺចាប់ឥតស្រាកស្រាន្ត បើខុកជាមានគ្រូ
យាំនិតូតែ ឬមានថ្នាំតុតធាប់ចំណាខមកមើលជម្ងឺខាងយាំនិណា កំឥតជាន
តាអ្វីសោះ នៅតែឈឺដដែល ព្រោះបណ្តាញអញមិនជាន អញ
គ្មានទ្រព្យគ្រប់ថ្នាំពាំនាះសោះ អញខ្វាចតែរូបព្រះអរហន្តីណាត្រីជាម
មួយប៉ុណ្ណោះ បើអ្នកណាទៅយករូបត្រាះអរហន្តីនេះពីតាណិជម្ងាក់ជាន
មកធ្វើតឲ្យខាងសោយហើយ នោះទើបបណ្តេញអញចេញពីវិទ្យាសា
ជាន អញលែងហ៊ានទៅតាទៀត ។

លុះព្រឹកឡើង ពួកចិសាបបែកគ្នាទៅកកន្លែងរៀងខ្លួនហើយ បុរស
បណ្ឌិតចាំតាក្យចិសាបម្ងាក់នោះចាស់ក្នុងចិត្ត ទើបចុះតាដើមវិជ្រហើយ
សែ្វងរកតាណិជអ្នកមានធនធានានោះ ។ (ខ្ញុំមិនដឹងជាបុរសបណ្ឌិត
ដើរកតាណិជនោះប៉ុន្មានថ្ងៃ-ខែ-ឆ្នាំទេ) ប៉ុន្តែ ខ្ញុំដឹងថាក្រោយមក
បុរសបណ្ឌិតរកតាណិជឃើញដូចប្រាថ្នា ហើយក៏ចូលទៅនិយាយសុំ
ស៊ីឈ្នួលធ្វើការនៅផ្ទះតាណិជនោះដោយសំដីថា ៖

"ខ្ញុំសុំនៅធ្វើការជួនលោកតេញមួយឆ្នាំ ហើយខ្ញុំមិនយកថ្លៃឈ្នួល
ជាប្រាក់កាសទេ ខ្ញុំសុំតែរូបព្រះអរហន្តីណាត្រីជាម (notre dame)
ដែលមានក្នុងផ្ទះលោក" ។ តាណិជក៏ព្រមតាមតាក្យសុំនោះ ។

បុរសបណ្ឌិត ខំយកចិត្តទុកដាក់ធ្វើការឲ្យតាណិជពាំងពីថ្ងៃពាំងយប់

គ្មានតិតៀនយូរយឺតដើម្បីឲ្យគេពេញចិត្តស្រឡាញ់ខ្លួន ។ លុះធ្វើការគ្រប់មួយឆ្នាំហើយ ក៏ចូលទៅនិយាយសុំរូបនោះពីនាយពាណិជ ។

នាយពាណិជធ្វើយថា អញពេញចិត្តនឹងការងារដែលឯងធ្វើណាស់ ប៉ុន្តែអញចូលចិត្តឲ្យស្រុតឯងវិញ ព្រោះអញស្គាយរូបនោះពេក កាត់ចិត្តឲ្យឯងមិនដាច់សោះ ។

បុរសបណ្ឌិត ខេលោក ! ខ្ញុំមិនដឹងជាយកប្រាក់ពីលោកទៅធ្វើអ្វីកើតទេ ខ្ញុំចង់បានតែរូបព្រះអរហន្តដែលលោកសុខចិត្តព្រមឲ្យខ្ញុំនោះប៉ុណ្ណោះ ។

ពាណិជ - អើ ! បើដូច្នោះ ត្រូវឯងនៅបំរើអញឲ្យគេញ្ញមួយឆ្នាំទៀតទៅ ទើបអញឲ្យរូបនោះ ។

បុរសបណ្ឌិតសុខចិត្តនៅបំរើពាណិជគេញ្ញមួយឆ្នាំទៀត ដោយយកចិត្តទុកដាក់ធ្វើការដូចឆ្នាំមុន ដល់គ្រប់មួយឆ្នាំចូលទៅសុំយករូបពីនាយពាណិជ ។ ចេះតែធ្វើទើរគេចកែមិនចង់ឲ្យរូប ប្រាប់ថា " អញឲ្យថ្ងៃឈ្នួលឯងជាប្រាក់វិញ បើឯងនៅតែខ្ជូចសុំយករូបនោះមិនឈប់ត្រូវឯងនៅបំរើអញឲ្យគេញ្ញមួយឆ្នាំទៅមុខទៀតចុះ អញនឹងឲ្យរូបនោះតាមឯងសុំមិនខាន " ។

បុរសបណ្ឌិតប្រកាន់សច្ចធម៌ជានិច្ច ខ្ជាប់ចិត្តនាយពាណិជជានិច្ច ក៏ព្រមនៅបំរើនាយពាណិជមួយឆ្នាំទៀត ដោយទំបំរើដូចឆ្នាំមុន ។ ឥតធ្វេស

ប្រហែស រហូតដល់គេញាមួយខ្នាំ ជាតំរង់ចំខ្នាំ ទើចចូលទៅសុំយក
រូបនោះពីនាយពាណិជ ។

នាយពាណិជ ដោះរូបដែលខ្លួនព្យួរនោះដាក់ឱយមកកាន់ហើយ
និយាយនឹងបុរសស៊ីឈ្នួលថា ៖

"នែអ្នកចិត្តស្លូ! យើងឱ្យរូបព្រះអរហន្តដល់អ្នកជាថ្លៃឈ្នួល ចូរ
អ្នកខ្លួនយករូបនេះទៅចុះ ហើយឱ្យបានសម្រេចដូចក្តីប្រាថ្នានៃខ្លួនកុំបី
ខានឡើយ" ។

បុរសចណ្ឌិតឮដូច្នោះ ត្រេកអរណាស់ លើកដៃសំពះខ្លួន
យករូបពីនាយពាណិជ រួចលាពាណិជចេញពីផ្ទះនោះទៅ ដើរសំដៅ
ទៅកន្លែងដែលបិសាចធ្វើព្រះពុទ្ធរូបស្តេចឱ្យប្រឈូននោះ លុះទៅដល់
ហើយ និយាយអង្វរសុំគេចូលទៅកន្លែព្រះពុទ្ធរូបដោយច្រើនដងថា
«ខ្ញុំសុំចូលទៅកន្លែងនេះ ព្រោះមានចំណងនឹងមើលកេតព្រះពុទ្ធគ
ឱ្យស្រះជាជ្រះស្រឡះ" ។

ឮពាក្យដូច្នោះ គំយល់ច្រឡំថាបុរសពួលទៅគ្រាចខ្លួលព្រះមហា-
ក្សត្រតាមដំណើរ ។ ព្រះពុទ្ធរូបទ្រង់អនុញ្ញាតឱ្យអាមាត្យនាំបុរសចូលទៅ
កន្លែងបន្ទប់ព្រះពុទ្ធគ ដល់ហើយ បុរសសុំទឹកពីអាមាត្យមួយពែង
យកមកជ្រលក់រូបព្រះអរហន្តនោះទៅកន្លែពែងចឹងដែន រួចថ្វាយទៅព្រះនាង
ស្រប់ព្រះកន្ត្រា ។

ព្រះនាងទើបតែខ្លួលយកតែនឹកតាដៃបុរសបណ្ដើតក្នុមមិនខាន់តាំងស្រប់ព្រះកត្តាជន ស្រាប់តែបាសាចកំណាចដែលវាអួតអាងខ្លួនជាពូកែណាស់នោះ ស្ទុះចេញពីអង្គព្រះនាងទៅមួយរំពេច ហាក់ដូចជាផ្សែងមួយដុំខ្មៅហុយចេញទៅ ។ ពេលនោះ ព្រះពជធីតាស្រស់ថ្លាសម្បុរ ព្រះកត្តាចំត្រង់ញាញីមតាយ តែកាយសប្បាយព្រះទ័យកេតសះជាស្រឡះ មានកំឡាំងពលំដូចដើមវិញ ។

ឯព្រះមហាក្សត្រនឹងព្រះអគ្គមហេសីខតឃើញដូច្នោះ កំមានព្រះពជហឫទ័យសោមនស្សក្រៃលែង ឥតអ្វីប្រៀបស្មើបាន ទ្រង់ព្រះជន្មាថា " អញបានបរស់អ្វីឲ្យថ្លៃថ្លា តបគុណលោកគ្រូពេទ្យនេះ ល្អើយចុះ អញព្រះពជទានយសសក្តិនឹងទ្រព្យសម្បត្តិឲ្យច្រើនទៅចុះ " ទើបទ្រង់ហៅបុរសមកខ្លួលព្រះពជទាន ។

បុរសបណ្ដើតក្រាបខ្លួលថា សូមទ្រង់ព្រះមេត្តាប្រោស ! ខ្លួលព្រះបង្គំជាខ្ញុំមិនចង់បានរបស់អ្វីបន្តិចសោះ ។

ព្រះពជធីតាទ្រង់ព្រះសណ្ដាប់ពាក្យបុរសដូច្នោះ កំក្រាបខ្លួលព្រះវរៈពជបិតាថា ខ្ញុំម្ចាស់សូមព្រះពជានុញ្ញាតរៀបអាពាហ៍ពិពាហ៍ជាមួយបុរសនេះ ។

ព្រះមហាក្សត្រទ្រង់ឮពាក្យព្រះពជហឫទ័យនឹងពាក្យរបស់ព្រះពជបុត្រីណាស់ ដោយត្រូវតាមព្រះពជចំណង កំទ្រង់ចាត់ឲ្យរៀបពិធីមង្គលការ

ឲ្យរាជធីតានឹងបុរសបណ្ឌិតយ៉ាងខ្លាំង ។ ក្សាំតក្រៃលែង ។

ចាប់ដើមពីថ្ងៃនោះមក បុរសបណ្ឌិតបានទៅកន្លែព្រះបរមរាជវាំងជាមួយព្រះរាជធីតាជាព្រះជាយា ស្ទៀកពាក់សុទ្ធតែសំពត់អាវយ៉ាងល្អៗថ្ងៃៗ ហើយបរិភោគអាហារឆ្ងាញ់ឥសាជាមួយព្រះមហាក្សត្រផងដែរ ។

លុះចំណេរបន្តិចមក បុរសបណ្ឌិតក្រាបទូលសុំលាព្រះរាជានឹងចេញទៅសួរសុខទុក្ខម្ដាយរបស់ខ្លួន ដែលចាស់ជរាទៅឯស្រុកកំណើត ។ ចំណែកព្រះនាងជាយាសុំតាមព្រះស្វាមីទៅផងដែរ ។ បុរសនឹងព្រះនាងទៀងដំរីព្រះរាជវរៈព្រះរ៉ូនាំនៃព្រះមហាក្សត្រ អង្គុយទន្ទឹមគ្នាចេញដំណើរទៅ ដល់កន្លែងមួយ បុរសបណ្ឌិតចាលភ្នែកក្រឡែកទៅឃើញបុរសតាលជាសំឡាញ់ចាស់របស់ខ្លួន កំពុងបាន ទើបស្រែកសួរថា៖

ជំរាបសួរ សំឡាញ់ ! មេចឯងមិនស្គាល់យើងទេឬ? ឯងចាំទេតាលនោះ ឯងប្រកាន់ថា ការចិញ្ចឹមជីវិតដោយអំពើពុករលួយប្រសើរជាងអំពើសុចរិត មិនត្រឹមតែប៉ុណ្ណោះ ថែមទាំងឯងធ្លៀវក្លៃកន្ត្រកអញទាំងគូ ធ្វើឲ្យអញខ្វាក់សូន្យឈឹងទៀតផង ។

បុរសតាលឮដូច្នោះ ក្រឡេកមើលឃើញបុរសបណ្ឌិតជាសំឡាញ់ចាស់ ដែរព្រះរាជវរៈស្ដេចទន្ទឹមព្រះរាជបុត្រី ក៏ចាំមុខបានឥតក្ដៅក្ដាំងទើបកិតព្យាធង អៀនខ្មាសផង ជាក់មុខជ្រប់ លែងហ៊ានងើបមើលបុរសបណ្ឌិតទៀត ។

បុរសបណ្ឌិតប្រាប់ថា ឯងកុំភ្ញាក់អញឡើយ អញឥតបានតំនុំគុំគួនភ្លាក់ខ្លួនសឹងតែភ្លេចឯងរៀងខ្លួនឯង ព្រោះអញប្រកាន់យកតែភាពសប្បុរសុចរិតឃុត្តិដមិម្យាំងប៉ុណ្ណោះ ឯភាពខុសចរិតអញខ្ពើមណាស់ អញមិនហ៊ានជិតឡើយ ។ បុរសបណ្ឌិត ដំណាលរឿងកំរៀបសំខ្លួនសត្វត្រប់តាំងពីភ្លាក់ក្នុងហូតដល់ភ្លឺក្នុង ហើយបានត្រេកអរជាប្រពន្ធឲ្យបុរសតាលស្តាប់ ។

បុរសតាលស្តាប់រឿងនោះចប់ ក៏និយាយថា អញនឹងចូលទៅកន្លែងកន្លែងហូរ, រកដើមក្រៃនោះឲ្យឃើញហើយធ្វើត្រាប់សំឡាញ់អញខ្លះក្រែងជួនជាមានជាតពាសនាដូចគេ តែនៈស្រេច ក៏គេចចូលទៅរកដើមក្រៃនោះឃើញសត្វត្រប់ដូចបំណងមែន ឡើងដេកលើដើមក្រៃ អង្រួចថា អញមុខជាបានសម្រេចបំណងមិនខាន ។

សេចក្តីអំណររបស់បុរសតាលផុយស្រឡះ ដល់យប់ស្ងាត់ឈឹកបិសាចមកជួបជុំគ្នានៅក្រោមដើមក្រៃនោះ ជួនជាអកុសលមកដល់ ស្រាប់តែបិសាចម្នាក់មើលទៅឃើញបុរសនៅលើមែកក្រៃ ទឹកចិត្តស្អប់ខ្ពើមគាញ់ក្រញ៉ាក់ដើងបុរសធ្លាក់ចុះមកដី ហើយសម្លាប់ចោលនៅត្រានោះទៅ ។

(រឿងនេះ សូមអស់លោកពិចារណាមើលចុះ តារស់នៅដោយអំពើសុចរិតនឹងខុសចរិត តើអំពើណាប្រសើរជាងណា ? ដូចមានឧទាហរណ៍ដើមនេះស្រាប់) ។

រឿងស្រីគ្រប់លំក្ខណ៍

ប៉ុក-វិសិរ រៀបរៀង ឈោក តេង-ប្រុះ កំច័ស្ស

ជំពូក ១

អ្នកបង. ! ក្រែងវែស្អក ត្រូវនាំចៅឆនឲ្យទៅទៅរៀនអក្សរឬ ?

អើ .. មែនហើយ អូន! បងចង់ភ្លេចខេតើ ។ ចុះក្រែងអូនឯងនាំចៅស៊ីវ៉ែត្តន៍ទៅដែរឬ ?

ព្រោះតែរឿងហ្នឹងហើយ ទើបជាខ្ញុំត្រៀតមកសួរអ្នកបង ដើម្បីនឹងបានទៅជាមួយគ្នា ។

តើថាខាងសាវ៉ៃលមកសួរខាងមន្ត្រីលី អំពីរឿងនាំកូនៈទៅរៀនអក្សរ ។ ខាងម៉ូយជាម្តាយចៅស៊ីវ៉ែត្តន៍ ខាងបន្ទាប់ជាម្តាយចៅឆនដែលអាស្រ័យនៅក្នុងភូមិទាលគ្នា ក្នុងដែនមគធៈ ខាមជ្ឈិមប្រទេស (ប្រទេសវណ្ណៀសព្ទាថ្ងៃ) ។

ឯស្ត្រីទាំងពីរនាក់នេះសុទ្ធតែមេម៉ាយ ប៉ុន្តែស្ថាប់ចាលតាំងពីកូនទៅតូចៗដូចគ្នា ។ តាមទំនៀមទៅប្រទេសវណ្ណៀ បុរសទើនស្ត្រីត្រូវមានប្រពន្ធតែម្តង មានប្តីតែម្តង ។ បើប្តីស្លាប់ឬប្រពន្ធស្លាប់ អ្នកទាំងពីរគ្រានេះ ត្រូវតែទទួលអំពើអត់ឯងរហូតអស់មួយជីវិតរៀងខ្លួន ។

ដូច្នេះខាងមេម៉ាយទាំងពីរ ទើនគ្រាយមរណភាពនៃប្តីគាត្មា រមែងទំនេទទួលទានដោយសេចក្តីក្លាហាន ដើម្បីចិញ្ចឹមកូន ។ តម្លៃវត្ថុនារ

តាំងពីចំណេះវិជ្ជាយ៉ាងធំល្មមហើយ គឺថាចៅធនញ៉ាងអាយុដប់ខ្នាំ ចៅសិរីវឌ្ឍន៍អាយុប្រាំបួនខ្នាំ ។

ត្រឹកស្អែក គេឃើញទាំងមន្ត្រីល ធំធាងសាវ័ស្ត្រីកងាក់ដណ្តប់សំពត់ព័ទ្ធជុំវិញខ្លួនយ៉ាងស្អាតឆ្អាត នាំគ្នាបណ្តើរកូនមួយម្នាក់ឯកៗទៅឲ្យទៅរៀនអក្សរក្នុងសំណាក់លោកអាចារ្យម្នាក់ ដែលទៅក្នុងភូមិដាច់ឆ្ងាយជាប់ព័ភូមិខ្លួនបន្តិច ។ អំពីការចេញក្រៅក្នុងសម័យនោះ សិស្សណាដែលផ្ទះសំបែងនៅឆ្ងាយ ត្រូវតែសុំបំណាក់អាស្រ័យនៅជាមួយនឹងគ្រូ គឺរៀនជាង បំរើគ្រូអាចារ្យជាង ហើយមួយឆ្នាំដំបូង ក្នុងម្នាក់ ត្រូវចំណាយបួជាគ្រូ ១ កហាបណៈ ក្នុងឆ្នាំទី ២ ទី ៣ ឡើងទៅ រង្វាន់គ្រូកំចេះតែឡើងជាលំដាប់ តាមចិត្តសទ្ធា ប៉ុន្តែមិនមែនជាការបង្ខិំះទេ ។

លុះនាំកូនទៅដល់ផ្ទះអាចារ្យតាលណា នាងមេម៉ាយឡើងទៅមុតដើង ហើយលើកដៃសំពះជំពាបសួរ ជាសេចក្តីគួរសមតាមទំនៀមទម្លាប់ស្រុកថា:

សូមប្រណិបត័ន្ត ព្រះគេជ-គុណ ! សុខសប្បាយជាទេឬ ?

លោកអាចារ្យលើកដៃសំពះតបមកវិញ ហើយលោកថា:

ជាទល្អហើយ ! លើកដៃថ្វាយព្រះ !

រួចលោកសួរបន្តទៅទៀតថា:

ចុះនាងចាំងពីរនាក់ដែលមកនេះ តើមានការអ៊ើអ្វី ? ឬមួយយកកូនមកឲ្យនៅរឿង ?

ហ៎ ! មែនហើយ! ព្រះតេជព្រះគុណ! កូនយើងខ្ញុំសុទ្ធតែកំព្រាអាត្មាស្ងាប់ចោលតាំងពីនៅបឋមវ័ន្ទមុំៗយើងខ្ញុំសូមព្រះតេជព្រះគុណមេត្តាបង្ហាត់បង្រៀនឲ្យផង ហើយសូមឲ្យនៅសំណាក់ជាមួយ ព្រោះផ្ទះនៅឆ្ងាយ ។

-ចា៎ ! មិនខាស់អ្វីទេ នាង ! ប៉ុន្តែរឿងម្ហូបអាហារអត្តភាពខ្ជិលព្រោះខ្ញុំចាស់ហើយ។ ស្រែចំការក៏មិនបានធ្វើឲ្យមាំៗដូចគេដែរ ។

នាងមេម៉ាយចាំងពីរ ក្រោយដែលបានឱយយពីនេះពីនោះ អស់រយៈពេលប្រហែលកន្លះម៉ោង ក៏សូមលាលោកអាចារ្យវិលត្រឡប់ទៅទីលំនៅអាត្មាវិញ ។ មុននឹងចុះផ្ទះចេញ នាងនិយាយបន្តែមចំពោះលោកអាចារ្យ ជារសចក្តីបំណង ឱនរសចក្តីសម្រេចចិត្តរបស់ខ្លួនដ៏ជាក់ច្បាស់ថា :

សូមព្រះតេជ-គុណមេត្តាពង្រឹតឲ្យបានបន្តិច សូមកុំបារម្ភខ្វាចក្រែងយើងខ្ញុំពឹងឲ្យសោះ បើត្រូវការបន្ទុះ កំចេះតែប្រាប់យៅ សូមធ្វើយ៉ាងដូចម្តេចឲ្យតែបានចេះដឹង ចំណែកសាច់ឈាម ជូនពាំងអស់សូមមេត្តាពុកតែសែ្អកនឹងឆ្អឹងឲ្យ ។

លោកអាចារ្យធ្វើយតបពាំងញ៉ាំមៗ ថា:

-នាងកុំព្រួយអី ! ខ្ញុំគ្រាន់តែយើញពីកម្មៗ នឹងអាការប៉ុណ្ណោះ

គំអាចយល់ថាទេ : ក្មេងតាំងពីនេះ មិនបាច់ចាំប្រដៅច្រើនទេ ។

រួចនាងមង្គីលី ទើបនាំសាវ៉ាមកទិញយកផ្តាំ ចំពោះកូនតាំងពីរ ដោយចែកមុនក្រៀមក្រំថា ឲ្យចំយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ឲ្យចេះស្រឡាញ់គ្នា កុំទាស់គ្នា ហើយឲ្យគោរពប្រណិប័តន៍គ្រូបាធ្យាយ កុំបីធ្វេសប្រហែស ។

បាប់តាំងពីពេលនោះមក ចៅធនធីងចៅសិរីវឌ្ឍន៍តុំដែលធ្វើឲ្យតាក្ស ខ្វួនានៃម្តាយរបស់ខ្លួនស្ថិតនៅឥតលំដែលល្អឡើយ ។ អ្នកចំសិក្សាទើបប្រណិប័តន៍លោកអាចារ្យសព្វពេលវេលា មិនដែលធ្វើឲ្យទាស់ចិត្តម្តងសោះ ។

រីស្រួមកាលម្តង ។ អ្នកវិលចៅលេងផ្ទះ ដើម្បីសួរសុខទុក្ខម្តាយ ព្រមទាំងជួយធ្វើការងារផ្សេង ។ មានភ្ញៀវផ្ទះ ដាំបាយ ជីកគោយកទៅឲ្យស៊ីស្មៅជាដើម ។

កិច្ចសិក្សានៃមាណពទាំងពីរ មានសេចក្តីចំរើនជាទិច្ច ។ អ្នកមិនដែលខ្វះសេចក្តីបន្ទោសតិះដៀលអាចារ្យម្តងឡើយ សេចក្តីសរសើរនៃលោកអាចារ្យ ធ្វើឲ្យចៅធន ធីងចៅសិរីវឌ្ឍន៍ធើតតែមានសេចក្តីក្លាហានដំលើសលុបក្នុងការរៀនសូត្រ ។

កន្លងកាលតែពីរឆ្នាំ ចៅធនធីងចៅសិរីវឌ្ឍន៍ចេះអក្សរសាស្ត្រយ៉ាងម៉ត់ចត់ ។ ពីពេលនេះទៅ អ្នកសុំឲ្យលោកអាចារ្យបង្ហាត់

ប ន្ត្រៀខវិជ្ជាដទៃផ្សេង ។ មានក្បួនខ្នាត្តនឹងកូមិសាស្ត្រជាដើម ។ ចៅតាំងតែរតែងបានទទួលសេចក្តីសរសើរ នឹងសេចក្តីកប់អានពីសំណាក់លោកអាចារ្យច្រើនជាងសិស្សដទៃ ។

មួយទៀត ។ គេមើលឃើញហត់លំបាកក្នុងការរកទទួលទានដូចម្តេចក៏នាងមេម៉ាយឥតឮរឡើយ ។ នាងរមែងផ្តល់រង្វាន់សម្រាប់អាចារ្យផងគ្រឿងសំលៀកបំពាក់ នឹងប្រដាប់ប្រដាខាងការរៀនសូត្រសម្រាប់កូនរបស់ខ្លួនផង ព្រោះនាងយល់ច្បាស់ថា ចំណេះវិជ្ជាជាអលង្ការនៃមនុស្ស, ក្នុងជីវិតាគត គេទុកវិជ្ជាជាអាវុធ សម្រាប់តាប់ដាខ្លួនវិគ្រឿនទប់សត្តូតាំង-ឡាយ ។

ចៅធនឧទ្ធ័ចៅសិរីវឌ្ឍន៍ គេលាក្រមួយ ឃានាំគ្នាចូលទៅធ្វើវត្តប្រណាំបាន់ចំពោះលោកអាចារ្យ តាមការតត់ប្រជ្រាប់ ជាកិច្ចវត្តដែលខ្លួនធ្លាប់ប្រព្រឹត្តជាធម្មតាមក ។ ក្រោយពីការដំណាលរឿងអ្វីឆ្ងាយ ។ លោកអាចារ្យសួរសិស្សទាំងពីរថា "ចៅឯងបានរៀនអក្សរសាស្ត្រ ទំនឹងវិជ្ជាដទៃចេះល្មមប្រើការបានហើយ តើឥឡូវ ទៅត្រូវការចង់រៀនវិជ្ជាអ្វីថែមទៀត ចូរប្រាប់យើងមកមើល ?" ។

ចៅធនដោយបានគិតទុកមុន ទើបតូចដំណរទៅលោកអាចារ្យវិញថា: "ខ្ញុំបានចង់រៀនវិជ្ជាមើលដីភូមិ តាន្ត្រាស" ។

ចំណែកចៅសិរីវឌ្ឍន៍ លុះដញ្ជឹងមួយស្របក់ទើបដំណរចំពោះលោក

ភាពាវ្យថា «ខ្ញុំបាទចង់រៀនវិជ្ជាមើលស្រីគ្រប់លក្ខណ៍ ទានប្រោស" ។

ទៅដន ភាលបើបានឮសំឡាញ់ជាបឋលោកគ្រូថា ចង់រៀនវិជ្ជា មើលស្រីគ្រប់លក្ខណ៍ដូច្នោះក៏និយាយយ៉ាងថា: «កឿនឯងកុំរៀនវិជ្ជា នេះ ព្រោះស្រីគ្រប់លក្ខណ៍មិនស្ងួរមានទេក្នុងលោក ហើយបើស្រីគ្រប់ លក្ខណ៍មានចំនួនតិចយ៉ាងនេះ តើធ្វើដូចម្តេច យើងនឹងរកយកជួបប្រទះ? ម្ល៉ោះហើយ ភាសងឹមរបស់យើង ទំនងបញ្ជាក្រុមាឲ្យយើញដំណឹង ប្រាកដដោយភក្រម ហើយជួនភាល ទៅជាអសារបង់ក៏សឹងមាន" ។

បានឮពាក្យជួនយោបល់ដ៏ឆ្លាកេះស្មោះត្រង់ របស់សម្លាញ់ហើយ សិរីវឌ្ឍន៍ឆ្លើយតបទៅវិញថា «កឿនឯងថាហ្នឹងភាញហៅត្រូវហើយ ព្រោះមនុស្សគួរតែនិយមត្រង់កន្ទែងឆ្ងាយ ។ ដើម្បីប្រកបការចិញ្ចឹមជីវិត ប៉ុន្តែ ចូរកឿនរៀនវិជ្ជាមើលដឹកូមិចុះ ចំណែកអញបានជាបាញ់ចិត្ត ទៅខាងណោះហើយ ។ បុរាណាចារ្យពោលថា: «បួសដោយវិត្ត ចិត្តដោយខ្លួន" ។

ចំពោះកិច្ចសន្ទនានេះ លោកអាចារ្យឥតមានវាចាអ្វីសោះ លោក សម្រាន្តធ្វើត្រដើយចាំស្តាប់សិស្សថ្តោះយោបល់គ្នា ហើយលោកតេញចិត្ត ក្រៃពេក ដោយនឹកថាអំណោះទៅមុខសិស្សទាំងពីរនេះ ទំនងបានទៅជា មនុស្សមានមុខមាត់គ្រាន់បើ ដ្បិតវ័យទៅក្មេងសោះ វាចេះនិយាយវែក ញែកតាមខ្សល់ហេតុផលគួរឲ្យស្តាប់បាន ។

ដាអវៈសាន លោកអាចារ្យច្រើបាប់សិស្សថា «ឥឡូវយប់ឃ្លាហើយ ចូរទៅទាំគ្នាទៅគេងកក្នុងចុះ ឯរឿងរៀនវិជ្ជានោះមែនហើយ ពាក្រែចលើចំណាំរៀនខ្លួនទេ ដូច្នេះយើងចាប់រៀនពាក្រែកស្អែកទៅ ។

ដោយមានសេចក្តីគោរពចំពោះគ្រូបាធ្យាយ មាណពទាំងពីរមិនហ៊ានធ្វើឃំកបប្រសាសន៍តបវិញថាដូចម្តេចឡើយ ។ អ្នកក្រោកអង្គុយលុតជង្គង់សំពះលា ហើយថយទៅកន្លែងសម្រាប់ខ្លួនដោយស្ងៀមស្ងាត់ ។

ទៅដល់ទីលំវាល់ខ្លួន ខំសិក្សាវិជ្ជាតាមផ្នែករបស់ខ្លួនទីមែន ប៉ុន្តែមិត្តភាពរវាងទៅទាំងពីរ ឥតមានការប្រែធាឡើយ ។

ថ្ងៃមួយទ្នាំទេះតែប្រព្រឹត្តកន្លងទៅ ហើយតាំនាំយកទាំងអាយុសង្ខារមៃមនុស្សសត្វទៅជាមួយផង ។ រដូវរំហើយវិលទៅដួលនឹងរដូវក្រាំងវិលទៅដួលនឹងរដូវស្បា ហើយវិលវល់យ៉ាងដូច្នេះ ឥតដែលអាក់មួយវេលាដូចជាគ្រាន់ពាឡិកាស្វ័យប្រវត្តិ ។ ចក្រវាឡក៏វិលឥតឈប់ វិលឥតត្រឡប់ វិលឆ្ងិត វិលគ្មានអាណិតមេត្តា វិលទេបត្តា ចំពោះការសំពះអង្វរការខ្វែតខ្វល់ ការយំសោកសង្រែងសង្រៃជ្រោកខ្លួនប្រាណមៃមនុស្សនឹងសត្វ ដែលកំពង់តែញ៉ាមជាប់ក្នុងការក្រេបជញ្ជក់នូវរសនៃសេចក្តីស្នេហាកន្លងវត្តកាមនឹងគំលសតាម ។

ឥឡូវទៅទាំងពីរដល់អាយុម្ភាក់ជប់ប្រាំមួយឆ្នាំ ម្ភាក់ជប់ប្រាំពីរឆ្នាំហើយ ។ ចំណែកលោកអាចារ្យ បើតាមលោចដឹងអានក្បួនឫសស្ត្រាអ្វី

គោនតែភាក់រៃនតា ។ លើមានញាតិដឹតខានយកអ្វីមកជូន លោកដោះ
រៃនតាចេញហើយ យកដៃចាំនក្អែកពីខានលើ ដើម្បីតិទិត្យគានទុក-
ជនោះ ។ ចួនកាលគេសួរលោកថា :

ព្រះគេជព្រះគុណ ព្រះជន្មប៉ុន្មានហើយ ?

លោកមានវ៉ាចាស្រាប់តាំងមុខញាក់ទ្រីកៗថា:

ចំគប្បាយហើយ អ្នក ?

ថ្ងៃមួយ ចៅបែនអាយុដប់ពីរឆ្នាំ ដែលទើបមកនៅរៀនអក្សរ មក
ជំរាបលោកគាអាចារ្យថា:

– ខានប្រាស! អាញ្ចឹរដេកស្លាប់នៅក្បែរបន្ទប់ទឹក ។

លោកគាអាចារ្យមានប្រសាសន៍ថា:

– អើ! វាចាស់ហើយ - - ។

អាញ្ចឹរនេះ ជាឆ្កែ ដែលលោកគាអាចារ្យចិញ្ចឹមកអស់យោះពេល
ប្រាំពីរឆ្នាំហើយ ។

ចៅប៉ុងនឹងចៅស័ន ដែលមកពីសែងទឹកស្រះនៅមុខសាលារៀន
បានចួលមកជំរាបលោគាអាចារ្យថា :

–ជហ្វា សាលារៀនបាត់ភ្លាត់មកអម្បាញ់មិញ នៅពេលយើងនូ
កំពុងសែងទឹកយកមកងាត់ខាង ។

លោកអាចារ្យប្រាប់ថា :

។ អើ៎ សាលារៀននេះ ចាស់ត្រាំគ្រាណាស់ដែរ កសាងមកជាង
សាមសិបឆ្នាំហើយ បើចៅដើរតែឯង ចូរប្រុងប្រយ័ត្នផង ។

រីឯចៅធនធីចៅសិរីវឌ្ឍន៍ លុះបានរៀនវិជ្ជាចប់សព្វគ្រប់តាមបំណង
រៀងខ្លួនហើយ គឺសូមលាលោកគ្រូអាចារ្យវិលត្រឡប់ទៅផ្ទះអង្គាទៃ
យកចាំធីមិត្តភាពដ៏បរិសុទ្ធទៅជាមួយផង ។

លុះចៅធនបានអាយុម្ភៃក្រាំឆ្នាំ ឪពុកម្តាយបានទៅដណ្តឹងនាង
ពាក់ព័ន្ធនឹងម្ចាស់នៃគ្រួសារមួយដ៏សមគួរ យកមកឱ្យធ្វើជាភរិយា ។
ដោយតែនៅឆ្ងាយទៅលើវិជ្ជាមើលដីកូមដែលខ្លួនបានរៀនមក ទាល់ក្រោយ
អាពាហ៍ពិពាហ៍ មិនយូរប៉ុន្មាន ចៅធនចាប់ផ្តើមដើរស្ទង់រកមើលបេដកូមិ
ដើម្បីធ្វើជាទីលំនៅ ហើយនឹងប្រកបការកសិកម្មតទៅ ។ ប៉ុន្តែ ដ
ល្អដ៏ចម្រើនដ៏សុខសប្បាយ ក៏មិនងាយរកបានដោយស្រួលឡើយ គេដើរ
ស្ទង់ពីភូមិ ១ ទៅភូមិ ១ ពីស្រុក ១ ទៅស្រុក ១ ធ្វើឆ្ងាត់ទៃត្រនាង ។
ការដើរស្ទង់រកទីស្ថាននេះ ប្រព្រឹត្តទៅអស់រយៈពេលជាយូរថ្ងៃ ហើយ
ឃាត់ឆ្ងាយពីទីលំនៅដើមរបស់ខ្លួនផង ។

ជាអាសាន ឪពុកប្រុះដើមួយកន្លែង នៅមាត់ស្ទឹងមួយមានសភាព
ត្រឹមត្រូវតាមក្បួនដែលអ្នកបានរៀនមក ។ ឈ្មោះធនវិលត្រឡប់មកផ្ទះ
មានាំញ សូមលាលោក ហើយនាំប្រពន្ធទៅនៅប្រកបការចិញ្ចឹមជីវិត
ត្រង់ដីកូមិដែលខ្លួនបានតំណាត់ទុកហើយនោះ ។

ដោយអំណាចដ៏ល្អ គួរស្ងើចសរសើរនាងនេះ កេសុីចម្រើនជាទិច្ចដូច
គេឡើងកាំជណ្តើរ គឺថាបែរទៅស្រមៃមិនដែលខូចកន្លះដូរណាម្តង បែរមក
ចំការកើនជួនផលៗបីបួនណែនៗ ចេកដំឡូងគ្រាំអំពៅ ។ល។ ឥតចេះខ្វះ ។
ឯការធ្វើឲ្យទៅជាអ្នកមានទ្រព្យនោះ ធំបំផុត នៅត្រង់មានសេចក្តី
សុខ ។ គ្រួសារឈ្មោះធនមិនសូវដែលមានជម្ងឺចួលមកលុកលុយ
ឡើយ ។ បើគ្រួសារណាបានជួបប្រទះនឹងជម្ងឺញឹកញាយរៀងៗយ ទោះបី
ទ្រព្យហូរចូលដូចទឹកភ្នំដោយ គ្រួសារនោះនឹងអាចធ្វើឲ្យទៅជាអ្នកមាន
ទ្រព្យស្តុកស្តម្ភមិនបានឡើយ ។ ឪពុកណាតោលទុកថា « សូវឲ្យពេជ្ឈ
លក់ កុំឲ្យតែខ្មោចលក់ " ។

កន្លះយៈកាលតែបីឆ្នាំប៉ុណ្ណោះ ឈ្មោះធនរកប្រាក់សន្សំខ្លួនបាន
យ៉ាងច្រើន ជាដើមបានបង្ហើយណា ទាំងអាជីវកម្ម ទាំងការដាំស្រែ ហើយ
ក្នុងឈ្នួលស្រែប្រុសក៏មានប្រើឥតខ្វះ ព្រមទាំងមានចិត្តស្មូតត្រង់ចំពោះ
នាយចៅហ្វាយផង ។

នៅដំណាច់ឆ្នាំទីបួន ប្រពន្ធឈ្មោះធនសម្រាលបានកូនស្រីមួយ
មានរូបសម្បត្តិយ៉ាងសមរម្យ ។ គេដាក់នាមថា "សោភណា" ។

ចាប់ពីពេលដែលសោភណាប្រសូតមក ឈ្មោះធនរកទទួលបាន
បានចម្រើនលើសមុនជាកំណើន្តកាត គឺថាដាក់បាន ។ ក្រៃពីតែលោភ
មិនធ្វើ ។ គួរឲ្យអស្ចារ្យណាស់នៅស្រែជិតគ្នា ស្រែគេត្រូវប្តូរផ្តើមអស់

ស្រលោកធនខេះតែបានផល ។ អ្នកស្រុកនិយមហៅលោកធនជា
សេដ្ឋីមួយ ។

ឥឡូវសោកណាបានអាយុច្រាំបីឆ្នាំហើយ ។
កត្រីមួយ ក្រោយដេលបាយ ធនសេដ្ឋីនឹកវិយា អង្គុយជជែកគ្នា
លេងខៅលែងនិយាយអំពីរឿងផ្សេង ។ មានការធ្វើស្រែខឹងជាំដំណាំជាដើម
នាំចំផុត ធនសេដ្ឋីបានលើកយកបញ្ហាធ្វើតាសោកណាមកនិយាយ ។
តាលនោះ ក្រោយការប្រឡែងលេងជាមួយកូនឈ្លេសស្រី ។ សេដ្ឋីធ្វើ
កំសួមលាមាតាបិតាចូលទូលទានដំណេកមុន ។

ដោយកំប៉ាំងពីមុខកូន លោកសេដ្ឋីមានប្រសាសន៍ជាមួយប្រពន្ធថា:
នែអូន ! មើនាងកូនយើងធំគួរសមហើយ បងចង់ឲ្យរៀនអក្សរ
តើអូនឯងយល់យើញដូចម្តេច ?

ប្រពន្ធឆ្លើយភ្លាមថា :

ត្រូវមែនហើយ ប៉ាវ ! ខ្ញុំសព្វថ្ងៃទឹងនឹងខ្លួនឯងពេក ព្រោះមិន
ចេះអក្សរ កាលណាត្រូវការអានសៀវភៅអ្វី ។ មើលមិនបាន បង់ផ្ទៃ
លិខិតទៅណាមកណា សរសេរមិនកើត ចង់គិតគូរអ្វីបន្តិចបន្តួចជួបជាលក់
អាក៏ លក់ខ្លួនឯងជាគេ រង់ចាំពាលតែប៉ាវមក ទើបគិតរកទុសត្រូវ
ឃើញ អើ ! គិតបានខ្លះដែរតាមរៀបក្បាច់ស្រី ប៉ុន្តែវាបានតែការពេលរង
ជួបជាអាសោចបួនដប់ដើម ឬក៏ខ្លួនជាប់ដៃថ្លៃប្តីណ្ហោះ តែហួសពីចំនួនេះ

ទៅ ។បើមានដូចជាលក់អំពៅតាំងចំការ លក់ស្រូវតាំងដង្រែក ។ រកតិត
គួរមិនកើត ព្រោះឯងមិនចេះទាំងពួង ប្រកបការធំបំផុត ទៅត្រង់តាលណា
ឯងថាស់ទៅ ហើយត្រូវការរៀនធម៌អាថ៌ តើចិត្តឯងអ្នកណា ? មិនអីទេ
កុំបារម្ភចិញ្ចឹមជីវិត មានបាំង់ជាជំហរហើយ ចុះទៅម៉ាលោក បាំង់ជួយ
ខ្ញុំផងបានឬទេ ?

ពេលដែលប្រពន្ធកំពុងនិយាយ ធនសេដ្ឋីតបារីស្ទឹកសង្ឃឹ ហើយ
បង្ហុយផ្សែងតុយ ។ មានអាការធុញទ្រាន់ទឹងប្រពន្ធនិយាយដែងតេក បែក
ជាអូរហូរជោស្ទឹង ។ លុះប្រពន្ធនិយាយចប់ លោកសួរតាំងញឹម ។ ថា:

ម៉ែចប់ហើយ ! ចង់កំពុងតែពីរោះ ។

ខ្ញុំនិយាយដែងបន្តិចមែន ប៉ាក់ ប៉ុន្តែតើសំដីខ្ញុំមានត្រូវត្រចៃដែរឬទេ ?

ធនសេដ្ឋីនិយាយបញ្ជោរប្រពន្ធថា :

ប្រពន្ធសេដ្ឋីហើយ គាលណានិយាយខុស ប៉ុន្តែអូនឯងកុំគាល
ទឹករឿងរៀនធម៌អី យើងនៅមានកង្ហាងពេលំ ហើយអាចធ្វើការអ្វីសព្វ
ត្រប់ជាន មិនខាន់ថាស់ធ្វើអ្វីលែងកើតនោះទេ ។

ឮប្តីនិយាយចំអន់ដូច្នោះ ប្រពន្ធលូកដៃក្តិចប្តី ហើយនិយាយ
តាំងសើចថា :

- ប៉ាក់ ! កុំនិយាយផ្តេសផ្តាសចឹង !

– បើដូច្នេះ អូនឯងគេញចិត្តណាស់ក្នុងការរៀនយើងទៅរៀនមែនឬទេ !

– ចុះចាំបញ្ជាក់ឡើងវិញ ។ ប៉ុន្តែ ចាំវ៉ា! ខ្ញុំធ្លាប់ឮគេនិយាយថា: "កូនរៀនអក្សរហើយតាចមានស្មារតីចាំបាន លុះណាតែវាលើកដៃម្ខាងគង់ក្បាលវា រួចស្ទាបស្ទឹកត្រចៀកដល់", មិនដឹងជាលោកណាស្ទាបស្ទឹកត្រចៀកដល់ឬពុំដល់ ខ្ញុំបងឲ្យវាស្ទាបល្បងមើល ប៉ុន្តែតាស់ពេលនេះវាទៅគេងហើយ ។

– ពាក្យចាស់ថានោះ មិនសូវជាខុសប៉ុន្មានទេ ព្រោះលោកមានការពិសោធន៍ បងឥតមានការប្រឆាំងទេ ប៉ុន្តែតាមយោបល់បង ពោះបើមានលូកដៃស្ទាបស្ទឹកត្រចៀកដល់ក្តី ឬមិនដល់ក្តី យើងត្រូវតែឲ្យវាទៅរៀនចុះ ព្រោះអាយុវាគ្រប់ច្រាំបីឆ្នាំហើយ ។ មួយយ៉ាងទៀត ការដឹងក្តីរបស់វាហាក់ដូចជាសត្វគ្រប់គ្រាន់បើដែរ ចំពោះមតិបងនេះ តើអូនយល់ឃើញដូចម្តេច ?

– ខ្ញុំជាដើងក្រាយ ដោយដើងមុខទេ បើចាំវាឲ្យទៅរៀន ហើយវាត្រមទៅ នោះជាការគាប់ប្រសើរណាស់ពោះ យ៉ាងម្តេចម្តា តែមួយថ្ងៃបានអក្សរមួយតួជាមិនខាន ជាជាងនៅផ្ទះរត់តែលេងឥតប្រយោជន៍ ។

ព្រឹកស្អែក គេឃើញធនសេដ្ឋនាំកុមារីជាបុត្រីយកទៅឲ្យសិក្សាក្នុងសំណាក់លោកអាចារ្យម្នាក់ដែលនៅភូមិជាមួយ ។

សោភណាជាកុមារីមានចិត្តស្លូតបូត មានចរិយាសមរម្យ ទឹងមានៈសេចក្តីត្បាយាមល្អ ។ នៅក្នុងថ្នាក់រៀន នាងមិនដែលធ្វើឲ្យលោកអាចារ្យអាក់អន់ស្រពន់ចិត្ត ដោយសារតែអំពើខ្ជាំឆ្គងរបស់នាងឡើយ ។ នាងស្តាប់គ្រូនិយាយរៈឮល់ដោយផ្ទៀងស្តាប់ ទឹងដោយសេចក្តីគោរពយ៉ាងពន់ពេក ។ សិស្សដទៃគ្នា មិនដែលឧឡូលអំពើអសប្បុរសពីនាងៈសោភណាម្តងសោះ ។

មិនតែប៉ុណ្ណោះ នាងមានចិត្តជួរឧឡាយថែមទៀត ។ នៅពីក្នុងពេលចេញលេង នាងតែងតែចែករំលែកនំចំណីឲ្យដល់សិស្សពាលក្បាយៗឧឡូលតាមដងនាងជាញឹកញាប់ តើថានាងមិនអាចតាំងចិត្តជាមនុស្សថ្មុចបានឡើយ ទោះគុណសដែលនាងឧឡូលតាមអ្វី ក្នុងចំណោមមិត្តភក្តិដែលនៅលេងជាមួយគ្នា ។ ចើរើញសិស្សតូចៗ ឈ្មោះគ្នា នាងចេះហៅហ៊ាយចេះនិយាយលួងលោមផ្សះផ្សា សង្រួបសង្រួមឲ្យបានភ្លាត់ទឹង ត្រមាំងបានជាគ្នាឡើងវិញ។

ដូច្នេះ សិស្សដទៃតែងស្រឡាញ់កាន់សោភណាក្រៃពេក ទាំងគោរព ហើយពុកនាងជាគំរូតែងចិត្តសប្បុរសទឹងតែងចរិយាចរិយ ។ ឈ្មោះសោភណា ស្ថិតនៅរស់រើកក្នុងគ្រួសារនៃសិស្សពាលក្បាយ ដែលសិក្សាក្នុងថ្នាក់រៀនជាមួយ ។

សោភណាគោរពមាតាបិតាណាស់ ។ ពេលរៀបចេញទៅសាលារៀនក្តី ពេលត្រឡប់មកដល់គេហដ្ឋានវិញក្តី នាងតែងសំពះលាទឹងសំពះជំរាបសួរចំពោះអាពុកម្តាយ ឥតដែលមានអាក់ខានមួយដងឡើយ ។

ចំណែកមេរៀនទំនឹកវណ៌យកច្ចដែលគ្រូប្រគល់ឲ្យធ្វើ នាងទំបំពេញ
យ៉ាងម៉ត់ចត់ដោយឥតខ្ចុកឲ្យនៅសេសសល់ឡើយ ។ ម្ចាស់ហ៊ាយនាង
ជាន់តែងតែប្រើនាងជានិច្ច ជាន់ខ្លួលការសរសើរ ទំនឹកការពន់អានពីសំណាក់
លោកអាចារ្យផង ។

ដូច្នេះ ការសិក្សានៃធីតាសោភណា ក្នុងរយៈពេលតែពីរឆ្នាំជាន់ចប់
ខាងអក្សរសាស្ត្រ ។ នាងបន្តកិច្ចសិក្សាចំនួនពីរឆ្នាំទៀត ដើម្បីឲ្យវិជ្ជា
ផ្សេងដទៃមានន្ទន្តសាស្ត្រជាដើម ។

នៅពេលដែលធនសេដ្ឋីទៅដឹកបលោកអាចារ្យ ខ្លួនដំណើរបញ្ចប់
កិច្ចសិក្សានៃធីតាសោភណា ព្រោះការចេះត្រឹមប៉ុណ្ណេះល្មមសមគួរដល់
ឥត្ថីគេទេហ៊ាយ លោកគ្រូជាន់តាមលដឹកបលោកសេដ្ឋីថា: "កូនស្រីលោក
នៅអនាគត ទំនឹងជាន់ស្ត្រីមេផ្ទះដ៏យ៉ាងចំណាន" ។ សំដីនេះធ្វើឲ្យ
សេដ្ឋីជាអាពុកពេញចិត្តយ៉ាងខ្លាំងចំពោះវាសនាបស់ខ្លួន ព្រមទាំងរឹតតែ
តែស្នេហាកូនស្រីខ្លាំងឡើងទៀត ។

កាលវេលារមែងប្រព្រឹត្តទៅជាធម្មតា ឥតដែលឈប់មួយរំពេច ។
ការប្រកបអាជីវកម្មទំនឹងសេចក្តីសុខចម្រើនទៅគេហដ្ឋាននៃធនសេដ្ឋី ឥត
មានការប្លែកឡើយ ។

ល្ងាចមួយ ធនសេដ្ឋីអង្គុយដំណាលលេងពីនេះពីនោះជាមួយមនុស្ស
របស់លោក ដើម្បីសំដែងសមភាពនឹងសាមគ្គីធម៌ឲ្យកើតមានរវាងវាំ-

ហ្វាយនាយនឹងកូនឈ្លួល ។ ជាទីបំផុត លោកគោលនឹកឆ្នុកដល់ឈ្មោះសិរីវឌ្ឍន៍ជាសំឡាញ់របស់លោកថា មិនដឹងជាស្លាប់ឬរស់ ព្រោះតាំងពីពេលឈប់រៀនហើយបែកគ្នានៅផ្ទះរៀងខ្លួន មកដល់ឥឡូវនេះលោកមិនដែលបានទទួលដំណឹងអ្វីមួយអំពីមិត្រលោកម្ដងសោះ ។

ខណៈនោះ សោភណាកំពុងនៅអង្គុយជជែកប៉ះសំលៀកបំពាក់នៃកូនឈ្លួលក្បែរជើងភ្នំឆ្ងាយជិតបន្តើនប្រទីបមួយ ។ លុះបានឮឪពុកនិយាយថាមានសំឡាញ់ម្នាក់ តែមិនដឹងឥឡូវនេះនៅណា មានប្ដីឬក្រលំជុក ស្លាប់ឬរស់យ៉ាងណា នាងនិយាយដាក់ឪពុកថា : បើគាត់ជាមិត្រល្អមែនទាំ ដូចម្ដេចក៏ប៉ាមិនធ្វើសំបុត្រផ្ញើទៅសួរដំណឹងអំពីគាត់ផងនឹ ? អាណិតគាត់ណាប៉ា !

ឆន្ទសេដ្ឋីឆ្លើយតបកាំងមានទឹកមុខស្រួតថា : ម៉ែកូចអើយ ! ប៉ាមិនដឹងផ្ញើទៅកន្លែងណាទេ បើវាបាត់ដំណឹងសូន្យឈឹងដូចគេដឹកកប៉ាយ៉ាងនេះ ។ កាលពីប៉ុន្មានឆ្នាំមុន ប៉ាឮគេថាលោកមីងសារីខទួលអនិច្ចកម្មហើយ ក្រោយពេលដែលសិរីវឌ្ឍន៍លាចាកចេញពីផ្ទះ ដើម្បីដើរស្វែងរកស្រីត្រប់លក្ខណ៍ ។ ហើយប៉ាក៏ចេញចាកស្រុកកំណើតមកនៅទីនេះជាយូរមកហើយឆ្នាំណាស់ផងនឹ ។

លុះឮឪពុកនិយាយថា «ស្រីត្រប់លក្ខណ៍" សោភណានឹកឆ្ងល់មិនដឹងជា"ស្រីត្រប់លក្ខណ៍"នោះមានសភាពបែបណា ឬមួយជាស្រីខេត-

អប្បរ ឬមួយជាស្រីប្រកបដោយរូបសម្បត្តិនិងចរិយាសម្បត្តិ ។ ហើយ
សួរសព្វនៃពាក្យនេះទៀត កំព័រកេះសមរម្យគួរតែចង់ចាំបានយកមកដាក់ឲ្យគ
ក្នុងដួងហឫទ័យ ។ នាងនឹកមន្ទិលដូចជាចង់សួរចំពោះលោកអាពុកនូវ "ស្រី
ត្រង់លក្ខណ៍" នោះ ដូចម្តេច ? នឹកមន្ទិល ខ្លាចក្រែងជាការណ៍មិនគួរសម
ក្នុងរឿងសួរនេះ ព្រោះខ្លួនជាស្រី ហើយក៏ស៊ប់ត្រាំនៅស្ងៀម ប៉ុន្តែ
នាងនឹកមិនភ្លេចនូវពាក្យ «ស្រីត្រង់លក្ខណ៍» សោះ ។

ដល់ព្រឹកស្អែក នាងលបសួរម្តាយនាង ក្នុងទីស្ងាត់ថា:

មែ! ពីយប់មិញ ប៉ាមានប្រសាសន៍ថា «ស្រីត្រង់លក្ខណ៍» តើ
«ស្រីត្រង់លក្ខណ៍» ដូចម្តេច ?

រូបមែ៎ក្តី រូបខ្ញុំក្តី ជាស្ត្រីដែរ តើជាស្ត្រីអ្វីទៅវិញ ?

ម្តាយៈសើចញញឹមៗ ហើយឆ្លើយប្រាប់នាងស្មានថា:

– ម្តាយក៏ដូចកូនឯងដែរ មិនដឹងដែរ ជា «ស្រីត្រង់លក្ខណ៍» ដូចម្តេចទេ
ប៉ុន្តែ ម្តាយបានឮគេចាស់ៗដំណាលថា: "ស្រីត្រង់លក្ខណ៍" នោះ គឺស្រីប្រ
សើរណាស់ រកស្រីណានឹងប្រៀបផ្ទឹមពុំបានទេ គ្មានស្ត្រីណានឹងច្នៃតាម
បានទេ គឺជាស្ត្រីអស្ចារ្យ កូន ! ម្តាយឮគេចាស់ៗតែងដេរស្តីឲ្យកូនស្រី
ដែលមានការប្រញាប់ហើយនៅតែដេរ។ មិនត្រមត់ឲ្យមានខ្ចិលឡើយ: "ហ៊ន
ឯងមិនមែនស្រីត្រង់លក្ខណ៍ទេ រត់ឲ្យលឿនមក" បើតាមពាក្យនេះ
មែ៎ងឈល់ថា: "ស្រីត្រង់លក្ខណ៍" ប្រហែលមិនចេះរត់ទេ ។ ម្យ៉ាងទៀត

ឮដូច្នេះហើយ ក៏ឆ្លើយតបទៅកូនឯងវិញថា: "ប្រពន្ធដើមរបស់មាយើងជាស្រីកេរ្តិ៍ឈ្មោះ ប្រពន្ធនាយសំពៅដែលដូរទៅឲ្យមាយើងជាស្រីគ្រប់លក្ខណ៍ គ្រោះក្រាយមក នាយសំពៅទៅជាអ្នកក្រហើយមាយើងទៅជាអ្នកមានយសសក្តិធំ", ហើយលោកយាយគេលបញ្ជាក់ថា: "នាយសំពៅទៅជាក្រគ្រោះយកស្រីកណ្តាច់លក្ខណ៍ជាប្រពន្ធ មាយើងទៅជាអ្នកមានយសសក្តិ គ្រោះបានប្រពន្ធស្រីគ្រប់លក្ខណ៍" ។

ដោយចង់ដឹងលក្ខណសម្បត្តិនៃប្រពន្ធមាយើង ទើបប្រពន្ធនាយសំពៅ ទើបសោកណាដណ្តើងសួរម្តាយទៀតថា:

ខ្ញុំចង់ដឹងណាស់ ម៉ែ ! សូមម៉ែដំណាលរឿងមាយើងត្រង់ប្តូរប្រពន្ធគ្នាឲ្យខ្ញុំស្តាប់បន្តិចមើល !

-ម៉ែដូចជាចង់ក្តេចអស់ហើយ នៅចាំដែរ តែដោយស្រួចស្រួលព្រោះយាយកូនឯងបានដំណាលឲ្យស្តាប់តាំងពីម៉ែនៅជំទង់ម្ល៉េះ ចាំម៉ែនឹកបន្តិចសិន ។

រួចម្តាយសោកណាយកដៃស្ទាបថ្ងាសនឹកដញ្ជឹងមួយស្របក់ ទើបដាក់ដៃចុះហើយនិយាយថា:

"មាយើងជាអ្នកទីគាល់ក្រ តែមានប្រពន្ធល្អ ។ ថ្ងៃមួយប្តីនឹងប្រពន្ធទាំងគ្នាទៅដញ្ជាត់ត្រីនៅមាត់ទន្លេ ។

(មានត)

រឿងសាមកុក

កណ្ឌទី ៣៧

ឧកញ៉ាវិបុលរាជសេនា ង្ហួ-ភិន ប្រែរៀបរៀង

(តទៅ)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> ទំងបេះខុបាយកលបំណាន
> ទាំងមានសន្ធានស្នេហាជាតិ ។

អន្តរភាយមុខជាទំនងមានដល់ខ្លួនលោកម៉ងទាន ។ ឡៅតឹសួរថា ឆ្លូវដែលនៅខាងមុខឈ្មោះដំបន់អ្វី? ។ ពហានតាំងពួនឆ្លើយថា ពៅខាងមុខនោះទំនចូលដែនស្រុកកុងយុំង មានភ្នំធំឧឈ្មោះភ្នំកេងសាន់ ។ ឡៅតឹដឹងដូច្នោះ ក៏នាំទ្រព័ទ្ធស្រុតកូដើរពៅដល់ភ្នំកេងសាន់ ហើយឲ្យទ្រព័ទ្ធតាំងជំរំឈប់នៅប្រុបដើងភ្នំ ។ គ្រានោះជាវដូវរដូវណាស់ អាណាប្រជាទុកស្ត្រីតាំងពួនោះ ពៅជាឈឺឆ្អាត់ត្រូវរងាមានសេចក្តីលំបាកវេទនាជាច្រើន ខ្លះស្រែកខ្ញាយំរងំសាទក្នុងព្រៃ ប្រឡំតាំងសំឡេងស្រីទំនប្រុសចាស់ទំនក្មេង គួរឲ្យកើតសេចក្តីសង្វែគពេកណាស់ ។

លុះពលប្រហែលយាម ៣ ឃប់ ខ្មៅតាកំព្ចសំឡេងស្រែកហៅ
កញ្ជ្រៀមកតាមទិសឯដើង ដូចជារលើងរលំឈើព្រៃ. ខ្មៅតាភ័យតក់
ស្លុតចិត្ត ទើបឡើងសេះនាំគហាន ៤ នាក់លើកចេញទៅ ខ្លួនប្រុះ
ទឹងកងតាមក្រោយមក, ខ្មៅតាកំបរសេះនាំគហានចូលតបាំងជា
ពន្លឹក គហានចូលធ្លុកំភ្លោមតាំងខ្មៅតាបាន ។ លុះខ្មៅហ៊ុយត្រឡប់ឃើញ
ខ្មៅតាទៅកន្លែងចំណោមរវាងចូងជួរនោះ កំសុះតុះតារំលាយតាចូលទៅជួយ
ខ្មៅតា បានខំនងស្រួល តំបូលប្រយុទ្ធជ្រែកចេញទៅតាមខ្មៅហ៊ុយ
ទិសឯកើតប្រុះគ្នាទឹងប៊ុនផងលើកគហានមកចាំស្កាត់តាមុខ ។ ខ្មៅតា
កំបរសេះសំរុកចេញទៅមុខ ។ គហានស្រែកដេរប៊ុនផងថា អាចោរ
ពុយសុលក់ឈ្មោះម្ចាស់ នៅចេញមុខឥតភ្លាសមកបូលទឹងបូធ្លាសត្រូវ
ផែនដីទៀត ។ ប៊ុនផងឮដូច្នោះ មានសេចក្តីអៀនខ្មាសមិនបង្ហិនឲ្យខ្មៅតា
ឃើញមុខបាន តំលើកគហានបែរត់ទៅ ។

គហានចូធ្លុបានចំណាប់ តំលើកដេញខ្មៅតាប្រជាប់ចូលមក ។
ខ្មៅតាទឹងខ្មៅហ៊ុយ ២ នាក់បងប្អូនកំដួយគ្នាតាំលាយមកក្រោយ តំង
ចំតាពុកចាស់តែក្តីស្រាន ។ លុះគហានចូធ្លុគ្រាតចេញទៅឆ្ងាយហើយ តំ
ឈប់សំពកគហានទៅទីនេះ ។ លុះឃើញគហានផែលសល់ រត់តាមមក
ផងប្រហែលជា១០០នាក់ត្រប់ត្រួតាំងហ្វូងហ្វាយរបស់ខ្លួន ទឹងអាណាប្រជា-
ពុកស្រួតាំងតួងឆ្ងាត់ឆ្ងាយគ្រាត់គ្នាទៅ, ខ្មៅតាកំយំសោកសៅថា មនុស្ស

តាំងអស់នេះមកថ្ងៃស្អែកឯងស្លាប់គ្រោះតែយើងម្ចាក់ តាំងបុត្រតាយោរបស់
យើងក៏មិនដឹងជានៅទីឯណា ជាស្លាប់ឬរស់មិនបានឃើញនឹងកែកសោះ
ឡើយ, កាលឡៅពាឈប់អង្គុយឃាំនៅទីនេះខ្លួលយើញប៊ីហាន ត្រូវ
អារុធរបួសជាច្រើនអន្លើ ប្រឡាក់ឡើងជាយឈាមតេញអស់តាំងខ្លួន វត់
ចូលមកស្រែកប្រាប់ថា អឡូវដូឡុនប្រែចិត្តចូលទៅខាងព័តចូនហើយ,
ឡៅតាំងដូច្នោះ កំស្រែកតំហកឲ្យប៊ីហានថា ឯងនេះជាមនុស្សវត់តពីគ្រោះ
តិចារណាអ្វីសោះ ឯដូឡុនោះ ជាមនុស្សមានសុចរិតស្រឡាញ់យើង
ពិតត្រង់ណាស់ ដែលថាប្រែចិត្តចូលទៅខាងចូនោះ កុំសង្ស័យឡើយ ។
ខ្មៅហ៊ុយទ្វើយថា តាំដើមគេឃើញយើងជាតំខាក់បាន អឡូវ
យើងបងប្អូនដូនជាបទៅហើយ ប្រសិលគេប្រែចិត្តចេញទៅមែនទេដឹង ។
ឡៅតាថាឯចិត្តដូឡុនោះខ្មៅត្រង់តិតក្រាកជណាស់ ប្អូនចូរគិតមើលចុះ
កាលគួនអ៊ូទៅទីនឹងចូនូ ចេញមកសម្លាប់ងាប់ខ្លាំនលៀង ប៊ុនធីស្លាប់, ប្អូន
ក៏សង្ស័យថា គួនអ៊ូប្រែចិត្តចេញទៅនៅនឹងចូនូ តិតសម្លាប់គ្នាគ្រោះ
ដល់គ្រានេះទៀត ពោះបី ដូឡុងទៅនៅខាងចូនូមែនក្តី ពោះបីតាចង
តំដោយសារមានហេតុទើបទៅ ឯដូឡុងបងស្គាល់ឯនថា មិនមែន
ចោលបងជាក្រាកដ ។ ខ្មៅហ៊ុយមិនដឿនតទឹងណាស់ តំលើកតាហាន
សេះ ២០ ស្រួតវិលត្រឡប់ចូលទៅដួចនឹងដូឡុង លុះទៅដល់ដើម
ស្ពានខ្មៅងាំនំគៀវ ក្រឡេកឃើញខ្មៅត្រ១ នៅខាងទិសឯកើត តំនាំ

ឥហានចូលទៅ ហើយកាត់យកមែកឈើមកចងគ្របកន្ទុយសេះ ហើយ
បង្ខាំបង់ឥហានឲ្យបរសេះរំលងកំពុះឡើង ក្នុងពេលដែលកងទ័ពចូរួលរីក
មកដិត ដើម្បីរត់ចូលហុយដ៏ក្រៃលែមឡើង កងទ័ពចូរមិនដឹងគំនិតល់
ថាបង្ខិបពលនៅក្នុងព្រៃដាច្រើន, ខ្មៅហ៊ុមបង្ខាំបង់ឥហានដូច្នោះហើយ
គឺបរសេះទៅឈរគាន់ខ្លួនស្ងាត់នៅដើមស្ពាន ។

ឯជួឡឹងចូលចាំងជាច្រើបល់ នៅក្នុងជ្រោះកណ្តាលកងទ័ពចូរ
នោះវាយត្រឡប់ចេញមកហើយ គឺចូលពុះការទៅវិញខ្មៅ ស្ទុះស្ទងក
ខ្មៅតីនឹងគ្របគ្រួចាំងពួងមិនឃើញសោះ គឺវាយត្រឡប់ចេញមកវិញ រំលង
ដរាំនៅក្នុងទ័ពចូរ តាំងតីយាម ១ ហួតដល់ក្តីស្រាង ជួឡឹងគិតថានឹង
ស្ទុះស្ទងកេខ្មៅតីគឺមិនប្រទះសោះ ចាំងគ្របគ្រួកំបាត់អស់ទៅ ឧទ្ធជា
ប្រការម្តេចគឺមិនដឹងក្រោយមុខ ខ្មៅតីគឺបានផ្ទុកពុះនេះ ឲ្យយើងនៅក្បុ
បុត្រកវិយោ ឥឡូវមកឲ្យនៅសបាត់នៅក្នុងជ្រោះកណ្តាលចំណោមមេទ័ព
ជូច្នោះ ឃើញជាមិនគួរសោះឡើយ, ជួឡឹងគិតហើយគឺនឹកតូចចិត្តណាស់
ត្រឡប់គាំងមានចិត្តគិតឡើងថា ត្រូវតែនឹញ្ញាក់យើងលាយកងទ័ព ចូលទៅ
រកម្តងទៀតឲ្យឃើញគ្រប់គ្រួចាំងនោះ ពេះបើស្ងាច់ទៅក្នុងកណ្តាលណោ-
សគ្រាមកំភ្លាមការចុះ បើមិនឃើញគ្រប់គ្រួខ្មៅតីនោះទេ គឺមិនជឿនឹងបើ
យកម្ចុះទៅចុកឯណា, ជួឡឹងគិតដូច្នោះហើយ គឺមើរសេះពុះតាវិលាយ
ចូលទៅក្នុងជ្រោះកណ្តាលទ័ពចូរ ជាមួយនឹងឥហានិងប្រមៀលស្ទុ

៣១ ឃើញពួកអ្នកស្រុកត្រូវអាវុធបបួលតតាំងជាច្រើន ក្នុងចិត្តសម្លឹងមួយរំពឹងអីឯកឯ, ជូឡុងក៏ញាក់សេះរំលងទៅរកត្រង់ត្រួយក្តាប់ ប្រទះនឹងកាន់ឃ្លុំធំ ត្រូវអាវុធបបួលជាខម្លួន ដេកតួនទៅក្នុងតុម្ពស្មៅ, ជូឡុងក៏សួរទៅថា អ្នកបានប្រទះឃើញតាងកាំហ៊ូយិនតាងប៊ីហ៊ូយិនតាំង ២ នាក់ដែរឬទេ? កាន់ឃ្លុំឆ្លើយថា ឥឡូវអ្នកតាំងពីរឃើញកងទ័ពចូលមកជិតនឹងតាន់តំលោតចុះពីលើរទេះ ពកួនរត់បន្ទំចូលទៅក្នុងពួកអ្នកស្រុក ខ្ញុំក៏ជំរាយសេះតាមទៅរកដងជើងភ្នំ តាហានចូលមកាត់ត្រូវខ្ញុំបានថ្នាក់ពីលើសេះ ហើយដណ្តើមយកសេះទៅបាន ខ្ញុំក៏ឈឺលំបាកដើរទៅមិនរួចតំលួនមកពួនទៅទីនេះ ។ ជូឡុងឮតាហានម្នាក់ចុះពីលើសេះឮតាយកកាន់ឃ្លុំនឹងឮដឹងដំរេះ ហើយច្រាប់ថា អ្នកស្រុកត្រូតទៅមុនចុះ បើបានជួបប្រទះនឹងឮពីដាទៅហ្វាយយើងឲ្យដំរាបថា ឥឡូវនៅងកាំហ៊ូយិនខ្លាត់ភ្លាត់ទៅបាត់រកមិនតាន់ឃើញទេ យើងទៅស្រុះស្រួងរកឲ្យឃើញទើបទៅដាក្រោយ បើសិនណាយើងរកនាងកាំហ៊ូយិនមិនឃើញទេ គេះថានឹងស្លាប់ ក៏យើងមិនស្តាយជីវិតឡើយ, ជូឡុងភ្លាំហើយ តំបាយសេះរំលងទៅក្រោយវិញ ។

ខណៈពួលគេលនោះឮសំឡេងតាហានម្នាក់ស្រែកសួរថា ជូឡុងបរសេះទៅឯណា? ជូឡុងឮច្បាស់តិចៗសេះឈប់ ហើយងាកចូលទៅសួរថា អ្នកឯងឈ្មោះអ្វី? ។ តាហានឆ្លើយច្រាប់ថា ខ្ញុំបាទជាអ្នកបំរើរទេះឲ្យ

ខាងកាំហ៊ូយិនដ៏ វត្ថុខាងនោះត្រូវត្រួញបួសទៅមិនខ្លះ ។ ជូឡុងសួរ
ថា ខាងនៅឯណាឥឡូវនេះ ? ។ ភាហានឆ្លើយថា ខាងតេជ្ញាបាលចូលទៅក្នុងគ្រួសារអ្នកស្រុកនៅទិសខាងឦសាន ។ ជូឡុងឮហើយ ក៏តេជ្ញាភាហានទាំងអស់ ទំបារសេះស្រួតទៅតែម្នាក់ឯង ប្រទះនឹងពួកអ្នកស្រុកដែលតេះទៅភូនៅកន្លែង ។ ក៏សួរថា ឃើញខាងកាំហ៊ូយិនទៅណាក្នុងតំបន់នេះដែរឬ ? ។

ខាងកាំហ៊ូយិនឆ្លើយថា ខ្ញុំនៅឯណេះ ខាងកំពុងស្រាលក្នុងចិត្ត ព្រោះដឹងតែឃើញជូឡុងទៅដល់ ហើយថា អ្នកចូរជួយយកអាយុដ៏វែងខ្ញុំ ថាហើយ ក៏យំសោកតិចាប ។ ជូឡុងលោតចុះពីលើសេះខ្លាឃ្មុតចូលទៅគំនាប់ហើយថា ដែលខ្ញុំបាទមិនបានទៅកំណត់អ្នក។ ក៏ដោយសេចក្តីសំបាកដូច្នេះ ទោសខ្ញុំបាទខុសធ្ងន់ណាស់ ឥឡូវខាងកាំហ៊ូយិនមានកូនប្រុសនោះនៅឯណា ? ។ ខាងកាំហ៊ូយិនប្រាប់ថា កាលខ្លះបុះពីលើរេះ រត់ចូលទៅប្រាំនឹងគ្រួសារអ្នកស្រុកដែលមកជាមួយគ្នា លុះភាហានបួងួចដេញតាមយកចូលមកពីក្រោយ ពាំងអស់គ្នាកំបែកខ្ចាត់ខ្ចាយអស់ទៅមិនដឹងជាទៅនៅខាងណាទេ ។

កាលកំពុងតែនិយាយគ្នា ខ្លះឃើញកងទ័ពបួងួលើកមក ១ កងដេញគ្រប់គ្រួសារចូលមក , ជូឡុងឮសំឡេងគ្រហាយអីនឹងគ្នា ក៏តាយស្មុគស្មាតលោតឡើងសេះខ្លាឃ្មុត ក្រឡេកទៅឃើញអ៊ុតគាលើក

ភាហាន ១ កន្ត ប្រហែលខ្ចាន់ថ្ងាយ ចាប់បានប៊ីតុកចនៃដីកមកទាន
ក្រោយសេះ, ដួឡុងក៏បំផាយសេះចូលទៅស្រែកតំហកដោយសំឡេង
យ៉ាងខ្លាំង ទើបចូលច្បាំងតនឹងអ៊ុតា ។ បរសេះចូលតស៊ូនឹងដួឡុងមិនភ
ាន់ប៉ុន្មានក្លេង ដួឡុងក៏យកខ្លួនចាក់ត្រអ៊ីតោងក់តាលើសេះស្ទាប់
ហើយកាស្រាយចំណងប៊ីតុកចេញ ដណ្តើមសេះបានពីភាហាន ២ ហើយ
ឡប៊ីតុក ១ នានកាំហ៊ូយិន ១ ទៀងដំរសេរចេញទៅដល់ពុងស្ពាន ។
ទៀវហ៊ុយត្រឡប់ឃើញដួឡុង កំស្រែកថា ហេតុម្តេចបានជា
ដួឡុងប្រែចិត្តទៅចូលខាងចូនខ្លះ ។ ដួឡុងវិស្រែកតបថា អ្នកកុំស្តីដួច្នោះ
ដែលខ្ញុំបាត់ឃ្លាំងម៉ែះ ព្រោះខ្លាត់ខ្លាំងបាត់នានកាំហ៊ូយិន នានប៊ីហ៊ូ
យិនពាំង ២ មិនដឹងទៅឯណា ខ្ញុំទំនូរស្វែងតាមរកបានជាយើតឃ្លាមក
ជារក្រោយ ដែលថាខ្ញុំនឹងប្រែចិត្តចេញទៅស្រឡាញ់ចូនធ្លាតាមិនមែនទេ ។
ទៀវហ៊ុយស្តាប់ហើយថា នេះហាក់តែតានយ៉ាងមកក្រាប់ការធ្វើនស្រាល
ដល់ខ្ញុំជាមុន បើកុំតែដួច្នោះ ខ្លួនអ្នកនឹងខ្ញុំក៏តានប្រឡុំសុគ្គាទៅ ។ ឯដួ-
ឡុងសួរថា តឡប់ទៅហ្វាយយើងនៅឯណា ? ។ ទៀវហ៊ុយតើយថា បង
យើងនៅឯក្រោយផ្លូវមិនឆ្ងាយប៉ុន្មានទេ ។ ដួឡុងមិយាយនឹងប៊ីតុកថា អ្នក
ចូរនាំនានកាំហ៊ូយិនទៅឲ្យដល់ហ្វាយយើងមុនចុះ ខ្ញុំនឹងត្រឡប់ទៅ
ស្វែងរកនានប៊ីហ៊ូយិន នឹងអាតៅឲ្យឃើញសិនសឹមទៅជារក្រោយ ។ ដួ-
ឡុងនិយាយហើយបរសេះត្រឡប់ទៅជួបនឹងទៀហ៊ុអ៊ុនកំពុងលើកភាហាន

ប្រហែល ៩០ នាក់ បានសេះកាន់ខ្លួនសៀតគ្រប់ឈរស្មើគ្នាជុំវិញតំបន់ សេះចូលតម្រង់ខ្លួនដែលហ្វូងគោក្របីខ្លួនចាក់ត្រូវហែហ្វូងគោក្របីឆ្ពាក់ពីលើសេះស្ទាប់ ។ ពាហនពាក់អស់តំបែកភ្នាត់ភ្នាយគ្រប់ទៅ ។ ហែហ្វូងគោនេះជាមនុស្សបំពុកពុកចិត្តបន្តិចបន្តួច មានកំឡាំងច្រើន ។ ចួនស្រុកឆ្ងាយឲ្យកាន់ក្របីឈ្មោះតិថនកៀម បើនឹងកាប់ដែកគឺដូចកាប់បណ្តែលចេក ។

ជូរឫទ្ធិឃានក្របីហើយហូតចេញមកមើល ឃើញអក្សរចារតែជាប់នឹងផ្ទៃ គំនឹងថាត្រូវឯកឧបសម្ព័ន្ធ, ជូរឫទ្ធិគិតសៀតស្ពាយហើយបំផាលសេះពុះតារំហាយទូលទៅកេទាធិបតីហ្វូងដ៏ទ្រង់ទ្រាតម្ចាស់ឯង។ មិនបានគោតញ្ញាញើតនឹងសេចក្តីស្ងាប់សោះ ប្រទះត្រូវក្រុមអ្នកស្រុកពាំនៅ២ដងទន់ គំសួរកេទាធិបតីហ្វូងថាដូចម្តេច ។ មានមនុស្សម្នាក់ចង្អុលប្រាប់ថា ទាធិបតីហ្វូងត្រូវខ្លួនត្រង់ភ្លៅដើរមិនរួច ពក្លួតអង្គុយតាមខ្លួនទៅត្រង់ជញ្ជាំងផ្ទះត្រង់ណោះ, ជូរឫទ្ធិដឹងច្បាស់ផ្ទះបោះ គំបរសេះស្រួតទៅដល់ផ្ទះ ១ ភ្លើងឆេះទៅតែដញ្ជាំង គំចូលទៅតន់តេមើលឃើញទាធិបតីហ្វូងពតាត់ទៅតង្គុយយំនៅក្បែរមាត់អណ្តូង ជូរឫទ្ធិលោតចុះពីលើសេះតន់ចូលទៅតំនាប់ហើយតំយំ ។

ទាធិបតីហ្វូងនេះឃើញជូរឫទ្ធិទៅដល់ មានអំណរក្តីចិត្តណាស់ថាអ្នកមកជួបនឹងខ្ញុំគ្រានេះ គំដូចអ្នកមកយកជីវិតកូនទៅពុកឲ្យរស់ សូមឲ្យអ្នកមានសេចក្តីករុណានាំយកគាត់ទៅចុះ ដើម្បីឲ្យបិតាបានឃើញមុខ ឯខ្លួនខ្ញុំមុខជាស្លាប់ហើយ តាមតែវាសនាកម្មរបស់ខ្ញុំស្រាប់ ។ ជូរឫទ្ធិ

តបថា ដែលអ្នកបានដល់ខ្ញុំវាសេចក្តីខុសលំបាកពាំនាំម៉្លេះ តែព្រោះខ្លួនខ្ញុំបាទគ្រូនិរក្សាអ្នកមិនឈ្នះ ទោសពាំនាំអស់តែខ្ញុំតាក់សែខ្លួនខ្ញុំបាទជាមុន តែឥឡូវខ្ញុំបាទបានខំស្វះស្វែងមកតាមអ្នកឃើញហើយ សូមអញ្ជើញអ្នកឡើងជិះសេះចុះ ខ្ញុំបាទនឹងដើរដើងរក៉ាំងការតាមមុខពាំអ្នកចេញ ។ នាងប៊ីហ៊ូយ៉ិនឆ្លើយថា អ្នកកុំព្រួយជាខុសទឹងខ្ញុំឡើយ ជាតែខ្លួនខ្ញុំឈឺជួនណាស់ហើយមុខជាមិនរស់ទេ ខ្ញុំនេះប៉ិនឹងរស់រួចជីវិតក៏ពីព្រោះតែអ្នក ដែលអ្នកនឹងចុះពីលើសេះដើរដើងនៅ ប៉ាដូចជាជីវិតកូនខ្ញុំគ្មាននៅសោះឡើយ អ្នកចូលខំស្រូតយកតែកូនខ្ញុំទៅមុនចុះ កុំបីរវែលកំណាន់ចិត្តគិតដល់ខ្ញុំឡើយ ។ ជូឡុងឆ្លើយតបថា អ្នកកុំដែតដោះស្រាយឲ្យខ្ញុំបានធំចាំយូរឡើយ អាញ្ជើញឡើងសេះឲ្យឆាប់ចុះ សំឡេងភាហានចូរឮហ៊ោកញ្ជ្រៀវខ្ចាន់ៗតាំងពីខ្លួចូលមកគាន់តែជិតណាស់ហើយ ។ នាងប៊ីហ៊ូយ៉ិនថា បើអ្នកអាណិតហើយ ក៏ចូរស្រូតរួតយកកូនខ្ញុំរត់ទៅឲ្យរួចចុះ ខ្លួនខ្ញុំនេះនឹងនៅផងមិនបានទេ នឹងមកអំពាលរំលៃអ្នកនឹងខ្ញុំនេះ នឹងនាំគ្នាស្លាប់តាំងអស់នៅឯ ហើយតំយកកូននោះហុចទៅឲ្យជូឡុង។ មិនព្រមទទួល នៅតែទូចអញ្ជើញនាងប៊ីហ៊ូយ៉ិនឲ្យឡើងជិះសេះជាប់ ២.៣ គ្រា នាងប៊ីហ៊ូយ៉ិនក៏មិនព្រមឡើងជិះសេះសោះ ចេះតែអង្វរកះជាឃ្យូរណាស់ ។ សំឡេងភាហានចូរតូវតែហ៊ោកញ្ជ្រៀវខ្ចាន់ៗជិតចូលមក ។ ជូឡុងក៏និយាយថា អ្នកនៅតែអង់ធ្វើឲ្យឃ្យូរម្ល៉េះ បើកងទ័ពចូរសំលាប់ចូលមកហើយ

ឪឆ័ម៉ែនទាំគ្នាស្លាប់បង់ការទេទៅឬ ? ។ នាងប៊ីហ៊ីយ៉ែនឮដូច្នោះ ក៏យក
អាតៅជាបុត្រនោះ ចោះចាលទៅលើដែនដី ចំពោះមុខជូឡុងហើយក៏
លោតចុះទៅកន្លែងអណ្តូងទឹកស្លាប់ ១ រំពេច ។

ជូឡុងឃើញដូច្នោះ យំសោកជាក់ខ្លួនប្រាណ ដោយមានចិត្ត
អាណិតនាងប៊ីហ៊ីយ៉ែនណាស់ ហើយក៏កាយដៃក្បែរមាត់អណ្តូងនោះ
អស់ទៅប្រាថ្នាឪឆ័ម៉ែនឲ្យមានបុណ្យសាកសព ហើយយកសំពត់
រុំខ្លួនអាតៅធ្វើជាបៃបអន្ទឹងចងភ្ជាប់តតីនាងមុខ ដោះខ្សែក្រោះបញ្ចូល
ទៅក្នុងដើមទ្រូង យកអាតៅលាកភ្ជាក់ក្រោះនោះទៅវិញ ឡើងសេះបរ
ចេញមក ខណៈដូចជាឪឆ័ម៉ែនជាតាហានឆ្លងទន្លេ លើកពលតាហាន
ដេរតួងស្ងាត់តាមមុខជូឡុង។ កំបរសេះចូលចាំងឪឆ័ម៉ែនជាន់ចាន់ក្តេង ។
ហាន់បេងចាញ់ដៃជូឡុង ។ ចាក់ត្រូវឪឆ័ម៉ែនលំពែងធ្លាក់ពីលើសេះស្លាប់ ក៏
កាប់ចំណាយចេញទៅមុខជូបឪឆ័ម៉ែនកន្លែងខ្ញាខៀវទាប់ស្លាក់តាមមុខខៀត កំបរ
សេះចូលប្រយុទ្ធគ្នាឪឆ័ម៉ែនខៀវទាប់បាន ១៩ ក្តេង ជូឡុងកំពុងសេះវេះ
វត់ចេញ ។ ខៀវទាប់ យីញបានចំណាប់កំបរសេះដេញតាមទៅ ។ ជូ-
ឡុងបរសេះវត់ទៅដោយលឿនហាស់ណាស់ ប្រទះឪឆ័ម៉ែនថ្កុកចង្កុក ១ អន្ទេ
សេះវត់ដៀសមិនទាន់ កំប្លាក់ចុះទៅក្នុងចង្កុកនោះ ទាំងសេះទាំងមនុស្សក៏
ជួលប្រមូលលើគ្នា ។ ខៀវទាប់ក៏ដេញតាមទៅទាន់ លោកទៅប្រឆឺចាក់
ឪឆ័ម៉ែនលំពែង ។ ខណៈនោះជាបុណ្យជាវាសនាអាតៅ ដែលឪឆ័ម៉ែនបានធ្វើ

ជាក្សត្រសោយរាជសម្បត្តិមិនគួរនឹងស្លាប់ដោយគ្រឿងសស្ត្រាវុធ ក៏ឲ្យ
បណ្តាលជាតន្ទឺកភ្លើង ឆេះចេញអណ្តាតម្ស៉ឹង ត្រង់កន្លែងជួបឡុងញាក់នោះ
ខៀវខាប់ភ័យភ្ញាក់ដូចគេតន្ត្រាក់សេះនោះខុចថយមកក្រោយ ។ ជួបឡុងក៏
តន្ត្រីដឹងឲ្យសេះស្ទុះឡើងរួចក៏លោតចេញបានពីកងចង្កឹកវាល្ហាវត់ទៅបាន។
ខៀវខាប់ឃើញឡាស់ដូច្នោះ ក៏មិនអាចនឹងដេញតាម ។ ឯទាំងឡៀន,
នឹង ខៀវតឺ ២ នាក់ លើកគាហានវត់តាមពីក្រោយពីមុខហើយស្រែកថា
ជួបឡុងត្រានេះនឹងវត់ពីដៃយើងមិនរួចទេ ។ ឯចៀវហៀ នឹងចៀវឡាំ ២
នាក់ក៏លើកគាហានចេញទៅស្ទាក់ពីមុខ ។ ជួបឡុងបរសេះចូលប្រយុទ្ធគ្នា
នឹងពួកគាហានទាំង ៤ ក្រមនេះជាតន្ទឺក ។ ពួកកូនគាហានទាំងអម្បាល
ណោះ ក៏ចាមរកមព័ទ្ធជួបឡុងជាជ្រួលច្របល់ ។ ជួបឡុងក៏ហួតក្រប៊ីដេញ
កាប់ចាក់ស្ទាប់គាហានទាំងនោះប្រែនណាស់ ។

ចូតូឡើងទៅលើភ្នំកងស្មាន ត្រេះឡកម៉ាលមកក្រោយឃើញជួ-
បឡុងចូលប្រយុទ្ធតនឹកនន់ពាជ្រួលច្របល់ដោយគាហានទាំងពួង ឃើញ
ថ្លៃដៃដល់កាប់ត្តមិនមានកញ្ជើតទៅខាងណា ទើបស្រែកថា គាហាន
ល្អែតខ្លាកុះឈ្មោះអ្វីក៏មានថ្លៃដៃខ្លាំងតូចែកម្ល៉ះ ? ។ គាហានឮសួរ ក៏
បះសេះចុះទៅពីលើភ្នំ ចូលទៅស្ទាក់ពីមុខជួបឡុង ហើយស្រែកសួរថា
អ្នកឯងឈ្មោះអ្វី ? ។ ជួបឡុងក៏ស្រែកតបមកវិញថា យើងឈ្មោះខៀវ
ជួបឡុង ។ គាហានក៏ត្រឡប់សេះឡើងទៅជំពាមចូតូ ។ ក៏សរសើរថា

ភាហានេះមានអំណាចបំផ្លាញ ហើយកំចង្អាច់ឲ្យស្រែកប្រកាសថា កុំឲ្យនរណាយកឆ្កែបាញ់ជួរឡឹងឡើយ ត្រូវជួយគ្នាព័ទ្ធចាប់យកឲ្យនៅតាំងរស់ឲ្យបាន ។ ឯជួរឡឹង កំបរសេះចំពោះបាក់គាប់សម្រាប់តួតភាហានចេញតែក្នុងចំណោមបានដោយហេតុថា ចូរឲ្យភាមក្រាមភាហានតាំងពួនមិនឲ្យបាញ់ឥឡឹង តែថាបុណ្យបារមីបេះគាត៌ ដែលនឹងបានសោយជាព្រះមហាក្សត្រៃយ៍ទៅឯមុខ ទើបបណ្តាលឲ្យជួរឡឹងសម្រាប់មេកងឆ្កែកងទ័ពចូលបាន ២ នាក់, ភាហានឯក ៩០ នាក់ ឈាមកំហូរប្រឡាក់ពេញអស់តាំងក្រោះនឹងខ្លួនសេះ បំផ្លាញគេស្រោចទឹកលាក់ ។

ជួរឡឹងបរសេះនាំគាត៌ស្រែតទៅដល់ជើងភ្នំ ១ ។ ខ្លើ ប្រទះនឹងចុងដំនូ, ចុងស៊ុនបងប្អូនតាំង ២ នាក់ ដែលជាភាហានធំហៅហ្ជុន ញាក់សេះចេញមកស្វាគមន៍ ។, ជួរឡឹងកំបរសេះចូលប្រយុទ្ធគ្នានឹងចុងដំនូ, ចុងស៊ុនបាន ៣ ក្បួនចាត់ត្រៀបចុងដំនូឆ្ងាត់ពីលើសេះស្ទាច់, រួចជួរឡឹងកំបរសេះស្រែតតៅទៅ ។ ចុងស៊ុនកំបរសេះចេញតាមខ្នាត់ពីក្រោយ ជាប់គ្នានឹងសេះជួរឡឹង ភ្លាតនឹងចាក់ដោយលំពែង សេះក៏ស្ទុះដៃងឹហួសមួយថ្នាក់ រៀបនឹងចាក់កំផុតទៅពាក់ទៅបានទើមគ្នា ។ ជួរឡឹងភ្លាកសេះត្រឡប់មកតនឹងចុងស៊ុន ខ្លួលសេះចុងស៊ុនដេញខ្នាត់ជិតទៅភ្លាកខ្លួនមិនបាន ដើមទ្រូងចុងស៊ុននឹងដើមទ្រូងជួរឡឹងក៏ទៅប៉ះខ្ទង្គិចគ្នា ជួរឡឹងយកលំពែងវាត់លំពែង

(នៅមានត)

ផ្នែកកំណាត់ដ៏ជំនាញប្រវត្តិការណ៍

អំពីសេចក្តីថ្លែងការណ៍សារពត៌មាន របស់ព្រះតេជព្រះគុណ ព្រះពោធិវង្ស ហួត - តាត អគ្គាធិការនៃពុទ្ធិកសិក្សា

ចាប់តាំងពីថ្ងៃទី ១៩ មិថុនា រហូតដល់ថ្ងៃទី ១៧ កក្កដា ១៩៧៩ ព្រះតេជ ព្រះគុណ ព្រះពោធិវង្ស ហួត - តាត អគ្គាធិការនៃពុទ្ធិកសិក្សា ព្រមទាំងសហការី គឺលោក យឹម - វ៉ែន ទីប្រឹក្សាបច្ចេកទេស ១, ព្រះវិន័យសំវរៈ ថាច់ - កឹង អគ្គាធិការរងកូមិភាគទាំងដើម ១, ព្រះគ្រូមុនី-សោភ័ណ សេរ-ខាង អគ្គាធិការរងកូមិភាគទាំងត្បូង ១, លោក រស់-ហួ លេខាធិការ ១, ជាទនិម្ត អញ្ជើញទៅទស្សនាចរត្រួតត្រាសាលាពុទ្ធិក-បឋមសិក្សាគ្រប់ខែត្រក្នុងព្រះរាជអាណាចក្រ ដើម្បីតាមឲ្យដឹងពីសោភ-ភាពនៃការប្រតិបត្តិការងារ និងការលំបាកនានារបស់លោកគ្រូអ្នកគ្រូ ដែលកំពុងបំពេញការងារនៅតាមមូលដ្ឋាន ដើម្បីជួយដោះស្រាយនូវបញ្ហាទាំងនោះ ឲ្យបានទាន់ពេលវេលា។

ដំណើរទស្សនាចរនេះ ជាទូទៅមានលទ្ធផលល្អប្រសើរ ដែលអាចសង្កេតឃើញតាមរយៈការប្រជុំជាមួយមន្ត្រីនៃខែត្រនីមួយៗ ដែលមានចំនួនសរុបទាំងអស់ ៩ លើក ដូចតទៅ :

លើកទី ១ - នៅខែត្រតាកែវ - កំពត - កំពង់ស្ពឺ,

លេីកទី២ - នៅខែត្រត្រៃវែង - ស្វាយរៀង ,

លេីកទី៣ - នៅខែត្រកំពង់ធំ - សៀមរាប - ជាត់ដំបង - តេាជា-
សាត់ - កំពង់ឆ្នាំង ,

លេីកទី៤ - នៅខែត្រកំពង់ចាម - ក្រចេះ - ស្ទឹងត្រែង ,

លេីកទី៥ - នៅខែត្រកណ្តាល ។

នៅខែត្រតាកែវ មានការប្រជុំ ២ កន្លែង គឺនៅវត្តអំពិលជប ស្រុក
សំរោងទី១, នៅវត្តស័ាយតេនាកម ក្រុងតាកែវ ១ ។

នៅខែត្រកំពត មានប្រជុំពីរកន្លែង គឺនៅវត្តស្រែកាន់ ស្រុកបន្ទាយ
មាស១, នៅវត្តកំពត ក្រុងកំពត ១ ។

នៅខែត្រកំពង់ស្ពឺ មានកន្លែងប្រជុំ១ គឺនៅវត្តម្រុំ ក្រុងកំពង់ស្ពឺ ។

នៅខែត្រត្រៃវែង មានកន្លែងប្រជុំ ២ គឺនៅសាលារៀនក្រុងត្រៃ-
វែង ១ និងវត្តសិរីសោភ័ស ស្រុកកំពង់ត្របែក ១ ។

-នៅខែត្រស្វាយរៀង មានទីប្រជុំ១ គឺនៅវត្តជម្ពូព្រឹក្ស ។

-នៅខែត្រកំពង់ធំ មានទីប្រជុំ១ គឺនៅវត្តកំពង់ធំ ក្រុងកំពង់ធំ ។

-នៅខែត្រសៀមរាប មានទីប្រជុំ ១ គឺនៅវត្តដំណាក់ ក្រុង
សៀមរាប ។

-នៅខែត្រជាត់ដំបង មានទីប្រជុំ២ គឺនៅវត្តប៉ូស្សីក្រោក ស្រុក
មង្គលបុរី១, នៅវត្តភ្នេាធិ៍ល ក្រុងជាត់ដំបង ១ ។

-នៅខែត្រពោធិសាត់ មានកន្លែងប្រជុំ១ គឺនៅវត្តបន្ទាយដី ក្រុងពោធិសាត់ ។

-នៅខែត្រកំពង់ឆ្នាំង មានទីប្រជុំ១ គឺនៅវត្តខេតធតាកម ក្រុងកំពង់ឆ្នាំង ។

-នៅខែត្រកំពង់ចាម មានទីប្រជុំ៣ គឺនៅវត្តសុគន្ធាភម ស្រុកដើនរៃ១, នៅវត្តចំនុក ក្រុងកំពង់ចាម១, នៅវត្តរំហារខ្ទឹម ស្រុកស្វាយឃ្មុំ ១ ។

-នៅខែត្រក្រចេះ មានទីប្រជុំ ១ គឺនៅវត្តសិរីសម្ភវាស្ត្រ ក្រុងក្រចេះ ។

-នៅខែត្រស្ទឹងត្រែង មានទីប្រជុំ ១ គឺនៅវត្តកតុញ្ញាភម ក្រុងស្ទឹងត្រែង ។

-នៅខែត្រកណ្តាលមានទីប្រជុំ ៩ កន្លែងគឺ:

១-នៅវត្តជាតមន្ទីល ស្រុកតញ្ជាញ ២-នៅវត្តស្វែង ស្រុកកំពៅញ ៣-នៅវត្តខេតវិសាល ស្រុកស្អាង ៤-នៅវត្តសំបាំង ស្រុកកោះធំ ៥-នៅវត្តស្វាកែត ស្រុកកៀនស្វាយ ៦ នៅវត្តថ្មគរ ស្រុកល្វាឯម ៧-នៅវត្តចតុម្មុខភម ស្រុកមុខកំពូល ៨ នៅវត្តកន្ធីយ៉ាភម ស្រុកខ្សាច់កណ្តាល ។

នៅត្រង់ទីប្រជុំ ព្រះតេជព្រះគុណ ព្រះពោធិវង្ស មានព្រះពុទ្ធដីកាប្រស្រ័យទាក់ទង សំដែងសេចក្តីគ្រែកអរចំពោះ ព្រះសង្ឃទាំងអស់

ដែលនិមន្តមកពីខេត្តឯទៀត ព្រមទាំងប្រជាស្រុកយកកង់ចក់ ចំពោះមន្ត្រីទៃគ្រស្រុក ឃុំ មានលោកចៅហ្វាយទៃត្រ-លោកចៅហ្វាយស្រុក- ទីឯលោកមេឃុំជាដើម ដែលបានមកជួយទប្តូរក្នុងកិច្ចសន្យានេះ ។ រួចខើបត្រះគេជព្រះគុណព្រះពោធិវង្ស ថ្លែងពន្យល់អំពីកិច្ចសិក្សាខាងព្រះពុទ្ធសាសនាយ៉ាងពិស្តារ ដូចមានៈសេចក្តីជាគោលតៈទាំងនេះ ៖

១- ពន្យល់អំពីព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ដែលមានព្រះគុណជាអម្ចាស់ជីវិតលើតួនឹងភាពីព្រះអង្គ ទីឯសម្តេចព្រះទុបយុវរាជជាព្រះបិតាឯករាជ្យជាតិ ទ្រង់ជាអគ្គសាសនូបត្ថម្ភក ទ្រង់ចាត់ជួយរំលុកបំរុងព្រះពុទ្ធសាសនាគ្រប់បែបគ្រប់យ៉ាង ទ្រង់ព្រះបរមរាជានុញ្ញាតឲ្យរៀបចំជាសាលាពុទ្ធិកបឋមសិក្សា . ពុទ្ធិកមជ្ឈមសិក្សា.ពុទ្ធិកឧត្តមសិក្សា ឲ្យមានរបៀបរៀបរយដូចជាការសិក្សាខាងគាណាចក្រ ឬការសិក្សាក្នុងសាកលលោក ដើម្បីញ៉ាំងព្រះពុទ្ធសាសនាឲ្យមានវឌ្ឍនភាពជិតភ្លឺស្វាងរុងរឿង ដូចមានព្រះពាសនូវកថា សម្តេចព្រះទុបយុវរាជ ទ្រង់ចាត់ថ្វែងក្នុងទុតាសបើកការសិក្សាពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ- ទីឯសម្ពោធគ្រឹះស្ថានព្រះសីហនុ ពីថ្ងៃទី ១០ ខែមិថុនា ១៩៥៩ ។

២- ពន្យល់ពីកិច្ចបឋិក្សាខាងព្រះពុទ្ធសាសនា សុំឲ្យព្រះសង្ឃយកចិត្តទុកដាក់ទំនុកបំរុងពេញ ព្រោះជាមូលដ្ឋានសម្រាប់បណ្តុះបណ្តាលព្រះសង្ឃឲ្យមានការចេះដឹង បើព្រះសង្ឃចេះដឹងហើយ ទើបអាចញ៉ាំងព្រះពុទ្ធ

សាសនាឲ្យមានវឌ្ឍនភាពភ្លឺស្វាងជាន ។

៣- ពន្យល់អំពីព្រះសង្ឃជាបុគ្គលគួរគោរពបូជាអំពីគ្រហស្ថ ក្នុងសម័យបច្ចុប្បន្ននេះ គ្រហស្ថមានវិជ្ជាច្រើន ព្រះសង្ឃគោរមានវិជ្ជាច្រើនជាងគ្រហស្ថទើបសមរម្យ បើព្រះសង្ឃឆ្ងីតល្ងង់ មុខជាគ្មានអ្នកណាគោរពទេ ព្រះសង្ឃដែលល្ងង់ ឥឡូវអាប់ឧន្ធោលជាងខ្លួនឯងផង ខ្ចីឆ្ងល់ទៅព្រះសង្ឃឯទៀតផង មិនតែប៉ុណ្ណោះ ធ្វើឲ្យព្រះពុទ្ធសាសនាដែលជាប់តែភ្លឺស្វាងឲ្យអាប់ឧន្ធោផង ។

៤- ពន្យល់អំពីព្រឹត្តិការណ៍របៀបសិក្សាសម័យបុរាណនឹងបច្ចុប្បន្ន ដើម្បីឲ្យព្រះសង្ឃទំនៀង ព្រោះសម័យនេះហើយ ដែលព្រះសង្ឃត្រូវធ្វើដំណើរទៅកាន់ការភ្លឺស្វាងឲ្យទាន់ពេលវេលា ។

៥- ពន្យល់ថា ក្នុងសកលលោកនេះ ប្រទេសណាមិនទាន់មានព្រះពុទ្ធសាសនា ក៏ត្រូវប្រជាជនឲ្យឆ្ងីន ប្រទេសណាទាន់មានហើយគេខំប្រឹងធ្វើឲ្យរុងរឿងតទៅទៀត ។ ប្រទេសកម្ពុជាមានព្រះពុទ្ធសាសនាចំនួនជា ២០០០ ឆ្នាំហើយ គួរព្រះសង្ឃនឹងគ្រហស្ថជ្រោមជ្រែងព្រះពុទ្ធសាសនាឲ្យរុងរឿង ដើម្បីផ្សាយខ្លួនទៅក្នុងប្រទេសនិងសកលលោក ព្រោះព្រះពុទ្ធសាសនាមានតួនាទីសន្តិភាព ។

ជន្លាប់មក ព្រះគ្រូមុនីសាត័ណ សេខ-ម៉ាន អគ្គាធិការនៃ

ឱ្យនថ្ងៃឯពន្យល់អាចារ្យបង្រៀន តាមកម្មវិធីថ្មី តាមរបៀបវិធីគរុកោសល្យ ។

គឺនោះមកទៀត លោក យឹម-រ៉ែន ទីប្រឹក្សាបច្ចេកទេស ជាន ពន្យល់លោកគ្រូមេគណៈ អនុគណៈ - ចៅអធិការវត្ត ដែលមានសាលាតុំទ្វីកបឋមសិក្សា នឹងលោកអាចារ្យបង្រៀនឱ្យជ្រាបពីមុខតំណែងបច្ចេកទេសដែលជាភារៈរបស់លោក គឺកិច្ចការជាអធិការប្រចាំខែត្រ-អធិការប្រចាំស្រុក អំពីការជួយទប្បន្ថែសាលាតុំទ្វីកបឋមសិក្សា - អំពីត្រួតសាលា -អំពីរៀបចំសាលា -អំពីការសុំបើកសាលាថ្មី - អំពីការសុំអាចារ្យបង្រៀន អំពីអាចារ្យណាឈប់លែងបង្រៀន ។

ទីបំផុត ជានចែកសៀវភៅសម្រាប់ចង្រៀន - សៀវភៅសរសេរ - នឹងលិខិតផ្សេងៗ សម្រាប់សាលាតុំទ្វីកបឋមសិក្សា ។

នៅត្រង់ខ័ណ្ឌទ្វីបប្រជុំ មានដំណើរការប្រព្រឹត្តទៅដោយស្រួលគាំងអស់ ព្រោះមានលោកចៅភ្នាងខែត្រ - លោកចៅហ្វាយស្រុក - លោកមេឃុំ នឹងសហការី អញ្ជើញមកជួយទប្បន្ថែស្មើត្រង់ខ័ណ្ឌទ្វីប ។

ក្រសួងធម្មការ សូមឆ្លៀតឱកាសដ៏ប្រពៃនេះ សូមនាយថ្វាយបង្គំចំពោះលោកគ្រូជាមេគណៈ - លោកគ្រូអនុគណៈ - លោកចៅអធិការ ព្រមទាំងព្រះសង្ឃក្នុងព្រះពុទ្ធសាសនាចក្រ សំដែងនូវគារៈ

វិភាគដ៏ខ្ពង់ខ្ពស់ សូមព្រះអង្គជួយទប្ចត្ថម្ភសាលាដែលសង់នៅទីវត្ត ដើម្បីញុំាងសាលាពុទ្ធិកបឋមសិក្សាតាំងនេះ ឲ្យមានវឌ្ឍនភាពបរិបូណ៌ទៅអនាគត ។ បើតុទ្ធិកបឋមសិក្សាចំរើនហើយ ព្រះពុទ្ធសាសនាក៏នឹងចំរើនតាមលំដាប់ ហើយប្រទេសកម្ពុជាក៏នឹងឡើងទៅកាន់សន្តិភាពនិងវឌ្ឍនភាពសម្បូណ៌ដោយអ្នកប្រាជ្ញបណ្ឌិតខាងព្រះពុទ្ធសាសនា ដែលជាមគ្គុទ្ទេសក៍ដ៏ប្រសើរ សម្រាប់ជីកតាំងជាតិខ្មែរទៅតាមមាគ៌ានៃយោបាយសន្តិភាពដ៏ទត្តិទត្តមនៃសម្តេចព្រះនរោត្តម សីហនុ ជាព្រះបិតាឯកភាពជាតិ ទៅកាន់គ្រែយនាយ តាមហាសុភមង្គលគ្រប់យ៉ាងសមតាមព្រះពុទ្ធបំណងតាមលំដាប់ ។

មួយទៀត ក្រសួងធម្មការ សូមថ្លែងអំណរគុណជ័ង្រាលគ្រប់ជំពោះឯកទត្តមព្រះពុទ្ធប្រតិភូប្រចាំខែត្រ សហជីវិនទៅហ្វាយខែត្រ ទៅហ្វាយស្រុក ត្រមាំងសហការរបស់លោកដែលបានជួយទប្ចត្ថម្ភកិច្ចការទស្សនាចរគ្រប់គ្រងគុណព្រះពោធិវង្សនេះ ឲ្យមានដំណើរការប្រព្រឹត្តទៅបានដោយល្អប្រពៃ ទី៥ សូមតំណែងយ៉ាងមុតមាំ លើឯកទត្តមព្រះពុទ្ធប្រតិភូប្រចាំខែត្រ ទី៧ សហជីវិនទៅហ្វាយខែត្រ សមឲ្យជួយទប្ចត្ថម្ភវត្តអារាមទីឯសាសនសិក្សា ដើម្បីឲ្យបានរួចរាល់រឿងពាក់ព័ន្ធបរិបូណ៌ទីដើម្បីឲ្យបានទៅដល់ប្រយោជន៍ដល់ព្រះពុទ្ធសាសនាណាមួយក្រុមគ្រួសារ ។

អំពីការតាំងបៀអធិការ

ចានតាំងតំកូ ឡេ-ជិនលន់ ជាបៀអធិការ វត្តកណ្តាលកោះសុទិន ឃុំកោះសុទិន ស្រុកកោះសុទិន ខែត្រកំពង់ចាម ។

អំពីការតាំងគ្រូសួត្រ

ចានតាំងតំកូ កែន-យឹម ជាគ្រូសួត្រស្តាំ វត្តពិតិក្ខាពម ឃុំស្វាយចៅ ស្រុកសង្កែ ខែត្រចាត់ដំបង ។

ចានតាំងតំកូ ប៊ុត-ឆ៊ីយ ជាគ្រូសួត្រឆ្វេង វត្តពិតិក្ខាពម ឃុំស្វាយចៅ ស្រុកសង្កែ ខែត្រចាត់ដំបង ។

ចានតាំងតំកូ ជុំ-តុល ជាគ្រូសួត្រស្តាំ វត្តកណ្តាលកោះសុទិន ឃុំកោះសុទិន ស្រុកកោះសុទិន ខែត្រកំពង់ចាម ។

ចានតាំងតំកូ អឹម-ខេង ជាគ្រូសួត្រឆ្វេង វត្តកណ្តាលកោះសុទិន ឃុំកោះសុទិន ស្រុកកោះសុទិន ខែត្រកំពង់ចាម ។

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អង្គាជ្យ នបុ. ការយោធ្រួចរង្គាត់ ។

អង្គី–ភ្ជ ច្រ. ទួលទៅដិត ។

អង្គុ ចុ. បន្ទាយ, បន្ទាយឃ្មាំ ។ អង្គាល, អង្គាលក ចុ. បន្ទាយ ។ -ចារិក ចុ អធិការទីព្រៃ ។

អង្គុ សំឃុង្គ ចុ. ការយាប៉ះទង្គិចដ៏ខ្លាំង, សួរទង្គិចគ្នា ។

អង្គុ ហាស ចុ ការយាសើចដ៏ខ្លាំង. សំណើចប្លោកប្លាយ. (នៃគីរិ:) ។ អង្គ -ហាស្យ នបុ. ការយាសើចដ៏ខ្លាំង ។

អង្គ្យា ស្ត្រ. ការយាដើរត្រួច, ការយាដើរសាត់ព្រាត់ ។

អណិមនិ ចុ. ជម្ងឺជាគល្ងិត, បរមាណូ ។

អណីមាណ្ឌវ្យ ចុ. ឈ្មោះឫស ។

អណុ (-ណ្វី) គុ. ខ្លាវ, ល្ងិត, ស្តើង, ខ្សោយ, សុខុម; ដែលប្រមាណមិនបាន ។ ចុ. គ្រាប់ (millet?) ។ នបុ. ឈ្មោះវិសោ ។ – ភូ នបុ. ភាពនៃអណូ ។ – មាត្រិក គុ. ដែលមានមាត្រាជាបរមាណូ ។ អណ្វន្ត ចុ. ប្រស្នាដែលដោះស្រាយបានដោយត្រាជ្ញាសុខុមពន្លឹកភាព ។

ភាវនាសុទ្ធិយា


ទស្សនាវដ្ដី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣១ លេខ ៩ ខែកញ្ញា

ព.ស. ២៥០២ គ.ស. ១៩៥៩

ភ្នំពេញ



អក្សរសិល្បៈ

ទស្សនាវដ្តី ផ្សាយដំណឹងទាំងវិទ្យាសាស្ត្រ និងអក្សរសាស្ត្រ

ប្រកបដោយផ្នែកច្បាស់លាស់ និងមានរូបភាពល្អ

ផ្នែកសាសនា	ទំព័រ
- គារវកថា ដោយព្រះឧបាលី ឆាំ - សុវណ្ណទត្ត	៩៦៤
- មេត្តាវិហារកថា ដោយព្រះជាស្តេចសង្គ្រង្សី ម្ចាស់ - ប៊ុត	៩៦៧
- សុវត្ថិភាព (តទៅ) លោក ជុង - ជែ ដកស្រង់ពីសាស្ត្រាស្លឹកឱវាទ	៩៧៥
ផ្នែកអក្សរសាស្ត្រ	
- រឿងហង្សជួយខ្លួន (តទៅ) លោក គឹម - ភាន ដកស្រង់ពីសាស្ត្រស្លឹកឱវាទ	៩៧៤
- រឿងប្រដែងនឹងរឿងបុកណ្ដែងទល់ប៊ុន(តទៅ) លោក ភិយ - ប៊ុក រៀបរៀង	៩៩១
- រឿងស្រីគ្រប់ស៊ីក្ខណៈ (តទៅ) ឃុក - វ៉ែន រៀបរៀង លោក ផេង-គ្រី តំរឹមរួ.	១០២៦
- បន្ទាមុតយកបន្ទាដោះ លោក ប៊ូ - ប៊ូ រៀបរៀង	១០៣៧
- ទៅលេងហាងស្រូតិចួនដំរៃ លោក ស្ងួន - រម្មឺន រៀបរៀង	១០៤៥
- រឿងមណោមាគ (តទៅ) លោក ប៊ី-សុវណ្ណា ដកស្រង់ពីសាស្ត្រស្លឹកឱវាទ	១០៥១
- រឿងសាមពុក (តទៅ) ឧកញ៉ា ឆួ - កន ប្រែ	១០៦១
ផ្នែកកំណត់ទំនៀមប្រវត្តិការណ៍	
- បុណ្យឆ្លាក ជួយឧបត្ថម្ភសមណនិស្សិត នៅតុក្កិមហាវិទ្យាល័យព្រះសីហនុរាជ គណៈកម្មការបុណ្យរៀបរៀង	១០៧០
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តទៅ) ព្រះឧបាលី ជាំង-ខាត់ រៀបរៀង	១០៧៦

ចូលឆ្នាំ មាន ១២ លេខ តម្លៃ ជិតខ្លួនវា ២៣០០

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

sommaire

Partie religieuse :

— Garavakatha par Preah Maha CHAK-SUVADH . . . 965
— Metta Viharakatha par Preah Balat Sangreak MOUL-HIN . 978
— Sarabajataka (suite) relevé du manuscrit sur feuilles de latanier par M. THANG-VONG 985

Partie littéraire :

— Histoire de Hang-Yon (suite) relevée du manuscrit sur feuilles de latanier par M. IM-FHON 994
— Contes et Légendes du Japon traduits par M. RAY-BUC. . 1010
— La femme vertueuse par Yok Vochir revue et corrigée par M. PHENG-CHRIV 1026
— Tirer une épine du pied par M. BOU-PO 1037
— "Se promener au paradis pour quelques jours" histoire racontée par M. NHOUNG-SOEUNG 1045
— Histoire de Marana Mâtâ relevée du manuscrit sur feuilles de latanier par M. By-Sovann 1050
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1061

Notes et Chroniques :

— Bon Phka à l'Université Bouddhique Preah SIHANOUKRAJ 1070
— Dictionnaire Sanskrit-Khmer (suite) par Vén. PANG-KHAT . 1076

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

ផ្នែកសាសនា

គាវរីកបាំ

របស់ព្រះមហា ជក់-សុវ៉ែត្ថ វត្តមហាមន្ត្រី

និមួ ៣ ជំពូ

សូមឆ្លាយបន្ថែមចំ.តារក្រោះតេវត្រើម មានត្រាភ្នែជាដើម ដោយ
ភ្លាតាំង ៣ គឺ: តាយភ្លារ ១, វ៉ែភ្លារ ១, មនោភ្លារ ១ ។

សូមតាណិនាអំពីតារវ: ដែលមានមកពីគម្ពីរគង្គីតុនិកាយ ដូច
សេចក្តីតវ៉ាខ្លះ ៖

តារវ:មោរមាន ៦ ប៉ាំងគឺ:

១. ពុទ្ធតារវតា តោរពេកង្គីត្រាភ្នែ,

២. ធម្មតារវតា តោរពេកង្គីត្រាធម៌,

៣. សង្ឃតារវតា តោរពេកង្គីត្រាសង្ឃ,

៤. សិក្ខាតារវតា តោរពេកង្គីសិក្ខា គឺតារសិក្សាវ្រៀនសូត្រ,

៥. អបប្បមាទតារវតា តោរពេកង្គីសេចក្តីមិនប្រមាវ,

៦. បដិសណ្ឋារតារវតា តោរពេកង្គីបដិសណ្ឋារ: ។

សេចក្តីអធិប្បាយ: ទី១-ពុទ្ធតារវតា សេចក្តីតោរពេំតោះត្រាភ្នែ
តោះ គឺតាញ្ជាំងសទ្ធាសេចក្តីជឿ នឹងបញ្ជាក់សេចក្តីផ្ទែរជ្ងាឲ្យកើតឡើង

ក្នុងព្រះពុទ្ធយ៉ាងដាក់ចិត្តស់ ហើយសំដែងខ្លួនជាពុទ្ធមាមកៈ ជាអ្នកកាន់
តាមខ្លួនព្រះពុទ្ធជាម្ចាស់ គឺខ្លួលយកព្រះពុទ្ធអង្គជាឥតិធរបស់ខ្លួនដោយ
ត្រៃទ្វារគឺ កាយ វាចា ចិត្ត, ហើយប្រតិបត្តិតាមសាសនា ដែលជាពាក្យ
ប្រៀនប្រដៅរបស់ព្រះអង្គ ដោយសេចក្តីគោរព, តាំងចិត្តខ្ជាប់ថាៈ
ព្រះពុទ្ធជាអគ្គបុគ្គលប្រសើរលើសលុបក្នុងត្រៃភពគឺៈ កាមភព, រូបភព,
អរូបភព, ព្រះអង្គជាសាស្តាចារ្យនៃពពួកមនុស្ស ទេវតា មារ ព្រហ្ម
តាំងអស់, មិនតែមនុស្សប៉ុណ្ណោះទេ សូម្បីទេវតាដែលកាមាវចរសួគ៌
ន៍ដែលទេវតា ដែលនាព្រហ្មលោក តំណែងគោរពព្រះពុទ្ធតាំងអស់ដែរ ។
ការគោរពយ៉ាងនេះ ចាត់ជាគោរពក្នុងព្រះពុទ្ធមន្តិ. មួយយ៉ាងទៀត
ការពោលដល់គុណព្រះពុទ្ធអង្គមានបទថា អរហំដាដើម ទ្រង់ពុទ្ធបរិយាយ
ឃើញច្បាស់ដោយបញ្ញារបស់ខ្លួនដើម្បីបំផុតសព្វ ទ្រង់សេចក្តីដ្រេជ្ញាឲ្យ
ចំរើនច្រើនឡើងដោយលំដាប់ ហើយកាន់យកជាបៃបថែនដើម្បីកន្លងទុក្ខ
តាម ដូច្នេះគំចាត់ជាគោរពក្នុងព្រះពុទ្ធ ។ មួយទៀត ការមិនយកព្រះ
នាមព្រះពុទ្ធមកច្រានត្បូរលេង ដោយរើហាស្មុកតំបែង ដើម្បីសើច
លេងសប្បាយ ដូច្នេះគំចាត់ជាគោរពក្នុងព្រះពុទ្ធអង្គដែរ ។

ម្យ៉ាងទៀត ការចូលទៅកាន់បូជនីយដ្ឋាន ដែលជាទីប្រតិស្ថាន
បូជនីយវត្ថុផ្សេង ។ ដូចព្រះស្តូប, ព្រះបដិមាករ, ព្រះចេតិយ,
ដែលជំគល់ព្រះសារីរិកធាតុ ហើយសំដែងសេចក្តីគោរពតាមត្រែង

បើភាក់មួកតប្បីដោះចេញ , បើថុំងធ្រតប្បីដំខ្លោះចេញ , បើភាក់
ស្បែកជើងតប្បីដោះចេញ , ធ្វើសក្ការៈបូជាដោយផ្កាឈើ , ទៀន , ធូប ,
ឬ ក្រាបសំពះថ្វាយបង្គំ ដូច្នេះគំាថាគោរពក្នុងព្រះពុទ្ធគុណដែរ ។
ម្យ៉ាងទៀត ដោយហេតុដែលព្រះបរមសាស្តាចារ្យ កាលដែលនឹងបរិនិព្វាន
បានត្រាស់ថា ម្នាលអានន្ទ! ធម្មវិន័យដែលតថាគតសំដែងទុកហើយ
បានបញ្ញត្តទុកហើយ ដល់អ្នកទាំងឡាយ លុះតថាគតបរិនិព្វានទៅ
ហើយ ធម្មវិន័យនោះនឹងជាសាស្តាចារ្យនៃអ្នកទាំងឡាយ ។ ព្រោះ
ហេតុនេះ ទើបយើញថា ការគោរពក្នុងព្រះពុទ្ធគុណក៏ដាប់តាត់ដល់ការ
គោរពក្នុងព្រះធម្មនោះឯង ។

ទី២-ធម្មានុវត្តា គោរពក្នុងព្រះធម្មនោះ បានដល់ការសិក្សា
រៀនសូត្រប្រតិបត្តិចំរើនភាវនា ដោយមិនមានសេចក្តីប្រមាទប្រហែស
ធ្វើសក្ការសិក្សា ប្រតិបត្តិចំរើនភាវនានោះ ឈ្មោះថាសិក្សាប្រតិបត្តិ
ចំរើនភាវនាដោយគោរព ។

ឯពាក្យថា ធម្មនោះតាមន័យព្រះបរមត្ថសំដែងថាមាន ១០ ប្រការ
គឺ: សោតាបត្តិមគ្គ ១, សោតាបត្តិផល ១ ។ល។ ព្រះនិព្វាន១ ថែមព្រះ
បរិយត្តិ ១ ទៀតជាគំរប់ ១០ ។

ចំណែកធម៌ ៩ ទាំងដើមហៅថាលោកុត្តរធម៌ ឯលោកុត្តរធម៌នេះ
យោគាវចរគប្បីឆ្លងចិត្តស្រុះយកដោយការសិក្សា ដោយគោរព

មិនមែនប្រតិបត្តិស្មើ ។ ចំរើនភាវនាដោយស្មើៗ នោះទេ លុះណាតែមានទុច្ចរិតស្ងប់ក្នុង ចៃដន្យចាស់ក្នុង តាំងចំរើនភាវនាដោយគោរពក្រៃលែងណាស់ ទើបអាចឈានចាប់ស្រាវជ្រាវបានដូចបណ្តាមគ្គផលតាំងឡាយ មានៈ ហតាបត្តិមគ្គជាដើម មានព្រះនិព្វានជាទីបំផុតបានដោយងាយ ។ ឯព្រះបរិយត្តិធម៌ជាធម៌ដែលព្រះបរមសាស្តាទ្រង់គ្រាស់សំដែងទុកមកដើម្បីប្រយោជន៍ដល់ពួកវៀនយ្យសត្វរៀនយកដោយគោរព គឺយកចិត្តទុកដាក់ ។ បរិយត្តិធម៌នេះ ចែកជាខន្ធមាន ៨៤.០០០ ព្រះធម្មក្ខន្ធ បណ្តាធម៌តាំងនេះ បើបុគ្គលមិនបានសិក្សារៀនសូត្រដោយគោរពទេ តែមិនអាចនឹងបើកយោងដូរបុគ្គលនោះ ឲ្យជាអ្នកចេះដឹងប្តូរឲ្យរួចពាក្យទុក្ខបានដែរ ។ លុះណាតែបុគ្គលនិក្សាយាមប្រឹងប្រែងសិក្សារៀនសូត្រដោយសេចក្តីគោរពឥតងាក ទើបអាចយឺត.យោងបុគ្គលនោះឲ្យរួចពាក្យទុក្ខតាំងតួងឋាន ។ ឯធម៌តាំង១០យ៉ាងហៅថាពុទ្ធសាសនា ព្រោះសុទ្ធតែជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ឯសាសនានេះនឹងរុងរឿងក្តីថ្កុំថ្កើង តែអាស្រ័យនូវបរិស័ទតាំង៤ គឺ ភិក្ខុ, សាមណេរ, ឧបាសក, ឧបាសិកា រៀនធម៌ដោយគោរព, ទ្រទ្រង់ដោយគោរព, ពិចារណានូវធម៌ដោយគោរព, ថាបើមិនបានប្រតិបត្តិតាមធម៌ ៤ ស្ថាននោះដោយគោរពទេ សាសនាមិនរុងរឿងបាន មានតែសាបសូន្យទៅវិញមិនខាន ។ មួយទៀត ការយល់ស្តាប់ធម៌ដោយគោរពនេះឯង រមែងជាចុងស្ងប់ក្នុង

ដល់មនុស្សទេវតា, ជាទីបំផុតចុះមកដល់សត្វតិរច្ឆាន កំមានទុបនិស្ស័យដែរ (ដូចមាឧទិភាឧមមាទ្ធ ទៅក្នុងនន្តម្ពីរមង្គលសូត្រឯណោះស្រាប់) ។

ម្យ៉ាងទៀត ធម្មៈ សព្ទនេះ តាមន័យអដ្ឋថា ត្រមាំងដីតាលោកប្រែថា ទ្រទ្រង់ ថា សួយឡើង ។

អធិប្បាយថា: សតារៈណាធ្វើនូវសត្វភាំងឲ្យដែលទ្រទ្រង់នូវខុតហើយទ្រទ្រង់នូវសត្វភាំងឲ្យនោះ មិនឲ្យលិចធ្លាក់ចុះក្នុងអបាយភាំងឲ្យ ៤ផង ក្នុងវដ្តទុក្ខភាំងឲ្យផង, សតារៈនោះបានឈ្មោះថា ធម្មៈពិត, គឺបុគ្គលណាបានទ្រទ្រង់ធម៌ល្អ រក្សាធម៌ឲ្យល្អហើយ រៀបកធម៌ដែលល្អនោះឯងរមែងទ្រទ្រង់រក្សាបុគ្គលនោះឲ្យល្អវិញ មិនឲ្យធ្លាក់ចុះទៅក្នុងអបាយភូមិភាំង ៤ នោះឡើយ ម្យ៉ាងទៀតបុគ្គលណាបានទ្រទ្រង់នូវធម៌ដ៏ខ្ពង់ខ្ពស់រៀសសព៌ាំផុតក្នុងសព្ពាទទ្ធលល្អហើយ ធម៌ដ៏ខ្ពង់ខ្ពស់នោះទំនងទ្រទ្រង់បុគ្គលនោះឲ្យស្ថិតទៅក្នុងឋានៈដ៏ខ្ពង់ខ្ពស់រៀសសព៌ាំផុត គឺព្រះនិព្វានជាសុខក្សេមក្សាន្តពុំភ្លាឲ្យធ្លាក់ចុះទៅក្នុងវដ្តទុក្ខភាំងឲ្យនោះឡើយ ។

ទី៣- សង្ឃគារវតា គោរពក្នុងព្រះសង្ឃ ។ ព្រះសង្ឃនោះសំដៅយកភ្លាសាវក លោកបានធម៌រៀសសង្ឃនាំគ្នាដោយប្រកេរជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមីនិងព្រះអរហន្ត គោលដោយបរិយាយយ៉ាងនេះ អនុលោមតាមន័យនេះសម្តីសង្ឃដែលលោកមានសីលបរិសុទ្ធិ មានមារយាទស្ងប់ស្ងៀម មានឥន្ទ្រិយស្រគត់ស្រគំ

មានគុណធម៌គួរគោរព ដែលមានសភាពដែលបានេះគំរើឈ្មោះថាសង្ឃ ។
ឯការគោរពក្នុងព្រះសង្ឃគឺការគ្រាបសំពះ ការក្រោកទទួល ការធ្វើ
អញ្ជលិកម្ម ការធ្វើសាមីចិកម្ម រហូតដល់ការអើពើផ្សេងៗ ដូចដឿតាម
ពាក្យប្រៀនប្រដៅរបស់លោក, ប្រតិបត្តិតាមឧត្តរបស់លោក មិនសំដែង
អាការមើលងាយដូច្នេះជាដើម ចាត់ជាគោរពក្នុងព្រះសង្ឃ ។

ខ ៤- សិក្ខាការវតា គោរពក្នុងសេចក្តីសិក្សា ។ ការតាំងចិត្ត
សូត្រឿនពាំនីពាំនែវ តឹផ្លូវធម៌ទឹងផ្លូវលោក មិនខ្ជិលច្រអូស ទប្បាហ៍
ស្តាប់ច្រើន មើលច្រើន បើមិនចូលចិត្តសេចក្តីពាក់ព្រៀត្រង់ណា តប្បី
សួរដណ្តឹងលោកអ្នកប្រាជ្ញដែលចេះដឹងត្រង់ណោះ បើចូលចិត្តជាក់ច្បាស់
គួរកំណត់ទុកក្នុងចិត្ត ឬសរសេរកត់ទុកក្រែងភ្លេចភ្លាំងមានច្បាប់ស្រាប់
ដូច្នេះចាត់ជាគោរពក្នុងការសិក្សា ។ បើពោលដល់ប្រយោជន៍ការសិក្សា
ជារបស់សំខាន់បំផុតពាំងក្នុងតតិលោក ពាំងក្នុងតតិធម៌ ការសិក្សានេះ
ជាគុណសម្បត្តិមួយ ដែលគេនិយមកាន់តួរៗពាំងស្រុក-ប្រទេស
សូម្បីជាតិ សាសន៍ណាក៏ដោយ គេតែងតែកាន់តាមការសិក្សានេះដែរ,
ហើយទំសិក្សាសូត្រ-រឿនឲ្យបានចេះដឹងជ្រៅជ្រះឡើង ឲ្យបានជាអ្នកអង់
អាចសីហនាទគ្មាហាន ក្នុងទីប្រជុំជនធំ ។ អាចនឹងជួយស្រោចស្រង់
សង្គ្រោះដល់ប្រជាជាតិមាតុភូមិរបស់ខ្លួន ឲ្យបានរួចអំពីគ្រោះថ្នាក់យ៉ាងធ្ងន់
គឺសេចក្តីល្ងង់ខ្លៅ ឲ្យឡើងកាន់កាពជាអ្នកចេះដឹង ឲ្យជាអ្នកមានប្រាជ្ញា
ហ៊ាហាន ចេះចាកតង្គាគាំពារសេចក្តីសាមគ្គីឲ្យល្អ អាចនឹងញ៉ាំងជាតិ

សាសនា ព្រះមហាក្សត្រិយ៍បានសំដែង ឲ្យបានរុងរឿងថ្កុំថ្កើងស្មើ
ឈានឯទៅតែអាស្រ័យធម៌ដ៏ឯកវិសុទ្ធធម៌ជាន់ខ្ពស់ដ៏ឯកគ្មាន ទៅតាមកាលសម័យ
ថ្មីនេះឯង ។ ការសិក្សាយ៉ាងនេះ ហៅថាសិក្សាដើម្បីប្រយោជន៍ដល់
ប្រទេសជាតិជាការគោរពដ៏ឧត្តម ម្យ៉ាងទៀតបុគ្គលដែលចំសិក្សាដើម្បី
ការនៃខ្លួនថាពហុស្សុត បេះចាំទូរទៅក្យតេចន៍របស់ព្រះសម្ពុទ្ធជាម្ចាស់
បុគ្គលនោះ គោះបើមិនបរិបូណ៌ដោយគោតសម្ព័ទ កំបានរៀបរាប់ថាជា
អ្នកមិនត្រលំបាកដោយការចិញ្ចឹមជីវិត មិនប្រាសចាកប្រយោជន៍ដ៏ល្អទេ
គោះនឹងបួសទៅសិក្សាតមណា រមែងជាទីពឹងអាងនៃជនតាំងពាយ ព្រោះ
មានសេចក្តីឆ្ងៀវឆ្ងាតអង់អាចក្លាហានក្នុងការនិយាយស្តី មានបញ្ញាដឹង
អត្ថដឹងធម៌ ទាំងខ្លួនឲ្យតាំងនៅក្នុងសម្មាបដិបត្តិជាសប្បុរស ហើយប្រកប
ក្នុងសារប្រយោជន៍ ។ ហេតុដូច្នេះ សម្តេចព្រះបរមសាស្តា ទ្រង់
សរសើរគុណធម៌តិ: ពហុស្សុតច្នេះជាច្រើនប្រការ ។ បុគ្គលជាពហុស្សុត
មានធម៌បានស្តាប់បានរៀនហើយដោយច្រើន ទ្រទ្រង់ធម៌ដែលបានស្តាប់
បានរៀននោះ មានធម៌ដែលស្តាប់ដែលរៀនហើយសន្សំទុក, ធម៌ណា
ដែលពីពេកក្នុងភាសាដើម ពីពេកក្នុងកណ្តាល ពីពេកក្នុងទីបំផុត ប្រ-
កាសត្រហ្មចរិយៈ ព្រមទាំងអត្ថទាំងព្យញ្ជនៈ បរិសុទ្ធបរិបូណ៌អស់ដើង
ធម៌ទាំងអម្បាលនោះ បុគ្គលបានស្តាប់បានរៀនហើយដោយច្រើន បាន
សំឡឹងពិចារណា ហើយចិត្តក៏បានចាក់ធ្លុះចំពោះធម៌ ជាគុណប្រយោជន៍

ធ្វើបុគ្គលនោះឱ្យជាទីពឹងអាស្រ័យនៃសត្រហ្មចារីទាំងឡាយ ការសិក្សា
មានគុណានុភាពដែរបន្តិច ទើបលោកប្រដៅឱ្យតោរពក្នុងកិច្ចសិក្សា ។

ទី ๙. អប្បមាទតារវតា គោរពក្នុងសេចក្តីមិនប្រមាទ ។ សេចក្តី
មិនប្រមាទនេះ គឺធម៌ជាសត្រូវដល់សេចក្តីប្រមាទ ដោយអត្ថថា ចាន
ដល់កិរិយាដែលមិននៅប្រាសចាកសតិ គឺកិរិយាដែលមិនវង្វេង ឈ្មោះ
ថាសេចក្តីមិនប្រមាទ គោរពក្នុងសេចក្តីមិនប្រមាទនោះ គឺបំពេញសេចក្តី
មិនប្រមាទឱ្យបរិបូណ៌ក្នុងសន្តាន ដោយអធិប្បាយថា មិនស្រវឹងក្នុង
លាភ យស សរសើរ សុខ ក្នុងវ័យ ក្នុងសេចក្តីមិនមានរោគ ក្នុងជីវិត
ដូច្នេះ ចាត់ជាគោរពក្នុងសេចក្តីមិនប្រមាទ ។

ម្យ៉ាងទៀត ធ្វើសេចក្តីមិនប្រមាទក្នុងការលះសេចក្តីអាក្រក់ មិន
ប្រមាទក្នុងការបំពេញសេចក្តីល្អ ទាំងពីរនេះមានសេចក្តីអធិប្បាយថា
ការមិនប្រមាទក្នុងការលះនោះ សេចក្តីថា អំពើណា ។ ប្រព្រឹត្តទៅដើម្បី
ខូចប្រយោជន៍ខ្លួនទីដ៏អ្នកដទៃ អំពើនោះ ។ ជាអំពើគួរលះ; ពោះបីបន្តិច
បន្តួចក៏មិនត្រូវប្រមាទឡើយ ។

សមដូចសុភាសិតដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែងថា :

មាវមញ្ញេថ ចាបស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
បូរតិ ពាលោ ចាបស្ស ថោកំ ថោកំបិ អាចិនំ ។

សេចក្តីថា: បុគ្គលមិនគួរមើលងាយថាបុណ្យមានប្រមាណតិចនឹងមិនឲ្យផលឡើយ, សូម្បីតែកម្មពីរដែលគេបើកមាត់ចំហពុះក្នុងទឹកល ក៏រមែងគេញដោយដំណក់ទឹកភ្លៀងដែលធ្លាក់ពីលើអាកាសចុះមកបន្តិចបន្តួច ។ គេញបានយ៉ាងណាមិញ, មនុស្សកាលបើសន្សំបាបសូម្បីបន្តិចបន្តួច ។ ក៏គេញដោយបាបឯង យ៉ាងនោះដែរ ។

ចំណែកខាងអ្នកមិនប្រមាទក្នុងការបំគេញសេចក្តីល្អនោះ អធិប្បាយថា អំពើណា ។ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ខ្លួនឯងក្តី អំពើនោះ ។ ជាអំពើគួរបំគេញគួរចំរើន គោះបីបន្តិចបន្តួចក៏មិនត្រូវប្រមាទឡើយ, ដូចមានសុភាសិតនៃព្រះមានព្រះភាគទ្រង់ប្រដៅថា:

មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
បូរតិ ពីជកោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។

សេចក្តីថា: បុគ្គលមិនគួរមើលងាយបុណ្យថា បុណ្យមានប្រមាណតិចនឹងមិនឲ្យផលឡើយ ប្រៀបដូចកម្មពីរមែងគេញបានដោយដំណក់ទឹកដែលធ្លាក់ពុះយ៉ាងណា, អ្នកមានប្រាជ្ញាកាលសន្សំនូវបុណ្យបន្តិចបន្តួច ។ គង់តែគេញបានដោយបុណ្យនោះដែរ ។

ការប្រៀនប្រយ័ត្នត្រង់យ៉ាងចាត់ជាសេចក្តីគោរពក្នុងសេចក្តីមិនប្រមាទមក្យ៉ាង ។

មួយវិញទៀត ព្រះសយម្ភូញាណជាម្ចាស់ទ្រង់ត្រាស់ឲ្យលះកាយទុច្ចរិត, វចីទុច្ចរិត, មនោទុច្ចរិត, កុំឲ្យប្រមាទក្នុងការលះទុច្ចរិតទាំងនោះ ឲ្យធ្វើកាយសុចរិត, វចីសុចរិត, មនោសុចរិត ឲ្យកើតមានឡើង កុំឲ្យប្រមាទក្នុងការចំរើនសុចរិតទាំងនោះ ។ សេចក្តីមិនប្រមាទនេះ បើពោលតាមសេចក្តី ក៏គឺមានសតិបដ្ឋានិមិនទ្រឹង្គសូត្រសតិសម្បជញ្ញៈ សមដូចព្រះពុទ្ធដីកានៃព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ចត្តារិ កិត្តវេ ឯកាយនានិ អត្តនុបេន អប្បមាទោ សតិ ចេតសោ អាវរណានំ ខយាយ ម្នាលតិក្ខាទាំងឡាយ! សេចក្តីមិនប្រមាទតឹសតិ, ជាធម៌ក្សាទុកនូវចិត្តជាធម្មជាតដែលអ្នកភាំងឡាយត្រូវធ្វើ ក្នុង ៤ ស្ថាន តាមសមគួរដល់ខ្លួន សេចក្តីមិនប្រមាទដែលអ្នកភាំងឡាយត្រូវធ្វើក្នុង ៤ ស្ថាននោះ គឺ ១- ចិត្តរបស់អាត្មាអញកុំត្រេកត្រអាលក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីត្រេកត្រអាល ; ២- ចិត្តរបស់អាត្មាអញកុំប្រទូស្តក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីប្រទូស្ត; ៣- ចិត្តរបស់អាត្មាអញកុំវង្វែងក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីវង្វែង; ៤- ចិត្តរបស់អាត្មាអញកុំស្រវឹងក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីស្រវឹង ។ តាលបើពោលដោយសេចក្តីប្រតិបត្តិជាទុបការៈដល់សេចក្តីមិនប្រមាទនោះក៏គឺមនសិការៈ (ធ្វើទុកក្នុងចិត្ត) ដល់នូយវិយធម៌ ។ បុគ្គលនឹកពិចារណាដល់សេចក្តីសូន្យនៃសង្ខារដោយអំណាចជាស់ ឈឺ ស្លាប់ក្តី, នឹកពិចារណាថា ខ! សេចក្តីជាស់ ឈឺ ស្លាប់

ជាតិយកែកទន្ទ្រានចូលកាន់តែជិតរាមករហើយ ដូច្នេះក្តី; តអំពីនោះទៅ
ទើបមិនប្រមាទចំពោះឃ្នាតបំភេញកុសលឲ្យកើតឡើងក្នុងសន្តាន ។ ត្រោះ
ហេតុនោះបានជាព្រះបរមសាស្តាជាម្ចាស់ តាលទីឯត្រាស់ដាស់តឿនពុទ្ធ
បរិស័ទមិនឲ្យប្រមាទក្នុងកាលដែលព្រះអង្គខៀបនឹងទ្រង់ថា មាច្ចធាឯ
តិក្ខវេ អាមន្តយាមិ វោ ម្នាលភិក្ខុទាំងឡាយ ! តថាគតដាស់
តឿនអ្នកទាំងអស់គ្នាវិញថា សង្ខារទាំងឡាយមានសេចក្តី
សូន្យជាធម្មតា, អប្បមាទេន សម្បាទេថ អ្នកទាំងឡាយចូរ
ញុំាងប្រយោជន៍ឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ ។ មួយវិញ
ទៀត តោលដោយអត្ថ តាលទីឯប្រកបកិច្ចការណាមួយទាំងផ្លូវលោក
ទាំងផ្លូវធម៌ មិនត្រូវបាតសតិបារតីនៅសព្វកាលវេលា នេះចាត់ជា
គោរពកន្លងសេចក្តីមិនប្រមាទ ។

ទី ๖- បដិសណ្ឋារតាវតា គោរពក្នុងបដិសណ្ឋារៈ ។
បដិសណ្ឋារៈនោះបានដល់តាទេខ្លួលដោយមេត្រី, ចែកចេញជាពីរប្រការ
គឺ:អាមិសប្បដិសណ្ឋារៈ១, ធម្មប្បដិសណ្ឋារៈ១ ។ តាទេខ្លួលក្បៀវដោយ
ទ្រព្យរបស់ជាការសមគួរដល់ក្បៀវដែលមកដល់លំនៅខ្លួន ដូចឲ្យគោជនា-
ហារ ទីសំណាក់អាស្រ័យជាដើម ហៅថាអាមិសប្បដិសណ្ឋារៈ ។
ការដែលធ្វើអាមិសប្បដិសណ្ឋារៈនោះ គួរតែឲ្យប្រព្រឹត្តទៅដោយធម៌
ដូចសំដែងខ្លួនតាមគួរសម យ៉ាងដូច្នេះហើយ លើកមុខមាត់ក្បៀវដែល

មកនោះដោយសេចក្តីអើតើងដល់ក្រៀវក្តី, ការខ្ជិលខ្ជាខណៈនាំទៅក្នុងនរណាស្អប់ក្តី ហៅថាធម្មប្បដិសណ្ឋារៈ ។ ការគោរពអើតើងក្នុងបដិសណ្ឋារៈដល់ក្រៀវដែលមកទីគំនៀរបស់ខ្លួន ដោយអាមិសឬ ដោយធម៌ដូចពោលមកហើយនោះ ឬគ្រាន់តែប្រាស្រ័យ ដោយវាចាដែលហៅថា សម្មោទនា គឺនិយាយប្រាស្រ័យឲ្យគេតែសេចក្តីត្រេកអរមានសួរដល់សុខទុក្ខជាដើមនេះ ចាត់ថាគោពេក្នុងបដិសណ្ឋារៈ ។ កាលបើពោលដោយអាការៈដែលប្រព្រឹត្តទៅហើយ ការធ្វើបដិសណ្ឋារៈនេះជាប្រពៃណីនៃយមតមកបស់បុរាណកបណ្ឌិត សូម្បីក្រៅពុទ្ធសម័យ ទោះបើក្រៀវនោះមកល្អក៏ដោយ អាក្រក់ក៏ដោយ ក៏ឲ្យសំគាល់យើញថា ជាកិច្ចដែលត្រូវធ្វើតាមទាន់ សេចក្តីនេះគប្បីយើញក្នុងរឿងព្រះវេស្សន្តរ ព្រះបាទក្លីបដិសណ្ឋារៈដល់ព្រឹទ្ធព្រាហ្មណ៍ដែលមកទូលសូមព្រះពេជកុមារគាំងតែនឹងសម្តេចសហស្សនេត្រ ដែលកាឡកេទ ជាព្រាហ្មណ៍មកទូលសូមទានមន្ត្រី ព្រះមន្ត្រីក្រាបទូលប្រាស្រ័យឲ្យតែសេចក្តីត្រេកអរ ហើយអញ្ជើញឲ្យសោនជើងឲ្យចូលទៅក្នុងអាស្រមបទ ឲ្យរើសផលាទុនជាមធុរសជាបស់ត្រចរភោគ, ឲ្យផឹកវារីថ្លាត្រជាក់ដែលជនមកអំពីជ្រោះភ្នំតាមសេចក្តីគាប់ចិត្ត ។ លុះដល់មកពុទ្ធប្បាទសម័យ សម្តេចព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ប្រដៅឲ្យគោរពក្នុងបដិសណ្ឋារៈដូចគ្នា សូម្បីបព្វជិតក៏ត្រូវធ្វើដែរ

ដូចយ៉ាងអាតន្តិកៈមកដល់ទីសំណាក់ជាទាវនៃពៅអាវស ឱនគួរទទួលដោយកិច្ចវត្ត ។

បើតោលដោយខួរក្បៅ សេចក្តីគោរពនេះ ជាគុណធម៌មួយដ៏ល្អ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានត្រាស់ទុកថាជាធម៌ជាគ្រឿងទ្រទ្រង់សាសនា ឲ្យរុងរឿងអស់កាលជាអង្វែងតទៅបាន តែថាព្រះតុទ្ធសាសនានឹងរឹងមាំប្តូចំពោះតែរុងរឿងឡើងក៏ត្រេះសេចក្តីគោរព ឱនសេចក្តីមិនគោរពនេះឯងជាហេតុ, សេចក្តីនេះគប្បីដឹងដោយទេសនាន័យដែលព្រះអង្គទ្រង់ត្រាស់ដល់មហាកស្សបៈប្រាប់ឲ្យសេចក្តីអន្តរធានៃព្រះសទ្ធម្ម ដែលឱនមានឡើងក៏ត្រេះតិក្ខុ-តិក្ខុនី-ឧបាសក-ឧបាសិកា មិនមានសេចក្តីគោរពកោតក្រែងក្នុងព្រះសាស្តា ក្នុងព្រះសង្ឃ, ក្នុងការសិក្សា, មិនមានអ្វីដទៃដែលអាចលុបលាងព្រះសទ្ធម្មឲ្យសាបសូន្យទៅបាន ត្រែវអំពីហេតុ តែសេចក្តីគោរពនឹងសេចក្តីមិនគោរពកោតក្រែងនោះឡើយ ព្រោះហេតុដូច្នេះ សាធុជនអ្នកប្រុងប្តូសេចក្តីចំរើនដល់ជាតិ-សាសនា- ព្រះមហាក្សត្រ ប្រុងប្តូសេចក្តីចំរើនដល់ខ្លួន គប្បីធ្វើសេចក្តីគោរព ៦ ប្រការនេះចុះ ។

ការពណ៌នាអំពីតារៈ ចប់ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះ ។

មេត្តាវិហារកថា

របស់ព្រះជាឃ្លាំងសង្ឃរ័ត្ន អួល ហ៊ុន វត្តខ្ពស់ណោម

ឧទ្ទេស ៣ ជាំង

សូមនមស្ការ ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធព្រះគន្ធីទាវ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃជោយរតោវត) ។

មេត្តាវិហារំ យោ តិក្ខុ បសន្ទោ តុទ្ធសាសនេ
អតិក្កច្ច បទំ សន្តំ សង្ខារូបសមំ សុខំ ។

សេចក្តីថា តិក្ខុណាមួយមានមេត្តាធម៌ ដើម្បីបំពេញព្រះពុទ្ធសាសនាតិក្ខុនោះ គប្បីបានខ្លួនថ្លូវស្ងប់ជាសុខ ជាទីបាយ ជាទីរម្ងាប់បង់ខ្លួនសង្ខារ ។

សូមតាំងនាមតាមបាលីពុទ្ធភាសិត ដែលមានក្នុងគន្ថរចនាយ អដ្ឋកថាធម្មបទ ផ្នែកខាងសុត្តន្តបិដក ដែលព្រះពុទ្ធទ្រង់សំដែងក្នុងព្រះចំពោះតិក្ខុជាច្រើនរូប ។ សូមរៀបរាយបាលីថា « មេត្តា » ជាមុនរួចសឹមតម្រៀបរាយបាលី ថា មេត្តាវិហារី តាទៅ ។

មេត្តា ប្រែថា សេចក្តីរាប់អានជាប់ស្និទ្ធ, ស្និទ្ធស្នាល មកអំពីសព្ទដើមថា « មិទ: » សមដូចវិគ្គហៈថា សត្វេសុ ទាសោសុ មេដ្ឋតិ សិនេហាតីតិ មេត្តា ធម្មជាតិណាជាប់ស្និទ្ធ រាប់អានស្និទ្ធស្នាលចំពោះសត្វទាំងឡាយទាំងពួង, ធម្មជាតិនោះឈ្មោះថា មេត្តា ។

មេត្តាធម៌នេះ ជាធម៌សំរាប់ធ្វើមនុស្សសត្វ ឲ្យបានចំណេះនូវសេចក្តីសុខសម្រាន្តគ្រប់ពេលវេលា , ទុកដូចជាការពារធម្មយកថាព្រះពុទ្ធសាសនាសំរាប់ការពារសង្គមរបស់មនុស្សកុំឲ្យមានការបៀតបៀនគ្នាឯងដែរ ពាំនាំជាឧបាយដ៏វិសេសសំរាប់បន្ធូរបន្ថយនូវពេតតី គោធៈ ព្យាបាទៈ ជាដើមឲ្យស្ងប់រម្ងាប់បាន ព្រោះគោធៈទាំង ព្យាបាទនេះ ជាឈ្នួនសង្គ្រាមកាន់ផ្លូវចិត្តសំរាប់ដុតកំដៅសត្វឲ្យក្តៅក្រហាយអន្ទះអន្ទែងឯ បើស្រាវជ្រាវពិតឲ្យច្បាស់ តាមេត្តាទាំង ១ ទី មិនដាយរម្ងាប់កំដៅកាន់ផ្លូវចិត្តនេះបានទេឡើយ ។

មេត្តាធម៌ ជាធម៌សំរាប់កសាងសង្គមមនុស្សឲ្យបានចំណេះនូវសេចក្តីសុខ ចំរើនខាងសីលធម៌ , វឌ្ឍនធម៌ , អារ្យធម៌ មិនថាសង្គមណាឬបក្សណាឡើយ ពាំនាំជាគ្រឿងជំនួយមេត្តាភាវនា សាមគ្គីភាព ក្នុងសង្គម ឬប្រទេសមួយ ។ ឲ្យបានវឌ្ឍនភាពជាដរាប ។

មេត្តាធម៌ជាសន្តិធម៌ គឺធម៌ស្ងប់សំរាប់ធ្វើចិត្តមនុស្សកុំឲ្យបៀតបៀនព្យាបាទគ្នាទៅវិញទៅមក ។ មេត្តាធម៌ជាធម៌ត្រជាក់ អាចលត់នូវភ្លើងខាងផ្លូវចិត្ត ទាំងផ្លូវកាយបានដោយពិត ។

មេត្តាវិហារី ប្រែថា កិត្តិនាមរបស់ដោយមេត្តា បើតាមឋានលីភុទ្ធសាសនេះ ក៏ហាក់ដូចជាព្រះសម្ពុទ្ធទ្រង់ជាស់ត្រឿនចំពោះតែកិត្តិ មិនខ្លះទៅដល់ត្រឹមស្តេច ប៉ុន្តែក្នុងទីនេះបានជាព្រះអង្គទ្រង់សំដែងដូច្នោះ ព្រោះមានច្រើនតែកិត្តិទៅតាល់ស្តាប់ធម៌ទេសនាកាន់ទីនោះ ទើបព្រះអង្គសំដែង

ចំពោះតែកុំតែម្តង ។ ព្រះពុទ្ធជាអ្នកប្រាជ្ញមានព្រះទ័យពោរពេញដោយមេត្តានេះឯងគប្បី ប្រាថ្នាឲ្យសត្វទាំងអស់បានទទួលនូវសេចក្តីសុខ-ចំរើនគ្រប់ៗគ្នា ។

តែកុំគួរជាអ្នកមានចិត្តប្រកបដោយមេត្តាគ្រប់តំរិយាបថទាំង៤គឺ : ដើរឈរ-អង្គុយ-ដេក ពោះដើរក្តី-ឈរក្តី-អង្គុយក្តី-ដេកក្តី គួរតែជាអ្នកក្រាស់ដោយមេត្តាធម៌នេះជានិច្ចឲ្យច្រើនជាងគ្រហស្ថ ព្រោះតែកុំអ្នកមានមេត្តាធម៌ រមែងជាអ្នកនៅជាសុខដូចម្តេចក្នុងសាសនានេះ ។ តែកុំណាគ្មានមេត្តាធម៌ទេ, តែកុំនោះរមែងជាទទួលនូវទុក្ខ នាំមកនូវសេចក្តីអន្ទះអន្ទែងក្នុងព្រះពុទ្ធសាសនា ចំពោះខ្លួនឯង ព្រោះតែកុំព្រះសាសនានេះ គួរតែកុំមានមេត្តាធម៌ជាសាធារណៈ ។

ប្រជាជនក្នុងប្រទេសទំនួយ ឬក៏ក្នុងលោកលោក បើគ្មានមេត្តាធម៌ ប្រាកដជាមានចិត្តប្រកបដោយការបៀតបៀនគ្នាពុំខាន ។ យើងជាអ្នកប្រាថ្នាសេចក្តីសុខ-ចំរើន សេចក្តីសាបសូន្យរុងរឿង គួរតែតាំងចិត្តពោរពេញដោយចំពោះបុគ្គលដទៃ កុំប្រណាំងឈ្លោះទាស់នឹងគេ គួរតាំងចិត្តប្រកបដោយការពេញចិត្តគ្នាទៅវិញទៅមក ត្រូវតាំងចិត្តថា គេស្អប់សេចក្តីទុក្ខ ស្រឡាញ់សេចក្តីសុខ, ស្អប់ក្រ ស្រឡាញ់ទាន, ស្អប់សេចក្តីវិនាស ស្រឡាញ់សេចក្តីចំរើន ដូចអាត្មាអញដែរ, គេដូចអញ។ដូចគេ ។ បើបុគ្គលណាផ្តាច់សេចក្តីសុខអំពីអ្នកដទៃ ហើយប្រមូលយក

សុខមកដើម្បីខ្លួន បុគ្គលនោះឈ្មោះថាមិនមានមត្តាធម៌, ឈ្មោះថាគ្មាន
មិត្តភាពរវាងមនុស្សសត្វ រហូតដល់លោកទាំងមូល ។ ព្រោះថាផ្ទះមួយ។
ប្រទេសមួយ។ ឬប្រទេសទាំងអស់ក្នុងសកលលោក បើជនក្នុងផ្ទះឬ
ប្រទេសនោះ។ មិនមានមេត្តាធម៌ ច្រកតដាមិនមានមិត្តភាពរវាងផ្ទះ
មួយ-ប្រទេសមួយឡើយ បើមិនមានមិត្តភាព រវាងគ្នាទំនឹងគ្នាហើយ
សាមគ្គីធម៌ គឺការព្រមព្រៀងក៏មិនមាន, បើការព្រមព្រៀងគ្នាមិនមាន
ហើយ សេចក្តីសុខរបស់ជនក្នុងផ្ទះ-ប្រទេសនោះ។ ក្នុងលោកនេះក៏
មិនមាន, បើសេចក្តីសុខក្នុងលោកនេះមិនមានហើយ សេចក្តីសុខក្នុង
លោកខាងមុខ ក៏ងឹតតែមិនមានៈជាងទៀត ។

មនុស្សគ្រប់ជាតិក្នុងលោក គួរតែជាអ្នកសម្បូណ៌ដោយមេត្តាធម៌
នេះណាស់ គួរបែរមកកាន់កំណប់សុខក្នុងព្រះពុទ្ធសាសនា គួរអនុវត្តតាម
សាសនា តម្រង់ចិត្តដើម្បីឱ្យចិត្តចេះកាន់តាមចំពោះបុគ្គលដទៃ ដូចខ្លួនយើង
ពោះគ្រហស្ថ ឬបព្វជិត ក៏គួរជ្រាបសេចក្តីស្រឡាញ់កាន់តាមនេះឱ្យតែតែ
រឹងប៉ឹងឡើង ។ បើបុគ្គលដទៃមានជម្ងឺ ពោះគ្រហស្ថ ឬបព្វជិត បើ
មានថ្នាំសំរាប់កែចំជាត់ពេលនោះ គួរតែជាក់ថានជូលបុគ្គលដែលមានជម្ងឺ
នោះ កុំស្តាយស្រណោះឱ្យសោះ ព្រោះការឱ្យនេះជាផ្លូវចិត្តមួយ
ដ៏ប្រសើរចាត់ជាគិលានទាន ។ ការឱ្យបែបនេះ ចាត់ចូលក្នុងការ
សង្គ្រោះចំពោះអ្នកជម្ងឺ ឬអ្នកចិញ្ចឹមគ្រូសំឡាញ់ឆ្កែតោកយ៉ាកត្រូជាបត្រូដូស

ឥតខ្ចីពីងពំនាក់ ដូចសមាគមគិលានសង្គ្រោះនេះ ជាអង្គការមួយជួយផ្គត់ផ្គង់ខ្ញុំសុខភាពដល់ព្រះសង្ឃ ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនា ឋិតនៅយូរសាសនាឲ្យចំរើនរុងរឿងតទៅអនាគត ។ ការសង្គ្រោះចំពោះអ្នកជម្ងឺនេះ អ្នកប្រាជ្ញទាំងឡាយតែងប្រព្រឹត្តឥតដែលខានឡើយ ។ គិលានសង្គ្រោះដែលពុទ្ធបរិស័ទធ្វើមកនេះ ជាសាខានៃមេត្តាធម៌ជាយថាគត ។

មេត្តាធម៌នេះ មុនដំបូងលោកឲ្យចំរើនចំពោះអ្នកមានគុណមានមាតាបិតាជាដើម បន្ទាប់មកត្រូវចំរើនចំពោះបុគ្គលជាកណ្តាល ដែលមិនជាទីស្រឡាញ់ មិនស្អប់សិន រួចទើបត្រូវចំរើនចំពោះបុគ្គលដែលយើងស្អប់ ដកចិត្តនោះរលាយការស្អប់ លែងមានជាកររវៃរកការស្អប់ទៀត ។

មេត្តាធម៌អាចហុចអាទិសង្ឃដល់បុគ្គលអ្នកចំរើន ១១ ប្រការគឺ:

១. សុខំ សុបតិ អ្នកមានមេត្តាធម៌នៃដែកជាសុខ,

២. សុខំ បដិពុជ្ឈតិ អ្នកមានមេត្តាធម៌នៃភ្ញាក់ឡើងជាសុខ,

៣. ន បាបកំ សុបិនំ បស្សតិ អ្នកមានមេត្តាធម៌នៃដែមិនឃើញសុបិនអាក្រក់ ដោយហេតុណាមួយ,

៤. មនុស្សានំ បិយោ ហោតិ រមែងជាទីស្រឡាញ់នៃមនុស្សទាំងឡាយច្រើនប្រការ,

៥-អមនុស្សត្តំ ចិយោ ហោតិ រមែងជាទីស្រឡាញ់នៃពួកអមនុស្ស តែពួកឯសាចកជក្ខុត កំមិនអាចបៀតបៀនបុគ្គលអ្នកមានមេត្តាធម៌,

៦.ទេវតា រក្ខន្តិ ទេវតាតែងរក្សាបុគ្គលអ្នកមានមេត្តាធម៌,

៧-ជាស្ស អគ្គិ ភ វិសំ ភ សត្ថំ ភ កមតិ ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងអាវុធក្តី មិនឆេះ មិនពុល មិនមុត បុគ្គលអ្នកមានមេត្តាធម៌,

៨.តុវដំ ចិត្តំ សមាធិយតិ ចិត្តរមែងតាំងនៅមាំ,

៩-មុខវណ្ណោ វិប្បសីទតិ ទឹកមុខរមែងស្រស់បស់,

១០.អសម្មុឡ្ហោ កាលំ ករោតិ ធ្វើមរណកាលនៅ មិនវង្វេង,

១១. ឧត្តរិំ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ បើមិនទាន់ចាន់ចាស់បានសំរេចមគ្គផលទេ រមែងទៅកើត ក្នុងព្រហ្មលោកមិនខាន ។

បុគ្គលអ្នកចំរើនមេត្តាធម៌ រមែងបានទទួលអានិសង្សគឺ ១១ ប្រការដូចរៀបរាប់មកនេះយ៉ាងដូច្នេះឯង, មិនតែប៉ុណ្ណោះឡើយ ថាជាអ្នកមានចិត្តដឿបិបក្នុងព្រះពុទ្ធសាសនា, ព្រោះហេតុដូច្នោះបានជាព្រះពុទ្ធព្រះអង្គទ្រង់ត្រាស់សំដែងបញ្ជាក់ អំពីអានិសង្សរបស់បុគ្គលអ្នកចំរើនមេត្តាធម៌ថា: បុគ្គលអ្នកចំរើនមេត្តាធម៌មែនបានដួចប្រទះនូវសេចក្តីសុខ ជាផ្លូវស្ងប់ជាទីរំលត់បង់នូវសេចក្តីក្តៅក្រហាយបាន ជាសេចក្តីសុខឥតប្រែប្រួល គឺព្រះនិព្វាន ។

សង្ខារូបសម : ក្នុងបាលីពុទ្ធកាសិតនេះ អដ្ឋកថាប្រាប់ថា ព្រះនិព្វាន។ កិត្តិដែលបានមគ្គផលនិព្វាន ក៏ព្រោះតែមានមេត្តាធម៌ឬថាមានធម៌នេះជាជំហរ ឬស្ពានសំរាប់ឆ្លងទៅកាន់ព្រះនិព្វាន ។ ក្នុងព្រះពុទ្ធសាសនានេះ ព្រះពុទ្ធទ្រង់ជាកំពូលអ្នកប្រាជ្ញក្នុងសកលលោក ត្រាស់សរសើរចំពោះបុគ្គលអ្នកមានមេត្តាធម៌នេះណាស់ ព្រោះថា មនុស្សយើង ទោះបីនេះជាមានបុញ្ញានុភាពក្លៃយ៉ាងណាក៏ដោយ ប៉ុន្តែបើបុគ្គលនោះឯង គ្មានមេត្តាធម៌ក៏ឈ្មោះថា មិនមានសេចក្តីសង្គ្រោះដល់អ្នកដទៃ ខ្លះអាចភ្ជាក់ទៅជាអ្នកបៀតបៀនគេ ធ្វើឲ្យគេវិនាស ឲ្យគេសោយសុទ្ធ បង់ឲ្យថ្កុំថ្កើងរុងរឿង តែខ្លួន ឬ គ្រួសារខ្លួន ឬក៏បានសុខតែម្នាក់ឯងប៉ុណ្ណោះទៅវិញ នឹងសន្មតថា ជាអ្នកប្រាជ្ញដោយមេត្តាពុំពាន់ជាន់ឡើយ ។

ការសង្គ្រោះចំពោះសមណៈ មានអាគារ ឬក្រហស្ថដែលមានធម៌នេះ ពុកថាជារបាំងនៃមេត្តាធម៌ដោយតិត ។

មេត្តាវិហារកថា សន្មតថាចប់ដោយសង្ខេប ។

សូមព្រះពុទ្ធសាសនាកែផ្សាយខ្ជាក់ទៅគ្រប់សកលលោក !

សូមការពារជិតជនប្រកបដោយសុភមង្គលគ្រប់ប្រការ !

សូមសកលលោកប្រកបដោយសន្តិភាព !

សុរពជាតក

(តទៅ)

ណោក ថង-រឹង បច្ឆិមតិសារស្ត្រសិក្សាពិត

រឹងចៅអាវ៉ាស លុះសួរបង្ហិចសព្វៗនៃខ្លួនហើយ មកកាន់អាកាសវិញ ក្នុងពេលបីថ្ងៃ គឺតដល់មាស ទើបបើកភ្នែកមើល ឃើញសំពៅចេញរួចឆ្ងាយទៅហើយ ទើបគិតថា «ប្រាកដជាកុដុម្ពីក៍នេះ លួចយកមាសអញ ហើយយកភរិយាអញមកដាក់ជំនួស សចាហំ តំ បុច្ឆិស្សាមិ បើអញនឹងសួរវាវិញ ការណ៍ណាគាត់នឹងខ្លួលជឹង តួរអញកុំសួរឡើយ ត្រូវរកឧបាយផ្សេងទៀត» គិតដូច្នោះហើយ ក៏ហៅកុដុម្ពីក៍នោះមកប្រាប់ថា ម្នាលឧបាសក! ឥឡូវ អាត្មាមានចំណងចង់ទៅសួរញាតិឯណោះ ចូរអ្នកអនុគ្រោះឲ្យប្រពន្ធអ្នកទៅនឹងអាត្មា ចំនួនពីរបីថ្ងៃនឹងវិលមកវិញ ឯហិរញ្ញនេះ អាត្មាសុំផ្ញើទុកនឹងអ្នកទៀត។ កាលនោះ កុដុម្ពីក៍មានសេចក្តីត្រឿនត្រូលក្នុងចិត្ត ទើបលើកហិរញ្ញទៅទុកក្នុងផ្ទះ នាំភរិយាទៅប្រគេនព្រះសុខត្តសមណៈនោះ។ ឯព្រះសុខត្តសមណៈនាំភរិយានោះទៅផ្ទះញាតិរបស់លោក ដំណាលប្រាប់ញាតិសព្វគ្រប់ ផ្ញើភរិយាទុកនៅទីនោះ ហើយចាប់ស្វាព្រៃមួយមកប្រដៅឲ្យដឹងតាមឧស្សា នាំមកកាន់អាកាសវិញ លុះនាំស្វាមកដល់ប្រាប់កុដុម្ពីក៍នោះថា ម៉ៃឧបាសក! អាត្មានាំភរិយាអ្នកទៅដល់

ព្រៃមួយ កូនអ្នករស់ស្ទឹកឈើស៊ុំ ឥឡូវបួចឆ័ត្រកំទុសព័ទ្ធខ្សែ
អាត្មាមានសេចក្តីតក់ស្លុត ចូលដាន់មកឱ្យអ្នកវិញ ។ កុដុម្ពីក៍មាន
ចិត្តតក់ស្លុតក៏ស្រែដីថា បពិត្រលោកម្ចាស់ ! លោកម្ចាស់ទាំយកមនុស្ស
ទៅ ហេតុអ្វីក៏ក្លាយទៅជាស្វាវិញ ; យល់ខុសប្រពៃណាព័ត្បុណាពេក
ណាស់ ។ ទើបព្រះសុខន្តសមណៈស្រែដីថា ម្ចាស់ទ្រង់សក !
មនុស្សក្លាយខ្លួនទៅជាស្វាគ្រោះអំពើអកុសលខ្លះតើ ! សូចេ ឯ
សង្ឃសិ ថាបើ អ្នកមិនជឿតាក្ស ចូរអ្នកសួរម្ចាស់ខ្លួនចុះ ។ ទើប
កុដុម្ពីក៍សួរស្វាថា ក្តី មម បុត្តោសិ ម្ចាសពាន ! អ្នកជា
កូនរបស់យើងឬ ? ។ ពាន ធ្វើយថា ន វ បុត្តោស្មិ បពិត្រអ្នក
ជាឪពុក ! ខ្ញុំនេះជាកូននៃអ្នក ។ កុដុម្ពីក៍លុះឮស្វាថាដូច្នោះ ឥតមាន
សេចក្តីសង្ស័យអ្វីឡើយ ដឿដាក់ថាជាកូនមែន ក៏កើតទុក្ខខ្លាមនស្ស
ខ្លាំងយ៉ាងយប្រការផ្សេង។ តាលតែសន្ទុះបាត់ស្មារតី លុះដឹងខ្លួនវិញសួរ
ព្រះសុខន្តសមណៈថា បពិត្រលោកម្ចាស់ ! អកុសលខ្ញុំម្ចាស់បានធ្វើ
ដូចម្តេច ? បានជាកូនខ្ញុំម្ចាស់ជាមនុស្ស ប្រែខ្លួនក្លាយទៅជាស្វាដូច្នោះ
តើមានពេទ្យហ្មណា ចេះធ្វើឱ្យប្រែទៅជាមនុស្សវិញបានដែរឬ ? បើ
ព្រះគុណម្ចាស់ដឹង មេត្តាជ្រាបខ្ញុំម្ចាស់ផង ។ តែសំ តាថេន្តាំ
នាគាលអ្នកចាំឆ័ត្រកំពុងនិយាយគ្នាដូច្នោះ, កាលនោះ ព្រះបរមគោតម-
សម្មា ព្រះអង្គមកដល់អាពមន្ទុះ គង់នៅក្រោមដើមឈើមួយ ឮសម្លេង

កុដ្ឋម្ចាស់កំពុងយំ ទើបចូលទៅកាន់សំណាក់ព្រះសុវត្ថសមណៈ ទមស្សការ
ហើយអង្គុយនៅ ។ ឯព្រះសុវត្ថសមណៈឃើញអាការបស់ព្រះចម-
ពោធិសត្វ ប្រកបដោយលក្ខណៈ៣២ និងអនុព្យញ្ជន:៨០ បានបូជា
កំដីនិងថា ព្រះមហាបុរសនេះ គាត់មានប្រាជ្ញាអាចពិភាក្សាក្តីរបស់
អញបាន គួរអញសំដែងហេតុទាំងភូតិទ្យាគាត់ដឹង តែតដូច្នេះហើយ
ទើបដំណាលប្រាប់ ហេតុដែលឈ្លោះប្រកែកគ្នាថា មហាបុរិស
បណ្ឌិតមហាបុរស ! ចូរអ្នកជួយពិចារណាក្តីរបស់យើងទាំងពីរផង ។ ទើប
ព្រះបរមពោធិសត្វសួរចំពោះកុដ្ឋម្ចាស់ថា ម្នាលកុដ្ឋម្ចាស់ ! ដំណើរដើម
ដូចម្តេច ? ចូរអ្នកប្រាប់យើងដោយត្រឹមត្រូវ ស្មោ ឥដ្ឋ ឥដ្ឋ ស្មើ
កុដ្ឋម្ចាស់ក៏ប្រាប់តាមដំណើរ ។ រីឯព្រះបរមពោធិសត្វជ្រាបហើយ
ពិចារណាថា រឿងមនុស្សដែលប្រែទៅជាបត្តូនេះ មានៈបីប្រព្រឹត្ត
អំពើទុស្សីមួយ, ហើយសួរទៅព្រះសុវត្ថសមណៈវិញ ។ ឯព្រះ
សុវត្ថសមណៈក៏ប្រាប់តាមដំណើរគាំងពីដើមមកដែរ ។ ទើបព្រះមហា-
បុរសតិចារណាថា :

" បើផ្លូវត្រង់ រឿងមនុស្សអ្នកដើរក៏ត្រង់ ថាបើផ្លូវរៀបរឿងមនុស្សអ្នកដើរ
ក៏រៀបទៅតាមផ្លូវដែរ ; បើមាសសុទ្ធសាធគាចក្លាយទៅជាទង់ដែងបាន
មនុស្សក៏គាចក្លាយទៅជាសត្វស្វាបានដូចគ្នា, នេះមកពីមនុស្សប្រព្រឹត្តអំពើ
រៀបវេរ " ។

ព្រះអង្គទ្រង់តិចតួចណាដូច្នោះហើយ ទើបត្រាស់សួរទៅកុដុម្ពិកនោះថា ម្នាលកុដុម្ពិក ! ឯមនុស្សគាចកន្ទុញលនោះ យើងដឹងហើយ, ប៉ុន្តែបើអ្នកចេះមន្តអាចសេពទន់ដែរ តើហ៊ានចូលទៅជិតព្រះសុខត្តសមណៈឬក្បាយទៅជាមាសបាន . យើងក៏អាចសេពមន្តវិជ្ជាធ្វើពានកូនអ្នក ឬក្បាយទៅជាមនុស្សបានដូចគ្នា ; បើអ្នកសេពទន់ដែរមិនបាន , ពានរនេះក៏សេពឬក្បាយទៅជាមនុស្សពុំបានដែរ ។ កុដុម្ពិកបានស្តាប់ហើយ លាវិលទៅផ្ទះវិញ ដំណាលប្រាប់ប្រពន្ធថា កូនយើងបានជាក្អាយទៅជាពានរដូច្នោះ ព្រោះអំពើអកុសលនៃយើង តែតយើងលួចមាសព្រះសុខត្តសមណៈ ដូច្នោះ ចូរនាងយកមាសទៅជាក់ដូចដើម យកទន់ដែរចេញ អម្ចាស់ បុត្តា មនុស្សក្អ កូនយើងនឹងបានជាមនុស្សដូចដើម ។ កាលបើប្រពន្ធយកមាសទៅជាក់វិញរួចហើយ , កុដុម្ពិកក៏លើកហិបទៅប្រគេនព្រះសុខត្តសមណ; ។ ឯព្រះសុខត្តសមណ; បើកហិបមើលឃើញមាសហើយពោលថា : ទន់ដែរក្អាយជាមាសដោយអានុភាពនៃការខៀតត្រង់, ឯមាសក្អាយជាទន់ដែរដោយអានុភាពនៃអំពើរឿងអាក់, ទើបសរសើរប្រាប់ ព្រះមហាពោធិសត្វដោយពាក្យថា " ការឃើញនូវព្រះអរិយទាំងឡាយជាការប្រពៃ , ការនៅរួមជាមួយសប្បុរសទាំងឡាយ . នាំមកនូវសេចក្តីសុខសព្វកាល, បុគ្គលដែលមានសេចក្តីសុខជានិច្ច . ព្រោះមិនស្និទ្ធស្នាលជាមួយពាលជនទាំងឡាយ " ។

រីព្រះបរមពោធិសត្វកំណើតព្រះសុខត្តសមណៈ ឆ្ពោះព្រះតក្រែវកាន់
ព្រៃព្រះហិមពាន្ត ។ ឯព្រះសុខត្តសមណៈ នាំយកភាន្តរៅលែងកន្លងព្រៃធំ
ព្រួចនិមន្តរៅកាន់ប្អូននៃញាតិរបស់លោក នាំយកក្មេងមកប្រគល់ឲ្យក្នុងផ្ទះវិញ ។
តោពិសត្តសប្ប តុណាឧកាវេធ សត្តាសប្ប ភវំ
ឧណ្ណាតោ ឧសេប្បសិ បតិត្រអើយ ! ឮដំណលនោះ រំពាសនានៃ
ព្រះឥន្ទ្រាធិរាជ កំសម្តែងនូវភាពរាក់ដាក់ ព្រោះអាទុកាតនៃគុណរបស់
ព្រះបរមពោធិសត្វ ទើបព្រះឥន្ទ្រាធិរាជបង្គាប់ព្រះវិស្សុកម្មថា៖ វិសសុ-
កម្ម ម្នាលវិស្សុកម្ម ! ឥឡូវព្រះសុរពកុមារជាតុន្នឹង មានព្រះ
ទ័យចង់បួស អ្នកចូរនិម្មិតបរិក្ខារនៃឥសាលាថ្វាយចុះ ។ ឯព្រះវិស្សុកម្ម-
ទេវបុត្រ ទទួលព្រះពាក្យរួចហើយ ហោះផ្លោះមកពីស្ថានទេវលោក
និម្មិតអាស្រមពុកក្តីរៃព្រៃមួយ, និម្មិតស្រះបោក្ខរណី ហើយនឹង ចប្រង្គ
ប្រវែង២៤ហត្ថជិតសាលា ចាក់ពោយពាយដីខ្លាច ហើយចារឹកអក្សរពុកថា
យេ យេ ឥសោ វ៉ែនទាំងឡាយណាមួយ ចង់បព្វជ្ជាចូរយកគ្រឿង
ប្រដាប់ទាំងនេះហោង, ស្រេចហើយព្រះវិស្សុកម្មបណ្តេញឥសីពួកឥសី
ម្រឹគាឡសាហាវ រួចហោះទៅកាន់វិមានវិញ ។ តស្មឹ ខណេ
តស្មឹ ខណៈនោះ ព្រះបរមពោធិសត្វទ្រង់យាងទៅដោយមាតិតមួយព្រះ
អង្គឯង ក្រេឡេកមើលទៅឃើញអាស្រមហើយ ព្រះអង្គចូលទៅដិតដំនឹងថា
សម្តេចឥន្ទ្រាធិរាជឲ្យមកសាងថ្វាយ ទើបបើកទ្វារមើលឃើញអក្សរចារឹក

ព្រះអង្គមានព្រះរាជហឫទ័យសោមនស្សពន់ប្រមាណ ទ្រង់ផ្ទាស់ត្រឿន
រាជកេរចេញ ប្រដាប់ស្បៃភ្លាំនស្បែកខ្លា ទ្រង់ប្រព្រឹត្តចង្រ្កមដើរទៅដើរ
មកពុំជាច់ សំដែងវិរិយាបថរបស់អ្នកបួសឲ្យប្រាកដ ទ្រង់លាន់ព្រះឧទ្ធ
ថា អហោ សុខំ អហោ បរមសុខំ "អ! សេចក្តីសុខ, អ!
សុខនេះជាសុខប្រសើរ," ស្រេចហើយព្រះអង្គគង់នៅទី១ រំពឹងគិតទៀត
ថា សេចក្តីសុខក្នុងរាជសម្បត្តិ នឹងយកមកប្រៀបផ្ទឹមគ្និបញ្ញាដូនេះពុំបាន
ឡើយ, បញ្ញាឈ្មោះថាពុំមានភ័យ ពុំមានឥន្ទ្រាយ ជាទីប្រាថ្នារបស់អ្នក
ប្រាជ្ញទាំងពួង, លុះតិចារណាដូច្នេះរួចហើយ ព្រះអង្គទ្រង់ចំរើនឱ្យព្រហ្ម-
វិហារ៤ បានលុះឱ្យសេមាបត្តិ៨ ឈានសុខ១ឧ វិហារសិ ព្រះ
អង្គនៅជាសុខក្នុងឈាន, ប្រការមួយទៀត ព្រះសុរពោធិសត្វទ្រង់
មានព្រះប្រាជ្ញាល្បីខ្ជាតក្នុងលោកដរាបដល់ឥតាមាវចរសូត្រ ។

ឧ កាលព្រះបរមពោធិសត្វគង់នៅក្នុងព្រៃព្រះហិមពាន្ត, មានស្រុក
មួយឈ្មោះឧត្តរកុរុ ទៅឆ្ងាយពីព្រៃព្រះហិមពាន្ត ទៅក្នុងស្រុកនោះ
មានពួកក្រានចំនួន៩០០ នាក់ ។ ឯកាលនិវសំ ក្នុងថ្ងៃមួយ ក្រានទាំង
នោះ កាន់អង្រែត ថ្នល់ សំណាញ់ចេញទៅនេសាទត្រី ។ មានក្រានម្នាក់
បង់សំណាញ់ទៅត្រូវក្តាមមួយយ៉ាងធំ គិតថាជាគល់ឈើ ទើបលោតចុះ
ម្តុជទៅក្នុងទឹកប្រយោជន៍ដើម្បីនឹងដោះសំណាញ់ ហើយយកដៃទាំង
ពីរកើបកន្ត្រាក់សំណាញ់ខោះឡើងពីក្នុងទឹក ឯអ្នកនៅក្នុងទូក កំដួយគ្នា

ខាញ្ចាំងពីខាងក្រៅ យកមកដាក់លើរូបស្រមៃតែយើញក្តាមឧយ៉ាងធំ កំ
ប្រែកហៅពួកព្រានចាំងអស់ឲ្យមកមើល ។ ព្រានចាំងអស់ លុះយើញ
ហើយ លាន់មាត់ទ្រហឹងគ្នាថា ក្តាមនេះធំណាស់ប៉ុ៎ ! យើងពុំដែលយើញ
ឡើយ ទើបតែយើញក្នុងថ្ងៃនេះ ។ លុះលួចត្រង់ក្រោយនោះទាំងយកក្តាម
មកផ្ទះប្រាប់អស់ពួកក្នុងភូមិភាំងឡាយ ។

ឯកោ កាសកោ គាលនោះ មានអ្នកស្រែម្នាក់
មកមើលក្តាមនោះ លុះយើញហើយ មានចិត្តមេត្តាករុណាស្រឡាញ់
ដូចកូនបង្កើត ទើបឲ្យប្រុងតែចាងដល់ក្រោយបំណាច់ យកក្តាមនោះទៅ
ដាក់ក្នុងស្រះមួយជិតផ្ទះ ។ ឯក្តាមនោះ ពុំមានភ័យអន្តរាយអ្វីឡើយ នៅ
ជាសុខសប្បាយក្នុងស្រះ ។ ថ្ងៃមួយចុះសោនោះចេញទៅស្តុកស្រែ យក
ក្តាមទៅជាមួយ លែងឲ្យទៅក្នុងទឹក ។ ឯក្តាមក៏ចេញពីទីដែលអ្នកស្រែ
ទុកឲ្យនៅ ទៅរកអាហារបរិភោគ ។ គាលនោះ មានក្អែកមួយ យើញ
ក្តាមហើយរកើរទៅជិតប្រាប់ថាកុំជាអាហារ ។ ឯក្តាម លុះយើញ
ហើយលើកជង្គើ្របទាំងពីរឡើងដើម្បីការពារខ្លួន ។ ឯអ្នកស្រែយើញ
ក្អែកដូច្នោះ ទើបលើកដង្ហួញឡើង ដេញក្អែកឲ្យហើរទៅ រួចយកក្តាម
ទៅដាក់ក្បែរខ្នែរស្រែដ៏ថា: ម្នាលក្តាម ! ចូរអ្នកទៅក្នុងទីជិតនេះចុះ បើ
អ្នកវារទៅឆ្ងាយ នឹងបានជាចំណីក្អែកហាន ។ ក្តាមឮដូច្នោះ ទើប
ស្រែដ៏ថា បពិត្រអ្នកមានបុណ្យ កាលក្អែកនោះមក ខ្ញុំដើរខ្លួនដៃរ ក៏ពុំអាច

ស៊ីខ្ញុំបានទេ, ថាដូច្នោះហើយ ក្តាមនោះក៏វាចូលចុះទៅក្នុងចំការថ្ម ១ ។
កាលនោះ មានក្អែកមួយទៀត ក្រឡេកឃើញក្តាមនៅក្នុងថ្មដូច្នោះ
ទើបលើកជើងម្ខាងឡើងឈរ ហើយឆ្មៀងក្អែកខ្លាំងហាមាត់គំតទំនឹងចំកក្តាម
នោះជាគាហារ ។ ក្តាមគិតថា ក្អែកនេះវាប្រុងចំកអញស៊ី អញដណ្តើង
សួរវាលមើល គិតហើយក៏សួរថា ម្នាលក្អែក ! អ្នកទំនឹងស៊ីយើងឬ ? បាន
ជាលើកជើងម្ខាងឆ្មៀងក្អែក ហាមាត់ដូច្នេះ ។ ក្អែកឆ្លើយដោយពាក្យ
កុហកថា ម្នាលក្តាម ! យើងមានសេចក្តីអាណិតអាសូរអ្នក បើអ្នកនៅក្នុង
ទីនេះ ទំនិរវិនាសខ្លួន ដោយសារអ្នកស្រែនេះ សម្លាប់អ្នកយកទៅ
ស្ងោរចង់រកតជាគាហារ យើងមកនេះ ក្រែថ្នាំទំនាំអ្នកទៅឯព្រៃព្រឹះ
ហិមភាន្ត ប្រសិនបើអ្នកទៅកាន់ព្រៃហិមភាន្តទំនឹងបានសេចក្តីសុខច្រើន
ក្រែសចាកភ័យគាំងពួន ព្រោះជាទីក្សេមក្សាន្ត ។ ក្តាមស្តាប់ហើយពុំ
ដឿសោះ ឆ្លើយតបថា សំដីរបស់អ្នកពុំសមសោះ ព្រោះអ្នកក្លែវស្រែនោះ
ជាឪពុកធម៌របស់យើង ឪពុកទំនឹងមកសម្លាប់កូនដូចម្តេចកើត អ្នកកុំ
ស្រដីដូច្នេះឡើយ បើអ្នកស្រដីទំនឹងយើងដោយត្រង់ យើងទំនឹងតាមពាក្យ
របស់អ្នក ។ ក្អែកឆ្លើយថា នែកូយ ! យើងពុំជាអ្នកកន្ទុតាលដូចក្អែក
ដទៃទេ. យើងឃើញអ្នកនៅក្នុងចង្រឹតនេះយូរណាស់ បើអ្នក
នៅទីនេះមុខជាទំនឹងស្លាប់ តស្មា ហំ តំ អាជាយ ព្រោះហេតុនោះ
យើងនាំអ្នកទៅឯព្រៃហិមភាន្ត ឲ្យអ្នកទៅមើលស្រះធំ អ្នកកុំសង្ស័យឡើយ

តំយភ្លាចឡើយ ។ ភ្លាមស្តាប់ហើយឆ្លើយថា ម្នាលក្អែក ! បើអ្នក
និយាយពិតយើងនឹងទៅជាមួយអ្នក ប៉ុន្តែ យើងចង់ដណ្តឹងប្រស្នានឹងអ្នក
សិនមើលបន្តិច ចូរអ្នកឆ្លើយកុំខាន ។ ក្អែកឆ្លើយថា រមនុស្សគេមាន
ប្រាជ្ញា មេធាវី ដឹងក្នុងប្រស្នាទើបដោះបាន យើងជាតិសត្វតិរច្ឆាន
មានប្រាជ្ញាតិច ទីណាដោះស្រាយដូចម្តេចបាន ។ ភ្លាមឆ្លើយថា អ្នកឈប់
នៅទីនេះសិន យើងនឹងទៅប្រាប់សេចក្តីដល់ម៉ែឪយើង ថាដូច្នោះ
ហើយ ក៏ទៅដល់ស្រែដំកង់ថា បពិត្រម៉ែឪ ! ក្អែកនោះ នឹងនាំខ្ញុំទៅ
ព្រៃហិមភាន្ត ខ្ញុំនឹងលាម៉ែឪទៅព្រៃហិមភន្ត ប៉ុន្តែ ខ្ញុំស្មុគស្មាញនឹង
ក្អែកនោះលើសើល បើកស្រាយបានក្តី តុំបានក្តី ខ្ញុំនឹងលាម៉ែឪទៅ ។
ឯបុរសនោះ បានស្តាប់តាក្សក្តាមហើយពោលថា យថា សុខំ
គច្ឆសិ ចូរទៅទៅកុំឲ្យបានសេចក្តីសុខសប្បាយ យំ យំ ទុក្ខសិ
បើទៅក្រាញ់អ្វី ។ ចូរសម្រេចតាមក្រាញ់ ទុក្ខ សោក ភេត តំយ
កុំដាច់ដល់ទៅឡើយ ចូរទៅឈ្នះអស់សត្រូវចំនឹងឲ្យាយ ។ រីឯក្តាម
កាលបើបុរសនោះគន្ធាតហើយ ក៏ទៅកាន់សំណាក់ក្អែកវិញ ពោល
ថា ម្នាលក្អែក! បើអ្នកស្រាយប្រស្នាយើងបាន យើងនឹងទៅជាមួយ បើ
ស្រាយពុំបាន យើងមិនទៅនឹងអ្នកឡើយ, ម្នាលក្អែក ! ប្រស្នានោះ
ដូចតទៅនេះ ៖

(មានត)

រឿងបាដ្ឋយន្ត

(តទៅ)

លោក អ៊ិម-ភន បម្លែងពីសៀមជាខ្មែរ

បទកាលកត្តិ

កាលនោះព្រះបាទ សម្តេចនរនាថ យល់ព្រះប្អូនភ្លា ឈឺទ្រហោ
ណាស់ ញ័រអស់កាយា សម្តេចពាដា ថប់ព្រះប្អូនវត្ត ។ ព្រះអង្គ
ឋបក់ ត្រសឹងនៃអ្នក ប្អូនមាសស្នេហ៍ស្និទ្ធ ក្សិណាក្សត្រឱ្យកន្ទួល ដង់
អួលអាណិត ព្រះប្អូនតោកក្តាត់ សែនសោយសោក ។ ទ្រង់ព្រះកន្ទែង
ខំបន្ទូលថ្លែង ន្ទូវគំនួញថា ប្អូនមាសបង ម្តេចម្តងនេះណា យើងមក
កំព្រា លំបាកតោកយ្រ ។ តែបងនឹងប្អូន មកសំរាលកូន កណ្តាល
ទ្រូងព្រៃ ឥតអ្នកណាមួយ ទឹងជួយឡើងនៃ ជាធ្វេចកាន់ផ្ទៃ ប្អូនមាស
ឡើយហោង ។ នៅស្រុកនាយក៉ា ព្រះអយ្យកា ព្រះអយ្យកោរងឆ ព្រះ
ជនកជនី បេតស្លួនគ្រង់ អស់ញាតិផៅងឆ ចោមចាំរក្ខា ។ ខេះ
ខ្លះអស់ញាតិ លំបាកសល់ខ្លួន កណ្តាលតូច ប្អូនកំសត់ ឥតច
អត់ទៅរក៉ា យើងរងវេរ កម្មវិបាកបាន ។ ចើរនៅស្រុកនាយ បងមាន

អ្នកម្តាយ អ្នកជាប្រធាន អស់ញាតិកា វង្សាបន្តាន មើលមាស
គល្យាណ ថ្នក់ថ្នមចិត្រ ។ ខ្លះតែងកេងាំ រកឆ្មបមកចាំ មិនមានឲ្យក្រ
ខ្លះកេមេមត់ ខ្លះត់ភៅក៍ អស់តាំងតេឲ្យហ្ន មានថ្នាំធាប់ធុត ។ ការ
ភ្នោចបិសាច ការអស់តាំងពា ជតូតក្រាតជ តេឲ្យស្ទុះធ្លូនស្តាំ តេឲ្យ
ថ្នាំបរិសុទ្ធ ខ្លូវអស់មេមត់ សែនត្រេនលៀងស្ងា ។ ខ្លះសោតសឹង
ស្រេន អង្វរហើយបន់ ភ្នោចនឹងគ្រីហា ខ្លះសោតត់រក ហោរមកម៉ីម្ចា
លៀងតាយជាតា តន់គួរថ្កតា ។ ខ្លះសោតសឹងភៅ រកដាំខឹតក្តៅ
ស្រេងប្លន់សង្សារ ខ្លះរកមេនំ ស៍ក្តិសមសក្តា រក្សាកុមារ មិនឲ្យមាន
ហ្នាង ។ ឥឡូវតាកយ៉ាក យើងមកលំបាក កាលគ្រានេះម្តង ត្រូវមាច
ស្រេះសួរឲ្យ តែប្លន់ងឹងបង មកកណ្តាលដង ត្រៃត្រូវចាំមភាន្ត ។ ឥត
ញាតិជៅជង តែប្លន់ងឹងបង ម្តេចឡើយមកមាន ដម្ងីមហាច្ងន់ តេក
ត់ន់ប្រមាណ ធ្វើម្តេចនឹងជាន រួចឥឡូវតើយ ។ សម្តេចពជា សែន
សោយសោក ណាស់ណាស់ពុំស្បើយ ទាំងនាថទេវី សឹងពិលាប
ហើយ ក្សត្រាត្រាណត្រើយ លោមយាគប្លន់តេន ។ ត្រូវងឹងបងតើយ
កុំសោយសោកឡើយ ព្រៃនេះហានស្ងាត់ ក្រែងភ្នោចបិសាច ពាជតូត
ឮមាត់ ប្លន់មាសប្រមាត់ ភាលៀតចំខ្លា ។ ប្លន់ហើយឥឡូវ ឥតតេឲ្យ
ណានៅ ចេះមន្តគាថា ការភ្នោចបិសាច ពាជតូតនាយា ទាងតើយ
បងមហា ថ្លង់តន់ប្រមាណ ។ ហាក់ដូចអ្នកយក កុំសុម៉ៅមែក សង្កត់

លើប្រាណ បងធុញថប់ថៃ ឥតឯស្រាកស្រាន្ត ដ្បិតប្អូនមាសមាន
ជម្ងឺនេះម្តង ។ ប្អូនអើយហេតុវ៉ា- ចាកយើងនំតា បុពាណជាតិផង តាម
មកពាល់ឮ នាព្រៃនេះហោង អាចឲ្យយើងវង ខ្ញុំទុលំពុំក្សាន្ត ។
ថ្នេអ្ហើបងម្ចុះ ជម្ងឺប្អូននេះ មកខ្ញុំឯប្រាណ បងនឹងឈឺតាង ឲ្យនាង
ស្រាកស្រាន្ត ឥតលុះពុំបាន ឯជ៏ឥឡូវអើយ ។ ចូរប្អូនមាសអត់ តាម
ភ្លើកំសត់ យើងណាប្អូនអើយ វៀតព័ត្រើត យើងឯងផ្តល់ហើយ ព្រ-
លឹងមងអើយ ចៀសចាកតុំបាន ។ នាងនារីរតន៍ ស្តាប់ព្រះរៀម
ឃាត់ នាងនាថកល្យាណ តាចអត់ជម្ងឺ នាងឈឺក្នុងប្រាណ
ហាក់ហើយស្រាកស្រាន្ត នាងតុំសោតា ។ សម្តេចកូដរ ថ្វាថ្លែង
អង្វរ អស់ពាំងទេវតា ខ្ញុំវាខ្ចោចបិសាច ពាជកូតធងណា ស្តេចសូត្រ
គាថា ប្រសើរទត្តមោ ។ អ្នកថាតន្តេ ទេវសព្ទ វ៉ាសិទ្ធិតោ
សោឡសសតំ ហាំវាទា ថលចព្វាតា ចិសាចសតូ ។ យាចិសម្ភ
នាសិទេវ៉ា មហាខ្ញុំតំ ដយដយា ខ្ញុំនាតាយំ ខំរទិប្បំ ឥតនិយ ។
បតិត្រទេត្តា អ្នកបិតនៅនា សោឡសវិស័យ តោះអ្នកបិតហាន ហ៊ាម
ពាន្តនាយនៃ សឹងសត្វព្រឹក្សព្រៃ ស្រះស្រង់តង្គា ។ សូមអ្នកតាំងតោះ
ជ្រោមជ្រែងដួយដោះ ខ្ញុំតយើងហោងណា គ្រានេះឲ្យបាន ស្រាក
ស្រាន្តខ្ញុំភ្លា ឆុតឆាប់ប្រសង្រ្គា- កដតាលនេះម្តង ។ ខ្ញុំវាតស់ចិសាច ពាជ
កូតផងតាច ថ្មេបិតនៅហោង ដោយដងហ៊ាមពាន្ត រ៉ាហាននេះហោង

កុំប៉ះអ្នកឯង ចិត្តបៀតចិន្តា ។ សូមអ្នកមែនមាន ចិត្តចិន្តាថ្កាន ជ្រោមជ្រែងរក្សា
ជ្រួតយើងតោកយាក លំបាកណាស់ណា តែព័ត៌អង្គ៌ា កណ្តាលព្រៃព្រៃ ។
ស្តេចសូត្រគាថា អង្វរខ្លោច អស់តាំងខ្មោចព្រៃ ខើបព្រះកូមិន្ទ ខន្ធ
ដៀស្ដង្ហ មានព្រះហឫទ័យ ទ្រង់ព្រះចិន្តា ។ ផ្តង់ព្រះស្មារតី សម្តេច
តូម៌ ចំរើនភាវនា តាះខ្មោចបិសាច ក៏ដកូតអាយា ស្តេចឃុកធម៌ជាំ
តំនាក់សត្វថ្ងៃ ។ តែដ៏សម្ភារ សម្តេចតូបាល ទ័ណ្ឌទាន៏ទាថនៃ បាន
សាន៏ពីមុន មកនៈច្រើនក្រាស់ក្រៃ ត្រេះគុរម៌ថ្ងៃ ថ្ងៃរឹទ្ធិ៏តុំបាន ។ រ
កូណោះណា អ្នកនៈន៏នាថជា គន្ធ៏គន្ធកសព្យាណ ប្រសូតកជបុត្រ
បរិសុទ្ធប្រុបប្រាណ រួមបរិបូណ៌ដូន ចេញាចាកទ្រវ ។ បុត្រគេន៏ត្រកូល
ដូចតែវត៌ព្យ ថ្នាំថ្លៃបវរ ត្រេះតន្ត្រ សាត៌ណ ដូចបន្ទូលែនឯ ឮពាអម្ពរ
ពាលគេញាបូណ៌ម៌ ។ ប្រកបតើតមក ជាបុត្រពន្ធុក ត្រេះជនកជនន៏
ត្រកាលត្រកូល អម្បូរជាត៌ តើតកបអស់ន៏- សូរសេមសោភា ។ កូណ
នោះត្រេះអង្គ ជនន៏តមកស្រង់ ត្រេះកន់បុត្រា ស្រង់តាំនខេត៌ កូត្រី
កញ្ញា សាយសត្វអង្គ៌ា ជាស្រេចឫទ្ធត់ឆ្ងាន ។ នាងនាថរ៉ា ដោយស្រង់
គង្គ៌ា ត្រជាក់នោះហោន នាន៏ថ្វាយបង្គំ ប្រណម្យកបាន អង្វរត្រេះ
បន ត្រេះជាទកូម៌ ។ បភិត្រអង្គាស់ ខ្ញុំរ៉ាណាស់ ញ៉ាអេស់ឥន្ទ្រិយ ពល
ពប់តុំបាន សូមតានតូម៌ ស្តេចកេអគ្គី ឲ្យខ្ញុំអាន៏ក៌ ។ ពន៏ព្រះខ្ញុំវ ស្តាប់
ព្រះប្អូនខូល ស្តេចៈសោយសោភា ណាស់ណាស់ន៏តិត គាណិត

អនាថ អាសូរប្អូនភ្លា ពេកពន់ប្រមាណ ។ ស្តេចទំបន្ទូល នុប្អូន
បណ្តាស ធ្វើម្តេចនឹងបាន ក្តៅឆ្ងល់ប្អូនស្ងួន ខ្ញុំមខ្ញុំនអាណ្តាណ
ដែតក្តៅសោតគ្មាន សូន្យរសោះទេណា ។ មាសអើយពីហាន ព្រៃ
ព្រៃហិមពាន្ត ទៃត្រខ័ណ្ឌកន្ត ដុះដោយរបោះ បន្ទោះព្រឹក្ស សឹង
បន្ទន់ក្រឹស្ម ឥតមានក្រសោះ ។ ស្តេចស្តែងតេវ ឃលៅក្តៅភ្លឺវៅ
នាគត្រានោះ កណ្តាលសម្ភុខ ច្រកដស្មានស្មោះ ស្តេចចំគ្នាឆ្ពោះ
យកក្តៅនោះណា ។ សម្តេចភូមី ថ្នមព្រះអង្គស្រី បន្ទូលផ្តាំថា
ទៃហប្អូនព្រលឹង បងនឹងលីលា ទៅថ្ងាខេត្រា យកក្តៅនោះហាន ។
នុប្អូនមាសថ្លៃ សូនអើយនោះនៃ ខ្ញុំមខ្ញុំនស្នេហ៍ស្នង នាងនៅនឹងកូន
ណាបន្ទមាសបង បងអ្នកនឹងផ្តន្ត វិលវិលឆាប់ណា ។ រីឯនាងនាថ
នុនុបព្រះថ្ងាច ទៀនទូញទូលថា សូមព្រះអង្គឆាប់ ក្រឡេបមកភ័
អ្នកអើយប្អូនយហា ខ្លាចតន់ពេកវៃក្រ ។ ខ្ញុំនៅឯកឯង ត្រមោច
កណ្តែង កណ្តាលទ្រនៃព្រៃ កុំបីព្រះអង្គ ផ្សារផ្សងល្បើយនៃ ស្តេច
ឆាប់វៃ ។ កុំយូរឡើយហាន ។

បទត្រឡប្បគីតិ

កាលនោះព្រះភូមី ផ្តាំប្អូនស្រីស្រេចឥតឆ្គង ស្តេចតង់យន្តហោះផ្សែ
លុះកណ្តាលអាកាស ។ ធៀបឆាប់ខន់ឫបៅ ស្តេចសំដៅដល់

តេត្រា ព្រះហស្តថ្វៃប្រាំ ចាប់អង្គុត់នៃអគ្គី ។ ឋានហើយហោះម្ខ
ម្នា ពីតេត្រាចរចេញទៀ ព្រះហស្តតាន់អគ្គី ដាក់លើយន្តហើយហោះ
ផ្សឹង ។ ឯអស់អ្នកតេត្រា តិតតាមផ្លើលអីឯតឯ ស្ទើរតែកូតតេត្រា
ជង ស្រែកបង្គើលអីឯត្រួបគ្នា ។ ឯអង្គព្រះភូមី ឋានអគ្គីពីតេត្រា
ដាក់លើយន្តនោះណា ព្រះករតាន់តើចយន្តហោះ ។ រីតែកើងមិញ
ត្រូវឡើល នេះដួចដល់ឡើយន្តនោះ នេះចាំងឡើងបាន្សហោះ នេះ
ឡើស្ទាបសងខាងណា ។ យន្តមាសមិញរេដោះ រុះជ្រាក់ប៉ុះកង
ង្គ្រាំ សម្តេចត្រះពជា ជ្រាក់កងតាលនោះឯងនៃ ។ ហង្សយន្ត
មិញសោតសាត់ អណ្តែតឋាត់ភ្នាត់ទីនៃ ពីត្រះឋានជ្រាស្តជ័យ
ដោយទឹកហូរឡើលជាត់ទៅ ។ តាលនោះពោធិសត្វ លំឋាកក្តាត់
តាលជ្រាក់ទៅ កណ្តាលសាគរត្រៃ សាត់ត្រាក់តិដ្ឋន្តមាសមៃ ។
ស្តេចហែលហើយសោយសោក សោកអមោក្សត្រង់តេកត្រៃ ចង្អៀត
អស់ហឫទ័យ រៃឯតានតឹងចរតន៍ ។ ផ្លូកផ្លើកក្សត្រឡើកឡើល ឯង
អង់អួលអួលតាណិត ទ្រង់ព្រះតឡើងក្តាត់ ខ្លួនខ្លួញដោយតាក្សចាំ ។
ទុះញាឋានយន្តហោះ ដោយមណ្ឌលត្រះវិហាស៍ ឥន្ទ្រយន្តនោះ
ណា ជ្រាក់កងទឹកសាត់ឋាត់បង់ ។ ម្ខើរហើយសមអញក្ស័យ
តាលខេរនៃតិតភ្លុំលង់ អសារតេណ្តាលកង ម្ហាសមុទ្ទខេរឯង
ណា ។ តោះបើអង្គអញមរណ៍ កង់សាគរតម្ពក ពុំឃ្លាខ្លួន

ឡើយណា តិតអាសូរតែប្អូនស្រី ។ ខ្ញុំនតន់ពន្ធុក សង្ឃឹតមក
បង់ចុរី បង់ទាំងព្រះជន្ម ត្រូវជនកនៅនាយធង ។ ហេតុដូច្នឹតប្អូន
មាសថ្ងៃ - ខាងអាល័យអាឡោះបង់ ខ្ញុំឥឡូវម្តេចម្តង ខេះបងបង់មេ
មាសមិត្ត ។ ឧសារសោះមកមរណ៍ កូនិសាតខេះឯងឥត ដំណួច
ដំណឹងពិត តុំចុះដង់ដល់ប្អូនភ្លា ។ ខ្ញុំកូរពៅផ្តែផ្តាំ ខេះបង
ចាំ ចាំក្តាត់ណា តុំឃើញបងលើលា ខាងវែងសែនសោយសោក ។
តិលាចអស់ចិត្តប្អូន ហើយនាំកូនយោនយោគ្រា ដើរដោយដងមាតា
តុំជើងជំបន់ទិសទី ។ ខ្ញុំមាសត្រលឹងបង តុំដែរមេដើរឯងដោយដី ឥឡូវ
ខេះប្អូនស្រី មកលំចាកដូចខ្លួនបង ។ ខ្ញុំអាសូរប្អូនក្មេង តុំដែលដឹង
ខ្លួកកំយាធង ទើបតែគ្រាខេះម្តេង មាសមេមកលំចាកក្រៃ ។ បងនិតមួយ
ខ្លាចក្រែង ឧ.ន.រង្វើងកណ្តាលព្រៃ សមដើរហតហាលថ្ងៃ ជាតុរតង
ជាតន់ ។ ប្អូនអើយបងបាច់ថៃ ឈឺឥតឯស្រាកស្រាន្តស្រួន ខ្លួក
ផ្ទើះអួលអង្គកន់ ឥតឯសើយដល់តិចណា ។ មួយឈឺប្អូនបណ្តាល
មួយអាសូរឈឺចុគ្រា ខ្លួនស្ទុនពុំងា ជាកើតមកលំចាកក្រៃ ។ ខ្ញុ
ចុគ្រាសំឡាញ់ ប្រសូតចេញ-ចេញតិថ្ងៃ មានរៀងក្នុងព្រៃ ព្រះ
ហិមពាន្តហ៊ានត្រីក្សា ។ កាលនោះឯអាពុក ជាន់យល់មុខ.មុនជាក់
រំលេចតុំលន់ណា ហើយអាពុកប្រែប្រាសបង់ ។ ជាបុគ្រស្ទុនច្បូមថ្ងៃ
មកមរណ៍ក្សីយ-ក្សីយលិចលង់ កណ្តាលប្រភ៉ាលក្នុង មហាសមុទ្រគម្លាក

អាពុកពុំគិតខ្លួន គិតតែប្អូន-ស្ងួនកំព្រា ព័ទាក់ទិរ៉ាមា នៅវាព្រះ
ហឹមភាន្ត ។ ថ្ងៃនេះអាពុកប្រាស ប្រាសទៅកសបុត្រកល្យាណ ម្ល៉ះ
ហើយសមពុំបាន យ៉ាម្ដុំកូនភន្ទកឡើយ ។ អាពុកគិតទៅគ្រប់
គ្រង់ហើយថប់-ថប់ពុំស្បើយ ខ្លួនអាពុកអើយ អាពុកថប់ពេកច្រើនក្រៃ។
បំណាច់មាសភន្ទក បាត់បានមកពាច់ចង - សន្ទិដ្ឋក្រុងប្រើយ លែងអាពុក
បានក្សា ។ ថ្ងាក់ថ្នម-ថ្នមផ្ដេកដួត ឲ្យសង់ចិត្តអាពុកក៏ សន្សឹមប្រាស
ឃ្លាតឃ្លា តាមដោយកម្លាំងពុកបាន ។ ម្ដងៗសោតៈពាះប៉ៈប៉ៈ បាប
តំពីពុកណាត្រង់ ក្រែងយើងតាំងពីបាន ធ្វើអំពើអំពាល់តិត ។ ពេញខ្លួ
តៀតែម្ដ ខេះបងចាំដាយកំហិត ទឹងផ្ដល់ផ្ដាច់ដីតែ ឲ្យក្បីណាក្បួយ
នៃដន្លា ។ តាំងនេះហតុតែកម្ម បងមកតាមពាន់នេះណា ឲ្យប្រាស
ប្អូនតុំវ៉ា កណ្ដាលព្រៃណាទាំងអើយ ។ ម្ល៉ះសមមាសត្រលឹង តែង
ខ្ទឹង-ខ្ទឹងហើយ មើលផ្លូវភ្ញាំយល់ឡើយ គិតស្មានបងរួចទៅបាន ។
មិនដឹងជារឹងមាំណ៎ា ក្នុងសាតនៃម្ដាយ ខ្ញុបងអាសូរហៅ ជាមេម៉ាយ
ឯងកំព្រា ។ តែព័ទាក់ទិងកូន ស្ងាត់សោះសូន្យក្នុងអង្គា ខ្ញុបង
ប្រណីណា ក្រែងសត្វម្ដ៉ាយងាប់ឃ្លងផង ។ ពាំដើរមកតាមឋានៈ ជួបប្រទះ
ប្អូនមាសបង ទឹងកូនតន់ប្អូនត្រង់ ក្រែងវាចាប់បរិកោក្ដា ។ មួយ
សោតក្រែងត្រជាក់ រងាអ្នកមាសស្ងួនភ្ងា ដោយឥតអគ្គីណា សម
ប្អូនតែឯងឯកអង្គ ។ នៅព្រៃព្រឹះហឹមភាន្ត ខ្លួលខ្លាហានឆ្នេរស្រះស្រង់

សោះសូន្យដីវាតបង់ ដ្បិតកំសត់វែងគំគ្រា ។ ឧបុដ្ឋនមាសថ្លើមថ្លៃ
ក្រែងប្អូនក្សីយ១ជន្ម ចាន១បង់នៅទូក បងនឹងលើកសពប្អូនស្រី ។
ស្រេចហើយបងនឹងក្សីយ ផងមាសថ្លៃរពេចខ្ញុំ ទាំងបុត្រស្ងួនភ្ងាប្រិយ
បងបូណាមួយនឹងគ្នាហោង ។ ឥឡូវម្តេចប្អូនមាស មេត្រាសត្រាត់បម្បែង
បង ស្ងួនអើយតែនេះម្តង បង៏ថប់ថែអន់អួលផ្សា ។ ឈឺធួលធៀបស្ទើរ-
នេះ ហក់ហើយស្ទើរប្រុះទក ដូចអ្នកយកកាន់ថ្វា កាន់កាត់កូវពុត
តោះបង ។ តោះឈឺដោយតិរខាន់ តុំឈឺដូច្នេះជាម្តង ដ្បិតត្រាសប្អូន
ស្នេហ៍ស្ងួន តិបងឈឺពន់តេកណា ។ ប្អូនអើយបងតិតណ្ដែង មួយ
សោតក្រែងអស់តេតា សោកៈជ្រាមក្រែងក្សោ ឲ្យប្អូនមាសមានបុត្តិ ។
ទឹងបុត្រស្ងួនសង្សារ នៅកណ្តាលព្រៃទួរៅ ឧបងប្រណីចៅ សមរស្បើម
ស្ងាត់ឯងហោងណា ។ សមប្អូនខ្ជិនក្តាត់ ចាំបង់ចាត់ពន់វៀ
តាលកលសោយសោក ពិសោយលន់តន់តេកព្រៃ ។ សូមប្តីបុត្រពន្ធក
ហើយរត់រកដោយជង្រៃ នេត្រនាងតតីរំពៃ ឯអាកាសវៀហស៍ផង ។
សមរកសត្វហានព្រៃ ហ៊ឺមតាន្តរជ្រោះជ្រលង អស់ចិត្តប្អូនហើយហោង
សមប្អូនមាសទឹងមណា ។ សូមមួយមួលចាំងថ្ម រំពេចខ្ញុំព្រមផងគ្នា
កុំឲ្យត្រាសឃ្លាតឃ្លា ចាកចម្បែងដូច្នេះនៃ ។ សម្តេចព្រះពជ្រ សោក
ឈឺផ្សាបុត្រាថ្លៃ នៅកណ្តាលត្រះព្រៃ ទឹងថ្លៃងថ្លឹងពុំបានណា ។ នេះ
ទើបស្តេចខ្ចីញាតិ ព្រះជនកទឹងមាតា ព្រះទុស្ខថ្លៃថ្លែងថា ឧអម្ចាស់ចាំង

ព័រតង្ស ។ កាលកូនយាត្រាមក ព្រះបិតាមានតម្រង់ កន្ទែងទាំងព័រតង្ស
ទុបផ្តែភ្លាំះហ៊ីយផ្តាំផ្តិត ។ ពាក្យអ្នកទាំងព័រផ្តាំ នោះកូនចាំ។ទៀងទាត់
ទ្បែកូនធាប់លែងថ្ងាត់ កុំឲ្យយូរលេងទ្បើយណា ។ អ្នកអ័យឥឡូវកូន
អសារសូន្យក្នុងតគ្នា ហង្ស្យែយន្តមិញយ្ងាតយ្ងា ជាប់ភាត់ចាត់ចង់ហើយ
ណា ។ កាលកូនភ្ញុំចាន់ ថ្ងាន់ត្រូវទៅទាំងព័រទ្បើយ សមកូនលុះដល់
ត្រើយ ត្រូវម្ចើតិ៍ឃ្លះទៅហាង ។ ឧត្តមមានគុណ គុ.ណមហាចន្ទ់ាកន្ទួង
ម្ល៉ះកូនភ្ញុំចាន.សង ព្រះគុណទាំងព័រនេះទ្បើយ ។ ហោតុបាបពៀរព័ត្រែង
តម្រាបសំកូនមកផ្តល់ហ៊ីយ តម្ងាស់ថ្ងៃកូនអ័យ កំកូនតិតភ្ញុំចាត់ណា ។
សៈម្តេចព្រះភូមី ហៃលដលធ័តំមង់ដា ប័ទ្ធនទ្បែងក្រាសក្រា– កដនៅប
ពត្រែដង ។ ព្រះអង្គលើកទសកវ ថ្ងាត់ថ្ងាបវាវៃខ្លាដង្គង ជាក់លើព្រះសិរ
ហោង បង្គំគុណព្រះតេន៍ត្រៃ ។ មួយតិតគុណព្រះពុទ្ធ ជាមកុដប្រ-
សើរក្រៃ ខ្ញុំគុណព្រះធម៌ថ្លៃ ខ្ញុំគុណព្រះសង្ឃសោតហោង ។ ខ្ញុំ
គុណអស់ទេព្តា រៃងក្បាសម្ភុដង្គង ខ្ញុំគុណមាតាត្រង ខ្ញុំគុណព្រះ
វៃបិតា ។ ហើយព្រះអង្គក្រៃវែង តែងចំរើនធម៌ការនា ស្តេចយកព្រះ
ធម៌ជា ត្រើយទាំងាក់ព្រះអង្គហោង ។ តេជៈព្រះធម៌ថ្លៃ ក្សត្រែជៀស្ត
ជ័យក្បាត្រង តស់ទាំងទេព្តាធង រួមក្បាព្រះនរោថ ។ មួយសោត
ព្រះចារម៉ែ ស្តេចសាងព័ត្បុណជាតិ ជ្រោមជ្រែងជួយព្រះចាខ ច្រាកដ
កាលខេះឯណ៎ះហាង ។ ក្សត្រាណានោះនាយតេត្រា ខ្ញុំអស់ញាណិជខោះដង

នាំនាយកេត្រាច្បង់ ឈ្មោះហៅសម្ដេចគោបរ ។ បើកការកេត្រាត្រង់
យល់ព្រះអង្គកន់សាគរ ឯនាយកេត្រាអរ ឱ្យកូនឈ្មួញចុះសម្បាំន ។ ៧
ស្រង់ព្រះពោធិសត្វ បុរសតន់ដួចឡើងជាន ដល់ជាក់លើសំបាំន
ហើយនាំទៅដល់កេត្រា ។ ឯនាយសំពៅសង់ សួរដណ្ដឹងព្រះរាជ
អ្នករើយហេតុអ្វីណា តំអ្នកមកហែលដល់ង៉ា ។ ត្រូវមានលំបាកច្រើណា
ចេះហេតុមានប្រការអ្វី ចូរអ្នកថ្លែងពិតប៉ា ដំណើរនោះច្រាប់ឃើញ ។
ក្សត្រិណានោះព្រះជៀសជ័យ ស្ដាប់ស្រមៃនាយកេត្រា ខៃទើបព្រះរាជ
បន្ទូលច្រាប់ដំណើរតែ ។ កំណើតព្រះអង្គជា បុត្រក្សត្រាត្រង់ចុះ
ច្រាប់តាលព្រះភូមិ៍ ចេញចាកតីព្រះនគរ ។ ច្រាប់តាលព្រះអង្គចាន
នាងកល្យាណនាំចេញចរ តាប់ដួនឈឺទរ ឈប់ប្រសូតរាជបុត្រា ។
នៅតណ្ដាលព្រះព្រៃ ក្សត្រថ្លាថ្លៃច្រាប់តាលត្រា ស្ដេចតងីយន្ដយាត្រា
មកយកកូនតីសំពៅ ។ ច្រាប់តាលព្រះភូមិ៍ ចានអគ្គីហ៊ោយហោរ
ហៅ ច្រាប់តាលព្រះចមរចៅ ដាច់យន្ដខ្ទាក់កន់សាគរ ។ ស្ដេច
ច្រាប់អស់សេចក្ដី សព្វឥតចន្លះឡើយណា រឯនាយកេត្រា ន្ទូវអស់
ពាំនឹកូនឈ្មួញជន ។ ចានស្ដាប់ព្រះតេជបុល ច្រាប់ប្រការដូច្នោះហោន
ហើយចរចាឥតឆ្គង សឹងតាសួរព្រះរាជា ។ ឯអង្គពន្យល់ពោធិ - សត្វវរ-
រិសេសសោភា នៅខ័ណនាយកេត្រា ស្ដេចពុំគិតតួព្រះអង្គ ។ គិតតែរាជ-
យោ ខ័ណបុត្រក្សត្រិយ៍ច្រាសបង់ ស្ដេចគិតហើយស្ដេចទ្រង់ ព្រះតម្រិះ

សោកពេកណា ។ ពុំដែលឡើយហៅមាន ស្រាលស្រាកស្រាន្តពីទុក
ព្រះអង្គសោយសោក ជាទិន្នន័យរៀងមកហោង ។ កាលនោះមានកេត្រា
មួយទៀតណាបើកទ្វារចំទ្វង ដោយតឿនដែលកន្ទុង កេត្រាបំឆើលាបរ។
ឯនាយកេត្រានោះ ដោយនាមឈ្មោះហៅសាន រាណាំដនោះចើរបរ
ទំនិតអស់ក្លូនឈ្មួញជង្ហណា ។ បើកសំពៅទ្វង្វាស់ យល់ហង្សមាសក្នុងគង្គា
រើសយកឡើងម្ដងម្នា ជាក់លើសំពៅនាវៃ ។ យល់ហង្សមាសតិចត្រ
ត្រេកអរក្តោងតន់ពាកក្រៃ យកវិកទិសរិសេច ពុំទីដឹងហោះដោយរហាស ។
ដំណើរភោជនីសត្វ ប្រុសតេន្ទជ័រកេជា នៅទីដនាយកេត្រា យើងឈប់
សម្រុះនៅនេះឯង ។ ហើយយើងមកស្រដី ថ្ងាថ្ងៃដតក្បត្រៃថ្ងៃ នាងនៅឯដ
ក្នុងព្រៃ តំត្រាក្រាត់ព្រះស្វាមី ។

បឧកាកតតិ

កាលនោះនាងនាថ ចាំព្រះភ្លូថ្កាល ដួចដាំទិនបី យល់ព្រះបង់ថាត់
រវៃតេន្ទក្បត្រៃ សែនសោយសោកពី- លាបលន់ណាស់ណា ។ នាងយក
ព្រះករ ចាំងពីនោងនរ តតក់ទក ហើយរហៀបទឹងក្បួយ ប្រល័យ
ជន្មា ហេតុដូតសោក ឈឺសង្ឃាថៃ្ង ។ ឈឺអស់ទក នាងនាថឈឺផ្សា
ព្រះរៀមរសពល ផ្សាខ្ទាបក្តៅក្តាត់ ស្រែតេន្ទំទមល ប្រះប្រាណដួល
ដល់ ដេកដោយធាក ។ នាងឈឺស្វាមី ហាក់ដួចវត្តី នេះក្នុងទក
សត្វសាច់សួតថ្លើម ដង្ហើមរយា ក្តៅក្តាត់ឈឺផ្សា ឡើងឡង់សន្ធប់ ។

រៀងខ្លួនស្មារតី សម្តេចទៅ ថ្ងៃថ្ងៃសោកសល់ តុំអាចមិថ្មាន ច្រើន
ច្រាណមិនល់ សន្ធឹកដួលដល់ លន់តន់ពេកក្រៃ ។ លុះភ្ញាក់ស្មារតី
ដាលដោះខ្លួនពី កូមិកតានោះនៃ នាងមិបុត្រតន់ ត្រាច់តាត់ដោយ
ព្រៃ រកព្រះចមក្រៃ តុំឃើញខ្លួយណា ។ នាងនាថប្រាសើរ នឿយ
ណាស់នាងដើរ តួនព្រៃព្រឹក្សា ហើយហាលថ្ងៃផង តុំរតងបាត នាង
មិបុត្រា ចូលឈមអស្រឹង ។ ក្រោមម្លប់ព្រឹក្សា ហើយយកតស្ពោ
ល្អមានដាំឡ នាងក្រាលផ្តក្តិត បុត្រតន់ថ្នមថ្ងៃ ចំជៀហើយនៃ
នាងនាថខ្ញុញ ។ ឧបុត្រថ្ងៃម្តាយ ចាបអ្វីអប្បាយ ឱ្យកូនស្ងួនភ្ងា
កើតកូនសាន្តគ្រោះ សូន្យសោះតំព្រា ប្រាសព្រះបិតា ឯពជរៀស្ងួយ ។
កូនអើយម្តាយស្រាក រកអាតុកន្តក ដោយជនឹព្រៃព្រៃ តុំឃលំសោះសូន្យ
ណាកូនមាសថ្ងៃ តំម្តាយសង្រៃ សង្រ្តែនសោក ។ អម្តាស់ម្តាយ
អើយ ឥឡូវនេះហើយ ម្តាយនឹងយាត្រា រកព្រះកូនរា ព្រះវរបិតា
ម្តាយនឹងយកថ្វា ទៅតុំបាន់ឡើយ ។ ក្រែងកូនមាសថ្ងៃ ត្រូវតំដៅ
ថ្ងៃ កើតជម្ងឺហើយ ម្តាយរៃងផ្សាក្តៅ ឥតឯហៅស្ទើយ អម្តាស់ម្តាយ
អើយ អ្នកនៅនេះនៃ ។ នាងយកព្រះខ្សែ រតន៍រស្មីឧត្តម ប្រ-
សើរពេកក្រៃ ស្ងួនសូកាណិរតន៍ ល្អឥតដំឡ នាងចងនៅដៃ
ព្រះហស្តបុត្រា ។ ហើយនាងមិបុត្រ នាងទ្រង់តំសត់ ពិលាបខ្ញុញ
ថា ឧមាសន្ធឹនផ្ទៅ អ្នកជៀមតា ឱ្យឆ្អែតបាងណា អម្តាស់ម្តាយ

អើយ ។ ម្តាយនឹងយាត្រា ទៅតាមបិតា អ្នកវង្សវៃអើយ ម្តាយ
ឈឺពេកក្តី ឥតឯហៅស្បើយ អម្ចាស់ម្តាយអើយ ម្តាយមកវិញ ណា
ទាន់ផ្តែកពស់បុត្រ សោយសោកស្រយុត ញ៉ាំអស់អង្គា ខ្ទីះខ្ទឹក
ខ្ទួល អន់អួលទុក ទាន់ថើបបុត្រា ស្រេចហើយទាន់ថា ។ ចេញ
បង់បុត្រា រកជជាយា ត្រាច់កេកូធរ ស្រីតេន៍ពន្ធក ទាន់យកព្រះ
ករ ទាំងពីរទាន់គរ ទ្រូងទ្រនំសោក ។ ទាន់ស្រែកអន្ទះ អន្ទែង
ស្មៅស្មះ រត់រកពស់ សត្វជ្រោះជ្រលង ដោយជង្ឃង្គា ពុំយល់ព្រះ
មហា ពន្ធកថ្លើមថ្លង់ ។ ទាន់រៃអង្គាសល់ រកវៀនច្រូចដល់ សា
គរនាយនៃ ត្រាច់ដើរដោយឆ្នេរ តម្ពាដលស័យ ពុំឃើញដៀស្ងដ័យ
ទាន់ភាថ្ងូញថា ។ ព្រះបតិត្រ ថ្នាំបង្កែរថើបិត នឹងខ្ញុំវិញ ណា
វង្សវៃព្រះមាស ប្រែប្រាសឃ្លាតឃ្លា ខ្ញុំឯងឯក- សារៈសារសូន្យ
សស់ ។ ទ្រព្រះពន្ធក ប្អូនត្រាច់ដើរកេ ដោយដៃនក្រសល់ ព្រៃព្រឹក្ស
ហាន្តរាយ សត្វសាយពុំយល់ អ្នកអើយប្អូនខ្សល់ ខ្ញុំតែម្នាក់ឯង ។
ទ្រព្រះប្រសើរ អ្នកអើយប្អូនមើល សម្ដេចធំធេង ខ្ញុំលាយថ្កាត់ត្រើយ
ទ្រះហើយប្អូនក្រែង ទ្វាចព្រះអង្គឯង ក្សត្រិយកងគង្គា ។ ខ្ញុំមើលមហា-
ក្សត្រ ទ្វាចក្រែងឡល់ផាត់ ចោកព្រះសត្វមហា - សត្តមកប្រាប់ទ្នេរ
តម្ពាដលសា សពព្រះពន្ធ ពុំយល់ឡើយនៃ ។ ប្អូនមើលអាកាស
ពពកសាត់ផាស សាត់ទៅច្រើនក្រៃ ទ្រព្រះប្រសើរ ប្អូនមើលស្រមៃ

ហាក់ដូចក្សត្រថ្ងៃ ស្តេចហៀរហោះផ្សង ។ ទ្រង់ស្រមៃ ពាក្យទេវនៃ
ស្នាងជាព្រះជន ឯព្រះបាតត្រ ជាតិមិត្តនេហាង អ្នកអើយប្អូនអើ ខ្ញុំនៅ.
មនស្ស ។ ទ្រង់យល់ហោង ហើរហើយរលាំង តាមដោយហៅហោះ
ប្អូនស្នងព្រះជន ហោះផ្សងមកណា មិនដឹងបក្សា ហង្សហើរហួសទៅ ។
ប្អូនអើស្រណោះ យល់បក្សាខោះ តែតជាព្រះទៅ ព្រះអង្គភ្ញាក់ឆន់ ហង្ស
យន្តមាសផ្តៅ រស្មីសន្ធៅ ត្រោងក្រោយអាកាស ។ ម្តេចស្បើយព្រះ
មាស មិត្តមិញប្រែប្រាស ជនប្អូនទៅអាយ ឈឺផ្សងផ្សាផ្សឹង ពាក្យស្ងើរ
ភ្ញាយ ស្មារតីយមាយ ដួសខ្លួរឆ្ងឹង ។ ព្រះរាជា ប្អូនតែតមួយណា
មួយខ្ញុំភ្ញាចក្រែង ព្រះមាសពន្ធុក ហោះរកប្អូនឯង ហើយស្តេចរំងឹង
ទំហង់ដែលឈប់ ។ ក្រែងព្រះទេសាល រកប្អូនពុំឃាល់ ហើយរំលឹ
ត្រឡប់ រត់រកដោយដង ក្រែងឯសាយសព្វ ពុំឃាល់ស្តេចឈប់
ហង្សយន្តមាសមៃ ។ ប្អូនត្រាច់ដើររក សក្តិត្រឈូងឆក ពុំឃាល់ប្អូន
ណា ក្រែងសត្វម្រឹគផង យកដំបូងភាជា ក្បាលក្បែរជង្ហា សោះសូន្យ
ចាត់បង់ ។ ពោះព្រះចក្រី មរណ៍មែនតិតក្តី លែងចាន់ឃើញហង្ស
ប្អូនមើលពុំឃាល់ តូចចាត់ព្រះអង្គ ចាត់ស្តេចចាំងហង្ស ចាំងអង្គកជា ។
ព្រះទេសាល អ្នកតែយប្អូនឆ្ងល់ ពន់ពេកណាស់ណា ប្អូនពុំដឹងដើរ
ទិសមាគ៌ា ទឹងរកព្រះមហា ពន្ធុកថ្មីមថ្ងៃ ។ ព្រះត្រាណត្រៃយ
អម្ចាស់ប្អូនតែយ ប្អូនកុំព្រាយព្រៃ ត្រូវចាកណ្តាន ឯកឯងកន្ទឹងព្រៃ

ប្រាសព្រះដៀស្ដេច ចេញពីទក ។ ឧព្រះបាទបង ពីថ្ងៃនេះហោង
តែនឹងឃ្លាតឃ្លា និកសោះសូន្យ បងប្អូនសាលគ្រា នេះទៅអញ្ជា
ព្រៃព្រះហិមភាន្ត ។ ឧព្រះពន្ធុក ស្ដេចនាំប្អូនមក បងនឹងទៅថ្កូន
ក្រុងទេពប៉ុរី ជាទីពរជ័យ ម្ដេចខ្លែយមកមាន ទុក្ខព្រាត់ប្រាសគ្នា ។
ឧអម្ចាស់ថ្ងៃ ប្អូនជាវុក្កបៃ ឯកអង្គអនិច្ច ត្រេមាចព្រាត់ប្រាស ព្រះមាស
ស្ដេហា ក្នុងព្រៃព្រឹក្ស ខ្លួនឯងស្ងាត់ ។ ឧព្រះមេត្ត ថ្លៃប្រាសប្អូន
ទៅ អសារសល់ត្តាត់ ប្អូនឃើញ ខ្លាច ស្លោះស្លេចត្រមាត់ ដ្បិតព្រះ
ប្រាសត្រាត់ ចាកបម្រែបង់ ។ ប្អូនឈឺទសពល ឈ្លើងឿនដូចតល
អគ្គីនេះកង់ ឧពះក្ដាត់ក្លាត់ ដ្បិតឃ្លាត់ព្រះអគ្គ ព្រះហើយប្អូនឆ្ងល ដូរវែងឆ
សោកសល់ ។ ទាន់នាថវៅ រែតន៍ក្សត្រី សោយសោកសល់ ខឿង
ខ្លួញព្រះបាទ ឧទាថទសពល ខេត្រាជោរជល ស្រក់ស្រោចតត្រា ។
ទាន់ខ្លួញបណ្ដើរ ស្រើតន៍ប្រសើរ ត្រាច់ក្នុងឥន្ទា ពុំយល់ស្ងាមី ក្សត្រី
ថ្ងៃថ្នា ទាន់នាថវែងជា ខ្លួនខ្លួញទៅមោង ។ ដំណើរនេះឯង កាល
ក្សត្រីថ្ងៃ ត្រាច់តត្រេះបង ខិតខន្ធត្រានេះ យើងសែ្ងសួរណេះបាង ដោយ
ជាវំនង ដំណើរទាន់នាថ ។ ខ្ញុំបាយើងទៅថ្ងៃឆ ដំណើរដំណែង
ខិតខន្ធតំរាល ក្សត្រីមួយអាច រើសាងដកុមារ. កាលត្រាយទាន់នាថ
ត្រាច់តេស្ងាមី ។ ឥឡូវនេះឯង សុរិយោល្ងាចថ្ងៃ ថ្ងៃតបហើយទ្បី យើង
ខឹងបង្ហាប់ ទុកសែ្ងសិនឯង ខ្សែតំរូវតៃ ត្រាន់ត្រេប៉ម្ងឹរហោង ។

(មានត)

រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

(ត)

លោក ភិយ-ប៊ុក រៀបរៀង

ព្រះមហាក្សត្រដ្ឋវៃ បានសូមអញ្ជើញលោកឲ្យមកធ្វើជាទីប្រឹក្សាបេសព្រះអង្គ, តែលោកមិនត្រូវទទួលដំណែងនេះ ព្រោះលោកយល់ថា ព្រះមហាក្សត្រអង្គនេះ បានដណ្តើមពីសម្បត្តិឪពុកា ។ លោកក៏បានអញ្ជើញទៅកាន់ដ្ឋអូអេ ; ព្រះមហាក្សត្រនៃរដ្ឋនេះ សូមឲ្យលោកកាន់ដំណែងជាន់ខ្ពស់ ។ ប៉ុន្តែ លោកមិនត្រូវទទួល ។ ក្នុងពេលនោះ ទទួលមានព្រះអង្គម្ចាស់ជាកូនក្មៃនៃព្រះមហាក្សត្រដ្ឋលួ បានយកដង្វាយមកជូនលោកឲ្យវិលទៅរដ្ឋលួវិញ ។

លោកគុង-ហ្វូឆឺស៊ី បានវិលត្រឡប់ទៅកាន់ដ្ឋកំណើតរបស់លោកគ្រាមួដែលលោកបានធ្វើដំណើរទៅកាន់ដ្ឋឯទៀត អស់រយៈវេលា ១៤ ឆ្នាំ ។ ព្រះបាទដាំយព្រះចៅដ្ឋលួ ទ្រង់មិនបានឲ្យលោកកាន់ដំណែងអ្វីឡើយ ទ្រង់គ្រាន់តែប្រឹក្សាជាមួយនឹងលោក ចំពោះបញ្ហាណាដែលស្មុគស្មាញ ។ ក្នុងពេលនេះ លោកបានតែរៀបចំសៀវភៅដែលលោកតែងគឺ:

១- សៀវភៅ យី-ឆឺង បានដល់សៀវភៅពណ៌នាអំពីការតែងប្រែត្រង់យ៉ាង,

២ សៀវភៅ ជួ-គីង បានដល់សៀវភៅប្រវត្តិសាស្ត្រ,

៣-សៀវភៅ ចេ-គីង បានដល់សៀវភៅតណាំនាតិកាត្យឃ្លោង,

៤-សៀវភៅ យ៉ុ-គីង បានដល់សៀវភៅក្លែង ឬ វិរ្យាសាស្ត្រ ផ្សែងខ្លួសៃមកពាក់ព័ន្ធមនុស្ស អមនុស្ស ទៅតាមទំនៀមហ្នឹង ។

លោកបានមានប្រសាសន៍ថា: ប៉ែខ្ញុំសៅទៅ ៩០ ឆ្នាំទៀត ខ្ញុំទំនៀតប្រែ សៀវភៅតណាំនា អំពីការប្រែប្រួលសត្វយ៉ាំងឲ្យបានតិស្ដាជាងនេះទៅទៀត ។

មុនលោកនឹងលាចាកលោកម្ដង, កន្លងកាលនោះ លោកនៅបង្ហាញសត្វ, លោកបង្ហាញបានសត្វចំឡែកមួយ ហៅថា គោតិសិង្ហ (Licorne) ។ លោកក៏ទឹកដល់ភ្នែកដែលលោកមកចាប់ជាសន្ធិ ក្នុងដៃនៃមាតាលោក ។ មាតារបស់លោក បានសុបិនឃើញ សត្វគោតិសិង្ហនេះដែរ, លោកក៏ចេញវាចាថា "អាយុខ្ញុំអស់ហើយ" ។

តមក លោកមានជម្ងឺវាតម្ងន់, កន្លងកាលនោះ មានសិស្សរបស់លោកម្នាក់ បានមកសួរលោក។ មានប្រសាសន៍ថា:

"អ្នកមកយឺតយូរភេត. . តិតវាលាកលែងស្គាល់គ្នាហើយ, ខ្ញុំមិនដែលបានជួបប្រទះនឹងអ្នកណាម្នាក់ ដែលចង់បានខ្ញុំ ធ្វើជាគ្រូបាអាចារ្យសោះ" ហើយលោកប្រឿងថា:

"ព្រះវិហារតិត តុំដែលទឹកតិត ពីការត្រាំគ្រា ជួបរូបខ្ញុំនេះ តាម

ដោយសង្ខារ តែងចាស់គ្រាំគ្រា សូន្យស្ងាប់ចុងបង ។ ជីវភាពខ្ញុំ
កល់ថ្ងៃតែងំ ធ្វើការត្រឹមត្រង់ ជាដង្ហើយមេឃ ឥតមានបង្គន់
សួយពីតក់ផុង ឲ្យអ្នកចាន់ចេះ » ។

មុនពេលដែលលោកទទួលអនិច្ចកម្មមួយថ្ងៃ លោកបានពោលថា :
កាលខ្ញុំអាយុ១៥ឆ្នាំ ចិត្តខ្ញុំរួលវាយតែពីការសិក្សា, អាយុ៣០ឆ្នាំ
ខ្ញុំបានពិចារណាអំពីលក្ខណៈវិជ្ជាដោយមាំមួន, អាយុ៤០ឆ្នាំ ខ្ញុំលែង
សង្ស័យចូលអំពីវិជ្ជាទាំងឡាយ, អាយុ៥០ឆ្នាំ ខ្ញុំបានស្គាល់បរបញ្ញត្តិ
ច្បាប់មហាមេឃ តែច្បាប់ដែលមហាមេឃបានតំណាលចំពោះដីសត្វមួយ ។
ដើម្បីសម្រេចខ្ញុំដោតវាសនាទាំងឡាយ, អាយុ៦០ឆ្នាំ ខ្ញុំបានយល់ដោយ
ស្រួលនូវហេតុនៃព្រឹត្តិការណ៍ទាំងឡាយ, អាយុ៧០ឆ្នាំ ខ្ញុំបានចំពេញ
ការណីយកិច្ចចំពោះចិត្តរបស់ខ្ញុំដោយមិនឲ្យហួសកំរិតតាមសមគួរ ។

លុះដល់កំណត់ លោកគំរលត់ខន្ធទៅតាន់លោកខាងមុខក្នុងឆ្នាំ
៤៧៩ មុនគ្រិស្តសករាជ ។

តើលទ្ធិរបស់បណ្ឌិតកុង-ហ្វូជីយ៉ាងណាទៅ ?

លទ្ធិរបស់បណ្ឌិតកុង-ហ្វូជីសឺ មិនមែនសំដៅយកប្រមន្ត ឬជាយោ
បល់ឬគួរជាលក្ខណៈទេ, លទ្ធិកុង-ហ្វូជីសឺមិនមែនជាសាសនាទេ
គឺជាទស្សនវិជ្ជានីតិវិទ្យាសាស្ត្រលាយជាមួយគ្នា ។ ចំពោះលទ្ធិនេះ គ្មាន

សាសនា គ្មានសិលធម៌ទេ ! មានតែវិជ្ជាឥតប្រយោជន៍ដែលមានលំនាំ
ទៅតាមជាតិចិត្តប៉ុណ្ណោះ ។

តើលទ្ធិវេស់កុដ-ហ្គុតសឺ ធំជាងសាសនាពុទ្ធយ៉ាងណា ?

ព្រះពុទ្ធសាសនា យក «កម្ម» គឺអំពើដែលសត្វធ្វើជាមូលដ្ឋាន, យក
អដ្ឋង្គិកមគ្គជាំង៨ ជាល័ក្ខណៈនៃការប្រព្រឹត្តប្រតិបត្តិ ; អ្នកណាជាន់លះ
បង់ទូរតណ្ហា តស៊ូចំពោះតែលសង់ត្រឹងសៅហ្មង ធ្វើចិត្តវេស់ខ្លួនឲ្យ
ធូរផង់ អ្នកនោះនឹងបានសេចក្តីសុខតាមសំដាប់ រហូតដល់បរមត្ថសុខគឺ
ព្រះនិព្វាន ។

លទ្ធិកុង-ហ្គុតសឺយកវិជ្ជាឥតប្រយោជន៍ជាល័ក្ខណៈ ដោយយល់ថា
មនុស្សមានវិជ្ជា មិនយូរមិនឆាប់ទឹងនៅជាបណ្ឌិត, វិជ្ជាបានអាងទ្រឹស្តី
តតិបណ្ឌិតបានអាងការប្រព្រឹត្តប្រតិបត្តិ ។ វិជ្ជានេះ យកមកអនុវត្តន៍កន្លងដប់-
កាតពាល់ថ្ងៃ រចនាជីវិយវេស់ខ្លួនឲ្យទៅជាបណ្ឌិតវាង, ព្រោះហេតុ
នោះ បានជាមានពាក្យមួយឃត់ខ្នងដែលលោកកុង-ហ្គុតសឺតោលទុកថា :

" បេះឲ្យដឹងថាខ្លួនបេះ, ល្ងង់ឲ្យដឹងថាខ្លួនល្ងង់ ; នេះហៅថា
បេះពិត, បើល្ងង់មិនដឹងថា ខ្លួនល្ងង់ ប្តូរបែរតាំងខ្លួនជាអ្នកបេះ ធ្វើ
ម្តេចនឹងដេញសេចក្តីល្ងង់ចេញពីសន្ដានចិត្តបាន ! ធ្វើម្តេចនឹងឲ្យការបេះ
ដឹងនោះចូលមកប៉ិតនៅក្នុងសន្ដានចិត្តបាន ! , លុះត្រាតែខ្លួនល្ងង់ ស្គាល់
ច្បាស់ថាល្ងង់ពិត ទើបកែល្ងង់នោះ ឲ្យទៅជាបណ្ឌិតបាន ។ បណ្ឌិត

មានវិជ្ជាជាដើម្បីហេតុ មានការប្រព្រឹត្តិល្អជាសកម្មភាព មានសេចក្តីសុខជាផល" ។ នេះជាលទ្ធិកុន-ហ្វូងសឺ ។

តើលទ្ធិកុន-ហ្វូងសឺ នឹងលទ្ធិតាវខុសគ្នាយ៉ាងណាខ្លះ?

លទ្ធិតាវ គឺលទ្ធិរបស់បណ្ឌិតឡៅសឺ ដែលយកចិត្តជាមូលដ្ឋានគឺអសកម្មភាពជាគោល គឺជារូបកាយនៅស្ងៀម ចិត្តចេះតែពិចារណាគិតគូរ ឈ្លេចឈ្លី ឲ្យលះខ្ចូរដនិត់ងឡាយ ។ នេះជាលទ្ធិតាវ ។

ឯលទ្ធិកុន-ហ្វូងសឺ សំដៅយកកាយវាចាចិត្ត, គឺបុគ្គលប្រព្រឹត្តកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជានទុក្ខ; បើប្រព្រឹត្តកាយសុចរិត វចីសុចរិត មនោសុចរិត ឈានសុខ ។

លទ្ធិតាវ សំដៅយកសមាធិចិត្តតែមួយ សមដូចពុទ្ធភាសិតកន្លះគាថាមួយខទុកតែកាយ ត្រង់អញ្ជាតរកិរិយាថា:

ទុដ្ឋិក្កហាស្ស លហុនោ យត្ថ កាមនិបាតិនោ
ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ។

ប្រែថា សេចក្តីបង្ក្រាប់ចិត្ត ដែលសន្តិត់សន្តិទជាន់ដោយក្រ ដែលស្រាល មានប្រក្រតីធ្លាក់ទៅតាមក្រុងថ្នាក់នៃអារម្មណ៍ណាមួយជាន ជាគុណឲ្យសម្រេចប្រយោជន៍ ព្រោះចិត្តដែលគេបង្ក្រាប់ជាន តែងនាំសុខមកឲ្យ. ។

ថ្ងៃមួយ លោកសីលូ បានសួរបណ្ឌិតកុង-ហ្វូជឺសាថា ដូចម្តេច ដែលហៅថា មនុស្សល្អ ? ។

បណ្ឌិតកុង-ហ្វូជឺសាឆ្លើយថា មនុស្សល្អ គឺមនុស្សចេះគោរពគោតខ្ជាចចាស់ព្រឹទ្ធាចារ្យ ។

លោកសីលូ សួរថា : តែប៉ុណ្ណោះទេឬ លោកគ្រូ ? ។

បណ្ឌិតកុង-ហ្វូជឺសាឆ្លើយថា : មនុស្សល្អធ្វើខ្លួនឱ្យបានចំរើន ហើយញុំាងអ្នកដទៃឱ្យចំរើនផង ។

លោកសីលូ សួរទៀតថា តែប៉ុណ្ណោះទេឬ លោកគ្រូ ? ។

បណ្ឌិតកុង-ហ្វូជឺសាឆ្លើយថា មនុស្សល្អ ធ្វើខ្លួនឱ្យបានចំរើនដើម្បីសន្តិភាពផងដែរ ។

ប្រៀបធៀបទ្រឹស្តីលោកកុង-ហ្វូជឺសាំ គឺ:

១-កម្ម ,

២-ការរៀនសូវិជ្ជាគាំងឡាយ ,

៣-ការប្រព្រឹត្តប្រតិបត្តិសូវិជ្ជាគាំងឡាយ ដើម្បីរចនាខ្លួនឱ្យមានវិឌ្ឍនភាព ,

៤-ការគោរពដឹងជើងតា ទេវតា អមនុស្ស ។ល។ ,

៥-គតិបណ្ឌិត ។

អធិប្បាយ

១ កម្ម: ប្រែថា អំពើ; អំពើល្អ អំពើអាក្រក់ ហៅថាកម្ម; អ្នកណាធ្វើល្អ ឋានល្អ, អ្នកណាធ្វើអាក្រក់ ឋានអាក្រក់, ហេតុដែលណា ឋានផលដែលខោះ ហេតុល្អផលល្អ, ហេតុអាក្រក់ផលអាក្រក់ ជាវិសត្ថនីធម្មជាតិពាំនាំឲ្យ មានហេតុមានផល, សកម្មភាពនៃមនុស្សពាំនាំឲ្យមានគោលការ មានកំណួល, ស្គាល់ហេតុ-ផលឈ្មោះថាស្គាល់គោលការនឹងកំណួល ។ នេះដាច់ធំសំខាន់ដ៏កំពូលវិចារណញ្ញាណរបស់មនុស្សគោកាន់សុត្រតភាព ។

២-ការរៀនខ្លួវិជ្ជាពាំនាំឲ្យ: លោកកុង-ហ្វូសឹឋានគោលថា ត្រូវតែសិក្សាខ្លួវិជ្ជាពាំនាំឲ្យ, ឯការសិក្សា ត្រូវតែពាក់ព័ន្ធរហ័យចំណាំបើគ្មានការគិចារណា ទាំឲ្យមានតេលវិលា, គិចារណា តែគ្មានការសិក្សាទាំឲ្យកាន់ច្រឡំ ។

តើការសិក្សាជាអ្វីទៅ ?, ការសិក្សាគឺការរៀនយកខ្លួវិជ្ជាពាំនាំឲ្យរួចគិចារណាឲ្យយល់ការខុសត្រូវ ហេតុផលសព្វគ្រប់ ។

៣-ការប្រកាន់ភ្ជាប់ប្រតិបត្តិខ្លួវិជ្ជាពាំនាំឲ្យ, ដើម្បីរចនាខ្លួនឲ្យមានវឌ្ឍនភាព: លោកកុង-ហ្វូសឹឋានគោលថា: ទត្តមសិក្សាឬសែនវិជ្ជាខាងវិធីប្រតិបត្តិ តែការធ្វើឲ្យចំរើនខាងវិចារណញ្ញាណដែលយើងឋានទទួលពីព្រះអាទិទេព (Roi du ciel) ដើម្បីរចនាខ្លួនឲ្យមានសភាពដ៏ខ្ពង់

ខ្ពស់ ។ ករណីយកតិច្ចត្រូវតែមានដូចគ្នា ពីបំតាំងតាមខ្សែខ្ពង់ខ្ពស់បំផុត រហូតដល់មនុស្សថោកទាបល្ងិតល្ងង់ ។ ការកែប្រែប្តូរចេតនាខ្លួនឯងឲ្យបានវិសុទ្ធភាពចាត់ជាមូលដ្ឋានទៃវិត្តនៃធម៌ជាយថាតិ ។ មនុស្សដែលមានប្រាជ្ញាមុតមាំ ល្អបវរញ្ញាមធ្យម អាចសិក្សាទៅតួតមរំដោះបាន ។ មនុស្សដែលមានបញ្ញាខ្វះខ្លាយ ជាងមញ្ញាមធ្យម មិនអាចបំពេញទៅតួតមរំដោះបានទេរឺយ ។

៤- ការគោរពជីវិតជាទេវតា អមនុស្ស ។ល។ : តើការប្រើកម្លាំងរបស់ខ្លួនដើម្បីយុត្តិធម៌ ជល់ការគោរពជីវិតជា ។ ល ។ នេះយ៉ាងដូចេះ ។ ពួកទេវតាទីរ៉ែទេពធីតាដែលត្រូតត្រាពិភពលោក, តាក្សជិនថា ចៀង-ម៉ង់ ប្រែថា "អំណាចស្ងាត់" បានជល់គណត្តិរបស់ព្រះអាទិទេព ។ គណត្តិនេះ គឺគេប្រគល់ជូនចំពោះបុគ្គលណាដែលមានគុណសម្បត្តិ ចរិយាសម្បត្តិបរិបូណ៌ ។

៥- គតិបណ្ឌិត: អ្នកណាមួយ មានការសិក្សាល្អហើយ ប្រតិបត្តិទៅតាមការចេះដឹងនោះ, បើពោលដោយចំពោះ គឺអ្នកណាមួយយល់ការខុសត្រូវដោយខ្លួនឯង អ្នកនោះឈ្មោះថា មានគតិបណ្ឌិត ។

លោកកុង-ហ្វូ-ស៊ីបានពោលថា មនុស្សដែលមានគុណសម្បត្តិដ៏ខ្ពង់ខ្ពស់ ត្បាយាមកដ៏ការប្រព្រឹត្តិត្រូវតែណ្ណាល ត្រូវតែណ្ណាលនេះឯងជាកំពូលនៃគុណសម្បត្តិទាំងឡាយ ។

អ្នកណាមិនស្គាល់ផ្លូវកណ្តាល អ្នកនោះមិនស្គាល់ធម៌ មិនស្គាល់មូលដ្ឋានពិភពលោកនឹងច្បាប់សាកល ឈ្មោះថា មិនអាចជ្រាស្រ័យចំពោះវត្ថុដែលគេឃើញដោយមំសចក្ខុ ។

ព្រោះហេតុនោះ ទើបជណ្ឌិតកុង ហ្វុងសឺ បានណែនាំមនុស្សឲ្យប្រតិបត្តិតាមផ្លូវកណ្តាល ជាហេតុនាំមនុស្សឲ្យបានសេចក្តីសុខគ្រប់យ៉ាង ។

សុភាសិតរបស់បណ្ឌិតកុង-ហ្វុងសឺ

ក) អាណត្តិព្រះអាទិទេព

-អាណត្តិព្រះអាទិទេព គឺជាគោលការសម្រាប់ប្រតិបត្តិតាមផ្លូវច្បាប់ ដែលព្រះអាទិទេពទ្រង់ផ្តែរអំណាចចំពោះសត្វទាំងឡាយ ។

-អាណត្តិព្រះអាទិទេព រមែងផ្តែរអំណាចមកឲ្យមនុស្សគ្រប់រូបប៉ុន្តែបើមនុស្សប្រកបដោយទុច្ចរិត, អាណត្តិព្រះអាទិទេពរមែងលះបង់ពោលមនុស្សថែបខេះ ។

-កាលណា គេប្រព្រឹត្តល្មើសនឹងអាណត្តិព្រះអាទិទេព គ្មានអ្នកណាជួយទេ ។

-ក្នុងលោកគ្មានព្រះអាទិទេពពីរទេ, ប្រជាពលរដ្ឋក៏គ្មានព្រះមហាក្សត្រពីរដែរ ។

ខ) ជីដូនជីតា

- ត្រូវធ្វើតបកម្មចំពោះជីដូនជីតា ហាក់ដូចជាជីដូនជីតានោះមកបីតនៅចំពោះមុខយើង ហើយត្រូវគោរពនឹងសំដែងនូវកតញ្ញូតាធម៌ចំពោះលោកជាទីបូ ។

គ) បុព្វណបណ្ឌិត

- ខ្ញុំជឿជាក់ចំពោះបុព្វណបណ្ឌិត ទើបខ្ញុំមានវិត្តកត្តិចំពោះលោក ខ្ញុំកើតមកមិនមែនឃើញភ្លាមៗដែរ ខ្ញុំជាមនុស្សស្រឡាញ់បុព្វណបណ្ឌិត ហើយខ្ញុំក្បាលាត្រូវរស់នៅតែរៀងរាល់ថ្ងៃ ។

លោកសឺ - ចាង ទូនស្តេវណ្ឌិតកុង-ហ្វូនិស ថា "សូមលោកត្រូវមេត្តា ! តើមានន័យការប្រតិបត្តិបស់មនុស្សដែលមានគុណសម្បត្តិនោះតើយ៉ាងណា ? " ។ លោកកុង - ហ្វូនិសឆ្លើយថា: "មានន័យនេះជាមានន័យត្រាច់ត្រង់ទៅមុខ មិនចាំបាច់ធ្វើតាមបុព្វណបណ្ឌិតទេ, " ដើម្បីដូចសេត្រូតត្រាប្រទេសអស់រយៈពេលខ្លី ដើម្បីសេនោះ គាបចេញមនុស្សតាបឲ្យទៅជាស្មូត ហើយបំបាត់នូវគោការកំណាចចំពោះអ្នកដទៃបាន " ។

ឃ) តាកន៏ត្រូវតែដែលមើលខុសយើញ

បើគេមិនគាបប្រព្រឹត្តទៅលើមនុស្សដោយសមមៀបាន ម្តេចឡើយគេនឹងគាបប្រព្រឹត្តទៅនឹងអមនុស្សបាន ! ។

បណ្ឌិតមិនដែលគោលតំរើតំកមចំពោះអ្នកណាឡើយ ។ តែងត្រូត

ត្រាប្រទេសខ្លួនដោយប្រើគុណសម្បត្តិនិងសមត្ថភាពដ៏ឥតប្រាណនោះ គឺ
ដូចជាផ្កាយក្រតៅដែលបិតនៅស្ងៀមឥតប្រែប្រួល ចំណែកផ្កាយឯទៀត
វិលជុំវិញផ្កាយនោះ ហើយយកផ្កាយនោះជាមគ្គុទ្ទេសក៍ ។

ច្បាប់ទាំងនេះមានសភាពសម្រាប់អស្ចារ្យ ដែលនៃច្បាប់
នោះអាចពាយកនាគតបាន ។

ន) ចំនៀមទម្លាប់និងក្បួន

កាលណាមាតាបិតារស់នៅ យើងត្រូវចំពោះញុកណើយកិច្ចចំពោះ
លោកទាំងពីរ ដោយយកគោលច្បាប់ព្រះអាទិទេពមកជាមូលដ្ឋាន ។

កាលបើ មាតាបិតាខ្លួនអនិច្ចកម្ម ត្រូវយកសព្វលោកទៅកប់ឲ្យ
ស្រួលបួលដោយធ្វើពិធីបុណ្យតាមចំនៀមទម្លាប់ ។

ប) ទុត្តមមនុស្ស (មនុស្សឆ្កួតខ្លះ)

ទុត្តមមនុស្ស កាលណាលោកអង្គុយជិតតុបរិភោគអាហារ លោកមិន
បរិភោគដោយប្រញាប់ប្រញាល់តាមឃ្លាននោះទេ, កាលណាលោកបិត
នៅក្នុងផ្ទះរបស់លោក, លោកមិនបិតនៅស្ងៀម ឬត្រេកត្រអាលសប្បាយ
ដោយគ្មានគុណទេ, លោករមែងតាំងខ្លួនលោកក្នុងអប្បមាទធម៌ គឺ
ប្រព្រឹត្តកណើយកិច្ច គោលតាក្យផ្នែមស្លូមជាដំបូង, លោកបួលចិត្ត
សេពគប់មនុស្សដែលមានចិត្តស្លូតត្រង់ ដើម្បីនិងកែប្រែចរិយាមារយាទ
របស់លោកឲ្យដូចមនុស្សនោះ ។

ទុត្តមមនុស្ស តើមនុស្សដែលយកវាចាស្អប់ខ្ញុំមកតនុវត្ត ហើយ
ភោលៈវាតាមសាកម្មភាពស្អប់ខ្ញុំ ។ លោកតែងប្រព្រឹត្តសេចក្តីល្អ
ចំពោះមនុស្សទាំងអស់ មិនស្រឡាញ់អ្នកនេះ ស្អប់អ្នកនោះឡើយ ។

ហ៊ានមនុស្ស (មនុស្សថោកទាប) រមែងមានតំនិតតែប្រយោជន៍
ផ្ទាល់ខ្លួន គ្មានចិត្តល្អចំពោះមនុស្សឯណាទេ ។

ទុត្តមមនុស្ស យកតែសេចក្តីសុចរិតជាមូលដ្ឋានសម្រាប់ប្រតិបត្តិ ។

ទុត្តមមនុស្ស មានចិត្តទន់ធន់ ទន្ទឹចិត្តស្លូតស្ងាត់ ។

ទុត្តមមនុស្ស ទន់មនុស្សមានគុណសម្បត្តិទុត្តុដ្ឋទុត្តម តែងព្រមាម
ដើរតាមផ្លូវកែណាស ។

ទុត្តមមនុស្ស ត្បាយាមតិចាណា កុំឲ្យអកុសលចូលមកសង្កត់ចិត្ត
បេសរំលោភបាន ។

ទុត្តមមនុស្ស តែងធ្វើឲ្យចំរើនគុណសម្បត្តិមនុស្សឯទៀតជានិច្ច ។

ទុត្តមមនុស្ស តែងរស់នៅដោយសន្តិភាពចំពោះមនុស្សទាំងឡាយ
តែមិនប្រព្រឹត្តតាមមនុស្សទាំងនោះទេ ។ មនុស្សថោកទាប តែងប្រព្រឹត្ត
ប្រតិបត្តិតាមមនុស្សថោកទាប តែមិនរំលេមធ្យាបាយចំពោះសាកម្មភាព
បេសខ្លួន ឲ្យត្រូវនឹងសម្មភាពបេសទុត្តមមនុស្ស ។

បុគ្គលពិចារណាថែរក្សាភាសីតាសាណាស់, បើខុសវាជាបងប្អូន វាមិន
ខ្វាយយើង បើឲ្យវាទៅឆ្ងាយពីខ្លួន វានឹងស្អប់តំនុំតំនួនយើង ។

ដើម្បីទទឹងឲ្យបានគុណធម៌, ត្រូវយើងខំចំពេញការណ៍យកច្បាប់ទី ១, ត្រូវពុំគប្បីផ្ទុយនៃការណ៍យកច្បាប់នេះជាទី ២ ។

ឆ) ការឲ្យដង្ហើមខ្លះ ការគួរសម

អំពើទាំងអស់ អ្នកអាចប្រព្រឹត្តបានដោយសេរី ប៉ុន្តែកុំឲ្យសេពគប់នឹងមនុស្សដែលមានប្រាជ្ញានឹងចិត្តខ្លះឡើយជាដំណាច់អ្នក, បើអ្នកជួបអ្នកខ្ពើមខ្លួស ត្រូវប្រញាប់កែចរិយាវេជ្ជសាស្ត្រអ្នកភ្លាម ។

ចូរអ្នកតិះដៀលណាដោយមុឺងមាត់នូវចរិយាវេជ្ជសាស្ត្រមនុស្សថា តើមនុស្សទាំងនោះ មានចរិយាបែបណាខ្លះ? ។ តើអ្វីដែលនាំឲ្យកែកាយសម្បាយចិត្ត ។

ឈើគុកគេមិនអាចយកមកធ្វើជាក្បាច់រចនាបានទេ ឯដុំថ្មដ៏តក់ក៏គេមិនអាចលាបថ្នាំពណ៌សបានដែរ ។

អ្នកណាដែលមានវិជ្ជា តាំងពីថ្ងៃដែលកើតមក អ្នកនោះគេហៅថា បណ្ឌិតទី ១, អ្នកណាដែលត្បាយាមកដ៏ការសិក្សាទើបមានវិជ្ជា អ្នកនោះគេហៅថា បណ្ឌិតទី ២, អ្នកណាមានបញ្ញាអាប់ខ្មួន ប្រឹងត្បាយាមសិក្សា ទើបមានវិជ្ជា អ្នកនោះ គេហៅថា បណ្ឌិតទី ៣, អ្នកណាល្ងង់ខ្លៅ, ហើយមិនរៀនសូត្រ អ្នកនោះ គេហៅថា មនុស្សល្ងង់ ។

សកម្មភាពអាក្រក់ ៤ យ៉ាងគឺ:

១.អ្នកណាមិនខ្ជិនប្រជាប្រជាពស្ត្រ, ហើយយកច្រាជ្រាំ

សម្ងាប់ប្រជាពស្ត្រី ឲ្យប្រជាពស្ត្រីភ្នាក់ផ្អើលនាំសេចក្តីអាក្រក់ អ្នកនោះគេហៅថា មនុស្សកំណាច ។

២-មិនជាស់គ្នឿនប្រជាពស្ត្រីជាមុន ហើយបណ្តោយឲ្យគ្នាប្រព្រឹត្តទៅតាំងរាំងឆ្ងល់ នេះគេហៅថា កំហែងចំពុះ ។

៣-មិនបង្គាប់គ្នាឲ្យល្អាស់ល្អាស់ ហើយបង់ឲ្យការនោះសម្រេចដោយល្អ នេះគេហៅថា អយុត្តិធម៌ ។

៤-ធ្វើចិត្តកំណាញ់ចំពោះខ្លួនឯងមនុស្សតាំងឡាយ នេះគេហៅថា មានសាកប្បតិយៅអាក្រក់ ។

ទុត្តមវិជ្ជាមិនត្រូវដូចឲ្យមនុស្សល្ងីល្ងើទេ ។

មនុស្សមានប្រាជ្ញាមធ្យម គេអាចនឹងប្រុងប្រយ័ត្នទុត្តមវិជ្ជាបាន ។

បើអ្នកចង់សន្តានឹងមនុស្សចំពោះរឿងខាងប្រាជ្ញា បើអ្នកអាត់ខាន មិនបានសន្តាន អ្នកនឹងខូចកិត្តិយសចំពោះខ្លួនឯង ។ បើមនុស្សណាមួយ មិនត្រូវការដោយគារខ្ជិនពីអ្នកខាងប្រាជ្ញា បើអ្នកនោះតែងខ្ជិនមនុស្សនោះ អ្នកនឹងបាបសំដី ។ មនុស្សជាបណ្ឌិតមិនឲ្យខូចកិត្តិយសចំពោះមនុស្សតាំងឡាយសោះឡើយ តាំងមិនឲ្យខូចការខ្ជិនរបស់ខ្លួនចំពោះអ្នកដទៃផងនេះទៀត ។

គួរអ្នកខ្ជិនចំពោះជនដទៃ កុំប្រកាន់ហានៈឲ្យសោះ ។

តាមធម្មតា បើយើងមានការតប់រំគេចខិតចូលជិតគ្នាបាន ។ បើមិនមានការតប់រំ យើងបិតនៅឆ្ងាយពីគ្នា ។ មានតែមនុស្សដែលមានវិជ្ជាជាន់ខ្ពស់ទេ មិនប្រែប្រួលក្នុងការរស់នៅ ជាមួយមនុស្សទាំងល្អាយដែលស្មុគស្មាញ ។

ជ) ការត្រួតត្រាមនុស្សទាំងល្អាយ-ប្រជាពស្ត្រី

បណ្តិតដែលត្រួតត្រា, ត្រូវធ្វើសេចក្តីល្អចំពោះប្រជាពស្ត្រី, បង្គាប់ឲ្យប្រជាពស្ត្រីធ្វើការ, កុំធ្វើអាក្បត់រំលោភឲ្យប្រជាពស្ត្រីស្អប់, ចង់បានគោរពគ្រាន់ជាបង្គួរ កុំលោភនឹងកំណាញ់ហួសប្រមាណ, ត្រូវមានចរិយាថ្លៃថ្នូរ ទើងមានយោធាខ្ពង់ខ្ពស់ត្រួតត្រា ។

បើមន្ត្រីទាំងឡាយក្នុងសង្គមគោរពចំពោះខ្លួនខ្លាំង ប្រជាពស្ត្រីនឹងមិនខ្លាចគោរពចំពោះខ្លួនម្ចាស់ទេ, បើមន្ត្រីប្រព្រឹត្តដោយយកយុត្តិធម៌ជាមូលដ្ឋាន ប្រជាពស្ត្រីគោរពគោកខ្លាចជានិច្ចរាល់, បើមន្ត្រីពេញចិត្តប្រព្រឹត្តដោយសេចក្តីស្មោះស្ម័គ្រនឹងភក្តីភាព, ប្រជាពស្ត្រីតែងតែប្រព្រឹត្តប្រតិបត្តិពុំខាន។ បើមន្ត្រីបក្ខពួកតែជាមូលដ្ឋាន, ប្រជាពស្ត្រីលែងគោរពគោកខ្លាច ។

បើមន្ត្រីធ្វើសេចក្តីល្អ ហើយគ្មានអ្នកណាយល់ផ្ទុយ នេះជាការល្អកម្រិតបំផុតគ្មាន, បើធ្វើសេចក្តីអាក្រក់ ហើយគ្មានអ្នកណាយោគហាម នេះជាហេតុធ្វើជន្ធ្យវិនាស ។

មន្ត្រីបើមានបំណងចង់ឲ្យរដ្ឋចំរើន, ត្រូវតែគ្រួតគ្រាព្រះពជអាណាចក្រដោយល្អ, បើចង់ឲ្យព្រះពជអាណាចក្រធំរឹងមាំ ត្រូវគិតតែប្រយោជន៍របស់ជនទូទាំងអស់ ។

ឈ) ទាក់ទង ។

រៀបមិនមែនបិតនៅឆ្ងាយពីមនុស្សទេ, បើរៀបបិតនៅឆ្ងាយពីមនុស្ស គេមិនហៅថា រៀបទេ ។ មនុស្សគាបធ្វើផ្លូវនៃគុណធម៌ឲ្យរួលំខូលាយបាន, ផ្លូវនៃគុណធម៌មិនអាចធ្វើមនុស្សឲ្យដំនៅបាន ។

មនុស្សណាមួយស្អប់យើង។ ត្រូវប្រើសេចក្តីយុត្តិធម៌ទៅវិញ, ឯមនុស្សដែលធ្វើល្អនឹងយើង។ ត្រូវធ្វើល្អទៅវិញ ។

មានចិត្តស្មោះត្រង់ហើយស្រឡាញ់ក្តីពិតជាទៃ ឲ្យដូចការស្រឡាញ់ខ្លួនឯង ។

បណ្ឌិតមានការយើតក្នុងការពោលវាចា ហើយសកម្មក្នុងការដែលត្រូវធ្វើ ។

ចប់លទ្ធិរបស់បណ្ឌិតកុង-ហ្វូ-ស៊ី

(មានទៀត)

រឿងស្រីគ្រប់លំពូណ៌

(តមក)

យុក-វណ្ណ រៀបរៀង ណោក ផេង-ស្រ៊ែ ពិន្ទុត្ថ

ប្តីថ្មកដញ្ចាត់ ប្រពន្ធកណ្តៀតកញ្ជើតាមក្រោយ តែកញ្ជើ
នោះខ្ទុះចុត ។ ប្តីដញ្ចាត់ចានត្រី ហើយចាក់ដាក់មកកន្លែកញ្ជើដែល
ប្រពន្ធកណ្តៀត ឯត្រីដញ្ចាត់ចានធ្លាក់ទៅក្នុងទឹកអស់ តាមរន្ធកញ្ជើខ្ទុះ
ឯប្រពន្ធឥតអើពើសោះ ។ លុះលុយទឹកដញ្ចាត់ទៅ ។ ប្តីប្រពន្ធ កំសត់
ចានទៅដល់ខន្ធីមន្ធីសំពៅមួយដែលឈប់ចតនៅខ្ទីនោះ ។ ប្រពន្ធ
នាយសំពៅ កាលបើឃើញត្រីចេះតែធ្លាក់ទៅក្នុងទឹកវិញតាមរន្ធកញ្ជើ
ដូច្នោះ ក៏មានវាចាប្រាប់ទៅប្រពន្ធមាយើងថា នាងអើយ! ហេតុអ្វីក៏
មិនរកបាចស្មៅចុករន្ធកញ្ជើ ! មិនអាណិតប្តីទេ្ច គ្មានដញ្ចាត់បែក
ញើសហូរញើស ហើយត្រីឥតមាននៅតង់មួយសោះដូច្នេះ ។ នាយ
សំពៅនិមិត្តតែបានឮកិរិយានៃអ្នកាសដូច្នោះគឺប្រចំណុះ ដោយខឹក
ស្មានថា ប្រពន្ធខ្លួនស្រឡាញ់ខាយើង ហើយនិយាយបន្ទោសថា ហឺ
ឯងចេះដឹងអ្វី! ។ ប្រពន្ធឆ្លើយថា បានដាំខ្ញុំប្រាប់ ព្រោះអាណិតប្តីដែល
ខំដញ្ចាត់ស្ទើរស្វាប់ហើយឥតមាននៅសល់ត្រីមួយ ។ នាយសំពៅក្តៅ
ជុំដ្រមុះ ពោលតំរែងប្រពន្ធថា បើមានឯងស្រឡាញ់វាណាស់ក៏ទៅ
ចុះ អញឥតស្រណោះទេ ។ ដែលនាយសំពៅហ៊ានពោលយ៉ាងនេះ

គ្រោះម្យ៉ាងដោយការប្រច័ណ្ឌ ម្យ៉ាងទៀត ដោយយើញប្រពន្ធមាយើងមានរូបល្អហើយចង់ជាន រួចនាយសំពៅហៅមាយើងមកនិយាយជួញប្រពន្ធគ្នា ។ ប្រពន្ធមាយើងជាន់ទៅនាយសំពៅ ប្រពន្ធនាយសំពៅជាន់មកមាយើង ដោយប្រការដូច្នេះ ។

លុះខ្ពើយនិយាយចប់ហើយ សោកណាគតក៏ញាប់ចិត្តចំពោះប្រពន្ធនាយសំពៅដែលជាន់មកជាប្រពន្ធមាយើងភាន់ពេក ។ នាងធ្វើការ នាងដើរ នាងគេង នាងតែងតែគិតដល់ប្រពន្ធមាយើង ដែលជាស្រីគ្រប់លក្ខណ៍ជាន់ច្បាស់ ។

ពេលវេលាញាំងក្រមេស៊ីខួបឱ្យប្រព្រឹត្តទៅជាធម្មតា ។ ចំណែកសោកណាគាន់តែតញ្ជូរបេតញាតិ ហើយជាទីស្រឡាញ់ពប់អាននៃកូនឈ្លួលទាំងឡាយត្រមាំដ៏អ្នកស្រុកដិតខាង ។

ឥឡូវនាងដល់សោឡសឆ្នាំហើយ ។ នាងធ្វើកិច្ចការតែងផ្ទះទាំងអស់ជំនួសម្តាយនាង ។ សោកណាមិនប្រគាន់ខ្លួនច្រណា ។ ពេលថ្ងៃនាងត្រាក់តីត្រាលឹម ដើរដាំបាយដាំទាំផ្គែមហ្អែម ទូកូនឈ្លួលប្រុសស្រីឱ្យចេញទៅធ្វើការណាតាមនាងវិញ ។ មានមានាសីជំនិតពីរនាក់សម្រាប់ទៅធ្វើការផ្ទះជាមួយ គឺនាងសុភី ១ នាងចន្ធី ១ ។ សុភីនឹងចន្ធីមានអាយុប្រឹងជាងនាងបន្តិច ។ ទោះបីមានការខុកចិត្តចំពោះសេចក្តីស្មោះត្រង់នៃមាសីទាំងពីរនោះក៏ដោយ សោកណាទៅតែមិន

បណ្តាយឲ្យទាស់ធ្វើការតែឯកឯង ដោយមិនមានការត្រួតពិនិត្យមើលខ្លះឡើយ ។

ក្រោយពេលដែលឈ្មួលប្រុសស្រីចេញផុតទៅ នាងត្រួតមើលស្តូកទំនិញទូរ៉ោសផ្ទះជួតតុទូ ដង្ហឹកដង្ហាក់ពាង ក្រោកគក់សំលៀកបំពាក់លាងបានឆ្នាំនឹងអែង ។ ល ។ នាងមិនបណ្តាយឲ្យស្តូកទំនិញខ្ជះខ្ជាំស្តូខេ នាងទុកគ្រាន់តែឲ្យជួយកំឡាំងនាងប៉ុណ្ណោះ ។ ព្រោះនាងយល់ថា ចាយសម្ងួមិនឆ្ងាញ់តិសា ដាំហេតុនាំឲ្យកូនឈ្លួលធ្វើការមិនពេញលេញ ទំនងជាហេតុនាំឲ្យចំណាយច្រើនពេក ។ នាងមិនកំណាញ់ខេ ប៉ុន្តែក្នុងហ៊ានៈជាស្ត្រីមេផ្ទះ នាងចូលចិត្តថា ត្រូវតែចេះសំចៃ ត្រូវចេះរកមុខចាយយ៉ាងណា ធ្វើកុំឲ្យចាយប្រាក់ឥតប្រយោជន៍ ។ បើស្តូកទំនិញទូរ៉ោ ធ្វើឲ្យបែកខ្ទាំងឬបែកចានឬកែវធ្វើអ្វីមិនសមរម្យ នាងមិនបន្ទោសខេ នាងបែរជាតន្សាំលោកឲ្យដំបូន្មានវិញ ។ ម្ខោះហ៊ាយទាស់ពាំងពីរគោរពនាង ត្រមាំងមានចិត្តស្រឡាញ់នាងជាទីបំផុត ។

ធនៈសង្ឃឹងតែយស្រឡាញ់កូនណាស់ ហើយខ្លួនសោកណាជាព្រះចន្ទ្រមួយវង់ក្នុងគេហស្ថានរបស់លោក ។ សោកណាជាទីគួរសមណាស់ចំពោះភ្នែកនៃទីមិត្តភក្តីនៃលោកធនៈសង្ឃជាពិតា ។ តាលណាមានភ្ញៀវមកផ្ទះ នាងយកចិត្តទុកដាក់ជូន ដោយមុខរីករាយមិនចាំបាច់ឲ្យគាត់-ម្តាយបង្គាប់ឡើយ ។ គាត់ប្រកបដោយសុខុមរបស់

ខាង បណ្តាលឲ្យក្បៀវមានចិត្តត្រេកអរនឹងសារៈសើរយ៉ាងពន់ពេក ។ មាន
ពាក្យទំនៀមមាត់ឥណ្ឌៀថា: "មានក្បៀវមកផ្ទះ ឈ្មោះថាគេនាំសិរីសួ
ស្តីមកឯ" ។ ដូច្នេះកោះបើយើងតំពុងមានចិត្តថ្នាំងថ្នាក់រវល់គ្នាក្នុងផ្ទះក៏
ដោយ បើមានក្បៀវចូលមក ត្រូវយើងសំដែងកិរិយាពេកយកពាក់ពាក់
ទៅគេក្បៀវមួយរំណែសិន បើមិនដូច្នោះ សិរីសួស្តីដែលក្បៀវនាំមក
ឱនវិនិវេសចេញពីផ្ទះយើងនឹង ។

សូម្បីស្ងួមយាចកក៏ដោយ តែមកដល់ផ្ទះសោកណាហើយ ខឿន
តែនឹងបានអ្វីខ្លះត្រឡប់ទៅវិញជាមិនខាន ។ ម្ល៉ោះហើយធនសេដ្ឋីបាន
ទៅជាកូដម្ចាស់ផ្ទះអ្នកស្រុកឡាញ់រាប់អាន រហស់មនុស្សទាំងឡាយក្នុង
ស្រុកជាមួយផង ក្នុងស្រុកដទៃផង ។

ចំពូក ៦

លុះវិលត្រឡប់មកផ្ទះកំណើតវិញ សិរីវឌ្ឍនឹងតម្កើងប្រហែសក្នុង
ការងារឡើយ ។ អ្នកជួយធ្វើកសិកម្មម្ចាស់ មិនចាយប្រាក់ផ្តេសផ្តាសទិញ
ចំណែកលុយទុកដើម្បីការពារនឹងឧបស័គ្គជាយថាហេតុ ដែលអាចនឹង
កើតមានឡើងបានក្នុងគ្រួសារ ។

បន្ទាប់ពីគេលអាពាហ៍ពិពាហ៍នៃថៅធនជាមិត្រ សិរីវឌ្ឍន៍គិតថា:
"ខ្លួនអញជាមិត្រនឹងធន ឥឡូវគេមានប្រពន្ធហើយ ។ នាំកិយាទៅទៀវ
ភូមិល្អ ដើម្បីប្រកបអាជីវកម្ម ចំណែកខ្លួនអញគួរគេម្តីតែទៅលក់ស្រែឯ

រកស្រីគ្រប់លក្ខណ៍ តាមក្បួនដែលបានរៀនមក ដើម្បីដណ្តឹងយកធ្វើជាប្រពន្ធ ។ ជីវភាពនៃគ្រួសារអញសព្វថ្ងៃ មានសភាពតាំមួនគួរសមហើយ តែថាត្រាក់តាសមានខុសបំរុងក្នុងការចាយវាយត្រប់ត្រាន់ តាមហានៈនៃគ្រួសារមធ្យម" ។

លុះពិចារណាដូច្នេះហើយ សំរើង្គន៍សុំលាឪមេម៉ាយចេញដើរស្វែងរកស្រីគ្រប់លក្ខណ៍ ដើម្បីដណ្តឹងយកមកធ្វើជាគូសង្សារ ។ ឪកាន់ជំពប់អ្នកមានគុណថា : "សូមអ្នកមេម្រាបថា ដរាបណាកូនមិនទាន់ជួបស្រីគ្រប់លក្ខណ៍ ដរាបនោះកូនមិនរើលវិញទេឡើយ" ។

នាងសារី កាលបើបានឮកូនសោះចេញទៅស្វែងរកស្រីគ្រប់លក្ខណ៍ ទឹកចង់ឃាត់កូនដែរ ព្រោះខ្លួនគាត់តែចាស់ តែនាងមែរដាអាក់ខានវិញដោយទឹកយើញថា បើឯងឃាត់កូនទៅ ហាក់ដូចជាបង្អាក់បំណងរបស់កូនជាបំណងដែលកូនបានចិញ្ចឹមពុកក្នុងដួងចិត្ត មកយូរណាស់ហើយ ។ ប៉ុន្តែ នាងគ្រាន់តែខូនាងកូនថា: " កំរិយាមាយោងជាដើមទុង ឯព្រឹត្យសម្បត្តិនឹងវិលជាដើងក្រោយ ត្រូវកូនប្រតិបត្តិតាក្យម្តាយកុំប្រមាទ" ។ ចៅសំរើង្គន៍ត្រាច់ចរៀបគយគន់តាមភូមិតូចបួលភូមិធំ ពីស្រុកមួយទៅស្រុកមួយទទួលក្តាត់នៃត្រីណា ចូលកាន់ទីក្រុងន.ា ប្រយោជន៍រកនារីគ្រប់លក្ខណ៍ ។ ជួនកាលអ្នកសំណាក់នឹងផ្ទះអ្នកស្រុក ជួនកាលជួលសំណាក់តាមវត្តលោកសង្ឃ ។ ការស្វះស្វែងនេះ បានជួបប្រទះទេវតាគ្

ទីដែលចក្តីខ្វល់ខ្វាយច្រើនប្រការ ។ ប្រាក់គាស់ដែលយកពីផ្ទះទៅចាយ
អស់រលីង សំលៀកបំពាក់ហែកគ្មានសល់ ។ ម៉េចក៏ដូច្នេះ តើអ្នក
ទីដែលធ្វើដូចម្តេច ដើម្បីភ្ញាក់ដែលចំណាយរបស់អាត្មាឲ្យសម្រេច ? មាន
ម្ចាស់ភ្ញាក់មួយ បានផ្តល់ឲ្យដល់ប្រាក់ដ ចំពោះជួនចិត្តនៃអ្នកស្រុកស្រែដែល
កំសត់ ដើម្បីជោរស្រោយបញ្ហាពីភាពបណ្តោះអាសន្ន ។ អ្នកចូលស៊ី
ឈ្នួលក្នុងសំណាក់អ្នកស្រុក អ្នកកូមិភាគរបរតស៊ីកម្ម អ្នកខ្ចាស់ឈ្នួល
តែងតែញាប់ញ័រគ្រប់គ្នាចំពោះការងារ ទីដែលបាយទៀងសីរីខ្ពស់ ។ ពោះបី
តែមានថាស្តុកស្តាលទីដែលខ្លះយ៉ាងណា ក៏អ្នករក្សាការសម្ងាត់របស់ខ្លួន
មិនឲ្យអ្នកណាម្នាក់ដឹងឮឡើយ ។

ចូរកុំលះអ្នកចូលឆ្លើការឈ្នួលរំសាយរំគេលមួយថ្ងៃ ចូនការពីរ-
ថ្ងៃ ឬបីថ្ងៃ ចូនការមួយឆ្នាំក៏មាន ហើយអ្នកឆ្លៀតនូការនោះ ក្នុង
គេលមានពាក្យក្តីដែរ ។ ដើម្បីពិនិត្យសង្កេតនាំត្រូវលក្ខណ៍ ប៉ុន្តែអ្នកពុំ
ដែលបានជួបមុខដែរសោះ ។ មានខាងខ្លះប្លែកដែរគួរសម ខាងមានដំណើរ
ទីការបង់ប្រាក់ យ៉ាង មានខាងខ្លះទៀតដំណើរគួរសម ខាងធ្វើការប្រឡាក់
ខ្មៅ ខាងមុខអុត មានខ្លះទៀតរបកគំហើម ដំណើរកំសត់ ធ្វើការ
កំណត់ជួនជាមួយក្រុម ញាញីមកស្រែសន្តដោយបើត ខាងចាំយាមមិនម៉ត់-
ចត់ ជាន់តែងាងតែងតួរដើរកុំជាន ចំណែកមួយងារបស់ខ្លួនគឺកិច្ចការ
ក្នុងផ្ទះបណ្តែតបណ្តោយទុកឲ្យតែកូនឈ្លើ ហើយបើរខ្លួនមានមិន

ជ្វាញ់ តាន់តែទៅរកម្ហូបចំណីតាហារឯផ្សារបន្តែម ។

អ្នកស្នេហ៍ស្នងយើងគ្រាំតែកក្បាល ហើយគិតថាណាថា «អញមិនដឹងនឹងទៅរកនៅឯណាទេ ឲ្យស្រីគ្រប់លក្ខណ៍នោះ ។ អញដើរមកខេះ អស់រយៈពេលច្រើនឆ្នាំ ថាខន្ធឯកាត់ស្រុកដែនក៏ច្រើន ហើយអាយុកាន់តែច្រើនផង បើបណ្តាយពុកឲ្យចាស់ខ្លួនទៅ ហើយប្រសិនបើថាខដួបនារីគ្រប់លក្ខណ៍ត្រឹមត្រូវតាមក្បួនមែន តើគេនឹងព្រមឲ្យលួយកខ្លួនធ្វើជាប្តីប្តាទេ ។

លុះគំនិតខេះដុះឡើង ស៊ីរីឲ្យខ្លួនមានសេចក្តីព្រួយថាអ្នកយ៉ាងខ្លាំង ។ ឥឡូវអ្នកមានអាយុដាច ៤០ ឆ្នាំហើយ ។

ថ្ងៃមួយអ្នកចូលទៅសំណាក់នៅវត្តលោកសង្ឃ ។ ខណ្ឌលយប់នោះមានភ្លៀងធ្លាក់យ៉ាងច្រើន ។ លោកគ្រូទៅអធិការមានព្រះហឫទ័យសប្បុរស ថាខប្រពន្ធកន្ទៃនឹងមួយស្អាតជាប់តែឯងដល់អ្នកកំសត់យើង ។ វេលាដែលព្រះគគ្គសង្ឃសឹងស្ងាត់ ហើយព្រះគ្រិះណាអន់ណា នៅមានតែគ្រាប់តូចៗធ្លាក់មក ដំណក់ភ្លៀងដែលស្រក់ពីលំយាបមកដល់ក្បាលឲ្យមានសូរជាបង្អាក់តក់ . . . តក់ . . . តក់ មកប៉ះនឹងសោតប្រសាទ ថាកំសត់អនាថា ។ ដោយយកសូរដំណក់ទឹកភ្លៀងជាអារម្មណ៍ ថាកំសត់ស្រាប់តែរលឹកស្រុកកំណើត រលឹកដល់ម្តាយមេម៉ាយដែលអ្នកចាន់លះបង់ចោលមកជាយូរឆ្នាំ តុំដឹងជាលោកមានសេចក្តីសុខទុក្ខយ៉ាងណាៗ

អ្នកនឹកចង់សំដីចៅធនជាសំណួរញាំ ដែលបានហាមឃាត់មិនឲ្យរៀនវិជ្ជានេះ ។ ទើបមានគំនិតថ្មីមួយកើតឡើងថា «ស្រីគ្រប់លក្ខណ៍មានប្តីគ្មានបើមានក៏មិនដឹងនៅឯណា ។ ម្យ៉ាងទៀតរឿងគ្រប់លក្ខណ៍នឹងមិនគ្រប់លក្ខណ៍នោះ ស្រេចនៅលើការអប់រំរបស់គ្រួសារនឹងរដ្ឋាភិបាលទេតើ ។ ក្មួនដែលអញបានរៀននេះជាក្មួនកុហក អញគប្បីរៀបត្រឡប់ទៅស្រុកកំណើត ហើយបន្តការជាមួយប្រពៃណីរបស់មាតាវិញ ទើបល្អ ទើបសមជាកូនមានសេចក្តីកតញ្ញូ" ។

ប៉ុន្តែក្នុងរឿងនោះ ស្រាប់តែបំណងដើមជ្រែកចូលមកដំណាស់ក្នុងៈ បើមានក្មួនហើយ ស្រីគ្រប់លក្ខណ៍ទៀតមាន ។ ពាក្យបុរាណមានចែងទុកមកថា "មិនដែលមានក្តីឆ គ្មានផ្សែងទេ" ។ ត្រូវតែញ៉ាំងបំណងក្នុងដែលបានដៅទុកនោះឲ្យសម្រេច ទើបគេញាប់អង្គុយប្រុស ឯការសុខទុក្ខជាធម្មតារបស់មនុស្សលោក មិនគួរក្រេកឆ្ពោះតាមកម្លាំងឲ្យលំនេះឡើយ ។

ព្រឹកឡើង សិរីវឌ្ឍន៍ក្រោកថ្ងាយៗឆ្ងំលាលោកគ្រូមេត្តា ហើយធ្វើដំណើរចេញទៅទៀត ដោយដោតចិត្តទៅលើស្រីគ្រប់លក្ខណ៍យ៉ាងមាំឥតកម្រើកដូចសត្វប្រឡាំងកាសឈ្មោល តាំងផ្តែកវាសនាលើប្រឡាំងកាសញ៉ាដូច្នោះ ។ អ្នកនោះបន្តដំណើរផ្សេរព្រៃទៅទៀត ចូលព្រៃលេចវាលផុតពីវាលចូលព្រៃ កាត់ស្រុកតូចធំនិគមជនបទ ហើយតាំងចិត្ត

ចូរជាអាយុដ៏វែងស្រេចស្រែត្រង់លក្ខណ៍ តើថាបើមិនបានជួបទេ ស្លាប់ក្តី រស់ក្តី អ្នកលែងគិតដល់តំណអស់ ។

ចាប់តាំងពីសិរីវឌ្ឍន៍ចេញចាកស្រុកតំណើតមកដល់ថ្ងៃនេះ មានចំនួនដប់ប្រាំបីឆ្នាំហើយ ។ អ្នកដើរទៅរកផ្ទះ ដោយចិត្តស្មានថា មិនលែងនឹងមានកូនមែនទៅទាំងមុខ ។ ប៉ុន្តែពុំដូច្នោះ អ្នកដើរចូលទៅក្នុងព្រៃញាតិសន្តានសោះ ទើបថយក្រោយកំឡាយ ម្ល៉ោះហើយបុរសគំនត់តោងតែតបុលទៅមុខ ។ ស្បៀងគាហារគ្មាន ។ អ្នកគាស្រេវស្រែតែផ្លែឈើបន្តបន្តេស ។ មុខទឹងនឹងបេះមកខួលពាន អ្នកឃ្លាំមើល ថើសត្វស៊ីផ្លែណាខើបអ្នកហ៊ានស៊ីផ្លែនោះ ។ ភោគាវរៃហែកដាច់អស់ ដោយគោសទឹងបន្ទាប ។ សិរីវឌ្ឍន៍អស់សង្ឃឹមព្រោះអ្នកឃើញតែសេចក្តីស្លាប់នៅប្រចាំតែម៉ុង ។ អ្នកដើរតេច គ្រាន់តួនអំពីសត្វសាហាវ មានដំរីខ្លាចចេកជាដើម ។ ឃ្លើ ។ អ្នកឮខ្លាស្រែក ដំរីកេងខ្លែ ដែលធ្វើឲ្យអ្នកព្រឺកស់សពាង្គកាយស្ងើរស្ងេតជាក់ស្មារតី ។ ជួនកាល គោះភ្លាត់ជំរុសម្បើមលៀនអណ្តាតភ្លែម ។ ឃាតាត់មុខអ្នក ជួនកាលអ្នកដើរជាន់លើទ្បាដំរី ហើយអ្នកភ្ញាក់ភ័យ ស្ទុះស្រែកភ្ញាត់មាត់ តែម្នាក់ឯងកណ្តាលអព្វា ឥតមានជនណាម្នាក់ជួយញញឹម ឬជួយព្រួយអ្នកឡើយ ។ ជួនកាលអ្នកត្រាច់ត្បូល ។ ភៅ ស្រាប់តែកប្បាសំអុតមានសុទ្ធតែសរសៃពីងពាងព័ទ្ធជុំវិញ អ្នកត្រូវតែឈប់អង្គុយដើម្បីបេះសរសៃចេញ

ខេះចាលចេញដោយសឹមៗ ព្រោះអ្នកភ្ញាប់ឮចាស់ ។ តោលថាស្មារតី
ឥឯពាងចំរៃក្នុងទឹងខ្លាក់ ។ ម្ល៉ោះហើយអ្នកត្រួយណាប់ លោតែ
ខ្លាក់ក្នុក មិនដឹងបើមឹងទៅចិតឯដនណាឡើយ ។ ពេលកត្រីអ្នក
ឡើងដេកលើប្រតាបឈើ ខ្លាចក្រែងសត្វសាហាយដោយ ។ កណ្តាល
យប់ស្ងាត់ឈឹង សំឡេងតូកនឹងលលកភ្លេចដែលទម្លុះហៅស្រែតាជា
ទីសម្ងំសម្រាកនៃសត្វទាមា ធ្វើឲ្យអ្នកត្រីក្បាលប៉ុនកះញ្ជ ។ សីរីខ្ពស់
ត្រាចំតែក្នុងព្រៃអស់យេះពេលកន្លះទៃ ។

ត្រលឹមថ្ងៃទី ១៦ អ្នកចុះតាំដើមឈើ ហើយដើរទៅមុខបន្តិច
ស្រាប់តែឮសូរស្ទើរស្ទិបៗ ដូចឲ្យលាប់ទាក់ទៅតាមដងមុខ ។ ប៉ុន្តែស្ទឹក
ឈើឥតកម្រើក ។ ក្រឡេកមើលតាមចន្លោះដើមឈើទៅមុខ អ្នក
ឃើញដៃថ្ងូរសាចាំងផ្លេត ។ គឺជាស្ទឹងមួយដែលហូរមកពីជ្រោះភ្នំ ហើយ
ហូរតាត់កណ្តាលព្រៃហាត់ព្រៃហាងនេះ ។ បុរសអនាថាឈរនៅមាត់
ស្ទឹងក្រឡេកមើលទៅត្រើយម្ខាង ក្រឡេកមើលបន្តាយតាមដងស្ទឹង
ដោយសេចក្តីទុក្ខព្រួយ ។ អ្នកជញ្ជឹងគិតថា បើនឹងធ្វើទៅត្រើយនាយ
តើបានអ្វីធ្វើ ឥឡូវនេះដែលខ្លាចក្រែងមានក្រពើ ។ ទៅទីនោះមិន
មានអ្វីជាសញ្ញាថា មានមនុស្សមកដល់ឡើយ អ្នកឃើញតែស្មាមជើង
សត្វព្រៃដែលដើរចុះមកកេះទឹកធឹក ។

បុរសអនាថាសំឡឹងទៅខាងណោះម្តង ទៅខាងណោះម្តង ដារបៀប

មនុស្សពាល់គំនិត ។ ចន្លិចមក អ្នកឃើញអ្វីស្ងួតអណ្តែតចុះមកតាមទន្លេ ។ អ្នកសំឡឹងមិនដាក់ក្នុក ដោយសង្ឃឹមថាប្រហែលជាទូកបស់អ្នកស្រុកណាអុំមក ហើយខ្លួនមុខជានឹងអាចសុំដំរោះដោយសារផងបាន ។ ចុំន្តែលុះមកជិតល្មមសំគាល់បានថាជាអ្វី គឺគល់ឈើសោះ ជាគល់ឈើដ៏ធំយ៉ាងធំចង្រ្កាន ។ កាលបើបានយល់ច្បាស់ជាគល់ឈើហើយ សំរីវិញ្ញាណសុះសៅចុចវិលនៅដដែលនោះឯងមួយខន ។ ជាកុសល គល់ឈើនោះអណ្តែតកន្ទេរត្រើយដែលអ្នកឈរនៅ ។ លុះគល់អណ្តែតមកខន្ធឹម អ្នកតំត្រៃវិនវិលដួចគេចដ៏សំណាញ់ ដោយគាន់ចុងតំងិនសងខាង ហើយចាក់ពាក្យអួសសន្សឹមៗចូលមកខាងបាន ។ អ្នកតិតថា ទៅឯនាយខាងក្រោមស្ងួត មុនជានឹងមានភូមិមនុស្សដាមិនខាន ។ រួចអ្នកឡើងលើគល់ បណ្តែតខ្លួនតាមយថាកម្ម ដោយពឹងផ្តែកទៅលើដំណួយនៃខ្ពង្គា ។

ចំណែកព្រះអាណារះឡើងយ៉ាងច្បាស់ ចាំងរស្មីមកលើក្តារតាវលិ្ងតំងិនច្បាយ ជាប្រផ្នូលនៃថ្ងៃប្រកបដោយសុភមង្គល ។ គេឮសូរមាន់ព្រៃរងាវស្រួយស្រែសខ្ទួលព្រះអាទិត្យ ដែលទើបត្រាច់ចរចាកចេញពីយប់សន្ធិយា ហើយដែលធ្វើឲ្យសត្វតាតព្រឹនព្រមតាំងមនុស្សនានាប្រុងសាកសេចក្តីព្រួយបារម្ភ អំពីការស្ងិតនៅក្នុងរត្តិកាលនោះ ។

(មានត)

បន្ទាមុត យកបន្ទាជោះ

លោក ប៊ូ-ប៊ុ រៀបរៀង

វិស័យមនុស្សភាល បើពុំមានម្នាក់ណា សង្កត់សង្កិនផ្លាញ់ផ្លាល ទេ ក៏តែតែបានចិត្តព្រហើនកោងកាចឈ្លានពាន ទាំងឡើងលើសដើម ដោយសំគាល់ថា គេខ្លាចខ្លួន ដូចគ្រាប់គៀបម្ជូបានហើយ កំឡើងចាំបេះតែគៀបញាយ ។ តទៅទៀត ។ ប៉ុន្តែ បើមានម្នាក់ណាគេដឹងពុតខាន់ គេធ្វើអំពើយង់ឃ្នងផ្លាញ់ផ្លាល់តបវិញក្លាម ។ ។ មនុស្សភាលកំនឹងកងចាលអស់ពុតត្បុតខ្លះមិនខាន ។ ដូចមានរឿងដំណាល ក្នុងកូដកំណែជាតតទុកនិបាតថា ៖

មានឈ្មួញពីរនាក់ ម្នាក់នៅក្រុង ម្នាក់នៅស្រុកស្រែ ជាសម្លាញ់នឹងគ្នាយ៉ាងជិតស្និទ្ធ រកស៊ីលក់ដូរចូលគ្នាជានិច្ច ពាល់តែដឿចិត្តគ្នាទៅវិញទៅមកឥតសង្ស័យ ។ ថ្ងៃមួយ ឈ្មួញនៅស្រុកក្រៅយកផាលច្រាំយទៅដើរកនឹងឈ្មួញនៅកងក្រុង ។ ឯឈ្មួញអ្នកក្រុងខ្លួលយកផាលទៅទុកនៅកន្លែងមួយ ហើយចេះតែលក់ដាច់អស់ផាលទៅ ទើបគិតថាសម្លាញ់អញ ដឿទុកចិត្តអញយូរណាស់មកហើយ អញនិយាយគ្នា កំចេះតែដឿអញដែរ ឥឡូវនេះ ត្រូវអញធ្វើឲ្យបាយកលយកប្រាក់ថ្លៃផាលរបស់សម្លាញ់ឲ្យអស់ទាំងប្រាំយោងផាល, ទើបប្រើមនុស្សឲ្យកេរតេបអាចម៍កណ្តុរ

ពីខែនេះខែនោះឲ្យបានច្រើន យកមកបាក់តវាជាតំនរធំនៅត្រង់កន្លែងដែលខ្លួនជាត់ផ្ទាល់នោះ ធ្វើហាក់ដូចជាកណ្តុរស៊ីផ្ទាល់អស់ ដោយតំនិតគិតពុតថាមើលម្ចាស់ឯញមកពារប្រាក់ថ្លៃផ្ទាល់ ឯញនឹងប្រាប់ថា បានប្រាក់ពីណាមើលកណ្តុរវាស៊ីផ្ទាល់អស់ទៅហើយ ឥតបានលក់ផ្ទាល់មួយសោះ ។

កន្លងមកមិនយូរប៉ុន្មានថ្ងៃ ឈ្មួញស្រុកក្រៅមកពារកប្រាក់ថ្លៃផ្ទាល់ពីឈ្មួញអ្នកក្រុង ។ ឈ្មួញអ្នកក្រុងធ្វើឫកពាហាក់ដូចជាអាណិតម្ចាស់ខ្ចាំងណាស់ និយាយប្រាប់ថា ឥម្ចាស់! ខ្ញុំមិនចង់នឹកនាទេ តែនឹកពីរឿងផ្ទាល់ឡើង អាណិតម្ចាស់ណាស់ស្ទើរស្រក់ទឹកភ្នែក ដ្បិតកណ្តុរវាស៊ីផ្ទាល់ចាំងប្រាំរយអស់រលីង ឥតសល់ផ្ទាល់មួយសោះ សូម្បីតែលក់ជាប់ផ្ទាល់មួយកំភួនដៃរ ខ្ញុំឲ្យគេរៀបពុកជាត់ផ្ទាល់ទៅកន្លែងមួយជិតជិតល្អណាស់ លុះកន្លងមកមិនយូរប៉ុន្មាន ខ្ញុំឲ្យមនុស្សទៅដញ្ជូនយកផ្ទាល់មកលក់ ស្រាប់តែជាត់ផ្ទាល់អស់ គ្មានឃើញមួយសោះ ត្រូវប្រាប់ជាឃើញសុទ្ធតែអាចម៍កណ្តុរទៅវិញ ប្រាកដជាកណ្តុរវាស៊ីផ្ទាល់អស់ ហើយវាជុះអាចម៍ពុកគរទៅកន្លែងនោះ មើលម្ចាស់មិនដឹងខ្ញុំ ចូរម្ចាស់ទៅមើលឲ្យឃើញនឹងភ្នែកខ្លួនចុះ រឿងនេះហួសវិស័យខ្ញុំនឹងថែរក្សាការពារបានហើយសូមម្ចាស់កុំគិតស្មានថាជាការអ្វីឡើយ ។ ឈ្មួញជនបរទួលទៅមើលកន្លែងជាត់ផ្ទាល់ ឃើញសុទ្ធតែអាចម៍កណ្តុរមែន ទើបនៅស្ងៀមស្ងាត់មិនថាអ្វីមួយម៉ាត់ស្រោះ ប៉ុន្តែ ខឹកកន្ធិចក្តីថា ផ្ទាល់ជាដែក ជារបស់រឹង

ណាស់ ៖ មិនមែនជាគាហារចំណីរមេស់តណ្ហាទេ ហេតុអ្វីគំរាមញ៉ែអញ
និយាយថាតណ្ហាស៊ីផ្លែអស់ ឆ្នេញតណ្ហាគេចតែដែកជាចំដែរឬ ?
ម្យ៉ាងទៀត កូនឬសរបស់ដែក គឺមិនគួរទាំឲ្យតណ្ហាកាត់ឬស៊ីបានទេ
បើដូច្នេះ ចាស់ជាសម្ងាក្ងៀនេះមិនស្មោះត្រង់នឹងអញទេ មុខជាគិតកោង
ក្រោកច្រាស់យកច្រាក់អញជាច្រាកជ ណ្តើយចុះ ចាំអញគិតធ្វើឲ្យបាយ
កលផ្ទាល់នឹងឲ្យបានកលវិញ ព្រោះវិស័យកាលបើមិនធ្វើឲ្យដឹងខ្លួន
ខ្លះទេ មុខជាក់ចេះតែបានចិត្ត ចេះតែឡើងថាង ហ៊ានកុហកបញ្ឆោត
ក្រោកច្រាស់អញញយ ។ តទៅទៀត ហើយព្រហើនមើលងាយអ្នកដទៃ
ថាគេមិនដឹងដល់គំនិតខ្លួនរៀបរៅរបស់ខ្លួន ពេលនេះ គួរតែអញខ្លួនាន
សម្ងាក្ងៀនអញដោយអាជ្ញាដ៏ធ្ងន់ ទើបបាន ស្មើសមគ្នា ។

ឈ្មួញជនបទស្រុកក្រៅ លុះគិត ឃើញយ៉ាងនេះហើយ ថ្ងៃមួយ
ទៅលួចនាំយកកូនប្រុសតូចរបស់ឈ្មួញអ្នកក្រុងទៅផ្ទះគឺកឯកំពង់ ហើយ
នាំកូននោះទៅផ្ញើលាក់បំពួនទុក ឪពុកញាតិសន្តានរបស់កូនមិនឲ្យ
អ្នកណាដឹងឮ ហើយផ្តាំថា កុំឲ្យកូនតូចនេះចេញមកក្រៅបន្តិចឲ្យសោះ
រហូតដល់ខ្ញុំត្រឡប់មកយកកូននេះទៅវិញ ។ អ្នកផ្ទះគំរាមលើលថែរក្សា
កូននោះតាមបណ្តាំគ្រប់ប្រការ ។ ឯឈ្មួញអ្នកស្រុកក្រៅផ្ញើកូនរួចហើយ
ត្រឡប់ទៅឯផ្ទះឈ្មួញអ្នកក្រុងវិញ ។ ចំណែកឈ្មួញអ្នកក្រុងបាត់កូន ខំ
ដើរកេសព្វច្រកល្ហកពុំឃើញ ជ្រួតកាលសម្ងាក្ងៀនលួចនាំយកកូនទៅនោះ

ខ្ញុំពុំបានដឹង លុះស៊ើបសួរដំណឹងទៅ ឮគេថ្លែងថា សម្លាញ់នាំកូនទៅ
ងូតទឹកតាំងពីព្រឹកព្រហាម លុះពេលដឹងព្រលប់ទើបឃើញសម្លាញ់ខោះ
មកដល់ផ្ទះ ក៏ស្រែកសួរពីចម្ងាយថា នែសម្លាញ់ អ្នកនាំកូនខ្ញុំទៅងូតទឹក
មែនឬទេ ?

ឆ្លើយ- ខ្ញុំនាំកូនអ្នកទៅងូតទឹកមែន ។

សួរ - នាំទៅងូតទឹកកន្លែងណា ?

ឆ្លើយ- នាំទៅត្រង់កំពង់អ្នកនេះឯង ។

សួរ - ចុះម៉េចក៏បាត់យូរដល់ម្ល៉ះ ?

ឆ្លើយ- ព្រោះតើតហេតុដែលគួរឲ្យតក់ស្លុត បើប្រាប់គេទៅ
គ្មានអ្នកណាជឿទេ ។

សួរ - តើតហេតុដូចម្តេចខ្លះ ?

ឆ្លើយ- តើតហេតុខ្លួនឆាបកូនក្មេង ។

ឈ្មួញអ្នកក្រុង គ្រាន់តែឮដូច្នោះ ក៏ខឹងដល់កូនខ្លួនភ្លាម ទើប
សួរយ៉ាងប្រញាប់ថា កូនខ្ញុំទៅឯណា ?

ឆ្លើយ- កូនសម្លាញ់សត្វខ្លួនឆាបយកទៅបាត់ហើយ, ខ្ញុំចុះ
ទៅងូតទឹក ឮវាទៅចាំលើមុត្រាំង ស្រាប់តែសត្វខ្លួនហើរចុះពីអាកាស
មកឆាបយកកូនសម្លាញ់បាត់ទៅ ខ្ញុំដេញវាមិនទាន់សោះ ជាការហួស
វិស័យរបស់ខ្ញុំ ។ ដេញតាមវាលតែអស់កម្លាំងតែមិនរួច ទើបវិលមកវិញ

ព្រោះជាប់ដេញតាមសត្វខ្វែង ថ្មានជាខ្ញុំបាត់ឃ្លាតាំងពីព្រលឹម ដល់ព្រលប់យ៉ាំងនេះ ។

ឈ្មួញអ្នកក្រុងទឹកអាល្អេះអាល័យស្តាយកូន ក៏ខ្លួញយំសោកស្រក់ទឹកភ្នែកសស្រាក់ហើយនិយាយថា សត្វខ្វែងនោះខ្លួនវាតូចទេ ម៉េចក៏វាធាបយកកូនខ្ញុំដែលខ្លួនធំជាងវាទៅរួច ពាក្យអ្នកឯងនោះមិនគួរឲ្យជឿទេ (ដែលគេថាយ៉ាំងនេះ ព្រោះគេក្លែងរឿងកណ្តុរស៊ីដាលដែក) ។

ឈ្មួញស្រុកក្រៅធ្វើយថា សត្វខ្វែងវាតូចក៏មែនហើយ ប៉ុន្តែវាធាបយកកូនទៅបាន ទើបជារឿងគួរឲ្យទ្រាំ គួរឲ្យអស្ចារ្យណាស់ អ្នកចាំងពីរប្រកែកដដែកឈ្លោះគ្នាជាខ្លាំង ឈ្មួញអ្នកក្រុងប្រកែកមិនព្រមជឿថា សត្វខ្វែងធាបយកកូនខ្លួនសោះ សូម្បីស្តាប់ឮចាំងអស់ ក៏គ្មានអ្នកណាម្នាក់ជឿដែរ ។ ឯឈ្មួញស្រុកក្រៅ ប៉ះពុកជាគេមិនជឿពាក្យខ្លួនសោះ ក៏នៅតែនិយាយពាក្យដដែលថា សត្វខ្វែងធាបកូនក្មេងយកទៅបាត់ មិនរើរុះប្រប្រួលឡើយ ។ ទើបឈ្មួញអ្នកស្រុកក្រុងនាំយករឿងនេះទៅប្តឹងទៅក្រមសាលាចាប្រកាន់ថា ឈ្មួញស្រុកក្រៅសម្លាប់កូនបេះខ្លួនដោយគាងថា សត្វខ្វែងធាបយកទៅ ។

គាលគុលាការសួរដេញដោលថា «អ្នកបាននាំកូនក្មេងទៅដូតទឹកឯកំពង់ពិតមែនឬទេ ?

ធ្វើយ— បាទ! ខ្ញុំបាទបាននាំក្មេងនោះទៅដូតទឹកមែន ។

សួរ – សត្វខ្វែងឆាបយកក្មេងនោះទៅមែនឬ ?

ឆ្លើយ– ចាទ! មែនពិតហើយ ។

តុលាការសួរផ្ទួនៗដល់ ៣ ដងថា សត្វខ្វែងឆាបយកក្មេងនោះទៅមែនឬ ? ឆ្លើយថា មែនពាំង ៣ ដង ។ តុលាការមិនជឿពាក្យថា សត្វខ្វែងឆាបក្មេងនោះសោះ ចេះតែជម្រឹតសួរហើយសួរទៀតគំហកគំហែងយ៉ាងណា ចម្លើយនោះតែឆ្លើយប្រកាន់ពាក្យដដែលឥតរើរុះ ។

តុលាការនឹងវិនិច្ឆ័យថា ចម្លើយ សម្ងាប់កូនក្មេង ឬលួចតម្រិតកូនក្មេងក៏មិនបាន ព្រោះពុំមានសាក្សីជាសំអាងថា ចម្លើយបានធ្វើយ៉ាងនោះមែន, ឬនឹងវិនិច្ឆ័យតាមពាក្យរបស់ចោទក៏ថា ក្មេងនោះសត្វខ្វែងឆាបយកទៅក៏មិនបាន ព្រោះមិនមានអ្នកណាដឹងឃើញឯង ទើបតុលាការលួងលោមឈ្មួញស្រុកគ្រៅថា សូមទ្រាំបន់តាមការពិតទៅចុះ រឿងនេះតើដូចម្តេច ?

ឈ្មួញស្រុកគ្រៅតបថា គេលនេះ គួរអញ្ជើញសេចក្តីពិតហើយ ទើបចាប់ផ្តើមសួរតុលាការថា លោកខ្ចាប់ឃើញកណ្តុរស៊ីផាលដែរឬទេ ?

តុលាការឆ្លើយថា យើងមិនខ្ចាប់ឃើញទេ លុះឆ្លើយយ៉ាងនេះហើយ លោតែនឹកឃើញក្តាមថា ប្រហែលជាចោទក៏នឹងចម្លើយមានរឿងខាស់ខែងគ្នាពីមុនមកហើយ ទើបសួរថា រឿងកណ្តុរស៊ីផាលនោះមាន

ហេតុដូចម្តេចខ្លះ ចូរដំណាលឲ្យយើងស្តាប់ផង ។

ឈ្មួញស្រុកក្រៅដំណាលរឿងដើមប្រាប់តុលាការថា យើងខ្ញុំទាំង
ពីរនាក់ជាសម្លាញ់ធំជិតគ្នា ដើរកុកចិត្តគ្នាជាយូរយារណាស់មកហើយ ខ្ញុំ
បានយកដាលដែកប្រាំរយទៅផ្ញើធំជិតសម្លាញ់ពុកលក់ឲ្យផង លុះខ្ញុំមកទារ
ប្រាក់ថ្លៃដាល សម្លាញ់អ្នកចោទក៏ប្រាប់ខ្ញុំថា ដាលអ្នកឯងធំកណ្តាស៊ីអស់
ទៅហើយ អ្នកចូរទៅមើលអាចម៍កណ្តាចុះ ខាងក្រោយមក ខ្ញុំទាំកូនចៅស់
សម្លាញ់ទៅដូតទឹក ក៏កើតសត្វខ្លែងមកនាយយកកូនក្មេងទោះ។ បើ
កណ្តាស៊ីដាលបាន សត្វខ្លែងក៏នាយយកក្មេងទៅបានដូចគ្នា បើកណ្តា
ស៊ីដាលមិនបានទេ សត្វខ្លែងក៏នាយយកក្មេងទៅមិនបានដូចគ្នាដែរ ។

ទើបតុលាការសួរចោទក៏ថា កណ្តាស៊ីដាលមែនឬទេ ?

ឆ្លើយ- រឿងនេះមិនមែនទេ ព្រោះខ្ញុំបញ្ជោតយកប្រាក់ថ្លៃដាល
របស់គេ បានជាប្រាប់តុលាការថា កណ្តាស៊ីដាលអស់ទៅហើយ ។

សួរ- អាចម៍កណ្តាមានប្រែនទៅកខ្លែងនោះមែនឬទេ ?

ឆ្លើយ- មែន ព្រោះខ្ញុំប្រើមនុស្សឲ្យដណ្តើមអាចម៍កណ្តាយកពី
ដៃដែលមកបាក់នៅពីនោះ ។

សួរ- អ្នកព្រមបង្វិលប្រាក់ថ្លៃដាលឲ្យដល់ចម្លើយវិញឬទេ ?

ឆ្លើយ- ខ្ញុំព្រមបង្វិលប្រាក់ថ្លៃដាលឲ្យចម្លើយតាំងអស់ ។

តុលាការនិយាយនឹងចម្លើយថា ឥឡូវនេះ ចោទគេព្រមឲ្យ

ប្រាក់ថ្លៃជាលមកអ្នកវិញហើយ រឿងកូនបស់ចោទក៏ដែលអ្នកនាំយក
ទៅឆ្លូតចំកន្លោះ សុគូខ្លួនឆាបយកទៅមែនឬទេ ?

ឆ្លើយ- មិនមែនទេ !

សួរ- អ្នកយកក្មេងនោះទៅទុកឯណា ?

ឆ្លើយ- ខ្ញុំយកទៅផ្ទើទុកនឹងញាតិនៅភូមិឯណោះ ។

សួរ- អ្នកព្រមទៅយកកូននោះមកប្រគល់ឲ្យចោទក៏វិញឬទេ ?

ឆ្លើយ- បើចោទក៏ព្រមបង្វិលប្រាក់ថ្លៃជាលឲ្យខ្ញុំ។ ក៏នឹងព្រមបង្វិលក្មេងឲ្យដល់ចោទក៏វិញដែរ ។

តុលាការនិច្ឆ័យឲ្យឈ្មួញអ្នកក្រុងប្រគល់ប្រាក់ថ្លៃជាល ឲ្យទៅឈ្មួញស្រុកក្រៅ ហើយនិច្ឆ័យឲ្យឈ្មួញស្រុកក្រៅប្រគល់កូនឲ្យឈ្មួញអ្នកក្រុងវិញ ។ ចាប់ដើមអំពីនោះមក ឈ្មួញទាំងពីរនាក់ក៏សុខចិត្តសងជំនឹងគ្នាលែងចោទប្រកាន់គ្នាទៅវិញទៅមក ប៉ុន្តែ លែងទុកចិត្តគ្នាតទៅមុខទៀត។

រឿងនេះ ជានគតិជា ២ យ៉ាងគឺ:

១- ឈ្មួញអ្នកក្រុង ត្រូវមហាជនតិះដៀលថាជាមនុស្សអាក្រក់ខ្ជះខ្ជិតខ្ទ្រុស្តមិត្ត មិនគួរអ្នកជនឯចូលសមាគមសេពគប់ជាប់រកឡើយ ។

២- ឈ្មួញស្រុកក្រៅ ត្រូវមហាជនលើកដំកើងសរសើរថាជាមនុស្សល្អសុចរិត មានទុប្បាយល្អិតសុខុមគិតធ្វើកិច្ចការល្អញ៉ាំញ៉ីលកិច្ចការចំបាត់សេចក្តីខ្ជះខ្ជិតរបស់ឈ្មួញអ្នកក្រុងជាន ដូចសុភាសិតបុរាណថា ៖

បិត្តាមុត្ត យកបន្ទះជោះ ។

ទៅលេងស្ថានសួគ៌ប្លងដំបូង

លោក ញ្ញង-សឿង រៀបរៀង

កាលពីយូរទៅបន្តិចហើយ មានសេចក្តីដំណាលថា មានគ្រូគ្រះកម្ពង់ខ្ញាក់នៅក្នុងតំបន់មួយ ល្បីល្បាញថាជាអ្នកចេះដឹងធម៌វិបស្សនាកម្មដ្ឋានច្រើនល្អិតល្អន់ណាស់ ។ យាង-តាចាស់ ។ តាំងជិត តាំងឆ្ងាយ ផ្តើលក្តួលឈូងរៀងសមណធម៌(១)ពីលោកគ្រូខោះជាច្រើនគ្នាណាស់ ស្ទើរតែកេតូបនៅសំណាក់ឥស្សរិយមិនបាន ។ លោកគ្រូគ្រះកម្ពង់ខ្ញាក ជាទីពឹងលាភសក្ការៈច្រើនពាសពេញប្រជ្រុសជាយភ្នំយ៉ាងធូរស្រួល ។ ឯអ្នកដែលបានរៀនចេះហើយត្រឡប់មកផ្ទះវិញ· មិនដឹងជាបានរៀនដល់ថ្នាក់ណា ហើយជាទីសម្រេចធម៌ព្រះកម្ពង់ខ្ញាកនោះដូចម្តេចទេ, តែចេះតែអួតសរសើរតៗគ្នាថា បណ្តាគ្រូគ្រះកម្ពង់ខ្ញាកទាំងអស់មានតែលោកគ្រូមួយនោះទេដែលគេញាំងគ្រូ "ធម៌ក្នុង" ពិតប្រាកដ ។

ថ្ងៃមួយ មានយាយម្នាក់ឈ្មោះយាយខែន នៅភូមិឡាយពន្តិចពីតំបន់នោះ គាត់ជាទីគោរពសរសើរលោកគ្រូខោះខ្លាំងណាស់អត់ព្រំមិនជាន កំផ្តើលទៅនឹងគេដែរ ។ ក្មួយប្រុសរបស់គាត់ ជានរៀបចំប្រដាប់ប្រដាជូនដំណើរគាត់ទៅតាមបំណង ។ មិនយូរថ្ងៃប៉ុន្មានយាយខែនក៏ជានិលត្រឡប់មកផ្ទះវិញ ។ គាត់មានថ្ងូរតាតរិយាបថរបៀប

១- សព្វថ្ងៃគេហៅក្បាយថា សំណាក់ធម៌ ។

ស្រេគត់ស្រេគំរម្យាមដាងពីមុន តាំងពីថាហានិយាយឡើងកាលណា
តំបែកពីជម្ងឺតាហើយគាត់ច្រើនតែនិយាយឱ្យចិត្ត ។ ហើយ ។ផង ជា
ហេតុនាំឱ្យក្លួនចៅរបស់គាត់ ព្រមទាំងអ្នកជិតខាងភូមិផងរបងជាមួយខ្លះ
សំគាល់ពុតដាក់ថា គាត់ចាស់លុះធម៌សមាធិ យ៉ាងជ្រៅជ្រះម៉ត់ចត់ពិត
ប្រាកដមែនខែន ។ កាលបើមានអ្នកជិតខាងដែលធ្លាប់ស្និទ្ធស្នាល ទៅ
និយាយលេងសំណាន្តជាមួយនឹងគាត់ ដោយពាក្យមិនគួរសមផ្តេសផ្តាសគាត់តបភ្លាមថា "ខ្ញុំឥឡូវនេះមិនដូចតាដែមទេ" ហើយបើមានគេសាកសួរគាត់អំពីរបៀបធម៌កម្មដ្ឋានយ៉ាងណា ។ គោះ គាត់តបថា រឿងនេះលោកគ្រូចាន់ហាមដាច់ខាត ប្រាប់មិនបានទេ ព្រោះជា "ធម៌កុង" អ្នកណាចាន់ទៅរៀនផ្លាស់ខ្លួន អ្នកនោះទើបបានដឹងចំពោះខ្លួនតែម្នាក់ឯង ។ កាលបើគេចេះតែដដែកសួរដេញដោលខ្លាំងៗទៅទៀត គាត់គ្រាន់តែប្រាប់យ៉ាងខ្លីថា គាត់ចាន់ធ្វើហានសម្រាប់ខ្លួនគាត់ពុតជាស្រេចហើយ ។ ពួកអ្នកស្រុក អ្នកភូមិនោះ លុះបានឮដូច្នោះហើយ ក៏បែកយោបល់គ្នាជាពីរ អ្នកខ្លះថា យាយខែនដូចជាមិនសូវស្រួលបែបបែក ធ្នូង, អ្នកខ្លះថា កុំនិយាយលេងវ៉ុយ គាត់ចាន់លុះ "ធម៌កុង" របស់គាត់ពិតប្រាកដមែនហើយ ។

ចំណែកយាយខែន គាត់តែងអត្តិយការនាស្មើងស្មាធ៌ទៅមុខគ្រែព្រះធម៌ ក្នុងផ្ទះគាត់រៀងរាល់យប់ជាធម្មតា ។ តាមពិតមក, យាយខែន

តែងរឿបខ្សៀវ ពណ៌នាអួតសរសើរយ៉ាង តែពីរឿងស្តេចតាវតឹង្ស
ស្តេចតុសិតថា សម្បុរអស្ចារ្យណាស់ ព្រោះត្រូវឆន័តាត់ចាន់ដៅដល់
រឿងកល់យប់ក្នុងពេលដែលគាត់ចាន់ចូលតាន់សមណធម៌នោះ។ យ៉ូវៗដៅ
យាយវែន ចង់ហោះដៅស្តេចបួតិតាំងរូបស្រស់ ព្រោះគាត់គិតថា ចាន
ដៅដល់តែត្រូវឆន័ដូចជាមិនអស់ចិត្តសោះ, ដើមថ្ងៃមួយ គាត់ចូល
តាន់សមណធម៌តាំងថ្ងៃត្រង់ ក្នុងបន្ទប់ផ្ទះគាត់មួយស្របក់ធំ ស្រាប់តែ
គាត់ក្រែកតាមុខត្រែវព្រះធម៌ ហើយស្ទុះឡើងឈរចំពុតដើងលើមាត់បង្អួច
ត្រង់ស្តាលដំណេក, ក្បាលគាត់ងើយបន្តិច, ក្អែកគាត់សំឡឹងដៅលើអា-
កាស ហើយគាត់ស្រែកយ៉ាងច្បាស់ខ្លាំងៗ ថា « លោសិនហើយ កូនចៅ
អើយ! អញដៅលេងស្តេចបួនដប់ថ្ងៃ កុំឲ្យរន្ធឹងមើលផ្លូវអញ "។
កូនចៅនៅកងឹផ្ទះកើផ្អើលធោធោឡាឈូធរ ខ្លះស្ទុះស្ទាដៅកេរាប់យាត់គាត់
តែចូលដៅក្នុងបន្ទប់គាត់មិនរួច ព្រោះគាត់ខ្ចាស់ខ្លាំកក្លាពើកឯងជាប់ ខ្លះ
ជាឲ្យរកដណ្តើរដោត់តាមបង្អួចតាក្រៅ ដើម្បីឲ្យឯងដៅចាប់យាត់គាត់ឲ្យចុះពី
មាត់បង្អួចវិញ ខ្លះទៀតថាណ្តើយមិនអីទេ គាត់គ្មានដៅហាននោត
ហោះដៅណាទាំងសំដូចេះទេ។ ឯអ្នកជិតខាងក៏ទាំងចាស់ ទាំងក្មេងកំ
ផ្អើលឈូធរតែប្រាក់ខ្ចាត់ខ្ចាយនៅតាំងថ្ងៃត្រង់ ស្រែកហៅគ្នាថា មកប៉ុយ
ដៅមើលយាយវែនហោះដៅលេងស្តេចបួតិ។ កាលបានដៅដល់
អ្នកខ្លះថាគាត់លេងរឿងមែនវែន ប្តូកលេងៗទេ អ្នកខ្លះតបមកវិញថា

ក្នុងតែឈ្មោះគាត់ថា « ខែនខ្យ » ក៏អាចដឹងបានហើយ តើជាមុខជំនាញ
សេនមែនខែនហើយ, អ្នកខ្លះទៀតយល់ថា កុំគាស់ទាត់ភ្ជួសផ្ដាស ចាំ
មើលគាត់សិន ។ អ្នកពាំដ៏អស់គ្នា កំពុងប្រឹងសរឆ្កឹតចាលក្នុងសំឡឹង
ជាន់ខ្ពស់ពីរយៈមាត់បង្អួច ទៅលើដេយ ដោយប្រយ័ត្នប្រយែងក្រែងគាត់
ហោះលឿនដេកលើមិនគាន ។ ឯក្មួនចៅរបស់គាត់ រវល់ជ្រលក្របល់
ជាមួយនឹងខ្នែងតំនិតគ្នាមិនដាច់ស្រេចតែពីរឿងគាត់ សោះ មួយថាដូច្នេះ
មួយថាដូច្នោះ ។ តែសោះ យាយខែន លើកដៃពាំនាំពីប្រណម្យសំពះ
តម្រង់ត្រឹមច្រមុះចិញ្ចើម រួចហើយគត់ចាក់ដៃម្ខាងខ្វាកសំយាកស្ទឹម
ចង្កេះនឹងស្មុត ដៃម្ខាងទៀតលាតលូបុះបេះក្លក់ត្បាញទៅមុខគត់ម្រាម
ងឹងស្មុត ហើយរង្គត់ត្បាញត្បាញឆ្លើងម្ខាង ពាក្យបែបដូចក្មួយកន្សោយរៀន
ហោះ ក្នុងគាត់ឆ្មេងបើក ។ មួយស្របក់ ស្រាប់តែលេចធ្លាក់មាត់
បង្អួច ក្បាលដាំចុះក្ដួសទំនោដីរឹង ក្បាលដាំណេក ។ អ្នកឈរមើល
ខ្លះភ្ញាក់ព្រឺតស្រែកថា ឯងប្រឹងសំឡឹងមើលទៅលើមេឃស្ទើរមិនហ៊ាន
ចាំប្រិចភ្នែក ព្រោះឮថាគាត់ហោះទៅស្ថានសួគ៌ ឥឡូវគាត់ត្រឡប់ជា
ស្រេចចុះមកស្ថាននរកវិញឯណេះ ! ។ ឯពួកក្មួនចៅគាត់ក៏ជ្រលក្របល់
សួនរំសាក់ឯក្រហេបក្រហប ញ័រខ្រគត់ខ្រគើតស្រែកភ្ញាក់មាត់ភ្ញាក់
ភ្ញាក់ ប៉ះន្ទោសគ្នាលន់ តេ ហើយនាំគ្នាសុះទៅលើតបីគ្រែកន្លែងគាត់ឡើង

យកទៅលើផ្ទះ ។ អ្នកឈរមើលតាំងនោះ ក៏ចាន់ផ្តួយឈឺឆ្អាលតាំង
អស់គ្នា ។ ប៉ុន្តែដីវិតអាយុសង្ខារយោយទៅទេ ចាន់ថយចេញចាក
រូបកាយរបស់គាត់ តាំងពីក្មេងពេលដែលគាត់ប៉ះដល់ដីភ្លាមម្ល៉ះ មាន
ផ្តូរអ្វីនិងសោះ បើក្បាលគាត់សំយុងដាំចុះមកមុន ជួនគេបុកបម្រុក
សម្រួញសង្កុញកគាត់ផ្ទប់ទៅនឹងដីដូច្នោះទៅហើយ ។ ពេលនោះកូន
ចៅនឹងក្រុមគ្រួសារគាត់ យំរោះបោកខ្លួនក្រាលកន្ទុតកន្ទេញស្ពាយ
ស្រែណោះអោះខ្លោះអាល័យបង្គាយកំសត់ មិនតួរប៉ុន្រាតាំងស្រស់ ។
ដូច្នេះសោះ ។ គាបាងដឹងជាក់ថា យាយទៅអស់អាយុបង្ខាដូច្នោះ
ហើយ, ពួកក្មេង ។ ខ្លះនិយាយគ្នាថា យាយទៅគាត់ចាន់លាកូនចៅ
ទៅសេចស្ថានបួតិតែប្តូនដល់ថ្ងៃទេ, ឥឡូវនេះ គាត់ចែរជាទៅហួត
លែងត្រឡប់រឿតែម្តង ។ ចំណែកពាសាំ ។ មានទឹកមុខស្លូតសូប់ក្រៀម
ក្រំត្រង់ ។ គ្នា ដោយមិនភ្លេចថាមានគ្រោះថ្នាក់ដល់ស្លាប់ដូច្នោះសោះ ។

បន្ទាប់មក ពួកកូនចៅនឹងក្រុមគ្រួសារព្រមទាំងញាតិមិត្តទាំងអស់
ក៏ចាន់បញ្ចាប់រឿងយាយទៅ ដោយរៀបចំធ្វើបុណ្យបូជាសពគាត់តាម
ប្រពៃណីធម្មតាទៅហោង ។

រឿងមរណាមតា

(តមក)

លោក ប៊ិ - សុវណ្ណ ចម្លងពីសារស្ត្រាស្ងាំរត

ប្រទះហ្វូងសត្វទ្រឹត ដើរតតឹកក្នុងអគ្គា ខ្លះដេញខ្លះដល់គ្នា សឹងសត្វ
សុទ្ធតាលយង់ឃ្នង ។ ដំរីរមាបង្ខា ជាសដេញគ្នាកេរ៉ំពង ខ្លះ
ចយកាំងតន្ទង ដល់ចាលចាញ់ដេញចូលព្រៃ ។ កុដម្ពីក៏កុលកេសី
ឃើញដំរីកាំងកិតកំង ទំដើរប្រុំព័ទ្ធថ្ម ដល់ចុងស្រុកវែងក្រស្មោះស្មាន ។
ជាស្រុកជនបទ ដោយខ្មៀយហត់ឈប់សម្រាន្ត លុះព្រឹកឡើងខើប
ចាន ចូលក្នុងស្រុកក្នុងភូមិនោះ ។ ខេត្តនោះធំល្វឹងឃ សុខសប្បាយ
ភូមិច្រើនច្រុះ ជញ្ជីយកតែប្រុស ពាប់ដល់សែនរូបជាតំធំ ។ មនុស្ស
ក្នុងខេត្តនោះក្តី ខាងកេស៊ីមិនស្ងៀង ខាងមន្តខាងអាគម នោះសង្ឃឹក
ឃ្មាតខ្លីខ្លាន់ ។ ខន្ធេញរេញរត់មាត់ ញាប់ញ័រក្តាត់មើលមិនខាន់
រឿនត្រូវរៀបរង្គាន់ ផ្ទះមួយល្វែងជាក់មិនអស់ ។ រេចៀបខាងសេសចាប
ចេះដាបមិនចន្លោះ លួចបន់យកប្រុស កាប់សម្លាប់ឥតញ្ញើត ។
ស្រុកក្រៅទៅដូរទិញ លក់ទំនិញមិនសូវកើត ដល់ពារក្រអើត អាង
តែកាប់ចាក់ចេញចុះ ។ មិនច្រេះធ្វើការងារ មិនខ្មស្អាហ៍រកស៊ីសោះ ខំ
គ្នាស្រើបស្រួលស្រុស ធ្វើជាចោរលួចប្លន់ ។ មានមេស្រុកជាធំ

ចុះចូលដុំភ្នំចេស្តា ឱដ៏រះគតយ៉ាងណា ស្តាប់បង្គាប់មេស្រុកនោះ ។
ម៉ោដល់ពេលវេលា ភនាំគ្នាមកចំពោះ ឃ្លាំចាប់មនុស្សច្រានចុះ ផ្តាច់
ជីវិតធ្វើតាលិការ ។ បបួដាអាកូរព្រៃ សូមជោគជ័យសូមចេស្តា ចេញ
ធ្វើចោរកាលណា ឲ្យមានលាភបានច្រើនឥន ។ កាលនោះឯកុដ្ឋម្ចីក
កុលកេសីប្តីប្រពន្ធ នាំគ្នាចូលដំបន់ ខេត្តកាម៉ស្រុកចោរនៅ ។
កាលចោរនាំគ្នាចាំ គន់តយឃ្លាំទៅដើមផ្លូវ កុដ្ឋម្ចីក់ដើរចូលទៅ
ចោរចាប់ជាប់ចងម្ចីម្ចា ។ ឯនាងកុលកេសី ឃើញស្វាមីត្រូវចោរ
នាងគិតក័យតក្តមា ចំរះរត់ចូលទៅ ។ យកចិញ្ចៀនមួយនោះ ត្បូង
កូប្រះមាសឆ្នៃនផ្តៅ ទៅដូនមេស្រុកទៅ ពោលអង្វរសូមពោសប្តី ។
មេស្រុកមិនមានចិត្ត នឹកអាណិតកុលកេសី ទើបស្រែកយាត់ស្រដី
ប្រាប់ទៅចោរចំនោះថា ។ អស់គ្នាយើងកុំចាប់ កុំសម្លាប់ចោរទេណា
ដ្បិតមានន៍នេះត្រូវជា ញាតិសាច់យើងខ្លះឯទៅ ។ ចោរឮទៅ
ហ្នាយប្រាប់ ស្រែកប្រញាប់ថាញាតិជៅ ឲ្យលែងប្តីនាងទៅ ទើប
ស្រាយលែងចេញម្ចីម្ចា ។ រីឯទៅកុដ្ឋម្ចីក់ រួចពីក្តីមកវិញ នឹកគុណ
មេស្រុកជា ស្រាយលែងទោសពុំពិយាង ។ ទើបនាងកុលកេសី
នាងនៃខ្លួនក្រាបក្រោមបាទ មេស្រុកសុំអនុញ្ញាត សូមផ្ញើរខ្លួនលើមេស្រុក ។
ថាយើងតាំងខ្លួនហា សូមលោកជាធម្មជនក ទោះធ្លងទោះសុខទុក្ខ ផ្ញើ
ជីវិតលើលោកម្ចាស់ ។ មេស្រុកស្តាប់ហើយថា ឯកះខ្លួនម៉ងណាស់

ដ្បិតនុគឺវាចាស់ ឥតកូនចៅតពីក្បា ។ នុសូមអ្នកតាំងខ្ញុ ជាបុត្រស្នេហ៍ ផ្ទៀងខ្ញា ក្រែងនុស្លាប់កាលណា អ្នកលើកខ្មោចស្រោចឆ្អឹងនុ ។ គោះ ពាក្យគេចន្លំឆ្គាំឆ្គង គោះសៅហ្មងគោះខុសត្រូវ ឲ្យអ្នកអត់គោសនុ នុ ទុកស្នេដូងនេត្រា ។ មេស្រុកហាហៅ៧ កវីយោនៅក្នុងត្រីហា ឲ្យ រៀបគោជនា យកមកឲ្យកូនបវរកោត ។ កវីយោរៀបរួចបាន ថាសូម ពានដំកបលោក ឲ្យចូលមកបវរកោត ខ្ញុំចង់ស្តាប់មុខកូនជង ។ កុដ្ឋម្ចីក នៅកវីយោ បណ្តើរគ្នាចូលត្រសង ដល់បុតជង្គង់ជង ។ ផ្តុំអញ្ជលី លើកហត្ថា ។ សំពះសួរតាំងពី តាំងកុដ្ឋម្ចីកខ្ញុំកវីយោ សង់សួរសង ចរចា ហាក់ដូចជាបុត្រខុវ ។ ហើយបវរកោតគោជន ឆ្អែតឆ្អន់ឆ្អែត ឆ្អន់ហើយចេញចរ មេស្រុកសោតសាខរ រៀបលំនៅទំនេត្រា ។ ហើយ យកខ្ញុំប្រុសស្រី ប្រើប្រាស់តាមចិត្តារ ឲ្យស្រែដីល្អជា គោក្របីសេះ កុះករ ។ តាំងនេះព្រោះកេសី ជាតិជាស្រីមានលំក្ខណ៍ល្អ ត្រាប្តី ត្រូវមិនត្រូវ មិនខ្វះចាយតាំងថ្ងៃនោះ ។

បឋកាកកតិ

កុដ្ឋម្ចីកនោះណា - ខ្ញុវនាងកវីយោ - សុខសាន្តស្នានស្នោះ ស្នានស្នេហ្ចខ្លួយ - ឥតភ័យឥតរម៉ាះ ដោយមេស្រុកនោះ - អាសូរ ស្រឡាញ់ ។ នាងកុលកេសី ប្រើខ្ញុំប្រុសស្រី - ឲ្យចរឲ្យចេញ - ឲ្យ ជួយជួញប្រែ ធ្វើស្រែចំណេញ - អាសក្រាក់ចានគេញ - ចានពោរតាំងផ្ទះ

ហើយនាងឡើងទៅ ប៉ិតាឯមិនៅ លើកដៃសំពះ ថាសូមកូមិនឹ នឹងនៅ ធ្វើផ្ទះ ឲ្យឆ្ងាយស្រឡះ ស្រឡាញ់កូមិថ្ម ។ ឯធម្មបិតា ស្តាប់ហើយ ធ្វើយថា អើកូនពីស៊ី តាមតែចិត្តឯង ចំណង់កូនស្រី នាងស្រឡាញ់ដី ទ្រនំណាយកចុះ ។ នាងកុលកេសី បានស្តាប់ពាក្យប៉ា- តាធម៌ដូច្នោះ ក្រោយក្រាប់ដាក់ប្បាស់ សំពះលាចុះ ទៅមើលកូមិនោះ នឹងសង់ផ្ទះថ្ម ។ ឯកូមិនោះជា បើអ្នកឯណា ជាខ្ញុំគេក្តី នៅកូមិនោះណា បានជាសេដ្ឋី នាងកុលកេសី នាងស្គាល់ដៀងជាក់ ។ ហេតុនាងស្រីថ្ងៃ បាន សាងច្រើនក្រៃ ជាស្រីមានលំក្ខណ៍ នឹងបានជាធំ ទុត្តមអនន្តរ អនេតជាអគ្គ ជាឯកនារី ។ ហើយនាងក្រឡាប់ រៀបវិញមកគ្រាប់ ស្ងាមីខ្លី កុដុម្ភ័កបានស្តាប់ សាស័ក្តពាក្យតី នាងគ្រាប់តាមី ពីកូមិ ថ្មីនោះ ។ អវេតនុបមា ហើយធ្វើយទៅថា នាងអើយបើដូច្នោះ នាងរៀបកោដនា កោក្តារួចចុះ នឹងប្រើខ្ញុំឬប្រុស ឲ្យទៅគ្រាបដី ។ ចាបនឹងកោដនា ចំណីភីសា នោះត្រូវខ្ញុំស្រី រៀបទ្យក្បៀតធ្វើ ធ្វើ ការលើកដី ឯខ្ញុំនាងស្រី ជាមេគំនិត ។ ស្រេចហើយកុដុម្ភ័ក តាក់ តែងធ្វើតី រួចនាប់ដូចចិត្ត សង់ផ្ទះធំល្អ សឹងថ្មនឹងឥដ្ឋ ចាយឥលាប ក្តិត ដណ្តាំងដុំវិញ ។ ផ្ទះក្លោះត្រដឹង ហោណាំងខឹង ត្រែតាំង រៀបតេញ ល្អល្អះត្រកាល ពនហាលដុំវិញ ដើងផ្តាំថ្កល់តេញ ដោយ ក្បាលសសរ ។ មានដើងដើមផ្តា ខាងត្បូងត្រីហា រៀបឥដ្ឋចាយអ

មានដើមផ្កាត្រចៀក ឈើសព្វមិនគ្រ មិនដឹងបើយក៏ បើកបង់មិនអស់ ។ ហើយតែងចំកស្រះ ថ្ងាំងំក្រចះ កណ្តាលឆ្នេរគោះ រៀបឋ្ងាក្តុំ ជាត់ធំខ្ពង់ខ្ពស់ ហើយឱ្យដាំអស់ ឈើបរិសោភ្ការ ។ គួលែនសីរមាន់ ខ្ទរខ្ទៀបចេកចាន់ បង្គ្រាំពុទ្រា ធូរេនដូងល្មុត មង្ឃុតសេដា ហើយឱ្យដាំ ផ្កា កំពូលភ្នំនោះ ។ សង់កេងមួយស្រាប់ ខុកជាសម្រាប់ ទៅលេងស្រះនោះ គ្រាន់តែអង្គុត ជាខុក្ខប្តាត់សោះ រីឯស្រះនោះ ឯជ័ងត្រីហា ។ ជាំឈូកសម្រាល ផ្កាកែវន្ទាល ពេញកន្ទឹគង្គា កុមុទុត្បល ផុសផុល សឹង្ហផ្កា មេឃ្មុមឃ្មា ហែមហែលទៅមក ។ ត្រីច្រើនប្រការ ពាសពេញត្រៀបត្រា សំកាំងសំកក បណ្តើរកូនមើរ ទៅស៊ីឫសចក ខ្លះហែលតួនផ្រក តួនផ្រប់រេរ ។ ឯកើតឱ្យរៀប សង់កេងនឹងរៀប ជំនុំកិច្ចការ ខ្លួលភ្ញៀវមក គេយកភ័ស្តុការ មកដូនតាលណា ឱ្យទៅកេងនោះ ។ ឯលំចង្ហុះធំ ប្រុសស្រីរៀវរ៉ាំ ផ្ទះជាយចំពោះ បងប៊ីជាន់ ខេត្តខណ្ឌធំស្មោះ ឯភ្ញាវបួននោះ មានខ្ញុំចាំភ្ញាវ ។ រៀបរួចអស់ក្តី នាងកុលកេសី ឡើងទៅក្រាបលា ខ្លួរបិតាធម្មិ នឹងធម្មិមាតា ជាកូនក្រាបលា ទៅនៅផ្ទះថ្មី ។ បិតាមាតា ធម្មិទានមេត្តា នាងកុលកេសី ហៅគ្នាមកជុំ ខ្លួរខ្ញុំប្រុសស្រី ហែកុលកេសី ទៅឡើងត្រីហា ។ នាងនៅផ្ទះថ្មី ពាសាទសី រត់ចូលមហិមា ត្បូងកែវប្រាត់មាស ពេញពាសច្រើនជា អនេកគណនា ភប់សែនកប់កោដិ ។

អ្នកស្រុកដីតឆ្ងាយ ពួកចោរចាំឆក្បាយ លែងលួចសោះសោត
ខ្លួចភ្លាចបុកណា នាងមានចំណោទ សឹងភ្លាចសឹងកោត សឹងចុះចូលដុំ ។
ឯមនុស្សក្រីក្រ បបួលគ្នាមក សូមៈទៅដាំខ្ញុំ ជាម៉ឺនជាពាន់ តាមជាន់
កុះកុំ កុះតរជួបជុំ ជួបជីតស្រឡាញ់ ។ ទៅយូរហ៊ានច្រាក់ ហួល
ព្រៃស្ងៀកភាក់ លោះខ្ញុំវិតវិញ ជួនច្រាំដំបរ តៀតរៈភាវពេញ
រកស៊ីចំណេញ ដំឡូងច្រើនពេក ។ ខ្ញុំខ្លះមិនចេះ គិតដួញរេះ ជីក
សៀជីកសៀក ក្រមួនចន្ទុះ ខ្លះលោះភ្លេចរែក រកតាមចំណេក ចំ-
ណេញពាល់ខ្លួន ។ ខ្លះចេះគ្រាន់បើ លេខហាសោះតើ គិតដួញក្រ
មួន ក្រពញ៉ាយក្លុក ដោយមុខដោយខ្លួន ខ្លះចេះគ្រួន រែកលក់
ដោយផ្លូវ ។ ខ្លះលួងបំផុត គិតកាបទសដុត លក់បានទិញស្រា
ជីកអស់ច្រាក់កាស ក្រឡេះម៉ីម្ហា រៀបទៅគ្រឹហា ប្រពន្ធះជរម្ហាយ ។
ខ្លះចេះយ៉ាងឯក លែងស្ពាយលែងរែក ជួញប្រែស្រុកឆ្ងាយ ហ៊ាន
មាសហ៊ានច្រាក់ ទុកដាក់មិនចាយ ហើយនាំខ្ចល់ខ្លាយ យកជូននាង
ម្ចាស់ ។ ចូលខ្ញុំកំដរ ច្រើនច្រុះកុះករ ពាលពាលច្រើនណាស់ គោ
សេះដំរី ក្របីពេញពាស តូចធំកែវកងក្រាស ឥតឯមានខ្វះ ។ មាស
ច្រាក់ច្រើនលន់ អនេកច្រើនពន់ អនន្តមហិមា ចាំងអស់នោះមិញ
គិតកាញ់គណនា ពាប់ឃ្លាំងត្រូវជា ឃ្លាំងបួនកោដិតត់ ។ ឯខ្ញុំដែល
ប្រើ ធ្វើការសោះតើ មិនមេះពាត់ នាងឲ្យខៅអាវ ឈ្នួតខ្ញុំសំពត់ បើ

ខ្ញុំនាងអត់ មិនវាយមិនដេរ ។ ម្ចាស់រែងស្រុកព្រាញ ស្មានស្មោះអស់
អញ សរសើរគ្នាន់គ្នែរ ថាម្នាក់ម្ចាស់ស្រី ប្រណីយើងវែរ ខ្ញុំរលាក
មិនដេរ មិនចេះយកខុស ។ ឯធម៌បិតា ឃើញបុត្រស្នេហា ទ្រព្យច្រើន
ដូច្នោះ ពោរពេញគោដំឃ្លាំង ទើបតាំងឲ្យឈ្មោះ ឃកហេតុគោដ
ខោះ មកតាំងនាមា ។ ឈ្មោះកុលគោដ៏ តុដូម្ដង៏សដ្ឋី ពីថ្ងៃ
នោះណា នាងកុលកេសិ ស្រីមានលក្ខណា ពីស័ចិត្តជា នាងវែងង
ប្រណិបត័ន ។ បិតាមាតា ធម៌មានមេត្តា អាសូរនាងក្លាត់ នាង
ចាន់ចំណី តំស្លូតូនាងកាត់ នាងតិតចែតចាត់ ជាភាគបីណា ។
មួយភាគនាងចែក នាងដូនរំលែក ទៅធម៌បិតា មួយដូនម្ដាយធម៌
ពាល់ ។ រៀលា ភាគមួយដូនស្វា – ម៌មានប្រតិព័ទ្ធ ។ នាងមានជិត្ត
អស់អញទុស្សហ៌ គោរពប្រណិបត័ន បិតាមាតា ភាតារៀមវែង
អស់ទ្រព្យសម្បត្តិ ហូរចូលសព្វថ្ងៃ ។ មានមួយភាគ្រែ នាងកុលកេសិ
កើតអស្ចារ្យក្រៃ ទន្ទឹតកន្ទ័ពោះ ញ៉ាំរអស់សរសៃ មានតិបុត្រថ្ងៃ
ប្រកបលក្ខណា ។ ហេតុរោគច្បាត់ ចុះចាប់ជាបុត្រ កេសិធីតា លង់
លុះចូលចប់ ជាដប់មាសា កើតហេតុអស្ចារ្យ ម្ដងខ្លែតគួរស្ងែង ។
ព្រឺអស់ភេមា ញ៉ាំរអស់អង្គា អង្គកាយក្រែញង៏ ហាក់ដូចអណ្ដែត
ក្រសែតអង្គឯង ស្រាលខ្លួនឆោងឆេង កំរើកចិត្តា ។ ទើបនាងសម្ដែ
បុត្រ្ដូចគ្រប់ ពីកន៏កាយា ឈ្លួះពីសី ប្រែប្រួយកក្រើ ដូចដួងចន្ទ្រា

សម្បុរល្អល្អន់ ។ ឯកុលកេសី កុដុម្ពីក៍សេដ្ឋី ត្រេកអរពេកពន់ ថ្នមបុត្រពុំផ្ទាំ ស្នេហាឥតអន់ សេដ្ឋីតិតគន់ បង្គាប់បបរីវារ ។ ឲ្យរើសមេនំ តែលៀនចោមដុំ ម័ថុមត្បាថ្មាល បំរើជ្រួចជ្រៀន ពាល់រៀនដោយងារ ខ្ទះធ្វើអាហារ បញ្ចុកបុត្រថ្លៃ ។ ផ្តិតសីនឹតអប់ គ្រឿងខេសឈ្ងុយឈ្ងប់ ជាអច់ព្រៃយ . ខ្ទះកាន់ដៃនី សោភ័ណ្ឌតំរៃ បក់ប្រោយសត្វថ្លៃ មិនមានប្លាន់សៅ ។ មិនឲ្យរះបាម មួសសុខវុយភេម ជាត់ដាំយចេញ្ញាៗ ពុំឲ្យមានមោះ ឥតលោះឥតក្តៅ ម័ថ្នមនៅមិនមានដិនធ្ងន់ ។ រីឯមេស្រុក ជាជមិដនក ស្រឡាញ់ពេកតន់ នាងធមិកយ៉ាកា ស្នេហាឥតអន់ លុះយូរដល់ជន្ម ជាតិចាស់ដក ។ មេស្រុកនូនាង តាំយាំលាង រំលត់ជន្មា កុដុម្ពីក៍សេដ្ឋី កេសីធីតាលើកសពសង្គារ រួចស្រេចអស់ក្តី ។ ពីថ្ងៃនោះៗ អស់ស្រុកក្នុងក្រៅ គោតទ្វាចសេដ្ឋី កុដុម្ពីក៍ជាំ ជំនុំការអ្វី ដម្កល់សេដ្ឋី ជាទីប្រជាន ។

បទព្រហ្មកិត្តិ

រីកុដុម្ពីក៍សេដ្ឋី ស្រដីទីតាសិកស្ថាន សម្រេចកដការបាន ជាស្តេចត្រាញ់ក្នុងប្បី ។ ឯកយោនិមល នាមនាងកុលកេសីស្រី ត្រកូលវង្សជាតិ មានឧលក្ខណ៍លើសលោកា ។ នាងតិតនាងសន្ធត ឲ្យនាមបុត្រីកញ្ញា ហេតុដោយនាងស្នេហា ឲ្យឈ្មោះនាងកុមារី ។ លុះចំរើនធំឡើង ល្អថ្កុំថ្កើងស្រស់ប្រិមប្រិយ ហេតុនាងសាងបុរេ ជា

ជននីពោធិសត្វ ។ ប្រកបនូវខៀលក្តណ៌ លើសអន័ឥណាស់ត្រូវខ្លាត
មិនក្លាយកាយនារយោ ដូចស្រីស្រុកស្រែចំការ ។ សម្បុរសស្រស់
ស្រិល ដូចតាលមាសរចនា ព្រះគ័ណ្ឌដូចផលា ផ្ទៃមាត់ថ្លាដ៏មាស
សោភ័ណ ។ ភត្ត្រាសមសុះដ៏ មូលម៉ដ្ឋម៉ដ៏ដូចវាំងចន្ទ គូមោដូចកេ.
ម័ណ្ឌ សមនេត្រាយដ៏ភ្លៅស្រិល ។ ខន្ធាតិត្ថាំងសែ - សិបដូចតេ
ង្ហែមហានីល ជិតដិតប្រកិតស្រិល ផ្ទៃតន្ថាសមប្រិមប្រិយ ។ កា
មាតាំងតូតាប់ ដូចស្រទាប់ឈូកប្រណិមី នាសាសមតាសី ស្រង់ស្រួល
ស្រៀបដ៏ខត្តម ។ អង្គាតាងស្រឡះ ឥតអង្គ្រឹសអង្គាសម ចង្កេះ
មូលរៀវក្តុំ សមល្អស្មើតឆើតតេកតិត ។ តន់ពីព្រះជាខ ដកបនាដល់
សិរសិដ្ឋ ល្អត្រប់រាំងបញ្ចពិធ កល្យាណីនីនិន្ទ ។ ព្រោះនោងសាង
កុសលទី ជាជននីអង្គតតាវ ហើយនាងឋានយកផ្កា ថ្វាយបច្ចេកស.ម្ភ-
ធី ។ ផលនោះដួយត្រូវនឹ ឡូលអង្គកាយនារី មានចិត្តពិព្វាធើបជា
អស្ចារ្យតេកចំឡែកក្រៃ ។ បតិត្រអើយកាលនោះ ហេតុកម្មត្រោះតុមារី
ឋានធ្វើពីអតី - តាតែងតាមពិតពុំឃ្លាត ។ លុះជន្មឋានច្យុំពីរ គោម
ស្រុស់ស្រិលរូបល្អក្តាត់ មានស្រីមួយដួងជាតិ ជាមេម៉ាយឈ្មោះកាលី។
មានកូនស្រីពីរនោះ មួយនាមឈ្មោះចន្ទនី កូនមួយទៀតនោះនៃ
ឈ្មោះចន្ទិចិត្តថ្លស្បា ។ រីឯមេកាលី មានបងស្រីមួយនាមា ឈ្មោះ
កាលីនីយា រួមទុរមួយស្មោះស្មាន ។ កាលីថ្លីលែងលង់ ពេលល

ចោះបង់ពុំកប់អាន សព្វថ្ងៃគាលីមាន ចិត្តខ្មោមនស្សកើតពុំក្តា ។
ត្បិតខ្លួនជាមេម៉ាយ ពុំសប្បាយក្នុងចិត្តា ក្រៀមក្រំៗពក រិះដញ្ជឹងតែកងចិត្ត ។ ថាខ្លួនអញមេម៉ាយ ជាចំណាយភាក្សតែពិត ទឹកខ្សើងខ្ទើនផ្អែតចិត្ត ឆ្អិតផ្អែតឆ្អល់សល់សែនសោះ ។ គាលីនៅខៀបជិ ផ្ទះកុដុម្ពីក៍សេដ្ឋីនោះ គាលីធ្វើជាស្មោះ ដើរទៅមកកុដុម្ពីក៍ ។ បើបានសរតើម្តី ផលចំណីមិនហិនស៊ី យកៗទៅជូនកុដុម្ពីក៍ តែសព្វថ្ងៃមិនដែលមាន ។ ហេតុស្រីចិត្តឫស្យា ឥតលក្ខណាៗទៅក្នុងគ្រាណា គន់គិតចង់តែបាន យកកុដុម្ពីក៍ជាស្វាមី ។ ទើបកេមន្តសិលសិទ្ធិ បញ្ចូលចិត្តមហាសេដ្ឋី រកបានឱកាលី រៀបស្ងួតស្អាងអង្គអាត្មា ។ លាបត្រែងលាបក្រមួន មេក្លាចែតន្ទុះជាត់តក្រាំ យកស្ងួតសិតកេសា ជូនសំភោងហាត់ក្រមុំ ។ ស្មៀតតាក់រើសកេរ្តិ៍ ដណ្តប់ក្តីសឹងជាប៉ាំ ចំឆ្លៀនមានស្ងួនដុំ តាក់បញ្ចើរដើរលេងផ្សារ ។ លុះដល់ផ្ទះសេដ្ឋី ហើយគាលីឈរកេរ តិតធ្វើកលមាយា លួងសេដ្ឋីឲ្យចូលចិត្ត ។ និយាយឡកលលេង ហាក់ដូចក្មេងពាលពេញពិត ដោយសារមេកស្នេហ៍សិទ្ធ្ត្រូវកុដុម្ពីក៍ទប់ពុំបាន ។ ស្មាលស្ទិទ្ធនឹងគាលី រៃអង្គមេត្រីសៅរ្មៃប្រាណរួមចិត្តស្និទ្ធរួមថាន សាន្តសោមនស្សពាល់ពាក្រ ។ រួមសៅរ្មៃសញ្ជិទ្ធ ក្មេចនឹកនាងកុលកេសី ក្មេចបុត្រស្ងួនប្រិមប្រិយ ក្មេចដំណេកទិនព្រៃ កាលីបានកុដុម្ពីក៍ រួមវៃណ៌ជាកវិយោ មិនគិតកេរ្តិ៍ខ្មែនខ្លា ដោយវង្វែង

ចិត្តអន្ធការ ។ ឯនាងកុលកេសី ឃើញស្វាមីស្ងួនស្នេហ៍ស្មោះ ចាប់
ចិត្តដូចត្រកាល ទើបកាលីស្រីឥតលក្ខណ៍ ។ នាងគិតពុំឲ្យខាន ពុំ
ប្រច័ណ្ឌក្រែងបែកចាក់ នាងធ្វើជាស្មោះស្ម័ត្រ ស្ងួនស្នេហាឥតសៅម៉ង ។
កេរកាយដែលបង់អាន ស្ម័ត្រស្មោះស្មានស្ម័ត្រមួនបង ក្នុងដួងក្តីឃើញចំនង
កុលកេសីពុំក្រឡា ទើបប្រើឲ្យហៅ កាលីទៅលើគ្រឹហា ហើយរៀប
ពិនិត្រ ឲ្យកាលីនៅសុខសាន្ត ។ ទុកដាក់រាជាចុង រៀបបំរុងឲ្យជន-
ជាន ឲ្យខ្ញុំស្រីប្រុសប្រាណ គ្រាន់កាលីប្រើធ្វើការ ។ រេរះសេរដំរី
ឲ្យកាលីតាមចិត្តា កាលំចេញទៅណា ខ្ញុំខ្ញែវិញាមែនដុំ ។ ហេតុ
កម្មកុលកេសី ឃានធ្វើពីបុព្វជាតិ កម្មនោះតាមដៅយដាត តាន់ថ្មី ។
បៀតអាត្ម ។ រីឯតរាយថ្មី ឈ្មោះកាលីចិត្តមិច្ចា- ទិដ្ឋិចិត្តហ៊ឺហ្ម
បៀតបៀននាងតរាយមុន ។ ក្នុងដួងក្តីជាស្វាមី ឃានកាលីស្រឡាញ់
លន់ រាងឆ្នួចិត្តគិតគន់ គិតស្អប់នាងកុលកេសី ។ ពុំស៊ីពុំស្នេហា
ពុំចេះចាពុំបេតិ ស្មោះស្នេហ៍តែកាលី ជាតរាយចុងបណ្តាច់ ។ តាំង
ពីឃានកាលី តាឡកណ្តាលជាតូតាប់ ស្នេហ៍ស្ងួនតែតអត្ត តើតចង្រៃ
ក្នុងអង្គា ។ តើតហ៊ានហោចខ្ចប់ក្តាយ តើតអន្ធពាយអស់ទ្រព្យា ដំរី
សេរថា គោក្រចីសឹងស្លាប់ស្លុត ។ ឥសាខ្លួនឯង ស្លាប់ពីរនេះ
រស់រត់ ឆនឆានបួនកោដិតូត ឃាត់រលាស់អស់ឆេងរហាង ។

(មានត)

រឿងសាមកុក

កណ្ឌទី ៣៧

នាយវិរៈបុលភដិសេនា ជួ-ភិន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
ទឹងបេះខុបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ចុងស៊ុនដោយរហ័ស ក៏ដុលខ្លាតរបួតឆ្លាក់ចុះ ទើបដកយកគ្រប៉ិកាប់បង្ក្រុះត្រូវចុងស៊ុនចំក្បាលរហូតចុះទៅ ដូចនេតុះ ដាច់ភាក់កណ្តាលខ្លួនជា ២ ចំណែកឆ្លាក់ស្លាប់ ១ រំពេច រួចជូឡងក៏បរសេះ គេចស្រូតរត់ទៅដល់ស្ពានខៀនថាំន៍កៀវ ខ្លួលឮសំឡេងតាបានចូតូវស្រែកហៅមកពីក្រោយ កំឡាំងសេះទឹងកំឡាំងជូឡងក៏ខន់ចុះ ខ្លួលក្រឡេកឃើញខៀវហ៊ុយឈរលើស្ពានកំស្រែកថា គ្រានេះ ខ្ញុំអស់កំឡាំងណាស់ហើយ ឲ្យអ្នកជួយខ្ញុំផង ។ ខៀវហ៊ុយកំស្រែកថា អ្នកស្រូតតូងស្ពានទៅចុះ ខ្ញុំនឹងខ្លួលតស៊ូ ។ ឯជូឡងក៏ស្រូតតូងស្ពានទៅចម្ងាយផ្លូវ

ប្រហែល ២១០ សិន (៨ គ.ម.) ដួចនឹងខ្លាតឈរនៅទីនោះ ដួឡុងចុះពីលើសេះនៅតំនាប់ខ្លាតិ៍ហើយអង្គុយយំ អធិប្បាយសេចក្តីខ្សែខ្លាតិ៍ស្តាប់ទ្រង់ប្រាប់ ហើយថា ខ្ញុំបានយកបានតែអាតៅ ជាបុត្រលោកវ៉ាដាក់នៅក្នុងគ្រោះ កាលខ្ញុំបានគំលាយចេញមកពីក្នុងចំណោមទ័ពនោះ បានប្រប្លែកគ្នានឹងភាហានបួន ស្រាប់តែបានឮសំឡេងអាតៅស្រែកយំម្តង ។ ឥឡូវបាត់បួនឆ្ងាយឆ្ងាយរហើយ មិនបានឮសំឡេងយំសោះនឹងជាអន្តរាយយ៉ាងណាក៏មិនដឹងឡើយ ។

ដួឡុងក៏ដោះគ្រោះចេញ ស្រាយយកសំពត់ដៃលវ៉ុអាតៅនៅកន្ទុយនេះមកលាចេញ ឃើញអាតៅនៅដេកលក់ ក៏សែនទឹកអរជាន់ប្រមាណ ហើយកំនិយាយនឹងខ្លាតិ៍ថា បុណ្យតិបុកណាបង់លោកខ្លាំងណាស់ បានជាបុត្រលោកមិនមានប៉ះរលើសេចក្តីអន្តរាយ ដួឡុងស្រាយហើយតអាតៅហុចជូនទៅខ្លាតិ៍ ។ ក៏ទទួលយកអាតៅជាបុត្រហើយធ្វើជាខឹងំលាក់អាតៅទៅលើដី ហើយថា ព្រោះតែអាចង្រៃឯង ។ បានជាដួឡុងតាហានឯកបង់អញ ឥឡូវតែនឹងថ្លង់ការដោយស្មើកសត្រូវ ។ ដួឡុងឃើញដូច្នោះគ្រប់ណាស់ ក្រោកចូលទៅរហ៊ីសប្រញាប់ចាប់លើកតអាតៅឡើងជាក់លើភ្លៅ ហើយលូតដង្ហិនចុះតំនាប់ខ្លាតិ៍ថា សូមលោកកុំប្រកាន់ខឹងនឹងបុត្រប៉ុលាភ្លឺយ

ខ្ញុំនឹងទុកឲ្យគ្រហស្ថដ ជាទីតបស្នងសងគុណលោក ។

ឯប៊ុនផង លើកមាហានដេញដីតតាមជួរឡងទៅដល់ស្ពានខៀង ចាំទំរៀវ ឃើញខៀវហ៊ុយកាន់លំពែងឈរស្មាក់លើស្ពាន ក្រឡេកទៅឃើញកណ្តាលទ្វារធួលីដីហុយទ្រលោមតាមដើងរសេះ ដែលមាហានខៀវហ៊ុយវាយឲ្យចោលផុសឡើងពេញក្នុងព្រៃ គំសំគាល់ថា មានមាហានភ្លួនបង្កប់ទៅជាច្រើន ឯរសេះនោះក៏មិនចានឲ្យបរចេញមក ។ ខ្លួលចេយិន, លីខៀន, ហៃហ៊ូអឿន, ងាំកង៉ិន, ខៀវលៀវ, ខៀវគាប់, ទីងទៅជួ ចាំង ៨ នេះ នាំមាហានលើកតាមមកមាន់ ក្រឡេកឃើញដូច្នោះគិតថា ខ្លួនបេងប្រើកលឧបាយបង្កប់មាហានខុកទៅចំនោះហើយ ក៏នាំគ្នាឈប់បង្គន់ទៅចំនោះចាំងអស់ . ទើបប្រើបំរើឲ្យទៅដំកបចូនទូ ។ ដីនដូច្នោះ កំលើកទ័ព្រសួតមកថែមទៀត ។

ខៀវហ៊ុយក្រឡេកទៅ ឃើញមាហានលើកមកជាច្រើន ឃើញសប្បធនចាំងមកពីក្រោយក៏ដឹងថា ចូនូះលើកតាមមកផង ទើបស្រែកតំហកយ៉ាងខ្លាំងថា ខ្លួនអញឈ្មោះខៀវហ៊ុយ នរណាដែលមានថ្នាំដៃខ្លាំងពូកែ ឲ្យចេញមកតស៊ូគ្នាល្ងងកម្លាំងមើលចុះ ឲ្យឃើញពាក្យឈ្មោះ ។ មាហានចូនូឮសំឡេងខៀវហ៊ុយ ក៏ត្រិះរិះតាំងអស់គ្នា ស្ងាំងកាំនមិនចានចូលច្បាំង ។ ខៀវហ៊ុយក៏ឱ្យមាហានស្រាយមែកឈើពីកន្ទុយ

សេះចេញអស់ ហើយកំឡុងពេលភ្ញាក់ស្ពានតាំងអស់ចេញ រួចនាំពាហនតាំងនោះត្រឡប់ទៅវិកប្បវត្តិ ទើបពាណិនារឿងក៏វិលត្រឡប់ទៅស្តាប់ត្រង់ប្រការ ។ ឧបាលិតបថា ខ្ញុំនៅនេះមានថ្លៃដែរ តែបើកំពុងមែន តែថាទឹកស្តាយព្រោះធ្វើទុក្ខយមិនបានរហូត ដោយនៅពេលភ្ញាក់ស្ពានចេញអស់ ប៉ាដូចនឹងប្រាប់ហេតុឲ្យបួនដួងដឹងថា មនុស្សពាលយើងតែង ឲ្យលើកតាមមកខ្លាំង បើលែងមានភ្ញាស្ពានចេញទេ បួនដួងក៏នឹងសំគាល់ថា បង្កប់មនុស្សទុកក្នុងព្រះប្រែងក៏នឹងញាក់ញ៉ាតខ្លាច លុះនៅយូរហើយកំពុងពាហនដាក់ចុះផ្លូវ នឹងជម្រើសទៅកំពង់ពោធិ៍ដែរ ។

ឯខ្សែរលៀវ, ខ្សែរខាប់, នឹងទៅឆ្ង ឃើញខ្សែរហ៊ុយរត់ទៅហើយក៏ត្រឡប់ទៅប្រាប់បួនដួងថា ឥឡូវខ្សែរហ៊ុយភ្ញាក់ស្ពានចេញអស់រត់ទៅបួនដួងឮដូច្នោះគិតថា ខ្សែរហ៊ុយនោះមានតែខ្លួនម្នាក់ឯង គ្មានពាហនទេ ឋានជាភ្ញាស្ពានចំណាស់អស់រត់ទៅ ព្រោះខ្លាចយើងលើកខ្ពស់តាម, ហើយទើបតែណ្តែពាហនបាន ៣ ពាន់ ឲ្យទៅធ្វើស្ពានជាថ្មវែង ៣ សិន (១២០ម.) កំណត់ឲ្យហើយតែកន្លងវេលាថ្ងៃមួយខ្លះទើបអាចលើកពាហនឆ្លង ។ លុះខ្សែរនិយាយខ្លះថា ដែលលោកនឹងចង្អុលលើកខ្ពស់តាមឲ្យទៅនោះ ខ្ញុំបាទគិតក្រែងខ្លាចដាក់ទុកយូរបង់ ឯខ្សែរហ៊ុយនឹងមានតម្រេកប្រាថ្នាចង់ធ្វើទុកយូរដល់ប៉ុណ្ណោះមិនមែនទេ សូមឲ្យលោកកុំគាស់លើកខ្ពស់ប្រញាប់ទៅឡើយ ។ បួនដួងថា ទុកយូរតែប៉ុណ្ណោះ

ទីឯភ្លាចអ្វី គោះមើលើសជាដំនេះ កំមិនត្រូវគោតភ្លាចដែរ ។ ចូរធ្វើស្រួត លើកចំពត្តដ៏ស្ពានតាមទៅ ។

ខ្លៅពីចុងឮមំឡើងថាហានហ៊ោកញ្ជ្រៀវពីខាងក្រោយ ដូចជាខឹងក្តុកក្តួលចាប់ផែនដី មើលទៅយើញផង់ធួលហុយខ្ទេលមកលើគាសកំនិយាយថា យើងទើបទៅវិលនេះ កំនៅមានខ្ទេទៅខាងមុខពីខាងក្រោយកំមានកងចំតលើកត្រលុកតាមមក តើយើងទើងត្រូវគៃតយ៉ាងណាទៅអេះ? ទើបប្រើឲ្យជូឡឹងត្រៀមតាលយោធាទាំមកការពារពីខាងក្រោយ ចាំរើកងចំពត្តដែលលើកតាមមកនោះ ។

ខណៈនោះ ចូរធ្វើយាយទើងថាហានចាំងពួងថា ខ្លៅពីគ្រានេះជូចត្រីចាំងទៅក្នុងសិង, ខ្លាំងមងចាំងទៅក្នុងត្រួង បើទើងលះបង់ចុកឲ្យយូរកើងរត់រួចទៅបាន បីជូចត្រីរួចទៅក្នុងទឹក, ខ្លារួចទៅក្នុងព្រៃ ថាហានយើងចាំងអស់គ្នាចូរជួយឡើយគ សង្ឃឹតចំតាមចាប់ខ្លួនខ្លៅពីឲ្យបានចុះ ។ ខណៈនោះតួតថាហានក៏ចំស្រួតប្រជ្រៀតគ្នាលើកតាមទៅ ។

ឯតួនអ្វីដែលទៅស្រុកកាំងហែ បានថាហាន ១ ម៉ឺន ចុះទូកលើតត្រឡប់មកដល់ភាកណ្តាលផ្លូវដើងដំណើងថា ខ្លៅពីមែកចំពត់រត់មកដល់ស្ពានខៀវជ្រាំងកៀវ កំឲ្យថាហានចូលចតទូកត្រង់កំពង់ហាន់ជិនហើយលើកថាហានឡើងលើគោកមកស្ពាត់ខ្លួលខ្លៅពី ។ ខ្លួលខ្លៅពីកាត់ច្រូតទៅដល់ជួបប្រទះគ្នាត្រង់កំភូមួយអន្ទើ កំជួបនឹងកងចំពត្តទៀត

លើកដាច់ដៃដោយឥតគ្រោយោលភ្លាមមកតាមផ្លូវធំ ។ គួនអ៊ូកឃើញសេះ
ជាច្រើនដេញតាមហានឲ្យស្រែកហៅឡើងពីមាត់កំពង់មក ។ ចូនួយឃើញ
ដូច្នោះ កំនឹកឃើញដល់ពាក្យលើកឡើងហាមមិនឲ្យលើកទ័ពមក ឃើញ
ត្រូវដូចពាក្យថា តើជាកលទុជាយវេចស់ខ្លះបងពិត ។ ចូនួយក៏បង្គាប់ទ-
ហានឲ្យថយត្រឡប់មកវិញ ។ គួនគ្លីក៏ដេញចូលតយុទ្ធសង្គ្រាមតាម
ចម្ងាយផ្លូវប្រហែល ១០០ សិន (៤ គ.ម) ឃើញតាហានចូនួយថយទៅ
មិនបានតទល់ គួនអ៊ូកថយត្រឡប់ទៅមុខវិញតាមផ្លូវគាត់ ប្រទះ
នឹងភ្លៅតីក៏មានទំណាស់ណាស់ ទើបនាំទៅចុះទូកហើយសួរថា នាងប៉ី-
ហ៊ីយើងបងថ្លៃខ្ញុំថាទ ទៅឯណាក៏មិនឃើញ ។ ភ្លៅតីក៏អធិប្បាយរឿង
តាមដែលបានតតាំងប្តឹងនឹងចូនួយឲ្យគួនអ៊ូស្តាប់ ហើយថានាងប៉ីហ៊ូ-
យើងលោតស្លាប់ក្នុងអណ្តូងទឹកទៅហើយ ដូច្នេះយកបានតែតាគៅមក
ឲ្យបង ។ គួនអ៊ូបានឮដូច្នោះ ក៏អង្គុយចុះទន្ទេញយំអាឡោះអាល័យ
ហើយថា កាលថ្ងៃទៅតាមហៅស្តេចព្រះពេជដំណើរចេញទៅប្រពាតព្រៃ
កាលណោះ ដើរបងកុំឃាត់ហាមខ្ញុំបាទ កាលណាទនឹងបានមកលំបាក
តោកយ៉ាកយ៉ាងនេះ ។

ភ្លៅតីថា គ្រានោះខ្ញុំបងក៏អនាថា រកទីពឹងដែលនឹងតាំងខ្លួនមិន
កូមិហានមិនបានឲ្យល្មមជាទីពុកចិត្ត តែរៀបើញថា ខ្លួនបងដូចជាជ្រក
ជាប់ទ្រូង វែកន្ទេរធ្វើការនោះមិនរហូតបានជាឃាត់ហាមប្អូនដូច្នោះ កាល

ខ្លៅតិនិយាយនឹងគួនក្តីដូច្នោះ ។ ខ្លួលខ្លៅតិលើកកងឹចំតូកមកផល់ត្រែយកាងលិច ។ ខ្លៅតិបានឮសំឡេងហាកំតិចស្ងួតស្មារតី ក្រឡេកទៅឃើញនាយគូកតែងខ្លួនភាក់ការដួតក្បាលសំពត់ស កំសង្កើតស្គាល់បានថាខ្លៅតិ, ខ្លៅតិឲ្យគាហានតាំងពួងសម្ងំនៅស្ងៀម ។ លុះខ្លៅតិមកដល់កំបតគូកចូលទៅគំនាប់ខ្លៅតិហើយយំថា ឥឡូវខ្ញុំបានដឹងថាលោកបានថ្លង់ការនឹងចូនូបែកចំពាត់មក ខ្ញុំបានកំបានរ៉ះរកណ្តាគាហានឲ្យបានលើកមក ប្រាថ្នាឲ្យនឹងជួយលោកមា ។

ខ្លៅតិឮដូច្នោះកំត្រេកអរណាស់ ទើបអធិប្បាយរឿងតាំងតាំដើមដល់ចប់ប្រាប់ខ្លៅតិជាក្មួយឲ្យស្តាប់គ្រប់ប្រការ ហើយឲ្យបន្ទុយគូកចេញពីមាត់កំពង់ ខ្លួលក្រឡេកទៅឃើញគូកចម្បាំងទុកងបើកក្តោងមកតិចិសឯលិច។ ខ្លៅតិប្លែកងឹចិត្តក៏សួរខ្លៅតិថា ខ្ញុំបារកណ្តាគាហានលើកមកគ្រានេះកំអស់លើង ស្រុកកាំងរំហែកំមានមនុស្សស្លូចស្តើងណាស់ ឥឡូវមានគូកចម្បាំងបើកក្តោងមកជាច្រើន ប្រហែលជាគាហានចូនូខ្លះ យើមិនដូច្នោះកំមុខជាគាហានដីវយើឲ្យរលើកមកធ្វើអន្តរាយជាក្រុកជាតិនឹងគ្នាយ៉ាងម្តេចលុះគូកចម្បាំងនោះចូលមកជិត ខ្លៅតិក្រឡេកទៅឃើញពុងបេងអង្គុយខាងក្បាលគូក , ស៊ុនះទៀនអង្គុយខាងកែមកំមានសេចក្តីត្រេកអរណាស់ ទើបឲ្យគាហានស្រែកហៅ ឲ្យចូលមកហើយសួរថា ហេតុម្តេចកំលោកនៅបង្អែបង្អង់ដូច្នេះ ។ ពុងបេងគំនាប់ហើយម្ល៉ើយថា ដែលខ្ញុំបានពង់

នៅដូច្នេះ ព្រោះខ្ញុំថាខៅកេណ្ឌមនុស្សមកខ្លាតថាខជាយឺតយូរ ។ ខ្លៅតិថានស្តាប់ដូច្នោះកំឱ្យបើកក្តោងទូកដែតមក ហើយប្រកាន់ខ្ជាប់ដើម្បីនឹងតតរក។ ថាយច្បាំងតនឹងចូតូតខៅ ។

ខុនបេងនិយាយថា អាណាខែត្រកែ្សមាត់ទឹកដែលនៅដែតស្រុកកាំងហែនោះ មានទីបន្ទាយតូស្នាមក្លោះមាំមួនល្មមនឹងតាំងនៅតស៊ូនឹងចូតូថានសុំឱ្យលើកទ័ពខៅតាំងនៅស្រុកហែខៅមាត់តំពង់ស្រុកកាំងហែចុះ ចំណីត្រីសាច់នឹងស្រូវអែងក្លិរស្បៀងអាហារកំបរបូណ៌មិនខ្វះខាត ហើយកំច្រាប់ខ្លៅតិថា អ្នកចូរស្រុតត្រឡប់ខៅស្រុកកាំងហែឱ្យឆាប់ ដើម្បីនឹងត្រៀមពលថហានតាំងពួនឱ្យត្រមទុកជួយការពារធ្វើការខៅខាងមុខ ។ ខ្លៅតិធ្វើយថា ដែលនឹងឱ្យត្រឡប់ខៅប្រមូលពលថហាន ត្រៀមបំរុងការទុកនោះកំគួរហើយ តែខ្ញុំថាតិតថា នឹងចង់អញ្ជើញលោកខៅជង ឱ្យជួយចាត់ចែងថហានតាំងពួង កាលណាស្រេចហើយសឹមត្រឡប់ខៅនៅស្រុកហែខៅតែម្តងចុះ ។ ខុនបេងយល់ឃើញត្រូវ ទើបឱ្យតួនអ្នាំថហាន ៥ តាន់ខៅនៅរក្សាស្រុកហែខៅ ហើយកំនាំខ្លៅតិខៅស្រុកកាំងហែជាមួយនឹងខ្លៅតិ ។

ឯចូតូដែលថានខៅប្រទះទ័ពតួនអ្នាំនៅកណ្តាលផ្លូវនោះ កំសំគាល់ថាជាកលខុនបេង ទើបមិនអាចនឹងតាមខ្លៅតិខៅ កំនាំពលថយត្រឡប់មកវិញតិតិថាខ្លៅតិរត់ខៅត្រាខ្លះ មុខជានឹងស្រុតរូតខៅវាយយកស្រុកកាំង

ខ្សែនដាច្រាកដបើខ្សែតីចាន់ស្រុកកាំងខ្សែនហើយកំនិងតាំងខ្លួនជាម៉ាមួន
ចាន មុខជាធ្វើការដោយឆកម្រណាស់ តែតហើយកំលើកតាហានវិលមក
វិញ នឹងទៅវាយយកស្រុកកាំងម្សែន ។

ខណៈនោះតុងយីដែលនៅក្បែស្រុកកេងជាវ ដឹងថាស្រុកសុីងយ៉ុង
នោះខ្សែនដល់ឫធ្លូហើយ លុះដឹងថាបួនទ្រលើកមកដល់ដែនស្រុកកេងជាវ
កំនឹកក្លាច ឃើញថាខំងតសូមិនចាន កំនាំតាណាប្រដាក់ស្ត្រីតាំងពួង
ចេញមកតំនាប់បួនធ្លូហើយឲ្យអញ្ជើញបួនទ្រលះទៅក្នុងស្រុក ។ បួនទ្រកំពាត់
ដែនរៀបចំតាណាប្រដាក់ស្ត្រីតាំងពួងវ្រៃទៅដាសុខតាមប្រក្រតី ហើយ
តីគ្រោះប្រឹក្សាខំងសនាតាហានថា ឥឡូវខ្សែតីទៅតាំងនៅស្រុកកាំងហែ
ហើយ យូរទៅតាដ៏មុខឃើញថា ដាចិត្តគំនិតមួយគ្នាខឹងស្រុកតងដឹ
ដួចស្មៅក្រពាញជ្រក បើមិនដំរះដកឫតស់ចុសរលះចញទេ កំនឹង
លួតលាស់ដុះខ្សែនវិញលើសជើម ហើយជាប់ជាភួជរ ។ គ្នាទៅទៀត
ខំងតប្រការម្តង ទើបនឹងកំពាត់ខ្សែតីចេញគុន ។

ស៊ុនហ៊ីវធ្វើយថា ដែលមហាឧបាជរលើកទ័ពមកគ្រានេះ កំយើញ
ថាជាការធំតខ្លីណាស់ ប្រាកដទៅគ្រប់ដំបន់ សូមឲ្យលោកមានសំបុត្រ
ទៅដល់ស៊ុនគួន បបួលមកដើរលេងវិត្រក្នុងស្រុកកាំងហែ ហើយបួរ
តតគួរបបួលបាច់ខ្សែតីឲ្យបាន បើបានខ្សែតីហើយនឹងចែងស្រុកកេងជាវ

(មានត)

បុណ្យភ្ជុំ

ជួយឧបត្ថម្ភសមណនិស្សិត

នៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ឧណៈពន្ធការបុណ្យ រៀបរៀង

កាលពីថ្ងៃសុក្រ ទី ៤ កញ្ញា ១៩៥៩ វេលាម៉ោង ២០ មានការជួបជុំ
នៅក្នុងទីបរិវេណនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដើម្បីធ្វើបុណ្យ
ភ្ជុំមួយ នៅក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកទាំងពីព្រះគន្ធ
ដោយមានព្រះពជ្រាទុញ្ញាគតីសម្តេចព្រះពុទ្ធឃោសាចារ្យ ។

បុណ្យភ្ជុំនេះ ដែលចាត់ចែងធ្វើឡើង ដោយអស់លោកអតីតដ្ឋ-
មន្ត្រីក្រសួងឧត្តការ នឹងលោកដ្ឋលេខាធិការក្រសួងធម្មការបច្ចុប្បន្ន ដើម
អស់លោកអ្នកពុទ្ធបរិស័ទ្ធទាំងឡាយ ចូរជ្រាបអំពីព្រឹត្តិការណ៍នៃសមណ-
និស្សិត ដែលកំពុងសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យសព្វថ្ងៃ គឺជាព្រឹត្តិ-
ការណ៍ដ៏លំបាក ព្រោះសមណនិស្សិតទាំងនេះបានសិក្សាតាំងពីពុទ្ធិក-
បឋមសិក្សា រហូតដល់ពុទ្ធិកមជ្ឈមសិក្សាពីឆ្នាំរួចមក ហើយ ក្នុងរយៈកាល
៧ ឆ្នាំនេះ គឺនៅក្នុងការទប់ត្នុកនៃមាតាតែដែលទំលក្រ ។ លុះផុត
ពីរយៈកាល ៧ ឆ្នាំនេះមក ចានត្រូវជ្រើសរើសឲ្យចូលមកសិក្សាក្នុងពុទ្ធិក-
មហាវិទ្យាល័យព្រះសីហនុរាជ មានរយៈកាលយ៉ាងតិចត្រឹម ៣ ឆ្នាំគត

ទៀត ដើម្បីសិក្សារៀនដាន់ខ្ពស់ខាងព្រះពុទ្ធសាសនា នឹងខាងផ្លូវលោក ។ រីឯសមណនិស្សិតចាំវ័ននោះ ទោះបីបានមកសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យ កំពង់តមែនហើយ ប៉ុន្តែការចូលតម្កល់ទោះមុខដីគោក កំត្រូវទៅតែរួលពីសំណាក់ញាតិញោមដដែល រីឯញាតិញោមនៃសមណនិស្សិតចាំវ័ននោះ សុទ្ធតែនៅឯខែត្រក្រៅឆ្ងាយ។ ហើយមិនដែលជាអ្នកសម្បូរណ៌ជាយជនជានជន ម្ល៉ោះហើយការចូលតម្កល់មិនបានដិតដល់ ថែមទាំងសមណនិស្សិតចាំវ័ននោះ ដែលបានរួលការសិក្សាខ្ពស់ៗឯង ត្រូវបង្ខំមកប្រាយោមបេះខ្លួន នឹងពេលវេលាបេះខ្លួនឲ្យច្រើនឡើងទៀត ដើម្បីឲ្យសមដល់គម្ងន់នៃការសិក្សានោះ ម្ល៉ោះហើយដីគោកនៃសមណនិស្សិតដែលបានបាត់តែប្រព្រឹត្តទៅតាមធម្មតានោះ ត្រឡប់ជាមានដំណើរមិនស្រួលនឹងបណ្តាលឲ្យមានការអាក់អន់ ។

អស់លោកមន្ត្រីនឹងពុទ្ធបរិស័ទទាំងឡាយ បានជ្រាបព្រឹត្តិការណ៍ដូចខាងលើនេះហើយ កំមានចិត្តអាណិតគាស្ងួរសមណនិស្សិតចាំវ័ននោះ ទើបរួបរួមគ្នាធ្វើជាបុណ្យផ្កាមួយ ដើម្បីប្រមូលបច្ច័យដែលកើតពីសទ្ធាជ្រះថ្លានៃអស់លោក-អ្នកជាពុទ្ធសាសនិកជន យកទៅជួយចូលតម្កល់សមណនិស្សិតចាំវ័ននោះ ដើម្បីឲ្យមានដីគោកស្រួលបួលឡើងវិញ ហើយនឹងបានតាំងព្យាយាមសិក្សាតទៅទៀត ។

មុខនឹងធ្វើបុណ្យផ្កានោះ ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត គាត អគ្គាធិការនៃពុទ្ធិកសិក្សាបានធ្វើចុតហ្វាយ ថ្វាយសម្តេចព្រះចុបយ៉ាកជាជ

ប្រមុខនៃពជរដ្ឋភិបាលសូមព្រះពជគ្ឃានព្រះពជាន្ទុញ្ញាត ។ សម្តេចព្រះ
ឧបយុវពជ ទ្រង់ក្រោសព្រះពជគ្ឃានព្រះពជាន្ទុញ្ញាត ហើយទ្រង់ចាន
ចូលចាប់កុសលកុដិបុណ្យផ្ការនេះ ដោយព្រះពជទ្រព្យផ្ទាល់ព្រះអង្គ ចំនួន
៥.០០០រៀល ផងដែរ ។

នៅឧកាសបុណ្យផ្ការកុដិនេះ មានសម្តេចព្រះមហាសុមេធា.
ធិបតី សង្ឃនាយកគណៈមហានិកាយ និងសម្តេចព្រះសុធម្មាធិបតីសង្ឃ
នាយកគណៈធម្មយុត្តិ ចាន់និមន្តទៅជាអធិបតី ដោយមានព្រះតេជព្រះ
គុណព្រះគោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សា ទៅអមសម្តេចតាំងពីព្រះ
អង្គកុដិតំនាងដែរ ។

អស់លោកមន្ត្រីធំៗតូចតាំងឡាយ ក៏ចានអញ្ជើញទៅចូលចាប់កុសល
កុដិបុណ្យផ្ការនោះតាមសទ្ធារៀងខ្លួនកុដិហានៈជាពុទ្ធសាសនិកជន ព្រម
តាំងអស់លោកជាពុទ្ធបរិស័ទតាំងឡាយ ដែលមាននាមកុដិប្រូក្រាម
បុណ្យក្តី មិនមាននាមកុដិប្រូក្រាមបុណ្យក្តី ក៏ចានអញ្ជើញទៅចូលចាប់
កុសលតាមសទ្ធារៀងៗខ្លួន ។

ដល់ម៉ោង ៦០ គត់ និមន្តសមណនិស្សិត ៤០ រូប ចំរើនព្រះបរិត្ត
នៅទីគ្រឹះស្ថានព្រះសីហនុ ។

ដល់ម៉ោង ៤៩-៣០ នាទី និមន្តសម្តេចព្រះមហាសុមេធាធិបតី
ប្រកាសធម្មទេសនា ដល់ម៉ោង ៦១ ទើបចប់ ។

លំដាប់ពីនោះ គណៈកម្មការបានរួបរួមចង្ហែយដែលកើតពីសទ្ធាជ្រះថ្លា នៃពុទ្ធបរិស័ទចាំនឹងឡាយ បានចំនួន ៥៨ ៦៣៧.០០ ។

នៅពេលបន្ទាប់ពីនោះ គណៈកម្មការបានចាត់ចែងឲ្យកត្តិនជាតិខ្មែរម្នាក់ឈ្មោះ គ្រូឌុ និយាយរឿងកម្រើកផ្ទួនមហាជន ស្តាប់ជាការកំសាន្ត ។ ការនិយាយរឿងកម្រើកនោះ នាំឲ្យមហាជនពេញចិត្ត ហើយសប្បាយកែកយណាស់ ឥតមានអ្នកណាម្នាក់ដែលចូលទៅស្តាប់ហើយធុញទ្រាន់សោះឡើយ ព្រោះអ្នកគ្រូឌុនោះមានសារមូងពីកេះ ហើយចេះនិយាយប្រកបដោយសំនួនពេហារកក្បាយ ហើយថែមទាំងចេះបង្ហាញការយោគឲ្យសមទៅតាមទំនងនៃរឿងក៏រំនោះផងទៀត រហូតដល់ម៉ោង ២៤ ទើបចប់ដោយសន្តិ ។

ការក្រោយបុណ្យផ្កាំនោះមួយថ្ងៃ គណៈកម្មការបុណ្យបានធ្វើសេចក្តីសំដែងកតញ្ញូតាធម៌ ទីឆ្នាំទ្វិសក្ខុសលផ្សាយតាមវិទ្យុជាតិ ទីឆ្នាំបុរកឆ្នាំការសែតកម្ពុជា ដូចមានតទៅនេះ ៖

ការតាំថ្ងៃសុក្រទី ៤ កញ្ញា ១៩៥៩ នេះ តាំងពីម៉ោង ១៩ ដល់ម៉ោង ២៤ គណៈកម្មការបុណ្យបានចាត់ចែងធ្វើបុណ្យផ្កាមួយ ដើម្បីជូយទុបត្ថម្ភដល់សមណនិស្សិតចាំនឹងឡាយ ដែលកំពុងសិក្សាសព្វថ្ងៃ នៅក្នុងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកចាំនឹងពីព្រះអង្គ ដូចមានកម្មវិធីបុណ្យដែលបានផ្សាយតាមវិទ្យុជាតិពី

ថ្ងៃមុនស្រាប់ ។ បុណ្យផ្កានោះ ចានទទួលលុយផលតបច្ចុយចំនួន ៥៨.៦២៣.០០ ដោយរួបរួមទាំងអស់ ។ បច្ចុយទាំងអស់នេះ គណៈកម្មការបុណ្យ ចានប្រគល់ទៅលោកគណនេយ្យការនៃពុទ្ធិកមហាវិទ្យាល័យ ឲ្យយកទៅដើទុកទៅធនាគារហើយ ឲ្យចាត់ចែងបើកយកតាលំនៃ តាមចំនួនដែលមានតំរិតមកដួយទុបត្ថម្ភសមណនិស្សិតទៅ ដកបដលអស់ចំនួនប្រាក់ខាងលើ ។

គណៈកម្មការបុណ្យ សូមសំដែងដោយគោរពនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅចំពោះសម្តេចព្រះទុបយុវរាជ ជាព្រះបិតាឯកភាជ្យជាតិ ដែលទ្រង់ចានទ្រង់ព្រះសព្រះរាជទាន ព្រះរាជានុញ្ញាតឲ្យចាត់ចែងធ្វើបុណ្យផ្កានេះ ហើយសម្តេចទ្រង់ចានចំណាយព្រះរាជទ្រព្យ ចូលចាប់កុសលក្នុងបុណ្យផ្កានេះផងដែរ ។

សូមអរព្រះគុណដ៏ខ្ពង់ខ្ពស់ ចំពោះសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ដែលមានទីតព្រះទ័យត្រជាក់ ចានលះបង់កិច្ចកង្វល់ផ្លាល់ព្រះអង្គ ហើយទិមន្តទៅជាអធិបតីក្នុងការបុណ្យនោះ មិនតែប៉ុណ្ណោះចានទាំងប្រទានចតុប្បច្ចុបចូលចាប់កុសលក្នុងបុណ្យនោះផងដែរ ។

សូមអរព្រះគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តមនឹងអស់លោកទាំងឡាយដែលជាអ្នកផ្តើមធ្វើបុណ្យផ្កានេះ ដែលមានឧាមចារឹកក្នុងប្រក្រមបុណ្យស្រាប់ ព្រោះឯកឧត្តមនឹងអស់លោកទាំងឡាយព្រមទាំងពុទ្ធបរិ-

ស័ខ្វះនោះ ចានជ្រាបពីស្ថានការណ៍នៃតុទ្ធិកមហាវិទ្យាល័យសង្ឃគ្រប់ ទើបចានផ្តើមធ្វើដោយសេចក្តីជ្រះថ្លា ហើយចានបរិច្ចាគធនធានរៀងខ្លួន ត្រមាំងចានដឹកនាំអស់លោកអ្នកតាំងឡាយឯទៀត ឲ្យកើតចិត្តជ្រះថ្លា ចានចូលមកជួយអនុមោទនាកុងកិការបុណ្យនេះ ។

សូមអរព្រះគុណជាអនេក ចំពោះព្រះសង្ឃនីងអស់លោកអ្នកជាពុទ្ធ-បរិស័ទាំងឡាយ ដែលមិនមានឆាមក្នុងប្រក្រាមនេះទេ ប៉ុន្តែចានមិនខ្ជះ អញ្ជើញមក ជួយអនុមោទនាកុងបុណ្យដ៏នេះ ដោយចានបរិច្ចាគធនធាន តិច-ច្រើន តាមកម្លាំងសទ្ធារៀងខ្លួន ។

នៅចំអាសាននេះ គណៈកម្មការបុណ្យសូមទុទ្ធិសផលដែលកើត ឡើងអំពីការបុណ្យនេះ ថ្វាយចំពោះព្រះគុណជាអម្ចាស់ដ៏វិត សម្តេច ព្រះមហាសុត្រិយោទិ នីងសម្តេចព្រះទុបយុវៃជ ជាព្រះបិតាឯកពជ្យជាតិ សូមទ្រង់ចានប្រកបដោយសុខសុស្តីសិរីមង្គលគ្រប់ប្រការ នីងសូមឲ្យមាន ជន្មាយុយឺតយូរអស់កាលជាអង្វែងតទៅ ។

សូមទុទ្ធិសផលប្រគេនចំពោះសម្តេចព្រះសង្ឃនាយកចាំងពីព្រះអង្គ សូមឲ្យចានប្រកបដោយសេចក្តីសុខសន្តិ កុំបីមានកេតាពាធមកបៀត បៀនព្រះអង្គចានឡើយ ជាបដល់អាសាន ។

សូមទុទ្ធិផលចំពោះឯកទុតម នីងអស់លោក-អ្នកជាពុទ្ធបរិស័ទាំង ឡាយ សូមឲ្យចានប្រកបដោយសុភមង្គល វិបុលសុខ គ្រប់ទិវាកត្រី អស់កាលជាអង្វែងតទៅ ។

ព្រះមហាប៉ាង-ខាត់ រៀបរៀង

អណ្ឌ ឧបុំ ពង, ស៊ុត ។ *អណ្ឌក* កំមាន *ឫ* –*តដាហ* បុំ. សំបកនៃស៊ុត, (ស្រោមនៃពិភពលោក) ។ –*កោត* បុំ. សំបកនៃស៊ុត, (ស្រោមនៃពិភពលោក) ។ – *គត* គុ. ដែលតាំងនៅក្នុងស៊ុត ។ – *ជ* គុ. ដែលកើតក្នុងស៊ុត; បុំ បក្សី, ត្រី ។ – *ជគ្គរ* បុំ. ក្រុង ។ –*កោឝ* ឧបុំ. ភាវៈបែកនៃស៊ុត ។

អតិជ គុ. ដែលចោត, បុំ. ដំរាសចោត, ត្រសាង ។

អតិត្ថបិំនិ្ធ គុ. ដែលមានតែក្តីតិះមិនមាន ។

អតិៈបិ្របិតិ គុ. ដែលសន្សំហើយ ក្តីប្រោះមិនមាន, ដែលមិនឆ្អែប់ ។

អតិប្បិ គុ. ដែលខ្ពង់តិត ។

អតិទិ, សរិ. មិនមែនអ្នកនោះ, មិនមែនបស់នោះ ។ ឧបុំ. ភាវៈមិនមែនក្តីប្រោះ ។ – (*អតទ*) *ហ៊ីមាណ* គុ. ដែលមិនក្តីរងើរអ្នកនោះ, ដែលមិនក្តីរងើរបស់នោះ ។ – *វិទ* (*អតទ្វិទ*) គុ ដែលដឹងក្តីប្រោះក៏មិនមាន ។ – *វិយវិភ្វាម្យ* (*អតទ្វីយ–*) គុ. ដែលដឹងក្តីរាល់ឃាមបស់ខ្លួនក្តីប្រោះមិនមាន ។

អតិង្គ គុ. ដែលមិនមែនតួច, ដែលប្រមាណជាន ។ បុំ. ភាវៈទេព, ភាព ។ – *ពល* គុ. ដែលមានកម្លាំងតិចមិនមាន, ដែលមានកម្លាំងច្រើន ។

(មានត)


ភាវនាសូត្រ

ទស្សនាវដ្ដី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ១០ ខែតុលា

ព. ស. ២៥០២ គ. ស. ១៩៥៨

ភ្នំពេញ



ភ្នំពេញសារទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
– វិចារណកថា	លោក ស៊ុន-ភ័ន	រៀបរៀង ១០៨១
– ប្រវត្តិព្រះសុមេធាវើរី	លោក ឃួរ-ឆុន	រៀបរៀង ១០៩៤
– សុរពជាតក (តមក)	លោក ថង - រឹង	បម្លែងពីសាស្ត្រាស្ងឹកវែត . . ១០៩៩
ផ្នែកគន្ថរសាស្ត្រ		
– រឿងហង្សយន្ត (តមក)	លោក គឹម - កន	បម្លែងពីសាស្ត្រាស្ងឹកវែត . . ១១០៧
– ព្រោះហេតុអ្វីបានជាសត្វសេកត្រាប់ពាក្យមនុស្សតែមួយម៉ាត់ ។ ជាតកឥតន័យ		
	ព្រះមហា ម៉ែន-រៀម	រៀបរៀង ១១២១
– រឿងត្រោងនឹងរឿងបុរាណប្រទេសជប៉ុន(តមក)	លោក ភ័យ - ប៊ុក	រៀបរៀង . ១១៣៨
– រឿងស្រីគ្រប់ល័ក្ខណ៍ (តមក)	យុក - វណ្ណ	រៀបរៀង លោក ផេង-ត្រីវ ពិនិត្យ . ១១៤១
– ការស្រាវជ្រាវរកប្រភពនៃបុណ្យកន់បិណ្ឌ និងភ្ជុំបិណ្ឌ		លោកជាប-តិន រៀបរៀង ១១៥១
– រឿងមរណមាត្រ (តមក)	លោក ប៊ី-សុវណ្ណ	បម្លែងពីសាស្ត្រាស្ងឹកវែត . . ១១៥៦
– រឿងសាមកុក (តមក)	ឧកញ៉ា ឆូ - កន	ប្លែង ១.៧៧
ផ្នែកកំណត់ទិនប្រវត្តិការណ៍		
– ពត៌មានផ្សេង ។	របស់ក្រសួងធម្មការ	. . . . . ១៤០២
– វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ (តមក)	ព្រះមហា ជាង-ខាត់	រៀបរៀង . . ១៤០៤

តម្លៃលក់ មាន ១២ សៀវភៅ ជាំវិញជាវ ៣៣០០

KAMBUJASURIYA

Revue religieuse et litteraire
éditée par l'Institut Bouddhique

sommaire

Partie religieuse :

— Editorial par M. SIN HEAN 1081
— Pravattisumedhatheri par M. YOU-OUN 1084
— Surabajataka (suite) relevé du manuscrit sur feuilles de latanier par M. THANG-VONG 1099

Partie littéraire :

— Histoire de Hang-Yon (suite) relevée du manuscrit sur feuilles de latanier par M. IM-PHON 1107
— Pourquoi le perroquet parle-t-il mot à mot par M. MEN-RIEM 1121
— Contes et Légendes du Japon (suite) traduits par M. RAY-BUC. 1128
— La femme vertueuse par Yok Vochir revue et corrigée par M. PHENG-CHRIV 1141
— L'origine de la quinzaine des morts par M. CHAP-PIN 1151
— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN 1156
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1177

Notes et Chroniques :

— Nouvelles diverses du Ministrère des Cultes 1202
— Dictionnai e Sanskrit-khmer (suite) par Preah Moha-PANG-KHAT : 1204

Prix d'abonnement annuel (comprenant 12 numéros): 2$0,00 .

វិចារណកថា

លោក សុខ-ហ៊ាន រៀបរៀង

ព្រះសម្ពុទ្ធជាបរមគ្រូ ទ្រង់ជាអគ្គបុរសដ៏ឆ្នើមក្នុងលោក, ព្រះអង្គទ្រង់មានព្រះកដហឫទ័យ ប្រកបដោយព្រះមហាករុណាគុណយ៉ាងធំមហិមាចំពោះសត្វលោក គឺព្រះអង្គទ្រង់ស្ដេចយាងទៅសួរសុខទុក្ខ-ធម៌ចំពោះព្រះអង្គ ឥតគិតដល់ការនឿយហត់ព្រះកាយតិចសោះ, លុះបានត្រាស់ដឹងមោក្ខធម៌ហើយ ព្រះអង្គទ្រង់យកនូវព្រះធម៌ដ៏សុខុមនោះ មកទេសនាពន្យល់ណែនាំសត្វលោកឲ្យប្រតិបត្តិតាម ដើម្បីឲ្យបានច្រាសចាកទុក្ខភ័យគ្រប់យ៉ាង ហើយនឹងបាននូវសេចក្ដីសុខ ដែលសត្វលោកតែងតែត្រូវការគ្រប់គ្នា ។

ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ជាឧទាហរណ៍ដ៏ឧត្តមមួយនៃបុគ្គលអ្នកឃើញដល់សង្គមធំ ព្រះអង្គទ្រង់មិនជាប់ជំពាក់នៅក្នុងសង្គមតូចណាៗទេ ហើយទ្រង់មិនប្រកាន់ជាតិភាសាវណ្ណៈវង្សត្រកូល ឬនីលក្ខណៈរួមដែលមានវង់តូចដទៃៗ ជាគ្រឿងបែងចែកវាងមនុស្សទេ គឺព្រះអង្គទ្រង់ប្រកាន់ថា មនុស្សគ្រប់ៗគ្នាយកក្នុងលោកដូចគ្នាគ្រប់គ្នាអស់ សុទ្ធតែចង់បានសុខស្អប់ខ្ពើមទុក្ខគ្រប់ៗគ្នា បានជាព្រះអង្គទ្រង់បញ្ញត្តមក់ទប្រៀនប្រដៅពុក

តាំងប៉ុន្មានប្រយោជន៍ដើម្បីសង្គមធំ មិនបានបញ្ចូលក្នុង ចំពោះមនុស្ស
ជាតិណា ភាសាណា ពួកណាទេ, តែសេចក្តីចំណុច នេះណា ។ គឺអាចប្រតិ
បត្តិតាមបាន ហើយអាចទទួលផលបាន តាមសមត្ថភាពដល់ការប្រតិបត្តិ
ជូនគ្នាតាំងអស់ ។

ប្រជាពលរដ្ឋខ្មែរតាំងមូល សុទ្ធសឹងជាអ្នកកាន់ព្រះពុទ្ធសាសនា
តាំងពីបុរាណកាលមក, បានជាប្រជាពលរដ្ឋខ្មែរពេញចិត្តចំពោះព្រះពុទ្ធ
សាសនា ទទួលយកគុណជាសារណៈដ៏ខ្ពង់ខ្ពស់នោះ ព្រោះជាសាសនាអាច
ផ្តល់ខ្លឹមសុភមង្គល សុខសន្តិភាព វឌ្ឍនភាពគ្រប់យ៉ាង ដោយប្រើ
ភ្នែកជាកណ្តាល គឺព្រះពុទ្ធសាសនាបង្រៀនប្រដៅឲ្យមានអធ្យាស្រ័យចេះ
អត់ឱន ឲ្យឆ្លើសចំណុចល្អ មិនចំពោះតែជនរួមជាតិរបស់ខ្លួនប៉ុណ្ណោះទេ
ត្រូវធ្វើចំពោះសត្វលោកតាំងអស់ក្នុងសាសារលោក ព្រោះគេក៏ត្រូវការ
រស់នៅ ត្រូវការសុខដែរ តែងតែជួយជាយើងវិញ ។ ទំយើងសំខាន់
បំផុត, ព្រះពុទ្ធសាសនា បានប្រៀនប្រដៅឲ្យមានចិត្តមេត្តាករុណា
ដោយមេត្តាករុណាចំពោះសត្វលោកទូទៅ ។

ដោយប្រទេសកម្ពុជាសព្វថ្ងៃ ដែលមានព្រះករុណាជាម្ចាស់ជីវិតតាំង
ព័ះព្រះអង្គ ទ្រង់សម្តេចព្រះនរោត្តមសីហនុជាព្រះបិតាឯករាជ្យជាតិ ទ្រង់ជាព្រះ
អគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមរបស់ជាតិខ្មែរ ទ្រង់បានយល់ឃើញវិសារប្រយោជន៍

ជាតម្លៃនៃព្រះពុទ្ធសាសនា មាន-ហេតុផលគ្រប់គ្រាន់ ល្មមនឹងដឹកនាំប្រទេសរបស់ព្រះអង្គទៅកាន់សេចក្តីសុខក្សេមក្សាន្តបាន ដូចន័យខាងលើនេះហើយ ទើបទ្រង់ដឹកនាំប្រជាពលរដ្ឋខ្មែរតាំងមូលឲ្យប្រកាន់យកនូវនេយ្យបាយអត្ថក្រឹត្យ ជានេយ្យបាយក្រៅប្រទេស សម្រាប់ប្រទេសខ្មែរ គឺប្រព្រឹត្តអនុលោមទៅតាមព្រះពុទ្ធសាសនា ដែលបានយកផ្លូវកណ្តាល, ផ្លូវមធ្យមជាគោល ដើម្បីសន្តិភាពនៃលោក ។

ទៅថ្ងៃអាសាឍ, ប្រជាពលរដ្ឋខ្មែរខួងខ្ញុំសុទ្ធសឹងជាពុទ្ធសាសនិកជន ត្រូវប់គោរពតាមព្រះពុទ្ធោវាទ ដែលប្រៀនប្រដៅឲ្យចូលចិត្តចំពោះការពិតនឹងការសុខស្ងប់, ឲ្យលះបង់ជម្ងឺអាក្រក់ ដោយកិច្ចការនាំយកនូវធម៌ល្អ, ឲ្យយកចិត្តទុទ្ទឹមកដំនួសការយោរយៅ ទើបឲ្យយកគុណទៅសងតបាច ។ រឿងពបដកបមក ក៏បានខួលឥដ្ឋមនុស្សជាផលពីការកុសលរបស់ខ្លួនដ៏សមរម្យ គោលគឺបានស្ថិតនៅក្រោមការដឹកនាំដ៏ប្រសើរនៃព្រះរាជបល្ល័ង្កសព្វថ្ងៃនេះ ទឹងសម្តេចព្រះឧបយុវរាជ បានចៀសផុតព័ត៌ក្តីងសង្គ្រាម ស្ថិតនៅក្នុងសុខសន្តិភាពទឹងសំបូរណាភាពជាបំបូណ៌ ។

ប្រវត្តិព្រះសុមេធាវីរៈ

ឃុនសុវត្ថិវេទី យ៉ូរ៉ូ-អ៊ីវ៉ង ប្រែតាមបាលី

ដែលមានក្នុងគម្ពីរពុទ្ធវង្ស ខុទ្ទកនិកាយ នៃសុត្តន្តបិដក

ព្រះពុទ្ធគោតម ព្រះនាមសុមេធា ជាកូនដំណាលនៃព្រះបាទគោតមរាជ សាយកវង្សក្នុងនគរ មន្ទាវតី ព្រះនាងមានសទ្ធាជ្រះថ្លា ដើម្បីចម្រើនក្នុងព្រះពុទ្ធសាសនា ដោយការបានស្តាប់ធម៌នៃព្រះពុទ្ធជាម្ចាស់ ។ អាស្រ័យហេតុដែលព្រះនាងបានស្តាប់ធម៌ជាញឹកញាយ ព្រះនាងក៏មានការរះចាំនូវពុទ្ធវចនៈប្រើន ជាស្ត្រីតហុស្សក បានថ្វាយទ្វីនជាឧបាសិកា រក្សាខោសឋសីល មានតិរិយាមារយោនត្រឹមត្រូវតាមតន្ត្រីពុទ្ធឧដ្ឋ ។ ឯណាស្ត្រីតាំងឡាយ ដែលប៉ុនប្រសប់ខាងសំដែងធម៌ ព្រះនាងសុមេធាដូចរូបដែរ ដែលកាលប៉ះជាងមុនចិតា មានប្រាជ្ញាឈ្លាសវៃ ចេះសំដែងធម៌ដ៏វិចិត្រ ពីរោះអស្ចារ្យ ។

ក្នុងថ្ងៃមួយ ព្រះអង្គម្ចាស់ក្សត្រ សុមេធា ទ្រង់បានជ្រាបតាមានថា ព្រះពុទ្ធមាតាបិតា ទ្រង់នឹងព្រះវេជាន់ញ្ញាតព្រមថ្វាយព្រះនាង ទៅជាអគ្គមហេសី នៃព្រះពុទ្ធាតម្ចាស់ ១ អង្គ ទ្រង់ព្រះនាម អ្នធិកវត្តិ សោយរាជ្យនៅនគរ កាណវតី ដែលស្តេចនឹងយាងមកជណ្តើង ក្នុងពេលតាប់ ។ ។ ព្រះនាងកាលបានជ្រាបដំណឹងនេះហើយ ក៏បានយាងចូលទៅគាល់ព្រះវេជមាតាបិតា ហើយក្រាបទូលអំពីសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ-

សាសនា ខ្ញុំឯងសេចក្តីយល់ឃើញតាមផ្លូវធម៌ របស់ព្រះនាង ដូចមាន
សេចក្តីតទៅនេះ ៖

បពិត្រព្រះមាតាបិតា ខ្ញុំម្ចាស់នេះ ជាអ្នកត្រេកអរនៅភ្ញាក់ក្តី ក្នុង
ព្រះទ័ព្វានហើយ ដោយខ្ញុំម្ចាស់យល់ថា ការកើតជាមនុស្សក្តី ជាទេវតា
ក្តី សឹងតែមិនទៀង មិនបានថេរទេ ខ្ញុំបានចាប់នោលទៅថ្វាយដល់ត្រកាមខ្ញុំ
តាំលេសកាម ដែលជាបរស់សោះសូន្យ មានការត្រេកអរតិច មាន
សេចក្តីចង្អៀតចង្អល់ច្រើន ។ ពួកជនពាលតែងលួងចិត្ត ក្នុងកាមភាំង
ឡាយណា កាមភាំងឡាយនោះ ជាបរស់ខ្មោចផ្សារ តើតឈើជាប់
មានតិសដូចអស៊ីពិស ។ ពួកជនពាលដែលដក់ជាប់ភ្ញាក់ក្នុងកាម
សឹងតេញណែនត្រៀបត្រា ក្នុងនរក រនៃក្នុងលាំបាកអស់កាលយូរអង្វែង
ឆ្នាំ តែងទៅរនៃក្នុងសង្រែងសង្រៃក្នុងកំណើតប្រេត អសុរកាយ តិរច្ឆាន។
ព្រោះពួកជនពាលភាំងនោះ ជាអ្នកល្ងង់ អាប់ឥតប្រាជ្ញា ។ ថ្វីតែរំ-
តើបាប មានតំនិតអាក្រក់ មិនសង្រួមរាំងកាយវាចាចិត្ត គ្មានបេតនា
ប៉ងនឹងធ្វើការកុសល បណ្តាយចិត្តសូន្យទៅក្នុងអំណាចតណ្ហា ឲ្យតណ្ហា
ប្រមែតដឹកនាំទៅក្នុងតំនៃទុក្ខ គ្មានប្រាជ្ញាស្មារតីក្តីស្វាងក្នុងអរិយសច្ចៈ ។
បពិត្រព្រះមានគុណ មនុស្សមានចំនួនច្រើនមាក់ណាស់ ដែលមិនដឹង
អរិយសច្ចធម៌ ត្រេកអរតែនឹងកត តេញចិត្តតែនឹងការកើតជាទេវតា ។
សូម្បីការកើតក្នុងកតជាទេវតា ក៏មិនទៀង ទុកជាកតមិនទៀង ពួកជន

ពាលក៏នៅតែមិនតក់ស្លុតនឹងភព ដែលត្រូវតែតញ្ជាយ ។ នោះឡើយ ។ ពួកសត្វនិច្ចាត មិនអាចនឹងបួសក្នុងពុទ្ធសាសនាបានទេ ត្រោះពួកសត្វនោះវិបត្តិតែទេ ហើយវង្វេងក្នុងគ្មានស្រាក មានតែមនុស្សជាតិទេ ទើបអាចបួសបាន ។ ហេតុនោះ ការបានអត្តភាពជាមនុស្ស ដែលគ្មានវិតលរូបកាយ ពុតជាលាភធំរបស់សត្វ ។ អាស្រ័យការណ៍នេះ សូមទ្រង់តាំងពីរអង្គ ព្រះមេត្តាប្រោសព្រះពជាទញ្ញាត ឲ្យខ្ញុំម្ចាស់បួសក្នុងព្រះពុទ្ធសាសនា ។ ខ្ញុំម្ចាស់កាលបើបានបួសហើយ ខំប្រឹងប្រែងប្រព្រឹត្តធម៌ ដើម្បីលះបង់ជាតិនឹងមរណៈឲ្យអស់ ។ ប្រយោជន៍អ្វី ដោយភពដែលជនកាលត្រេកត្រអាល ប្រយោជន៍អ្វី ដោយរូបកាយដែលជាៈទាសភតខ្វឹមសារ ត្រោះព្រះសម្ពុទ្ធទ្រង់ត្រាស់ឲ្យដឹងក្នុងលោកហើយ ខណៈវិបត្តិ ខ្ញុំម្ចាស់កន្ទុងដុតហើយ ខណៈសម្បត្តិខ្ញុំម្ចាស់បានហើយ ខ្ញុំម្ចាស់មិនហ៊ានប្រព្រឹត្តឲ្យស្មៅហ្មងសៅ ឲ្យខូចត្រហ្មចរិយធម៌ទេ រហូតអស់មួយជីវិត ហេតុនេះ សូមទ្រង់ព្រះពជាទុញ្ញាតឲ្យខ្ញុំម្ចាស់បួស តាមសេចក្តីក្រាបបង្គំទូលសុំនេះ កុំខានឲ្យខាន ។

ព្រះនាងសុមេធា កដធីតា លុះក្រាបបង្គំទូលលាៈតាបួសយ៉ាងនេះហើយ ក៏ដួលចុះលើផែនដីនាផ្ទៃប្រាសាទ ។ ឯព្រះពជមាតាបិតា កាលទ្រង់បានជ្រាបហើយ ពាំនឹងព្រះពជហប្ញទ័យជាទុក្ខព្រួយខ្លាំង ហាក់ដូចភ្នំធំសង្កត់លើព្រះអង្គ ទ្រង់ទំសម្រុះសម្រួលលួងលោម

ធីតា ពាំងព្រះនេត្រាសោរតេញដោយទឹកព្រះនេត្រថា ៖

នុធីតាសំឡាញ់នុពុកអើយ ចូរក្រោកអង្គុយឡើង ស្តាប់នុពុកនិយាយ យើងជានុពុកម្តាយនេះ ចាស់ៗហើយ មានសង្ឃឹមតាំងផ្អែកតែលើនាងទេ ឲ្យនុពុកលះបង់នាងម្តេចបាន ។ នាងចង់បួស តើបួសមានប្រយោជន៍អ្វីដល់យើង ។ នែកូនស្រីមាសសំឡាញ់ នុពុកបានសម្រេចចិត្តថា ខឹងថ្វាយនាងដល់ព្រះភ្លាអនិកត្ត ជាស្តេចមានបុណ្យសោយភក្ស្យនៅខនរាំណាតិ នាងនឹងបានជាអគ្គមហេសី ជំលៀសស្ត្រីពាំងឡាយ នៃព្រះភ្លាអនិកត្តនោះ ហើយព្រះពរណាចក្រនៃស្តេចនោះ ជំរុលាយ ជាប្រទេសមានកោតខ្លាច្រើន ដែលជាហេតុឲ្យនាងបានសេចក្តីសុខសាន្ត ឲ្យមានឥស្សរិយយស ជាជំរកលែងនាងអាចនឹងប្រើប្រាស់ខ្លួនសម្បត្តិភាំងនោះ តាមចិត្តប្រាថ្នា ។ នែកូនស្រី ឮថា ស៊ីលា ព្រហ្មចរិយធម៌ នឹងការកាន់ តាមជាអ្នកបួសនេះ គេធ្វើបានដោយកម្រណាស់ ចុះបើកូនឯងនៅរៀងក្មេងម៉្លេះ ធ្វើម្តេចនឹងប្រព្រឹត្តព្រហ្មចរិយធម៌ តាមគេជាអ្នកបួសបាន ។ នុកូនស្រីមាសនុពុកព្រះភ្លាអនិកត្ត ខឹងស្តេចមកដណ្តឹងនាងកូនគេសឲ្យ ។ ហើយ នុពុកខឹងថ្វាយនាងទៅជាអគ្គមហេសីនៃស្តេចនោះ ចូរកូនស្រីកុំខឹងតាស់ឡើយ ។

គ្រានោះ ព្រះអង្គម្ចាស់ក្សត្រីសុមេធា យកព្រះកូសាដូតទឹកព្រះ

នេត្រអំពីព្រះភក្ត្រ ហើយមានព្រះសវណីយ៍តបថា ៖

បពិត្រព្រះកដមាតាបិតា ខ្ញុំម្ចាស់មិនត្រូវការព្រួយសម្បត្តិទាំងនោះទេ ព្រោះជារបស់គ្មានខ្វឹមសារ ខ្ញុំម្ចាស់ត្រូវការតែបព្វជ្ជាតែប៉ុណ្ណោះ ព្រោះជាគេមានពេលខំនេះអាចប្រតិបត្តិធម៌បាន បើខ្ញុំម្ចាស់មិនបានបួសទេ ខ្ញុំម្ចាស់ស្អប់ស្អាប់ជ្រុសើរជាង ព្រោះហេតុនោះ សូមព្រះអង្គកុំខ្វល់ឃ្លាំឃ្លាតតាមព្រះបាទអនិកវត្តដែលនឹងស្តេចមកដណ្តឹងនោះឡើយ ។ ខ្ញុំម្ចាស់ឃើញស្អប់ថា សរីរៈនេះ មិនស្អាត មានក្លិនអាក្រក់ គួរខ្ពើម រូបកាយនេះកុកដូចជាកាកុនស្អែក ដែលច្រកពេញណែនដោយសាកសព ឬដោយវត្ថុមិនស្អាត ដែលតែងហូរចេញមកតាមទ្វារទាំង ៩ នឹងតាមរន្ធរោម ។ មួយទៀត ខ្ញុំម្ចាស់ឃើញថា សរីរកាយនេះ ជាគ្រោងឆ្អឹង ដែលសង្កាប់ក្បាលដោយសាច់ ឈាមនឹងស្បែក ជាលំនៅនៃហ្វូងដង្កូវ តាលេបីជីវិតរលត់ចុះតំបន់ទៅ រូបកាយក៏ជាចំណី នៃពួកសត្វតិរច្ឆាន ។ ក្នុងពេលនេះ គេនឹងឲ្យសរីរកាយនេះ ដោយឥតយកថ្លៃ ឬសូម្បីតែខ្លួនក្បាលទុក ក៏គ្មានអ្នកណាម្នាក់ត្រូវការទេ ។ រូបកាយនេះ បើគេពន្លាត់ឆ្អឹងការៈខាងក្នុងឡើងត្រឡប់មកខាងក្រៅវិញ គេនឹងឃើញក្បាស់ជាជារបស់គួរខ្ពើម សូម្បីមាតាបិតាបង្កើត ក៏ប្រាត់នឹងក្លិនអសោចិ៍នោះពុំបាន ។ កាយនេះ បើគ្មានវិញ្ញាណហើយ មិនយូរទេ គេនឹងយកទៅដុតចោលឬកប់ចោលក្នុងព្រៃស្មសាន ជារបស់គ្មានប្រយោជន៍ មិន

ដល់ទីដ៏អង្គត់ទុស មានឋិតាឋប្បបុត្តធីតា ដែលកាន់តាលំភ្នែចនោះ សឹង
ប្រញាប់ដួតលាងដៃដើងខ្លួនប្រាណ ព្រោះមានសេចក្តីខ្ពើមរអើម ។ ចំ
ណង់មើដនដទៃ ដែលមិនជាប់ជាសាច់សាសោហិតនឹងភ្នែចនោះ មិន
ដឹងជាខ្ពើមយ៉ាងណាទៅ ។ ពួកជនតាលតែងស្រឡាញ់ចង់ចិត្ត ក្នុងរូប
កាយដែលឥតខ្វះសារ នៅពាក់ក្នុងតោរតេញដោយខ្លាកមាត់ ខ្លាសម្បារ
ខ្លាកនោម ខ្លាកន្លែក ខ្លាកលៃង លាមកចាស់ថ្មី សឹងតែយើញជាក់នឹង
ភ្នែក ។ បពិត្រព្រះមាតាបិតា ពាក្យដែលខ្ញុំម្ចាស់ក្រាបទូលមកនេះ ជាន
សេចក្តីថា ទុក្ខ ជាតុ អាយតនៈ ជាឋ្យសតលៃនសេចក្តីទុក្ខ លំបាក
វេទនា ។ រួបកាយនេះ ជាគ្រោងឆ្អឹងសាកសព គួរឲ្យស្អប់ខ្ពើមយ៉ាង
នេះទៅហើយ តើឲ្យខ្ញុំម្ចាស់ត្រូវការប្រាថ្នាឲ្យគេចូលដណ្តឹងខ្ញុំម្ចាស់ម្តេច
ជាន ។ ការលំបាកឈឺចាប់ ដោយលំពែងស្រួច ៣០០ ធ្លាក់មកមុតរូប
កាយ កាលថ្ងៃ កប់ដេញ ដោយហេតុតែប្រព្រឹត្តធម៌ ជាគ្រឿងធ្វើឲ្យ
អស់ទុក្ខ ការលំបាកឈឺចាប់នោះប្រសើរ ។ រីឯជន ឯកជាន ប្រតិបត្តិតាម
ពុទ្ធាវាទ ហើយជាន់សេចក្តីលំបាកដោយហេតុណាមួយ ការលំបាក
នោះ ជាហេតុឲ្យអស់ទុក្ខក្នុងសង្សារវដ្ត ។ សង្សារបស់ជនតាល ដែល
លំបាករឿយ ។ ជាសង្សារវែងឆ្ងាយ ។ ពួកសត្វដែលអន្ទោលចុះអន្ទោល
ឡើង ពីភពទៅខ្ពស់ ពីខ្ពស់ទៅភព ពីមនុស្សទៅទេវតា ពីទេវតា
មកសត្វតិរច្ឆាន ពីសត្វតិរច្ឆានទៅប្រេត អសុរកាយ នរក តែងនាំយក

តាំងខ្ញុំក្តាប់ជាមួយនៅផងជាដរាប ព្រោះកូនខ្ចីនោះ សេចក្តីសុខសាន្ត
គ្មានទេ ឯសេចក្តីសុខដ៏ក្រៃលែង មានតែកូនហានព្រះនិព្វាន ។ ដូចណា
គាត់ពុទ្ធសាសនា ទំព្យាយាមលះជាតិនឹងមរណៈបាន ដូចនោះឈ្មោះថា
បានដល់ព្រះនិព្វាន ។ បពិត្រព្រះមានគុណធ្ងន់ ខ្ញុំម្ចាស់សូមក្រាបបង្គំលា
នឹងចេញទៅបួសកូនថ្ងៃនេះហ៊ាយ ប្រយោជន៍អ្វីដោយគោតសម្បត្តិ ដែលជា
របស់ខ្ពុកស្មើកំហាកដែលគេត្រូវតែខ្ជាត់ចោល ។ ចំណែកខ្ញុំម្ចាស់ដ៏ឧត្តម
គ្មានត្រូវការនឹងគោតសម្បត្តិនោះទេ សូមព្រះគុណាទ្រង់ជ្រាប ។

ឯាលព្រះនាងសុមេធា ភរិយា កំពុងពណ៌នាជម្រាបត្រមាំង
ពួលាព្រះពុទ្ធគាថា កំស្រាប់តែព្រះបាទអនិកវត្ត ស្តេចទ្រង់ព្រះពុទ្ធ-
ដំណើរ ចូលមកដល់ច្រកសាខកូនព្រះបរមពុទ្ធកំង រថស់ព្រះបិតាព្រះ
នាង ដោយមានព្រះពុទ្ធបរិតារកំទេចព្រះ ។ ដើរជាក្បួនហែហមទ្រង់ ត្រម
តាំងគាន់ជង្គាយដ៏ប្រណិតវិចិត្រថ្លៃថ្លា ជាគ្រឿងបណ្ណាការគ្រប់ដៃ ដើម្បី
នឹងដណ្តឹងព្រះនាងសុមេធា ។ កូនភាលានោះ ព្រះនាងសុមេធា កំពុងគាន់
ព្រះខាន់គោគាត់ព្រះកេសា ដែលមានពណ៌ខ្មៅរលើប ស្អុតរាន់ រួច
ហើយបន្ទាប់ពីការប្រាសាទ តន់តែនក្នុងចំរើនឈានសមាបត្តិ ពិចារណា
នូវអនិច្ចសញ្ញា ។ តាប់ដួនព្រះបាទអនិកវត្ត ដែលព្រះអង្គស្តេចស្តាំ
ដោយគ្រឿងអលង្ការ វិចិត្រដោយមាសនឹងតែមណី ស្តេចចូលទៅជួប
នឹងព្រះនាងសុមេធា នៅខាងកូនប្រាសាទ ដោយព្រះដំណើរឬសាន់

ទ្រង់មានព្រះកដបន្ទូលអង្វរព្រះនាងថា ៖

នែនាងសុមេធា មានតក្តែជូរផង សូមនាងស្តាប់បង បងបាន
នាំគ្រឿងបណ្ណាការដ៏មានដំរៃ ចូលទៅដណ្តឹងព្រះនាង ដល់ព្រះកដ-
មាតាបិតានៃព្រះនាងហើយ ។ ទ្រង់ក្រាស់បញ្ជាឲ្យបងចូលមកនិយាយនឹង
ព្រះនាងផ្ទាល់ខ្លួន ។ ឥឡូវនេះប្អូនសំឡាញ់ពេញចិត្តបងអើយ រូបប្អូនមាន
ពន្លឺស្មើ មានលំអជូរផង ជាហេតុនាំឲ្យបងស្រឡាញ់ពេញចិត្តក្រៃលែង
ដូចឱ្យលាភដ៏ត្រៃគរអនៃអ្នកមានញើស ពុំនោះដូចទឹកដ៏ត្រៃគរអ នៃអ្នក
ស្រែកទឹក ។ បងមានចិត្តដោងដ៏ធំជ្រាលជ្រៅស្មុគស្មាញក្នុងរូបប្អូន មិនអាចនឹង
ពាក្យចិត្តដែលលង់ស៊ប់នោះ ឲ្យត្រឡប់វិញបានទេ ដូចត្រីជាប់សន្ទូច
ឬដូចដំរីចុះប្រេង មិនអាចកន្ទេរ ។ ហេតុនោះ សូមប្អូនដួយលត់
សេចក្តីក្រហល់ក្រហាយនៃបង ដូចត្រូវភោគជាតំណាំឲ្យអ្នកជម្ងឺ ឬដូចគេ
ឲ្យគោជនដល់អ្នកស្រេកឃ្លាន ពុំនោះសោតដូចគេយកទឹកលត់ភ្លើង ។
សូមនាងព្រមទទួលធ្វើជាភរិយាបង បងនឹងអភិសេកប្អូនជាអគ្គមហេសី
ធំលើសស្តេចតំាង ៩០០ នាក់ ឲ្យមានស្រីជាបរិវារចាប់យកបំរើប្អូនធ្វើស្តាំ ។
កដអាណាចក្រ របស់បងធំណាស់ ហើយសម្បូរដោយភោគទ្រព្យនឹង
ឥស្សរិយយស ដែលជាហេតុឲ្យប្អូនបានសេចក្តីសុខសម្រាន្ត ។ កដ-
សម្បត្តិ បងនឹងប្រគល់ផ្តាច់ឲ្យប្អូន សូមនាងប្រើប្រាស់សម្បត្តិតំាងនោះ
តាមប្រាថ្នាចុះ ។ សូមប្អូនសង្រ្គោះស្រោចស្រងឹខ្លួនបងឲ្យរួចពីកំុទ្ធ

ផង សង្គ្រោះព្រះពុទ្ធសាសនាជាតិភាសាបួន ឲ្យរួចផុតពីក្តីវិនាស ដែលព្រះអង្គ
តែងព្រះរាជយោគសោកាខ្លាំងផង ។

គ្រានោះ ព្រះពុទ្ធឥសី សុមេធា ក្រាបបង្គំទូលតបថា បពិត្រ
ជាទេវនិករត្ន សូមទ្រង់ព្រះមេត្តាប្រោសអត់ឱនទោសខ្ញុំម្ចាស់ ។ ក
ក្រាបបង្គំទូលទ្រង់ឲ្យជ្រាប ។ សូមមហាបពិត្រទ្រង់ជ្រាបថាខ្ញុំម្ច
ពុំជាន់ស្អប់ទ្រង់ទេ តែរូបខ្ញុំម្ចាស់ជាកាមរបស់ទ្រង់ ដែលទ្រង់ត្រូវការ
ជាន់ទៅរួមរសតម្រេក ហេតុនេះសូមទ្រង់តិចារណាឲ្យឃើញគុណ
ទោសរបស់កាម ឲ្យជាន់សព្វគ្រប់សិន ។ ទ្រង់តែងជាន់ទ្រង់ជ្រាប
គុណប្រយោជន៍របស់កាមហ៊ើយ ទើបទ្រង់ពេញព្រះពុទ្ធហឫទ័យស្ងួ
កាម តែត្រង់ទោសរបស់កាមប្រហែលទ្រង់ពុំជាន់យកត្រង់ចិត្តតិចារ
ឲ្យជិតដល់ទេ ហេតុនេះ សូមទ្រង់ព្រះសណ្តាប់ ខ្ញុំម្ចាស់នឹងថ្ង
សេចក្តីឲ្យទ្រង់ជាន់ជ្រាប ដូចតទៅនេះ ៖

ព្រះបុពកដ៏ធំពុទ្ធ ព្រះនាមមង្គាតុ ទ្រង់ជាស្តេចមហាចក្រ
ធំត្រួតត្រាលើទ្វីបចាំងបួន ទ្រង់ប្រសើរផុតជាងពួកជនអ្នកបរិភោគកា-
ទ្រង់មិនឆ្អែតនឹងកាម ទ្រង់ទិវង្គតទៅ ចាំងមិនត្រប់ត្រាន់សេចក្តីប្រាថ្ន
ភ្លៀងបង្អុរចុះខ្លួរតែ ៧ ប្រការ ត្រប់ទិសចាំងដប់ ស្រោចស្រប់ឲ្យ
ជនណា រតនវត្ថុចាំងនោះក៏នៅតែមិនល្មម មិនឆ្អែតចិត្តនៃជនខ្លះ
ជនតែងស្អប់ទៅចាំងមិនឆ្អែតកាម ។ ពួកជនដែលចេះតែត្រេកត្រអ

ធំដ៏តាមយ៉ាងនេះ ព្រោះមិនបានយល់ច្បាស់ថាតាមជាសត្រូវឲ្យទោសជល់ខ្លួន តាមពុកដូចជាសស្ត្រាវុធ ពុកដូចជាឈើស្រួច ពុកដូចជាសត្វមានពិស ឬពុកដូចជាគប់ភ្លើង ថ្ងៃណាមួយវានឹងឲ្យពុកដល់ខ្លួន ។ តាមនេះ ដែលឲ្យផលជាសុខ កំសេចក្តីសុខនោះមានប្រមាណតិចតួច ហើយមិនខៀងខាត់ មិនបិតវេរយើនយូរទេ ឯដែលប្រកួយឲ្យផលជាទុក្ខវិញ សេចក្តីទុក្ខនោះមានអំណាចខ្លាំងក្លាណាស់ អាចដុតបាឫទ័យសត្វឲ្យក្តៅក្រហល់ក្រហាយតឹងជាខ្លាំង បណ្តាលឲ្យទៅជាឈឺចាប់ស្ងាប់ខ្លួនក៏មាន ដឹកនាំចិត្តឲ្យប្រព្រឹត្តកំហុស មានទោសជាទម្ងន់ក៏មាន ។ មួយទៀត ជនអ្នកបរិភោគតាម ពុកដូចគេបរិភោគផ្លែឈើតុល ពុកដូចសត្វតាំងដុំសាច់ដែលសត្វឯទៀតត្រូវការដែរ ពុកដូចគេដកយល់សប្តីបានតំណប់ ពុកដូចជាខ្លែវបស់គេមកប្រើប្រាស់ ពុកដូចជាពេគម្ហូមួយដែលគេតក្នងខ្លួន ឬពុកដូចជាគេចុះទៅក្នងរណ្តៅពេញដោយរងើកភ្លើង ព្រោះជនអ្នកបរិភោគតាមត្រូវតែបានទទួលសេចក្តីទុក្ខ សេចក្តីវិនាសគ្រោះកម្ចាក្រាកជ ។ ពិត្រព្រះបមាល ហេតុនេះ សូមទ្រង់កុំត្រេកត្រអាលនឹងតាម សូមទ្រង់ស្តេចលែត្រឡប់ទៅព្រះពជនិវេសន៍ត្រង់អគ្គីវិញចុះ ព្រោះខ្ញុំម្ចាស់តុំមានត្រូវការនឹងតាមទេ ឬគួលត្រូវភ្លើងនេះក្សាល ប្រញាប់លត់ភ្លើងនោះ យ៉ាងណាខ្ញុំម្ចាស់ដែលមានជាមណោះតាមជាប់ជាខ្លួន ក៏ត្រូវតែប្រញាប់ចេញបួសដើម្បីប្រឹងកំចាត់ជាមណោះនោះកុំយ៉ាងនោះឯង ។ ក្នុងរឿងនេះ អ្នក

ណាមួយនឹងមកជួយកំចាត់ដកមរណៈជាដំណួសខ្ញុំម្ចាស់ ពុំបាន១ឡើយ ។

បន្ទាប់ពីនោះមក ព្រះនាងសុមេធា ជាទេវតាទៅឃើញព្រះពុទ្ធមាតាបិតា ស្តេចយាងមកទ្រង់ព្រះកន្សែងសោកា ទៀបទ្វារប្រាសាទ ក៏បានក្រាបទូលសេចក្តីដូចតទៅនេះ ៖

សូមព្រះពុទ្ធមាតាបិតាទ្រង់ជ្រាប សង្ឃរបស់បុគ្គល ដែលយំសោកស្តាយ ព្រោះហេតុស្លាប់ឬក្រាត់ច្រាសចាកសត្វនឹងសង្ខារដែលស្រឡាញ់គេញាប់ចិត្ត ដាសង្ឃរវែងឆ្ងាយណាស់ ។ សូមទ្រង់នឹកគន្លះមើលខ្ញុំទឹកភ្នែក ទឹកដង្ហើរនឹងឈាម ក្នុងកាលដែលទ្រង់អាឡោលទៅមកក្នុងកាលវិដ្ឋសង្ឃរ ដែលមានជំរៅនឹងចំនួនស្មើមហាសមុទ្រទាំងបួន ។ សូមទ្រង់នឹកមើលខ្ញុំតំនរឆ្អឹងរបស់ទ្រង់ ក្នុងកប្បមួយ ។ ដែលមានកំពស់នឹងចំហាស្មើនឹងភ្នំវេបុល្ល ។ សូមទ្រង់នឹកមើលខ្ញុំមាតាបិតារបស់ទ្រង់ ក្នុងសង្ឃរវដ្ត ដែលមានចំនួនច្រើនជាន់ដុំដំ ដែលរុះរយកដែនដីទាំងជម្ពូទ្វីបមកលាញ់ប៉ុន ។ គ្រាប់ក្រៃចុង ។ សូមទ្រង់នឹកមើលខ្ញុំការក្រចាននឹងភត្តភាពជាមនុស្ស ដូចជាការក្រនៃអណ្តើកខ្វាក់ ដែលហែលក្នុងមហាសមុទ្រហើយនៅឆ្ងាយអំពីទឹកដែលអណ្តែតក្នុងមហាសមុទ្រដែរ អណ្តើកខ្វាក់នោះ មិនងាយហែលទៅប្រកក្បាលខ្លួនក្នុងប្រហោងនឹមនោះឡើយ ព្រោះហេតុខ្សល់នឹងរលកបក់បោកច្រានទៅកាន់ទិសផ្សេង ។ គ្នា ។ សូមទ្រង់ពិចារណាឱ្យឃើញច្បាស់ថា រូបកាយនេះ មានទោសច្រើនប្រការ ជារបស់ឥតខ្លឹមសារ ដូចគ្នានឹងភាពុះពេក ជារបស់គ្មានទៀងពាត់បិតបៀរយើងឃ្លា

ទេ កើតមកគ្រាន់តែឲ្យចំរើនវៃព្រស្នូសានប៉ុណ្ណោះ ។ សូមទ្រង់នឹក
មើល នូវសេចក្តីខ្ពក់ក្តួលក្តៅក្រហាយផ្សា របស់សត្វដែលក្នាត់ខ្លួនទៅកើត
ក្នុងនិរក ។ សូមទ្រង់នឹកមើល នូវការឲ្យព្រួយលំបាកក្នុងការចិញ្ចឹម
ជីវិត ពល់ជាតិកំណើត ។ សូមទ្រង់ធ្វើដំណើរចិត្តទៅកន្លងអាយសង្ខតធម៌
តាមតុល្យភាពវិញ ។ សូមទ្រង់ពិចារណាមើលចុះ កាលបើសថជាថ្នាំ
ពូកែស័ក្តិសិទ្ធិមានហើយ ភេតដែលមានក្នុងខ្លួន ម្នាលប្រយោជន៍អ្វី ដែល
ឱសុធឲ្យមានតទៅទៀត ។ កាលបើអមតធម៌ គឺធម៌មិនស្លាប់ មាន
ហើយ រូបកាយជារបស់ត្រូវស្លាប់ត្រូវរលាំទុក្ខក្តៅក្រហាយ មានប្រយោជន៍
អ្វីដល់ទ្រង់ ។ កាលបើនេក្ខម្មធម៌ ជាធម៌ឥតសត្រូវ មានហើយ តាម
ជារបស់នាំឲ្យកើតសត្រូវ មានប្រយោជន៍អ្វីដល់ទ្រង់ ។ កាលបើព្រះ
និព្វាន ជាធម្មជាតិគ្មានគ្រឿងចាក់ស្រេះ មានហើយ តាមជាចំណង
ចងសត្វឲ្យជាប់នឹងកន្លែងក្នុងទុក្ខ មានប្រយោជន៍អ្វីដល់ទ្រង់ ។ កាលបើព្រះ
និព្វានជាគុណជាតមិនចេះចាស់មានហើយ តាមជារបស់ចាស់ត្រូវឈឺស្លាប់
មានប្រយោជន៍អ្វីដល់ទ្រង់ ។ មែនពិត ព្រះនិព្វានមិនចាស់ មិនស្លាប់ មិន
សោក មិនមានសត្រូវ មិនជង្អៀតចង្អល់ មិនមានភ័យ មិនមានក្តៅ
ក្រហាយទេ ព្រះនិព្វាននោះ គ្មានលំគាំលាយទេ គេគប្បីបានហួត
មកដល់សត្វថ្ងៃនេះ ។ បុគ្គលណា មានសេចក្តីព្យាយាមដើរតាមអដ្ឋង្គិក-
មគ្គ គឺប្រឹងដើរតាមផ្លូវប្រកបដោយអង្គ ៨ បុគ្គលនោះអាច ទៅដល់

ព្រះនិព្វានជាឋានបរមសុខបាន ។

ហេតុនេះ សូមទ្រង់កុំលះបង់ចោលនូវសេចក្តីសុខដ៏ធំទូលាយ ទៅ
រកយកនូវសេចក្តីសុខស្តួចស្តើងតិចតួចតាមឡើយ បំណាច់បានមកកើត
ជាអង្គមនុស្សជាតិ ។ សូមប្រយ័ត្នព្រះអង្គកុំឲ្យមានសេចក្តីស្តាយក្រោយ
ដូចត្រីជាប់សន្ទូច ។ បើទ្រង់ប្រកបខ្ជិលក្នុងតាម ទ្រង់នឹងសោយទុក្ខ
ទោមនស្សក៏បាប់មិនអស់ ប្រមាណមិនបាន ។ ព្រោះហេតុនោះ សូម
ទ្រង់លះកាត់តាមទាំងឡាយចេញ ។

ព្រះនាងសុមេធា កាលបានពណ៌នាធម៌ រំលឹកព្រះស្មោះតើនៃព្រះពុទ្ធ-
មាតាបិតា ទ្រង់ព្រះបាទអនិរុត្តយ៉ាងនេះហើយ ក៏បោះសត់ទាំងសំណុំ
ដែលកាន់នៅត្រង់ហស្ត ចោលទៅលើផ្ទៃផែនដី ។ ព្រះមហាសត្វត្រាំង
ឲ្យ ព្រះអង្គ ទ្រង់បានធ្លាស្បែរយបាតការគានតិងក្នុងព្រះទ្រូង លែងសោយ
សោក ព្រោះបានស្តាប់ធម៌ដែលព្រះនាងពណ៌នានោះ ។

ក្នុងខណៈនោះ ព្រះបាទអនិរុត្ត ទ្រង់ប្រណម្យអញ្ជលីទូលអង្វរព្រះ
ពុទ្ធមាតាបិតានៃព្រះនាងសុមេធាថា សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស
អនុញ្ញាតបើកនាងសុមេធា ឲ្យបួសតាមបំណងចុះ ។ ព្រះបាទសាក្យ-
ពុទ្ធនឹងព្រះពុទ្ធទេពី ទ្រង់បានទទួលយល់ព្រម ព្រះពុទ្ធានុញ្ញាតឲ្យព្រះ
ពុទ្ធធីតាបួសតាមប្រាថ្នា ដោយមានព្រះបន្ទូលថា ធីតាសំឡាញ់ឥតុក
ឥឡូវនេះ ឥតុកបានធូរស្រាលក្នុងចិត្តហើយ បំណងឥតុកដែលចង់

ឱ្យកូនស្រីមានប្តីក្តី ចង់ឱ្យគ្រប់គ្រងរាជសម្បត្តិកន្លងតែទៅនឹង ៦ ក្តី កំសោយ
ចេញពីចិត្តផុតអស់ហើយ ដោយការបាននាប់ធម៌បេះនាង ផុតក
បានភ្លឺច្បាស់ក្នុងចិត្តថា ការប្រគល់រាជ្យឱ្យ ទុកដូចប្រគល់គំនរក្តីឱ្យ
ដល់កូនស្រីវិញទេ ដូច្នេះ ចូរនាងទៅបួស ក្នុងពុទ្ធសាសនា តាម
តេញប្រាថ្នានាង ដើម្បីធ្វើឱ្យអស់ទុក្ខចុះ ។

ព្រះនាងសុមេធា កដកញ្ញា កាលបានព្រះរាជានុញ្ញាតអំពីព្រះមាតា
បិតាហើយ ក៏បានចេញទៅបួស ហើយបានចំរើនក្សន្តិធម៌ បាន
សម្រេចអភិញ្ញា ៦ ព្រមទាំងបានលុះអរហត្តផល ដល់នូវគាថាជាព្រះ
ឱណាស្រេច ១ អង្គ ។ ក្នុងកាលដែនធឹងបានឱ្យភាន ព្រះសុមេធាថេរី បាន
ប្រកាសនូវបុព្វចរិត គឺអំពើកុសលដែលនាងបានសាងមកក្នុងកន្លងមុនថា ៖

កាលព្រះមានព្រះភាគ ព្រះនាមកោនាគមនៈ ទ្រង់បានគ្រាស់ឡើង
ក្នុងលោក ខ្ញុំសុមេធា ធីងសំឡាញ់ខ្ញុំពីនោក ឈ្មោះនាងធនញ្ជានី ១
ឈ្មោះនាងរេមា ១ ទាំង ៣ នាក់ មានសទ្ធាជ្រះថ្លាក្នុងពុទ្ធសាសនា
បានរួបរួមធនធាន ចំណាយកសាងព្រះវិហារថ្វាយមួយ ក្នុងអាចមនៃសង្ឃ
ថ្វាយដល់ព្រះសម្មាសម្ពុទ្ធព្រះនាមកោនាគមនៈ ។ ដោយអំណាចអានិ-
សង្សនៃវិហារទាននេះ យើងទាំង ៣ នាក់ បានទៅកើតក្នុងឋានសួគ៌
ទេវលោក មួយម៉ឺនដង បានទៅកើតជាមនុស្សក្នុងត្រកូលខ្ពង់ខ្ពស់ ក៏
កប់ម៉ឺនដងដូចគ្នា ។ កាលយើងទៅកើតជាទេវតាក៏ជាទេវតាមានឫទ្ធិ

ធំ មានអានុភាពធំជាងនេះទៅតាំងពួង កាលយើងមកកើតជាមនុស្សកំពុងត្រូវសម្លាប់ដោយសេចក្តីសុខជាងជនពាលពួង ។ ចំណែកខ្លួនខ្ញុំសុមេធានេះ ឋានកើតជាស្រីកែវ ជាអគ្គមហេសីនៃស្តេចចក្រ មានរតនៈ ៧ ប្រការ តំណាក់ច្រើនជាតិ ។ អានិសង្សនៃវិហារទានរបស់ខ្ញុំនោះ ជាហេតុជាប្រតិភជាឫសគល់ នៃព្រះនិព្វាន ដែលខ្ញុំតដូចជាស្ពានប្តូរនាវនាំចម្លងខ្ញុំ ឲ្យមកដល់ឋានៈជាអ្នកវាសនាអស់តាលេស ហើយនឹងបរិនិព្វាន ក្នុងថ្ងៃនេះឯង ។

ក្នុងប្រវត្តិព្រះសុមេធាថេរ
មានសេចក្តីលៃបំភ្លឺពីពោសកាម
ឲ្យយើញច្បាស់ជារបស់នាំអាមណាម
នាំរហាមកើតទុក្ខព្រួយគ្មានស្រាកស្រាន្ត ។
តុអនិច្ចាមនុស្សយើងប្តូជ្ជន
កម្មក្រាសធ្ងន់ស្ទើត្រាំធន់តាមកាមប្រាន
ពោះកាមកាចអាចផ្តល់ទុក្ខរំជាលមាន
តែមិនចានយកព្រះធម៌មកជាគ់ខ្លួន ។
បើធ្វើចិត្តឲ្យបានដូចសុមេធា
នោះមុខជានឹងបានសុខដ៏សមសួន
សមជាអ្នកកាន់ពុទ្ធសាស្ត្រហ៊ានខ្ជាប់ខ្ជួន
អាចរើខ្លួនរួចផុតទុក្ខតាំងពួងអើយ ! ។

សុរពជាតក

(តមក)

លោក ជិង-រិង បកប្រែពីសាស្ត្រសំស្ក្រឹត

រីឯទុក្ខដ៏ជាធំលើសអស់ទុក្ខទាំងពួងក្នុងលោកិយនេះ តើទុក្ខដូចម្តេច ? ។

សោ តោ តោ រីឯក្អែកនោះឆ្លើយថា ក្អែកណាដែលបុគ្គលកាត់ស្លាប កាត់កន្ទុយហើយ ក្អែកនោះ ទទឹងដល់ខ្លួនសេចក្តីទុក្ខលើសអស់ទុក្ខទាំងពួងហោង ។

ក្តាមឆ្លើយថា អើក្អែក! អដាឯន្តោ អ្នកពុំដឹងអ្វីឡើយ អញទទឹងដណ្តឹងប្រស្នាជាគម្រប់តិរតៅទៀត; អញ្ញោហិ សុទំ វ. តមោ ។ល។ ភូញ្ជ មេ ឧសេ្សហិ បញ្ហន្តិ សុខអ្វីទាំងអស់ ក្នុងលោកនេះ ទទឹងបរលោក ? ចូរអ្នកដោះស្រាយខ្លួវប្រស្នានេះ ។

ក្អែកឆ្លើយថា បើបុគ្គលណា បានបរិភោគសំឡាក្លាដែលបុគ្គលរៀបណ្តាប់តាត់តែងស្អុះហើយ ដកបដល់ឆ្អែតស្កប់ស្កល់, ដូច្នេះឈ្មោះថា ជាសុខលើសសុខទាំងពួង ។

តំ សុត្វា កក្កដកោ ក្តាមបានស្តាប់ពាក្យនោះហើយ ឆ្លើយថា ម្នាលក្អែក! អ្នកពុំដឹងឡើយ អ្នកចេះតែស៊ីខ្លួន, ដូច្នោះ យើងទទឹងដណ្តឹងប្រស្នាជាគំរប់ ៣ តៅទៀត; ម្នាលក្អែក! ថាបើឃ្លានបាន

បរិភោគដល់ប៉ុន្មានវាគ្គ តុំអាចនឹងចំបាត់ឃ្លានបាន តើអ្នកឃើញថា ឃ្លានអ្វី ?, ជូរអ្នកដោះស្រាយប្រាប់យើងផង ។

ព្រឹកឆ្លើយថា យោ អាបាវុប្បន្នេ បើអ្នកណាមួយ តត់អាហារតុំបាន លុះឃើញគេបរិភោគ ក៏មានសេចក្តីស្រេកឃ្លានតើតឡើង នេះឈ្មោះថា អតិជាតៈ ។

ក្តាមឆ្លើយថា ម្នាលព្រឹក ! អ្នកដឹងតែខាងលោភម្យ៉ាង តុំដឹងប្រស្នានេះ ឡើយ យើងនឹងសួរប្រស្នាជាគំរប់ ៤ តទៅទៀត, ម្នាលព្រឹក ! រស្មីអ្វី ស្អុលើសរស្មីតាំងពួង ក្នុងលោកិយ ទើបបរលោក ? ។

ព្រឹកដោះស្រាយថា រស្មីដែលហូរចេញពីក្នុងព្រះអាទិត្យ ក្តីព្រោងព្រាតភ្លេញតាំងអាកាស មានអំពូនឹងពពកច្រាសចេញអស់ ហៅថា រស្មីស្អុលើសរស្មីតាំងពួង ។

ក្តាមស្តាប់ហើយឆ្លើយថា អើព្រឹក ! អ្នកឥតដឹងថា គួរតុំគួរទេ ដូច្នេះជូរដោះសេចក្តីប្រស្នាជាគំរប់ ៥ តទៅទៀត; ម្នាលព្រឹក ! អាក្រក់អ្វីលើសពីសម្បុរសៅហ្មងទៅទៀត ក្នុងលោកិយ ទើបបរលោក ? ។

ព្រឹកឆ្លើយថា សត្វណាមួយ អត់អាហារតុំបានច្បាយទឹកបរិភោគសម្បុរមែនសៅហ្មង ស្តាំងស្តួមអាក្រក់ណាស់ហោង ។

ក្តាមស្តាប់ហើយនិយាយថា ម្នាលព្រឹក! អ្នកតុំដឹងសេចក្តីពាក់ព្រៀ

គុណខ្មោចទេ អ្នកថ្មឲ្យត្រែរួចពីមាត់ ដូច្នោះ យើងនឹងដណ្តើងប្រស្នាជាគំរប់ ៦ តទៅទៀត; ម្នាលក្អែក! អ្វីធំ ក្រៃលែងជាងលោកិយនឹងបរលោក ? ។

ក្អែកឆ្លើយថា ថ្មឯណាពុំមានខ្នែងតាន់ល្អ នេះឈ្មោះថា ធំលើសបេស់ពាំនឹងពួន ។

ក្តាមស្រដីថា អ្នកឯងពុំដឹងថា អ្វីជាប្រយោជន៍ អ្វីមិនមែនប្រយោជន៍ទេឬ ដូច្នេះចូរអ្នកដោះប្រស្នាទី ៧ តទៅទៀត; ម្នាលក្អែក! ខ្ពស់អ្វីក្រៃលែងខ្ពស់ កន្លងផុតលោក នឹងបរលោក ?, ចូរអ្នកប្រាប់យើងផង ។

ក្អែកឆ្លើយថា អាកាសខ្ពស់លើសអ្វីទាំងអស់ កន្លងផុតលោក នឹងបរលោកនេះ គ្មានអ្វីខ្ពស់ជាងអាកាសទេឬ ។

ក្តាមនិយាយថា ខ្យល! អ្នកពុំអាចដោះស្រាយបានទេឬ ដូច្នោះអ្នកត្រូវដោះស្រាយប្រស្នាទី ៨ តទៅទៀត; ម្នាលក្អែក! អ្វីក្តៅ ក្រៃលែងក្តៅ កន្លងផុតលោក នឹងបរលោក ? ។

ក្អែកឆ្លើយថា ភ្លើងជម្ងាក្តៅពុំស្មើនឹងភ្លើងរកេ ភ្លើងរកេក៏ក្តៅពុំស្មើនឹងភ្លើងកល្ប ភ្លើងកល្បនេះឈ្មោះថា អតិឧណ្ហាៈ ហោង ។

ក្តាមឆ្លើយថា អ្នកស្រដីនេះ ពុំត្រូវទេ ចូរឆ្លើយប្រស្នាទី ៩ តទៅ; ម្នាលក្អែក! អ្វីត្រជាក់ក្រៃលែងត្រជាក់កន្លងផុតលោកនេះ នឹងលោកខាងមុខ ? ។

ក្អែកឆ្លើយថា ខឹកកន្ធឹកត្រជាក់លើសអ្វីទាំងអស់ក្នុងលោកនេះ ខ្ញុំឯងលោកខាងមុខ ។

ក្លាមប្រាប់ថា អ្នកឯងនោតល្ងង់ខ្លៅទាំងណាស់ យើងខុតអ្នកឯងជាអ្នកឥតប្រាថ្នាជ្រុល ឆ្លើយប្រស្នាយើងពុំរួចឡើយ ដូច្នោះចូរឆ្លើយប្រស្នារបស់យើងជាគំរប់ ១០ តទៅ; ម្ចាស់ក្អែក! អ្វីស្អិតស្អុយលើសវត្ថុដទៃ ក្នុងឥឡូកលោក ខ្ញុំឯងលោក? ។

ក្អែកឆ្លើយថា វត្ថុដែលស្អិតស្អុយលើសអ្វីទាំងអស់ គឺឃ្យល់ ។

ក្លាមឆ្លើយថា អ្នកជាអ្នកស្រាយប្រស្នារបស់យើង ពុំត្រូវ ១ ឡើយ អបញ្ញត្តិ អ្នកឯងជាអ្នកឥតប្រាថ្នាជ្រុល ឧទ្ធោ ល្ងង់ខ្លៅ ឥហាវញ្ចោ ប្រសប់តែខាងបោកបញ្ឆោតគេ ឯសេចក្តីពាក់ព្រៀពពុំដឹងសោះ កេដិ តយា កម្មិ សច្ចមិ យើងខ្ញុំងាកមកជាមួយអ្នកដូចដើមវិញ ដូច្នោះយើងពុំទៅឡើយ ។

ក្អែកនិយាថា ម្ចាស់សំឡាញ់! ប្រស្នាដែលសំឡាញ់សួរនេះ គួរតែពុំគួរតើ អញ្ជាំ បុច្ឆាហិ ចូរអ្នកសួរប្រស្នាឯទៀតចុះ យើងខ្ញុំឯងនឹងដោះស្រាយឲ្យត្រូវ ។

ក្លាមឆ្លើយថា ដើរ! បើដូច្នោះ អ្នកចាំឆ្លើយនូវប្រស្នាទី ១១ តទៅ; តមោ លោកេ ។ល។ វិសប្បដ្ឋហិ មម បញ្ហាន្តិ ម្ចាស់ក្អែក! ខ្ញុំតែអ្វីក្នុងលោកនេះ ព្រមទាំងលោកខាងមុខ លើសលែងជាង

ឆន្ទិតត្ថាំងអស់ ដែលហៅថា អតិត្តមៈ?, ចូរអ្នកធ្វើយប្រស្នានេះច្រាប់យើង ។

វត្តិយំ អតិអច្ឆរោ ។ល។ អយំ អតិតមោ ជាម ភៃក្តាម! ឆន្ទិតក្នុងពាក្យ មានតភាគអត្ថអច្ឆរា ពុំមានស្ទើព្រះចន្ទនឹងផ្កាយ ឈ្មោះថា អតិតមៈ ឆន្ទិតក្រៃលែងជាងឆន្ទិតត្ថាំងពួង ។

ក្តាមស្តាប់ហើយពោលថា អ្នកឯងពុំដឹងអ្វីទេ ដូច្នេះយើងនឹងដណ្តឹងប្រស្នាជាគំរប់ ១២ តទៅទៀត; ឧទស្មឹ លោកេ សនេវ-លោកេ ។ល។ អតិរុច្ចតិ សភាពអ្វីរឿងក្នុងលោកនេះ ព្រមទាំងទេវលោក? ។ ល ។

ភែ្លកធ្វើយថា ម្នាលក្តាម! ព្រះអាទិត្យរឿងក្នុងពេលថ្ងៃ ព្រះចន្ទរឿងក្នុងពេលកត្រី របស់ទាំងពីរនេះរុងរឿងជាងអ្វីទាំងអស់ ។

ក្តាមស្តាប់ហើយថា ម្នាលភែ្លក! អ្នកនេះជាអ្នកអន្ធពាលមែន ពុំដឹងអ្វីឡើយ, ដូច្នេះចូរធ្វើយប្រស្នាខ្ញុំ ១៧ តទៅទៀត; ម្នាលភែ្លក! ភ្នំទឹមក្តី ភ្នំសម្បកក្តី ភ្នំស្នឹកក្តី ឬក៏ផ្ទៃទឹងភ្នក់ក្តី តើភ្នំអ្វីក្រអូបជាងភ្នំគន្ធជាតនេះ? ។

ភែ្លកធ្វើយថា ម្នាលក្តាម! បណ្តាគន្ធជាតទាំងអស់ មានសម្បកឈើ ទឹមឈើជាដើម ពុំស្ទើនឹងភ្នំសាច់ជាតម្រេកចិត្តសត្វទាំងឡាយឡើយ ព្រោះភ្នំនេះ ក្រអូបលើសលែងភ្នំទាំងពួង ។

ក្តាមឆ្លើយថា អ្នកឯងដោះប្រស្នានេះ ពុំត្រូវទេ អ្នកឯងដឹងតែខាងស៊ី; ទើបក្តាមសួរប្រស្នាទី ១៤ តទៅទៀតថា កូនអ្វីស្អុយជាងគេក្នុងលោកនេះ ? ។

ក្អែកឆ្លើយថា លាមកមនុស្សស្អុយជាងគេក្នុងលោកនេះ ។

ក្តាមសួរប្រស្នាទី ១៥ តទៅទៀតថា អ្វីខ្ជាំងជាងគេក្នុងលោក ។

ក្អែកឆ្លើយថា ព្រះនាគយណ៍ខ្ជាំងជាងគេក្នុងលោក ។

ក្តាមតោលថា ម្នាលក្អែក! អ្នកឯងថា ព្រះនាគយណ៍មានកម្លាំងច្រើនោះ ពុំត្រូវឡើយ អ្នកនេះល្ងង់អ្វីមាលក្បាយ ចេះតែខាងស៊ីទេ, ទើបក្តាមសួរប្រស្នាទី ១៦ តទៅទៀតថា អ្វីឆ្ងាយជាងគេ ក្នុងលោកនេះ ? ។

ក្អែកឆ្លើយថា ចក្រវាលឆ្ងាយលើសអ្វីទាំងអស់ សត្វបក្សីបក្សាហើរទៅពុំដល់ឡើយ ។

តំ សុត្វា តកក្កដកោ ក្តាមស្តាប់ពាក្យនោះហើយ និយាយថា ឆេះ តុំ ជាឆាសិ អ្នកឯងពុំដឹងអ្វីទេ ទើបក្តាមសួរប្រស្នាទី ១៧ តទៅទៀតវិញ អ្វីហ៊ាសជាងគេក្នុងលោកនេះ ? ។

ក្អែកឆ្លើយថា ខ្យល់ត្បូរសង្ឃរហ៊ាសជាងអ្វីទាំងអស់ ។

ក្តាមសួរប្រស្នាទី ១៨ តទៅទៀតថា អ្វីប្រសើរជាងគេក្នុងលោកនេះ?

ក្អែកឆ្លើយថា ព្រះឥន្ទ្រាធិរាជប្រសើរជាងគេទាំងអស់ ។

ក្តាមស្តាប់ហើយនិយាយថា ម្នាលក្អែក! អ្នកឯងពុំដឹងអ្វីទាំងអស់ ជាន់តែខាងចោកឋភ្លោតគេស៊ី ដូច្នោះ ចូរធ្វើយប្រស្នាទី១៩ តទៅទៀត; ម្នាលក្អែក! ទឹមអ្វីប្រសើរលើសទឹមដរែ? ។

ក្អែកធ្វើយថា កុំមានទឹមលើសអ្វីដរែទាំងអស់ ព្រោះឲ្យលប់ចាក់មកគ្រឹ ភ្លើងរៃត្រឹ ពុំអាចធ្វើកុំឲ្យរៃនាសបានឡើយ ។

ក្តាមធ្វើយថា ពុំត្រូវទេ, ចូរធ្វើយប្រស្នាទី ២០ តទៅទៀត, ម្នាលក្អែក! រសអ្វីប្រសើរជាងគេទាំងអស់? ។

ក្អែកធ្វើយថា រសបាយការសាលី ទឹងសាច់ ប្រសើរជាងរសទាំងអស់ ។

ក្តាមបានស្តាប់ហើយ តិះដៀលក្អែកថា ឆាឆ អក្ខរាលម្នាលក្អែកអន្ធពាល! អ្នកឯងជាអ្នកអប្បវត្តប្រាជ្ញា ឧក្ខដាតុឆោលល្ងង់ភ្លៅណាស់ ដេឆោ វត ប្រសប់តែខាងស៊ី វាញ្ញតក្ខសលោ ឈ្លាសវៃតែខាងចោកឋភ្លោតអ្នកដរែ ដោះស្រាយប្រស្នាពុំត្រូវ, ន តយា តមិសព្វមិ យើងទឹងមិនភ្លៅជាមួយអ្នកឡើយ តុំ ឯវ តុច្ឆាហិ ចូរអ្នកភ្លៅតែម្នាក់ឯងចុះ ។

ក្អែកឮក្តាមតិះដៀលដូច្នោះ ក៏ស្រដីថា ឆាឆ្ក ម្នាលក្តាម! ប្រស្នានេះ យើងពុំដឹងកំពិតមែន មយា សហាយា ប៉ុន្តែ ខ្ញុំមានសំឡាញ់ជាច្រើន គេមានប្រាជ្ញា វិចក្ខណសាលា ប្រសប់

ភានសំដី ចូរអ្នកទៅជាមួយខ្ញុំដែរយើង។ ខ្ញុំនាំអ្នកទៅ តរៈ បញ្ញាសុទ្ធ
អត្តំ ជាឯសុទ្ធមិ យើងសោតកំចង់ដឹងប្រស្នារបស់អ្នកណាស់ដែរ ។
ទើបក្តាមពោលថា បើអ្នកស្រដីពិតមែន យើងនឹងទៅជាមួយអ្នកដែរ ។
ក្អែកស្តាប់ហើយ ត្រេកអរឥតឧបមាដោយគំនិតថា បើក្តាមនេះទៅ
ជាមួយអញ ។ ខ្ញុំនាំទៅកាន់សំណាក់របស់សំឡាញ់អញ លុះដល់ខ្ញុំង
ប្រស្នារួចហើយ នាំវាទៅឯស្រះធំកន្លែងព្រៃ រួចនាំទៅកាន់សំបុកអញ។
ខ្ញុំនឹងហែកវាស៊ីជាអាហារ ។ ឯក្តាមកំដណ្តើងទៅក្អែកថា សំឡាញ់របស់
អ្នកឈ្មោះអ្វីខ្លះ? ។ ក្អែកប្រាប់ថា ខន្ធាយ ១, ខាយព្រាន ១, ក្អែក ១
ស្វា ១, ខ្លាធំ ១, កំន្ទុរ ១, ខេត្តា ១ ។ ក្តាមសួរថា បើយើងទៅជាមួយ
អ្នក តើទៅដោយវិធីដូចម្តេច? បើអ្នកហើរទៅដោយស្លាប យើងដើរដោយ
ដៃ ។ ក្អែកប្រាប់ថា យើងយកដៃដើរយើងតាំងពីរកៀរក្បែរអ្នកទៅ ។
ក្តាមឆ្លើយថា ដើងអ្នកតាំងពីខ្ទង់ចុះ យើងខ្ញុំងក្អាស្លាប់ពុំខាន, បើយើង
យកដង្កៀបរបស់យើងពីរគោងកអ្នក សឹមអ្នកហើរទៅ, ដូច្នេះ យើងពុំ
មានភ័យឡើយ ជាបើអ្នកព្រមនឹង យើងក៏ព្រមទៅ បើអ្នកមិនព្រម
យើងពុំទៅឡើយ ។ ក្អែកស្តាប់ហើយ ឈរនៅស្ងាលចុះ ។ ក្តាម
យកដង្កៀបតាំងពីរគោងកក្អែកជាប់ ។ ទើបក្អែកនាំហើរឡើងទៅលើ
អាកាស ទៅកាន់សំណាក់ខន្ធាយជាមុន ។ (នៅមានត)

ផ្នែកអក្សរសាស្ត្រ

ពឿងហង្សយួន

(តទៅ)

លោក អឹម-ភន បច្ចុងពិសាស្ត្រាស្ត្រាវរិត

បទភ្ជុំដង្គំលីលា

នេះបទប្រាកដចំនាំ កុដង្គំលីលា ថ្លៃឯទំនាន់នៃ ។ ទីដែលថ្លៃ
សំដែងស្រដៀ ដំណើរអំពី ក្សត្រមួយនោះណា ។ នគរបៀរ
ស៊ីមា សន្ធតនាមា តាកណាស៊ី ។ ព្រះអង្គស្តេចទ្រង់ពីរ៉ូ ជាចៅ
ប៊ូរី នាមព្រះព្រហ្មទត្ត ។ សម័យថ្ងៃមួយមហាក្សត្រ ស្តេចចំនាំថ្វាត់
ប្រាតព្រឹក្សា ។ អេហ៍ពលសកលយោធា មន្ត្រីសេនា ហៃព្រះជ្រៀស្ត
ជ័យ ។ ស្តេចដល់មណ្ឌលព្រឹក្សវៃត្រ ព្រះចាទក្សត្រថ្ងៃ ប្រាតសប្បាយ ។
ទីហានចាមភាន្តវៃត្រឆ្ងាយ រាលវែងលោះលាយ ឈើផងច្រែនពណ៌ ។
ស្រះស្រង់តំពងកប្ល ស្ទឹងបឹងបវរ ខ្ពង់ខ្ពស់ខ្វែងភ្នាត់ ។ ព្រះតាយ
រំតើយជាយជាត់ ព្រះអង្គមហាក្សត្រ ក្រសាលស្ងើមក្សាន្ត ។ ព្រះចាទ
ខនាថថ្លៃឆ្ងាន ស្តែងស្តេចលុះចាន ដល់ដើមក្រឹស្នា ។ ក្សិណានោះ
ស្តេចឆ្ពោះនេត្រា យល់ឃើញកុមារ ពិសេសពិស័យ ។ អស់អង្គជួរផង

រពកក្រៃ ខាងនាថបុត្រី បទុមកេសរ ។ ក្សត្រថ្លៃព្រះទ័យសាទរ
ស្តេចយកព្រះករ បីបុត្ររតន៍ផ្តង់ ។ ពាជាតនាអស់អង្គ យកព្រះទំរង់
រតន៍មានដំឡៃ ។ ចង់នាហត្ថាបុត្រថ្លៃ ក្សីណាក្សត្រជៀសជ័យ ត្រេក
សោមនស្ស ។ បន្ទូលមធុរត្រាស់ថា រីកូនខេះណា មិនកូនពាស្តួចឆ ។
បុត្រមហាក្សត្រាច្បាស់ឮឆ ស្តែងស្តេចត្រាប់ត្រង ខតរធំក្តាត់ ។ ខើប
ចាខសូរកាណិកែវរតន៍ ត្បូងពេជ្រវិក័តិ ចង់ជាសំគាល់ ។ តក្រោ
សោភាព័រពណិ សោតជាបន្ទាល់ ខៀងច្រាកដក្តាត់ ។ សេចក្តីហេតុអ្វី
វិបត្តិ ចាខជាច្រាសត្រាត់ មាតាបិតា ។ ជាកំព្រាអញតាប់ហើយណា
អញរើសយកជា កូនឆមិអញ្ញហោង ។ អញឲ្យសេពសោយភក្សត្រង
ជាស្តេចស្តែងស្តង អង្គអញឯងណា ។ ក្សត្រក្សត្តិស្តេចចាខបុត្រា
ហើយត្រេកជា ដុំចរោរពេល ។ ស្រាប់ស្រេចស្តែងស្តេចចាខដល់ ទី
ឋានមណ្ឌល មណីរោងរតន៍ ។ តុំលង់ព្រះអង្គមហាក្សត្រ ស្តេចឲ្យ
ដញ្ជាត់ ត្រលឹងបុត្រា ។ ចរិបូណិតុំយូរឡើយណា សម្តេចពាជា
រើសតេមន៍ ។ រក្សាបុត្រាទុត្តម អង្គុយដិតដុំ នូវបរិពារធង ។
ភាពួតរួមរក្សាត្រង់ មិនឲ្យមានហ្មង ដល់តិចឡើយណា ។ ក្សីណាក្សត្រ
ព្រហ្មទត្តពាជា ទ្រង់ព្រះចិន្តា ក្នុងព្រះហឫទ័យ ។ បុត្រាតុំជាថ្លៃមថ្លៃ
អញរើសមៅនៃ ក្រោមដើមត្រីស្នា ។ អស់អង្គតុំហួងដួចផ្កា រួសរស
គន្ធា ពិរោះល្អែងល្អើយ ។ ស្តេចតិតកង់ចិត្តស្រេចហើយ ក្សត្រា

ត្រាណត្រើយ ចេីកបន្ទូលថា ។ សន្ទនក្រោកជនាមា ស្តេចឱ្យហៅថា
ចៅក្រីស្នក្ខមាវ ។ យេីងថ្លែងសំដែងតិកាល សាម្តេចកូចាល ព្រហ្ម
ទត្តពាជ ។ រេីសបុត្រតិស្សទ្ធសោក ដំណេីរនេះណា យេីងស្ទែះ
ក្សេណេះហោង ។ យេីងនិយាយតាំដើមទង ដំណេីរខ្ញុំនង នាងនាថទុត្តមៗ
ក្សត្រីមហេសីសួស្តីសម នាងនាថបខ្ញុំម-កេសរមិញ្ញណា ។ នាងនាថ
សង្វាតយាត្រា ក្នុងវិត្រត្រីក្សា កេព្រះបាទបង ។ អស់កលតុំយល់ជាមួង
នាងវិលវិងដួង ជល់ដេីមក្រឹស្នា ។ នាងរកតុំយល់បុត្រា នាងតក់ទុក
សោយសោកសល់ក្រៃ ។ ឈឺធ្មៃបហាក់ហៀបនឹងក្សួយ ហេតុនាង
អាល័យ ឈឺដង្វៃតបុត្រចាត់ ។ នាងវែងផ្សាផ្សងក្តៅក្តាត់ ញ៉ាថ្ងេីមប្រមាត់
សួតសរសៃសាច់ ។ ហាក់អ្នកប្រឡាក់ប្រចាច់ យកទឹន្ធូរម្រេច ញ៉ាញីប្រ-
បល់ ។ នាងឈឺជម្ងឺខ្លាំងសល់ សោកសោះដាលដល់ ដួលសន្ធំលង់ ។
នៅនាងាកឯកអង្គ ឯងឥតចិត្តលង់ ទេីបនាងនាថក្បាក់ ។ ស្មាតេីក្សត្រី
អួលអាត់ ទឹកភ្នែកសស្រាក់ ដោយព្រៃសស្រោច ។ តក្រាំពាសស
ល្អោច ដួចកលគេរបាច តុងគោះចោះបង់ ។ ក្សត្រីទេវីរាម- ង្គលតក់ទ្រូង
ទ្រង់ កន្ទេីងសោក ។ នាងខួញខំខួញថ្ងៃងថា ឧកូនសួនភ្ញា ព្រលង
មាសម្ភាយ ។ ម្តេចបាបុត្រាតណ្ណាយ ប្រែប្រាសត្រាត់ឆ្ងាយ តីទ្រូង
ម្តាយទៅ ។ ម្តាយប្រាសនិកសព្រះបៅ លែងបានជាន់ទៅ ជាតីរនាក់ណា ។
ឥឡូវម្តាយនៅកំព្រា ប្រាសម្តេចតាំងបា បណ្តូលថ្ងេីមថ្ងៃ ។ កូនអេីយ

ម្ល៉ះហើយតាំងថ្ងៃ នេះសមគ្គាយក្សិយ ជីវិតហោងណា ។ ដ្បិតប្រាសនិកាស
បិតា ហើយប្រាសទាំងបា តន្ទុកហ្លួងយ ។ សូវស្មោះក្សត្រាប់ជាក្រៃ
រស់នៅច្នេះនៃ តែងរងទុក្ខា ។ ឬរស់ជាមនុស្សច្នេះណា រស់ងើរវែង
ខ្លះទុក្ខគ្រាស់ក្រៃ ។ កូនស្ងួនខ្ញីមខ្ញុនថ្មីមថ្ងៃ គ្នាយក្រែងមួយនៃ សក្ក
ឆងពាង ។ មាសថ្ងៃប្រពៃពុំងា នាំយកទៅជា អាហារចំណី ។ ចុះបក្ត
ភ្ញាពិសី គ្នាយគិតក្រែងប៉ះ- សាចផងទាំងឆ្អាយ ។ យកចាពុំងានោមនាយ
ទៅទុកហានាយ ដំបន់នានា ។ ស្ងួនខ្ញីមខ្ញុនពុំងា គ្នាយក្រែងខ្លាច
ខ្លែព្រឹក្សនោះផង ។ លាក់ចាស្ងួនក្លាស្នេហ៍ស្នង ឬគ្នាយតែងរង ទុក្ខខ្មៀង
ជ្ងន់ក្រៃ ។ គ្នាយឈ្លងគិតឯងមួយនៃ ខ្លាចក្រែងច្បើរក្រៃ ត្រាច់ត្រង់
ហើយណា ។ មកដល់យងំយល់ស្ងួនក្លា ហើយរើសចានចា នាំទៅ
ជានឹយ ។ ក្រឹស្នាសាខាត្រសាយ ឈើនេះដែលគ្នាយ ផ្តួតចំប៉ាចា ។
គ្នាយអ្នកចាំជាក់ណាស់ណា ឃើញតែក្រឹស្នា ដែលគ្នាយឈប់ទៅ ។
ម្តេចប្រាសកូនមាសឆ្ងៃនេះ ព័ទ្ធន៍គ្នាយទៅ ចាតងងឹឃ្លាតឃ្លា ។
គ្នាយស្រែករកអ្នកត្រងំណា ឱគ្នាយយល់ចា ដូចចិត្តចំណង ។ ស្ងួន
ខ្ញីមខ្ញុនឥតឆ្គង កូនអើយនេះម្តង គ្នាយគំតពុំយល់ ។ ព្រួងគ្នាយឃើ
សាយើសព្វសល បុត្រចាត់ពុំយល់ មុខមាសថ្ងៃមថ្ងៃ ។ នាងសោក
អាមោក្សពេកក្រៃ នាងវែងសង្រែ បុត្រថ្ងៃចាត់ចង ។ ក្សត្រីទើរវែង្ស
លោកទុសកវង្សង៍ ជាក់លើសិរ ។ វង្សាពេកសព្វ ទេត្រីក្សបិតង

ត្រះកែត្រព្រឹក្ស ។ ក្សត្រីប្រណិធានថា បពិត្រខេត្តា ខេត្រឹក្សនៅនៃ ។ ទីហានហាមតាន្តត្រះកែត្រ ផងអ្នកដទៃ បិតព្យសោឡសសួគ៌ ។ សូមអ្នកកុំហាក់បុត្រា អ្នកច្រាប់ទុក្ខ ឲ្យទុំបានយល់ ។ កូនសួនទុំមទុំនមល សោះទុំតែងខល់ ខុក្ខដូច្នេះណា ។ ក្សត្រីខេរ៉ៃសោតា អង្វរខេត្តា ខេត្រឹក្សនោះផង ។ សម្រេចស្រាប់ស្រេចហើយហោង នាងចិត្តាផ្តង ទីឆតាមបុត្រា ។ ស្រីតន់នាងតន់ត្រឹក្ស ក្រោមដើមក្រឹស្ន យល់ស្មាមដើងជាន់ ។ ទៅនាងពាកជាក់ស្បាន់ នាងតិតន្លេ ត្នាន់ ថាមទុស្សនេះនៃ ។ ពាមកវែរកលេងត្រៃ ពរើសបុត្រថ្លៃ អញ មែនពិតណា ។ នាងនាថឡិយ្ហាតយាត្រា តាមបុត្រសួនក្ស ដោយជាន់នោះនៃ ។ ក្សត្រីខេរ៉ៃតែន់ថ្លៃ ដើរដោយដងត្រៃ ហាមតាន្តនោះហោង ។ ឈ្លងឆកជ្រោះប្រកជ្រលង អស់តាំងម្រឹតផង ដើរដោយហ្វូងក ។ ស្រីថ្លៃប្រតៃសោតា នាងនាថយាងយា. ត្រាត្រាច់យងំយល់ ។ ពជសីហ៍ចេញព័មណ្ឌល គុហាថ្លើងថ្កល់ សីហនាទចេញចរ ។ មើលឡើងថ្ងៃប្រឹងឈប់ឈរ ដោយព្រឹក្សាតរ សំពន្ធគាគ្ន ។ តជសីហ៍ដំរែលៀងគា ដើរដោយហ្វូងក រ៉ែរកគោជ្ជក៍ស្ត ។ ដំរែរកស៊ីដេរដោស គោតគៀងពេញតាស ខ្លោងខ្លាស៊ីឡាយ ។ រមាំងខ្លីងខ្លាងប្រើសត្រាយ ញ៉ាងញ៉ាងក្សីខ្សោយ ដោយពណិទីនៃ ។ ពាំងមហិសាត្រាស់ត្រៃ ខនេឡាងគោត្រៃ ឈ្លូសរមាសខ្លា ។ សំនោច

ទាំងពោចស្វាន់ស្វា បបកប្រមា ខន្ធាយសោតនៃ ។ ម្រឹគគគីកច្រើន
វៃក្រ ដើរជោយជនវៃព្រៃ ដោយជនថ្នាត់ថ្នល់ ។ ខ្លះស្រែប់ខ្លះឈប់ខ្លះ
ជល់ គ្នាឯងអស់កល ខ្លះគៀងគូរ ។ ខ្លះព្រាត់កូនបាត់ឃ្លាតឃ្លា
រត់រកកូនវ៉ា ពុំឃ្លានស៊ីស្មៅ ។ ខ្លះយល់កូនដល់ឈប់ខៅ អត់ឱ្យ
កូនចៅ ខ្លែតខ្លួនស្លាប់ស្លាល់ ។ ក្សត្រខេរិនីមិល នាងរត់ភៀយល់
អស់ទាំងម្រឹគផង ។ នាងវែងកណ្តែងកន្ធង សោយសោកក្តាត់ហោង
ពិលាបពួញថា ។ ឧសភ្នូនេះព្រាត់កូនវ៉ា ដូចអញឯងណា ព្រាត់កូន
បាត់បង់ ។ កូនស្ងួនខ្ចីមខ្ចួនសាច់ស- ង្ហារសូន្យនាក្នុង ព្រះព្រៃ
ព្រឹក្សា ។ សត្វខ្លះប្រទះកូនវា កូនសោតម៉ីម្ហា រត់រកចៅមេ ។ ឧអញ
វែងម្នេញឥតស្លៀ ក្រាសកូនមាសស្នេហ៍ សោះសូន្យពុំយល់ ។
កូនអើយម៉ែរហ៊ោយម្តាយខ្លាល់ ខ្ញុះខៀងលុះដល់ ក្សីណាក្សីយជន្ម ។
ឧស្ងួនខ្ចីមខ្ចួនមាតា ម៉ែរហ៊ោយសមប្តា ទំងអត់ទីតរជាះ ។ ម្តាយទឹក
ភ្នែកដើមនោះ កូនអើយតុងតោះ ម្តាយវែងខ្ចោចឆ្ងាយ ។ ក្សត្រីខ្ចី
ឃ្លាតយាងយោ- ត្រាត្រាច់ស៊ីសា កណ្តាលហ្វូងសត្វ ។ នាងសោក
អមោក្សត្រេកក្តាក់ នាងនាចពុំគិត ខ្លាចខ្លួនឡើយណា ។
តេជៈព្រះបារមីតា នាងសាងច្រើនគ្រា ថ្វីងថ្លែងពុំបាន ។ ទេវតា
ទៅនាហ៊ាមតាក្តី សឹងសត្វពិមាន សោឡូសសួគ៌ា ។ សឹងតែ

ជ្រោមជ្រែងរក្សា វិរតន៍ជាយា ប្រក្រតីទៅហោង ។ ហ្វូងសត្វ
ច្រើនគ្គាត់កន្ទុង តុំអាចយើសយ្ងង ចៀតចៀនខាងណា ។

បទព្រហ្មគីតិ

ក្សត្រិណានោះនាងទៅ អគ្គមហេសីវរជាយា នាងតាមពាជបុត្រា
ត្រាច់ក្នុងព្រៃព្រះហិមភាន្ត ។ ឈើជងឹះសាតច្រើនពណិ សត្វរង្គារ
ចំសម្រាន្ត តៀងគួយសត្វសាន លោតលេងលើដើមត្រឹក្សាព្រៃ ។ នាង
យល់អស់បក្សា នាងសោក-សោកាក្រៃ ខ្លួញៗទៅព្រះដៀស្តង្ឌយ
ខ្លួវំខ្លួញនោះឯងថា ។ ព្រះបាទបតិត្រ ឆ្ងាយវែងស្ងួន-ស្ងួនស្ងេហា
រួមឯក-ឯកអគ្គា មូលមណ្ឌលនឹងប្លួនស្រី ។ នេះម្តងម្តេចព្រះមាស
មិត្តប្រែប្រាស-ប្រាសទំាស ទំាសចាកចេញពី ទ្រង់ប្លួនទៅ
អសារសល់ ។ ខ្ញុំប្រាសពីព្រះបង តំខ្ញុំរង់រងទុក្ខលំ ហើយប្រាស
ប្រាសតុំយល់ ទាំងកូនស្ងួន-ស្ងួនស្ងេហ៍ស្ងួន ។ ប្លួនវែងឃឺឆ្ងាសល់
ម្តេចមកយល-យល់សត្វជង ទាំងពីរហៅត្រសង ទៅចំរលងលើត្រឹក្ស
ព្រៃ ។ ទុបាន-ឋានក្រឹស្នា ដើមសាកលាស់លូតលៃ ទ្រង់ផ្ចាំ-ផ្ចង
ប្រពៃ រីករុះរោយដោយធាក ។ ពាំដោរដូចអ្នកអប់ ធ្លុះត្រឡប់ទាំង
ធាក ត្រសៀកជាតំរាត បក់លំគោន-លំគោនខង ។ ហាវ្យហើរ

លើតំរឹងគូ ៗ ទៅទំនៅរុក្ខាហោង ចឹកពាប់-ចាប់ផលផង ហើរទៅទំ-
ទំតំរឹងគូ ។ ទ្រព្រះ.ព្រះបពិត្រ ភ្ជាប់រែងឋិត-ឋិតនៃបទៅ ទឹងប្អូនម្តេច
ឥឡូវ ព្រះប្រែប្រាស-ប្រាសពុំឃើញ ។ ទដើម-ដើមក្តាំពាក់ ធំត្រ
សាក់ត្រសាយសល់ ទ្រង់ផ្កា.ផ្កាទឹម.ល តាំងរៀក្រៃ.ក្រៃតេកណា ។ ខ្ញុំ
ហើរ-ហើរទៅទំ ទំយោសយំរកគូវ ដូចអន្ធតញ្ញឯងណា ខ្ញុំងឿញ
រកព្រះរៀមថ្ម ។ ទដើមកល្បត្រឹក្ស លូតសាស់ស្តឹក-ស្តឹកល្អក្រៃ
ទ្រង់ផ្កា ផ្កាប្រៃ ប្រៃតេក-តេកកន្ទុង ។ រុះកេយដាសដោយដី ធុំ
ក្លិនតិងដោរល្អប់ល្អង ព្រះតាយបក់ខ្ទង ធុំត្រឡប់តំរឹងទិសា ។ មយូរ
ទំយោសយំ យំរងំធ្វើយកូនគ្នា ប្រគៀង-គៀងគូវ ក់ចឹកចាប់បុប្ផាផល។
ចម្ប៉ា.ចម្ប៉ាពុំ ពុំត្រសុំត្រសាយសល់ មានផ្កា-ផ្កាទឹមល ធុំត្រអូបក្រ
វែមចឈូប ។ មយូរ-មយូរចឹក ចាប់តល្បត្រឹក្សបរិភោគស្កប់ ហើយ
ហើរ-ហើរទៅឈប់ ទៅនាដើម.ដើមចម្ប៉ា ។ ទប្អូនយល់ចក្ខី តំរឹង
ឈ្មោលញីគៀងគូវ ប្អូនផ្គត់-ផ្គត់ឃឺផ្សា ឈឺទុក-អួលក្តៅក្តាត់ ។ ទ
ព្រះបុទចមះចៅ ភ្ជាប់រែងនៅ.នៅនៃបទិត្យ ភ្ជាប់ស្នាល.ស្នាលស្នេហ៍
ស្និទ្ធ ស្និទ្ធនៃបទិត្យទឹងប្អូននៃ ។ ឥឡូវម្តេចព្រះអាស មកប្រែប្រាស-
ប្រាសទីនៃ ប្អូនផ្គត់-ផ្គត់អាល័យ អាឡោះលន់តន់តេកណា ។ ទដើម
ដើមតាកែស ល្អតិសេសទ្រង់ប្តូជា ទសត្វ-សត្វសាវិតា ហើរទៅទំ.ទំ
រោតលេង ។ មាត់ប៉ែន-មាត់ប៉ែនធំ ផ្លែសោតពុំ.ពុំរុះឯង តិងដោរ

តាំងរាល្អែង ខ្លូវក្ងែនផង-ផង។តួម ។ សាវិកា-សាវិកាមើល មើលហើយ ហើរ-ហើរទៅទំ ទំហើយ-ហើយយាសយំ យំហើយឋ-ឋវិកោតផល ។ ភូតាន-ភូតានតន ផ្កាស្ពឹលនតាសេសសល់ ហើយទ្រែង-ទ្រែងខ្លូវផល ផលប្រសើរ-ប្រសើរក្រៃ ។ សេកហើរ-ហើរទៅទំ ទំសម្ងំ-សម្ងំឮ ភូតាន-ភូតានតែ ទំតាំងគួ-តាំងគួរ ។ តុដើម-ដើមសុក្រំ លាស់ត្រសុំសឹង ទ្រែងផ្កា មានផល ផលផងជា ជាឋង្គើម-ឋង្គើមឋង ។ ស្រគំស្រគាលផល សេកសោមឃល់-ឃល់ហើយហោង ហើឋហើរ-ហើរត្រសង ចេញពីដើម-ដើមភូតាន ។ រន្ទេម-រន្ទេមទំ នៅទ្រែងសូរសព្ទសាន ឋវិកោតផលផងមាន សេតិសា-តិសាសល់ ។ ប្អូនឃើញឃើញឋក្ស ប្អូនសោក-សោកាសល់ ប្អូនផ្តក-ផ្តកគិតដល់ ដល់ព្រះថ្ងៃព្រះថ្ងៃឋង ។ ឆ្ងាប់ទៅ-នៅនៃឋនិត្យ និត្យស្នាលស្ងួន ស្ងួនស្នេហ៍ស្នង តវល្ងែនេះម្តង ក្រោតប្រែប្រាសពីប្អូនថ្ងៃ ។ លលក-លលកហោរ ហើរហើយមើល-មើលរំពៃ ចុះទំទ្រែងក្រៃ ឮលើដើម-ដើមរំដួល ។ រំដួលរំដួលផ្កា មានផលាដូចគេត្បូរ លលក-សាតសៀសួ ទៅទំលេ-លើវត្តា ។ តុប្អូនយល់លលក យាសយំកេ-កេតូវ ប្អូនផ្តកស្រណោះណា តុះតុព្រះទាសប្អូនអើយ ។ ប្អូនឈឺអន់ឆួលអាត់ ប្អូនកេងកេតុំយល់ឡើយ តុអម្ចាស់ប្អូនអើយ អ្នកនិត្យទៅ-ទៅឋានណា ។ តុសត្វសត្វពុកក្រូ ទំតាំងគួ-តាំងគួរ លើជ្រៃ-ជ្រៃសាឋ ជាដំណេក-ដំណេក

នៅ ។ បរិភោគ-បរិភោគផល ផ្អែមស្ពៃស្ពៃ ហើយហើរនៅ ខ្លះចំ-ចំនិត្យ
នៅ នៅតាំងគូ-តាំងគូណា ។ ឧសគូ-សត្វបក្សី រៃនេះស៊ីតាំងគូរា
ឧអញ្ជាម្តេចឃ្លាតឃ្លា ខ្ញុំឯព្រះចុងព្រះភូមិ ។ ចោរលោភហិចហើរ
នៅ នៅចំនៅ-ដើមសុរភី តាំងគូរគៀនឈ្មោលញី ស៊ីហើយយំ-
យំស្តែងស្តើយ ។ ឧប្ជូនឮសត្វសកុ ប្ជូនអាណិតណាស់ឯកដើយ
ដ្បិតប្រាសព្រះគ្រាណាត្រើយ ពីទ្រូងប្ជូនអសារសោះ ។ ម្តេចឡើយ
ឮសត្វសកុ យំស្រែងាត់ឱ្យអាឡោះ ឧប្ជូនរៃនស្រណោះ រៃនលន្ទុង
លន្ទោចលន់ ។ ប្ជូនរៃនអន់អួលអាត់ រឭកឯកណាប្រុសតន់ រៃន
ឈឺ-ឈឺឆៀបលន់ ឥតឯស្បើយដល់តិចណា ។ តារៅ-តារៅចំ នៅ
តាំងកំពុងសឹងភ្លា ស្ទឹកស្ទាម-ស្ទាមសាខា តារៅយំតេគ្នា ។ ឧអញ
គួរអន់ឮ សត្វខេរណាប្រដូចជា អង្គឧអញឯងឯ។ រៃនខ្លាក្រែង
ពងា ។ រន្ទេច-រន្ទេចចំ តាំងគូយំខ្លួរសារិកា ហើយហៅតើខោះណា
នៅចំលើរំដេញមាស ។ ទ្រង់ភ្លាំ-ភ្លាំក្រពុំ ផលផនឱ្យរុះដេរដាស រំ
ដេញ-រំដេញមាស សត្វរន្ទេច-រន្ទេចចំ ។ ឧប្ជូនឃលមក្ស តាំង
គូរ.រយាសយំ ឧឥឱ្យរំម្តេចខ្ញុំ កំព្រាព្រាត់ព្រះភូមិ ។ ឧត្រាប
ព្រាបត្រៃចំ ចំហើយយំតាំងឈ្មោលញី ខ្លះសោតរកចំណី មកឱ្យកូន
បរិភោគ្លា ។ ឧម្ចាយឃលប់ក្ស រកចំណីឱ្យកូនវា កូនអើយទ្រូងម្ចាយ
ផ្សា ផ្សព្វខ្លួរខ្លុំតេកណាសៅនៃ ។ ដ្បិតម្ចាយកំព្រាព្រាត់ ប្រាសកូន

វត្ថន៍ស្លូនថ្លៅមថ្ងៃ ច្រូងម្តាយឈើក្រៃក្រៃ ឱនថ្ងៃនថ្ងំនតុំបាន១ឡើយ ។ កំរ
វិក-ការកេងយុំ យំរងំសត្តូលើងលើយ ចាំងគ្នូ-គូរហើយ ចំរៀ
លើដើមឫសនាគ ។ ខ្លួនឮសត្តូសត្តូ ក្នុងព្រៃស្ងាត់ស្រមៃហាក់ ប្រហែល
ជួចពាក្យអ្នក ព្រះរៀមរក្សដង្ហើយហៅ ។ ក្លួនរែង-រែងខ្លីឃ្លាត ចំ
សង្ឃឹតឆ្ពោះសំដៅ ដើរត្រាច់-ដើរត្រាច់ៗ យល់ការកេង ការកេងយំ ។
ហើយប្លួនរែងឈើផ្ទក តក់ទក-ទុកក្រុំ ឈើធៀបអួលអាត់អន់ ច្រូង
រែងច្នន់-ច្នន់កន្ទួង ។ ខ្ញុបាបផ្តល់នាជាតិ ខេះខ្ញុំឃ្លាតទឹងព្រះបង ខ្ញុំសូម
សត្វជាតិដង ក្រុំប៉ាមានហៅឃ្លាតឃ្លា ។ ជាតិអើយជាតិខេះហោង បើ
ព្រះបង់កើតជាតិណា សូមសេតៈសោយសុសា-ភ្លាយខ្លួរបុណ្យបរិបូណ៌
ក្រៃ ។ ខ្ញុំប្លួនសូមច្រាបថ្វា សូមកើតជាស្រីស្លូតថ្លៃ ប្រកបនឹងដ៏ផ្សឹងដ៏យ ចាន
ជាខ្ញុំស្លូមីតិត្តិ ។ ជាតិអើយជាតិឯណា ព្រះកើតជា-ជាស្តេចយក្ស
ហើយខ្ញុំជាប្លួនអ្នក សូមកើតជាស្តេចយក្សស្រី ។ អញ្ជាខ្ញុំសូមច្រាបថ្វា
ឲ្យបានជាអគ្គមហេសី ជាតិអើយជាតិណាក្តី ដើព្រះបង់ស្តេចកើតជា។
កដហង្សអាសមណ៍ កំប្លួនស្រីសូមច្រាបថ្វា ឲ្យបានទៅកើតជា គូនឹង
ព្រះបាទភូមី ។ ជាតិអើយជាតិណាហោង បើព្រះបង់ចាប់បដិ - សន្ធិ
ជាកដសីហ៍ ប្លួនសូមកើតជាគុហា ។ មាសមានឫស្ទើរផ្តៅ ជាប់ទៅ
ច្រកេងជា ស្តេចតង់ក្សេមសុខសា-ភ្លាយក្រសាលព្រះហ្ឫទ័យ ។ ឬ
មួយស្តេចកើតជា ជាមច្ចា-មច្ចាថ្ងៃ ឲ្យប្លួនព្រះជ្រៀសជ័យ សូមកើត

ជាព្រះតង្គា ។ ថ្វាយង្គំ.យង់ជ្រះជ្រៅ ជាំលំនៅព្រះពុទ្ធជា ស្តេចហែល
ហែលសេងណា ក្រសាលឥត-ឥតឯហ្មង ។ ព្រះហើយខ្ញុំប្អូនស្រី ថ្វាយ
ថ្នាំតិជាតំនេះម្តង សូមសព្វ សត្វជាតំផង កុំបីមានហៅឃ្លាតឃ្លា ។
ជាបបួលសុះជ្ញាន ដល់និព្វានទៅខ្ញុំគ្នា ព្រះហើយខ្ញុំថ្វាថ្នា ឲ្យជ្ញានដូចនឹង
ព្រះបង ។

បទកាកគតិ

ចខគាកគតិតែង ដំណើរដំណែង អំពីនាងនាថ ខៀនខ្ញុំ
ព្រះបង នោះហោងសល់ខ្លួត នាងនាថសង្វាត គ្រាចំក្នុងវៃព្រហោង ។
គាលខោះខេវ៉ា វែកដក្សត្រី អនុជាស្នេហ៍ស្នង សោយសោកខ្លួញ្ញ័
ស្វាមីនាងហោង នាងនាថវែងវង ខ្លួគ្នាគមនស្បា ។ នាងឈឺពីក្តី
មួយឈឺស្វាម៍ មួយឈឺបុត្រា នាងសោយសោកសល់ ខ្លួញខល់ខ្លួគ្នា
នាងត្រាចំកេជា អំឡុងយូរក្រៃ ។ នាងតាមដោយជាន ដល់ស្រុក
ពាក- ណាសីនោះនៃ គាចំដួនភក្ត្រី ឥតចំអាស្រ័យ ក្សត្រីរតន៍ថ្លៃ
នាងនំយាត្រា ។ ដល់ផ្ទះដួនចាស់ មានសប្បុរសណាស់ ជាអ្នកក្រងថ្នាំ
ក្សីណានោះក្សត្រី ទេវីគិតថា អញសំចតណា ផ្ទះដួននេះនៃ ។
ទើបនាងថ្លែងថា អ្នកដួនអ្នកតា . ខ្ញុំសូមអាស្រ័យ សូមផ្ទះដួនឈប់ តែ
យប់នេះនៃ រួចជ្ញានដល់ថ្ងៃ ខ្ញុំលាដួនទៅ ។ យាយមាលាស្តាប់

ពាក្យតំពេះនាង : ត្រេកអរហើយហៅ នាងអើយយាយអា នាងចម្រើក
ទៅ នេះនឹងយាយទៅ អង្គាស់យាយអើយ ។ នាងនាថកល្យាណ នាង
ឡើងទៅថ្ពាន ផ្ទះដូនតាស់ហើយ រកជក្សត្រី ទៅត្រាណត្រើយ នាង
តង់ស្រេចហើយ នាងនាថប្រណិប័តន៍ ។ នៃដូនឧទ្ទិសតា សម្រេចហើយណា
នាងតង់ស្ងៀមស្ងាត់ ទៅរយាយមាលា ចាចាផ្តេកផ្តិត ស្តេក្សត្រីតែន
ខ្លួនតាក្សនេះថា ។ អ្នកអង្គាស់យាយ មានប្អូនឆោមនាយ អ្នកមកពី
ណា ចូរនាងរៀបរាប់ ប្រាប់ប្រាប់យាយវ៉ា នាងអើយយាយអា. ស្តេ
នាងតេកក្រៃ ។ នាងនាថទ្វាស់ឆ្លើយ ថាអ្នកយាយអើយ ខ្ញុំនេះ
នៃ ព្រាត់ប្រាស់ពីប្តី ស្វាមីថ្លើមថ្លៃ នាមអ្នកនោះនៃ សុវណ្ណកុមារ ។
ប្រាសចាំងបុត្រា ទើបប្រសូតជា តំរូប៉ុក្សារ បីនេះទៀងទាត់
ហើយត្រាត់អស្សារ សូនសោះកន្ទារ ព្រឹក្សនោះនៃ ។ ដោយបាន
មើលដាន ស្នាមជើងសម្រាន្ត មនុស្សជង់ដើរក្រៃ ពាក់សែបុត្របាន
នាំថ្ពាន់មកឲ្យ ក្នុងស្រុកនេះនៃ មែនមិនខេឡើយ ។ ឯយាយមាលា
ស្តាប់នាងប្រាប់ប្រៈ ការដូច្នោះនៃ ទើបតាត់ចរចា ប្រាប់ថានាងអើយ
មហាក្សត្រត្រាណត្រើយ នាមព្រះត្រហ្មទត្ត ។ ស្តេចទៅប្រភាត
សម្តេចនរោត្ត រកសែពាជបុត្រតែន ព្រះបាទក្សត្រា លីលាវិនិថ្ងាត់ មក
ថ្ពាន់ហានបិត ស្តេចឲ្យរើសកេ ។ មេនំក្រមការ រកក្សកុមារ បុត្រា
ពន្ធក សត្វព្រះប្អូរ៉ាយ ក្សត្រៃថ្លឲ្យយក បុត្រាពន្ធក មកជាកូន

ធម៌ ។ នាងអើយភាក្សយាយ ដំណើរច្រាបច្រុយ ឲ្យនាងបានស្គាល់ កុំបីនាងថ្លែង ចារចែងខូចខ័រ ជ្រាបដល់ព្រះភាណិ ទ្រង់ព្រះក្រោធក្រៃ ។ យាយសូមឃាត់នាង នៅនៃអំភ្លាង ទំនិយាយឯងនៃក្រែងបានជួបជួន កូនស្ងួនថ្លើមថ្លៃ បានដូចហ្លួងឃ្វៃ ចិត្តនាងច្រឡាំ ។ នាងនាថស្ងួនស្ងាប់ ពាក្យពីរោះតាប់ ទើបនាងឆ្លើយថា បើអ្នកយាយមាន ចិត្តក្សត្តមេត្តា ខ្ញុំនៅនេះណា ទំនិយាយឯងហោង ។ ឯយាយមាលា ពិភ័ត្តិរក្សា ស្រឡាញ់ស្នេហ៍ស្នង យកនាងទុកនៅជាលៀវហោង មិនមានឲ្យហ្មង ដល់តិចឡើយណា ។ ឯក្សត្រីថ្លៃនាងនៅនេះនៃ ទំនិយាយមាលា រំពាក់ក្សត្រី ទេវីក្រុងឆ្លា តាងយាយមាលា ប្រក្រតីសព្វដង ។ ឯយាយទំនិតា ជានៅក្រុងឆ្លាដួយតាងយាយហោង រំយាយមាលា តែងយាត្រាធន ខាំឆ្លាងក្រុងទៅថ្វាយពរជា ។

បទភ្នុដង្គលីលា

នេះបទច្រៀកដចនឹងជា ភុជង្គលីលា ដោយដាន់ខំនឹង ។ ថ្លែងតាលទេវីនាងក្រុង ល្អក្អះហ្មត់ហ្មង រំលេចបុប្ផា ។ ខំនិថ្លែងសំដែងតណិតា តាលនាងក្រុងឆ្លា ក្សត្រាត្រាច់ច្រើនតេត ។ បុប្ផាតាងដឹកវែក ច្រើនពណ៌អនេក អនន្តណាស់ណា ។

(នៅមានត)

ព្រោះហេតុអ្វីបានជាសត្វសេក ត្រាប់ពាក្យមនុស្ស តែមួយម៉ាត់ៗ ជាពាក្យឥតន័យ?

ដោយភិក្ខុ ធម្មរង្សី សិស្សពុទ្ធិកនហារិឡាល័យព្រះសីហនុរាជ

កាលអតីតកាល សត្វដែលគេកក្លាពុកកន្ធុះ ហើយបង្ហាត់បង្រៀនឲ្យចេះនិយាយនោះ មិនតែសត្វសេកទេ គឺមានបក្សីម្យ៉ាងទៀតហៅ លោរិកេត(១) ។

ដោយមនុស្ស បានដឹងថា បក្សីតូចនេះ ជាសត្វឆ្លៀវឆ្លាសជាងគេ, ខ្មាំរហើយ គេត្រូវតែបង្ហាត់បង្រៀនវាតែបន្តិចបន្តួចប៉ុណ្ណោះ ។ បក្សីនេះ ហើរពួនភាក្យអ្វីមួយ, វាអាចធ្វើត្រាប់បានដោយស្រួល ហើយមិនត្រឹមតែប៉ុណ្ណោះ វាថែមទាំងអាចនិយាយ បញ្ចេញគំនិតផ្ទាល់របស់វាទៅកាមនុស្ស ជំនួសការធ្វើត្រាប់សំឡេងដែលវាបានឮដុំវិញខ្លួនវាថែមទៀតផង ។ ប៉ុន្តែសាកាតាំងនេះ បានផ្ទាស់អស់ទៅ ទៅត្រាមួយ ៖

ថ្ងៃមួយ គេដំណាលថា មានកសិកម្មាក់ បានឃើញក្រមុំមួយត្រាប់ឆ្មើតទៅកន្ធរស្រែរបស់ខ្លួន ។ ក្រមុំនេះ ជារបស់អ្នកជិតខាងម្ចាស់មែកសិកម្មនោះ ប៉ុន្តែបើពុកជាជួញចោរកំដោយ កសិកម្មបានចាប់ក្រមុំនោះយកទៅសំឡាប់, តន្ទុះសាច់ ចំអិនបរិភោគ, សល់ប៉ុន្មាន កសិកម្មយកទៅលាក់ពុក ។ សាច់មួយចំណែក គាត់លាក់ពុកលើដំបូរផ្ទះជាយ

---

(១) សត្វនេះ នៅក្នុងសន្តានសោក, តែតួបជាងសោក ។

ហើយចុំណែកដែលសល់ពីនេះ គាត់លាក់ទុកក្នុងឆ្កែវាបន្ទ ។

ថ្ងៃក្រោយមក, អ្នកជិតខាងនោះ បានដើរមកសួរកសិករថា:

"អ្នកបានឃើញក្របីខ្ញុំទេ?"

"ទេ, ឥតឃើញទេ", កសិករឆ្លើយ ។

ខណៈនោះ បក្សីសេរីភេត របស់កសិករ ក៏និយាយឡើងថា:

"ក្របីនោះ ម្ចាស់ខ្ញុំសំឡាប់ទៅហើយ, គាត់បរិភោគខ្លះ លាក់ទុកខ្លះ; សាច់មួយចំណែកគាត់លាក់នៅក្នុងឆ្កែវាបន្ទ ហើយមួយចំណែកទៀត គាត់លាក់នៅលើធ្នើរផ្ទះបាយឯណោះ!" ។

ក្នុងដូច្នេះ, អ្នកជិតខាងនោះ ក៏ទៅរកមើលត្រង់កន្លែងដែលបក្សីប្រាប់ ក៏បានឃើញសាច់ក្របី ក្នុងទីនោះមែន ។ ប៉ុន្តែ កសិករបានឌិយាយថា:

"ចា៎ស! ទីនេះ ជាកន្លែងដែលខ្ញុំតែងតែទុកសាច់, ក្របីអ្នកខ្ញុំមិនឃើញទេ, ឯសាច់នេះ ជាសាច់សត្វដទៃទៀតទេ!" ។

បក្សីសេរីភេត បានស្រែកឡើងម្តងទៀតថា:

"គាត់សំឡាប់ពាក់! សាច់មួយចំណែកគាត់លាក់ទុកនៅក្នុងឆ្កែវាបន្ទ មួយចំណែកទៀត គាត់លាក់នៅលើធ្នើរផ្ទះបាយឯណោះ!" ។

អ្នកជិតខាងនោះ ក៏ទៅជាឡប់គំនិត មិនជឿថា តើត្រូវយក
តាមភាក្យមនុស្ស ឬ តាមភាក្យបក្សី ។ ម្ចាំះហើយ គាត់ក៏យក
រឿងវាំនេះ ទៅប្តឹងតុលាការ ។ សំណុំរឿងនេះ ត្រូវគេសំរេចការ
កាត់សេចក្តី នៅថ្ងៃណាមួយ ជាខាងក្រោយមកទៀត ។

កសិករដែលបានលួចក្រមា និយាយទំនឹងខ្លួនឯងថា: "ហេតុដូចម្តេច
បានជាគេយកតាមភាក្យលោរកេត ជាងភាក្យអញ! " ។

ពេលនោះ កសិករ បានចាប់បក្សីលោរកេតចេញពីទ្រុងរបស់វា
ហើយយកទៅដាក់ក្នុងកាជន៍ទៅលើស្ពានធំមួយ ។ គាត់គ្របកាជន៍
ដោយក្រណាត់យ៉ាងជិតដិតសូម្បីខាងក្នុង ។ ឯខាងក្រៅវិញ ជាពេល
មានព្រះចន្ទ្រតោញ់ មានស្មៅក្តៅត្រចះ តែលោរកេត ដែលនៅក្នុងកាជន៍
មិនអាចឃើញទេសភាពទាំងនេះសោះឡើយ ។ ពួចហើយ គាត់ចាប់
ផ្តើមគោះកាជន៍, ដំបូងបន្តិចៗទេ បន្តាប់មក រឹតតែខ្លាំងឡើងៗ រហូត
ដល់លាន់សំឡេងដូចខ្លះ ។ គាត់យកទៅបោយទឹក ជួសទឹកស្រោចបន្តិចៗ
ទៅលើក្រណាត់ដាលំជាប់ រហូតដល់មានបំឡេងដូចជាក្អៀងបង្អុរចុះ ។
តេញមួយពេលនោះ គាត់គោះកាជន៍ ហើយចាក់ទឹកតែយ៉ាងនេះរហូត
ដល់ពេលត្រលឹមស្រាង ។ ទើបឈប់ ហើយគាត់យកបក្សីលោរកេត
ចេញពីកាជន៍ មកជាក់ក្នុងទ្រុងដដែលវិញ ។

ព្រឹកនោះ ជាពេលត្រូវកាត់ក្តី, កសិករបានយកបក្សីសោរិកគេ ចូលទៅកាន់ក្រសួងតុលាការ ។ អ្នកដឹកខាងដែលចាត់ក្រមឹ កំពប់ រៀបដុំកប់ចៅក្រមពីដំណើរសត្វសោរិកគេ ច្រាប់តាត់ ឲ្យយើញនូវ សាច់ដែលកសិករបានលួច ។ ចៅក្រម គំសួរទៅសត្វសោរិកគេ ដើម្បីកេតិ៍ស្តុតាង ។ បក្សីនិយាយតាមពាក្យដែលវាបាននិយាយពី មុនរួចមកហើយ ម្តងទៀតថា:

"តាត់បានសំឡាប់ក្រមឹ, សាច់មួយចំណែក តាត់លាក់ទុកក្នុងឆ្នាំរ បាន ហើយមួយចំណែកទៀត តាត់លាក់ទុកលើដំបូរផ្ទះចុងយ" ។

បុរសដែលលួចក្រមឹ ឆ្លើយឡើងថា:

"ពន្យល់! សាច់ដែលខ្ញុំប្រចាំទុកនៅលើដំបូរផ្ទះចុងយ ខឹងក្នុងឆ្នាំរ បាននោះ ជាសាច់សត្វដទៃទៀតទេ, ម្តេចបានជាគេឲ្យទម្ងន់ គេ ដឿទៅលើពាក្យបក្សីចំកួតនេះ ជាជំពាក្យខ្ញុំទៅទៀត ?" ។

"បក្សីសោរិកគេ ជាសត្វធ្លាប់ទ្វាសត្យតណាស់!" ចៅក្រមនិយាយ។

"ពន្យល់! វាត្រូវតែនិយាយពាក្យឥតន័យជាងពាក្យមានន័យ" កសិករឆ្លើយ, សូមពន្យល់ភ្លាមសួរវាខ្លួនឯងទៀតមើល, សូមសួរ វាថា "តើយប់មិញ មានសភាពយ៉ាងណាខ្លះ ?" ។

ចៅក្រមសួរទៅបក្សីសោរិកគេ ហើយបានឧទ្ទេសចម្លើយថា:

« ឃប់មិញ ជាកត្រីធំធំ មានត្បុះចុកក្បាលក្ងាន់ណាស់ ថែមទាំងមានក្លៀងចង្អុរចុះ ហើយមានខ្ទុះលាន់ខ្លាភ្លាសមើមអស្ចារ្យ!" ។

កសិករនិយាយថា :

« បើតាមលោកចំណាំ, ឃប់មិញនេះ ជាកត្រីស្ងប់ស្ងាត់ ហើយក្លីស្រឡះ ដោយមានត្រះចន្ទ្រះពេញវង់ចែងចាំងស្មើត្រចះត្រចង់, បើដូច្នេះតើវិញ្ញាណនេះ លោកអាចនោះខ្ញុំព័ចរលួចសំឡាប់ក្របី ដោយគ័ស្តុតាងបេះបក្សីនេះបានដែរឬ ? " ។

ពេលនោះ មនុស្សទាំងអស់ គ័ត្រូវកសិករនេះធ្វើឲ្យស្ងួតតាមឯះចាក្រមគិដូចគ្នា, ចៅក្រមនិយាយថា :

« ខេ, បើយ៉ាងហ្នឹង អ្នកឯងគ្មានទោសអ្វីទេ គ្រាន់តែប្រឡាក់ប្រឡូសដីតែ ដោយគ័ស្តុតាងរបស់បក្សីចំកួតនេះប៉ុណ្ណោះ, ហើយចាប់តាំងពីពេលនេះទៅ យើងមិនត្រូវចិញ្ចឹមក្បាសត្វនេះ ពុកក្ងានជួរបេះយើង ឲ្យជាសត្វមួយក្នុងចំណោមយើង តទៅទៀតឡើយ " ។

ដោយហេតុនេះ កសិករដែលលួចក្របី គំរួចខ្លួន ហើយលោរកេតទ្រព្យតែលែង ឲ្យទៅទៅកន្លែងវិញទៅ ។ បក្សីបានរស់នៅដូចអតីតកាល មុនពេលដែលវាបានស្គាល់មនុស្ស ហើយវាថែរក្សាការពារខ្លួនវា តាមចំណង់របស់វា ។

ប៉ុន្តែថ្ងៃមួយ, បក្សីសោរិកត ជាន់ជួបបក្សីថ្មីមួយទៀត រូបកាន់ជាងខ្លួនវា មានពណ៌ក្រហមខៀវយ៉ាងស្រស់រលើប ។ សោរិកត ជាន់សួរឈ្មោះបក្សីថ្មីនេះ ហើយជាន់ឧទ្ទិសបម្លើយថា :

« ខ្ញុំជាសត្វសេក, ខ្ញុំមកពីទិសខាងត្បូង ហើយឥឡូវនេះ ខ្ញុំប្រថុនធ្វើអាស្រ័យនៅក្នុងប្រទេសនេះ, ខ្ញុំនិយាយភាសាមនុស្ស » ។

ពេលនោះ សោរិកត និយាយថា :

« ចូរអាស្រ័យនៅក្នុងប្រទេសនេះ ឲ្យសប្បាយចុះ ! ប៉ុន្តែ កាលបើអ្នងឯងជាសត្វបក្សក មកនៅក្នុងទីនេះ ចូរឧទ្ទិសយកទុបទេសនីដ៏ការត្រមានរបស់ខ្ញុំ កុំបីភ្លេច; ខ្ញុំគឺនិយាយភាសាមនុស្សដែរ ហើយខ្លួនខ្ញុំ ត្រូវគេយុំត្រង់រក្សាពុកក្នុងដ៏ធ្ងន់មនុស្ស អស់រយៈពេលជាច្រើនឆ្នាំ; ខ្ញុំឮអ្វី ។ ទឹងត្រចៀកខ្ញុំ ហើយឃើញអ្វី ។ ទឹងភ្នែករបស់ខ្ញុំ; ខ្ញុំមិនត្រឹមតែនិយាយភាសា ដែលមនុស្សនិយាយនោះទេ តែថែមទាំងអាចបញ្ជាក្បួនវត្ថុតំនិតដ៏ល្អរបស់ខ្ញុំត្រង់ ។ ថែមទៀត ហើយខ្លួនខ្ញុំ ត្រូវគេចំបរបង់ចេញមក; តាមនេះ ជាការត្រមានរបស់ខ្ញុំ កាលបើមនុស្សជាន់ដឹងថា អ្នកឯងរបន្ទិយាយភាសារបស់គេ, គេមុខតែនឹងចាប់អ្នកឯង ហើយនាំយកអ្នកឯង ទៅផ្ទះរបស់គេពុំខាន; អ្នកឯងកុំនិយាយអ្វី

ក្រៅពីពាក្យដែលគេបង្រៀនអ្នកឯងនោះឱ្យសោះ! ចាំតាមគេតែប៉ុណ្ណោះ ជានហើយ កុំថាអ្វីគេទៀត" ។

បក្សីថ្មីគឺសេក ជានស្តាប់ហើយ គិតថ្លង់អណ្តើតបាត់ទៅហើយ។

បន្ទាប់មក ព្រឹត្តិការណ៍គំកើតឡើងដូចសត្វលោកកេត ជានភ្លាក់ពុកមកមែន ។

មនុស្ស គាលជានដឹងអំពីដំណើរដែលសេកចេះនិយាយនេះហើយ គិតាំគ្នាចាប់ យកទៅចិញ្ចឹមថែក្បុកក្នុងផ្ទះ បង្រៀននិយាយ តាមចំណង់របស់គេ ដូចគ្រាដែលគេចិញ្ចឹមសត្វលោកកេត ដូច្នោះឯង ។

ប៉ុន្តែ ដោយខ្វះចំពោះការនិយាយបញ្ជាក់នូវគំនិតដ៏ពិតៗរបស់ក្បុកដែលជាហេតុធ្វើឱ្យមនុស្សខឹង មិនគាប់ចិត្តចំពោះគំនិតថ្លង់នោះ, សេកគិនិយាយធ្វើគ្រាប់តែតាមតែពាក្យ ដែលក្បុកជានឮពីបបូរមាត់របស់មនុស្សតែប៉ុណ្ណោះឯង ។

អណ្តាតជាអាទិកន្លង

ស្លាប់ជីងរស្លុងជីង ពីព្រោះអណ្តាត

× × ×

រឿងព្រេងនឹងរឿងបុរាណប្រទេសជប៉ុន

(តទៅ)

លោក វ៉ិយ-ប៊ុក រៀបរៀង

គំរូកតញ្ញូតាធម៌នៃបុត្រម្នាក់

លោកកុម៉ាតហ៊ូកាលនៅជាកុមារ មានចិត្តស្រឡាញ់មាតាបិតាគន់ពេក ព្រមទាំងការគោរពនឹងមានកតញ្ញូតាធម៌ចំពោះមាតាបិតាជាអនេក ។ លោកកុម៉ាតហ៊ូ មិនដែលធ្វើឲ្យមាតាបិតាព្រួយចារម្ដងម្ដាសោះ ។ លោកបានធ្វើតាមចិត្តរបស់មាតាបិតានៃលោកទាំងអស់ ។ មាតាបិតាលោកមានចំណង់ចង់បានអ្វី លោកផ្គាប់ឲ្យត្រូវចិត្តបាន, លោកជួយធ្វើកិច្ចការផ្សេង ។ ដទៃទៀត ដូចជាចំអិនម្ហូបអាហារ នឹងគេហកិច្ចទាំងអស់ ដោយចិត្តមុខសោមនស្សជាដំបូង ។

មិនត្រឹមតែប៉ុណ្ណោះ គេតែងឃើញលោកកុម៉ាតហ៊ូទៅចិញ្ចឹមនំតាំងដើម្បីយកមកធ្វើម្ហូបក្នុងគ្រួសារ, ការណ៍ដែលកិច្ចមន្ត្រីនៃទំតាំងមួយចំនួនលោក ដែលមុនចិត្តក្តីបន្ទប់ចិត្ត ឬទាំងប្អូនប្រុសនឹងប្អូនស្រីតូចដែលចង់ពីក្រោយខ្នងដើរលេងកំសាន្តសប្បាយ ។

លុះចំរើនធំឡើង លោកតែងតែជ្រាបដោយជាក់ច្បាស់អំពីការលំបាកនៃមាតាបិតាចំពោះខ្លួនលោក ។ ដោយលោកគិតឃើញថា មាតាលោក បានចំណាយលោក រហូតដល់លោកមានអាយុ ៣ ឆ្នាំ ។ បិតា

របស់លោក តិតមែន តែក្រុមឲ្យសម្បត្តិ ចុំខ្ពែងចង់ញាតុំផ្សែង ។ សម្រាប់ក្មេងលេងជារបស់ ឪពុកម្តាយ ដែលកុមារតូចតែងតែលេង ។

លោកកុមារតូច ដល់តិតពីគុណបការរបស់មាតាបិតាដូច្នោះ ក៏និយាយថា គុណដ៏ប្រសើរនេះ អញមិនអាចនឹងសងគុណវិញបានឡើយ ។

លុះលោកមានវ័យវ័ឌ្ឍនាការចំរើនជាំឡើង លោកទស្សាហ៍ศึกษาសៀវភៅពួកសិល្បៈមិបណ្ឌិតចំនួន ដែលជនជាតិដ៏ប៉ុនប្រើនបូលចិត្ត ។ ក្នុងពួកសៀវភៅសិល្បៈមិបណ្ឌិតចំនួននោះ បានពណ៌នាដោយសព្វគ្រប់ អំពីអាកប្បកិរិយានឹងកាយវិការរបស់ក្មេង ចំពោះមាតាបិតាខ្លួន ។ គឺគោលថា កូនមិនត្រូវស្តោះទឹកមាត់ ស្លាប ក្អក ឬកណ្តាស់ ចំពោះមុខមាតាបិតាឡើយ កូនត្រូវមៀងមើលមាតាបិតាដោយចក្ខុដ៏ស្រទន់ស្រទាប, អេះអមាស់ដូនលោក ឪពុកបំរើគោរពអាហារដែលសល់អំពីលោកទាំងពីរ ។

លោកកុមារតូច តេញចិត្តយ៉ាងក្រៃលែង ឪពុងតំរូវនៃកតញ្ញូតាធម៌ដែលគេបានផ្សាយឈ្មោះលោកយ៉ាងខ្ចរខ្ចាយ នៅបុងបួរាប្រទេស ។

កុមារតូច តេញចិត្តខាងរឿងត្រួតចិនខែខាងអាជ្ញាធ្វើ ជាធំតាមៃមន្ត្រីធំម្នាក់នាម តូអែនយួ (ប្រែថា ស្វាបច្ចាំកាធំ) ។

ក្នុងរឿងនេះ មានសេចក្តីថា ព្រះចៅអធិរាជចិនខ្វល់ត្រាស់បង្គាប់ឲ្យលោកតូអែនយួធ្វើកណ្តឹងមួយយ៉ាងធំ ឲ្យមានសូរលាន់ឮឆ្ងាយ ។

លោកគ្រូអែនយូ កំហៅជាងរំលាយលោហធាតុយ៉ាងជំនាញម្នាក់មក ហើយ លោកយកស្ពាន់លាយជាមួយមាស ដើម្បីឲ្យកណ្តឹងលាន់ឮល្អ ហើយយកប្រាក់លាយថែមទៀត ដើម្បីឲ្យមានសំឡេងស្រួយរង៉ិ, តែលទ្ធផលនៃការលាយនោះ មិនបានសម្រេចដូចបំណងឡើយ; តមក លោកក៏បានទទួលព្រះពរជនិកាវ ព្រះពៅអធិពរដាថា បើលាយលោហធាតុជាលើកទីបីមិនបានលទ្ធផលទេ ខ្ញុំនឹងគ្រាស់បង្កាច់ ឲ្យគេកាត់ក្បាលលោកគ្រូអែនយូជាអវសាន ។

ខណៈនោះ នាងអាជូក៏ថ្វៃ ជាធីតាលោកគ្រូអែនយូ ទំលក់គ្រឿងមាសប្រាក់ដោយសម្ងាត់ ដើម្បីឲ្យបានសោហ៊ុយចំណាយក្នុងការរៀបការ តាមសារស្តីបណ្តែតម្នាក់ឲ្យជួយតិចតួចរឿងនេះ ។ តាមសារស្តីបណ្តែតនោះ ក្រោយដែលបានបើកសៀវភៅតម្រាផ្សេង ។ ព្រមទាំងតិចតួចមើលរូបគំនូរខ្មាំ តាមជោគជតាពសី ក៏ធ្វើយតបទៅនាងវិញថា " មាសប្រាក់ ខ្ញុំឯស្ពានជាលោហធាតុសម្រាប់ធ្វើតួកណ្តឹងនោះ មិនរលាយបូលគ្នាទេ លុះណាតែ មានលោហិតក្រហាចារមួយរូបបូលទៅលាយគ្នាជាន ទើបលោហធាតុទាំងនេះ រលាយបូលគ្នាបាន " ។

លំដាប់តមក លោកគ្រូអែនយូ កំពុងសោធការរំលាយលោហធាតុនោះជាលើកទី ៣ ។ ក្នុងពេលនោះ នាងអាជូក៏ថ្វៃ ក៏ពោលថា នាងចង់ឃើញកិច្ចការដែលបិតាធ្វើឲ្យបានជិតបន្តិច, ក្នុងពេលលោហធាតុកំពុងក្តៅ

រលាយ, នាងក៏លោតចូលទៅក្នុងឡរំលាយលោហធាតុ ហើយស្រែក
ថា "ដោយអំណាចកតញ្ញូតាធម៌ចំពោះបិតាខ្ញុំ សូមឲ្យលោហធាតុនេះ
រលាយចូលគ្នាជាសាច់មួយ" ។ ភ្លែលនោះ កណ្តឹងក៏តោតឡើងបញ្ចេញ
រូបកងយ៉ាងល្អស់ប្រាកដ មានទម្រង់និងពណ៌សម្បុរយ៉ាងវិសេស មាន
សំឡេងលាន់ឮខ្ទាំងជាងកណ្តឹងឯទៀត, ទៅក្នុងសួរនោះ មានសំឡេង
ដូចជាស្រែកថ្ងូរដូច្នេះ . . . ។

កុមារតូចតូចតែងចិត្តនឹងអានរឿងបែបនេះ ហើយមានចំណង់ចង់
តាំងខ្លួនជាវីរបុរសដូចរឿងខាងលើ ។ តែជីវិតរបស់លោកបិតានៅ
ដោយស្រួល គ្មានត្រឹត្តិការណ៍ដូចខាងលើនេះសោះឡើយ ។

លោកកុមារតូចតូច ប៉ុតនោះដល់អាយុ ៧៥ ឆ្នាំ កំពុងបានចំតែញ
ការណ៍យកចិត្តទុក្ខម្ល៉ាយដ៏ល្អស្អាត ដែលគេអាចកាប់បញ្ចូលឈ្មោះលោក
ទៅក្នុងពួកវរជននោះ ។

តែលោកកុមារតូចតូច មានចិត្តសោមនស្សយ៉ាងលើសលុប ដោយ
មាតាបិតាលោកបិតានៅដល់អាយុជាង ១០០ ឆ្នាំ ។

មាតាបិតាទាំងនោះ ពិតមែនតែកូនច្រូស-ស្រី បានចំតែញ
ការណ៍យកចិត្តទុក្ខគ្រប់ៗគ្នា តែនៅមានសេចក្តីព្រួយចិត្តជាខ្លាំង ព្រោះខ្លួន
លោកកាន់តែចាស់ជរាទន់ខ្សោយទៅ ។

លោកកុមារតូចតូច - ក្នុងរយៈវេលាដែលខ្លួនរស់នៅអស់ពេលជិយូរ

លង់នោះ ចានជួយបង្អង់ខ្សែចក្តីខ្លះនៃមាតាចិតា, តែសេសជាង់នេះ លោកពុំអាចបំបាត់សេចក្តីចាស់ជារបស់មាតាចិតាចាន ។ លោកចាន រិះគិតមធ្យោបាយសព្វយ៉ាង ចំពោះរឿងនេះ ។ ថ្ងៃមួយ លោកចាន រកឃើញមធ្យោបាយមួយដូចតទៅនេះ ៖

លោកទៅផ្សារទិញវត្ថុសម្រាប់ក្មេងលេង តិស្តរ ១ ប្រដាប់ចាត់ ស៊ី ១ ខន្លាយធ្វើពីក្រដាស ១, ហើយលោកទិញអាវ "តម៉ូណូ" មួយ ជាអាវមានដៃធំទូលាយ ដែលកុមារនៃជនជាតិដប៉ុនឱយមប្រើប្រាស់ ។ កុមាតហ្ស៊ូ ចានយកថ្មស្រីមួយដើមទៅចុះចំមុខផ្ទះលោក, ទៅចុងថ្មស្រីនោះ លោកយកក្រដែលធ្វើពីក្រដាសពណ៌ទៅចង ។ ព្រោះប្រទេសជប៉ុន ពេលពិធីបុណ្យឃុនែ មាតាចិតាដែលមានកូនមានអាយុថយពី ៧ ឆ្នាំ តែងធ្វើរបៀបនេះដែរ, និមិត្តរូបនេះ សម្រាយឃើញថា កុមារទាំងនេះ មានសភាពដូចត្រី ដែលឡើងទៅលើស្ទឹង តស៊ូនឹងចរន្តទឹកហូរប្រាស់ ដូច្នោះ ។

មាតាចិតាលោកកុមាតហ្ស៊ូ ដែលមានអាយុជាង ១០០ ឆ្នាំ មានចិត្តសង្ស័យ ដោយឃើញដើមថ្មស្រីពីរដើមមួយដើម ចុះចំមុខផ្ទះ ហើយនឹងក្រដែលធ្វើពីក្រដាសពណ៌ ហើយនឹងលោកកុមាតហ្ស៊ូពាក់អាវតម៉ូណូ ពណ៌ផ្កាកុលាបស្រស់ ដូចក្មេងពាក់លេង, ដើរត្រេតត្រែតលើដី ដូចក្មេងមិនចាន់ចះដើរ, គោលការណ៍មិនល្អស់ដូចពាក្យចចាមអារាម ។

ខ្ញុំស្តាប់ហើយសេចក្តីនឹងខ្ញុំយល់ដែលធ្វើតាមគ្រប់ជាស៊ុ ។

ការពិត្យយាមក្នុងដូចនេះ មកពីលោកមានចំណងចង់ឲ្យមាតាបិតាវិលទៅអស់គោលដៅយូរតទៅទៀត ដែលគេពុំបានជាកតញ្ញូតាធម៌ចំពោះមាតាបិតាក្នុងគ្រានោះ ។

ចប់រឿងលោកកុមារតិស្សៈ ។

រឿងព្រេងទាក់ទងដោយព្រះពុទ្ធសាសនា

រឿងព្រេងដែលទាក់ទងដោយ ព្រះពុទ្ធសាសនាចែកទាងមហាយាន គឺ: រឿងរុក្ខជាតិគឿ១, រឿងព្រះជាតិទាំង៦រូប១, រឿងចំណាប់នៃព្រះសង្ឃមួយអង្គ ១, រឿងដើមស្រល់ក្នុងព្រៃក្រុងតិម្ពរុ ១, ។ បណ្តារឿងទាំង ៤ នេះ យើងនឹងតម្កល់រឿងរុក្ខជាតិគឿជាមុន ។

១-រឿងរុក្ខជាតិគឿ

នៅប្រទេសជប៉ុន មានរុក្ខជាតិគឿខ្លះអាយុ ៥០ ឆ្នាំ ខ្លះអាយុ ១០០ ឆ្នាំ ខ្លះអាយុ ១៥០ ឆ្នាំ ខ្លះទៀតអាយុ ៦០០ ឆ្នាំ, រុក្ខជាតិនេះពិតមែនតែរុក្ខជាតិមានដើមធំ តាមកំណើតរបស់វា ប៉ុន្តែគេអាចធ្វើឲ្យសមែក ស្លឹក ផ្កា ឲ្យទៅជាតូចតាចបាន ។

រីឯនេះ ដំបូងគេយកគ្រាប់ទៅដាំក្នុងដបកែវតូច ។ លុះវាដុះចេញពន្លកចាក់ឫសជាច្រើន វាដញ្ចក់យកជាតិដីក្នុងកែវនោះអស់ហើយ គេយកវាទៅដាំក្នុងដបកែវធំបន្តិច ហើយគេធ្វើតាមវិធីនេះតទៅទៀត ។

រុក្ខជាតិនេះ ដោយគេឲ្យជាតិដី ដែលជាអាហារបស់វាមិនគ្រប់គ្រាន់ គឺទៅជាតូចខាប, លំងាប់តមក គេយកមែកវាច់ចងព័ទ្ធរវាងគ្នានឹងគ្នា មែកខ្លះចងផ្លាជនឹងគល់ ធ្វើឲ្យពាល់តែវាំងនុះបានដោយលំបាក ។

ដោយវិធីនេះ គេអាចធ្វើរុក្ខជាតិដែលមានអាយុច្រើន ឲ្យមានកំពស់នៅតែត្រឹមជាង ៥០ សង្ទីម៉ែត្រ ឯគល់វាមានទំហំ ៤,៨ ឬ ១០សង្ទីម៉ែត្រប៉ុណ្ណោះ ។ រុក្ខជាតិរបៀបនេះ មានមនុស្សជាច្រើនតែងចូលចិត្ត ។

មានសេចក្តីដំណាលថា: លោកតូម៉ូណារ៉ា និងភរិយា មានតែរុក្ខជាតិតឿ ៣ដើមជាកោតព្រឹត្តិ: ១-រុក្ខជាតិធ្យាំ អាយុ ១០០ ឆ្នាំ. ២ រុក្ខជាតិស្រល់ អាយុ ១២០ឆ្នាំ, ៣-រុក្ខជាតិអេរ៉ាប្ចី អាយុ ២០០ ឆ្នាំ ។ អ្នកទាំងពីរព្យាយាមថែរុក្ខជាតិតឿដើមនេះដាច់ខាត តែងស្ងាបអង្អែលដោយសេចក្តីស្នេហាពន់ពេក, ដូចជាអ្នកតំណាញ់តែងតន់សម្បត្តិរបស់ខ្លួន ឬដូចជាមាតាយើញកូនដូច្នោះ ។

អ្នកចាស់ពីរក្រណាស់ ជួនកាលខ្វះអាហារបរិភោគធម្មតា តែបើពុកជាយ៉ាងណាក៏ដោយ ក៏អ្នកទាំងពីរ មិនដាច់ចិត្តយកដើមឈើទាំង ៣ ទៅលក់យកប្រាក់មកចិញ្ចឹមជីវិតបាន ។ គេលនោះ លោកតូម៉ូណារ៉ា និងភរិយា បិតនៅក្នុងការលំបាកជាខ្លាំង បានបរិភោគតែនំមួយ ដែលធ្វើពីដើមម៉ាស្ទូ ហើយពុកមួយទៀតពេលក្រោយ, អ្នកទាំងពីរមានស្ថានភាពធ្ងន់ធ្ងរលែង ព្រោះគេលនោះ ជាគេលព្រឹកព្រហាមមាន

ព្រលឹងថ្នាក់ចុះគេញផែនដី ..។

អ្នកភាំងពីរ កំពុងឯងនៅក្នុងផ្ទះ ស្រាប់តែឮសូរគេគោះទ្វារ... , អ្នកភាំងពីរក៏បើកទ្វារ ក្រេឡេកទៅឃើញព្រះសង្ឃមួយអង្គ ស្បែកដណ្តប់សំពត់ពណ៌ប្រផេះទើមទ្ទួមកបិណ្ឌបាត ។

ព្រះសង្ឃនោះមានពុទ្ធដីកាថា " អាត្មាភាំងភ្ញាំងណាស់ សូមអ្នកមេត្តាឱ្យអាត្មាចូលផ្ទះកន្លែងនេះបានមួយស្របក់ " ។

លោកតួម៉ូណាវ៉ ទូលទៅព្រះសង្ឃវិញថា " មិនបាន:ទេ, ខ្ញុំព្រះករុណាក្រលំបាកវាន់តេកណាស់ មិនអាចទទួលព្រះតេជព្រះគុណបានឡើយ ហើយខ្ញុំព្រះករុណាគ្មានតែម្តុំប្រគេនព្រះតេជព្រះគុណផង កំពុងតែខ្វះខ្វលំបាក ដោយការស្រែកឃ្លានខឹងភ្លើងតេក " ។

ព្រះសង្ឃនោះបានមានពុទ្ធដីកាភាំងភ្ញាំងញាក់ថា: អាត្មាដែលមកសុំនេះ កន្លងខាមនៃព្រះសម្មាសម្ពុទ្ធជាម្ចាស... តែះបើលោកមិនអាចទទួលអាត្មាភ្លាន អាត្មាសូមលាហើយ" , ថាតែប៉ុណ្ណោះ ក៏ងើមទ្ទួហួសទៅ កន្លងពេលដែលកំពុងឮភ្លាកព្រលយាំងភ្លាំង ។

ក្រោយមកអ្នកភាំងពីរគិតគ្នាថា តិចដែលយើងធ្វើនេះ មិនសមរម្យទេ ។ ភរិយាគេលថា "យើងខុសធំហើយ មកបណ្តេញព្រះសង្ឃដែលមកសុំផ្ទះកន្លងយើង, ប្រសិនបើ ព្រះសង្ឃនេះសុគតទៅដោយសារសេចក្តីស្រែកឃ្លានខឹងភ្លើង តើយើងមានទៅជួសជាយើងណាទៅ" ។

លោកភូម៉ូណារីតបទៅកវិយាវិញថា "តើយើងធ្វើដូចម្តេច" ? ។

កវិយាឧយាយថា "បើពុកជាយ៉ាងណាក៏ដោយ ព្រះសង្ឃនេះមានសេចក្តីសំបាកជាងយើងទៅទៀត លោកគ្មានទីជ្រកសោះ ឯព្យុះព្រឹលកំពុងតែបោកបក់មកយ៉ាងខ្លាំងផង ឯងចូរតត់តាមលោកទៅ ទាំលោកមកផ្ទះយើងវិញ ឯចង្ហាន់នោះចាំយើងលៃលកតាមក្រោយ" ។

លោកភូម៉ូណារី យល់ស្របតាមសំដីប្រពន្ធ. កំពាក់ស្បែកជើងសម្រាប់ដើរលើទឹកកកតត់ទៅតាមព្រះសង្ឃនោះ លុះដើរបន្តិចទៅ កំបានឃើញព្រះសង្ឃនោះដួលនៅលើព្រឹលទន់កជិតគេហដ្ឋានមួយ ។ លោកភូម៉ូណារីឃើញដូច្នោះ កំគ្រាហ៍ទាំមកកាន់ផ្ទះខ្លួន រួចនិយាយទៅកាន់ប្រពន្ធថា: "តើយើងមានអ្វីប្រគេនលោកធាន់" ?

កវិយាឆ្លើយថា "យើងមានតែទំមួយ ដែលយើងរំលែកពុកតែម្សៃមិញ" ។ លុះប្រគេនហើយ ដោយសេចក្តីស្រេកឃ្លានខ្លាំង, លោកកំធាន់ទៅ ។

លោកភូម៉ូណារី បានក្រេះឡកមើលទៅ ឃើញព្រះសង្ឃនោះនៅខ្លាំង កំពោលទៅកាន់កវិយាថា "ត្រូវជុតក្តៅណ៎" ។

កវិយាពោលថា "យើងមិនអាចជុតក្តៅដ៏ថ្កានេះ ព្រោះយើងគ្មានទីសំសោះ" ។

លោកតូម៉ូណាវ៉ៃ ពោលបន្ទន្ទមថា យើងមិនអាចដុតភ្លើងកំដៅបានទេឬ ។

កវីយោពោលថា "យើងគ្មានចំណាំងឈើមួយកំណាត់សោះ បើទីនេះសុះត្រាតែ....." ។

លោកតូម៉ូរ៉ណា កំពោលថា "សុះត្រាតែ.... សុះត្រាតែយើងយកក្តួជាតិគឿនោះមកដុតទើបបាន" ។

រឿងនេះ អ្នកប្រាជ្ញតូរកត់សំគាល់ថា អ្នកទាំងពីរ លុះនិយាយគ្នាមកដល់ភាក្យថា យកក្តួជាតិគឿទៅដុតសុះ ក៏មានសេចក្តីជ្រួលច្របល់ក្នុងចិត្តជាខ្លាំង, ម្យ៉ាងទៀត បើអ្នកទាំងពីរនេះលះបង់ក្តួជាតិគឿទាំង ៣ ដើម គឺមិនមែនយកខ្លួនទៅធ្វើពលិកម្មទេ គឺយកដួងចិត្តរបស់ខ្លួនដ៏ស្អាតបរិសុទ្ធទៅធ្វើពលិកម្មវិញ ។

លោកតូម៉ូណារ៉ មានទឹកភ្នែករលេងរលោង ពោលថា យើងមិនត្រូវទ្បើព្រះសង្ឃនេះអនិច្ចធម្មដោយសារតែនេះទេ ត្រូវតែយកក្តួជាតិនេះក្តើទុសដុត ។

ពេលនោះ កវីយាកំដើរទៅយកឈើ ធុយ៉ា អាយុ ១១០ ឆ្នាំនោះមក នាងមានទឹកភ្នែកហូរសេស្រាក់ ហើយនាងក៏បាចំលេបីធុយ៉ាបោះទៅក្នុងភ្លើងទៅ ។ នាងមានចំណងចង់ស្រោចស្រង់ឈើពីរដើមទៀតតែភ្លើងឥតត្រាប្រណីទ្បើយ, ឈើធុយ៉ាក៏ត្រូវឆាបំណើភ្លើងអស់គ្មានសល់;

តមក កំត្រូវយកឈើស្រល់មកកាប់ចោះរៅក្នុងក្តើនក្តើនទៀត ។ ប្តីប្រពន្ធ
គិតលៃខុសឈើអេះប៉ូ តែខុសមិនបាន ដោយក្តើនធេះអស់ឈើ ២
ដើមហើយ ម្ល៉ោះហើយទាន់ជាតវិយោកយកឈើអេះប៉ូដែលមានអាយុ
២០០ឆ្នាំ កាប់ចោះរៅក្នុងក្តើនជាដំបូងបង្អស់ ។

លុះព្រះសង្ឃនោះបានអន់ចិត្តហើយ, អ្នកតាំងពីរកំត្រេកមើលមុខគ្នាដោយសេចក្តីព្រួយយ៉ាងក្រៃលែង ។

២- រឿងព្រះធម្មបិណ្ឌទាំង ៦ រូប

មានកសិករម្នាក់ឈ្មោះ មាត់ស៊ីជា ជាអ្នកមានក្នុងធម៌តមើលមិនសូវច្បាស់, ប៉ុន្តែ ជាអ្នកតែងតែចូលចិត្តស្តាប់ធម៌ទេសនាជានិច្ច ។

ក្នុងគ្រាដែលលោកធ្វើស្រែ លោកបានឆ្លៀតពេលមួយដងមួយកាល អញ្ជើញភ្ញៀវជាព្រះសង្ឃ ឬក៏មិនដូច្នោះទេ ក៏ទៅនិមន្តព្រះសង្ឃមកបួងសួងឲ្យ, តែដោយលោកមានក្នុងធម៌តមើលតិចសូវច្បាស់ លោកតែងតែនិមន្តព្រះសង្ឃបួងសួងដោយឯកន្តចិត្ត ។

ថ្ងៃដែលលោកគោរព ដោយសេចក្តីស្មោះស្ម័គ្រ ព្រោះលោកគិតឃើញថា ព្រះសង្ឃបួងនេះ ជាដំណាងនៃព្រះសម្ពុទ្ធជាម្ចាស់ ដែលទ្រង់ដឹកនាំសត្វលោកមនុស្សលោកទូវត្តតុកាំរៃសច្ច, ក្នុងគ្រាដែលលោកនិមន្តនោះ ដួនកាលលោកលើកម្រាមដៃប្រណម្យ សំដែងតាំងចិត្តចោះព្រះសង្ឃថា ដួនកាលលើកដៃចុះ-ឡើង ដើម្បីពោលធម៌ ឬសិក្សាធម៌ ។

លោកតែងធ្វើអភិវន្ទនាការចំពោះព្រះពុទ្ធអមិតាភៈ(១) ដែលជាធំ
ឆ្នាត់មានសភាពជាប្រុសកំឡោះ មានវង់មូលនៅលើព្រះលលាដ(ថ្ងាស)
ជាទិព្វិត្តរូបនៃតតិបណ្ឌិត ព្រះនេត្រចិញ្ចើមធំ ព្រះហស្តនៅលើព្រះឧទរ
ព្រះមត្តង្គុលី (ម្រាមមេដៃ) ខ្លាំង ។

ជាការបម្រុក, លោកមានចិត្តគោរព ទុំធំមានសេចក្តីស្រឡាំងស្រែង
ចំពោះព្រះរូប. ព្រះអង្គម្ចាស់ក្សត្រី « ក្វាន់ឧន » ដែលលោកតណិនា
ជាញឹកញាយចំពោះរឿងនេះ ។

តាមសេចក្តីដំណាលក្នុងរឿងត្រង់ជំពូនោះថា « ព្រះអង្គម្ចាស់
ក្សត្រី ក្វាន់ឧន ទ្រង់មានព្រះរូបធោមលោមតណិស្រស់ប្រឹមប្រិយប្រ-
កបដោយព្រះរាជហឫទ័យដ៏មហាសប្បុរស ។ ដោយហេតុនេះហើយ
បានជាព្រះនាងទ្រង់បានរួបរួមសេចក្តីទុក្ខ ជាមួយសត្វលោកទាំងអស់,
ព្រះនាងទ្រង់បានជួយសម្រាលសេចក្តីទុក្ខនៃសត្វលោកទាំងអស់ដែលអាច
ជួយបាន ។ ព្រះនាងទ្រង់ព្រះតម្រិះទៅកាន់សត្វដែលវង្វេងទុក្ខទោសក្នុង
នរក, ទ្រង់មានព្រះរាជហឫទ័យអាណិតអាសូរដល់សត្វដែលវង្វេងទុក្ខឈឺ

---

(១) ប្រែថា អ្នកមានពន្លឺ ឬរស្មីភាពពុំអស់ ។ តាមសេចក្តីដំណាលក្នុងគម្ពីរលទ្ធិមហា-
យានថា ព្រះអមិតាភៈនេះ ទ្រង់ប្រតិស្ឋានទៅឯឋានសុខាវតី ។ មហាយានពួកខ្លះ
ហៅថា អមិតាយុស ប្រែថា ព្រះពុទ្ធមានព្រះជន្មវែងឥតគណនា ។ ហៅខ្លីថា អមិតៈ
ហៅក្វាយថា អមិដា ឬ អយីដា ។ (មានសេចក្តីពិស្តារក្នុងគម្ពីរលទ្ធិមហាយាន ខាងលទ្ធិហីន-
យានពុំមានឱយាយទេ) ។

ចាប់ខ្លួនប្រាណកន្លងទៅនោះ ។ មានកាលមួយថ្ងៃ ព្រះនាងទ្រង់យាងចុះ
ទៅក្នុងស្ថានឧទ្យាន, កន្លះពេលនោះ ព្រះនាងទ្រង់ជ្រាបសំដែងជាដំហាយ
ចំពោះមុខសត្វនោះ ពាល់តែត្បូងនេះ ក្រឡេកមកឃើញព្រះនាងទ្រង់
មានរូបឆោមស្រស់ប្រិមប្រិយ ព្រមទាំងមានឱភគ្រែកគ្រែ ប្រកបដោយ
មហាករុណា ។ ពេលនោះ ក្លួកសត្វនោះមានចិត្តសប្បាយរីករាយឥតឧបមា ។
ព្រះនាងក៏ចាន់ឧន ទ្រង់ជញ្ជូរស្ទ្រីក្តីព្រោនព្រាតជុំវិញសត្វនោះ
ខៅព្រះភ្លៅមានបុប្ផាដុះចេញមកយ៉ាងស្រស់, ដោយអានុភាពនៃព្រះនាង
ទីដែលសត្វនោះដេកនៅក្នុងភាស ខៅជាស្ថានមួយយ៉ាងសប្បាយ ដូចស្ថានសួគ៌» ។

លោកម៉ាត់ស៊ុដា ខេញចិត្តរាងទស្សនាព្រះនាង ក្នាន់នឧយ៉ាងក្រៃលែង ។ ក្រោះព្រះបដិមាកនេះ មានទ្រង់ព្រះយង្សដ្ឋាន ព្រះបដិមាកខ្លះទ្រង់សណ្តិត, កន្លះទ្រង់ឆ្លង, កន្លះទ្រង់ផុសចេញពីបទុមជាតិ, កន្លះ មានអាការដូចជាទ្រង់ព្រះសណ្តាប់ទ្រូងសំឡេងពួញយំគង្វរជាយការឈឺចាប់នៃសត្វលោកទាំងឥស់, កន្លះ មានព្រះហស្តជាច្រើនហើយមានខ្នងដូចជាទ្រង់ស្ងាបអង្អែលសត្វលោក ឲ្យធុតពីសេចក្តីទុក្ខសោក ។

(មានត)

ពឿងស្រីគ្រប់ល័ក្ខណ៍

(តមក)

លោក ឈុក-វើរ រៀបរៀង លោក ផេង-ជ្រើរ ពិនិត្យ

ទៅឯត្រើយស្ទឹងមាន ខំខន្ធឹមគ្នាលើមកខ្ពង់ខ្ពែងភ្លឹង បែរមុខមកកេស្ទឹង គ្រលឹងត្រេកអរខាំងគួរប្រឹងផ្ចង់ផ្តងលេងសប្បាយយ៉ាងរីករាយ ។ នៅលើពុងឈើតាលខ្ពស់ត្រដួចដែលដុះក្បែរនោះ លលកឈ្មោលញីប្រឹងបូលរនាំគួរជាទីរំភើបចិត្ត ពាំងនេះហាក់ដូចគេប្រគំដន្ត្រីដូចដំណើរ ឧឆប្រសិទ្ធិពរចំពោះសិរីរុទ្ធ្យ សុំឲ្យអ្នកចរកៅដោយសុត្ថិភាព ។

ចំពូក ៣

ទៅក្នុងភូមិផ្ទះធនសេដ្ឋី ការប្រព្រឹត្តិទៅ មានសភាពដាប្រក្រតីដូចពេលមុនៗរៀងមក។ សោកណា ដោយមានស្ងួតខ្ទឹងចន្ទីជាដំនួយ តែងចំពេញការក្នុងផ្ទះឥតខ្វះបន្ទោរត្រង់ណាឡើយ។ កិច្ចត្រួតត្រាការក្រៅផ្ទះជាការនៃធនសេដ្ឋីជាបិតា ។ កូនឈ្មួលប្រុសស្រីនាំគ្នាធ្វើកិច្ចការសស្រាកសស្រាំឥតដែលមានពុតត្បុតម្តងសោះ ក្រោះចៅហ្វាយទាយមានចិត្តទូលាយឥតប្រកាន់បក្សា ចែកចាយម្ហូបចំណីស្មើភាគគ្នា ទឹងតាមឧបការគុណជូនស្រាល ។ ម្ល៉ោះហើយកេរ្តិ៍ឈ្មោះធនសេដ្ឋីលេចឮខ្ទរសុះសាយ ទៅក្នុងភូមិស្រុកជិតឆ្ងាយ ថាជាអ្នកមានជាមិសប្បុរស ចំពោះកូនឈ្លួលចំពោះមនុស្សដូតីទាងទឹងស្មមយាចក អ្នកកំសត់ខ្ពុតតាំងឡាយ ។

ជាធម្មតា នៅពេលរះសៀលប្រហែលម៉ោងប្រាំ តែកាលណាកិច្ច

ការផ្ទះរួចសព្វគ្រប់ហើយ សោភណាសេដ្ឋីធីតា មួយអន្ទៅដោយសូភី ទីឥនាងចន្ទីជាបរិវារ តែងនាំគ្នាទៅដួតទឹកដំរះកាលឯកំពង់ នៅមាត់ស្ទឹងជារាល់ថ្ងៃ ។

ថ្ងៃនេះ ពេលដែលយុវតីទាំងបីប្រុងប្រៀបទឹងផ្ទាស់សំពត់អាវ ដើម្បីចុះងូតទឹក ស្រាប់តែមានឈើគល់មួយអណ្តែតសៀរៗមានសត្វច្រាំងមកប៉ះជាប់ទឹងកំពង់នោះ ។ មានបុរសម្នាក់ អាវខោកណ្តាចប្រៀកងៀត សក់ដុះខ្ទេចខ្ទាក់មកលើស្មា ភុកមាត់ស្រមាម មុខស្មុកស្មាំងក្អែកស្មុក ទំនៅលើនោះ ដូចសត្វតន្តិក្កង៍ដូរទឹកដំឡើន ។ ដោយសេចក្តីអៀនខ្មាស បុរសនោះគិតថា មិនហ៊ានជាតមើលនារីទាំងនោះឡើយ ។ ក្នុងអង្គុយខ្នលាក់មុខ ដោយទឹកចិត្តទីងាសនាអាត្រក់បេះខ្លួន ។

សូភីស្រែកថា: «ឃើ! មើលមនុស្សចំកួតនេះ មកពីណាខ្លួនអាត្រាតយាំងដូច្នេះ!" ។

ចន្ទីស្រែកបន្ទាន់គ្នាទៀតថា: "ឃើ! មនុស្សនេះ តឹមនុស្សទេតួាតចង្រៃទេ! រុញច្រានវាឲ្យអណ្តែតចេញទៅឆ្ងាយខ្ពើមណាស់! រួចហើយតំណាតនាស្ពោះទៅខាង កុយ.. កុយ .. ។

ឃើញអាតប្បកិរិយាពាសីទាំងពីរមិនសមរម្យដូច្នោះ សោភណាមានវាចាយ៉ាងសុភាពទៅកាន់សូភីនឹងចន្ទីថា: "បងអើយ កុំពោលអ្វីមិនសមទេ

មនុស្សយើងគ្រប់បែប គ្មានទរណាចង់ខ្វះទេ ចង់តែសុខ គ្មានទរណាចង់ក្រទេ ចង់តែមាន ចង់តែសប្បាយ ដែលគ្នាជួកគ្នាទៅក្នុងស្ថានការណ៍ដ៏ដុនដាបស្ទើរតែមិនឡើងយ៉ាងនេះ យើងក៏ពុំដឹងដើមហេតុ ជាមកពីអ្វីៗបានទេ គួរយើងអាណិតអាសូរមេត្តាគ្នាផង ព្រោះគ្នាក៏ជាមនុស្សម្នាក់ដូចយើងដែរ ណាបង ! ។

បន្ទាប់ពីធ្វើយតបអ្វី ស្រាប់តែគាត់ងើបទៅផ្ទះ ហើយដំណរបងទសេដ្ឋីថា:

-សូមដំណរប្រសាសន៍ព្រះគេជព្រះគុណ! មានមនុស្សទៅត្បាតពីណាអត្រាត ខ្ញុំលើតល់ឈើដូចគ្នាត់ អណ្តែតមកប៉ះជាប់ទៅកំពង់យើង ។

ឮដូច្នោះ ដោយខ្លួនឯងជាប់ជាអ្នកមានធម៌សប្បុរស បងទសេដ្ឋីឆ្ងល់មួយស្របក់ ទើបសួរថា:

-មនុស្សនោះរបួសធ្ងន់បែបដូចម្តេច ដំឡូតួច សម្លាប់ទៀ? យី! អាសំ.ឡាញ់អញទេដឹង! ហ៎! បងឯងតក្រមានទេះទៅបានឲ្យគាត់ រួចហៅគាត់ឲ្យទៅឯងមកមើល ! យី! អញដូចនឹកសង្ស័យណាស់ ប្លាស់ជាអាសំឡាញ់អញហើយ ព្រោះបាត់ដំណឹងអំពីគាត់ចំនួនជាង ៦ ឆ្នាំហើយ ។ ហ៎! រត់ឲ្យធាប់ទៅ នៅបង្អែបង្អង់ចាំអ្វីទៀត ?

បន្ទាប់ធក់យកក្រមារត់ចុះមកកំពង់ទឹកវិញ ហើយខ្លួនរួបប្រាប់សោតណាថា :

-អ្នកអូន! លោកឪពុកបង្គាប់ថា ឲ្យហៅតាត់ឡើងទៅព្រោះខឹកសង្ឃ័យ
ក្រែងសំឡាញ់បេះសំលោក ដែលឃ្លាតគ្នាតាំងពីយូរណាស់មកហើយ
នោះ ។ សោកណាដ៏កក្ខាល ហើយឆ្លើយតបទៅវិញ ដោយទឹកមុខ
ស្រឡាំងស្រឡំថា:

-មែនហើយ អ្នកបង! លោកចាំខ្ញុំធ្វើដូច្នេះទើបសមទៅតាមច្បាប់
មនុស្សធម៌ កុំថាឡើយជាសំឡាញ់បេះសំលោកចាំ សូម្បីមនុស្សដទៃក៏ត្រូវ
តែធ្វើដូច្នេះដែរ ព្រោះគឺវាសង្គ្រោះជាតរណីយកិច្ច នៃមនុស្សគ្រាំងខ្លាយ។
ប្លែកតែសព្វនេះ តំបាក់ក្រមាទៅឲ្យអ្នកតំសត់យើង ហើយស្រែកប្រាប់ថា:

-ភូ! ចូរយកក្រមានេះស្ងួតឡើងមក លោកខ្ញុំឲ្យភូងឆ្ងាទៅឯផ្ទះ
មានការណ៍ ។

ដោយយល់ថា ឥឡូវដល់ភូមិតេហើយ ត្រូវតែឡើងគោក ទើប
បុរសតំសត់យកក្រមាខោះមកស្ងួតស្ងាត់ក្រៅខោរហែក ហើយចុះលុង
ទឹកឡើងគោក ដើរតាមចន្ទីតាំងមុខក្រៀមស្រពោន តាំងខឹកជាអ្នក
ក្រែងមានហេតុដ៏មិនតប្បីអ្វីកើតមានឡើង ។ លុះទៅដល់ផ្ទះហើយ ចុះ-
រសតំសត់លុតជង្គង់សំពះធនសេដ្ឋី ។ តំលើកដៃសំពះមកវិញ ព្រមតាំង
មានវាចាថា: "សំពះថ្វាយព្រះ" ហើយចង្អុលប្រាប់តន្ទែងឲ្យអាគន្ទុកដន
អង្គុយដំសមគួរ ។ បុរសតំសត់មិនហ៊ានមើលមុខធនសេដ្ឋីចំទេ គឺអង្គុយ
មុខទន្ទុះក្រៀមតាំស្លាប់ ក្រែងមានហេតុជាគន្ធង្ហារម្នាក់កើតឡើង ។

ចំណែកកុដុម្ពីក៍ លុះសំឡឹងសង្កេតមួយស្របក់ ទើបស្រែកថា "សិរីវឌ្ឍន៍ សិរីវឌ្ឍន៍! មែនឬទេ!" ។ អ្នកកំសត់ងើបមុខឡើង សំឡឹងចំធនសេដ្ឋី ស្រាប់តែក្តួលក្នុងទ្រូង ព្រោះអ្នកស្គាល់ជាសំឡាញ់ចេស់ខ្លួនកែវដែរ ។ សេចក្តីរំតើបឡើងមកដល់ដើមក ទឹកភ្នែករៀបហូរចេញមក ប៉ុន្តែអ្នកទាំងពីរញាស្ងួតត់ចប់ជាប់ ទើបធ្វើមតិចៗគាំងគាក់អួលថា: "មែនហើយ ខ្ញុំឈ្មោះសិរីវឌ្ឍន៍!" ។

លុះបានដឹងការណ៍ច្បាស់ហើយ ធនសេដ្ឋីក៏ស្ទុះចាប់ទបសំឡាញ់ ទាញទៅក្រោកឡើង ព្រមទាំងមានសំដីអោតអួលភេញដោយការរំភើបជួបគ្នាដែរ ។ រួចលោកងាកទៅប្រាប់សោភណាដែលទៅដឹងនោះថា:

-កូនស្រី ! ចូរប្រញាប់ ទៅយកទាំងវ៉ាមួយមកម្រាប់មកឲ្យសិរីវឌ្ឍន៍ ហើយចូរមើលធ្វើចាយយ៉ាងឆាប់ៗផង ឮឬទេកូនស្រី ! លោកធនសេដ្ឋីបែរទៅប្រាប់ឈ្លួសម្រុសម្នាក់ថា:

-ឯងនាំសំឡាញ់មកទៅផ្ទះទឹកដម្រះកាយយ៉ាងស្អាត ស្តាប់ចាន ឬទេ?ហើយលោកគោលដោយវាចាយ៉ាងស្និទ្ធស្នាលទៅកាន់សិរីវឌ្ឍន៍ថា:

-ទៅសំឡាញ់! ទៅផ្ទះទឹកដម្រះប្រាណឲ្យស្អាត ឲ្យត្រជាក់ស្រួលសឹមយើងសន្ទនាគ្នាលេង ឈប់ព្រួយទៅ ឯងមកដល់ទីនេះហើយ!

ខាងក្រោយស្ថានកិច្ច ជនទាំងពីរនាក់ ចាប់សន្ទនាគ្នាពីនេះពីនោះ

មានពោលរំលឹកដល់សម័យ នៃការទៅរៀនសូត្រក្នុងសំណាក់លោកគ្រូ អាចារ្យជាមួយគ្នាជាដើម ។ ប៉ុន្តែ អាកប្បកិរិយានៃជនទាំងពីរ មានសភាពផ្សេងគ្នា លោកធនសេដ្ឋីប្រែនទិយាយសំដីធំៗខ្ទាំងៗ ហើយបន្តិចៗ គេឮបួរលោកហៅសំឡាញ់ឱ្យដាក់ឈ្មោះ ឱ្យធំតែម ចំណែកសិរីវឌ្ឍន៍ និយាយសំដីតិចៗថ្នមៗ ក្នុងហាងៈជាអ្នកមានសេចក្តីគោរពក្រែង ខ្មីឮព្រួយបារម្ភ ។ ជួនកាលធនសេដ្ឋី សួរអំពីសេចក្តីខ្វះខ្លួលំបាកដែលសិរីវឌ្ឍន៍ជួបជួបប្រទះក្នុងរយៈកាលនៃការដើរស្វះស្វែងរកស្រីគ្រប់លក្ខណ៍ ប៉ុន្តែលោកមិនហ៊ានបន្ទោសសំឡាញ់អំពីការចេសមុខរឹងរូសទេ គ្រាន់តែបន្ទូលតាក្យថា: អើ! លោកៅដូចជាមិនឆាប់ចិត្តសោះ ស្រីគ្រប់លក្ខណ៍ គួរសំឡាញ់លះបង់ចំណងដឹងគម្រប់ខ្លឹនចេញៅ ។ ដល់ត្រង់រឿងនេះ សិរីវឌ្ឍន៍គ្រាន់តែញញឹម។ មិនហ៊ានធ្វើយតបថាដូចម្តេចសោះឡើយ ។

ខណៈនោះ សោភណាដើរចូលមកដល់ខ្លួនមន្ទីរ ចូលមកគាល់ឪពុក ហើយគេរំលឹកប្រាប់ថា ចង់ជួបលោកហើយ ប៉ា ។

ធនសេដ្ឋីទាំងសំឡាញ់ៅបន្ទូលថា ឲ្យចូលមកអោយ ។ លុះសិរីវឌ្ឍន៍បរិភោគផ្លែឈើហើយ សំឡាញ់ពាំងពីរ កំពប់ផ្តើមពោលសំណេះសំណាលគ្នាៅទៀត អំពីរឿងផ្សេងៗ ។ មានរឿងប្រកបការចិញ្ចឹមជីវិតជាដើម។ សំឡាញ់លោកសេដ្ឋីពោលអំពីជីវភាពខ្លួន។ ដែលខ្លួនបានប្រទះឃើញកន្លងមក នៅលើនៃការធ្វើដំណើរស្វែងរកស្រីគ្រប់លក្ខណ៍ ។ ជាអាសន

ធនសេដ្ឋីលោកឃើញសំដីថា :

អើសំឡាញ់ ! ឯងតិចិត្តក្មួយស្រីអញលេសមើល ។ តើវាមានលក្ខណៈ ដូចម្តេច ? ឱងមានចូលក្នុងក្រចកណាក្នុងតម្រាដែលសំឡាញ់ប្តូរមក នោះខ្លះដែរឬទេ ?

• រួចលោកស្រែកហៅវីរក្មួនស្រីមក ។ សោតណាក៏ដើរចូលមក ដោយសេចក្តីគោរព ហើយអង្គុយចត់ដើង នៅចំពោះមុខ សិរីវឌ្ឍន៍ តាមសេចក្តីបង្គាប់ឪពុក ។

សិរីវឌ្ឍន៍ចាប់តិចិត្តចំពីមុខ មើលចំៗ ស្ទុះនាងឡើងយ៉ាយ ស្តាប់សំឡេង សុំឲ្យនាងក្រោកដើរ ដើម្បីតិចិត្តដំណើរ ឱងមើលកង ។

លុះបានសង្កេតតិចិត្តលក្ខណៈសោភណាសព្វគ្រប់ហើយ សិរីវឌ្ឍន៍ញញឹម ។ ដោយចង់ដឹងភ្លឹងពេក ធនសេដ្ឋីសួរភ្លាមថា :

– ដូចម្តេចទៅសំឡាញ់ ? គួរសមដែរឬទេ ?

ឈប់រៀមមួយស្របក់ ទើបសិរីវឌ្ឍន៍ឆ្លើយច្រាបថា :

– គ្រាន់បើសំឡាញ់ !

ធនសេដ្ឋីឆ្លើយតបជាបន្ទាន់ទៅវិញឥតមង្ខឹងថា :

– បើអីចឹង អញឲ្យឯងយកធ្វើជាកូនយ៉ោ ឯងព្រមឬទេ ?

ឮដូច្នោះភ្លាម អ្នកកំសត់យើងអរព្រួច ដោយឱកកូនចិត្តថាបំណងគាត្មសម្រេចហើយ តែមិនហ៊ានបង្ហាញកាយត្រួតអាឲ្យសំឡាញ់ដឹង

ខ្ញុំចង់ត្រូវនឹងថ្ងៃសំការណ៍ ហើយអ្នកគ្រូនៃតែធ្វើយ៉ាងយ៉ាងនេះសុភាពថា:
ការណ៍ត្រូវហ្នឹង ស្រេចតែលើសំឡាញ់ ខ្ញុំជាជើនក្រាយទេ ។
អាតាហ៍តិតាហ៍ចុងក្រោយគឺ ៧ នៅថ្ងៃទី ៧ ចាប់ពីពេលដែលមានសេចក្តីព្រមព្រៀងគ្នារវាងសំឡាញ់ទាំងពីរ ។

ចំពូក ៤

ក្រោយពីធ្វើមង្គលការចុងក្រោយបង្អស់ ក្នុងពេលកត្រីប្រកបដោយបរិយាកាសត្រជាក់ស្រួល មានខ្យល់ជំនោរបក់មកពីសមុទ្រ ។ ស៊ីវ៉ាន់ខ្ញុំ ខឹងចិត្តក្មេក អង្គុយសន្ទនាគ្នាលេងយ៉ាងសប្បាយរីករាយនៅត្រង់យ៉ាដូង ។ ឃុបន្តិចមក ស៊ីវ៉ាន់ខ្ញុំទៀតទាស់នោះ ដើម្បីនិយាយនឹងអ្នកក្មេកថា:
-សំឡាញ់ ! ចំណែកខ្ញុំសម្រេចហើយ ។ ដូច្នេះ ខ្ញុំចង់ឃ្លាំងស្រែត្រង់លក្ខណ៍មើល ។ សូមសំឡាញ់មើលដីភូមិត្រង់ណា ដែលតាមឃ្លួនមើលដីភូមិថា អាក្រក់ជំនុត ជាភូមិដែលឈ្មោះណាទៅនៅហើយ តែងតែធ្វើឲ្យអ្នកនោះ ចួបប្រទះតែសេចក្តីវិនាសហិនហោចជានិច្ច ខ្ញុំនឹងទៅនៅសាកមើល ។

លុះឮសំដីមិនគប្បីដូច្នេះនេះសង្ឃឹកក្តៅឆួល ដោយនឹកថា អាខេះគ្មានអាណិតឯងសោះ ឯងកំពុងតែតមនឹងរកមើលទីដែលត្រង់ណាល្អគួរសម ដើម្បីឲ្យវាទៅនៅរកស៊ី ហើយកើតការលំបាកដូចឯងផង វាត្រូវចំចង់រកតែសេចក្តីវិនាស វាមិនពាល មិននឹកដល់រឿងខំលើតល់ឈើអាក្រាត

មានតែខ្លួនឯង គានេះចំណាកណាមកបំ ភ្លាមដែលឃើញដល់ផ្ទៃ ដើម
ដ៏ក្លៀវបែបឯង ថាមិនដល់ស្រីត្រចំលក្ខណ៍ ក៏មិនយល់ពាក្យចុងណាថា:
"អាតមផ្សំអាយុ" សោះ គានេះជាមនុស្សអកតញ្ញូគេញ ។ អើ! ថាមិ
ខូចជាស្រីត្រចំលក្ខណ៍មែនចុះ តែត្រចំលក្ខណ៍ហ្នឹង នឹងទៅធ្វើដូចម្តេចឲ្យ
កើតប្រឈមម្ចាត់ចាន ហើយខ្លះដើមទុន បើកូនមិត្រាសចាកសេចក្តីសុខ
គឺថាទេតើមិនជួយថែរក្សា តើត្រចំលក្ខណ៍ហ្នឹងអាចហាមឃាត់មិនឲ្យឈឺ
ចានឬទេ បើភ្លោចព្រាយ អាស្អែ អ្នកគា មិនត្រមសុខចិត្តរួមជាមួយនឹង
យើងផង ? ។

ឯនសេដ្ឋី មានចិត្តអាណិតកូនស្រីអាត្មាពន់ពេក ហើយនឹកថា: ខ្ញុ
សោកណាកូនស្ងួនអាតុក ធ្វើម្តេចប៉ាំចានជាធ្លាយឲ្យកូនទៅអាចំកួតនេះ
ប្លុះហើយ បើប៉ាំជីងតំនិតវាស្អុយបែបនេះ ប៉ាំមិនធ្លុតឲ្យកូនឯងទៅវាឡើយ
នេះគឺវាសនាអកុសលរបស់កូនដែលចានកសាងមក ។

រួចលោកសេដ្ឋីធ្វើយតប្រយ៉ាំងខ្ញី ចំពោះស៊ីវលីន៍ចាំងមុខស្ងើតតែ
ក្រុយថា:

-ថើសំឡាញ់ចង់ មិនជាការក្រូ!

តមក សំឡាញ់ចាំងពីរក៏បែកចេញពីគ្នាដោយស្ងៀមស្ងាត់ ហើយ
ទៅគាន់បន្ទប់ដំណេករៀងខ្លួន ។

ថ្ងៃជាបន្ទាប់មក ឯនសេដ្ឋីចាប់ផ្តើមដើរតេនិត្យដីកូមិ ហើយចាន

ប្រទះដំមួយកន្ទៃដ៍ នៅចម្ងាយប្រហែលជ្រុំបីគីឡូម៉ែត្រពីផ្ទះអាត្មា ជាភូមិ
ជាស់មានសុទ្ធតែព្រៃ ទឹងដើមឈើដ៏ ។ ស៊ុបខ្ទុះដែលគេបោះបង់ចោល
តាំងពីយូរអង្វែងឆ្នាំណាស់ទេហើយ ព្រោះគេនៅពុំបានសុខសោះ ។
គេលង់ គេឮតែសំឡេងសត្វគួក ទីទុយ មៀម រលកខ្មោច ខ្វែងស្រែក
គួរឲ្យព្រឺខ្លួនជាពន់ពេក ។ តែក្រោលម៉ាសណា ត្រង់នោះគ្មាននរណា
ហ៊ានដើរសោះឡើយ ព្រោះខ្មោចលង់សម្លាប់ណាស់ ដូនកាលវាទំម្ងុត
ជាស្រីក្រមុំ រំសាយសក់ខ្មាក់ពីលើចុងភ្នំមក ចួនកាលវាធ្វើជាតស់
ថ្នាន់ ឬជារឹតនៅពេញតែក្មេង ឬជាឆ្កែ ជាគ្នា ។ល។

តាមក្បួនតម្រាមើលដីភូមិ ទីនោះមានការចង្រៃទីធ្ងន់ការហ៊ានហោច
រកទីដទៃទៀតប្រៀបពុំបាន គឺថា បើឈ្មោះណាហ៊ានទៅនៅ ពោះបើខ្លួន
ឯងប៉ះមានទ្រព្យសម្បត្តិជាមហាសេដ្ឋីក្តី ជាអ្នកមានយសសក្តិធំក្តី ទីដ៏ត្រូវ
តែប្រែក្លាយជាអ្នកខ្ទុតខ្ទិត ឬរបូតឆាវសក្តិចេញដោយពិត ។ បើអ្នកនោះខ
ចំលក្រស្រាប់ កំទំដីតែតែហ៊ានហោចរហេមរហាមអស់មួយជីវិត សូម្បី
ខ្លួនប៉ុនប្រសប់ឃាំងណាក៏ដោយ ។

លុះរកដីភូមិបានហើយ ធនសេដ្ឋីនាំសីវ៉ាលីន៍ទៅចង្អុលប្រាប់ដោយ
សំដីត្រគោះថ្នុះរបាកថា :

-ទុះទ ! ដីត្រង់ទុះហើយ សំឡាញ់ ! បើឯងចង់ហ៊ានហោច ចូរ
ទៅនៅចុះ ! ។

(មានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ការស្រាវជ្រាវ

រឿងប្រកបនៃបុណ្យកាន់បិណ្ឌ ទិន ភ្ជុំបិណ្ឌ

លោក ចាប-ពិន រៀបរៀង

តាមដែលបានស្រាវជ្រាវមកឃើញថា:

កន្លងប្រទេសកម្ពុជាយើងមានសាស្ត្រា ឬតម្ពីរ ពេប ចែងពីប្រកបគឺដើមកំណើតនៃបុណ្យកាន់បិណ្ឌ ទិន ភ្ជុំបិណ្ឌ ដូចបានស្រង់ខ្លី ។ មកបរិយាយតទៅនេះ :

១-សាស្ត្រាវិជ្ជាធរចែងថា :

កាលព្រះសម្មាសម្ពុទ្ធគង់ព្រះធរមាននៅក្បើយ មានត្រីមហាវេរ ១ រូប ឈ្មោះព្រះឧបតិត្តស្ថេរ ចូលទៅហោះទៅកាន់ឋានឧត្តរកុរ ។ ពេលនោះដោយឫទ្ធិរបស់លោក ពួកសត្វនរកបានដកដង្ហើមស្រួលឆ្ងាយស្រួចក៏នាំគ្នាផ្តាំលោកថា « សូមប្រាប់ម្តាយឪពុកបងប្អូនកូនចៅញាតិផៅរបស់យើងខ្ញុំ មានឈ្មោះដូច្នោះ ។ នៅស្រុកឈ្មោះដូច្នោះ ។ សូមឱ្យគាស់រកុណាមកដល់យើងខ្ញុំ ធ្វើបុណ្យឱ្យទានឧទ្ទិសផលមកឱ្យយើងខ្ញុំផង កុំខាន បើដល់នោះខែកន្ទ្រមទៅហើយ ញាតិសន្ដានបានធ្វើបុណ្យឱ្យទានឧទ្ទិសផលមកឱ្យយើង, យើងខ្ញុំគ្រប់គ្នានឹងឱ្យពេសពួសាធុការដល់ពួក

ញាតិទាំងនោះឲ្យបានសេចក្តីសុខសប្បាយ » ។ល។

កាលព្រះមហាមោគ្គល្លាន ត្រឡប់ពីឋានឧរកមកវិញ លោកបានថ្វាយព្រះពរព្រះពុទ្ធ ១ ព្រះអង្គ ព្រះពុទ្ធអង្គនោះទ្រង់បានទូលសួរព្រះសម្ពុទ្ធថា « បើមាតា - បិតា ញាតិការបស់យើងខ្ញុំស្លាប់ទៅ ។ សោយទុក្ខកន្លងរកហើយ យើងខ្ញុំត្រូវការធ្វើបុណ្យទុំដល់ជូនទៅលោក តើត្រូវធ្វើបុណ្យអ្វី ? » ។

ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា « ត្រូវធ្វើចង្ហាន់ចំណាយបត្តបូរកាលថ្ងៃតាំងពីថ្ងៃ ១ រោចទៅដល់ថ្ងៃ ១៥ រោច ខែកត្តិក, ត្រូវសមាទានសីល ៥ និងទៅសីល, ត្រូវនិមន្តព្រះសង្ឃសូត្រធម៌ទេសនាជារៀងរាល់ព្រឹក ហើយត្រូវទុំដល់ជូនទៅពួកញាតិសន្តានដែលទៅកើតក្នុងទុគ្គតិភព, ញាតិទាំងនោះនឹងរួចរាល់ចាកទុក្ខ បានសុខក្នុងសុគតិភព ដូចសេចក្តីប្រាថ្នា" ។ល។

២-សាស្ត្រាអាទិសង្ឃបិណ្ឌបែងចែក :

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ចំពោះអនាថបិណ្ឌិកសេដ្ឋីថា « តែដល់រៀងរាល់ខែកត្តិក ដែលគេរៀបចាន់ចំណាយនោះ ម្តាយឪពុក និងញាតិសន្តានដែលស្លាប់ទៅកើតក្នុងទុគ្គតិភពជាច្រើនជាតិ សុទ្ធតែបានមកជួបជុំទាំងទូលផលដែលកូនចៅបានធ្វើបុណ្យចាន់ចំណាយ និងក្តុំចំណាយទុំដល់ជូនទៅឲ្យ ។ ដោយអំណាចអានិសង្សប្រគេនថ្វាយចំណាយបត្តបូរដល់

ព្រះសង្ឃទៅរនោចវត្តទ្រមែង ... ដែលកូនចៅទុំសជួនទៅនោះ ពួកញាតិទាំងចុំខ្មាន់កំចាន់ចេះរដោះចាកខុន្តតតា ទៅកើតក្នុងឋានសួគ៌ទៅ-លោកដូចសេចក្តីប្រាថ្នា .." ។ល។

៣-គម្ពីរប្រែតវត្ថុបែងបា :

កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជរាមានទៅឡើយ មានព្រានម្នាក់ទៅគ្រុំតាពណាស៍ តែងទៅចាញ់សត្វក្នុងព្រៃ កាលព្រានត្រឡប់ពីព្រៃមកវិញ ពួកកូនក្មេងតែងរោមកេមសុំសាច់ពលាំថ្ងៃ ។ ថ្ងៃមួយ ព្រានទៅចាញ់សត្វ ព្រានកំបេះម្ជាត្រមែក ឬម្ជាកដត្រីក្បូចដំរុំវិញ ខ្លួនខ្លះកែខ្លះយកមកផ្ទះ ។

លុះពួកក្មេងសុំសាច់ ព្រានកំឱ្យម្ជាខ្លះ ១ ស្មៅម្នាក់ ។ ដោយភោសខេះ ដល់ព្រានខ្លះស្លាប់ទៅ ។ កើតជាប្រែតអាក្រាត មានម្ជាត្រមែក ឬ ម្ជាកដត្រីក្បូជាប់ទៅនឹងក្បាលដើរក្នុងទឹក ដើម្បីទៅសុំអាហារអំពីពួកញាតិបរិគោត ។ លុះនោះគោលិយអាមាត្យនៃព្រះចុះពីម្តីសារជំនុកទៅបង្ក្រាបស្រុកបច្ចន្តគ្រាមចាន់យើញប្រែត ហើយមានសេចក្តីអាណិតក៏សួរប្រែតថា " យើងមានសត្វដុំ បើយើងត្រូវការឱ្យអ្នកតើធ្វើម្តេចអ្នកនឹងខ្លួលបរិភោគចាន ? " ។ ប្រែតឆ្លើយថា "បើក្នុងខ្លួនេះមានចាសកណាជាអ្នកម្ចាន់ត្រែស្រណោតមន៍ម្ចាន់សីល សូមលោកឱ្យសត្វដល់ចុំសកខ្លះ ហើយចុំសងលុះឱ្យមកខ្លួនុះ ។ " គោលិយ-

អាមាត្យធ្វើតាមប្រែតថ្លាប់ ប្រែតកំជានរួចចាកប្រែតភូមិនោះ ហើយប្រែតនោះផ្តាំថា "សូមលោកមេត្តា បើលោកធ្វើបុណ្យគាន់ឯណាន័មួយ ហើយសូមទុំសផលដល់ប្រែតឯទៀត ។ ធង ។ ។ លុះគាលើយអាមាត្យត្រឡប់មកស្រុកវិញ ជានថ្វាយគាន់ចំពោះព្រះពុទ្ធជាម្ចាស់ហើយគ្រាចបង្គំទូលរឿងប្រែតនោះ ព្រះអង្គទ្រង់សំដែងបេតនិកាយឲ្យច្រាកដឡើងដល់តុំរបរិស័ទក្នុងគ្រានោះ ។ ល ។

បណ្តាសាស្ត្រាន័ងគម្ពីរជាំង ៣ គឺ សាស្ត្រាវិជ្ជាធរ ន័ងសាស្ត្រាគាន់សង្ឃឹមណ្តា ជាសាស្ត្រាសម្រាយ គ្នាន់ឈ្មោះអ្នកតែង គ្នាន់ច្រាប់ថាតែងកន្លងសម័យណាទេ, ឯគម្ពីរ ១ គឺគម្ពីរបេតវត្ថុ ជាអដ្ឋកថាព្រះសុត្តន្តបិដក ខុទ្ទកនិកាយ ព្រះធម្មច្ចាលចារ្យតែងកន្លងសម័យក្រោយតុំខ្ញុំបរិនិព្វាន ដំណាលគ្នាន័ងអដ្ឋកថាព្រះសុត្តន្តបិដកនាំងពួង ។

ការតំចារណាតាមរូបរឿងក្នុងសាស្ត្រា ន័ងគម្ពីរដែលរៀបរាលមកហើយនេះ យើញថារបៀបបុណ្យកាន់បិណ្ឌក្នុងកម្ពុជរដ្ឋយើងនេះ ត្រូវតាមសេចក្តីកន្លងសាស្ត្រវិជ្ជាធរខ្លះ សាស្ត្រាអាន័សង្ឃឹមណ្តាខ្លះ គម្ពីរបេតវត្ថុខ្លះ គឺកំណត់ថ្ងៃ - ខែធ្វើ ត្រូវតាមសាស្ត្រវិជ្ជាធរ ន័ងសាស្ត្រាអាន័សង្ឃឹមណ្តា, ឯរបៀបធ្វើផ្តាំបិណ្ឌន័ងកិច្ចទុំសផលទៅប្រែត ត្រូវតាមគម្ពីរបេតវត្ថុ គឺថ្វាយបិណ្ឌដែលគេធ្វើទុំសឲ្យប្រែតនោះ គេប្រាប់ដោយផ្តាំធ្វើពីស្តាន់ក្រាម ឬក្រដាសព័ណ៌ន័ងផ្តាំឈើ ផ្សង ។ មាន

ចំនងដ្រហែលគ្នា ឪឯងគាត់ការបស់ប្រែតរ៉ែដែលមានចែងក្នុងឪគម្ពីរបេតវត្ថុ
នោះថា ប្រែតមានជាត្រចែកប្រដាប់ក្បាលដើរមកកេតាហារ ឯផ្នែកញាតិ
បេស់ខ្លួន គឺថា ចំនៀមដែលគេធ្វើបាយចិណ្ឌបាយបត្តបូរប្រគេនព្រះសង្ឃ
ហើយមានក្លិនក្បាច់ក្តីផ្កាជាលំអថ្វែតពីចិណ្ឌបាតមានឯទៀត ប្រហែល
ជាបុណ្យចិណ្ឌតូចនិតធ្វើតាមរឿងប្រែតកងឪគម្ពីរបេតវត្ថុនោះឯង ។

ការដែលតូចបស៊ែរជាតិខ្មែរ តែដល់ថ្ងៃ ១ កេចខែតូចបន តែឪ
ខាំគ្នាទៅកាន់ចិណ្ឌ កងឪគាកមកលាថ្ងៃ ដកបដល់ថ្ងៃ ១៥ កេច គេ
ក្តុំគ្នាធ្វើបង្អើយហៅថា ត្តុំចិណ្ឌ គោះបីអ្នកខ័លក្រលំបាកយ៉ាងណាក៏
ធ្វើឲ្យបានយ៉ាងតិចណាស់ត្រឹមថ្ងៃក្តុំ ជាថ្ងៃបង្អើយតុំហ៊ានអានោះ ក៏
ដោយហេតុនេះធ្វើតាមសាស្ត្រាជ្ញាធរ សាស្ត្រាអាទិសង្ឃចិណ្ឌ គម្ពីរ
បេតវត្ថុ ហើយឪឯងធ្វើតាមដំណើរចាស់ ។ ដែលថ្នាំបំផ្លើឲ្យយើញរឿង
មកតែរឿយ ។ ដោយមានចិត្តគាណិតដល់មាតាបិតាជីដូនជីតា ឪឯញាតិ
សន្តានដែលបែកហានទៅហើយ ។

បរិយាយពីប្រភពនៃបុណ្យកាន់ចិណ្ឌ ឪឯ ក្តុំចិណ្ឌចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

រឿងមរណមាតា

(តទៅ)

ឧបាសក ប៉ិ សុវណ្ណ ចម្លងពីសាស្ត្រាស្វាយរីត

កុដុម្ពីកវិប្រែជាខ្សត់ ខេរ្ញាយច្រាកដកើតរសាប់ហ្មង ខ្ញុំរត់ចោលអស់ធន
នៅតែកូនទំនីដ៏ករិយា ។ ទើបគិតទំនឹងប្រពន្ធ ថាទ្រព្យធនខ្ញុំតាសា
អន្តរាយការនានា យើងបានម៉ូចភ្នំមដ្ឋ ។ នាងកុលកេសីឆ្លើយ
ថាអ្នកអើយយើងគិតតន់ គិតដួញសព្វដំបន់ ឃុនចំណេញមរិកាត្តា ។
កាលឆ្លើយទៅវិញ ថាយើងចេញទៅផ្សារណ៎ា រកទិញសំណាញ់ថ្នា
ចេញទៅបន់ត្រីច្រាកដ ។ បានត្រីមកដូរជាក់ លក់យកច្រាក់តាម
តំសត់ ចិញ្ចឹមជន្មតំណាត់ តំរណើតក្រដូច្នេះណ៎ា ។ កុដុម្ពីកជាសាមី
ស្តាប់កាលីត្រូវចិត្តា ឧទ្ទូលពាក្យទៅថា គិតនោះគាប់ណាស់នាងអើយ ។
ឯនាងកុលកេសី ឃាត់ស្រដីថាអ្នកអើយ កុំគិតប្រមាទឡើយ គួរគោ-
រពដោយធម្ម ។ ជាតិនេះយើងលំបាក ហ៊ានគោកយ៉ាកគ្រោះវេក
យើងពីអតីតា ទើបកើតមកលំបាកម្ល៉ះ ។ យើងខ្ញុំធ្លុះវេក កម្មបា-
ណាតិជាតិនេះ យើងគួរនាំគ្នារិះ រកកាប់ទុសាបះបង់ខ្លួ ។ ទៅ
លក់ចិញ្ចឹមជន្ម ដោយដំបន់ចំការស្រែ តាមក្រកាមបុព្វេ កុំសាងបាប
កម្មទៀតទៅ ។ កាលីស្តាប់ហើយខឹង ទំសំឡឹងមើលក្រឡៃ ក្រ-
ឡេកភ្នែកមើលទៅ ក្តៅកង់ចិត្តឥតឧបមា ។ ស្រីដ៏លូកលឡក លៈ

ចំអកចុំអើងថា លោកជាអ្នកប្រាជ្ញ ចិត្តដឹងព្រះសង្ឃចាប់ចុំណ្យ ។
លោតទៅកេះសោះ មកលុកចុះចិញ្ចឹមជន្ទ យើងពីរប្តីប្រពន្ធ ជាអ្នកលន់ពុលតាត ។ ពុំដឹងកាំរកុសល បុណ្យមគ្គផលអស់ដាច យើងពីរជាអ្នកបាប យើងទៅចង់ត្រីចុះវិញ ។ ថាហើយនាំគ្នាកេ ប្រាក់ចានមកដើរកេវិញ សំណាញ់ចានមកមិញ បង់ត្រីលក់ដូចចិន្តា ។ ឯនាងកុលកេស៊ី ចរចូលព្រៃចូលព្រឹក្ស តាប់ឮសម្រែងផលា ព្រឹងតង្រៃលក់អាស្រ័យ ។ មួយថ្ងៃចានមួយស្លឹង មួយហួងនឹងហើយមួយតៃ ចានប្រាក់ហើយស្រីថ្ងៃ ដើរកេវិញទំចំណី ។ មកផ្ទៀងក្មេងខ្ទេ ហា បុត្រអាគ្នាបុត្រកាលី ដោយចិត្តនាងមេត្រី ស្នេហ្គាស្នើគ្នាមិនដូចគេ ។ ផ្លូតឹកបញ្ជាកចាយ ថៃសប្បាយដេកចំពេ ស្រឡាញ់បុត្រតាំងខ្ទេ មិនថាកូនគេឯងខ្លើយ ។ កុដម្ពីក៍ទូវគាល ទៅបង់ត្រីចានមកហើយ ឯនាងពុំតានតើយ ជួយជញ្ជាត្រីដូរលក់ ។ ជួបមុខកុលកេស៊ី មេគាលីមិនមានសុខ ក្តៅក្តាត់ចិត្តជាទុក្ខ តែងដៀមជាមដៀលយ៉ាងកាច ។ បញ្ជៀសដេរស្តីថា ទៅឆ្កែធ្លាក់ត្រីកណ្តាច ញ៉ុះញង់ប្តីឲ្យកាច ឲ្យតេតស្តប់កុលកេស៊ី ។ ថានាងមានសហាយ ប្រុសតាំងឡាយជាស្វាមី បើបានទំចំណី យកទៅជូនសហាយក់ ។ ស៊ីឆ្អែតសេសសល់ក្រោយ យកមកឲ្យអ្នកពីសា ទៅស្ងួតទៅស្មេហា ឧន្ទិសហាយជាប្រក្រតី ។ កុដម្ពីក៍ដេរហើយថា កាលដើមវាមានមេត្រី

ស្លូតត្រង់ទំនងស្វាមី ទើបកើតមានទ្រព្យសម្បត្តិ ។ ឥឡូវវាក្បត់ប្តី ខ្ញុំ
ប្រុសស្រីតែខ្លួនឯងតែ ខ្លួចទ្រព្យខ្លួចសម្បត្តិ ព្រោះវាចោរចេតអប្រិយ ។
កុដ្ឋម្តីក៍ស្វាមីនោះ ដេរចំពោះមុខកាល់ ដេរក់យកុលកេសី ថាច្រអូស
តេតណាស់ណា ។ ថាមានប្រុសដទៃ មិនមួលមៃសង្ឃឹក ជានទំណើរ
ជូនទៅប្រុសជាប្រក្រតី ។ នាំគ្នាស៊ីសប្បាយ ទំនងសហាយពាល់ពាត្រី
ឆ្អែតឆ្អល់សល់ចំណី ទើបឲ្យឯងស៊ីក្រោយ ។ កុដ្ឋម្តីក៍ដេរស្រែដី
ភយកេសីសព្វវេលា តែឈ្លោះឡើងតាលណា ដៀលកេរ្តិ៍កោះឲ្យ
អាម៉ាស់ ។ ថ្ងៃមួយនោះកាល់ ប្រាប់ស្វាមីថាអ្នកម្ចាស់ ខ្ញុំចង់ទៅ
ផ្ទះណាស់ ពីរបីថ្ងៃដ្បិតឈឺក្បាល ។ កុដ្ឋម្តីក៍ជាស្វាមី នាំកេសីចេញត្រ-
អាល ទៅបងប្តីត្រដូចតាល ពីមុនកូវគាប់តាលនោះ ។ កន្ទែងមិន
ជានត្រី ឯស្វាមីញ៉ាំពុងនោះ ខឹងខេរដេរតំកោះ ថាមេនេះស្រីចង្រៃ ។
ទើបកន្ទែងពុំជានត្រី មេអប្រិយកាន់កន្ទៀ ភនិតភអាល័យ សហាយ៣
ទើបកន្ទែងម្ល៉ះ ។ ឯនាងកុលកេសី ឮស្វាមីដេរដៀលតិះ ខំអត់ចិត្តគិត
រិះ ខ្លាចស្វាមីពុំគប្បាត់ ។ កុដ្ឋម្តីក៍ជាស្វាមី ស្អប់កេសីខឹងមិនបាត់
ហាស្តីដេរកាល់ម៉ាត់ ភាល់ៗស្ងាចមិនបាត់ដាយ ។ ខ្លាន់ៗថាកេសី
ជានប្រុសថ្មីជាសហាយ នាងស្តាប់ញ៉ាំក្តងកាយ ខឹងអត់សៀម
នៅពុំជាន ។ ទើបមានពាក្យធ្វើយថា បពិត្រស្វាមីប្រជានអ្នកដេរ
ភយប៉ុន្មាន ខ្ញុំអាចអត់ឥតបើយ ។ គួរតែអ្នកតិនិត្យ មើលយល់ពិត

ទឹងប្រុសណា ស្លាតកំសត់ទឹងគ្នា ពីមុនមានគុណខ្វះដែរ ។ ម្តេចពុំពិ-
ចារណា រកទោសាឲ្យប្រហែល ទំដេរថ្ងៃដែល ។ បើយើញាក្មេងតាម
ទោសចុះ ។

អនិច្ចាចែងអំពី គុណកេសីឱ្យចំពោះ កាលមុនកុដុម្ពីក៍នោះ ជាតិ
ជាកូនអ្នកស្រែក្រៅ ។ ឯនាងកុលកេសី ជាបុត្រីមេស្រុកនៅ
កុដុម្ពីក៍នោះបានទៅ ស្នេហ៍ស្មោគមនឹងកេសី ។ ទើបនាំគ្នារត់ទៅ អា-
ស្រ័យនៅក្រៅបូរី ជាបុរីស្រុកកុដុម្ពី កាសីខេត្តពារាណសីមា ។ រីឯអ្នក
ស្រុកនោះ សឹងស្រួលស្រុះបបួលគ្នា ធ្វើចោរលួចទ្រព្យា មកចិញ្ចឹម
ជីវិតនៅ ។ លុះដល់ដូវកាល ធ្វើជាពាលចោរឃោរ ឃៅ នាំគ្នាចរចូល
ទៅ ឃ្លាំចាំផ្ទះចាប់មនុស្ស ។ បើបានហ៊ោយតិឃាដ ខ្លះដុតជាតិ
ភ្លើកាក អាស័ព្ទដៃលក្បាស ស្លឹតកងវៃត្រសូមដ៏ឃោកក ។ កុដុម្ពីក៍
កុលកេសី នាំគ្នាលីហោជភាម ដល់ស្រុកចោរចោមចាប់ ខ្លះកុដុម្ពីក៍បាន
ហើយណា ។ ប៉ុនបំងនឹងតិឃាដ ផ្លាញជន្មជាតិភ្លើកាក កេសីក៍យ
តក្តមា យកចិញ្ចៀនមាសមួយទៅ ។ អង្វរមេស្រុកថា សូមមេត្តា
ទុកជីវិទៅ មេស្រុកមេត្តាទៅ កុលកេសីស្តីទៅថា ។ ហៃអស់គ្នាយើងអើយ
កុំចាប់ឡើយលែងទៅក៏ ដ្បិតនាងនេះជាប់ជា ញាតិសាច់យើងខ្លះ
លែងទៅ ។ ឯចោរទាំងនោះស្តាប់ ពាក្យមេប្រាប់ថាញាតិផៅ ឲ្យ
លែងជីវិនាងទៅ ទើបស្រាយលែងចេញម្ខាង ។ ហេតុនោះកុលកេសី

នាងស្រដីតបទៅថា បើអ្នកខឹងម្តេចម្តា សូមតិតគាលត្រាកំសត់ ។
កុដុម្ភីក៏ឮកេសី តបសេចក្តីខឹងពុំអត់ ក្តីគោះញ៉ែរន្ធត់ ចាប់ច្រវាខ្សែឆ័ងសំពង ។ ក៏យកដែកាតឹតត្រាំ ហើយឈរច្រំនឹងច្រវា មិនមានខ្លឹកមេត្តា មិនអាណិតកូលកេសី ។ នាងក្សីណាក្សយជន្មា ចាប់ជាតជាត្រដំរី ហែលទៅដាប្រក្រតី ខ័ក្តន់ខឹកនោះណា ។

បទគាគតិ

រឯកុដុម្ភីក៏ កាយកូលកេសី ស្ងាប់ហើយម្ន៏ម្ចា មកផ្ទះប្រញាប់ ប្រាប់ប្រាប់តរៀបា ថាមើកូនវ៉ា សួរកេម្តាយនោះ ។ យើងប្រាប់ថាម្តាយ រត់តាមសហាយ គិតគ្នាជូនោះ ហើយទៀងលើនា ត្រឹហាក្តាមបុះ ឯបុត្រីនោះ មើលផ្ទៃមាតា ។

បទព្រហ្មគីតិ

ថ្ងៃឯពីកូនកេសី ឈ្មោះនាងស្រីគុមារិកា អាយុដប់ឆ្នាំណា នាងចាំផ្ទះមើលផ្ទៃម្តាយ ។ នាងឃើញតែឪពុក នាងជាពុកលើកម្តាយដើរទៅសួរនៃយាយ ថាឪនីយណាវ៉ែ ។ មិនឃើញគាត់ទៅណា ឪពុកថាថ្ងៃហងយ៉ កុំដណ្តើងដើមដំ- ណើរម្តាយហងទៅពីរៃ ។ នាងថាព្រឹកមិញ្ញេ ឪនាំម៉ែទៅបងត្រី ម៉ែពុនសំណាញ់ថ្មី ឪឯងលើថ្នល់ដើរមុន ។ ឪគើយប្រាប់ខ្ញុំវ៉ា ប្រុងកូនផ្សាកុំចង់ឪ ប្តូរម៉ែដើរមិនទាន់

ដែលមកមុនដើរលេងលេណគាត់ ។ ដូនាំកូនទៅយក ម៉ែខ្ញុំមកគ្រែងអស់សំឡូ
ក៏ដេញក់ចោមតាំខ្ញុ តាត់ជាស្រីសមគិតគ័យ ។ ដូពុកលឺវេះថា កូន
តុំងាកុំគិតអ្វី ម្តាយស្លូនក៏មានប្តី រត់ទៅតាមសហាយក់ ។ នាង
ស្តាប់ដូពុកថ្លែង ថាដូឯងលាក់ដីនឹក ម៉ែខ្ញុំទៅហានណា ដូប្រាប់ខ្ញុំឲ្យ
ត្រង់ទៅ ។ ដូពុកកុហកទៀត ប្រាប់ចំបៀតបំបាំងទៅ ម្តាយកូន
មាសល្អេញល្អៅ មុជទឹកទៅហានទាគនាយ ។ នាងដឹងនឹងប្រាជ្ញា បុណ្យ
ក៏សនាថាអ្នកម្តាយ ដូពុកឥញាតាត់ក៏យ តាត់សម្លាប់ពីព្រឹកមិញ ។
ដឹងហើយញ៉ាំចំប្រប់ ខ្លួញសន្ធប់ភ្លាត់ឡើងវិញ តក់ខ្លែងដំប្រដេញ ថា
ម៉្លេះហើយសមកំប្រា ។ កូនអត់ពីម៉ែទៅ ឲ្យកូនទៅនឹងណា គេនឹង
ស្ទងក្បាំ កូនស្មេហាដូចអ្នកម្តាយ ។ ម៉ែមកឲ្យឆាប់ ។ ទៅជាប់ជីត
ប្តូទៅឆ្ងាយ មកយកកូនឯអាយ កូនឆ្ងីទៅនៅនឹងអ្នក ។ អ្នកម៉ែកូនហៅ
ហើយ មិនឮធ្វើយមកឬអ្នក ឬមួយបានដៃយកក្បាំ កាន់អ្នកទៅហានទាយ ។
បានជាមិនឮធ្វើយ ដូចម្តេចធ្វើយឬខ្មោចត្រាយ អាកែ្បកូតជង្កាយ
សត្វតាំងឡាយចឹកតាំស្លាប់ ។ មិនមានដំណឹងធ្វើយ ម្ចាស់គូនអើយឥត
គេប្រាប់ ម៉ែសេប្តូម៉ែស្លាប់ ឲ្យប្រុកជកូនឆ្ងីជីង ។ ឮ ម៉ែម្តេចមិនធ្វើយ
ហៅទ្វើយ។ ទំសំឡឹង ប្រែកូនឆ្ងីតាខតឹង ដើរដង្ហើតថែថប់សល់ ។
កូនសំនៅពុំគាប់ សូវតែកូនស្លាប់សោះអំពល់ កូនខ្លួញជកបដល់ ជាប់
ឡាស់ស្លាប់តាមម៉ែណា ។ នាងខ្លួញ។ ពន់ពេក ស្រែកទឹកភ្នែកស្រោច

ភក្ត្រា ខន់អស់ពាំងតាយា អត់ពាំងអាហារសន្ធៃ ។ ខ្ញុំតខ្លួលអួលអាត់
អន់ ហាក់ទឹងស្រន់ខ្លួញខ្មៀតនៃ លន់លង់ឥតស្មារតី ស្តាំងស្តូមក្រៃ
ស្ងឹតស្ងាំងថ្ងូរ ។ ទើបឧពុកគិតថា កូនពុំដាអញស្អណាស់ ហាក់
ស្រីសួតស្រៀវស្រស់ យំខ្លួញខ្លាំងឃល់ចម្លែក ។ សម្បារប្រមុខជ្រប់
ស្ងៀញស្ងាស្ងប់មិនបើកភ្នែក អញមើលឃើញដូចប្លែក បើមិនឃាត់
កូននេះស្លាប់ ។ ថាហៃមាសឧពុក កុំខ្លួញខ្លុកយំអួរអាប់ អញ
ទឹងអញវាយស្លាប់ ចូរកូនសៀមកូរៅវិញ ។ ខាងឮពាក្យឧពុក ទឹង
តំហកតំហរមិញ ខាងថាឧទ្ធរញ ខ្លឹងសម្លាប់អញខ្មៀតនៃ ។ ទើប
ខាងខំក្រោកឈោង ចាប់ប្រគោងដើរយកដៃ ដួតនេត្រតន់រំពៃ ឈ្លោក
រកម្តាយសត្វច្រកផ្ងូវ ។ ពុំឃើញខាងស្រយុត ដើរដួលស្តុតលុតឡើង
ទៅ លើផ្ទះហើយស្រែកហៅ ម៉ែទៅណាចោលកូនចាត់ ។ កូនដូច
កូនចាបត្រាប ឥតមេក្រាបថ្នមប្រយ័ត្ន ឰនឡន់រកមេជាត់ សសិត
ស្ងាបក្រាបខ្លួនឯង ។ តាំងថ្ងៃនេះទៅមុខ សមដាខ្លួនស្លាត់សូន្យឆេង
ឈឺស្លាប់តែម្នាក់ឯង ឥតញាតិត្រៀងមួយតិតជល់ ។ ខ្លឹងសួរដណ្តឹង
ណា ជួយដេរថាឱ្យរៀនស្គាល់ កិច្ចការអាចិថ្នាក់ថ្នល់ ប្រដៅកូនឱ្យ
ចេះដឹង ។ ម៉ែអើយខ្លួនកូននេះ មិនពាន់ចេះការផ្សេង។ ចេះតែ
ដើរតន់លង់ សព្វដោយលែ្វងឆ្ងាប់សប្បាយ ។ ដើរលង់លុះម៉ែទៅ
ដើរតហៅកូនហួបថ្ងាយ ឆាំកូនដេកនិយាយ ឥឡូវតើយស្ងាត់ជ្រងំ ។

ខ្ញុំម៉ែកូនស្រមៃ ដួចសំដីម៉ែហៅខ្ញុំ ចាំដឹកូនមិនចាត់ធុំ ចាត់តែខ្លួនតួន
ត្រង់ណា ។ កូនយើញតែពួកត្រាំ តែគ្រៀមចំខ្នើយត្រៀបត្រា ម៉ែ
ដេកនៅនេះណា ប្រកាច់ឯកូនប្រាំឡើង ។ ខុសម្តីបុកណា ខ្លួនកូន
ចានសាងតីត្រង់ ទើបឥឡូវនេះឯង ព្រាត់ប្រាសម្តាយតីខ្លួនចេញ ។
ខ្លីដឹថាអ្វីលើសកម្ម ឯដឹតែដឹតាមតីមុនមិញ ឲ្យរដឹខ្លួនឯង កម្មអញ
ម្តេចដល់ម្ល៉េះណា ។ កម្មវីកូនខលំខ្លួន ពុំស្រណុកកូដឹចិត្តា សោក
សៅក្តៅខ្លោចផ្សា តាំដឹតិថ្ងៃដល់យប់មក ។ កូនដេកនុបតែខ្លួន
មិនលក់សួឲ្យកូនស្ងាបរក មិនយើញម៉ែហើយក្រោក កូនដើរកេម៉ែ
កូដឹផ្ទះ ។ កូនស្ងាបរកអស់ថៃ សត្វពួកត្រៃមិនប្រទះ បតិត្រកេជកេជៈ
ឲ្យយល់សប្តិយប់នេះណា ។

បទកាកគតិ

អ្នកម្តាយកូនអើយ ម្ល៉ះកូនឥតត្រើយ ឥតតីដឹឥតតួន ឥតអ្នកណាឱដឹ
ឱតីដឹផ្ទើខ្លួន ដឹដឹឥតឱតួន ឱតីដឹអាត្មា ។ សង្ឃឹមជនក ចិត្តគាត់អាក្រក់
វង្វើដឹចូសា អ្នកយកកូនទៅ ដឹដនៅអ្នកណា អ្នកនៅហានណា ជិតឬ
ឆ្ងាយហើយ ។ ធ្វើម្តេចនឹដឹដឹដឹ ដំណើរដំណឹដឹ គ្រាន់ចានសរសើយ
អ្នកភ័យតខ្វឹក ខ្លាចខ្លឹកណាស់ហើយ អម្ចាស់កូនអើយ សមក្រែយជន្ម ។
មួយទៀតឬអ្នក ឥតុកគាត់អាក់ គាត់អនចិត្តា ទេវឱដឹក៏យដំ ម្តាយខ្ញុំមរ-
ណា ឬក្រតើព៌ា ខាំពាំទៅស៊ី ។ ធ្វើម្តេចនឹដឹចាន យដឹយល់រូបប្រាណ

សាកសពជនខ្លះ ទោះអង្គុយក៏ដោយ សំរាំសាអួតក្តី មិនបានយល់ខ្លី ឃ្លាំ
សាកអសុភ ។ ឬមួយក្រែងយក្ស ចិសាចនាំអ្នក លេបលួច
លាក់លុប ទើបចាត់ឃ្លាំក្រែ ពីថ្ងៃល្ងុះយប់ ទុកញ្ញតិត្រប់ តិត
ក្រែងអ្នកម្ចាយ ។ អនាគតនឹងខ្ញុំ គាត់ដេរខ្ចីវ រត់ចាត់ខ្ចាតខ្ចាយ
ថាបើអ្នកនៅ ឬទៅស្រុកឆ្ងាយ កំតួរអ្នកម្ចាយ យកកូនទៅផង ។
ម្តេចអ្នកចោលកូន បង់ចោរសោះសូន្យ ពុំគិតឡើយហោង ទុតអ្នក
ណា រក្សាសួនគ្រង ស្មាលស្ងួនស្នេហ៍ស្មន់ ដូចអ្នកឡើយណា ។
ឃើញតែដំណេក ដំណែលដែលដេក ជាជាន់មាតា កន្ទេលពួ។
ខ្លាំ ខ្នើយគល់សំរសា រៀបរៀងល្អជា ទំនេងនិត្យទៅ ។ កូន
ម៉ែលហើយនៃ កូនឮតស្រែម៉ែ ស្រម៉ែគិតទៅ ហាក់ដូចអ្នកមែ
ប្រែតប្រែហាហៅ ឲ្យកូនដឹងទៅ ទីឆ្ងល់ចំពោ ។ អ្នកមែភ្លាត់ទៅ
មិនទាន់ប្រាប់ ខ្លួនកូនខ្លះ ទុតអ្នកណា មេត្តាដូចម៉ែ រក្សាកូន
ថៃ កូនថប់មួយណា ។ ថប់ត្បិតអ្នកមែ អ្នកមិនមានគេ កំដរជាគ្នា
ធ្វើម្តេចដឹងផ្លូវ អ្នកទៅឋានណា កូនឮឯយាត្រា ទៅតាមអ្នកមែ ។
ត្រាន់បានជាគ្នា កំដរទៅក៏ ម្តេចឡើយទៅតែ អ្នកម្ចាយម្ចាក់ឯង
កណ្តែនធេនខ្លះ កូនតែឯនេះ លុះដល់ឋានមច ។ កុមារីវែង ខ្លះ
ខ្លុកម្ចាក់ឯង កណ្តាលភក្ត្រ ហើយលុតលើកតរ ថវាយាំនឹង ជាក់ស្តើ
សំរស់ សាសូត្រគាថា ។ គោន្ទោះខ្លះ សង្ឃរយោច មមាញ

និតណ្ហាថ : បមាតុយា : ជានាចក្ខុ នមោតេសំ ។ ភាលិតាវុ : ម៉ិតំ
អ្នថា ប្រែកត្តន្តំ នមោប្រែថា នទក្ខាវំ មេនៃខ្ញុំតាំង ប្រណាម្យកញ្ញលី ។
ក្តីម្រាមដាំង១០ ខុតតាងត្រឿងត្រប់ មាលាផ្កាក្ង ជាត្រឿងក្រយា
ចូជាពលី- តាវតាលកតី- រាវវាវន្ធា ។ តោន្តោខេវ សង្ឃាយោច
ជតិត្រខេតតា អ្នកបិតនៅហាន វិនានបត្តតា ក្រុំប៉ាំទិសា អញ្ជើញ
ចូលមក ។ មមវន្ទ: និតណ្ហាថ ចូរខ្ញុំលួយក តាវន្ធនា ក្រយា
ខ្ញុំក អញ្ជើញអ្នកមក ដៀងជួយវ៉ែន្តី ។ សូមអ្នកត្រមាន ក្រុយ
ក្រុំប៉ាំទិហាន លំនៅជនវិ អ្នកបិតហានណា មេត្តាក្រុំប៉ាំទិ ផ្សងស្រេច
កុមារី ដេកលន់លក់ទៅ ។ តាលេតតា តួនកាលនោះណា អក្រាត្រ
យប់ជ្រៅ តេជៈសុត្ថា កុមារីតាផ្សងទៅ ខេវតាបិតនៅ ក្រុំប៉ាំទិសា ។
រំជួលកក្រើត ហាក់ដូចតេលើក ហានខេតជាតា តាំងហេមតាន្ត ទិហាន
ព្រឹក្ស សួតិសុខកាមា. វចមិនសល់ ។ នាងខេតជាតា ប្រែក្រះតក្តា
ខៀងតយង់យល់ កុមារីក្រង់លក្ខណ៍ ដួងតក្តនិមិល នាងមានអំ.
ពល អំពីមាតា ។ ខេតទិសក្រុំប៉ាំទិ ជ្រាបសត្វសេចក្តី ថាខ
អនិច្ចា កុមារីវែលក្ខណ៍ នាងអ្នកតំក្រា ក្រាត់ក្រាសឃ្មាតឃ្មា មិនមួល
ជនវិ ។ តិតហើយហៀរមោះ ហៀរហិចផ្ទេកផ្ទោះ ចាកហានទិត្ថ
ទិ រំពៃសំដៅ លំនៅខេវិ ចូលដល់កុនិទិ ជំណោកកុមារិកា ។
រមិលមើលសត្វ ជង្ហើមធំថប់ ធ្លុតធ្លែតខ្លាំក អាណិតអនេក ស្ទើរ

វែកចិត្តា លុះលាន់មាត់ថា អាស្បូរអើម្ល៉ះ ។ អាយុ១០ឆ្នាំ ក្មេង
ណាស់ម្តេចកម្ម មកផ្តល់ដូច្នេះ ខុះខុអនិច្ចា កុមារីតានេះ គួរអញ
តិតរិះ ប្រាប់ទីមាត ។ ហើយទើបទៅ នាំហេតុនោះទី- យាយព័ត៌
នាំម្តាយនាងទៅ ជម្រាបតង្គ្រា ហើយដេរឈ្មោះគ្នា ពុំស្រាកពុំស្ប្រាយ ។
ឯនាងវយនាក់ ម្តាយនាងនោះក្តាក់ ទឹកស្តាប់ទៅហើយ តើថ្លូម្យ៉ាលមិញ
សម្តាញ់ម្តាយអើយ អាងចាប់ជាតិហើយ ជាត្រូដីរ ។ ហែលមកចាំទៅ កំពង់ទឹកផ្លូវ ដងទឹកប្រក្រតី ខេពតាប្រាប់ភ្នែ ហើយ
ហោរវិលខ្លី ទៅឋានទិព្វទី តាមានអាត្មា ។ នាងកុមារី ភ្ញាក់
ឡើងអំពី ដំណេកហើយណា ក្រោកចុះដើរត្រង់ កំពង់តង្គ្រា ដល់
នាងម្ខាង ចុះក្នុងទឹកហើយ ។ ស្រែចស្រែកហៅថា បពិត្រមាតា
អម្ចាស់កូនអើយ អញ្ជើញអ្នកមក រកកូនអ្នកអើយ មច្ចាព្រហើយ ហែល
មកម៉ែម្ល៉ ។ ដល់ហើយបម្រះ នេខ្យែលខនេះ ដឹតកុមារីតា នាងយល់សេចក្តី
ជាត្រីមាតា មកដល់នាងអា- ធិដ្ឋានផ្សំផ្សង ។ ថាបើមច្ច នេះជា
មាតា ប្រាកដពិតហោង ឲ្យចេះភាសា ដូចមនុស្សនោះហោង ឲ្យ
ប្រាកដផង តាលគ្រានេះឯង ។ ផ្សងស្រែចហើយណា តេជៈកុមា-
រីតា មានចិត្តចិត្តែង មច្ចាដ៏រ៉ា ចេះស្តីជាភ្លែង ប្រាប់កូនឲ្យថ្លែង
អំពីអតីតា ។

ប្រឌ្រប្បកីតិ

មច្ចូជាជនី ថ្លែងប្រាប់តាំហេតុខ្លួនថា កូនអើយកាលមាតា បង់សំណាញ់ទឹងឥតុក ។ ម្តាយមិនមានទោសទេ ស្រាប់តែគេដៀលជាក់មុខ ហើយវាយម្តាយឈឺចុក ភ្លាត់ចិត្តស្ងាប់កាលនោះណា ។ កើតជាត្រីដំរី ឥតចំណីបរិភោគ្គា នាងស្តាប់ហើយសោក ខឿនខ្លួនខឿតតែងលំបាកក្ខំ ។ ថាអ្នកមានគុណក្រៃ នៅសព្វថ្ងៃនេះឲ្យសុខកូនធឹងនាំកន្លង់ ចុងអង្កាំជាកោជនា ។ មកជួនអ្នកម្តាយថ្ងៃ ត្រឹកល្ងាចថ្ងៃត្រើសា អ្នកកុំព្រួយចិត្តា ត្រង់តាហាចំណីនោះ ។ ថាហើយនាងសោក យកហាគ្គាលូកថ្នមបុះ បីពង្រត់ម្តាយនោះ កើតទោមនស្សក្រៃនុក ។ មច្ចូជាជនី ឃើញបុត្រីនាងសោក នាងលួងនាងលោមថា កូនកំសត់មាសម្តាយអើយ ។ កុំនាងយំខ្លុកពេក កុំសង្វេគចូរនាងស្ងើយ កុំខ្លួញកុំសោកៈឡើយ កុំសង្រេងក្រៃឈឺថ្ពាត់ ។ មិនមានអ្នកណាថែ ចូរមាសម៉ែនាងស្ងៀមស្ងាត់ ម្តាយស្លាប់ចោលកូនបាត់ ពិតតុំពាន់ប្លាន់ខ្លួន ។ ហើយទើបត្រីដំរី ប្រាប់បុត្រីតាមនិទាន ពីកាលប្រសព្វបាន ជាតិយៅនៃកុដុម្ពីក ។ កំសត់តង្រិត្តា ចោលចិតាមាតាស្រី ដូចបាននិទានពី មុនមកស្រាប់មិនមានសល់ ។ ហើយប្រាប់ពីកុដុម្ពីក ភ្លាញដីវិដពាបដល់ ចាប់ជាតិកន្ទុរជោរជល ជាមច្ចូដំរីធ្លោះ ។ ហើយនាងប្រដៅប្លាប់ ជាតម្រាប់កូនស្រី

ស្មោះ សាស័ក្តិបច្ចាប់ពាំងនោះ មានទៅក្នុងបច្ចាប់ស្រីស្រាប់ ។ ឯនាង
កុមារី ស្គាប់ជននីខ្ញុំខ្ញាន់ច្រាប់ ហើយនាងស្គាប់ចាំចាប់ ចប់សព្វសុះឥត
ហ្នឹងសៅ ។ ស្រេចហើយកុមារី លាជននីទៅលំនៅ ជននីបើក
បុត្រទៅ តាមចិន្តាបុត្រក្សាប្រិយ ។

ខ្សែមួយជាដើមទី ថ្លែងអំពីកុលកេសី ក្សត្រិយទៅគេីតជាត្រី ជាន
ជួបជួនបុត្រពុំងា ។ ចាំខ្លួបខ្ញាយលើត ល្បងល្បិចលើកគោលតណានា
ចរិបូណ៌ជួបចូលជា ខ្សែមួយចប់ជាសូរេច ។

បឧតាគតតិ

នេះទៅរៀបកប់ រៀបរៀងសាសត្តុ សាសនិកាត្យកិច្ច តាខ្សែមួយមក
លៃលកពាក្យពេចន៍ ពាក្យពោលសម្រេច សំម្រួមចរចា ។ តិតតាកុមារី
លាកលាជននី ចេញចរយាត្រា តាំងយប់ងងឹត ពុំតិតអាក្អា តិត
តែមាគា ស្រងឹតស្រងាត់ ។ ទាងដើរម្នាក់ឯង ដល់នេត្រហូរល្ហែង
មិនស្បើយមិនជាត់ មុខតួរអនិច្ចា កុមារិការូបត្តែ ទល់ទុក្ខច្រាសត្រាត់
តណ្ហាលកត្រី ។ ដៃមួយជួតក្បែក ហូរទ្លាយពន់ពេក ពោរពេញឥត
ប៉ី ដៃមួយជាលដំ ត្រូងយំឥតប៉ី ខ្លួញខ្សែតសែនថ្នី ខឹកដល់មាគា ។
ឧអ្នកមានគុណ ច្រាសចោលកូនតន ឲ្យនៅឯកា ឥឡូវកូនខឹង
ខំពីងីអ្នកណា អ្នកអើយកូនផ្សា កូនខ្ចោចថ្មីម្ល៉ាយ ។ ធ្វើម្តេចកូន
ជាន យងំយល់រូបច្រាណ ស្គាប់ស័ក្តិអ្នកម្តាយ អ្នកនៅតងំចិត តន្ទឹក

ជ្រៅឆ្ងាយ ស្ងាត់សណ្ដូកម្ដាយ នៅជាប់ដីណា ។ ឬមួយក្រែងសត្វ
ក្រពើឆ្នាមកាត់ ពាំយកកោក្ដា ហេតុនោះទើបបាត់ សូន្យស្ងាត់សោះ
សា ឬក្រែងមច្ចុ ចឹកពាំយកទៅ ។ បើសត្វកោក្ដា សាច់ស្បែកកា-
យា តួរយើញធ្នើរទៅ ធ្នើរតើអកបាត់ សូន្យស្ងាត់បាត់ទៅ លិចក្នុង
ទឹកជ្រៅ អន្ទង់ត្រង់ណា ។ ធ្វើម្ដេចកូនបាន យល់ធ្នើរចូលក្រោណ
សាកសពមាតា ប៉ើពុំយើញគ្រប់ យើញសពកាយា ខោះធ្នើរសំសោ
បាតអ្នកថ្លៃ ។ កូនទឹងលើកសព សង្ឃារឲ្យគ្រប់ ឲ្យអស់សង្ឃឹយ
តាមដោយកំសត់ ខុគិតក្រៃក្រៃ ស្រេចហើយកូនស្ងួយ ទៅតាមអ្នក
ណា ។ ខុអ្នកម្ចាស់ថ្លៃ អ្នកមកស្ងើណាស្ងួយ ពុំយល់ច័ក្រាំ បើអ្នក
ស្ងើណាស្ងួយ ប្រលួយម្ដេចម្ដា តួរមានកបា ផ្ដែផ្ដាំកូនផង ។ ឲ្យកូន
បានដឹង ដំណើរដំណឹង ពាក្យគោលសាសង៍ បើអ្នកបិតា ក្រោធា
កន្ធង កូនយកខ្លួនរើ ទោសតាងមាតា ។ បើអ្នកមុត្តុក យោរទឹង
ញ៉ាញក់ ពយដំក្ដីណា តួរពយទៅផ្ទះ ចោកប្រាស់ម្ដេចម្ដា កូនទឹងដួយ
ការ ជួយការង់អ្នកម្ដាយ ។ ខេះម្ដង់ទាំមែ ទាំមកបង់ឯ ខេត្តជ្រៅឆ្ងាយ
យោរទឹងជាក់ច្រៃ ពយដំអ្នកម្ដាយ ឲ្យក្ងួយអន្ដរាយ រកសពពុំឃើល ។
កុមារគិតគ្រប់ គិតវែងថែមថប់ រឹងថែមខ្លួនឯង - ខុកូនឱនសែនពាន់
ផ្ដែតផ្ដង់អំពាល់ អំពីពុំយល់ ស្ងាត់សពមាតា ។ ខាងខ្លួញពាំងយម៉ ដួលដេក
សោកសពូ ផ្ដែតផ្ដង់ខុក សន្ធប់លង់ស្មារ ខៅកង់ព្រឹក្សា តែឯងឯងតា

ឥតអ្នកពីរផង ។ លុះភ្ញាក់ស្មារតី ឮសត្វបក្សី យោសយំអឺងកង ខ័ណ្ឌយ
មៀមមំ សព្វយំកន្ធង ខ្ទង់ស្រោកស្រែកផង ព្រឺព្រឺតសរសេរ ។ តួក
ស្រែកសន្ធាប់ ខ្ពរខ្ពាយឮសំពូ ឥឡូឆ្មាចា នាងគិតគាន់តាំង ស្ទាំងតាំង
កាមា ស្ងួនស្ងុតចាចា ដួលដើរពុំបាន ។ ផ្សារដោយនៅក្នុង ឮស្ទុរ
សំឡេង ក្នុងព្រៃស្មសាន សុទ្ធសឹងសត្វខ្លាច លន្ទោចតរបួន ញ័រ
អស់អង្គុច្បាណ មុខតួរអនិច្ច ។ ដើរយប់តែឯង - ភណ្ណាចភណ្ណែង
ភណ្ណាលព្រឹក្សា រំងើនរំលៃលៃ ខួញខ្លែខ្ទុគ្គា ដៃជំនក ឧពាស្ទើរខ្លាយ ។
តាំងពីអន្ទ្រាត្រ ពុក្ខខួញសល់ខ្លួត ស្មារតីកយមាយ · ប្រទះហ្វូងសត្វ
ប្រវាត់លោតលាយ ខន្ធោងប្រើសត្រាយ ចចកប្រមា ។ រមាសរមាំង
ប្រើសព្រៃខ្ពឹងខ្ពាំង ដំរីខ្ញាងខ្ញា កំហែងសន្ធាប់ ញ័រញាប់ព្រឹក្សា តិត
ភ័យប្រវ ជ្រកពួនលាក់ច្បាណ ។ ហេតុផលសំណាង កុមារីសាង
សត្វឆងពុំហ៊ាន ប្រមាថអង្គនាង ដៀសវាងឆ្ងាយហាន នាងក្រោក
ដើរបាន តិច ។ យាត្រា ។

បទតំនោល

លុះស្រាងព្រឹកត្រាងសុរិយា កុមារីយាត្រា វិលដល់មណ្ឌល
ហានបិត ។ កាលីមើលយល់ស្រីវត្ថ ដើរដល់តន់តិត ក្នុងចិត្តមន្ទិល
ថៃថា ។ ហេតុអ្វីថ្ងៃនេះកុមារីកា ចុះទៅតង្គា ព័ត្រឹកលុះស្ងាងសុរិយ ។
តិតហើយនិយាយច្បាច់ប្តី ថាអ្នកកុំបី ចណ្តែតចណ្តាយកុមារីកា ។

កុំរៀបតែម្នាក់ឯងា គួរហៅយកវា មកនិត្យមកនៅឯអាយ ។ មិនត្រូវឲ្យនៅ
ផ្ទះឆ្ងាយ ក្រែងអន្តរាយ អសារអាសោចក្តីរន្ធត់ ។ យប់មិនដែលនៅផ្ទះ
សោះ ពាក់ព្រេងដើរស្មោះ ដើរដល់ទៅឯកំពង់ ។ ឥយប់ឆ្ងាំតសូន្យសុង
សូន្យសោះយូរលង់ យូរលុះព្រឹកព្រាងទើបមក ។ កុដ្ឋម៉ាក់ស្តាប់ហើយ
ហៅវេក ហៅវេកកូនមក កូនមិញ្ញាមកប្តានបិតា ។ កុដ្ឋម៉ាក់ដណ្តើង
សួរថា កូនកែវទៅណា ទៅនៅឥយប់លុះព្រឹក ។ កុមារធ្វើយថាខ្ញុំទឹក
ខ្ញុំភ្នក់លើក រលេះរលួយក្នុងចិត្ត ។ ដ្បិតខ្ញុំនឥតភ្លេចពីធិតា អនាថ
អាណិត អាណាឯកាម្នាក់ឯង ។ លន្ទង់លន្ទោចកណ្តែង កណ្តាល-
ឯកឯង ឯកឥតតំនាក់អាត្មា ។ ខ្ញុំរលើកអ្នកមាតា ស្រមៃហាក់ជា
ហាក់ដូចសម្លេងជនន៏ ។ ហៅជាក់ខ្ញុំភ្ញាក់ថាកន៏ ចុះទៅអំពី មណ្ឌល-
មទ្ទិលក្នុងចិត្ត ។ ដើរកសតព្រៃហានបិត ថែជួនអស់ចិត្ត អស្ចារ្យពុំ-
ឃើញមាតា ។ ហេតុនោះខ្ញុំចុះគង្គា លុយកេមាតា សុំរុសព្វពុំឃើញ
នេះនៅ ។ បិតាថាពីនេះទៅ បើឮមាត់ហៅ កុំទៅកុំទុកចិត្តណា ។
កុំចុះដេរយប់លិលា ក្រែងជួនម្រឹគា តស៊ូខ្លាខ្លូរសត្វយោរយៅ ។
ម្តាយនាងឮភ្លាត់ទឹកស្តាប់ទៅ ពីម្យុលមិញ្ញាកូវ នាងីកំពង់គង្គា ។ កុំនឹក
រលឹកទៅព ចូរមកនៅនា នៅនឹងបិតានេះចុះ ។ ចំណីបាយត្រីនៅនោះ
យកស៊ីចុកចុះ ជួយមើលជួយថែរក្សា ។ បម្រុងទ្រព្យក្នុងគ្រឹហា ទោះ
ទ្រព្យខ្លួនណា កុំបោះកុំចោកបែកបាត់ ។ នាងស្រួលខ្លួលស្ងៀមស្ងាត់

វិលទៅផ្ទះវិញ ជញ្ជក់ខ្មេលខ្ចាល់ខ្ចើយ ។ ឃើញតែដំណេកជាគ្រើយ
តើតខ្មែរពុំស្បើយ តិតនឹកវិលឹកមាគា ។ ហូរហែងស្រក់ទឹកនេត្រា
សង្រោកតក្រោ តំយកដៃជូតក្រមិញ ។ ជាត់ក្រមាធ្វើហាក់-
ស្បៃមវិញ ក្នុងចិត្តក្តៅមិញ រំជងរំជួលខ្មែរខ្លាំ ។ ដៃមួយទប្អូក-
ខ្ចើយខ្ចាល់ ដៃមួយជូតជល តំដើរហើយយំចរណ្តើរ ។ លុះដល់តូក
ខ្ចាល់ដាក់លើ ផ្ទះហើយនាងរើ នាងរៀបដំណេកខ្មែរនៅ ។ កាលី
ជាស្រីឃោរឃៅ ឃោរឃើញនាងនៅ តំហៅហើយច្រាប់ច្រមាច្រើ ។
ជនឹកបុកស្រួវសារតើ ដណ្តើសូរធ្វើ ចំណីកំណុកកោក្តា ។ មិនស្កប់
ចំនេរត្រង់ណា ខានតែវេលា ឃប់ខានសំកន្តឹលប់ខ្មែរ ។ ម្ល៉ោះទំនាក់
ច្រំថ្មាកច្រាស់ រាដេរមិនខ្មែរ មិនខាតមិនខានមួយថ្ងៃ ។ មិនអត់មិនខ្មែន
ឈប់ដៃ ហើយប្រើទៅព្រៃ ឃ្វាលគោរកខ្មែសបន្ទៃ ។ នាងស្តាប់កាលី
ប្រើប្រៃ ខ្មើយហាត់ឥតល្អែ រកបែរបើកទ្វារក្រោលចេញ ។ ម៉ែគា
ចោលមកនាងដេញ ប្រមូលវិលវិញ ដើរចេញដើរដោយព្រៃខោះ ។
រហើយចូលក្នុងព្រៃរកខ្មែស ចងចាប់ស្រែចចុះ ហើយគៀងប្រមូលគោ
ចាន ។ ហើយដើរសព្វព្រឹក្សាខ្ពុ រកម្ចប់ចាំងច្រាណ ខេត្រតយ
ព្រៃក្រងឃ្មុតខៅឆ្ងាយ គៀងចូលប្រមូលហូងហ្វាយ មិនឲ្យគ្រាត់ព្រាយ
ព្រាត់ច្រាស់ចរចាកចោលគ្នា ។ រសៀលខេរចាប់សុរិយា ជ្រៀងជ្រៃ
ធីតា គៀងតយប្រមូលកូនមេ ។ រំពឹងជញ្ជឹងជួនថៃ ជាខ្មែគោមេ កូន

ឯកមួលមេរ៉ា ។ កម្មអញឲ្យដេញខ្ញុំចេញ ត្រាត់ប្រាសមាត្រ មិនមិត្ត
មិនមួលដួចសត្វ ។ តិតហើយមិនស្បើយស្រីតែ ឱ្យតែឱ្យលក្ខណ៍ក្តាត់
អាណិតអនាថអាត្មា ។ រីឯថាំរីឯថែមខ្លួនា ខ្លួនខ្លះ
ក្រៀមក្រំ ។ ហត្ថាទុកដាលដំ ដើរដោយខ្លួនឯង ខ្លួនតែអង្គឯងឯក ។
ដើរក្រៃដៃដួតខ្លីតក្បែក អាណិតនាងពេក នាងពុំសប្បាយហួយ ។ ខ្មៅ
ខន់ពេលតន់ល្ងាចថ្ងៃ ភ្លៀងធ្លាក្រាស់ក្រែ ក្រាស់ក្រែនឹងស្បើយស្រាក
ស្រាន្ត ។ រងាហត្ថាទុបក្បាល ក្រណាត់មួយគ្នាន សំពត់ចង្កេះជាក
ជាំ ។ ឥតឯមានតែថែទាំ រូបសៅរឯកម្ន កំណាឯកណ្តោចខ្លួនឯង ។
ភ្លៀងស្បើយផ្លេះធ្លើយនឹង រងាអួលក្រំ នាងយំអាណិតអាត្មា ។ ស្រណោះ
អាខ្លោះមាត សួតស្ងប់ត័ក្រែ ទុកដាលដំនឹងម្តាយ ។ ស្ទើរប្រែះរបេះ
ចេ្ញមក្តាយ អនិច្ចាធោមធាយ ខ្លួនធ្វន់ក្តងតាយលន់លង់ ។ ស្ទើរផ្តុតស្រ
យុតស្រយង់ ស្រយាកអស់អង្គ ឯកឥតនណោជាខ្ញុ ។ ទំផ្លងតំរង់
ឥន្ទ្រីយ ក្រោកឡើងចាកទី រីឯរែងខារ់ខ្លួនពុំក្បាន្ត ។ ក្រោកដើរកំ
ឈឺអង្គច្រាណ ប្រឹងច្រាណដើរចាន ដោយស្រាកដោយស្រាន្តខ្លះ ។
ភៀងគោម្រមូលគ្នាក់ ហើយចូលព្រឹក្សា រកបេះបន្ទេអន្ទក់ ។ ផ្តាំល្ងៀង
ត្រៀងត្រចុក ទ្រុយកំងអន្ទក់ ស្តន់ដើងបង្គន់ត្រកួន ។ ចង្កាច់ស្រាប់
ស្រេចស្រីស្តួន នាងរៀបលើកផ្តួន លើកផ្តុតលើចាច់ទុសវិញ ។ ហើយ
នាងប្រមូលគោដេញ គោដើរលិលវិញ វិលរឹងមកដប់ខ្នាក្រោល ។ ជាត់

ទសបើកទ្វាបញ្ចូល ពាក់កូនញីឈ្មោល ហើយនាងក៏ទ្វារចោះស្នៀត ។ ចូលចាប់អាឈ្មោលចងខ្នែត ហើយវិលមកស្នៀត គន្ធឹះរន្ទុកក៏ទ្វារ ។ ទើបខ្លួនទសរៀគ្រឹហា ដាក់ទសម័ន្ធ សំពះឥតុកលើថ្ពុះ ។ ឥតុកថា គ្រប់ប្តូខ្លះ ចានពាក់មើលច្បាស់ នាងធ្វើយថាពាក់គ្រប់ហើយ ។ មិនបង់មិនចាត់មួយឡើយ ចាក់សោទ្វារហើយ ទើបខ្ញុំវិលមកគ្រឹហា ។

ហើយនាងឡើងកន្ទេគង្គា កាន់ក្អមម័ន្ធ កណ្តៀតហើយខ្លួលចុះរៀ ។ យកចុងអង្ករច្រកនៅ ក្នុងក្អមខ្លួលរៀ តម្រង់កំពង់គង្គា ។ ដល់ហើយនាងហៅមាតា មច្ចាម័ន្ធ ហែលមកដល់កូនតុំលង់ ។ នាងយកកន្ទេក់នៅចុង- អង្ករលើកផ្ទង់ កំពេយឲ្យរៀមាតា ។ ហើយនាងដងទឹកម័ន្ធ ដើរដល់គ្រឹហា ឡើងយកឆ្នាំងចាយលាងដាំ ។ ឯកូនតាលីប្រចាំមិនដួយដណ្តាំ អង្គុយបង្អាប់កុមារ ។ ដូចខ្ញុំកញ្ឆេះចាគា រាដេរផ្តាសាប្រទុស្តប្រទេចទះតប់ ។ ខ្លាមខ្លារដោយសារវេស្តប់ ព្រានដួលដាស់តប់ឥតភាស់ឥតពោសទំនឹកគ្នា ។ នាងអត់មិនឈ្លោះទើងរា តាំតន្ទុនកំព្រាឈឺឆ្អាឈឺខាប់ជាំជាក់ ។ ដល់នេត្រហូរល្ហែងសស្រាក់ សរស្រោកឥតអាក់ ដោតជាំដោយសត្វជើងក្រាន ។ ទំអត់ក្រោកឡើងលាងចានចាបង្អួនសូចាន នាងដោះនាងដួសយកមៅ ។ លើកដួនឥតុកប្រើហៅប្រពន្ធកូនមៅ មកជុំមកដួបហួបចាយ ។ នាងថយអង្គុយមៅឆ្ងាយ រៀបត្រៀមាំងឡាយ សិតទឹកលាងជើងឥតុក ។ គេមកដល់ហើយស៊ីចុក

មិនមានមើលមុខ មើលមកនាងអង្គុយខាង ។ ស៊ីរួចពុញថាសចានជាង
នាងយកទៅលាង ហើយដាក់ចុកដាក់មើលថៃ ។ ចំណីសេសសល់
ដៃលគេ នាងបរិភោគតែ សេសសល់សំណល់សត្វថៃ ។ ស៊ីឆ្អែត
ហើយនាងស្រីថៃ កាន់ក្អមចុះវៃ ទៅដល់កំពង់តន្លា ។ ចុះដងទឹក
ឡើងម្ដង ជាក់ដល់សំរិសា ក្អមពីដម្រូតខ្លួនមក ។ ចាក់ពាងអុង
កងក្រឡ ត្រឡប់ទៅវិញ ដងជាក់លុះតេញាងគ្រប់ ។ ថៃមួយហាត់
ព្រួយគ្មានឈប់ ពីថៃលុះយប់ មិនឈប់មិនឈរសម្រាន្ត ។ ព្រលប់
នាងអុជទ្វាញ់ចាន ក្ដើងភ្លើងភ្លឺហាន ហើយរៀបរបស់ចុកដាក់ ។ រួច
ហើយកំដរគ្នាសោចាក់ តន្ទឹះតន្ទាក់ ចូលចោលដំណេកបិតា ។ សិត
ទឹកដាក់ដិតជាតា រៀបហិបដាក់ស្មា លើកដាក់ដិតក្បាលដំណេក ។
រៀបចិតាចូលដេក ចូលដល់ដំណេក នាងតក់ច្រកាប់ជាតា ។ ឥតុក
ដេកលក់ខ្ចិត្រា ហើយនាងលីលា ដើរចេញមកដំណេកនាង ។ ចូល
ដល់ជោរដេលយំភ្លាង ដេកលក់ភ្លឺស្រាង ចុះទៅចុកស្រូវអង្គរ ។ ស្ទុះយក
កន្ដក់សល្អ ខ្ចប់ចុងអង្គរ នាងយកទៅដួងជនធី ។ ញឹកៗ ល្ងាចព្រឹក
ទៅ ទឹកដល់ជនធី ស្រពោនតែក្រាមិនស្រស់ ។ មិនលេងមិនសើច
សួរឱ្យសោះ មុខស្ងួនក្រៀមក្រស់ អាល្ហែះអាល័យមាតា ។ ចំណីកា
ល៉ោះណា នាងតុំកោក្ដា នាងចាំបណ្ដាំជនធី ។ ចំណីរបស់នាងស៊ី
មើគ្មានទៅ នាងអត់នាងអន់ស្រៀមស្ងាត់ ។ តែងយកកន្ដក់ទៅថ្ងាត់

ទៅដួនប្រុសណាម៉ាត់ ជនន័យល់ ។ រីលា ។ ធ្វើវគ្គប្រុសណាម៉ាត់ថា ប្រ
ចាប់ចាត ម៉ែនខាន់ម៉ែនឲ្យអាក់ចិត្ត ។ ម៉ាតាអាសូរអណិត ព្រោះនាងមាន
ចិត្ត ស្លូតត្រង់គោតខ្លាចម៉ាតា ។ ទើបតាំងឲ្យនាមឈ្មោះថា មរណមាតា
តាំងតែពីថ្ងៃនេះទៅ ។ កាលជាស្រីយោរយៅ យើញនាងស្រីពៅ ឥពុក
អាសូរស្រឡាញ់ ។ ខេរខឹងសំឡឹងគ្នាន់ក្នាញ់ រីឯក្តីចិត្តម្នេញ រកពាស
កំហុសសត្វថ្ងៃ ។ ព្រឹកឡើងនាងចេញទៅព្រៃ ឃ្លាលគោសត្វថ្ងៃ មាន
ក្មេងចូលលេងជាគ្នា ។ ក្មៀងនុះជន់ជាកដោ ខ្លះបេះស្វឹកចា ដេរដួន
គ្របខ្លួនចិចចាំង ។ ខ្លះចុនសំបកចំពាំង មកគ្របមកចាំង មកកាន់រង
ក្មៀងគារខ្លួន ។ មរណមាតាស្រីសួន រងាគុបខ្លួន សំពត់តែមួយដោក
ជាំ ។ ម៉ែនហ៊ានអង្គុយដេរឃ្លាំ ដើរម៉ើលថែទាំ តៀងគោតាំងក្មៀងក្រែង
ជាត់ ។ លុះល្ងាចតៀងគោលែងថ្នាត់ អាសូរស្រែរត្អែ រងាញ័រអស់អង្គា ។
ព្រឹព្រួចសម្បុរពេមា ខំផ្ទប់ចាត ដោយដៃខ្លាចរលៃក្រែងដួល ។ រលើមខ្លួនឹម
ដង្កោល មេឃមីរភ្លៀងធ្លាល ស្រឡាប់ស្រោចពេញមា ។ មាត់សត្វស្រែ
ងាត់អង្គា លលុតចំពា ចោ៉ាលគោកក្មេកគ្រយង ។ ហូពូចាគួយ៉ាកង
ធ្វើយគ្នាសាសង សាសពូច្រវាត់ហើរចំ ។ ខ្លះហើរទៅរកគ្រួ ខ្លះចំយាស
យ៉ាំ ចាប់ចឹកផលាគោក្តា ។ ព្រឹនព្រួសជន្លួសត្រៀលស្វា ត្រមួងពុត្រា
ត្រមួចត្រមែងភ្លឹងភ្ជ ។ សត្វយំនើរតគួ អាអួតខុកត្រួ ពញាកត្រមាក់ខ្លាខ្លែង ។

(មានត)

រឿងស្មៅមួកកុក

ភាគទី ៣៧

ទោញ៉ាវិបុលភក្តិសេន ជួ-កិត្ត ប្រែរៀបរៀង

(តទៅ)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវិភាគវៃឆ្លាស បើបានអាន
> នឹងបេះទុបាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ។

ឲ្យស៊ីនគួនពាក់កណ្តាល ហើយនឹងស្បថស្បែតគ្នាជាបងប្អូន ម៉ិនបានគិតប្រទូសព៌យគ្នានឹងគ្នាតទៅ ប៉ើស៊ីនគួនយើញសំបុត្រ ក៏នឹងមានសេចក្តីគោតញ៉ាញ៉ើតបុណ្យនឹងច្រណ៉ា មហាឧបាជខ្លួចជាកំនឹងមកវាល់លោក ។ ចួនមួយល់យើញត្រូវ ទើបតែងសំបុត្រប្រើឲ្យមន្ត្រីក្តាន់ទៅស្រុកតាំងតាំង ហើយទើបឲ្យប្រុងប្រៀបរៀចចំបំរុងគ្រាចាន់តគោកចំពាកក ទុកស្រួចហើយវៃមឲ្យដំណឹងច្រាកដឡាខ្លីទៅថា គ្រាហានមហាឧបាជលើកទ័ពមកគ្រានេះតែ ១០០ ម៉ឺន ខ្មែងខ្លួនចម្បាំងវែលចតន្លៅជាយខ្នេងនោះ ប៉ើដូចជាឯងពាក់ទៅតាំងវាមួយហាសមុទ្រ ខ្លាងខ្លួនគាក់ខ្លេះ ក៏ឲ្យធ្វើបន្ទាយឆាយគ្នាបេញាទៅតាមរយ៉ៈផ្លូវដែល ប្រ ១០០ សិន (១២០ គ.ម.) ។

ឯស៊ុនតួន លុះដឹងថាបួនឆ្លើកទ័ពហួងកន្ធងមកដល់ស្រុកស៊ុងយ៉ុង ក្បាច់ឆន់ចេញទៅតំនាប់លើកស្រុកស៊ុងយ៉ុងឲ្យបួនឆ្លើយ ឥឡូវនឹងលើកទៅច្បាំងយកស្រុកតាំងឡងខៀត ស៊ុនតួនគិតក្នុងចិត្តនឹងមកដល់ស្រុក ទើបប្រឹក្សានឹងពួកខ្ញុំកដការថាំងភួងថា បួនឆ្លើកទ័ពមកនឹងវាយយកស្រុកតាំងឡងមុខជាមិនឈប់តែប៉ុណ្ណោះទេ នឹងធ្វើរំលងមកដល់ស្រុកយើង ។ នឹងគិតការប្រការម្តេច ? ។ ក្បាសុកធ្វើយថា ដែលនឹងការពារមិនឲ្យសឹកសត្រូវឆ្លងមកដល់ស្រុកនោះ ខ្ញុំបាទឃើញថាស្រុកកេងជីវានេះជាស្រុកធំ ពួកអ្នកស្រុកក៏ស្រុះស្រួលព្រមគ្រប់គ្នាបរិបូណ៌ បើយើងនឹងលើកទ័ពទៅវាយយកស្រុកកេងជីវា បានតាំងនៅឲ្យខ្ជាប់ខ្ជួនម៉ាំមួនហើយ នឹងបានម្តងអ្វីនឹងកងទ័ពបួនប៉ុណ្ណោះ ទោះលើសជាងនេះក៏នឹងការពារទុកមិនឲ្យសឹកសត្រូវចូលដល់ស្រុកបាន មួយទៀត បើបានស្រុកកេងជីវាហើយ ឃើញថានឹងតាំងខ្ជួនជាធំបាន ឥឡូវឲ្យក្បាច់ប៉ៀវគឹស្ងាប់ទៅហើយ ឲ្យពីសោតក៏បែកខ្ញែកតាំងខ្ជួនមិនបានបាន បែកទៅទៅនឹងឲ្យតែឯស្រុកតាំងវិហ ខ្ញុំបាទនឹងសុំយកអាសាធ្វើទុបាយតែងគ្រឿងសែន ធ្វើជាតំនាប់សពះក្បាច់ប៉ៀវ ហើយនឹងនិយាយល្បួងលួងលោមពួកអ្នកស្រុកនឹងមាហានក្នុងស្រុកកេងជីវា ហើយនឹងឲ្យតែឲ្យចុះចិត្តព្រមគ្នា ហើយក៏ឃើញថា នឹងធ្វើការកំចាត់បួនឆ្លើយបានដោយងាយ ។ ស៊ុនតួនឃើញត្រូវដួចចិត្ត កំចាត់ចែងរបស់ខ្លួនប្រគល់ឲ្យក្បាសុកទៅស្រុកតាំងវិហ ។

ឯខ្មៅតាកំប្រឹកក្បាលនឹងពុនបេនថា ចូរឆ្លៀកចំយមកគ្រានេះធំពាក្យណាស់ ខ្លាចក្រែងនឹងលើកតាមមកខ្មៀត យើងនឹងរិះគិតប្រការម្តេច ? ។ ពុនបេនឆ្លើយថា ដែលនឹងនៅក្នុងស្រុកគាំងហែនេះ យើញថាខ្ចីចង្អៀតចង្អល់ណាស់ បើចូរឆ្លៀកមកកំនឹងការរកពុំបានម៉ាមួន យើញថានឹងថ្លៃសការខ្មៀត សូមឲ្យលោកលើកទៅនៅស្រុកគាំងតាំងការស្រួយចំពីងស៊ុនគួនសិនចុះ បើសិនណាជាចូរឆ្លៀដឹងថាលោកទៅនៅនឹងស៊ុនគួនហើយ កំគង់តំនឹងលើកតាមទៅ ខ្លួចថាចូរឆ្លៀនឹងស៊ុនគួន កំគង់តំនឹងពុសចិត្តគ្នាឡើង យើងកំនឹងនៅជាកណ្តាល បើនរណាភ្លាត់ចំណាប់ សឹមយើងប្រញាប់ត្រួតដៃបន្ទុមយកឲ្យបានពុងដៃ យើញថាបានដំឃជំនះដោយងាយ ។ ខ្មៅតាឆ្លើយថា ដែលលោកគិតនេះត្រូវណាស់ តែស៊ុនគួននោះមានមនុស្សប្រកបទៅដោយដម្រេះប្រាជ្ញា ជួយគាំពារខំពុកចំរុងច្រើនណាស់ ខ្លាចក្រែងមិនត្រូវឡើយយើងនៅកំនឹងអប្បយសម្ចាស់គេ ។ ពុងបេនសើចហើយឆ្លើយថា ចូរឆ្លៀកចំតមកគ្រានេះសន្ធឹកសន្ធាប់ខ្លាំងណាស់ ដូចជាទឹងក្រឡាប់ស្រុតដែនដី មុខជាស៊ុនគួនទឹងតក់ស្លុតក័យខ្លាច នឹងប្រើមនុស្សស៊ើបការមកតាងយើង បើសិនជាយើញនរណាមកដល់លោក ហើយ ខ្ញុំនឹងសុំការស្រួយយកតែពួកតូច ១ ទៅជាមួយនឹងអណ្តាត ៣ ផ្ទាប់ទៅធ្វើឲ្យស៊ុនគួនពុសចិត្តគ្នានឹងចូរឆ្លៀបាន បើចូរឆ្លៀញ៉ាំកំនឹងចូលជួយខាងស៊ុនគួន បើយើញថាបានចំណាប់ហើយ យើងកំនឹងចូលដណ្តើម

យកស្រុកកេងនីវាជាកំរែខ្លះ ប៉ើសិនណា ស៊ីនតួនត្រឡប់ជាថាញ់គេ
យើងកំនឹងគិតកែខ្លះដណ្តើមយកស្រុកកាំងតាំងឲ្យកវិញ ។

ខ្លៅតាធ្វើយថាឯងគំនិតដែលលោកនិះគិតដូច្នះ កំយើញថាត្រូវ
តែថាបើនរណាទើមកកេ យើងនោះ កំនៅមិនទាន់យើញឡើយ តាល
ខ្លៅតាកំពុងនិយាយគ្នាទឹងទុងបេងមិនទាន់ផុតមាត់ ។ ពាហានត់ចូល
មកប្រាប់ថា ឥឡូវស៊ីនតួនប្រើខ្លៅសុកយកគ្រឿងសែនមកពីស្រុកកាំង
តាំង ទឹងមកគំនាប់សងខ្លៅវិញ ។ ខុងបេងក្បាហើយកំខះដៃអស
សំណើចហើយសួរខ្លៅតាថា តាលគ្រាស៊ីនកៀនចិតាស៊ីនតួនស្លាប់នោះ
អ្នកឆ្លាប់ចាននាំបេស់ៗគំនាប់សងដែរឬ ? ។ ខ្លៅតាធ្វើយថា ឯស្រុក
កាំងតាំងទឹងស្រុកកេងជីវាជាហារទឹងគ្នា ព្រោះចិតាខ្ញុំចាខសម្លាប់ចិតាគេ
ទឹងត្រឡប់ទៅគំនាប់សងដូចម្តេចចាន ។ ខុងបេងធ្វើយថា បើដូច្នះ
ដែលខ្លៅសុកមកគ្រានេះ យើញថា មិនមែនមកគំនាប់សងដោយ
សុចរិតទេ ប្រហែលជាមកស៊ើបយកការស្រុកទេសជាក្រាកជ ទើបខុង
បេងនិយាយទឹងខ្លៅតាថា បើខ្លៅសុកមកជួបទឹងលោកទឹងនិយាយការ
អ្វីដល់ចូរឆ្លើយការម្តេច លោកចូរនិយាយបដិសេធថាមិនដឹងអ្វីសោះ ទោះ
ប៉ីទឹងជដឹកសួរគេ ត្រូវឆ្លើយថាឲ្យទៅសួរខុងបេងវិញចុះ ។ ខ្លៅ
តា, ខ្លៅតាកំឲ្យបំរើទៅខ្លួលខ្លៅសុកនាំឲ្យឡើងមក ហើយកំរៀបតុ
រៀងអាហារឲ្យខ្លៅសុកមរិភោគតាមប្រពៃណី ។

ក្រុងលង្វេកសុភកំពុងចំរើនភាន [illegible] ក៏ស្តេចលង្វេកតាមថា ខ្ញុំបាទឮដំណឹងថា លោកមានដម្រិះប្រាជ្ញា ចាំងចិត្តក៏ល្អត្រឹមត្រូវណាស់ ជាទីសរសើរដល់មនុស្សទាំងពួង ខ្ញុំនេះជាមនុស្សបុណ្យតិច មិនបានជួបប្រទះឃើញលោកឡើយ ទើបមកជួបឃើញមុខក្នុងថ្ងៃនេះ ហើយក៏មានជាបុណ្យគ្រាបបស់ខ្ញុំទាំងណាស់ សូមខ្ញុំបានភ្ជាន់ដំណឹងមកលំនៅតាម លោកនឹងចូលចិត្តជាតន្ទឹក តើជាតិតមែនឬ ? ? ចូរឆ្លើយនឹងមានសេចក្តីពាក្យតិចប្រើនប៉ុន្មាន លោកប្រាប់ត្រង់ជាបានឬទេ ? ?

សាមកុកខ្សែ ៣៨

តាំងតីលង្វៀសុភកើសួរលង្វើតី ខុងបេងដាល់ដំណឹងតាងទំពូរ តាំងខុងបេងកើស្រុកតាំងតាំង បានតបពាក្យគ្នានឹងពួកតាមុំនស្រុកតាំងតាំង នឹងសុំតួន លុះសុំតួនប្រាប់សេចក្តីដល់ស្តាយបុង ។

លង្វើតីឆ្លើយថា ឯមនុស្សតាំងពីក្មេងរហូតមានសរសើរថា ខ្ញុំមានចិត្តល្អត្រឹមត្រូវនោះក៏មែនហើយ តែថាខ្ញុំមានគំនិតរិះគិតនោះមិនជាប្រមាណទេ តាំងពីតូចរហូតដល់ចាស់ ដែលក្តេរុះគ្មានឱនចុះឆ្ពោះមិនបាន បើសិនណាជាដឹងថាចូរឆ្លើយតបមកហើយ ខ្ញុំក៏ត្រូវតែរវេរគេចគ្រាន់តែយកតែខ្លួនឲ្យរួចទៅមិនហ៊ានទៅជិតទេ ហើយកម្រដែលនឹងដឹងយើញថា តាហានចូរឆ្លើយតបប៉ុន្មាន ដែលអ្នកមកសួរដូច្នេះខ្ញុំគិតស្រមៃចាស់ មិនដឹងធ្វើយ

ថាម្តេចទេ ។ ខ្លោសុកថា ខ្ញុំបានឮដំណឹងថា លោកបានច្បាំងនឹងបួនមួយ ខុនបេងបានប្រើកលទាយបញ្ឆោតដុតកងទ័ពខ្លួនអស់ ៦ ដង ឯបួនមួយក៏ស្ទុះតាមខ្លាច ហេតុម្តេចក៏លោកថាមិនដឹង ។ ខ្លៅពីថា បើអ្នកចង់ដឹងឲ្យជាក់ច្បាស់ ត្រូវទៅសួរខុនបេងចុះ ដែលនឹងសួរយើងនេះ ក៏ដូចជាសួរខ្យល់ទេ ។ ខ្លោសុកថា ឥឡូវខុនបេងនៅឯណា ? សូមឲ្យខ្ញុំបានឃើញមុខនឹងសន្ធឹងគ្នាបន្តិចផង ។

ខ្លៅពីក៏អញ្ជើញខុនបេងឲ្យចេញមកជួបនឹងខ្លោសុក ពាំនាំសងខាងក៏តំណាងគ្នាទៅរកទៅមក ។ ខ្លោសុកសួរខុនបេងថា ខ្ញុំបានឮពាក្យគេសរសើរដម្រែក្រាជ្ញាហោកកក្រែកអំពើកខ្លាំងណាស់ ដែលខ្ញុំបានមកជួបនឹងលោកថ្ងៃនេះ ជាវាសនានឹងរកទីបំផុតមិនបាន ខ្ញុំនឹងសុំសួរលោកបន្តិច ដែលលោកបានធ្វើការសង្គ្រាមតនឹងបួនគ្រានេះ លោកវិនិតប្រើកលទាយដូចម្តេច ? ។ ខុនបេងឆ្លើយថា ឯបួនមានប្រកបទៅដោយដម្រែក្រាជ្ញាទីណាតនិតតយើញច្រើន ខ្លួនខ្ញុំមិនអាចនឹងធ្វើការតទល់នឹងបួនបានទេ ព្រោះកំឡាំងខាងហានក៏តិច ទស្សាវ៍វេះគេចតាមកយកតែខ្លួនឲ្យរួច ។ ខ្លោសុកថា បើខ្លួនលោកនឹងខ្លៅពីតស៊ូនឹងបួនមិនបាន នាំគ្នាវេះរត់មក នឹងឈប់នៅប៉ុណ្ណេះឬ ។ នឹងវិនិតតវាងតទៅទៀត ? ។

ខុនបេងថា អាវស៊ីវៃហ្វាយស្រុកសាំងឆាំវ ជាមនុស្សក្លាប់ខាន

គ្នានឹងខ្លៅតែហៅហ្វាយខ្ញុំ ឥឡូវខ្លៅតែ កំតិតចង់ប្រែប្រួលទៅសុំពាក់
អាស្រ័យទៅផង ។ ខ្លោសុកថា ឯស្រុកសាំងតាំរនោះមុខុស្សម្នានឹង
ស្បៀងអាហារកំតិច តែខ្លួនអាស៊ីរនៅក្បែរឲ្យសុខមិនបាន តាលណានឹង
អាចហ៊ានការពារក្បែរអ្នកដទៃបានទៀត ។ ខុងបេងថា ដែលអ្នកមានប្រ-
សាសន៍នោះកំត្រូវហើយ តែថាឥឡូវទាល់តែនឹងជ្រក ហើយត្រូវតែទៅតឹង
ពាក់អាស្រ័យនៅសិនចំកាំងខ្លួនបាន ទើបរិះគិតការតទៅទៀត ។
ខ្លោសុកថា លោកនឹងទៅទីតឹងពាក់ នៅក្នុងស្រុកតាំងតាំងមិនល្អឬ ?
ព្រោះស៊ុនគួនហៅហ្វាយខ្ញុំកំមានចិត្តថ្លើមល្អត្រឹមត្រូវ កាប់អានខ្លួនៅគ្រប់
បណ្តាកស្តេចយ៉ាងស្និទ្ធ ស៊ីនតែបួលចិត្តស្រឡាញ់ជាច្រើន ហើយស្រុក
នោះកំបាំថ្លើចំណីត្រីសាច់ ឧដ្ឋស្រូវអង្ករស្បៀងអាហារ សុំលោកឲ្យ
បំរើទៅនិយាយនឹងស៊ុនគួនលេីលជាផ្លូវល្អដួងលោម ឲ្យបានជាចិត្ត
តំនិតមួយ ជួយគ្នារិះគិតកំចាត់ចេញ យើញថាទឹងបានសម្រេចដូច
សេចក្តីប្រាថ្នាវេស់លោក ។

ខុងបេងឆ្លើយថា អ្នកមានប្រសាសន៍នេះត្រូវក្រែពេក ខ្ញុំមាន
អំណរគុណជាអនេកណាស់ តែថាខ្លៅតឹងនឹងស៊ុនគួនោះ មិនជាប់ជាប់
អានគ្នាមកតាំដើម ពោះបីនឹងឲ្យទៅនិយាយកំក្រែងថាស៊ុនគួនឹងមិនប្រែ
ប្រួល បណ្តាលចិត្តឲ្យអាណិតអាសូរកុណា ·កំនឹកព្រួយការទៅទេ
មួយទៀត ឧដ្ឋរកមនុស្សពេះនិយាយ ឲ្យទៅជំនួសជាក្តែកប្រមុះនោះកំ

កម្រ ។ ខ្លោសុកថា សូត្រថ្លៃដូកាត់កន្ទបចន៍លោកកំប្លែនទៅនៅស្រុកកាំង តាំងជាទីប្រឹក្សាធំរបស់ស៊ុនតួនដែរ ចេះតែបន់ស្រន់បងឲ្យដួបនឹងលោក ជាជាតិ ឆុះនេះខ្ញុំនឹងសុំខួលឆាខាន់លោកទៅឲ្យដល់ស៊ុនតួនបានឲ្យត្រាតែបាន ។ ខ្លៅតាំងខ្លោសុកនិយាយដូច្នោះ ក៏ធ្វើយថា ឯខុនបងនេះ ជាគាថ្យរបស់ខ្ញុំ ប្រៀបដូចថ្មមប្រមាត់ បើឃ្លាតបាត់ពីខ្ញុំតែមួយស្របក់ក៏មិនបាន ធ្វើម្តេចខ្ញុំនឹងហ៊ានឲ្យទៅដល់ស្រុកកាំងតាំងនោះឡើយ ។ ខ្លោសុកក៏អង្វរលន់តួថា សូមឲ្យខុនបងទៅជួបគ្នានឹងចៅហ្វាយខ្ញុំបានម្តងចុះ ។ ខ្លៅតាំងក៏ធ្វើព្រងើយបែបមិនដឹងមិនឃើញខុនបងក៏ធ្វើជានិយាយនឹងខ្លៅតាំងថា ការគ្រានេះកំជួនជាប្រពាល់តួនឯងខ្លួនយើងណាស់មកហើយ ទឹងស្ងៀមព្រងើយមិនកើតទេ សុំលោកឲ្យខ្ញុំទៅបន្តិចចុះ នឹងបានដឹងការជួនស្រាសតិតតែប្រែក្សាខ្លួនទៅខាងមុខ ។ ខ្លៅតាំងថា បើដូច្នោះលោកនឹងទៅក៏ទៅចុះ ។ ខ្លោសុកឮហើយក៏ត្រេកអរសាទរ ទើបតាំងបំណាខ្លៅតាំង ហើយក៏នាំខុនបងទៅចុះទូកហើយថាបើលោកទៅជួបនឹងស៊ុនតួនហើយ កុំប្រាប់ថាបួនមានតាហានប្រើនុ ត្រូវប្រាប់ជាពាក្យតូចថាមានតាហានតិចទេ ខុនបងថា ខ្ញុំត្រង់នេះអ្នកកុំព្រួយឡើយ ខ្លួកជាភ្នាក់ងារខ្ញុំចុះ ។

ស៊ុះខ្លោសុកនឹងខុនបងទៅដល់ស្រុកកាំងតាំង កំពុងតែបងខ្ញុំសំណាក់ឲ្យខុនបងរង់ចាំដោយឯកមនស្ស ហើយក៏ចូលទៅជំរាបស៊ុនតួន ។

តំណួរថា អ្នកទៅស៊ើបស្តាប់កិច្ចការឯស្រុកកាំងវៃនោះ ដឹងការយ៉ាងម្តេចខ្លះ ។ ខ្សោសុកទូលថា ខ្ញុំបានទៅស៊ើបការនោះកំបានសេចក្តីមកហើយ តែថាដំណបលោកឥឡូវនេះមិនទាន់ស្រួលទេ ។ ស៊ុនគួនឮដូច្នោះទើបយកសំបុត្រដែលបួនឲ្យទៅនោះ ហុចទៅឲ្យខ្សោសុកមើលតាំងស្រាម ។ ខ្សោសុកទទួលហើយកំថា ដែលបួនឲ្យសំបុត្រមកនេះគ្រាន់ថ្នាំនឹងល្ហឹងក្បួនលោមឲ្យជាចិត្តមួយ ប្រយោជន៍នឹងបានគិតការតទៅមុខ យើញថាសេចក្តីនេះ មិនមែនមកដោយសុចរិតនឹងយើងទេ ឱយ ហើយកំហែកស្រោមចេញ មើលឲ្យស៊ុនគួនស្តាប់សេចក្តីថា ព្រះចៅហៀនតេឲ្យយើងលើកទ័ព ៩០ ម៉ឺន មកកំចាត់ខ្សៅចនចេញ ឥឡូវលើកមកកំបានស្រុកស៊ុនយ៉ុងនឹងអាណាខ្វែត្រស្រុកកេងជីវហើយ អាណាប្រជាទុក្ខស្តួកាំងតួងមានសេចក្តីត្រេកអរជ្រួន ឯយើងកំកាំពុងប្រមូលទាហានថែមទៀតបានដល់ ១០០ម៉ឺន នាយទាហាន ១០០ នៃមានចិត្តគិតដល់អ្នកទីនឹងចង់ជួបយើញមុខគ្នាម្តង សុំឲ្យអ្នកចេញមកដើរលេងក្រៃកន្លែងស្រុកកាំងវៃហែ ទីនឹងបានជួបគ្នានៃគិតកំចាត់ខ្សៅតាចេញ ព្រោះជាសត្រូវផែនដី បើសម្រេចហើយយើងនឹងបែងចែកស្រុកកេងជីវឲ្យអ្នកតាក់តណ្តាល ហើយយើងនឹងស្បថស្បែកគ្នាជាចិត្តថ្មីមួយតទៅ បើអ្នកយើញប្រការម្តេច កំឲ្យមានសំបុត្រតបទៅវិញឲ្យដឹងផង ។

ខ្សោសុកមើលសំបុត្រចប់កំសួរទៅស៊ុនគួនថា ចិត្តរបស់លោកទីនឹង

តិតប្រការម្តេចសោត ? ។ ស៊ុនតួនតបថាយើងនៅមិនទាន់ឃុនតិតគ្នាទេ ។
ខៀវចៀវទ្វើយថា ឥឡូវចូលឆ្នាំប្រមូលភាហានដល់ ១០០ម៉ឺន យកព្រះ
តម្រាស់ព្រះជៅហៀនតេមកនិយាយតាំងម្ល៉ះ ច្រាំថ្នាំនដើរតំបាត់អា-
ណាខៃត្រាំងអស់ឲ្យនៅក្នុងអំណាចខ្លួនតាំងអស់ ដែលលោកនឹងរិះ
តិតតស៊ូនឹងចូលឆ្នោះឥតអំពើទេ ទឹងអាស្រ័យឃុនកំត្រឹមត្រូវតែក្បែរជាយ
ខន្ធជារបាំង ឥឡូវមើចូលឆ្នាំឃុនស្រុកកេងជាវិហើយ ភាហានក្នុងស្រុក
នោះកំមិនប្រសប់ក្នុងដើងទឹកដូចគ្នានឹងស្រុកយើង ប្រសិនចូលឆ្នាំលើកទ័ព
ប្រទូសរ៉ាយស្រុកយើង ។ ក៏នឹងថ្លង់ការ សូមឲ្យលោកវិះតិតដោយ
ច្រាំថ្នាំនៅលន់តួចូលឆ្នាំដោយល្អចុះ អាណាប្រជាខុកស្តុកទាំងពួងក៏នឹងឃុន
ៈសេចក្តីសុខតទៅ បណ្តាទីប្រឹក្សាទាំងពួងឃុនឮខៀវចៀវនិយាយដូច្នោះ
ក៏ឆ្លើយទៅនឹងថា ដែលខៀវចៀវនិយាយដូច្នោះ យើញត្រឹមត្រូវតាម
ប្រវៃណីច្រាកដ ស៊ុនតួនកំនៅស្ងៀមមិនឆ្លើយថាប្រការម្តេច ខៀវចៀវ
ក៏វៃមនិយាយទៀនទៀតថា លោកកុំវិតក្តព្រួយឡើយ ចូរទំរិះតិតចេញ
នៅតំនាក់ចូលឆ្នាំចុះ ទើបឃុនសេចក្តីសុខ ។ ស៊ុនតួនក្រវីក្បាលហើយក៏នៅ
ស្ងៀម ១ ស្រចក់ ទើបក្រោកឡើងចេញពីទីជំនុំ ហើយដើរចូលទៅ
ខាងក្នុង ។ ខ្សោសុកក៏ដើរតាមទៅ ស៊ុនតួនចាប់ដៃខ្សោសុកចូលទៅ
ហើយនិយាយថា ដែលទីប្រឹក្សាទាំងពួងយើញដូចពាក្យខៀវចៀវដូច្នោះ
អ្នកនឹងតិតប្រការម្តេច ? ។

ខ្ញុំសុំក្រាបទូលថា ដែលអស់អ្នកចាំឆ្លងយល់ឃើញព្រមគ្នាទើបឲ្យ
លោកទៅគាប់ចូលនេះ ប្រយោជន៍យើញតែសេចក្តីសុខចំណែកដូចជា
ឲ្យបានខ្លួនទៅមុខវិញ ខ្ញុំបានម្នាក់ឯងមិនយល់ឃើញផងទេ សូមកុំឲ្យ
លោកចេញទៅគាប់ឡើយ ។ ស៊ុនគួនថា ដែលអ្នកមិនពេញចិត្តនឹង
ឲ្យយើងចេញទៅគាប់ចូលនោះត្រូវណាស់ តែសេចក្តីរិះគិតរបស់អ្នកនឹង
ឃើញប្រការម្តេចខ្លះ ? ។ ខ្ញុំសុំក្រាបទូលថា ខ្ញុំបានឃើញថាចូលឬ ?
នឹងចាញ់មេលោកឲ្យឆ្កួជាង់ ពោះបើនឹងខំនុកចំរុងកំគ្រាន់តែជាប្រមាណ
បើប្រសិនឲ្យមានថ្វាយព្រាវដើរតាមក្រោយ យ៉ាងច្រើនណាស់ កំត្រឹមតែ
៤នាក់ប៉ុណ្ណោះ ពោះបើនឹងឲ្យមានសេះជិះកំតែ ១, នឹងបានឲ្យដូចលោក
ទៅជាឯកចិត្តក្នុងស្រុកគាំងតាំងតែម្នាក់ឯងក៏ទេ ដែលអ្នកពាល់គ្នាយល់
ឃើញព្រមល្មមនោះ ក៏ប្រយោជន៍តែឲ្យខ្លួនមានសេចក្តីសុខចំណែកឯង
នឹងបានជួយឈឺចាប់ក្នុងចិត្តដូចលោកដូចខ្ញុំបានក៏ទេ ដែលលោកនឹងរិះ
គិតធ្វើការនេះនឹងចូលនោះ មិនត្រូវជឿស្តាប់ពាក្យសំដីអស់អ្នកចាំឆ្លងអម្បាល
ពោះតទៅឡើយ ចូរទំរិះគិតប្រឹងប្រៀបការនឹងក្បាលខ្លួនឲ្យមាំមួនចុះ ។
ស៊ុនគួនជក់ដង្ហើមធំហើយថា: ខ្លួនខ្ញុំអត់ឮបង់កំឡាំងនឹងចំបណ្តុះ
បណ្តាលមនុស្សអស់ចាំងនេះទុក ប្រាថ្នានឹងយកជាវិតិគ្រោះឲ្យដឹងការ
ខុសត្រូវធ្ងន់ស្រាលជួយឃើញតំណាងទេទេសោះ ឃើញតែខ្លួនអ្នក ១
មានតតាំងទៀងត្រង់ស្រឡាញ់ខ្ញុំមែន ។ ឥឡូវចូលក៏បានឱកាសហានអួនស្រួល

ខ្ញុំកជាឈ្លើយច្រើនណាស់រឹតតែមានចិត្តកំរើកឡើង ដែលរាយើងនឹងតតាំង
ការតទល់នឹងចូរធ្លោះនឹងកែប្រែយ៉ាងម្តេចទើបបានល្អ ? ។ ខ្លោសុក
ថា តាលខ្ញុំបានទៅស៊ើបស្តាប់ការឯស្រុកកាំងហែរនោះ ខ្ញុំបានជាន់ខ្លួន
ខ្លះចេងប្លន់ឬសដូតាត់កំនមកជាមួយ ថើលោកចង់ដឹងការកំពាក់ព្រៀងធ្លន់
ស្រាលព័ចូរធ្លប្រាការម្តេច សូមឲ្យលោការោខ្លួនខ្លះចេងមកសាកសួរ
រមើលចុះ ទើបនឹងជ្រាបច្បាស់ ។ ស៊ុនគួនថា អាចារ្យហ៊ុនឡឹងមកនៅទីនេះ
ដែរឬទេ ? ។ ខ្លោសុកថា ខ្ញុំនាំមកចាតចែងឲ្យសំណាក់នៅខាងក្រៅស្រុក ។
ស៊ុនគួនពន្លូថ្មោះត្រេកអរណាស់ ទើបថា ថ្ងៃនេះដួនពេលយប់ទៅហើយ
ចាំថ្ងៃស្អែកព្រឹក អ្នកចូរនាំខ្លះចេងចូលមកជួបនឹងយើង, ស៊ុនគួនក៏
ឲ្យរៀបចំទីកន្លែងដែលនឹងទទួលពួកទាំងមុខមន្ត្រី ប្រជុំទិយាយការឲ្យ
ជាទីរឿងព្រឿងច្រើនឲ្យបង្អួតឲ្យខ្លះចេងឃើញ ហើយចាត់កំណត់ឲ្យនាំខ្លួន
ទាំងពួងចូលមកជួបជុំព្រមគ្នាក្នុងវេលាព្រឹកស្អែកឲ្យអស់ ។

លុះវេលាព្រឹកនោះ ខ្លោសុកក៏ទៅជួបនឹងខ្លះចេង ជំរាបថា ស៊ុន
គួនឲ្យខ្ញុំមកអញ្ជើញលោកចូលទៅ តាក្យដែលខ្ញុំបានចរចានឹងលោក
កណ្តាលផ្លូវនោះ លោកកុំបីភ្លេចឡើយ ។ ខ្លះចេងអស់សំណើចហើយ
តបថា អ្នកកុំរវិតក្តព្រួយឡើយ ។ ខ្លោសុកក៏នាំខ្លះចេងចូលទៅគាន់តែប្រជុំ
ដើម្បីនឹងទៅតំនាច់ស៊ុនគួន លុះទៅដល់ទីជាន់ក្រោ ខ្លះចេងក្រឡេកឃើញ
ទីប្រឹក្សាសុទ្ធតែនាម៉ឺនតែងខ្លួនគេញយស អង្គុយចុះនៅថ្លែរៀងគ្នាជា

លាងដាច់ កំចូលទៅតែមាច់តាមប្រវេណីតាំងអស់គ្នា ប្តូរសន្ទូនាសាកសួរសុខ
ទុក្ខទៅវិញទៅមក ។ ខៀវចៀវយើញខុនបេងរួបតងស្អាតជាត - តែងខ្លួនមៀនសមជាអ្នកមានសំដីចរចាធ្លៀវធ្លាត កំតែងប្រមាខុនបេងនេះប្រហែលជាមកនិយាយបញ្ចុះបញ្ចូលមើលខ្លែបមាយជាក្រាកជ ត្រូវតែយើងចរចាសាកសួរតាមបរស្តាប់ តំណាំងប្រាជ្ញាទើងជម្រេះរិះគិតជាប្រការម្តេច ខៀវចៀវកំនិយាយថា តាដើមខ្ញុំដឹងថាគាចរបុងឡុងទៅដំបន់ភ្នំអាំងក្បាំងកាំង ឮគេនិយាយថា ប្រកបទៅដោយសតិបញ្ញាជាច្រើនដូចគាភរប្អូនតុងដាក់យើមែនដូច្នោះឬ ? ។

ខុនបេងធ្វើយថា ដែលគេសរសើរខ្ញុំនោះ គ្រាន់តែយើញបញ្ញាទាំងក្រៃ ដែលបានធ្វើការមកនោះកំដូចអ្នកពាំងពួងសំគាល់ ព្រោះការនោះមិនជាក្រលំបាកណាស់ណាទេ គេបើនណា ។ កំតែងធ្វើបាន ឯបញ្ញាទាំងកងនោះ នរណាទើងគាចកន្ទុងដឹងឲ្យយើញច្បាកដនោះគ្មានទេ ។ ខៀវចៀវថា ខ្ញុំបានឮគេដំណាលថា ខ្លៅតីទសព្វាហ៍ធ្វើសេចក្តីព្យាយាមទៅអញ្ជើញអ្នកដល់ ៣ ដងទើបបានអ្នកមក ខ្លៅតីមានអំណាចដូចត្រីបានទឹក ទើបតំរើកចិត្តគិតទឹកធ្វើការពំនូលាយទៅមុខ ចំរើនទើយកស្រុកកេងជាវិឡៃបានជាច្រាកជ ទុកដូចសន្ទូតទៅកងកណ្តាប់ដៃវិស័យដូចយកពាក្យមកគ្រាលអង្គុយភ្លាមដោយងាយដូច្នោះ ហេតុម្តេចស្រុកកេងជាវិនោះ កំត្រឡប់បានទៅជូនវិញ តើអ្នករិះគិតប្រការម្តេច ? ។

ខ្ញុំនឹងឮដូច្នោះក៏គិតថា ខៀវចៀវនេះជាចិត្តក្លាធំរបស់ស៊ុនតួន មានច្បាប់ជ្រៅខ្លាយណាស់ បើអញមិនតបឆ្លើយឲ្យពាល់នឹងពាក្យប៉ុណ្ណោះ គាលណានឹងបានតបនឹងស៊ុនតួនបានតទៅ គិតហើយក៏ធ្វើយថា ដែលខ្ញុំនឹងគិតធ្វើការយកទីដែនដីដែនស្រុកគេឯដូវនោះងាយណាស់ ក៏ដូចជាត្រឡប់ចាតដៃជាខ្លួនដៃភ្លាម ។ ពោះបើនឹងត្បាយាមធ្វើគាលណាបើនឹងបានសម្រេចគាលណោះ តែហេតុទាំងនេះ ក៏ព្រោះចៅហ្វាយខ្ញុំជាមនុស្សត្រង់ពិត គាន់សេចក្តីសុចរិតមិនគិតច្បាច្បាដែលនឹងដណ្តើមយកសម្បត្តិរបស់សែជាមួយគ្នា មិនព្រមធ្វើតាមពាក្យខ្ញុំ ទើបបានសេចក្តីព្រួយលំបាក មកនឹកគួចចិត្តដូរ្តាតឡើងនៅក្នុងចម្រៀងដែលគាន់យកពាក្យសំដីមនុស្សវែឡចឡចលចលើកចេកស្រុកស៊ុងយ៉ុងទៅប្រគល់ឲ្យចូនួ ចូនួ ទើបឡើងចិត្តគិតធ្វើការធំពន្ធឹកមកដល់ម្ល៉ះ ឯឡាតាចៅហ្វាយខ្ញុំនេះក៏មកតាំងនៅស្រុកកាំងវែហវិញ ច្រើនឆ្នាំនឹងធ្វើការឲ្យបានចំណេញធំតទៅទៀត មិនមែននឹងលាក់មុខដេកនៅស្រឡាំងៗ តែថាដូចយ៉ាងដូម្រែច្រើនជាអ្នកគ្រាន់តែជាការប្រឆាណប៉ុណ្ណោះ ពោះបើខ្ញុំនឹងលួកកេះច្រើនឲ្យឃើញដល់ការកក់ក្តៅ ក៏ទៅមិនអាចដឹងដល់ស្គាល់បានសោះដូចជាយកតែនូវទៅបោះជាក់កន្លាងដែលឯងឹត អាចនឹងចិញ្ចាំងរស្មីមិនភ្លឺស្វាងសោះឡើយ ។

ខៀវចៀវថា អ្នកនិយាយយ៉ាងនេះ ខ្ញុំភ្លាចមិនដូចពាក្យថាច្រើកដតែថាតែមាត់ស្រាប់ ម៉ាត់ថាទៅមានណោះ ដើងដើរទៅមានណោះឲ្យខុស

ឆ្នាំទៅ ឯអ្នកនគរដ៏ជាកំណាយនោះបានជាទីចង់ប្រកបដោយសតិបញ្ញា
អង់អាចដូចពាក្យសុភាសិត ជួយទំនុកបំរុងផែនដីព្រះចៅដ៏ហួនកុងត្រុបសត្រូវ
ស្រែកថាប ស្រុកខេមរកំដាសុខក្សេមក្សាន្តមែន ។ គួរមនុស្សត្រិះពិចារណា
លើកសរសើរថាមានដម្រេះប្រាជ្ញានោះពិតណាស់ យ៉ាងដូចខ្ញុំអ្នកនេះ
គាលទៅក្នុងទីដែលខ្លាំងកាំងនោះ ឮសព្ទសម្បាញថាមានប្រាជ្ញាទីដ៏តំនិតចេះ
រិះគិតប្រាកដណាស់ ប៉ាដូចជាដើងធ្លុះហូតទៅក្នុងដែនដីឬអាកាសកាំង
អស់ កាលខ្លៅតែមិនទាន់បានអ្នកមកទុកជាទីពឹងគ្រោះ កំរែងគិតធ្វើ
ការសម្រេចទៅបាន ហើយមានស្រុកខេមតាំងទៅជាសុខតាមវាសនា
នៃខ្លួន ឥឡូវបានអ្នកមកទុកជាទីប្រឹក្សាជាមាំមួន ឲ្យជួយទំនុកបំរុងការ
ដែលធំពន្ធឹក កំនឹកថាបានសម្រេចទៅតាមកំណើដម្រេះរិះគិតរបស់អ្នក
ហើយ ហេតុម្តេចខ្លៅតែរឹតតែមានសេចក្តីទុក្ខក្តៅទៅមិនបានសុខ
សោះ ឃើញថាទុក្ខតំដ៏អស់ខ្លះលើសតែដើមទៅទៀត ចេះតែព្រួយចង្អៀត
រត់ចោលទីកន្លែង ដោយចិត្តដេញមិនឈប់ មកជ្រកតួនទៅដូចកណ្តុរ
រត់តែអង្គប់ សូម្បីតែផែនដីជាម្តប់ប៉ុនស្លឹកពុទ្រាកំពេទៅជារបស់ខ្លួនមិនបាន
នេះហើយឬ ដែលខ្លៅតែបានអាស្រ័យសេចក្តីគិតរបស់អ្នកជួយទំនុក
ទំនុកបំរុងនោះ មនុស្សពាលតួនតាំងគ្នាមកសរសើរថា អ្នកមានដម្រេះ
ប្រាជ្ញាដូចខ្ញុំតុងដ៏ជាកំណាយនោះមិនសមសោះ ដែលខ្ញុំនិយាយតាំងអស់
នេះតាមដោយការពិត អ្នកក៏កុំអាលតួចចិត្តលួមរិះគិតតទៅទៀតបុះ ។

ខ្ញុំដេងឮដូច្នោះ តំយកដៃចិចមាត់ ហើយគិតសំណើចរួចនិយាយថា ធម្មតាអ្នកមានទ្រព្យជាដែលពិស្តារ តោះបើនឹងគិតការអ្វីតំរង់ទូលាយដោយកលល្បិច អ្នកមានទ្រព្យតិចក៏មិនអាចនឹងដឹងរហូតទៅបាន ចុះមាដូចស្តេចត្រកួដ៏ប្រសើរ តោះបើនឹងហ៊ានទៅគាន់ទិសដំបន់ណា តំរមែងផ្ទោះទៅលើអាកាសដ៏ខ្ពស់បំផុត ជាត់ទៅនឹងស្រមាប់មេឃលើ មិនបានហ៊ានចាបដូចសកុណជាតិដទៃ ដែលមានកំឡាំងតិចនោះឡើយ ឯអ្នកដែលមានជម្រះទ្រព្យតិចនោះ ចុះមាដូចបក្សាទាំងពួង ដែលមានកំឡាំងតិច មិនអាចហ៊ានស្មើនឹងស្តេចត្រកួនោះឡើយ , ១ទៀត ការដែលគិតធ្វើអ្វី ។ ដ៏ជាធំពន្លឹក នឹងនឹកគិតយកដោយស្រួតរួតឲ្យហ៊ានសម្រេចតាន់ចិត្តនោះមិនបាន ចុះមាដូចមនុស្សមានជម្ងឺឈឺធ្ងន់ធ្ងរខ្លាំង តេទ្យអ្នកព្យាបាលរកគ្រូពេតត្រូវដំបិនថា ខ្ញុំដែលប្រកបថ្នាំឲ្យបានសំគាល់ក្តារលើសគាគារជម្ងឺ កំឡាំងមនុស្សដែលឈឺកំរិតឡើយ ខ្ញុំដែលណាយតាមកំឡាំងថ្នាំពុំបាន ត្រូវតែចាំឲ្យជម្ងឺនោះធូរស្រាកស្រាន្តតាមពេលវេលា ព្យាយាមថែរក្សាពាល់តែជម្ងឺនោះខ្លួលអាហារបានច្រើនមានកំឡាំងហើយ ទើបតេទ្យប្រកបថ្នាំឲ្យលេចធ្លឹកបំរុងពេតនោះ ឲ្យថយទៅត្រាតែសះជាស្រឡះ ដូចយ៉ាងខ្ញុំតាចៅហ្វាយខ្ញុំ ដែលថ្លង់ការណាស់នឹងចូលរត់ចេញមកពីស្រុកយីឡាំទៅនៅស្រុកសុខនេះអ្វី ខ្ញុំពីដែលចៀវនោះសោត កំមានតាហានឯកតែ ៣ នាក់តើ គួនអ្វី , ទៀវហ៊ុយ , ដូច្នឹងប៉ុណ្ណោះ

ឧដ្ឋកូនតាហានទោះកំមិនដល់ខាន់ ដូចជាមនុស្សមានដំម្ងីឈឺចុះដូច្នោះ
តាលហៅទៅស្រុកស៊ុនអៀនោះ មិនមែនទឹងច្រាំថ្មតាំងខ្លួនជាធំនៅទី
នោះកំពេ គ្រាន់តែចាំចិត្តនៅ ព្រោះកេទីតាស្រីយពុំទាន់បាន, ១ ទៀត
ទីនោះកំជាបុរីស្រុកជនបទ មានមនុស្សក្រខ្សត់ស្តួចស្តើងតាំងស្បៀង
តាហាកំតិច បានជាមិនបានតាំងចិត្តនឹងសម្រេចរៀបចំស្រុកភូមិឲ្យ
រៀបរយ ទោះប៉ុយាំងនោះហ៊ុយក្តី ខ្ញុំកំបានដុតទ័ពបួនរួចមកនៅ
ទីវាលភុកបងម្តង នៅទីទន្លេបែះហោម្តង ខ្ញុំក៏បានបង្ហូរឈាមឲ្យលិចទ័ព
បួនស្លាប់អស់ជាច្រើន ដែលអ្នកថាខ្ញាន់តុងដាំកំយេល្អនោះកំនៅមិនទាន់
ប្រាកដជាបានធ្វើ។បាយកលក្នុងការសង្គ្រាមទៅទីណាដូចយ៉ាងខ្ញុំ កំឥត
អង្គីមាន ទោះប៉ុបួនបានស្រុកស៊ុងយ៉ុងគ្រានេះ កំមិនមែនយកបានដោយ
តលក្តារ បានតាគ្រោះឧៀបងងតប់តគ្នាទឹងមនុស្សអន្ធតាលលបលើក
ទៅឲ្យបួន ឯឧៀពីរៅហ្វាយខ្ញុំ កំមិនបានដឹងឃើញសោះ វាលា
នោះ ប៉ើរៅហ្វាយខ្ញុំមិនស្រុះស្រួលញ៉ាំសេចក្តីសុជរិត ប្រហែលពួកស្រុក
កាំងតាំងនោះ កំតង់ទឹងដណ្តើមយកតាំងស្រុកកេងជាវាងបាន កាបេ
ណាទឹងមានលំបាកដល់ទីនេះ ព្រោះតែចិត្តត្រង់សុចរិតដូច្នេះ ទើបមិន
បានតតបៀតបៀនដល់ពួកសៃជាមួយគ្នា ស្តីប្រាំឆ្នាំបានសេចក្តីលំបាក
វេទនាដូច្នេះ ហើយឯថែមតាំងម្ភៃទៅទៀត តីចាំសណ្តោងយកអស់ពួកអ្នក
ស្រុកដែលលើកគ្នាតតាមតាំងត្រូបត្រដោយសារស្រុកញ៉ាំឧៀពីរ ទឹង

ដោះយកតែខ្លួនគឺជាប់ចិត្តអាណិតអាសូរ ចាន់ជាចូលរួមកាត់តាមពាន់ប៉ាន
តយុទ្ធការពារជាយលំបាក ទើបត្រឡប់ជាតវៅនៅស្រុកគាំនរហើយវិញ
ដែលពួកតិចអាចតស៊ូនឹងពួកច្រើនបានយ៉ាំនេះ មានតែចៅហ្វាយខ្ញុំមួយ
ទើបហ៊ានធ្វើដូច្នេះ ក្រៅពីនេះគ្មាននរណាមួយដូចសោះ ឯការចាញ់
ទឹងឈ្នះនៃការសឹកសង្គ្រាមនោះជាធម្មតាប្រវត្តិមានមក មិនមែនថយ
ចៅតែត្រឹមចៅហ្វាយខ្ញុំទេ កាលគ្រាព្រះចៅហាន់គោចធ្វើសឹកនឹង
ព្រះចៅឈប៉ាអង្គក៏មានចាញ់ជាច្រើនដងណាស់ លុះឯក្រោយចង្អុរទើប
ព្រះចៅហាន់គោច មានជ័យជំនះអស្ចារ្យ ក៏បានជាក្សត្រិយ៍ដ៏ប្រសើរ
ឯដំណើរវឿងនេះ អ្នកកំសួមនឹងជ្រាបស្រាប់ហើយ យ៉ាងដូចអ្នកឯង
ប្រហែលចេះតែសំដែងសំដីនិយាយគ្របសង្កត់អ្នកដទៃទេ ហើយប្រៃ
លើកដំកើងខ្លួនថាល្អ បើប្រសិនជាមានការគម្រាមកដល់ខ្លួនក៏នឹងភ្ញាច
មិនអាចនឹងចេះប្រសប់ធ្វើឲ្យដូចពាក្យថា ការមួយរយ ភ្លេចធ្វើបាន
តែមួយ ក៏ប្រហែលមិនគើតរសោះ អំណើះពៅមុខ ក៏នឹងបានសេចក្តី
អប្បិយសដល់មនុស្សពាំនួន ។ ខៀវចៀវបានស្តាប់ទុនបេងថាឲ្យដូច្នេះ
ក៏ស្ងៀមស្ងាត់នឹងរកពាក្យតែ១ មាត់ធ្វើយតពៅខៀតពុំបាន ។

ខណៈនោះយីហ៊ួនឃើញខៀវចៀវស្ងៀមនៅហើយ ក៏ធ្វើយតប
ពៅទុនបេងថា គ្រានេះបូធូរលើកពាហានមក ១០០ ម៉ឺន ចឹងដូចរលក
សមុទ្រចាកជាន់សង្កត់ស្រុកគាំនរហើយឡើងពៅក្នុងចាតសាន រួកនឹង

តែតរៃក្រៅជាតាវោរប្រកាវម្តេច ? .. ។ ខុដ៏បេដ៏ធ្វើយតបទៅយីហ៊ីន
វិញថា ចូចូរលើកទ័ពមកគ្រានេះ អ្នកនឹងភ្ជាចណាស់ឬ ? ខ្ញុំគ្មានព្រឺ
ព្រួយតែក្តីអ្វីសោះឡើយ ពោះចំបូចូរមានទាហាន ១០០ ម៉ឺនកំមែន តែ
ថាសុទ្ធតែទាហានអ្នកនៀវដែលជាជាតិអ្នកស្រែ ស្រុកវៃព្រលើក្តើតាំងអស់
គ្នា ចូចូរនឹងប្រើការកំមិនមែនបានមុតទាំប៉ុន្មាន យើងកំមិនមានព្រួយ
បារម្ភសោះ ។ យីហ៊ីនអស់សំណើចហើយថា អ្នកបរាយាំងនេះ
ដូចជាលើកខ្លួនណាស់ ដែលបែកទ័ពតត់មកតាំងម្ល៉ះមិនពីព្រោះទាហាន
ផ្តេសផ្តាសនោះទេឬ ? បានជាភ្ជាក់ខ្លួនមកនៅស្រុកតាំងហែ បើអង្វរឲ្យ
គេជួយនៅបរាថា មិនភ្ជាចទៀត ខណាខុដ៏ជឿបាន ។

ខុដ៏បេដ៏ថា ដែលខ្ញុំបែកទ័ពមកនោះ កំព្រោះឲ្យតាហ្វាយខ្ញុំ
មានទាហានតិចតែ ៣ ពាន់ គឺតិចបំផុត ទើបគិតដោយល្បិចតត់មក
លាក់លៀមទៅស្រុកតាំងហែសិន មិនមែនខុដ៏ភ្ជាចថ្វាដៃចូចូរតែម្តងកំទេ
តង់ទៅរៃរេតិតធ្វើការតេវល់តទៅទៀត ឯស្រុកតាំងតាំងនេះ មនុស្សច្រំ
ណុះស្រុកកំច្រើន ទាហានកំកើនលើសលុបប៉ុនប្រសប់ស្មើគ្នា ថែម
តាំងស្បៀងអាហារទៀតកំបរិបូណ៌ ហើយមានខ្នងទ្វាន់ជាកំណាន់
ទៅមាំមួនណាស់ ជាជាងស្រុកស៊ុនអៀទៅទៀត ហេតុម្តេចកំមិក
តិតទ្វាក់ទ្វៀត តែនឹងឲ្យតាហ្វាយរបស់ខ្លួនទៅចុះចូលចូចូរតែម្តង ដូចជា
មិនមានសេចក្តីតៀនខ្ជាសសោះ ដែលអ្នកថា តាហ្វាយខ្ញុំភ្ជាចចូចូរនោះ

បើនឹងពិគ្រោះមើលកំរើយើញបើដូចជាខ្ញុំចតិចសមគួរ មិនស្មើនឹងពួកអ្នកឯណាក្រៃខ្ញុំចនោះទេឬយ ។ យើហ្នឹងស្តាប់ហើយកំពាល់តំនិតក្រុងជ្ញានឹងហាមាត់ធ្វើយទៅទៀតក៏ពុំបាន ។

ចៅហ្វាយើញយើហ្នឹងនៅស្ងៀមដូច្នោះ ក៏ធ្វើយតបៈទៅទុនឹងបេងថាអ្នកនេះបានរៀនខំយោយមកពីសំណាក់សោជន , ខ្ញុំវើយប្ត ? អ្នកមកពោលពាក្យដូច្នេះ ក្រុងថ្នាំនឹងបញ្ជុះបញ្ចូលពួកស្រុកកាំងតាំងឲ្យចុះចិត្តឬក្អី ? ។ ទុនឹងបេងធ្វើយថា អ្នកដឹងតែថាសោជន , ខ្ញុំវើយនោះ ជាមនុស្សពូកែខាងសំដីណាស់ ឯក្រុងដម្រេះក្រុងជ្ញានឹងតំនិតដែលរិះគិតរបស់សោជននឹងខ្ញុំវើយ ដែលចេះជ្រៅជ្រះប្រកាន់ម្តេចនោះ អ្នកឥតដឹងសោះ អ្នកចរចាដូច្នេះបើដូចជាមនុស្សពាក់កណ្តាលមនុស្ស ព្រោះថាដឹងមិនរហូត ឯសោជននោះបានធ្វើជាទុកជដល់ ៨ ខែក្រ , ខ្ញុំវើយសោតក៏បានជាទុកជដល់ ២ ផែនដី អ្នកពាំង ២ នេះមានដម្រេះក្រុងជ្ញាជ្រៅខ្លួលាយណាស់ ជួយទំនុកបំរុងផែនដីឲ្យកបាបជង ១ ទៀតជាអ្នកក្លៀវក្លាក្នុងការសង្គ្រាម ដែលអ្នកមកនិន្ទាថាជាមនុស្សពូកែខាងសំដីមិនគួរសោះ យ៉ាងខ្លួនអ្នកឯងពិតល់ឮ គ្រាន់តែឮដំណឹងថាចូរចុំណ្ងោះ ក៏ភ្ញាក់ខ្លួនទៅណាស់ លួងលោមឲ្យចៅហ្វាយជាម្ចាស់របស់ខ្លួនចេញទៅចំណុះចុះចូលសត្រូវមិនភ្លាសមាត់ទេឬ ? ទៅមកតិះដៀលអ្នកដទៃវិញ ចៅហ្វាបានឮទុនឹងបេងថាដូច្នោះ ក៏ពាល់ទៅស្ងៀម ។

ស៊ីហនីក៏ក្រោកឡើងសួរទុនីវេលីថា ចូរធ្វើនោះជាមនុស្សយ៉ាងម្តេច អ្នកស្គាល់ឬទេ ? ។ ទុនីវេលីថា ចូរធ្វើនោះជាសត្រូវនឹងព្រះចៅហៀនតេ ខ្ញុំណាកើតមានស្គាល់បានតាំងអស់ ហេតុម្តេចក៏អ្នកមកសួរដូច្នេះ ។ ស៊ីហនីធ្វើយថា កាលព្រះចៅហាន់គោចបានសោយរាជសម្បត្តិជាក្សត្រិយ៍ជាជ ដែនដីក៏អាចបានសេចក្តីសុខមកយូរអង្វែងប្រាកដ តែឥឡូវដែលអំណាត់ដែនជ័យនឹងកើតចលាចលហើយ ចូរធ្វើឲ្យប្រុងប្រយ័ត្នប្រមៀងត្រង់ណាស៊ីមាឲ្យនៅកងអំណាចរបស់ខ្លួនដល់ ២-ញាតិនហើយ ខ្ញុំតែចាំហ្មាយអ្នកមិនបានដឹងឮស់លក្ខណៈការធ្ងន់ស្រាលគួរឬ មកបណ្តាលចិត្តគិតហានតស៊ូនឹងចូរធ្វើដោយរួសរាន់ ដូចយកតតីមានទំនៀមជាដំណឹងអន្តរាយទៅឯណ ។ ទុនីវេលីថា អ្នកនិយាយដូច្នោះមិនត្រូវសោះ ឯខ្ញុំតែចាំហ្មាយខ្ញុំនោះប្រាកដជាមនុស្សសុចរិតកតញ្ញូនឹងដែនដីតែ ដែលខ្ញុំបានទំរាំតែតធ្វើការ តាំងម្ល៉ឹងក៏ឃើញថាជាមនុស្សល្អត្រង់នឹងព្រះចៅហៀនតេជាមហាក្សត្រ ឃើញថាចូរធ្វើជាសត្រូវកាជសម្បត្តិ ទើបបណ្តាលចិត្តឲ្យឈឺក្តៅនៅពុំសុខ ខ្ញុំទំមករាធុក្តវេទនាដើម្បីនឹងតបស្នងគុណព្រះតេជព្រះគុណម្ចាស់ដែនដី ដូចយ៉ាងខ្លួនអ្នក ក៏ជាមន្ត្រីខ្ញុំដែនដីត្រកូមព្រះចៅព្រះចៅហៀនតេដូចគ្នា ហេតុអ្វីក៏មិនមានសេចក្តីស្នេហាកតីស្រឡាញ់ម្ចាស់ក្រឡះយើញត្រូវខាងសត្រូវដែនដីវិញ គឺជាមនុស្សអកតញ្ញូគាក្រក់ណាស់ ទើបមកថ្នាស់តាន់យកថា តារដែនដីនឹងសាបសូន្យនោះជាស្រួល ពាក្យ

សំដីរបស់អ្នកគោលដូច្នេះ ខ្ញុំមិនចង់ឮចង់ស្តាប់តទៅឡើយ ។ ស៊ីហន
ឮនឮដូច្នោះហើយ កំអត់ទ្រាំក្នុងចិត្តហាមាត់មិនរួច ។

ឡុកចេកក៏ក្រោកឡើងសួរខុងរបង់ថា ឯបូជ្ឈនោះពោះបិនិដ្ឋប្រព្រឹត្ត
អាក្រក់អែបយកព្រះដម្រាស់ព្រះចៅហៀនតេ ដើរប្រាប្រាមសង្កត់សង្រែ
ខ្ណាំណាំងតួនឲ្យផែនដីជាចលាចលកំមែនបុះ តែព្រោះបូជ្ឈនោះជាពូជអម្ប៉ូ
រេបស់បូធាំដែលជាឧបាជតីផែនដីមុនមក ឯឡៅតីវិញជាពូជក្សត្រិយ៍រង
ឆ្នាះដំណតីព្រះចៅហៀនតេ យ៉ាងម្តេចយើងក៏មិនដឹង ដឹងតែថាត្រកូល
ឡៅតីនោះជាមនុស្សអនាថា ខ្លួនឡៅតីសោតក៏រកស៊ីត្បាញសំពត់លក់
ជារបរតួចតាច គួរឬទីងមកអង់អាចមិនគិតដៀមខ្លួន ហ៊ានតស៊ូនឹងបូធ្ន
នោះយើងមិនយើញផងសោះ ។

ខុងរបង់ថា អ្នកនេះឬជាឈ្មោះឡុកចេក កាលនៅក្មេងតួចល្អចំនេ
យកទៅឲ្យម្តាយ អង្គុយទៅចុះយើងនឹងនិយាយជន ដែលអ្នកពាក់អានថា
បូធ្ន្ជាពូជអម្ប៉ូរនៃបូធាំក៏មែនហើយ តែបូធាំគោះជាមនុស្សមានកតញ្ញូទឹង
ម្ចាស់ច្រាកជមកតីដើម ឯបូជ្ឈនេះជាមនុស្សបង់ជាតិបង់ត្រកូលមិនបាន
ប្រព្រឹត្តតាមប្រវេណីមែនជួនតា ធ្វើឲ្យខុងតាត្រកូលមេបារបស់ខ្លួន
ដែលនឹងពាក់អានថាល្អសមសួនោះ ក៏តែមនុស្សអន្ធតាលប្រហែលអ្នកឯង
ឯឡៅតីចៅហ្វាយយើងនោះ ច្រាកដជាពូជអម្ប៉ូរបស់ព្រះចៅហៀនតេ ។
ក៏ខំខ្ចីកបំរុងប្រាប់ថាណាស៊ីក្តី អ្នកឯណា ។ ក៏ដឹងយល់ស្តាល់តាំងអស់

ហេតុម្តេចអ្នកឯងមកដៀលថាជាមនុស្សអនាថា ... ទោះបីជាអ្នកគ្មានសំពត់លាក់ក្តីណា បើរាងជាធម្មតាប្រក្រតីតែងធ្វើមក ជាផ្លូវកេចិញ្ចឹមជីវិតមិនជាអ្វីណាស់ ឯព្រះចៅហាន់តោទោះសោត ក៏មិនសុទ្ធជាពូជព្រះកជវង្សមកពីដើម គ្រាន់តែជានាយបន្ទុកយុំប្រកបទៅដោយសេចក្តីឥស្សាយមកំបានជាក្សត្រិយ៍ដ៏ធំប្រសើរ ទើបមានដំណព្រះកជវង្ស ចាន់សោយរាជសម្បត្តិតរៗមក ដរាបដល់សព្វថ្ងៃនេះ អ្នកឯងមកមើលងាយប្រមាថឲ្យតិចៗហ្នឹងយើងនោះមិនគួរសោះ ព្រោះខ្លួនអ្នកឯងជាក្មេងនៅមិនទាន់អស់កូនទឹកដោះនៅក្នុងមាត់សោះ ទឹងមកអួតបេះដឹងជាងមនុស្សចាស់នោះកុំនិយាយតទៅទៀត ។ ឱ្យកបកភ្ញុងឆ្លើយថាជូនព្នោះហើយ ក៏ចាស់ប្រាជ្ញាឈប់ទៅស្ងៀម ។

លុះមជ្ឈន្ហបានឮភ្ញុងឆ្លើយថាជូនព្នោះ ក៏ធ្វើយឡើងថា ភ្ញុងបេងនិយាយនេះជារ៉ៅហារ៉ៃ យើងនឹងចាចតបផងមិនបាន ត្រូវតែយកភាក្យដែលមានខ្មុកក្នុងប្លាប់មកចាចផងទើបបាន ។ ភ្ញុងបេងថា ដែលអ្នកឯងនឹងឲ្យស្រាវជ្រាវយកភាក្យបុរាណតាក់តែងខ្មុកនោះពិរោះមែនហើយ តែបើយកមកចាចក្នុងសម័យនេះ ក៏គ្មាននរណាទទឹងបាន គេថាអ្នកនោះលួចយកភាកដម្រាចាស់មកសំដែង ឯអ្នកមានដម្រេះប្រាជ្ញា តែរមែងវិនិតនដោយតំនិតរបស់ខ្លួន ទោះបីនឹងធ្វើការណាស្ត្រាមយ៉ាងណាក៏ដោយ ក៏ត្រូវតែអាស្រ័យបញ្ញាជាបច្ចុប្បន្ន ទើបនឹងកៀរយកជ័យជំនះ

ចាន ដែលលោកអ្នកមានសតិបញ្ញាពីដើម ចានដួយខ្ទុះខ្ទុកចំរុងចែនដ៏នោះ
មិនមែនឥន្ទ្រិយកដម្រាមកត្រជាន់មើលទេ ឯខ្លួនអ្នកឯងនេះ ក៏ល្អតែមាន
ក្រជាសន្ទឹងពិធទំកភ្លៅ មកសរសេរតាក់តែងជាពាក្យនិយាយលេងតាម
សប្បាយនោះមែន ។

ឯតុក កំស្រែកឡើងថា ខុនបេន់នេះនិយាយខ្ជាំងពេកណាស់
យើងក្រែងតែមិនមែនដូចពាក្យថា យូរៗទាន់មុខ ឥឡូវប៉ុន្មែយើង
ដែលថាមិនកើតជាអ្វីនោះ ឥឡូវនាំគ្នាសើចចំអកលេងទៀតទេដឹង ។ ខុនបេន
ថា ឯលក្ខណៈមនុស្សដែលមិនកើតជាការមាន ២ ប្រការគឺ: មនុស្សមិន
កើតជាការតែល្អរមែនប្រកបដោយសេចក្តីពិត្យាយាម ធ្វើការតបស្នង
សងគុណគេហ្មាយនាយដោយសុចរិតយុត្តិធម៌តាមដម្រះច្បាប់ ហើយ
ក៏មិនត្រូតដៀមខ្លួនមិនចានំលុបគុណអ្នកដទៃ ដែលយកជាការមិនចាន
មិនកើតជាអ្វីសោះនោះ គឺមនុស្សជាអ្នកចរចាក្រមាច់តុកកំផ្លែងឲ្យគេសើច
លេង ការអ៊ូទម្លុយក៏ធ្វើមិនកើត មនុស្សចំពួកនេះចានឈ្មោះថា អាក្រក់
ជួជាតិ ដែលអ្នកឯណាៈថា ត្រូវយកពាក្យបុកណាមកចរចាជាមួយនឹង
យើងនោះនឹងប្រយោជន៍អ្វីយើងមិនត្រូវការទេ ។ ខ្ញុំប្រកាន់ចាំងពួងឃើញ
ខុនបេន់ធ្វើយតតបភាក្យសំដីមិនចានភ្ញាំងភ្លាត់ នឹងអ្នកឯណាចាំងអស់គ្នា
ក៏សំខ្លឹងមើលមុខគ្នាហើយនៅស្ងៀម ។

ឯអ៊ីឡាយស្រែកនិយាយតមកទៀតថា អ្នកចាំងអស់គ្នានេះគ្មាន

អញ្ជាស្រ័យសោះ ខ្ញុំនឹងមតេជញ្ញដោលថ្កូរតែនឹងខុនបេន ដែលមានជម្រះ
ច្រើជ្ញាខោះនឹងច្រើជ្ញាប្រយោជន៍អ្វី ឬឆ្នូលកកនឹងតមកនឹងធ្វើអន្តរាយ
ដល់ស្រុកភូមិហើយ ខៅមិនជួយរិះគិតការពារកំយអន្តរាយ តំមកនាំ
ចោមនិយាយតែនឹងខុនបេនជាក្បៀមកពីក្រៅជាគួរហើយឬ ? ហើយកំ
បែរមុខនិយាយខៅនឹងខុនបេនថា ខ្ញុំតំដឹងថាអ្នកមានជម្រះច្រើជ្ញាហើយ
ហេតុម្តេចខ្លើយអ្នកតំមិនយកពាក្យរបស់អ្នកខៅបរាបនឹងខៅហ្នាយខ្ញុំ តំ
មកច្រឡំនិយាយតែនឹងអ្នកចាំងអស់នេះ នឹងជាប្រយោជន៍អ្វី ។ ខុន
បេនធ្វើយថា អ្នកចាំងអស់នេះមិនបានដឹង ស្គាល់យល់លក្ខណៈល្អនឹង
អាក្រក់សោះ បានជាទាំងាមកស្រុះជេញដោលសួរសោក នឹងចង់ឲ្យ
ខ្ញុំគាល់សំដីនឹងដោះសាមិនបាច នឹងស្មៀមមិនធ្វើយតំមិនបាន ។ ជាធ្វើយ
តបខៅវិញខ្លះ ។

ខណៈនោះអ៊ុយតាយនឹងឡាសុក តំងាំខុនបេនដើរចេញពីលែងឹ
ក្រៅចូលខៅតេស៊ុនគនដល់លែងឹជាន់កណ្តាល ខឲ្លួលជួបនឹងដួងតាត់កំន
ជាបង ។ ខុនបេនតំគាំងាប់តាមប្រវែណី ។ ដួងតាត់កំនសួរថា ឬនមក
ដល់ស្រុកតាំងតាំងនេះហើយ ហេតុម្តេចខើមមិនខៅគេបង ។ ខុនបេន
ថា ឥឡូវខ្ញុំបានខៅខៅនឹងខ្លៅតី ដែលមកគ្រានេះជាផ្លូវពេជការ
ត្រូវតាយកតតិមានមកជាដំណឹងនឹ ប៉ើនឹងខៅគេបងតំដូចជារំលងផ្លូវជ្បាប់
ខ្ញាប់ សូមកុំឲ្យប្រកាន់ទោសខ្ញុំបាខខ្លើយ ។

(មានត)

ពត៌មានផ្សេងៗរបស់ក្រសួងជម្នាការ

អំពីការតាំងមន្ត្រីសង្ឃ

-ឋានតាំងលោកចៅអធិការ កាន់-អ៊ុំនោម ជន្មាយុ ៥១ វស្សា ៣០ នៅវត្តអង្គម្រះក្រៅ ជាទីអនុគណស្រុកឈូក. ខែត្រកំពត ។

-ឋានតាំងកិត្តិ សេរ-លឹម ជន្មាយុ ៣២ វស្សា ១២ នៅវត្តឯកវ្រែកតានង់ ជាទីអនុលេខាធិការ អនុគណស្រុកគោះសុទិន (កំពង់ចាម)។

-ឋានតាំងកិត្តិ ហាក់ ស៊ឹម ជន្មាយុ ៣៥ វស្សា ១៤ នៅវត្តឯកវ្រែកតានង់ ជាទីព្រះគ្រូមន្ត្រីលទីបឋាល ជាសហការីអនុគណ ស្រុកគោះសុទិន (កំពង់ចាម) ។

-ឋានតាំងព្រះគ្រូវិមលមុនី សម-ឃើម វត្តសង្កែ ជាទីព្រះគ្រូបញ្ជាវុត្តី អនុគណស្រុកសង្កែ (ចាត់ដំបង) ។

-ឋានតាំងលោកចៅអធិការ ឡាត់-ឃាំង វត្តបវ៉ុល ជាទីព្រះគ្រូសំវរសេត្ថា អនុគណដំបន់ល្អា ស្រុកមង្គលបុរី (ចាត់ដំបង) ។

-ឋានតាំងព្រះរាជាគណៈ ថង-ឃើម វត្តរោងធំក្នុង ជាទីព្រះគ្រូសទ្ធម្មប្បជ្ជោត ជាសហការីគណៈខែត្រចាត់ដំបង ។

-ចាន់តាំងព្រះសមុហ៍គណ សូវ-ជិត វត្តគរ ជាចៅព្រះចាងវ្អាត់ រមលមុនី ចាងវ្អាត់គណ ខែត្រចាត់ដំបង ។

-ចាន់តាំងព្រះវិន័យធរអនុគណ តិន-លឹម វត្តពោធិ៍កង ជាចៅព្រះវិន័យធរគណ ខែត្រចាត់ដំបង ។

-ចាន់តាំងព្រះសមុហ៍ រ៉ែ-ឆាំ វត្តគ្នំសំពៅ ជាចៅព្រះវិន័យធរអនុគណ ស្រុកសង្កែ (ចាត់ដំបង) ។

-ចាន់តាំងលោកចៅអធិការ ចាប-ឌី វត្តកែវ ជាចៅព្រះសមុហ៍គណ ខែត្រចាត់ដំបង ។

-ចាន់តាំងលោកចៅអធិការ គាត-ហុក វត្តតាកិត្តារាម ជាចៅព្រះសមុហ៍អនុគណ ស្រុកសង្កែ (ចាត់ដំបង) ។

(តមក)

ព្រះមហាប៉ាំង-ខាត់ រៀបរៀង

អត្តន្ត្រី គុ. (តិណ) ដែលឥតខ្សែ ។

អត្តន្ត្រីត គុ. ដែលអស់កម្លាំងមិនមាន, រុឹងប៉ុង ។ *អតន្ត្រីន* គុ. ដែលអស់កម្លាំងមិនមាន, រុឹងប៉ុង ។

អត្តបស្ស គុ. ដែលមានតបៈមិនមាន។

អត្តប្ផតបស្ស គុ. ដែលមានតបៈភ្លើមិនមាន, ដែលមានតបៈតឹងរុឹងមិនមាន។

អត្តមិស្រ គុ. ដែលមិនងងឹត, ភ្ញឺ ។

អត្តវ្រត គុ. ដែលមានបង្គាប់មិនមាន ។

អត្តវ្ឈាយ គុ. ដែលមានឆ្អុបនៃដើមឈើមិនមាន ។

អត្តកិ គុ. ដែលមានត្រិះរិះមិនមាន, ដែលឥតត្រិះរិះ ។ *អតកិត* គុ. ដែលមានត្រិះរិះមិនមាន ។

អត្តក្យ គុ. ដែលមិនគួរត្រិះរិះ, ដែលយល់មិនបាន ។

អត្តល នបុ. ឈ្មោះហានភេក ។

អត្តសិ អវ្យ. ពីខាងនោះ ។ ចាប់តាំងពី, ក្រោយពីនោះ, ព្រោះហេតុដូច្នោះ ។ *អតោ ន័មិត្តម៍* ព្រោះហេតុនោះបានដូច, *អតស្សាម៍* លំដាប់តទៅ, អតោ, ឥ, ឯទៃពីនេះ, *អតោ ចំម*, ព្រោះហេតុនោះ ។

ពុទ្ធសាសនបណ្ឌិត្យ


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣១ លេខ ១១ ខែវិច្ឆិកា

ព. ស. ២៥០២ គ. ស. ១៩៥៩

ភ្នំពេញ



អង្គុលិសន្ទេយ្យ

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
– ពុទ្ធនិយមនិងជាតិនិយម	លោកវរសេនីយ៍ទោ ស៊ូ- ណែម	រៀបរៀង . ១២០៥
– ភាសិតថ្នាក់ក្រោយថា	របស់ព្រះវិន័យធម្ម	ជោង-យុ . . . ១២១១
– សុរពេជ្ឈគត (តជប់)	លោក ចិង-រិង	បម្លែងពីសាស្ត្រាស្លឹករឹត . . ១២២៥
ផ្នែកអក្សរសាស្ត្រ		
– រឿងហង្សយន្ត (តមក)	លោក អឹម-ភន	បម្លែងពីសាស្ត្រាស្លឹករឹត . . ១២៣៩
– គតិបណ្ឌិតរបស់ព្រះជាទ	ម៉ាក់-អូរែល	ព្រះអធិភជ្ជឹមុំង
	លោក ភ័យ-ប៊ុក	ជិកស្រែងរៀបរៀង ១២៥៧
– រឿងត្រៃងនឹងរឿងបុកណប្រទេសដប៉ុន (តមក)		លោក ភ័យ - ប៊ុក រៀបរៀង . ១២៦០
– រឿងស្រីត្រចៀកវ៉ែន (តមក)	យុក - វដ៏រ	រៀបរៀង លោក ផេង-ជ្រឹវ តិនិត្យ . ១២៧៦
– រឿងមរណមាគ (តមក)	លោក ប៊ី-សុវណ្ណ	បម្លែងពីសាស្ត្រាស្លឹករឹត . . ១២៨៤
– ប៊ិសាចនិងខ្មោច	លោក ផេង-ជ្រឹវ	រៀបរៀង ១៣០១
– រឿងសាមកុក (តមក)	ឧកញ៉ា ស៊ូ - ភន	ប្រែ ១៣០៨
ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍		
– ពត៌មានផ្សេងៗ	របស់ក្រសួងធម្មការ	. . . . . ១៣១៨
– វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក)	ព្រះមហា	ជាំង-ខាត់ រៀបរៀង . . ១៣២០

ឆ្នាំ ១ ភាគ ១២ សៀវភៅ ជំរៀងថ្ងៃ ៤៣០១០០

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

sommaire

Partie religieuse :

— Le Bouddhisme et le Nationalisme par M. SO-NÈM . . . 1205
— Kayasantibhàvakathà par PREAH VINAYADHAMMA THONG-YOU 1211
— Surabajataka (suite et fin) relevé du manuscrit sur feuilles de latanier par M. THANG-VONG 1225

Partie littéraire :

— Histoire de Hang-Yon (suite) relevée du manuscrit sur feuilles de latanier par M. IM-PHON 1239
— Les Pensées de Marc Aurèle Empereur Romain, traduites par M. RAY-BUC 1257
— Contes et Légendes du Japon (suite) traduits par M. RAY-BUC. 1260
— La femme vertueuse par Yok Vochir revue et corrigée par M. PHENG-CHRIV 1276
— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN 1294
— Le démon et le loup par M. PHENG-CHRIV 1301
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1308

Notes et Chroniques :

— Nouvelles diverses du Ministère des Cultes 1318
— Dictionnaire Sanskrit-khmer (suite) par Preah Maha PANG-KHAT 1320

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

ពុទ្ធនិយមនឹងជាតិនិយម

លោក សូ-ណែម រដ្ឋលេខាធិការក្រសួងធម្មការ រៀបរៀង

ការធ្វើអត្ថាធិប្បាយពីព្រះពុទ្ធសាសនា ឬ ហៅម្យ៉ាងទៀតថា ព្រះពុទ្ធនិយម ជាការខ្វល់ខ្វាយខ្លាំងពន់ពេក ទើរកប្រៀបធៀបពុំបាន ។ ព្រោះពុទ្ធនិយមនេះ បានជ្រួតជ្រាប បែកសាខា បែកផ្សាយគ្រប់ទិសានុទិស ចេញជាគំនិត ដែលបានចងក្រងជាសាស្ត្រា ជាសៀវភៅ ជាអត្ថបទច្រើនទីដ៏ឥតគណនាបាន ទៅតាមសញ្ជាតិនីនីតាមភាសាទីនីនី ។

ក្នុងចំណោមអាទិនី "ទស្សនាវដ្តី" នេះ បំណងធំបំផុត គឺច្បាស់ត្រឹមតែវែកញែកជូនអ្នកអានតាំងឡាយជ្រាបថា តើលក្ខណៈពុទ្ធនិយមនីនីនេះលក្ខណៈជាតិនិយមមានលំនាំស្របគ្នា ឬ ក៏ផ្ទុយគ្នាយ៉ាងណា ? ។

ពុទ្ធនិយម ជាទស្សនវិជ្ជាមួយ ក្នុងចំណោមទស្សនវិជ្ជាច្រើន ដែលបានចាប់ផដិសន្ធិក្នុងលោក ។ ទស្សនវិជ្ជានេះ ជួយអស់លោក-អ្នកជ្រាបស្រាប់ ជាលទ្ធផលនៃការរៀន ការស្រាវជ្រាវ ការរិះគិត ការពិចារណា ចំពោះការរិះរកដោះស្រាយនូវបញ្ហាខ្លួនឯងនៃពិភពលោក ជាពិសេសចំពោះបញ្ហាសង្គម របស់អ្នកប្រាជ្ញម្នាក់ ព្រះទស្សនៃខ្លួនមួយ

ព្រះអង្គ ដែលតុំមែនអ្នកណាក្រៅពីព្រះសម្មាសម្ពុទ្ធនេះឯង ។ ដូច្នេះព្រះពុទ្ធនិយម មិនមែនជាអ្វីក្រៅពីមនុស្សនិយម ពោលគឺការដោះស្រាយបញ្ហាមនុស្ស មិនមែនដូចសាសនានានាជាដែរទៀត ដែលប្លាក់ទៅក្នុងសភាពនៃសាសនាពិត ។ ដោយស្ថិតនៅលើដំនឿតែមួយមុខ គ្មានការពិចារណា ដំនឿទៅលើវត្ថុលើកម្ងាំងវិសាមញ្ញផ្សេង ។ មានតាំពេលជាដើម ។

ឯមូលដ្ឋានដ៏មុតមាំនៃពុទ្ធនិយមនេះ ស្ថិតនៅលើព្រះធម៌ ទើលើអស់ជនានុជន ដែលគោរពទីឯប្រតិបត្តិតាមព្រះធម៌នេះ ។ ការគោរពតាមព្រះធម៌ព្រះពុទ្ធ បើពោលម្យ៉ាងទៀតថា ការសិក្សារកព្រះធម៌ គឺមិនសំដៅយកវត្ថុអ្វី ក្រៅពីការគោរពប្រតិបត្តិតាមមាគ៌ា ដែលព្រះសម្មាសម្ពុទ្ធបានទ្រង់ត្រាស់ទុកមក ក្រៅពីការសិក្សារកផ្លូវ ដើម្បីឲ្យទៅដល់ទីសុភមង្គលគឺព្រះនិព្វាន ។

ចុះគោលការណ៍នៃជាតិនិយម មានសំខាន់យ៉ាងណាទៅ?

បើប្រៀបធៀបទៅនឹងពុទ្ធនិយម យើងអាចទុកជាតិនិយមជាលក្ខណៈមួយ ជាទស្សនវិជ្ជាមួយបាន ដូចទស្សនវិជ្ជានានាដែរ ។ ព្រោះជាតិនិយមក៏ស្ថិតនៅលើគំនិត ដែលមានន័យវែងឆ្ងាយ មានការមិនឆ្គួតអ្វីដែលអាចនាំមកនូវសេចក្តីសៅហ្មង - សេចក្តីវិនាសដល់ជាតិ - ការមិន

ចំពោះប្រយោជន៍ជាតិដទៃ ហើយប្រតិបត្តិតែសកម្មភាពណាដែលហុចខ្លួន
សេចក្តីសុខ-សេចក្តីចំរើនដល់ជាតិ ។ មើនិយាយយ៉ាងខ្លី ជាតិនិយម
ជាគ្រឿងដើម្បីឈោងយកខ្លួនសុគមន្តិបជូនជាតិ ក្រោមការដឹកនាំដ៏មុះមុត
នៃដ្ឋប្បុរស ប្តីរបុរសណាម្នាក់ ។

ចំពោះខ្មែរយើង ជាតិនិយមបានកាន់យកជាស្រេចខ្លួនមានតាំងជីវិតមួយ
មានតាដែលសម្តែងព្រះទុបយុវាកដ្រង់ថានែកនៅភ្នាក់ជូនដំនូវមេជាតិ
ក្នុងព្រះសុត្តរកថា ព្រះសង្គីថា ទីឆ្ងាយសត្វព្រៃកដហ្មឹងយ ចង្រ្កាល
ដំបូលសំលៀងថ្មីទៀត ក្នុងអត្ថបទនានាបស់ព្រះអង្គ ក្នុងចំណោមពាក្យ
"អ្នកជាតិនិយម" ដែលបងប្អូនបានអានរួចខ្លះហើយក្តី ហើយដែលបងប្អូនមិនទាន់បានក្រែបនុជាសេត ។ ល ក្តី ។

សេចក្តីដែលបានតណិនាមកដោយត្រួស ។ នេះ គំសឹងបង្ហាញជូនអស់លោក-អ្នកជ្រាបខ្លះហើយថា ពុទ្ធនិយមនឹងជាតិនិយមមិនមែនជាលទ្ធិជាខ្សែរដៃជាមួយគ្នាទេ ។

នៅកម្ពុជាយើង ប្រវត្តិសាស្ត្របានខ្ពុកក្តីស្តាប់ដ៏ជាក់លាក់ ចំពោះដំណើរស្រេបគ្នានេះ ចំពោះការគោរពនិងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងដំណើរតាំងពីរ ។ ជាពិសេសយើងបានដឹងច្បាស់ថា ព្រះពុទ្ធសាសនា ជាអង្គការទ្រទ្រង់ជាតិនិយមខ្មែរជាយូរអង្វែងរហូតមកដល់សព្វ

ថ្ងៃ ។ ការប្រដាប់ខ្មែរយើងមានវប្បធម៌ជាដើម ដែលមានតិត្តិសព្ទល្បីល្បាញ តែងបានទទួលទុកត្តម្ភពីព្រះពុទ្ធសាសនាជាច្រើនមក ។ ជាទំនៀមរាល់ឆ្នាំជនជាតិយើងជាន់ដើម តែងចូលទៅស្រង់ឆ្នាំយកចំណេះវិជ្ជា ទៅទទួលសេចក្តីអប់រំពីវត្តអារាម ពីព្រះសង្ឃាចារ្យ ។ កាលបើបានបួសរៀនអប់រំគ្រាន់បើយោងការយោងត្រង់គ្រាន់ហើយ។ បើបានលាសិក្ខាបទមកគាន់ភាពជាគ្រហស្ថវិញ (ចណ្តិត) ទើបជនរួមជាតិទទួលកាន់ថាជាជនត្រឹមត្រូវជាជនល្អរដ្ឋាយតន្ត្រីធម៌ ទើបអាចរកគូការយោធបានសមរម្យ ហើយប្រកបរបរកទទួលបានត្រឹមត្រូវតាមសម្ភារដែរ ។

អ្នកខ្លះពោលថា កម្ពុជរដ្ឋយើង កាលដើម គេបានស្គាល់ខ្លឹមសេចក្តីរឿងរឿនខ្លាំងណាស់ ជនជាតិខ្មែរដែលមានព្រះមហាក្សត្រជាប្រមុខសុទ្ធសឹងជាអ្នកអង់អាចក្លាហាន មានសកម្មប្រយុទ្ធដ៏មុតមាំ ដើម្បីពុះពារកេរប្រយោជន៍ កិត្តិសព្ទកិត្តិនាមជូនជាតិមាតុប្រទេស ។

ហើយថា ក្រោយដែលបច្ចាមិត្តបានទាំព្រះពុទ្ធសាសនានេះ មកទុកជាកេរ្តិ៍មត៌ក លក្ខណៈដ៏វិសេសនេះ កំអះឥឡូវសាបសូន្យទៅ នាំប្រទេសចូលទៅក្នុងភាពជាយូរឆ្នាំរៀងដរាបមក ទល់នឹងរដ្ឋការព្រះនរោត្តម-សីហនុវរ្ម័នេះ ។ ព្រោះព្រះពុទ្ធសាសនាប្រដៅខ្លួនវិការណាចាក សម្បត្តិលោក ខ្លួនវិការលះបង់កិលេសតណ្ហា លោភៈ ដើម្បីយក

បរទេសដ៏ក្លៀវក្លា ។

កាលបើបានពិនិត្យដោយម៉ត់ចត់ទៅ អ្នកនឹងយល់ឃើញថា ការតវ៉ាលេងនេះ មិនប្រកបដោយភាពសុក្រឹតឡើយ ។ ព្រោះសារតែបានបង្ខិលបង្ខាស់អំពីបុព្វហេតុដែលនាំឲ្យកម្ពុជរង្គើយ៉ាងខ្លួលខ្វល់សេចក្តីអប្បត្ថនាមុននេះ ។ ការបែកបាក់សាមគ្គីរវាងខ្មែរនឹងខ្មែរមកពីលោភៈ មកពីការយល់ប្រយោជន៍ផ្ទាល់ខ្លួន មកពីខ្មែរយើងបានលះបង់ខ្លួនជាតិនិយមទៅបំរើប្រយោជន៍នៃបរទេស ។ គឺហេតុទាំងអស់នេះហើយ ដែលនាំឲ្យដែនដីខ្មែរយើងតែរួមមកនៅតួចត្រឹមទំហំសព្វថ្ងៃ ។

រីឯព្រះពុទ្ធាគមវិញ ក៏មិនជួយធនឹងប្រយោជន៍ប្រទេសឡើយ ព្រោះល្អីកណា មិនចាន់រកឃើញខ្លួវលោកុត្តរធម៌ មិនចាន់ចាន់ជួបប្រទះនូវព្រះនិព្វានទៅឡើយទេ ស្អីកនេះ លោកគិតនឹងធម្មតិកំរៃងអន្ទាលចូលគ្នាទៅវិញទៅមកជាដកបៈ ។

ក្នុងបច្ចុប្បន្នកាលនេះ លើកលែងតែជនខ្លះ ទេមរជនខ្លួទៅសឹងចាន់យកនូវទិដ្ឋិ ៤ ប្រការ ស្របពាំងគតិលោក ពាំងគតិធម៌ ដើម្បីស្វែងរកសេចក្តីសុខ សេចក្តីចំរើនដូនជាតិមាតុប្រទេស ។ ទិដ្ឋិពាំង ៤ ប្រការនេះមាន :

១- ឧដ្ឋាន: ការម្ចាស់ប្រកបការងារដែលត្រូវប្រកប;

២- អប្បមាទ: ការមិនធ្វេសស្មារតី;

៣- សញ្ញមៈ ការប្រយ័ត្នឥន្ទ្រីយ៍ទាំង ៦;

៤- ទមៈ ការទូន្មានចិត្តឲ្យមានវិបុលបញ្ញា ។

ការប្រកបការងារ ដែលត្រូវប្រកបនេះហើយ ដែលជាបញ្ហាធំ សព្វថ្ងៃនៅប្រទេសយើង ។ កាលបើទង្វាន់នេះ មានដំណើរស្រួលបួល បញ្ហាធំគឺ ឯកភាពរវាងសង្គកិច្ច ធំដូចព្រះភក្ត្រ ចំណាន នៃសម្តេចព្រះទេពឃុំវាដជាមិនខាន ។ ការចរិបូណិនូវផលិតផល ដែលប្រជាពលរដ្ឋយើងទំប្រឹងប្រែងធ្វើ នឹងនាំមកនូវសេចក្តីសប្បាយរីករាយក្នុងសង្គមជាតិ ។ ឯកភាព នឹងសម្បូរណាភាព នឹងរីកចំរើន ប៉ុន្តែតើញសើញរឿងភបជភបៅ ។

កាយសង្ខិភាវិកថា

របស់ព្រះវិន័យធម្ម ថោង-ឃុ វត្តសាលាវ័ន្តពេជ្ជោ

ឯមោ ៣ ជំពូ

សូមនមស្ការ ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធ ព្រមទាំងព្រះធម៌ មួយអន្ទឹងដោយពពួកនៃព្រះអរិយសង្ឃសាវ័ក (ដោយសេចក្តីគោរព) ។

សូមពណ៌នាភាសាថា កាយសង្ខិការ ដែលមានក្នុងអដ្ឋកថា ធម្មបទដូចតទៅ ៖

ភាសាថា កាយសង្ខិការ នេះ មកអំពី កាយ ប្រែថា " រូបដែលជាទីប្រជុំនៃការៈ៣ មានសក់, រោម, ក្រចកជាដើម រួមទាំងអស់ហៅថា កាយ " ឧធ សង្ខិ ប្រែថា " ស្ងប់, សាន្តត្រាណ, ពបពប, សះជាឧធ៍គ្នា " ឧធ ការ ប្រែថា " ការ ឬដំណើរ " រួមភាសានេះបូលគ្នាជា កាយសង្ខិការ ប្រែថា " ការ ឬដំណើរ ស្ងប់, សាន្តត្រាណ, ពបពប, សះជាឧធ៍គ្នាខាងផ្លូវកាយ " ។

សូមលើកយកអត្ថបទនេះ មកពណ៌នាបំភ្លឺដើម្បីបញ្ជាក់ត្រង់ភាសាថា " ស្ងប់កាយ " នោះ ដូចតទៅ ៖

កាយសង្ខិការ ការ ឬដំណើរស្ងប់ខាងផ្លូវកាយ ។

អធិប្បាយ ហេតុ ឬទុក្ខដែលនាំឲ្យស្ងប់ខាងផ្លូវកាយ ជាន ខាងការប្រព្រឹត្តិរៀបចាកមិច្ឆាជីវៈ " ការចិញ្ចឹមជីវិតខុស " របស់ត្រហស

គឺវៀរចាកដំនួញដែលមិនគួរជួញ ដូចជាជួញគ្រឿងសស្ត្រាវុធ (ចាន់ដល់គ្រឿងសស្ត្រាផ្សាល់ដៃមានជាវជាដើម; អាវុធគ្រឿងប្រយោលមានកាំភ្លើងជាដើម) ជួញសត្វគឺជួញដូរមនុស្ស, ជួញសត្វ; ជួញទឹកស្រវឹងគឺសុរាទេនីរមេរ័យ, ជួញថ្នាំពិសគឺថ្នាំសម្រាប់ពុល ។

ចំណែកខាងក្នុង បត្តជិតពុទ្ធសាសនិកវិញ ចាន់ខាងការវៀរចាកអនេសនកម្ម គឺគំរាពីស្វែរកមិនគួរ ២១ មានវេជ្ជកម្ម « ធ្វើពេទ្យហ្មេ » ទូតកម្ម « ធ្វើទូត នាំសាសន៍ឲ្យគ្រហស្ថទុសចាកធម្មវិន័យ » ជាដើម ហើយនឹងជាបច្ចេមិ គឺធម៌ដ៏លាមក ៥ មានភ្នួហ្មា « ការកុហក » ជាដើម ហៅថា មិច្ឆាជីវៈ « ការចិញ្ចឹមជីវិតខុស » ។

ការវៀរចាក ការចិញ្ចឹមជីវិតខុសនេះឯង ជាហេតុនាំឲ្យកើតសេចក្តីសុចរិតកាយ ហៅថា កាយសុចរិតភាព « ដំណើរសុចរិតខាងផ្លូវកាយ » ជាហេតុឲ្យចាន់សេចក្តីសុខជាផល ហៅថា សុខកាយ ព្រោះកាយសុចរិតលះបង់ប្រព្រឹត្តបៀតបៀនរំលោភជិះជាន់ កាប់សម្លាប់ចំពោះមនុស្សសត្វសង្ឃរជាដើរស្រួលញ៉ាញ ។ កាយសុចរិតភាព « ដំណើរសុចរិតខាងផ្លូវកាយ » នេះ សម្តែងពុទ្ធភាសិតថា អត្តាបជ្ឈំ សុខំ លោកេ « ការមិនបៀតបៀនគ (គឺមនុស្សជាតិជួញគ្នា ឬ សត្វដែលមានសរីរៈរាងកាយ ពាំនាំ-តួចជាដើម) ទើបជាសុខក្នុងលោក ត្រង់កាយមិនប្រព្រឹត្តខុសច្បាប់ ដោយកាយទ្វារ គឺវៀរចាកការសម្លាប់សត្វ, ការលួចបន្លំទ្រព្យ

សម្បត្តិរបស់អ្នកដទៃ, ការប្រព្រឹត្តិក្បត់ចិត្តនឹងប្រពន្ធកូនគេ, ការប្រព្រឹត្តិ
កន្លងអបាយមុខ "ប្រធានៃសេចក្តីវិនាស" ៦ យ៉ាងគឺ ក្រេបផឹកទឹក
ស្រវឹង គឺសុកនឹងមេរ័យ ដែលជាហេតុនាំឲ្យវិនាសហិនហោចខាតទ្រព្យ
សម្បត្តិឃើញតាមតែក្តីផង, នាំឲ្យចំរើនទាស់ការឈ្លោះប្រកែកគ្នាផង, ជា
ហេតុនាំឲ្យកើតពេគច្រើនយ៉ាងផង ជាហេតុនាំបណ្តាលឲ្យខូចកេរ្តិ៍ឈ្មោះឬ
ឲ្យកើតក្តីតហោនិទ្ទាផង នាំឲ្យលេចចេញកេរ្តិ៍ខ្មាសផង. ជាហេតុធ្វើឲ្យថ្លាជា
ឲ្យមានកំឡាំងថយ ឬនាំឲ្យខ្សោយសតិប្រាជ្ញាផង ។ ប្រព្រឹត្តដើរលេង
តាមប្រកល្លកកន្លងវេលាយប់ ដែលជាហេតុនាំឲ្យគេមនុស្សសង្ស័យចោទ
ប្រកាន់ថាជាចោរ ។ ប្រព្រឹត្តដើរមើលល្បែងមហោស្រព ដែលជាហេតុនាំ
ឲ្យខូចចិត្តនឹងបង់ភាគប្រាក់កាសទ្រព្យធនដែលបានមក ។ ប្រព្រឹត្តលេង
ល្បែងស្លាល់ ដែលជាហេតុនាំឲ្យលោភទ្រព្យសម្បត្តិ ទឹងស្តៅក្រហាយ
អន្ទះអន្ទែងក្នុងចិត្ត ។ ប្រព្រឹត្តសេពគប់នឹងជាបមិត្រ ដែលជាហេតុនាំឲ្យ
ប្រព្រឹត្តកាប់សម្លាប់លួចប្លន់ដល់ដំរិតៈគនឹងទ្រព្យសម្បត្តិរបស់គេ ឬជាហេតុ
នាំឲ្យជាប់គុកច្រវាក់ខ្នោះឃ្នាង ខ្ជិលច្រអូសនឹងកិច្ចការទាំងពួង ដែលជា
ហេតុនាំឲ្យខ្សត់ខ្សោយ ក្រទ្រព្យសម្បត្តិ នឹងខាតខូចប្រយោជន៍តម្រិះវិជ្ជា
ប្រាជ្ញា ។ មួយទៀតការប្រព្រឹត្តិផឹកសុក ជក់កញ្ឆា អាកៀន ដែលជា
ហេតុនាំឲ្យញៀនស្គាំងស្គមខ្ជូខ្ជួន ឃ្លង់ខ្ចៅ បង្កើតរោគជាពេគរបេងរឹងរៃ ។ ការវៀរចាកអបាយមុខនេះ ឈ្មោះថា ជំណើរនាំឲ្យសុខទាំងផ្លូវ

កាយ ។ អ្នកដែលមិនចង់នៅរៀបចាកវិញនោះ ឧដ្ឋសមដូចជាសុភាសិតមួយថា ឆ្លងស្រីឆ្លងស្រា ឆ្លងល្បែងពាលា អាត្មើសឹងឆ្លង, ពុទ្ធភាសិតក្នុងបាកវិសូត្រថា: ឥត្ថីឆុត្ត អ្នកលេងស្រី (មានពួកស្រីផ្កាមាសជាដើម នេះសុទ្ធតែនាំឲ្យកើតពេតក្នុងកាយ), សុរាឆុត្ត អ្នកលេងផឹកសុរា សូម្បីសុរាទេឭយគឺ ប៉ុន្តែ កំពប់បញ្ចូលក្នុងពួកសុរាទំនើមេរ៉ៃយ៉ាងអស់ សុទ្ធតែគ្រឿងស្រវឹង ធ្វើមនុស្សឲ្យវង្វេងវង្វាន់ មានតែនាំឲ្យវិនិវឹតតែកើតបមាទធម៌ពេញខ្នើរក្នុងពេលនោះ អក្ខឆុត្ត អ្នកលេងវ៉ៃល្បែងភ្នាល់ (គឺចាប់តាំងពីចៀរឡោះជាដើមឡើងទៅហៅថា ល្បែងភ្នាល់) ល្បែងភ្នាល់នេះ ចេះយើងឈ្នះគេថ្ងៃនេះប្តូរថ្ងៃស្អែកកាយនឹងចិត្តក៏នៅតែមិនស្ងប់ មិនស្កប់ស្កល់ដែរ តែម៉ើសនឹងជាលោភាញ់គេវិញ ដើរ ឈរ អង្គុយ ដេកមិនស្រណុក បាត់មិនល្ហើយឡើយ ចេះតែមានកិលេស សេចក្តីសៅហ្មងកកស្អុក ឧដ្ឋតណ្ហា សេចក្តីប្រាថ្នាឋចំណង់មិនចេះអស់.ហើយក្នុងចិត្ត នេះពាលជាលដោយក្តីងឿងឆ្ងល់ លោក: "សេចក្តីចង់ចាន់ពេក" ទោស: សេចក្តីប្រទូស្តប្តូនឹងស្អប់, មោហ: "សេចក្តីវង្វេងមិនដឹងសេចក្តីពិត" ជុតកំដៅឡើង ។ឥតស្រាកស្រាន្ត ។ អ្នកលេងល្បែងភ្នាល់ស៊ីសងនេះ មិនដែលឃើញអ្នកណាមួយមានកំណើតទេ, មានតែលង់លិចខ្ទេចខ្ទីជាដរាប ។

ឧទេស្សន៍ក្នុងពាក្យថា: កាយសង្ខ្លិភាគ ដំណើរស្ងប់នៃផ្លូវ

កាយ ផ្នែកខាងកាយកម្ម តែម្យ៉ាងទេ, តែគង់មានចូលជាប់ជាក់ខាង
ខាងវចីកម្មទីមនោកម្មដែរ ។

ដូច្នេះសប្បុរសចាំងឡាយ គប្បីជ្រាបថា: កម្មចាំងបីនេះ សុទ្ធ
តែចាត់ថាជាតួបុបចាំងអស់ ។ ក្នុងបុលីមានសំដែងអំពីបុប ៣ ពួកនេះ
ច្រើនជាងចំណែកដទៃ ព្រោះបុបអម្បាលនេះ ជាប្រធានៃបុប
ចាំងពួង, បុបចាំងនេះ ដូនកាលលោកហៅថា ទាប ដដែល
ប្រែថា: កម្មដ៏លាមក, ហៅថា ទុច្ចរិត ប្រែថា: សេចក្តីប្រព្រឹត្តិ
អាក្រក់, ហៅថា អកុសល ប្រែថា ការមិនល្អ, ហៅថា:
អកតរណីយកិច្ច ប្រែថា កិច្ចមិនគួរធ្វើ, ហៅថា អជ្ឈុចរិយ:
វិសមចរិយ: ប្រែថា សេចក្តីប្រព្រឹត្តិមិនជាធម៌, សេចក្តីប្រព្រឹត្តិ
មិនសម ។

បណ្តាបុបចាំងបុន្មាន ដែលបានពណ៌នាមកនេះ, ឥតមាន
ចំណែកណាមួយដែលជាបេសំគួរធ្វើសោះឡើយ សុទ្ធតែជាកិច្ចមិនគួរធ្វើ
ចាំងអស់ ។

សម្តេចព្រះកតវន្តមុនីបមេគ្រូ ទ្រង់ត្រាស់ទៅនឹងព្រះអានន្ទត្ថេរថា:
ឯតំ សេដ្ឋាវាំ អានន្ទ អកតរណីយំ វេធាមិ ប្រែថា
ម្នាលអានន្ទ! តថាគត ហៅ កាយទុច្ចរិត ជាចំទុច្ចរិត
ទើង មនោទុច្ចរិត ថាជាកិច្ចដែលបុគ្គលមិនគួរធ្វើដោយជាប់ខាត ។

ភាលបើបុគ្គលណាមួយជ្រុលកាយ ភ័ាចិត្ត ធ្វើអកវណ្ណិយកិច្ច ត្រូវដឹង
ខ្លួនចុះថា មុខជាខ្លីមានទោស បើយ៉ាងនិងតែត្រឹម ៥ យ៉ាងនិះ ខ្លួន
ឯងនិងតែដឿលខ្លួនឯងបាន ១, លោកអ្នកច្រៀងជ្រៀចដឹង រមែងនិងតែដឿល
បាន ១, តេក្តីឈ្មោះអាក្រក់ រមែងខ្ចាត់ខ្ចាយទៅនិះ ១, រាងកាយរមែងស្លាប់
ក្នុងវេលាជិតស្លាប់ ១, ខាងមុខអំពីទំលាយខន្ធ៧ រមែងទៅកើតក្នុង
ទុគ្គតិ ១ ។ ភាលបើដូច្នេះ គួរអស់លោកអ្នកតាំងខ្លួន អ្នកមានបញ្ញា
ចក្ខុត្រូវលះបង់អំពើអាក្រក់ដោយកាយឲ្យជ្រះស្រឡះចេញ ទើបហៅថា
"ស្លាប់ផ្លូវកាយ" តើថា មិនមានក្តីស្តៅក្រហល់ក្រហាយអនុះអនែងសោះ
សល់ខ្លួលតុនកាយ ។ សមនឹងព្រះតុទ្ធតម្រាស់ថា: ឧបសន្តោ
សុខំ សេតិ "អ្នកស្លាប់រមែងដេកជាសុខ" តើសុខគ្រប់អំរោចបាំ
តាំង ៤ ។

រួមសេចក្តីឲ្យខ្លីជាយស្តាប់ៗតើថា បើយើងមិនបៀតបៀនគេ, មិន
លួចទ្រព្យសម្បត្តិគេ, មិនប្រព្រឹត្តចំពោះប្រពន្ធកូនស្រីគេខុ, មិនដេរគេ,
គេក៏មិនបៀតបៀន មិនលួចទ្រព្យសម្បត្តិយើង, មិនរំលោភនឹងយើង
មិនដេរយើងវិញដែរ, តាំងនាំឲ្យកើត មេត្តាធម៌, តាំងករុណាធម៌
នឹងសន្តោសៈ សេចក្តីត្រេកអរតាមមានតាមបាន ជាប់យើងឥតឃ្លៀត ។ បើសិនជាយើង បៀតបៀនគេ លួចទ្រព្យរបស់គេ, ប្រព្រឹត្ត
ខុសនឹងប្រពន្ធកូនគេ, ដេរគេ, គេក៏នឹងប្រព្រឹត្តរំលោភតបវិញដែរ

សង្ឃសឹកត្រឡប់មកលើយើងវិញតុំតាន ។ បុពណសុតាសិតថា: យើង
ឲ្យទុក្ខគេ គេឲ្យទុក្ខយើង ។ សាសនធម៌ បញ្ជាក់ទៀតថា:
ការបៀតបៀនចាត់ការបំបាត់សម្លាប់មនុស្សសត្វ លួចប្លន់គេ ប្រព្រឹត្តល្មើស
ខ្ញីឆ្មប្រពន្ធកូនស្រីគេ ដេរប្រពៃបគេ ឈ្មោះថា ឆាំឲ្យបែក
បាក់មិត្តភាពនឹងសាមគ្គីធម៌ ។ ត្រង់នេះហើយដែលហៅថា «ភៀរ"
ប្រទូស្តភៅ ប្រទូស្តមកមិនស្ងប់ ម្ចាំរហើយចេះតែប្រឹងធ្វើបាបគេឲ្យ
ឋុកតាមតែអំពើចិត្ត ។ អ្នកណាស្វែងរកសុខដើម្បីខ្លួន ប៉ុន្តែជា
អ្នកបៀតបៀនមនុស្សសត្វទាំងឡាយ ដោយគាជ្ញា អ្នកនោះ រមែង
មិនបានសេចក្តីសុខទៅមុខទេ ។ អ្នកណាស្វែងរកសុខដើម្បីខ្លួន ដោយ
មិនបៀតបៀនមនុស្សសត្វទាំងឡាយ ដោយគាជ្ញាទេ, អ្នកនោះទើបបាន
សុខទាំងលោកនេះ ទើងលោកខាងមុខ ។

ចាប នេះ រមែងឲ្យទោសក្នុងលោកទាំងពីរ អ្នកធ្វើបាបកំរមែង
ក្តៅក្រហាយក្នុងលោកទាំងពីរតើ:

១- ក្នុងលោកនេះ រមែងក្តៅក្រហាយដោយគិតថា អាត្មាអញ
ប៉ុនធ្វើបាបដូច្នេះ ។ ។

២- លុះប្រែតថាកលោកនេះទៅហើយ ទើងតែតែក្តៅក្រហាយជាង
នេះទៅទៀត ។

សមដូចជាពុទ្ធភាសិតថា ១ ថា: សត្វចាបសូ អកាសំ

ការមិនត្រូវធ្វើអំពើបាបទាំងពួង (ដោយកាយវាចាចិត្តឬមិនប្រព្រឹត្តធ្វើទុស្ស
ឥតឈប់ឆង់ផ្លូវលោកផ្លូវធម៌គ្រប់យ៉ាង) ។ បុរសបុគ្គល ដែលត្រូវការដោយ
សេចក្តីសុខចំរើន មិនគប្បីប្រព្រឹត្តធ្វើបាបឡើយ ! ។ ពាក្យនេះ
បានដល់ព្រះនិព្វានជាដាច់ទាំងស្រុង ។ ព្រោះហេតុនោះ សាធុជនទាំង
ឡាយ អ្នកប្រាថ្នាសេចក្តីសុខចំរើនដល់ខ្លួនឥតឈឺអ្នកដទៃ មិនត្រូវធ្វើបាប
ដែលជាអំពើលាមកគួរខ្ពើមគួរខ្ពាំនោះទេ តែចំណែកជនណាមួយ បានបង
មានៈ នៅតែធ្វើបាបរឿយៗ ជនជនោះឯង នឹងត្រូវបាន
ទទួលនូវសេចក្តីទុក្ខសំបាកយ៉ាងមហន្ត ទាំងក្នុងលោកនេះ ទាំងក្នុង
លោកខាងមុខមិនខាន ឡើយ ។ សមដូចជាព្រះគាថាក្នុងគម្ពីរធម្មបទដូចតទៅ
ត្រង់យមកវគ្គថា៖

ឥធ សោចតិ បេច្ច សោចតិ
បាបការី ឧភយត្ថ សោចតិ
សោ សោចតិ សោ វិហញ្ញតិ
ទិស្វា កម្មកិលិដ្ឋមត្តនោ ។

ប្រែថា: ជនអ្នកធ្វើកម្មអាក្រក់ តែងសោកស្តាយក្នុងលោកទាំងពីរ
គឺក្នុងលោកនេះ ១, ក្នុងលោកខាងមុខ ១; ជនអ្នកធ្វើបាបនោះ តែង
ក្តៅក្រហាយចិត្ត ព្រោះឃើញកម្មដ៏សៅហ្មងរបស់ខ្លួន ។

អធិប្បាយថា: បុគ្គលអ្នកធ្វើបាបកម្ម អំពើអាក្រក់គ្រប់យ៉ាង មាន

ការសម្លាប់មនុស្សសត្វ លួចប្លន់ធ្វើបាបគេ ប្រព្រឹត្តមោះពុំគាប់នឹងបុរស
ស្រីដែលមិនជាស្វាមី· មិនជាតិយោរបស់ខ្លួន ក្នែងកុហកគេក្តី ផឹក
ស្រាំស្រវឹងមានសុភជាដើមក្តី លុះដល់មរណៈសម័យពេលជិតស្លាប់
ទៅក្នុងបច្ចុប្បន្នជាតិនេះ ក៏ខឿនតែឆេងខុក្ខសោកតុំដែលមាន ព្រោះឃើញ
ថាការកុសលអាត្មាអញឥតបានធ្វើសោះ, អំពើដែលអាត្មាអញបានធ្វើបែប
មកហើយនោះ សុទ្ធតែជាបាបកម្មទាំងអស់ ទ្បើរហើយ ក៏កើតសេចក្តី
ក្តៅក្រហាយស្តាយក្រោយ ដោយឆ្លាយតំនិតមិនបានគិតរកសីលធម៌ជា
ទីតឹងធ តែតែមានខុក្ខសោកក្រាកដេកបម្រះនេះខ្លៀលពាល់តែជាប់ដំដែតន្ទ្រើយ
ស្លាប់អស្សាវឥតការ ។ ការសោកស្តាយបែបនេះ ហៅថាវេរសោកព្រោះ
កម្ម ។ លុះដល់ស្លាប់ទៅក៏ទៅវេរផលវិបាក វេរសោកក្នុងបរលោកខ្មៅ
តីទៅនេះទៀតក្នុងក្នែងនរកជាក្រោកដពុំខាន ។ បុគ្គលអ្នកធ្វើបាបនោះតែងតែ
រវើរក់យក្តៅក្រហាយលំបាកក្នុងលោកទាំងពីរ ព្រោះឃើញកម្មដ៏ស្មៅហ្មង
របស់ខ្លួនយ៉ាងនេះឯង ។ ម្យ៉ាងទៀតក្តៅក្រហាយដោយស្តាយក្រោយ
ថា: « អំពើដែលអញធ្វើរួចហើយ សុទ្ធតែជាអំពីបាបអកុសល » ។
លុះទៅកាន់ខុគ្គតិភព ក៏ក្តៅក្រហាយក្រៃលែងជាកំយ៉ាភាពជានេះទៅ
ទៀត តីថាបើទៅកើតក្នុងនរក ខឿនតែត្រូវទាយទិរយបាល·គាបគ្បៀត
ចាក់តាប់ដោតផ្តាំ ចាប់ចោះចុះទៅក្នុងរណ្តៅរងើកភ្លើង បណ្តែញឲ្យ
រត់ឡើងដើមរកាមានបន្ទាស្រួចពីងមុតដូចដែក ឲ្យដេកគ្រាំស្រុះខ្លួនក្នុងខ្នុះ

ទឹកចិត្តដែលកំពុងតែ ឧស្សាហ៍ព្យាយាមរកវិធីណាមួយដើម្បីបំបាត់ទុក្ខ ។

សេចក្តីដូចបានពណ៌នាមកនេះ បើពុទ្ធបរិស័ទទាំងឡាយគ្រប់ជាន់ថ្នាក់ មិនមានការប្រព្រឹត្តិបៀតបៀនជិះជាន់គ្នាទៅវិញទៅមក ដោយកាយ ដោយវាចា ដោយចិត្ត តែងតែសោកទើបបានសន្តិភាព សុខសុទ្ធតែរាល់រូបរាល់នាម ការចម្រើនលូតលាស់ ដោយទុក្ខវិបាកក៏ដោយ សុខវិបាកក៏ដោយ ដែលជាហេតុនាំឲ្យមានការប្រកួតប្រជែងប្រណាំងប្រជែងគ្នាស្វែងរកសេចក្តីសុខ ដោយមិនគិតពីការបៀតបៀនជិះជាន់គ្នាទៅវិញទៅមក ដែលជាហេតុនាំឲ្យមានសង្គ្រាមប្រាំងប្រជែងគ្នាស្វែងរកសេចក្តីសុខដោយ

មានសទ្ធិភាពសុខសប្បាយគ្រប់ៗគ្នា, កាលបើគេនាំគ្នាប្រព្រឹត្តល្អធ្វើកាយ វាចាចិត្តឲ្យស្ងប់តាមតុល្យភាពខ្លះនេះ កាលណា កាលនោះ គ្រឿងសស្ត្រាសម្រាប់ប្រហារមានគំរោងក្តៅធំ-តួចជាដើម ដែលណាក៏ដោយចុះ ខឿងតែសាបសូន្យអស់ពុំមានរឿយ ។

បើសទ្ធិភាពកើតមានក្នុងឥរិយាបថក្តីតួបក្សណា, ឥរិយាបថក្តីតួបក្សនោះមានសេចក្តីសុខបរិបូណ៌ពិតប្រាកដក្នុងភពជាន់លោក ដោយភ្លាតភ្លំពុំមាន ។ បើជាមនុស្សពាលអស់អៀនខ្មាសជ្រែញរអាចំពោះអំពើទុច្ចរិតនោះ។ ជាកម្រៃដែលមកពីការកុសលកាន់សីលធម៌តាមព្រះពុទ្ធសាសនាគ្រប់ៗប្រទេស, ប្រាកដជាបានសទ្ធិភាព តែគ្រប់ៗប្រទេសពុំមាន ។ សមគ្គានន្ទឥរិយាបថទី២ថា កុសលសង្ឃសមគ្គា ប្រែថា: ការបំពេញកុសលឲ្យបរិបូណ៌ គឺថា មានតែបុណ្យកុសលប៉ុណ្ណោះទេ ទើបឲ្យសុខជាផលកម្រៃ ។

ដូច្នេះ សប្បុរសពាលឥតគួរខ្ជិលច្រអូសឡើយ ត្រូវតែប្រឹងព្យាយាមញ៉ាំងកុសលធម៌ឲ្យស្អាតផូរផង់ល្អជានិច្ចកាលទៀង ទើបបានឈ្មោះថាជាន់ព្រះពុទ្ធសាសនា បានទទួលលទ្ធផលដែលខ្លួនយើងថាជាអ្នកប្រកបដោយធម៌ ពាលអ្នកជាខែកំសុទ្ធតែជាអ្នកប្រកបដោយធម៌ដូចគ្នា ។ បើយើងភាគតិចជាអ្នកធម៌អ្នកកាន់ព្យាប័ព្រះពុទ្ធសាសនាត្រូវហើយ ប៉ុន្តែទាស់នៅមនុស្សភាគ

ច្រើន ក្រែវាជាភត្តុទ្ទេសាសនា តើសុទ្ធសន្តឹកាពារមែនចំរើនឡើងដូចម្តេច កើត?

កាលបើពួកមនុស្សពាលឯអស់ ជាន់សុទ្ធចំរើនត្រេកអរក៏ពាយ កើតទ្រព្យសម្បត្តិសម្បូរសប្បាយត្រប់ៗប្រាណ ឥតមានខ្វះខោសក៏យកឥតគិតតែបំពេញធម៌សុចរិតពាំងអស់ ទើបក៏ពាយត្រេកអរតទៅលោកនេះ លុះទៅកាន់លោកខាងនាយ ក៏រមែងក៏ពាយត្រេកអរធំឥតតែក្រៃលែងជាងនោះទៅទៀត សមដូចភត្តុកាសិតថា ៖

ឥធ មោទតិ បេច្ច មោទតិ

កតបុញ្ញោ ឧភយត្ថ មោទតិ

សោ មោទតិ សោ បមោទតិ

ទិស្វា កម្មវិសុទ្ធិមត្តនោ ។

ប្រែថា: បុគ្គលអ្នកជាន់ធ្វើបុណ្យខ្លះហើយ រមែងក៏ពាយក្នុងលោកនេះ ១, ក៏ពាយក្នុងលោកខាងមុខ ១, បុគ្គលអ្នកធ្វើបុណ្យនោះ ១ រមែងក៏ពាយធំធំតែក៏ពាយយ៉ាងក្រៃលែង ព្រោះឃើញនូវអំពើដ៏បរិសុទ្ធស្អាតរបស់ខ្លួន ។

អធិប្បាយថា បុគ្គលណាជាន់ធ្វើបុណ្យអ្វីផ្សេង ដែលជាកាមាវចរកុសល គឺការបំរើមាតាបិតាត្រូវបដ្ឋាយាចារ្យ ចំខ្លះបំរើអ្នកដែលគួរ

ចំនុកបំរុង សិក្សាកុងវិជ្ជាល្អ ស្តាប់ធម៌ទេសនា ឲ្យទានរក្សាសីល ចំរើនមេត្តាធម៌ បុគ្គលនោះរមែងរីករាយសប្បាយក្នុងជាតិនេះ ដោយគេញ ចិត្តចំពោះអំពើល្អដែលខ្លួនបានធ្វើហើយនោះថា: "អំពើអាក្រក់ៗអាត្មាអញមិនដែលធ្វើទេ, អំពើដែលអាត្មាអញបានធ្វើហើយ សុទ្ធតែអំពើល្អ។ មានប្រយោជន៍ចំពោះក្នុងបច្ចុប្បន្ន ចំពោះក្នុងបរលោកដោយពិត" ។ រីករាយដូច្នេះ ឈ្មោះថា រីករាយគ្រោះកុសលកម្ម ។ លុះដល់បុគ្គលនោះ រម្ងាប់ខ្លួនទៅកាន់លោកខាងមុខ កំពឹតតែរីករាយសប្បាយក្នុងពួកទេវតា ព្រោះតែងឡើងគេលណា មានរូប, សំឡេង, ក្លិន, រស, សម្ផស្ស, អាយុ, ពណ៌សម្បុរ, សេចក្តីសុខ, កម្លាំង, សេចក្តីឈ្លាសវៃ សុទ្ធតែជាទិព្វទាំងអស់ ឮដំហានសូតិទេវលោកនាយឯណោះជាច្រើនដង ។ សេចក្តីរីករាយដូច្នេះឈ្មោះថា រីករាយគ្រោះផលនៃកុសលកម្ម ។ បុគ្គលនោះរីករាយហើយរំងឹតតែរីករាយដោយក្រៃលែងក្នុងលោកទាំងពីរយ៉ាងនេះ ព្រោះឃើញអំពើបរស់ខ្លួនសុទ្ធតែបរិសុទ្ធហើយ អំពើនោះឡើកម្រែផលមក កំដាច់ពេញចិត្តបំផុតថែមឡើងទៀត ដូច្នេះឯង ។ បុគ្គលអ្នកធ្លាប់បានធ្វើបុណ្យតែងត្រេកអរក្នុងលោកទាំងពីរ គឺក្នុងលោកនេះ ត្រេកអរដោយខ្លួនឃើញថា "បុណ្យអញបានធ្វើពុកល្អហើយ, លុះទៅកាន់លោកខាងមុខក៏បានទៅសោយទិព្វសម្បត្តិ ត្រេកអរក្រៃលែងក្នុងបុរេឈ្មោះតុសិតអស់ ៥៧ កោដិឆ្នាំនិង ៦០ សែនឆ្នាំទៀត

ជាតំណាត់ ។

លោកថា ខឹងខំអត់ ខ្សត់ខំរក មានបុណ្យមិនចេះខ្ជិច ម៉ាន់ពូជ មិនចេះក្រ ជាឧធម៌ហើយ កុំគិតឡើយសម្បត្តិឥន្ទ្រហ្វាវ៉ៃ ឆុំកាសិតំថ្ម បុគ្គលសាបាត្រោះពូជមែកណា ។ រមែងជាន់ផលមែកនោះវិញ, អ្នកធ្វើល្អ រមែងជាន់ផលល្អ, ឯអ្នកធ្វើអាក្រក់ រមែងជាន់ផលអាក្រក់ ។

អ្នកបូជាគេរមែងជាន់ការបូជាវិញ, អ្នកគំនាប់គាប់គួរគេ រមែងជាន់ការគំនាប់គាប់គួរវិញ ។ អ្នកឲ្យសុខគេ រមែងជាន់សុខវិញ, ចំណែកខាងការឲ្យទុក្ខគេវិញរសាត កំដូចគ្នាដែរ ។

ដូច្នេះសាធុជនទាំងឡាយ អ្នកមានប្រាថ្នាប្រាថ្នាសុខ- ចំរើន ឥប្បី ទុស្សាហ៍ចំតេញបុណ្យកុសលឲ្យជាឧក្រាស់ក្រនឡើង ហើយកុំគប្បីមាន ធម្មប្រមាទក្នុងខ្លួនឡើយ យ៉ាងនេះឈ្មោះថា កាយសន្តិភាព ដំរែរ ស្ងប់ខាងផ្លូវកាយ ឬ សន្តិសុខ សុខដែលកើតអំពីសេចក្តីស្ងប់ (កាយ) ឬហៅថា កាយសោចេយ្យ ភាពជាអ្នកស្អាតកាយ ឬ កាយសាមគ្គី «សេចក្តីព្រមព្រៀងដោយកាយ» ។

សុរពជាតក

(តថបំ)

លោក ថង-រឹង បម្លងពីសាស្ត្រាស្ងឹករឹត

ក្តាមដណ្តើនប្រស្នាចំពោះខន្ធ្យាយ។ កំឡុយតុំរួច, ទើបបបួលគ្នា
ទៅកាន់សំណាក់នាយព្រាន ។ នាយព្រានកំឡុយតុំបាន, បន្ទាប់មក
កំបបួលគ្នាទៅកាន់សំណាក់ស្វា ខ្លាធំ កិន្នរ រហូតដល់ទេព្តា ។
ជនទាំង ៧ នាក់នេះ ឡើយតុំរួចដែរ ។

លំដាប់នោះ ក្អែកនឹងក្តាមត្រមាំងសំឡាញ់ ៧ នាក់ នាំគ្នាគ្រាច់
ត្រសងទៅកន្លាត ។ ឯកន្លាតកំពោះស្រែយតុំត្រូវចិត្តក្តាមឡើយ ។ ទើប
ក្តាមនិយាយថា ម្នាលកន្លាត! អ្នកពោះស្រែយប្រស្នាយើងតុំត្រូវឡើយ
អ្នកដឹងថា សមណព្រាហ្មណ៍ ឬអ្នកគ្រូជាជបណ្ឌិតណាមួយ មានទៅ
កន្លែណាដែរឬទេ ? ។ តិរច្ឆា ន្លាតឡើយថា ម៉ៃក្តាមមាស! ឥឡូវ
នេះ មានព្រះពជបុត្រមួយព្រះអង្គ ទ្រង់ព្រះនាមព្រះសុរពកុមារ
តម្ងុបញ្ញោ ព្រះអង្គមានព្រះប្រាជ្ញាច្រើន បណ្ឌិតោ ជាបណ្ឌិត
បញ្ញាតាមគុណាំ បមាយ ទ្រង់លះបង់នូវតាមគុណ៥ ចេញទៅ
ទ្រង់ព្រះផ្នួសនៅកន្លែព្រៃព្រះហិមពាន្ត, ដូច្នេះ យើងត្រូវនាំគ្នាទៅកាន់

សំណាក់ព្រះអង្គហោង ។ សំឡេញ់តំងអស់ កំនាំគ្នាទៅកាន់សំណាក់ព្រះសុរត តាជិសត្វនោះឯង ។ តស្មិ ខណេ ក្នុងខណៈនោះ អស់ពួកខេត្តាតំងឡាយគឺ រុក្ខខ្លៃតា, អាកាសខេវតា ភូមខេវតា ទឹងខេវតាដែលបិតនៅក្នុងទីជិវៃខៀតជាច្រើន នាំគ្នាមកប្រជុំគ្នា ចាំស្តាប់ការដោះអាចម្រស្មារបស់ព្រះចាមាតាជិសត្វ ។ ក្យាណោះ សត្វតំងឡាយមកដល់ហើយ ថ្វាយបង្គំនមស្ការ ព្រះសុរតតាបស រួចហើយអង្គុយនៅក្នុងទីដំសមគួរ ។ ឯព្រះសុរតតាបស លុះក្រឡេកឃើញសត្វតំង ១០ នាំគ្នាមកដូច្នោះ ទ្រង់ញញឹមញញែញមដោយព្រះតម្រិះថា អហេ អមិត្តា ជាតា វ៉ែសត្វតំង ១០ នេះ ពីដើមមិនដែលឃើញជាមិត្តនឹងគ្នា, ឥឡូវនេះ មកជាមិត្តសំឡេញ់នឹងគ្នាដូច្នេះ តើមានហេតុអ្វីអេះ! អហោ អច្ឆរិយំ ន៎ះអស្ចារ្យណាស់ម្ល៉ា ពួកខេវតាតំងឡាយបបួលគ្នាមក មានបើគាស់ចែងគ្នា ដោយហេតុអ្វីមួយ ឃានជាបណ្តើរគ្នាមកកាន់អាស្រមរបស់អាត្មាអញ ។ កាលបើសត្វតំងអស់មកដល់ហើយ ក៏ក្រាបទូលតាមដំណើរថា ចៅត្រៃព្រះតាបស! រីឯកូនឯងគ្នាមពីរនេះគាស់ចែងគ្នា អំពីដំណើរក្តាមស្ទួរប្រស្នាកែកូន, ឯកែកឆ្លើយពុំរួច ដូច្នោះឃានជាយើងនាំគ្នាមកកាន់សំណាក់ព្រះអង្គ ដើម្បីឲ្យព្រះអង្គដោះស្រាយ ។ ព្រះតាបសសួរក្តាមថា អ្នកឃា ដណ្តឹងប្រស្នាមែនឬ? ។ ក្តាមក្រាបទូលថា ខូលព្រះបង្គំឃានដណ្តឹងប្រស្នា ២០ ចំពូកគឺ:

១- តើពុទ្ធដីជាធំលើសពុទ្ធតាំងពួន ក្នុងលោកយ៉ាងនេះ គឺពុទ្ធដូចម្តេច ?,

២- សុទ្ធអ្វីជាធំលើសសុទ្ធតាំងអស់ ក្នុងលោកនេះ ទើបបរិលោក ?,

៣- បើបុគ្គលឃ្លាន បានបរិភោគដល់ប៉ុន្មានៗ ក្តី តុំអាចនឹងបំបាត់ឃ្លានបាន តើអ្នកយល់ថា ឃ្លានអ្វី ?,

៤- ស្មើអ្វីល្អលើសស្មើតាំងពួង ក្នុងលោកយ៉ាងទើបបរិលោក ?,

៥- អាក្រក់អ្វីលើសតិរស្សាសត្វក្នុងភៅវៀត ក្នុងលោកយ៉ាងទើបបរិលោក ?,

៦- អ្វីធំ ក្រៃលែងធំ ក្នុងលោកយ៉ាងទើបបរិលោក ?,

៧- អ្វីខ្ពស់ ក្រៃលែងខ្ពស់ ក្នុងឥឆលោកនេះទើបបរិលោក ?,

៨- អ្វីស្តើ ក្រៃលែងស្តើ ក្នុងឥឆលោកនេះទើបបរិលោក ?,

៩- អ្វីត្រជាក់ ក្រៃលែងត្រជាក់ ក្នុងលោកនេះ ទើបលោកទាំងមូល ?,

១០- អ្វីល្អិតសុខុមលើសវត្តដទៃ ក្នុងឥឆលោកនេះទើបបរិលោក ?,

១១- ធម៌តអ្វីក្នុងលោកនេះ ត្រមតាំងលោកទាំងមូល លើសលែងជាធម៌តាំងអស់ ដែលហៅថា អតិតម ?,

១២- សភាពអ្វីរឿងធ្លុះធ្លាយ ក្នុងឥឆលោកនេះទើបបរិលោក ?,

១៣- កូនខ្ញុំមក្តី កូនសម្បកក្តី កូនស្បែកក្តី ឬក៏ផ្លែឪឆ្អឹងក្តី តើកូនអ្វីក្រអូបជាងកូន គន្ធជាតនេះ ? ,

១៤- កូនអ្វីស្អុយជាងគេ ក្នុងលោកនេះ ? ,

១៥- អ្វីខ្វាំងជាងគេ ក្នុងលោកនេះ ? ,

១៦- អ្វីឆ្ងាយជាងគេ ក្នុងលោកនេះ ? ,

១៧- អ្វីរហ័សជាងគេ ក្នុងលោកនេះ ? ,

១៨- អ្វីប្រសើរជាងគេ ក្នុងលោកនេះ ? ,

១៩- ខ្ញុំមអ្វីប្រសើរ លើសខ្ញុំមដទៃ ? ;

២០- សេអ្វីប្រសើរជាងគេតាំងអស់ ? ;

ប្រស្នារបស់ខ្ញុំលព្រះបង្គំតាំង ២០ នេះ ក្អែកឆ្លើយពុំបាន ទើបខ្ញុំលព្រះបង្គំមកខ្ញុំលសួរព្រះអង្គ ។

បពិត្រអើយ! ឮដំណាលនោះ ព្រះបរមគោតមសត្ថុទ្រង់ត្រាស់សួរទៅក្អែកថា ម្នាលក្អែក ! អ្នកបានដោះស្រាយមែនឬ ?, តើអ្នកដោះស្រាយដូចម្តេចខ្លះ ? ។

ទើបក្អែកក្រាបបង្គំខ្ញុំលព្រះបរមគោតមសត្ថុ តាមលំដាប់នៃប្រស្នាដែលខ្ញុំនបានឆ្លើយតបទៅក្តាម គ្រប់តាំង ២០ គឺ:

១- ក្អែកណាដែលឋុគ្គលកាត់ស្លាបកាត់កន្ទុយហើយ, ក្អែកនោះឥណ្ឌដល់ខ្ញុំវាសេចក្តីខ្ញុំក្នុលើសអស់ខ្ញុំតូចតាំងពួង,

២- បើបុគ្គលណា ឃាតបរិភោគសំឡាញ់ភ្លា ដែលបុគ្គលរៀបណាប់ស្អប់ហើយ ដកបង្ហែតស្តប់ស្តល់ ដូច្នេះឈ្មោះថា ជាសុទ្ធលើសសុទ្ធតាំងពួង,

៣- បើអ្នកណាមួយអត់អាហារកេពុំឃាត លុះយើញគេបរិភោគកំមានសេចក្តីស្រេកឃ្លានកើតឡើង នេះឈ្មោះថា អតិឧត្តរៈ,

៤- ស្មៅដែលហូរចេញពីកន្លែងព្រះអង្គឯង ភ្លឺត្រាចត្រាតពេញតាំងអាកាស មានអព្ភូតទឹងពពកច្រាសចេញអស់ ហៅថាស្មៅល្អលើសស្មៅតាំងពួង,

៥- សត្វណាមួយ អត់អាហារពុំឃាតយកបរិភោគ សម្បុរមែងសៅហ្មង ស្តាំងស្តមអាក្រក់ណាស់ហោង,

៦- ថ្នឯណាពុំមានទេ ណែនតាន់ល្អ នេះឈ្មោះហៅថា ធំលើសបេស់តាំងពួង,

៧- អាកាសខ្ពស់លើសអ្វីតាំងពួង ក្នុងឥធលោកនឹងបរលោកគ្មានអ្វីខ្ពស់ជាងអាកាសឡើយ,

៨- ភ្លើងធម្មតាក្តៅពុំស្មើនឹងភ្លើងនរក ភ្លើងនរកក៏ក្តៅពុំស្មើនឹងភ្លើងកល្ប ភ្លើងកល្បនេះ ឈ្មោះថា អតិឧណ្ហៈហោង,

៩- ទឹកក្នុងក្តែត្រជាក់លើសអ្វីតាំងអស់ក្នុងលោកនេះ នឹងលោកខាងមុខ,

១០- វត្តវិជ្ជាស្ថិតស៊ុទ្ធមលើសអ្វីតាំងអស់ គឺឃល់,

១១- ឯធីតុក្នុងកត្រៃ មានរាងកម័ញ្ញដទ្ធការ តុំមានវិស្មីព្រះបន្ទូនឯង ផ្ទាយ ឈ្មោះថា ឯធីតុក្រៃលែងជាឯធីតុអ្វីតាំងអស់,

១២- ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទរុងរឿងក្នុងពេលរាត្រី រមស់តាំងពីនេះ- រុងរឿងជាងអ្វីតាំងអស់,

១៣- ឋណ្ឌាគន្ធជាតតាំងអស់ មានសម្បកទឹងទ្វីមឈើជាដើម តុំស្មើនឹងក្លិនសាច់ជាតិតម្រេកចិត្តសត្វតាំងឡាយឡើយ ព្រោះក្លិននេះក្រអូបលើសលែងក្លិនតាំងពួង,

១៤- លាមកមនុស្សស្អុយជាងគេ ក្នុងលោកនេះ,

១៥- ព្រះនាគយណ៌ភ្លាំងជាងគេ ក្នុងលោកនេះ,

១៦- ចក្រពាឡឆ្ងាយលើសអ្វីតាំងអស់ សត្វបក្សីបក្សាហើរទៅតុំដល់ឡើយ,

១៧- ឃល់ព្យុះសង្ឃរហ៊ាសជាងអ្វីតាំងអស់,

១៨- ព្រះឥន្ទ្រាធិរាជប្រសើរជាងគេតាំងអស់,

១៩- ក្តីមានទ្វីមលើសអ្វីដទៃតាំងអស់ ព្រោះឃល់បក់មកក្តី ក្លិនដទៃក្តី តុំអាចធ្វើក្តីឲ្យវិនាសបានឡើយ,

២០- រសជាយកាជសាល័ខឹងសាច់ ប្រសើរជាងរសតាំងអស់ ។

បត់ត្រព្រះតាបស ។ ខ្ញុំព្រះអង្គ ជាឧត្តុយ្យប្រស្នានេះតបថៅក្តាម ។

ក្រៀណោះ ព្រះមហាបុរសទ្រង់ត្រាស់ថៅកាន់ក្តាមថា ប្រស្នានេះល្អិតសុខុមណាស់ កាលណាក្អែកនឹងទ្វើយត្រូវ ចូរអ្នកជាំនឹងឲ្យយំាស្តាប់យើង ។ នឹងដោះស្រាយ ៖

១- ខ្មែកដំដាំលើសក្មេកជាំនឹងភួងកន្ទឹលោកនេះនឹងបរលោក ជាន ដល់ក្មេក ៨ ប្រការគឺ: ជាតិឧក្កដ្ឋ ១, ជាតិឧក្កដ្ឋ ១, ឥស្សរិយឧក្កដ្ឋ ១, មានឧក្កដ្ឋ ១, បិយេហិ វិបរិយោគឧក្កដ្ឋ ខ្មែកកើតអំពីការត្រាត់ប្រាសចាកកូនរបស់ជាទីស្រឡាញ់ ១, អបរិយេហិ, សម្ប យោគឧក្កដ្ឋ ខ្មែកកើតអំពីការជួបប្រទះនូវតែដែលមិនជាទីស្រឡាញ់ ១, យម្បិច្ច ន លព្ភតិ តម្ប ឧក្កដ្ឋ ខ្មែកកើតអំពីការប្រាថ្នាវត្ថុអ្វីមួយមិនបាននូវតែនោះដូចបំណង ១, សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ខ្មែកដោយចំព្រួញបានដល់សេចក្តីទុក្ខ ដែលកើតអំពីបញ្ចក្ខន្ធជាំនឹងប្រុំ ១; ខ្មែកជាំនឹង ៨ ប្រការនេះ ឈ្មោះថា ជាទុក្ខលើសអ្វីជាំនឹងអស់ ។

រីសត្វជាំនឹងអស់មានក្អែកនឹងក្តាមជាដើម ត្រូវជាំនឹងខ្ពាប្រមាណ ១ សែនកំឡុងសេដូហាធុការឮសូរព្រហ្មនឹងតេញជាំនឹងព្រួញក្បា ។

២- សុខជាចំលើសសុខជាំនឹងភួង ៖ បានដល់សេចក្តីសុខរបស់បុគ្គលដែលបានស្តាប់ធម៌ ឬបានឃើញធម៌ ហើយមានចិត្តត្រេកអរ

សាវក ជាអ្នកមានចិត្តប្រាសចាកកាមគុណ ៣ ចេញទៅបួស ត្រេកអរតែក្នុងធម៌ម្យ៉ាងឯង, សេចក្តីសុខដូច្នេះ ឈ្មោះថាជាសុខលើសសុខ ទាំងអស់ក្នុងលោកនេះ ត្រង់ទាំងលោកទាងមុខ ។

៣- បុគ្គលអ្នកឃ្លាន ពោះបីបានបរិភោគប៉ុន្មានៗ ក្តី ក៏ពុំអាចនឹងបំបាត់នូវសេចក្តីស្រេកឃ្លានបាន, ឯបានដល់បុគ្គលអន្ធពាល ចិត្តជាបមិច្ឆាទិដ្ឋិធ្វើបាបកម្មផ្សេងៗ ហៅថាពុំចេះឆ្អែតឆ្អន់, ម្យ៉ាងទៀត បានដល់បុគ្គលអ្នកស្វែងរកមគុណ ក៏ពុំចេះឆ្អែតឆ្អន់ដែរ ។

៤- រស្មីព្រះអាទិត្យភ្លឺតែក្នុងពេលថ្ងៃ រស្មីព្រះចន្ទភ្លឺតែក្នុងពេលយប់ ពុំអាចភ្លឺខ្ទុះទៅក្នុងពេលទាងមុខបានឡើយ , រីរស្មីព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រមែងភ្លឺរុងរឿងគាំងពីមនុស្សលោក ព្រហ្មលោក រហូតដល់ព្រះនិព្វានជាទីបំផុត, មួយទៀត បានដល់រស្មីគឺប្រាជ្ញា ព្រោះប្រាជ្ញាជាធម្មជាតិអាចខ្ទុះឃើញ បាប បុណ្យ គុណទោស ប្រយោជន៍ និងមិនមែនប្រយោជន៍ ទីបំផុតបានដល់ប្រាជ្ញាដែលពិចារណាឃើញ ព្រះត្រៃលក្ខណ៍គាំង ៣ គឺ ទុក្ខំ អនិច្ចំ អនត្តា ដូច្នេះបានជាថា រស្មីនេះវិសេសលើសរស្មីទាំងពួង ។

៥- បុគ្គលជាមិច្ឆាទិដ្ឋិប្រព្រឹត្តធ្វើតែអំពើទាំង ៥ គឺ: បាណាតិបាត ១, អទិន្នាទាន ១, កាមេសុ មិច្ឆាចារ ១, មុសា ១, សុរា ១;

បុគ្គលដែលមានចិត្តជ្រុលដោយអំពើអាក្រក់ទាំង ៩ ប្រការនេះ រមែងខ្ជិលច្រើនចំពោះអំពើជាកុសល, ជួបប្រទះឃ្លាតថា មានសម្បុរសៅហ្មង, លើសការសៅហ្មងទាំងអស់ ។

៦- ចិត្តរបស់សត្វទាំងឡាយ ឈ្មោះថា ធំ លើសអ្វីទាំងអស់ បុគ្គលអកធ្វើនូវអំពើជាកុសលក្តី អកុសលក្តី មានចិត្តជាអ្នកដឹកនាំ ។

៧- មនុស្សក្នុងលោកខ្ពស់លើសអបាយភូមិទាំង ៤, ទេវលោកខ្ពស់លើសមនុស្សលោក, ព្រហ្មលោកខ្ពស់លើសទេវលោក; រីឯព្រះនិព្វានខ្ពស់លើសគេទាំងអស់ ព្រោះព្រះនិព្វាន មិនអាចនរណាមួយទៅបានដោយដំរើ សោះ ពាជរថខ្សែង, គេទៅបានដោយអដ្ឋង្គិកមគ្គទើបដល់ព្រះនិព្វាន ។

៨- ភ្លើងធម្មតាក្តី ភ្លើងទារុក្តី ភ្លើងកិលេសក្តី តែងដុតសត្វទាំងឡាយ តែមួយពេលមួយខណៈប៉ុណ្ណោះ ឯភ្លើងស្តៅជាងនេះទៅទៀត បានដល់ ភ្លើងគឺរាគៈ, ទោសក្តី ភ្លើងគឺទោសៈ មោហក្តី ភ្លើងគឺមោហៈ, ភ្លើងទាំង ៣ គ្នាក់នេះ រមែងដុតកំដៅចិត្តសត្វខ្លះៗឥតស្រាកស្រាន្ត ធ្វើឲ្យសត្វក្នុងលោកនេះអន្ទះអន្ទែងគ្រប់ពាក្យ ។

៩- វត្តុសម្រាប់ធ្វើឲ្យត្រជាក់ មានទឹកនិងខ្យល់ជាដើមក្នុងលោក

នេះ ពុទ្ធសិទ្ធិធម៌ជាពុទ្ធកាសិត ដែលព្រះសម្ពុទ្ធទាំង៣ព្រោយសំដែងពុក
មកឡើយ ។ ធម៌ដែលជាពុទ្ធកាសិតនោះមាន ៧ យ៉ាងគឺ: ការ
ចិញ្ចឹមទូរមាតាបិតា ១, ការប្រព្រឹត្តិគោតព្រៃងចំពោះត្រកូលរៀមច្បង
ឬចាស់ព្រឹទ្ធាចារ្យ ១, ពោលសំដីផ្អែមល្អោះចំពោះពៅអ្នកផង ១,
មិននិយាយសំដីចាក់ដោតអ្នកដទៃ ១, មិនមានសេចក្តីកំណាញ់ ១,
និយាយតែសំដីពឿងពាត់ ១. បំភ្លាត់សេចក្តីក្រោធខឹងបាន ១ ។
ធម៌ទាំង ៧ យ៉ាងនេះ ឈ្មោះថាត្រូវតាក់លើសវត្តដទៃទាំងអស់ ។

១០- ចិត្តស្អិតជាងខ្សែទន់តាំងៅថ្ម ចិត្តក្រៀងស្អិតលើសចិត្ត
ឆ្មាតា ចិត្តខ្ពមហាសមុទ្រស្អិតលើសចិត្តក្រៀង ចិត្តដោះពជ្រសីហ៍ស្អិត
លើសចិត្តខ្ពមហាសមុទ្រ, ឯចិត្តដោះពជ្រសីហ៍ពុំស្អិតស្មើនឹងធម៌ជាពុទ្ធ-
កាសិតឡើយ; ធម៌ទាំងឡាយជាសភាវៈស្អិត ជាលើសអ្វីទាំងអស់, កម្រ
មនុស្សយល់បាន ដេះស្ពាប់, មានតែអ្នកប្រាជ្ញទេបលោកយល់បាន ។

១១- ងងឹតកន្លះតសរកត្រីពុំមានព្រះចន្ទនឹងភ្លាយ ពុំស្មើនឹងការ
ងងឹតក្នុងលោកខ្ពនេះក, ប៉ុន្តែ ការងងឹតលើសអ្វីទាំងអស់ ចាត់ជាការ
ងងឹត ៣ ប្រការគឺ: ងងឹតដោយអវិជ្ជា ១, ងងឹតដោយមោហៈ ១,
ងងឹតដោយទិដ្ឋិ ១; ងងឹតទាំង ៣ នេះឈ្មោះថា ងងឹតជាងការងងឹតអ្វី
ទាំងអស់ ។

១២- ឥន្ទ្រីព្រះអាទិត្យក្តី, ឥន្ទ្រីព្រះចន្ទក្តី ពុំដល់ឥន្ទ្រីរបស់អ្នកមានប្រាជ្ញាទាំងឡាយទេ, ព្រោះដូចអ្នកមានប្រាជ្ញារមែងមានឥន្ទ្រីដ៏ខ្លាំងក្លា អាចតាំងការណាយើញថាបបុណ្យគុណទោសទាំងអស់ ។

១៣- កូនគន្ធជាតទាំងឡាយក្នុងលោកនេះ មានខ្យល់បក់ទៅច្រើនជាងមនុស្សលោកសន្ទនថា មានក្លិនក្រអូបលើសអ្វីទាំងអស់, ក្លិនគន្ធជាតនេះ តុំអាចក្រអូបច្រាសខ្យល់ទៅបានទេ; ចំណែកខាងក្លិនរបស់សីល រមែងក្រអូបផ្សព្វផ្សាយខ្លួនទៅ ក្នុងមនុស្សលោកនិងទេវលោក ។

១៤- បុគ្គលណាមួយ ប្រព្រឹត្តអំពើអាក្រក់ មានកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតជាដើម ឈ្មោះថា ស្អុយក្នុងលោកនេះនិងលោកខាងមុខ ។

១៥- វត្ថុដែលខ្ពាំងជាងគេក្នុងលោកនេះ តុំមានអ្វីស្មើនឹងមច្ចុរាជ (សេចក្តីស្លាប់) ទេ, ព្រោះមច្ចុរាជអាចគំរាមសុំមនុស្សលោក ទេវលោក ព្រហ្មលោក តុំមានអ្នកណាមួយតាំងក្បាំងនឹងមច្ចុរាជនេះបានទេ ។

១៦- ព្រះនិព្វានជាធម្មជាតឆ្ងាយជាងអ្វីទាំងអស់ ។

១៧- ចិត្តរបស់មនុស្សយើងរហ័សជាងអ្វីទាំងអស់ ។

១៨- រឲសវែដលប្រុសើរជាងគេតាំងអស់មាន ៧ យ៉ាងគឺ:-
សទ្ធា ជឿរឲសវែដលគួរជឿ ១, សីល រក្សាកាយវាចារៀបរយ
ល្អ ១, ហិរិ សេចក្តីខ្មាសអៀចបាប ១, ឱត្តប្ប: សេចក្តីខ្លាចអំពី
បាប ១, សុត ជាអ្នកបានឮបានស្តាប់ច្រើន ជាអ្នកចេះចាំធម៌ធ៌ងវិជ្ជា
សិល្បៈច្រើន ១, ចាគ: ការបែងចែកទ្រព្យរឲសខ្លួនឲ្យដល់បុគ្គលដែល
គួរឲ្យ ១, បញ្ញា សេចក្តីដឹងស្គាល់រឲសវែដលជាប្រយោជន៍ ខឹងមិន
ជាប្រយោជន៍ ១; វត្ថុតាំង ៧ ប្រការនេះ ប្រុសើរជាងទ្រព្យដទៃមាន
មាសពេជ្រជាដើម ។

១៩- ទ្វីមរុក្ខជាតិដទៃ ។ ពុំស្មើនឹងទ្វីមកុសលធម៌ទេ, កុសល-
ធម៌នេះ ឋានដល់ឋាន ១, សីល ១, ភាវនា ១ ។

២០- រសរឲសធម៌ ប្រុសើរជាងរសដទៃតាំងអស់ ។

តាបបើព្រះសុរតតាបសដោះស្រាយប្រស្នាតាំង ២០ ចប់សព្វ
គ្រប់ហើយ, អែសនាគ្គាត្រមតាំងសត្វតាំងឡាយ លើកអញ្ជលីស្រែក
ហៅថ្វាយសព្វញ្ញុការពរចំពោះព្រះបរមគោតមសត្វ ខ្លះថ្វាយកម្រង
មាលា ខ្លះថ្វាយខ្លួនរតនៈផ្សេង ។ រួចហើយទៀលទៅលំនៅឋានដទៃ ។
ហោង ។ ឯក្តាមមានចិត្តត្រេកអរសាទរឥតឧបមាបានទៅកើតជា ។
ព្រះបរមគោតមសត្វ ទ្រង់ឲ្យផ្លែកសមាទានសីល៥ ហើយត្រាស់ទៅកាន់

ក្តាមថា: ម្នាលក្តាម ! អ្នកកុំទៅកាន់ដែនរបស់មនុស្សឡើយ ចូរនៅក្នុងស្រះធំនេះចុះ ។ ក្តាមក្រាបទូលថា បពិត្រព្រះគាបស ! ទូលបង្គំមានបុរសម្នាក់ជាអ្នកចិញ្ចឹមក្បុង, កាលដែលទូលព្រះបង្គំមកកាន់ដែនេះ ទូលព្រះបង្គំបានដាក់បគាត់តាមដំណើរ, ដូច្នេះ គួរទូលព្រះបង្គំក្រាបថ្វាយបង្គំលាព្រះអង្គទៅកាន់សំណាក់គាត់វិញ ។ គ្រានោះ ព្រះបរមពោធិសត្វទ្រង់បង្គាប់ទៅក្អែកថា: ម្នាលក្អែក ! ដូច្នេះ អ្នកចូរនាំក្តាមទៅកាន់បុរសជាបិតាក្តាមវិញចុះ ។ ក្អែកឮហើយ ក៏នាំក្តាមទៅកាន់សំណាក់បុរសនោះវិញ ។ ឯបុរសនោះ ឃើញក្អែកនាំក្តាមមកដូច្នោះ ក៏ឲ្យចុយចំណីដល់ក្អែកស៊ីឆ្អែតស្កប់ស្កល់ ហើយក្អែកសុំលាទៅលំនៅរបស់ខ្លួន, ទើបបុរសនោះឆ្លើយថា បើអ្នកឃ្លានតុំមានអាហារបរិភោគ ចូរអ្នកមកបរិភោគជាមួយខ្ញុំឯណេះហាន៎ ។ ឯព្រះសុរពោធិបសលុះអស់អាយុពីមនុស្សលោកនេះទៅ បានទៅកើតក្នុងត្រហ្មលោកនាយ ។

សន្តា រីសម្តេចព្រះបរមសាស្តា លុះទ្រង់សំដែងធម្មទេសនាចប់ហើយ ព្រះអង្គទ្រង់ប្រមូលមកនូវជាតកថា: តំ ក្ខ្វេ ម្នាលភិក្ខុសង្ឃទាំងឡាយអើយ ! តថាគតមិនមែនមានប្រាជ្ញាតែក្នុងកាលដែលតថាគតបានត្រាស់ប្រាជ្ញាសពោធិញ្ញាណហើយទេ កាលពីដើមក៏តថាគតមានប្រាជ្ញាដែរ, ស្រេចហើយព្រះអង្គទ្រង់ត្រាស់តទៅទៀតថា:

តទា សុវណ្ណកក្កដោ ក្តាមមាសកាលនោះ បាន

មកជាពហុលត្តេរកឆ៌កាលឥឡូវនេះ, ខ្ញែកកឆ៌កាបេនោះបានមកជាអង្គុ-
លិមាលត្តេរកឆ៌កាលឥឡូវនេះ, ពានរកឆ៌កាលនោះបានមកជាលោលុ-
ទាយិត្តេរកឆ៌កាលឥឡូវនេះ, កន្ធរកឆ៌កាលនោះ បានមកជាភិក្ខុកស្សប:
កឆ៌កាលឥឡូវនេះ, ព្រះឥន្ទ្រ បានមកជាភិក្ខុឈ្មោះអនុរុទ្ធ កឆ៌កាល
ឥឡូវនេះ, ភ្នាតបានមកជាភិក្ខុមោគ្គល្លានកឆ៌កាលឥឡូវនេះ, ព្រះតិស្ស-
ការ បានមកជាភិក្ខុឆន្ទ:កឆ៌កាលឥឡូវនេះ, រីព្រះមាតាព្រះបិតារបស់
តថាគតកឆ៌កាលនោះ បានមកជាព្រះមាតាព្រះបិតារបស់តថាគតដដែល
រីព្រះសោរតកុមារដ៏ជាព្រះអនុជតថាគត បានមកជាភិក្ខុអានន្ទ, ឯព្រះ
សុរតាថេរ អហាមេវ តីតថាគតហ្នឹងឯង សម្មាសម្ពុទ្ធោ បាន
ត្រាស់ដឹងនូវត្រើ្យជ្ញាសពេជ្ឈញ្ញាណ ជាទីពឹងពំនាក់របស់ទេវតានឹង-
មនុស្សទាំងឡាយ ។

សុរតជាតកចប់តែប៉ុណ្ណោះ

ផ្នែកអក្សរសាស្ត្រ

រឿងហង្សវិយគ្គ

(តទៅ)

លោក អឹម-ភន បណ្ឌិតសាស្ត្រាស្ថិតិរឹត

ទេវីកែវត្រីកញ្ញា នាងយកបម្ពាំ នៃបទឹងដំណើរ ។ នាងក្រសីតាំងខន្ធ
ដង្គើល ជារូបស្រីស្អាត់ សោតសីងរកំ ។ កែក្រាយដជាយខន្ធាំ
ចាខបលំនាំ ខន់ភ្នំផ្សារស្រី ។ នាងក្រងកម្រងមួយនី
នាងយកមាលតី នៃបទឹងស្រលិត ។ នាងក្រងកម្រងផ្កែកផ្តិត ជា
បក្សីសត្វ តីហង្សមាសមៃ ។ ចំនាក្តាត្រីក្សៃត្រៃ ហាក់សៅវិស័យ
ចឹកចាប់ប្តូប្តា ។ នាងក្រងកម្រងមួយណា នាងយកក្តាំងដាំ នៃប
ទឹងមហាហង្ស ។ នាងក្រងតាំងខន្ធសោតផ្ងន់ ជារូបពជហង្ស
ហើរតាំក្តីមាស ។ នាងក្រងផ្កាផងធ្នុះធ្វាស យកកំដេញមាស នៃប
ទឹងត្រយង់ ។ នាងក្រងតាំងខន្ធជាកង់ ក្លោកមាសតេនតង់ យាង
យាសរេក ។ នាងក្រងកម្រងមួយណា នាងយកយុក្តា អញ្ជន់ចម្បា
ប្រាល ។ នាងក្រងផ្កាផងត្រគាល ជារូបសេកសា- រិកាតាំក្តី ។
នាងក្រងកម្រងមួយនី នាងយកខ្លួនស្រី រកស្រស់កែសរ ។

នាងក្រងកម្រងបវរ ជារូបកន្ទុរ ទ្រើសទ្រង់ចាំ ។ កែក្រាយ
ដាយរោំ យានយាសខ្ទាំ ខន្ធជាខបខ ។ នាងក្រងកម្រង
ច្រកដ ជារូបស្តេចត្រួង ឆៀងនាបនាគា ។ នាងក្រងកម្រងមួយ
ណា សុពណ៌តេត្រា ថើកធ្លងផ្កែកផ្កោះ ។ នាងក្រងកម្រងមួយ
នោះ សន្ធតនាមឈ្មោះ មាលាសិរសី ។ ក្បូរក្បាច់រំលេចសឹងក្តី
ច្រើនពណ៌ពិសី តំសេសសោភា ។ នាងក្រងផ្កាផងនានា ប្រុសើរ
ជាតិជា ត្រកាលពេកពន់ ។ ដូនតាសោតណាសឹងគន់ ឃល់នាង
ស្រីតន់ ក្រងផ្កាល្អក្រៃ ។ ដូនតាថ្លែងថាមាសថ្លៃ មានច្រើជាវៃ
លើសលែងលោកផង ។ ក្បូត្រីក្រងក្តីឥតឆ្គង សុរេចហើយហោង
ខើបយាយមាលា ។ ទាំក្តីឃ្នាតខ្ញីយាត្រា ទៅដល់ពជា ក្រាបទូល
ថ្វាយហោង ។ ក្បូត្រថ្លៃប្រពៃឥតឆ្គង តែយល់កម្រងផ្កានោះល្អ
ក្រៃ ។ ព្រះចុះខន្ធនាថរាជ្យស្តេជ័យ សព្វព្រះហឫទ័យ ឧឡឹងផ្កានោះ
ណាស់ ។ តុំលង់ព្រះអង្គស្តេចត្រាស់ ដល់ឆ្លឹងដូនចាស់ តើយាយ
មាលា ។ ព្រះសូរបន្ទូលត្រាស់ថា ដូនអើយនរណា ក្រងផ្កាថ្លៃខ្លះ
ល្អម្តេចចំឡែកដល់ម្លេះ កម្រងផ្កានេះ មិនតើយាយក្រង ។ ខើបយាយ
អតិថ្វាយឥតឆ្គង បង្គំទូលស្តង ព្រះបន្ទូលថា ។ បពិត្រសម្តេចជាជា
ចៅខ្ញុំមួយណា ប្តីវាលែងចង់ ។ តែថាដួងវាពុំចង់ ឆ្លើតាវគ្គត់ឆ្គង់
រកស៊ីឡើយណា ។ ហើយចង់តែស្អាងអាត្មា តើមេរូបអា- ក្រតក្រៃ

តោកតាន់ ។ រួបស្បាតស្រែងត្រាតតត្រង អក្រក់លើមលាន់ ក្រៃ
លែងអស់ស្រី ។ សរសៃខ្លាញ្ជិលអប្រិយ ហេតុនោះទើរប្តី ក៏
លែងចង់ចោះ ។ ពិតពីកាលប្តីក៏នោះ ខ្នាំមួយសូន្យសោះ ជ្វាយ
វែងណា ។ ក៏មកត្រាច់រកខ្ញុំជា ជីដូនហើយក៏ ទៅនឹងខ្ញុំហោង ។
ខ្ញុំឯងតាក់តែងឲ្យក្រង ផ្កាខេះជាម្ដង មកថ្វាយក្សត្រថ្ងៃ ។ ហើយក្រង
ផ្កាខេះនៃ សព្វព្រះហឫទ័យ ខ្ញុំអរក្តៅណា ។ ហើយខ្ញុំខ្លួលសូម
ក្រាបលា ឲ្យទៅខ្ញុំវ៉ា ក្រងតាជីខ្ញុំហោង ។ ទើបមហាក្សត្រាឡាស់
ឮរ៉ា ស្តេចបន្ទូលផង ទៅយាយមាលា ។ អញស្តាយទៅយាយខេះ
ណា ចេះជាងក្រងផ្កា ត្រកាលក្រមាន ។ ទុសជ្បឹតតំទឹតតុំបាន ចរិ-
យាបថគ្មាន រួបអក្រក់ក្រៃ ។ ឱនឯងកក់មកខោនៃ កុងផ្ទះសព្វ
ថ្ងៃ តុំបានឡើយហោង ។ តាំងថ្ងៃនេះទៅជាម្ដង យាយឲ្យក់ក្រង តាង
យាយហោងណា ។ ក្សត្រីណាក្សត្រមែនមានមេត្តា ស្តេចឲ្យក្រៃត្បាំ
តែកែងគ្រប់គ្រាន់ ។ ក្សត្រថ្ងៃប្រសើរសោភ័ណ ស្តេចឲ្យគ្រាំទ្រ នៃ
យាយមាលា ។ យាយបានប្រទានក្សត្រា បង្គំក្រាបលា ទៅផ្ទះនាង
បិត ។ ប្រដាប់ស្រែច ហ៊ាយជញ្ជាត់ ក្រាលឆ័ទទៅថ្នាត់ តុំលង់ឡើយ
ហោង ។ ស្រីថ្ងៃប្រពៃកន្ទុង នាងនាថទៅផង នឹងយាយមាលា ។
ជួយចម្ងល់ចម្ងាក់ជា សោឡសៃស្បា ចរិបូណ៌ហើយនៃ ។ ក្សត្រី
ក្រងកិរីសត្ងថ្ងៃ ថ្វាយមហាក្សត្រថ្ងៃ ទ្វេរាជបុត្រា ។ នាងបានប្រទាន

ក្សត្រា ចំញ្ជើមអាត្មា ជាប្រក្រតីហោង ។ យើងនឹងស្វែងសំដែងដោយ
ជន ដំណើរខំខន រកផក្សត្រី ។ នៅនេះយើងនឹងស្វែងក្សិណ៏ ហើយ
យើងនឹងថ្លែងពី ព្រះចាំពព្រហ្មទត្ត ។ ព្រះអង្គទ្រង់ធម៌ពេកក្លាត់ រើស
ពជបុត្រតន់ នាងនាថមិញ្ញាណ ។

បទកាកតតិ

នេះនឹងថ្លាថ្លែង បទកាកតតិតែង និពន្ធដំណាល ដំណើរអំពី
ព្រហ្មទត្តភូថាល រើសបុត្រត្រកាល ក្រោមដើមក្រឹស្ន ។

កាលនោះព្រះចាំព សម្តេចនរនាថ ព្រហ្មទត្តពជា ចាន់ពជកុមារ
ព្យាចាំលក្សា ចាន់ចរិបូណិជា សោឡសន្ទាំនៃ ។ ចៅក្រឹស្នកុមារ
ចរិបូណិតេញ្ញាណ ទ្រង់នាមប្រពៃ ព្រះវរិចតា ករុណាតេតក្រែ
ខ័ណ្ឌឲ្យគ្រងផ្ទៃ ក្រោមតាឯពជា ។ កាលនោះព្រះចាំព ត្រាស់ប្រើអាមាត្យ
ចរចេញម្ដីម្នា ប្រាប់អស់ក្សត្រឥន គ្រប់គ្រងសីមា ចំណុះពជា
ចាំនរយឯកអង្គ ។ ឲ្យរើសបុត្រី មុខមាត់ប្រិមប្រិយ សោតសិនតែងអង្គ
គ្រឿងគ្រប់ប្រជាប់ ស្រេចស្រាប់គ្រប់អង្គ នាំមកពុំលង់ ថ្វាយព្រះ
ភូថាល ។ ស្តេចនឹងឲ្យជា ព្រះពជជាយា ចៅក្រឹស្នកុមារ តាមសត្វ
ព្រះច័យ បុត្រថ្លៃសន្ធារ រើសពជកញ្ញា មួយមួយឯណា ។
នោះខែជមាមាត្យ ខុនតតាំព បង្គំក្រាបលា នាំព្រះរុទ្ធារ ពជសារ

ទៅថា ទីធីអស់ក្សត្រា សព្វគ្រប់ហើយនៃ ។ អស់ស្តេចស្តេចស្តាប់ព្រះអាជ្ញាច្រាប់ ម្ចាស់ម្ចាស់ តែធីតូក្សត្រី ឃ្លាតខ្ញុំធាប់ក្រៃ ដោយតួចំរៃ នាំបួលទៅថ្នាត់ ។ ជល់ដុំពុំលន់ តាំងរយៈឯកអង្គ សឹងនារាតន៍ ទ្រង់ត្រឿងប្រដាប់ ស្រេចស្រាប់តេកក្តាត់ នាំថ្វាយមហាក្សត្រ ព្រហ្មទត្តពារ៉ា ។ ក្សត្រាក្សត្រេដៀស្តង្ឃ ឲ្យហៅបុត្រថ្លៃ ខតអស់ជាតា ទៅក្រឹស្នកុមារ ត្រអាលម្ចាស់ ខតអស់កញ្ញា បុត្រីក្សត្រផង ។ ខតគ្រប់ហើយនៃ តុំសព្វព្រះទ័យ ជល់មួយជាមួង អស់ពជាតា ក្រាបលាទៅហោង រៀលវែងទៅផ្ទង ស្រុកទេសទីនៃ ។ ក្សត្រាណោះ ព្រះបាទ ព្រហ្មទត្តនោថ ធ្វើពជៀស្តង្ឃ ស្តេចចេញព្រះសូរ

បន្ទូលថាហៃ កូនស្តួនថ្លើមថ្លៃ តន្ទុកថា ។ កូនអើយហេតុអ្វី អស់តំធីនារី រយៈឯកអង្គា កំកូនតន្ទុក តុំយកនាងីណា ជល់មួយជាតិជា អឃិអគ្គមហេសី ។ ទៅក្រឹស្នកុមារ បុត្រស្តួនសង្ឃរាថ្វាយវែរៃទ្វីយ ទូលថាបតិត្រ សម្តេចកូមី ខ្ញុំមើលអស់ស្រី អស់បុត្រក្សត្រផង ។ ខ្ញុំមើលមិនពេញ ចិត្តមិនស្រឡាញ់ ជល់មួយឡើយហោង សព្វថ្ងៃខ្ញុំតិត ក្នុងចិត្តខ្ញុំចង់ អធិដ្ឋានផ្សង តាមបុណ្យបុកណា ។ ក្សត្រាណោះមហាក្សត្រ ព្រះបាទព្រហ្មទត្ត ធ្វើពជាថ្លើងថ្លាន ស្តាប់បុត្របន្ទូល ក្រាបទូលក្សត្រក្សត្ត ទើបព្រះអង្គមាន ព្រះបន្ទូលថា ។ ដែអស់អាមាត្យ ចូលទៅឱ្យឃ្លាត ធាប់-ធាប់ម្ចាស់ ស្រាលស្រីឲ្យបាន

មួយអ្នកនេះឬទ្ធា មកឱ្យបុត្រា អញតាលនេះម្តង ។ អាមាត្យទូលថា ចៅ
យាយមាលៈល្អក្រៃពេក ឥស់អង្គឥន្ទ្រិយ ឥតបាច់មានឆ្គង លើស
លែងស្រីផង ៈលោតំយានេះនៃ ។ បើព្រះពជបុត្រ បានយល់ច្បាស់ជ
សព្វព្រះដៀស្តីជ័យ មានព្រះទ័យ ស្នេហាគេកក្រៃ សព្វព្រះហឫទ័យ
មិនខេះឡើយណា ។ ព្រះបាទឥសូរ ស្តាប់តាមាត្យទូល ទើបព្រះពជា
ស្តេចយាងព្រះសូរ បន្ទូលត្រាស់ថា ចៅយាយមាលា អាក្រក់ក្តាត់
ហោង ។ គាត់ច្រោះអញថា តើតព្យាធ៌ពេគា ពេញចាំងខ្លួនហោង
យកមកឥតតម្លៃ អសារខេហោង នៃអស់គ្នាផង ព្រួយយើងខេណា ។
អាមាត្យស្តែងស្តាប់ ស្តេចបន្ទូលច្រោះ ទើបក្រាបទូលថា បពិត្រ
ព្រះបាទ ខនាងកំណា យើងខ្ញុំអស់គ្នា ចង់ឱ្យដែរ ។ ម្យ៉ាល
ឱ្យដាក់ដុំ ម្យ៉ាលរូបឧត្តម តិស៊ីនិមិល យើងនាំមកថ្វាត់ ថ្វាយ
ក្សត្រទសពល ឧត្តឱ្យបានយល់ រូបនាងនោះណា ។ ស្តេចស្តាប់
អាមាត្យ ទូលទើបព្រះបាទ ត្រាស់បន្ទូលថា ម្យ៉ាះព្នេះចូរចៅ
ចរចៅម្យ៉ាល៉ះ ឱ្យសោះសង្ឃឹ សន្ធឹកសង្ឃៃ ។ ក្សត្រាណានោះអាមាត្យ
ក្រាបលាព្រះ ។ ក្សត្រាដៀស្តីជ័យ ចៅដល់ត្រឹហា យាយមាលានៃ
ថ្លែងថាមាសម្លៃ ព្រះបាទក្សត្រា ។ ត្រាស់ប្រើយើងមក ប្រយោជន៍ធំធឹង
យក អង្គនង្គឯងណា ចៅឥឡូវថ្វាត់ មហាក្សត្រេចស្តា ស្តេចខំធឹង
ឱ្យដា មហោសីបុត្រភេន ។ នាងនាថស្តែងស្តាប់ អាមាត្យថ្លែងច្រោះ

ត្រែកអរតេពកក្តាត់ តិតថាអញបាន រួមហានថវបិត ទីឆ៍កូនអញ
ពិត តាលម្ខង់នេះនៃ ។ នាឆ៍នាថជាយា ទីឆ៍យាយមាលា ម្ខ័ម្ខា
រៃ។ ភៅទីឆ៍តាជ្ញា ក្សត្រាជៀស្តជ័យ តាលនោះឯងនៃ តុំលង់ឡើយ
ណា ។ ទរអ្នកផឆ៍យល់ នាឆ៍នាថទិមិល ទ្រង់នោមៈសាតា សឹង
រតេមកមើល សរសើរថ្លៃឆ៍ថា នាង់នេះល្អជា អស្ចារ្យតេកក្រៃ ។
នាឆ៍នាថជាយា ភៅផឆ៍តាជ្ញា ក្សត្រៈជៀស្តជ័យ ដរាំកដៈកេង់តេន
ក្សត្រាថ្លៃថ្ងៃ តេនៈតេញព្រះទ័យ ត្រែកសោមនស្ស ។ ក្សិណាមហា-
ក្សត្រថ្ងៃ ទ្រង់ព្រះក្រោធក្រៃ ដេរយោយមាលា មឹង៍ចោរកញ្ជាស់ តូត
ណាស់មហិមា មឹង៍ប្រាប់អញថា ចៅអាក្រក់ក្រៃ ។ លុះអញឲ្យ
ឃក បានចៅមឹងមក ឥឡូវនេះនៃ នាឆ៍ល្អកន្ទឆ៍ ហ្មត់ហ្មឆ៍ល្មមល្មៃ
ឥតស្រើដរៃ ថ្លឹមផឆ៍បានណា ។ ក្សិណោះព្រះចៅ ស្តេចត្រាស់
ប្រើភៅ អញ្ជើញបុត្រា រ៉ាជកុមារ ត្រាលម្ខ័ម្ខា មកថ្លាឧបិតា ជិកជ
ជៀស្តជ័យ ។ ឃលំព្រះមាតា ស្តេចពុំស្គាល់ជា ជនទីក្សត្រថ្ងៃ តិត
ស្មាឧអ្នកកស្ត្រ តាំឆ៍ថ្លាសរសៃយ សព្វព្រះហ្ឫទ័យ តើតកួចស្នេហា ។
ចៅត្រើស្តកុមារ ទូលព្រះភូបាល ព្រះវរបិតា សព្វព្រះហ្ឫទ័យ
ក្សត្រៃថ្ងៃកុណា ខ្ញុំទឆ៍ឃកជា អយិអគ្គមហេសី ។ ក្លាលនោះមហាក្សត្រ
ព្រះបាទត្រាហ្ម៎ទត្ត ស្តាប់មុត្រក្សាប្រើយ ត្រាបទូលព្រះមហា ក្សត្រា
ធិបតី សម្តេចភូមិ ត្រែកសោមនស្ស ។ ស្តេចឲ្យស្រីផ្ការ ព្រះ

ស្តេចក្រមការ អភ័យយាយផងណា នាំនាងទៅស្រង់ ស្រេចទ្រង់តន្ទា
ចួរចន្ទន៍ក្រឹស្នា គ្រប់គ្រឿងប្រដាប់ ។ ស្តេចឲ្យភ្ញាក់ងារ រៀប
ឋណ្ណាការ ចរបូណិស្រេចស្រាប់ ធ្វើការជាធំ ដោយក្រមក្រឹត្យច្បាប់
តិមង្គលតាប់ អាពាហ៍ពិពាហ៍ ។ ឥសុំមុខមន្ត្រី សេនាបតី បុរោហិត
រៀបពេនក្សត្រថ្វៃ ច្រើនក្រៃណាស់ណា តាល់ព្រះរាជា ឯកដទ្ទម ។
ឥសុំតួរតន្ត្រី តិណពាទ្យកេរី សោតសឹងប្រគំ ចំរើរស្រែ ដោយខា
ត្រីក្សត្រម ច្បាប់ការជាធំ ឥតខ្វះឡើយណា ។ ហើយគោះគង់ជ័យ
បុរោហិតសោតនៃ សឹងសូត្រតាម ចំរើនសួស្តី ព្រឹទ្ធិដយ ថ្វាយ
ពរព្រះមហា ក្សត្រតាំងពីរអង្គ ។ សម្តេចភូបាល រៀបបណ្ណាការ បុត្រ
តាំងពីរតន្ត្រ ច្បាប់ការជាធំ ខត្តមទត្តង្គ នៃរាជព្រះអង្គ ព្រះបាទ
ជេដ្ឋ ។ ស្តេចយកបូរ ចំរើនវ័រស្រី បុត្រពីរអង្គា ព្រះអង្គអគ-
សេក ជាឯករាជ្យ គ្រប់គ្រងសីមា តាពណាសី ។ ស្រេចការហើយ
ណា ព្រះរាជបុត្រា ទូវព្រះជនន៍ គន់ច្រាសាទមាស ទ្តុះឆ្ងាស់ស្មើ
ស្មុះចូលរាត្រី យប់យូរសន្ធិយា ។ តន់វេលាកាល ទៅក្រីស្នក្ខមារ
ចរចរយោត្រា ទៅថ្ងាននាងនាថ នាគាលនោះណា នៃទេវទេវ្តា
ឯចដល់មកខ្ញុំ ។ កាលនោះមានឆ្នា មេនឹងកូនវ៉ា យល់ព្រះភូមិ
រស្តេចយោត្រាទៅ សំដៅសិរសី កូនឆ្នាស្រដី ជណ្តើងមេវ៉ា ។
ថាហៃមេអើយ នែណាឯងហើយ ហៅហានមហិមា ដើរលើ

ក្សាលយើង ឆ្ងន់ជើងម្ខែណា ពុំកោតសរសើរសោ យើងដល់តែចឡើយ ។
រីឯមេឡូ ថ្ងៃឯឃាត់កូនថា អម្ចាស់កូនអើយ កុំកូនចរចា ថ្ងៃឯថាខ្លោះ
ឡើយ លោកកោតក្តីឡើយ យើងជាតិរបួន ។ អម្បាលមាន
បង្កើតសរសើរសោ ម្ខាំកូនលោកហ៊ាន ឃកម្តាយឯងជា តរំយោនៃក្តាណ
កុំកូនមានសមាន ចិត្តគិតខ្លោះឡើយ ។ ក្តីណានោះពាង ឃានស្តាប់
មេរ៉ា ស្រដីខ្លោះហើយ ព្រះអង្គស្តេចទាន តុំឃានទៅឡើយ ក្តីត្រា
ត្រាណាត្រើយ ទៅធ្លុំវិញាណា ។ យាមមួយខ្មែតនោះ ស្តេចចរេទៅ
ខ្លោះ តំរង់តីត្រា កាលនោះឃុំមេ តពែមួយណា បំបៅកូនរ៉ា
ពុំលង់ក្តី ។ មេពែថា កូនអើយញ៉ាំឯឃា ដល់យល់តោដ ឃក
ព្រះមាតា ឯងជាមហេស៊ី ពុំដែលមានតិ- ឃុកណាខ្លោះណា ។
ក្តីណានោះស្តេចស្តាប់ លុះឮសារសំពួ តាក្សពែថា ស្រដីខ្លោះនៃ
ក្តីត្រាថ្ងៃយាត្រា ទៅថ្កាន់ក្រឡា បន្ទុំវិញហោង ។ យាមមួយខ្មែត
ណា ស្តេចទៅបួជា តំរង់ដីដង កាលនោះសោតនៃ សេះភ្លើមួយ
ផង ទឹងកូនរ៉ាហោង កូនសោតស្រដី ។ ដណ្តើងមេរ៉ា ដូចកល់
តាក្សឆ្នា យើងឃានថ្ងៃឯតី តាលមុនជាអតិ ព្រះជ័ខកូឃុលា ឮសតូ
ស្រដីជាអស្តារក្រៃ ។ ស្តេចទ្រង់ចិត្តា ក្នុងព្រះទយា ថាអញនេះ
នៃ ព្រះវរបិតា ក្តីត្រាដៀស្តីជ័យ រើសអញតីត្រៃ មកជាកូនធម៌ ។
សមនាងនេះណា ជាព្រះមាតា តែអញពុំស្គាល់ នេះសមខេត្ត

ធ្វើអស្ចារ្យសល់ ឲ្យអញឃ្លាតយល់ ជាព្រះមាតា ។ សមអ្នកគ្រាប់
មក ប្រយោជន៍ខ្លះក អញជាបុត្រា ដល់ស្រុកនេះអ្នក តិងពាក់
ខៅខា ផ្ទះយោយមាសា មែនមិនខេឡើយ ។ ស្តេចទ្រង់ចំពោ
អម្បាលនូវប្រែការដូច្នោះហើយ ក្សត្រិណានោះព្រះមហា ក្សត្រាត្រាណ
ត្រើយ ស្តេចតុំលង់ឡើយ រឹសវិនមកឋាន ។ ក្រឡាបខ្ញុំ ក្សត្រិណ
ក្សត្រខត្តម ស្តេចអធិដ្ឋាន ខឹងអស់ត្រីក្សា ខេត្តាហិមពាន្ត សោ-
ឡសសួតិហាន សឹងសព្វប្រថព័ ។ បពិត្រខេត្តា បើខាងនេះណា
ជាក់ជាជនខ័ អញាចរចូរមៅ ឥឡូវនេះខ្ញុំ សត្វជនកុំបី ចរចាខៀត
ខ្លើយ ។ ស្តេចអធិដ្ឋាន សច្ចាប្រណិធាន ជាសូរេចហើយ ក្សត្រិណ
នោះព្រះអង្គ តូចតន្ត្រីក្រាណត្រើយ តុំឲ្យរឲ្យងខ្លើយ ស្តេចមៅខៀត
ហោង ។ អស់សត្វនោះណា ពិតតុំចរចា ស្ងៀមស្ងាត់ជាម្ខង នៃ
ខើមព្រះមហា ក្សត្រាច្បាស់ច្បង ស្តែងស្តេចមៅម្ខង ដល់ព្រះមាតា ។
ឯព្រះជនខ័ ប្រសើរសល់ស្រី ឃលាកជបុត្រា មៅដល់ក្សត្រី ចុះតីក្រ
ឡា បន្ទំម្ខាង មៅក្តាន់បុត្រតន៍ ។ ឥតិបន្ទូលថា អ្នកឯងនេះណា
ព្រះចាតព្រហ្មខត្ត ដែសអ្នកតីព្រៃ ហើយនៃមហាក្សត្រ ឃកអ្នកមក
ថ្វាត់ ជាកូនធម៌ថ្ង ។ អង្គអ្នកឯងណា ប្រាកដជាក់ជា កូនម្តាយ
ឯងនៃ កាលនោះម្តាយព្រាត់ ខ្លាយខ្លាតតីព្រៃ ខឹងអ្នកនៅនៃ ហិមពាន្ត
នាយណា ។ សម្តេចកូមី ស្តេចស្តាប់ជនខ័ ប្រាប់ព្រះកជា ខើប

ក្សត្រត្រកូល ស្តេចខ្លួលមាគា ជាខ្ញុំនេះណា ជនកដៀស្តីជ័យ ។
គាលនោះព្រះបាទ ស្តេចទៅប្រគាត លើសខ្ញុំពីព្រៃ យកមកកែប្រែ
ជាកូនជនមនៃ អង្គខ្ញុំសព្វថ្ងៃ ពុំស្គាល់ខ្លាំយូរឡើយ ។ ឯព្រះមាគា
ស្តាប់កូនខ្លួលប្រកាដូច្នោះហើយ ទើបនាងថ្លែងថា ស្ងួនភ្ងាខ្លាំងអើយ
កុំកូនគ្រាណាត្រើយ សន្ទិះសង្កា ។ កូនអើយសំពត់ មួយដែលម្តាយ
បត់ ម្តាយក្រាលផ្តេកថា គាលម្តាយចូលឈប់ ក្រោមអូបក្រឹស្ន
ចិញ្ចៀនមួយជា ត្បូងសូរ្យកាន្តតន៍ ។ សឹងមានដំរៃ ម្តាយចងទៅ
ដៃ កូនមាសប្រមាត់ ចិញ្ចៀននោះណា កក្រាទើបថ្លាត់ តង់ទៅ
ប្តូបាត់ ណាកូនមាសថ្លៃ ។ សម្តេចភូមី ស្តាប់ព្រះជនន៏ ប្រាប់ដូច្នោះនៃ
ស្តេចដឿជាកំជា មាគាក្សត្រថ្លៃ ឥតមានព្រះទ័យ សន្ទិះសង្កា ។
ក្សត្រីណានោះព្រះអង្គ យកព្រះទំរង់ ទូវព្រះពាស្តូ ថ្វាយជាសាក្ស
ជនន៏គាលត្រា នោះឯងជាកំប្រាកដពិតពុំលន់ ។ សម្តេចពាជា សែន
សៅយសោកា ណាលំណាស់ខ្ញុំឮទ្រង់ កន្ទែងសោកសោះ គាល
នោះព្រះអង្គ ក្រោមក្រោមឃាតបង-ន្ទឹព្រះមាគា ។ ឯព្រះជនន៏ រៃពង្សក្សត្រី
ខ្លួលតស្តូ ទូវព្រះទំរង់ តេន្ទ៍ផ្តង់ហើយណា នាងនួបបុត្រា ទ្រង់
ព្រះកន្ទែងន ។ សែនស្តាយស្តោះស្តួ គាល្បិតអនាថ្ម បន្ទូលខ្លួញថ្លែង
ខ្លួនមាសថ្លៃ សព្វថ្ងៃម្តាយតែង ខ្លាំងខ្លួលមែន ក្នុងទ្រង់ពីក្តី ។

ជាពុកមួយណា ដរីតម្តាយព្រាត់ចុ បុត្រស្ងួនភ្ងាប្រើយ ពុកមួយ
ដរីតប្រាស ខ្លាសស្ងាម៍ សម្តេចកូម៍ ជនកកូនអើយ ។ ខេះ
ម្តងម្តាយបាន ហេតុបុណ្យបុពណ ដួចខ្ញំឯងបាហើយ ក្នុងទ្រូង
ម្តាយបាន ស្រាកស្រាន្តកូនអើយ ស្រយាលវៃល្អៃល្អើយ ពុកមួយគោះ
ហោង ។ ចៅក្រឹស្នក្ខមារ កូនស្ងួនសង្សារ បង្គំបួលស្នង បត់ត្រ
ឡកម្តាយ ខ្លាយដើមទង ដំណាលខំនង ដំណើរគោះម្តេច ។
នាងស្តាប់បុត្រា ខូលសូមចិន្តា ចង់ជ្រាបសាច់ត្រួច នាងចរចាចែង
ថ្លាថ្លែងសព្វសេច- ក្តីប្រាប់សម្តេច ព្រះរាជបុត្រា ។ ខ្ញុំម្ចាស់ម្តាយ
អើយ ដំណើរដើមឡើយ ឯឥពុកថា គ្រប់គ្រងរេហ៍តល សកល
យោជា ឋិតនៅសីមា ក្រុងខេតបូរី ។ ឯអញម្តាយថា ជាបុត្រក្សត្រ
ឯកជនឯបតី សោយរាជ្យនៅនា បញ្ជាលជានី ឯកឯងជាអ- ស្ងួរ
អស់រាស្ត្រផង ។ ឯឥពុកថា តង់ហង្សយន្តណា យាត្រាហោះផ្សង
ដួចដល់ស្រុកម្តាយ ឯងាយជាមួង សំណាក់នៅផង ព្រាហ្មណ៍ច្រូង
ហោក ។ ហើយព្រះអង្គនៅ បំរើព្រះចៅ ជាដីតាថា ស្តេចនៅ
ឯឯអង្គ យូរលង់នៅណា តាលគោះដីតា ចាត្រង់ត្រាងក្រៃ ។ ព្រះ
អង្គឱ្យចាប់ នាំនៅសម្ងាប់ នៅនាព្រះព្រៃ ឯងាពុកថា ច្រាជ្ញា
ឈ្លូងនៃវ៉ៃ សម្តេចជៀសជ័យ លួងអស់តេជ្ឈឃាត ។ ស្តេចរួចពីភ័យ
តង់យន្តមាសមៃ ហោះដល់ច្រាសាខ យកម្តាយជាកំលើ ហង្សយន្ត

មាសស្អាត ស្រេចហើយព្រះបាទ ហោះចេញមកវិញ ។ ចុំនចំនិសំ-
ដៅ ខ្ញុំនិងហោះឆ្ពោះទៅ ក្រុងខេតជ្ជប៉ី ហោះតាមដាន បញ្ជាលជាន
ចរចេញចាកពីរ ស្រុកប្រាំតីរថ្ងៃ ។ តុំខាន់ដលឡើយ អម្ចាស់ម្ដាយ
អើយ តាប់ម្ដាយឈឺថ្លៃ ខ្ញុំនិងប្រសូត្រថា ឯងណាមាសថ្ងៃ ក្បាលណា
ក្បាត្រជៀស្ដង់យ ព្រះជនកថា ។ តើចយន្តចុះឈប់ អាស្រ័យក្រោម
ម្លប ព្រះថ្ងៃសាខា ហើយម្ដាយសម្រាល ចាកាលនោះណា កណ្ដាល
ព្រឹក្សា ហេមតាន្តថ្ងៃព្រនោះ ។ ព្រះជនកថា យល់ម្ដាយវង្ស ស្ដេច
តនិយន្តហោះ ទៅរកអគ្គី ប្រាសតាកាលនោះ ខ្ញុំវាសសូន្យសោះ
ខ្ញុំនិងម្ដាយហោងណា ។ កូនអើយម្ដាយទៅ នោះចាំព្រះបៅ តាមាក់
ខ្ញុំនិងថា ចាំបាច់ខ្ញុំនាត់ យល់ចាត់ថ្នាះណា ម្ដាយសោយសោក
ណាស់ណាស់កូនអើយ ។ ម្ដាយយកព្រះករ ចាំនិងតាម្ដាយនរ តក់ទុក
ហើយ ដលនេត្រសស្រាក់ តតអាក់កូនអើយ មិនមានហៅ
ស្បើយ តាម្ដាយណា ។ ម្ដាយសោកសន្ទប់ ឯកឯងសូន្យសូន្យ
ដេកដោយនាក ម្ដាយភ្ញាក់ស្មារតី តាសន្ទប់ណា ហើយម្ដាយបាថា
រត់រកដោយព្រៃ ។ ម្ដាយឈប់ស្រែកហោ រកព្រះបម៉ៅ តុំយល់
ឡើយនៃ កូនអើយម្ដាយអា- សូរបាហាលថ្ងៃ ម្ដាយឈប់អាស្រ័យ
ក្រោមដើមត្រឹស្នា ។ ម្ដាយយកសំពត់ នេះឯងម្ដាយបាត់ ម្ដាយក្រាល
ផ្ដេកថា យកព្រះទំរង់ តេនិផ្ដង់នោះណា ម្ដាយបងនិងបា ហើយ

ម្ដាយផ្ដល់នៅ ។ ក្រែមដើមក្រឹស្នា ម្ដាយចំបៅថា ស្រែចាហ៊ីយ
ម្ដាយទៅ រកព្រះជៀស្ដេច ដោយព្រៃគ្រោះគ្រៅ តុំយល់ព្រះថា
ភ្លើយវិលមកថ្ងាត់ ។ ដល់ដើមក្រឹស្នា ម្ដាយតុំយល់ថា ស្ដាំតែម្ដាយ
ថាត់ ដួលសន្ធប់នា ឆាកហ៊ានស្ងាត់ ហេតុដូចតម្ដាយតាត់ ស្រ-
ឡាញ់កូនក្រៃ ។ ម្ដាយសន្ធប់លង់ តែឯងឯកអង្គ កណ្ដាលទ្រូងព្រៃ
លុះភ្ញាក់ស្មារតី ម្ដាយតំលាបក្រៃ តាមកូនមាសថ្ងៃ ដោយដាននោះ
ណា ។ ម្ដាយដើរព្រៃស្ងាត់ ឃើញតែហ្វូងសត្វ ចេង៎ឃ្នងពាន
ម្ដាយស្រាយស្រាកសល់ ខ្លាចលង់ខ្លុកា ម្ដាយតាមរកថា ដល់ស្រុក
នេះនៃ ។ កូនអើយម្ដាយឈប់ ហើយម្ដាយជួនឃប់ សូមចតតា-
ស្រ័យ ផ្ទះយាយមាលា តាត់ជាពេកក្រៃ ឃាត់ម្ដាយនៅនៃ ទឹង
តាត់ហាងណា ។ ហើយតាត់និយាយ ដំណើរប្រាប់ម្ដាយ ថាព្រះ
រាជា តាមព្រះត្រហ្មទ្ត្ត មហាក្សត្រើសថា ឃាតចំញឹមជា កូន
ធម៌ក្សត្រថ្ងៃ ។ ម្ដាយតតចង់មក តាន់កូនពន្ធុក ទ្វាចក្សត្រជៀស្ដេ
ដ៏ឃ ព្រះអង្គយកម្ដាយ មេម៉ាយច្នេះនៃ ក្រែងមហាក្សត្រថ្ងៃ ឃាត
ជាមរហស៍ ។ ម្ដាយនៅលង់ណា សោឡសរសា ម្ដាយតែងក្រង
ភ្ញី ទ្បៃយាយមាលា តាំងភ្លាមកន្ទឹ ថ្វាយព្រះភូមី ទឹងថាឯងរហាង ។
ក្រែងកូនមាសថ្ងៃ ថាខ្លួយលំលាយដៃ ភ្លាដែលម្ដាយក្រង្គ ហើយថាទ្បៃ
យកៈ ម្ដាយមកជាបង្គ ថាខជួបជួនផង កូនស្ងួនពុំឆ្ងា ។ សម្ដេចភូមី

ស្តាប់ព្រះជនទី ឋទ្ធុលត្រាប់ប្រ. ការដូច្នោះនៃ ក្សត្រៃថ្លៃសោភា ឋទ្ធុល
ទ្ធភ្ញាថា ។អម្ចាស់ថ្លៃ ។ ម្តេចឡើយអ្នកម្តាយ លំបាកអំបាយ ពេក
ពន់ណាស់នៃ ប្រាសម្តេចតាំងកូន សោះសូន្យទីនៃ ប្រាសទាំង
ដៀស្ងួយ ព្រះវរបិតា ។ ។ព្រះជនទី ការកូនចាកពី ។ទរអ្នកណា
ចានចិត្តខាត់ ហើយប្រាសត្រាត់គ្នា សង់សុះជួបជា សៅឡសន្ធាំ
នៃ ។ កំកូនតុំបាន ស្គាល់អ្នកមេមាន គុណតាប់ប្រពៃ ហេតុបាប
កូនឯង ពីត្រង់ក្រាស់ក្រៃ ឲ្យប្រាសទីនៃ ធំធ្ងន់ព្រះមាតា ។ កូន
ដូចតិរច្ឆាន សត្វជួសាទាឲ្យ មែនមិនស្គាល់ជា អ្នកមេមានគុណ
មហាធ្ងន់ឡើយណា នេះហេតុវេក កម្មកូនឯងនៃ ។ អ្នកស្គាល់កូន
ហើយ អម្ចាស់កូនអើយ ទើមតែទាថ្លៃ នេះកូនស្គាល់អ្នក ដៀង
ជាក់ពេកក្រៃ ជនទីនេះនៃ កូនសោយសោកសល់ ។ កូនឃើញអ្នក
ហើយ អម្ចាស់កូនអើយ កូនជាទុក្ខសល់ តានតឹងទុក មួយប្រ-
ការគេល់ ដ្បិតកូនតុំយល់ ព្រះវរបិតា ។ អ្នកអើយកូនស្តាប់ ពាក្យ
អ្នកម្តាយប្រាប់ កូនវែងឈឺផ្សា ផ្សាយផ្សព្វអស់អង្គ ប្រត្យង្គខ្យា
ដ្បិតកូនកំព្រា ប្រាសព្រះបរមៅ ។ ។ព្រះបិតា ធំពាដឃ្លាតឃ្លា
ប្រាសពីកូនទៅ ជាព្រះអង្គមាន វិញ្ញាណរស់នៅ ឬមួយព្រះហើ
ក្សយក្សយដន្ម ។ ។ព្រះទសពល កូនតុំបានយល់ ព្រះតក្តែអ្នកណា
ហេតុបាបកូនឯង ពីត្រង់វេក ផ្តល់កូនក្រៀលគ្រោ នេះឯងកូនអើយ ។

ព្រះវរមាតា នាងស្តាប់ប្តីត្រាស់ សោយសោកខ្លោះហើយ នាងនាថវែង ជា សោកពុំស្បើយ នាងថាកូនអើយ ម្តាយឯងសព្វថ្ងៃ ។ នៅតែ ខ្លួនខ្លួ ដ្បិតច្រាសអាពុក ចាំឃ្លាតពីមែ ម្តាយឈឺផ្សាផ្សង សង្រេង សង្រែ សន្ធឹកសង្ខែ ឥតស្បើយឡើយហោង ។ កូនអើយចូរចា ឲ្យ សង់សាលា ឲ្យទានកោដន៍ផង ហើយតួនយាយ អតច្រាយដើម ខង ដំណើរខំនង កាលច្រាតច្រាសគ្នា ។ ក្រែងព្រះទេសពស ស្តេច ដើរមកដល់ ស្រុកនេះស្តេចជា អ្នកកំសត់ចាន យកទានយើងណា ហើយព្រះកថា តែតំខ្លួនផង ។ បើស្តេចទតយល់ សមសោយសោក សល់ មិនខេឡើយហោង កូនអើយយើងចាន រួមហានដូចចង់ តាំង ចិជាម្តង ដូចចិត្តចិន្តា ។ កូនអើយមួយទៀ កុំថាស្រដី ច្រាប់ព្រះពជា ថាជាម្តាយឡើយ កូនអើយចូរចា អតច្រាយច្រាប់ថា ជាកំរោហោង ។ ព្រះពជបុត្រា ស្តាប់ព្រះមាតា ក្សិណាក្សត្រឮសច្បង់ តាកំតែងប្រ-ជាប់ តាប់-តាប់ដូចចង់ ស្តេចត្រាស់ថាផង ទើតកូនភ្លាកង៉ារ ។

បទតំណោល

កាលនោះចៅក្រីស្តុកមារ ត្រាស់ប្រើអ្នកការ ប្រជាប់ឲ្យសង់ សាលា ដ្បិតស្តេចមានព្រះយា ទ្រង់ព្រះសទ្ធា ទើតស្ថានព្រះពជកុ សល ។ អាមាត្យបង្គិំសពស ទៅតែងខ្លាយខ្លួល ប្រជាប់សង់ជាសា លា ។ ជាង-ជ្បាង់ភ្នាក់ភ្នៅចត្រា ហានហុងជ្រុងហ្នា កំស្តើងចិចមាស

ប្រាសផ្តៅ ។ ស្រេចហើយអាមាត្យចូលទៅ ក្រាបទូលព្រះថៅ កំ
ជ្រោបព្រះបាទភូបាល ។ ក្សត្រិណោះថៅក្រឹស្នកុមារ ឲ្យតែងគ្នាត់ជារ
មកគួរគំនួរប្រពៃ ។ មានជាឯស្រាប់ស្រេចហើយនៃ ក្សត្រិណក្សត្រជៀស្ន
ជ័យ នូវព្រះរាជមាតា ។ ស្តេចស្តេចទៅដល់សាលា ទើបព្រះមាតា
បង្គាប់ឲ្យអស់ជាឯផង ។ គួរជាយដំណើរខំនឯ ខ្ញុំយាយដើមទង
ព្រះបាទសម្តេចជង្ហ ។ ស្លែងមួយគួរគាលកជា តនំយន្តយាត្រា មក
ជាអាមាត្យក្សត្រថ្ងៃ ។ ព្រះថៅបញ្ជាលជៀស្នជ័យ ស្លែងមួយនោះនៃ
គួរគាលសម្តេចកជា ។ ស្តេចទ្រង់ព្រះសុគន្ធា ជិតអស់អង្គា កំប្រាល
ទន្លាលន្ធិនផ្តៅ ។ ស្លែងមួយគួរគាលព្រះថោ បញ្ជាលឲ្យហៅ ស្តេច
ទៅហើយទ្រង់ក្រោធា ។ ឲ្យអស់ពេជ្ឈឃាតផងវ៉ា នាំព្រះកជា ទៅ
ដល់នាក្នងព្រះត្រៃ ។ ស្លែងមួយគួរគាលក្សត្រថ្ងៃ តនំយន្តមាសមៃ
ហោះទៅដល់ប្រាសាទតន ។ ស្លែងមួយគួរគាលេមហាក្សត្រ នាំនាង
នាថថ្លាត់ ហោះចេញពីហានោះណា ។ ស្លែងមួយគាលកជា កើច
យន្តរេក គាលផ្តាំនៃព្រះជនក ។ ស្លែងមួយគួរគាលភូមី កើចយន្ត
ហោះពី នោះទៅឈប់ក្រោមព្រះថ្លៃ ។ ខាងឆ្នេរស្រែះស្រងំនោះនៃ
ហើយក្សត្រថ្ងៃ ប្រសូត្រព្រះពជបុត្រា ។ ហើយស្តេចជនព្រះតង្គា ស្រង់
ពជបុត្រា ស្រង់តាំងព្រះអគ្គមហេសី ។ ស្លែងមួយគួរគាលភូមី តនំ
យន្តហោះពី កំឡុងព្រះថ្លៃនោះណា ។ ទៅយកភ្លើងពីកេត្រា ស្លែង

មួយគូរដា នាងនាថនូវបុត្រាថ្លៃ ។ នៅរងំក្រោមដើមព្រះជ្រៃ ទាំងឆ្នេរដល
ស័យ តែពីព្រះអង្គឯងហោង ។ នាងឲ្យគូរស្រែចហ្មត់ហ្មង ដោយបទខំ
ខន ដំណើរដំណាលពាដា ។ នាងខតហើយសោយសោក ខ្លួញទៅ
ពាដា ព្រះរៀមព្រះពាដស្វាមី ។ ព្រះពាដបុត្រាសឹងតី- លាបង្ហឹងជនន៍
តាំងពីព្រះអង្គសោក ។ លុះបន្ទូសោកហើយណា នាងវិតងំសោជន៍
អា- ហារដងអនេកពេកក្រៃ ។ ឲ្យដាំនានិត្យប្រពៃ ស្មូមយាចកនៃ
ជាសព្វប្រក្រតីរៀងណា ។ ហើយនាងនាថឲ្យទ្រព្យា នៃយាយមាលា
ឥតខ្វះកន្លះឡើយហោង ។ ហើយឲ្យដាសេដ្ឋីឯង ដាំឆកន្ទួង សែង
អ្នកតាំងឡាយនានា ។ រហើយនាងឲ្យចាំសាលា បើអ្នកឯងណា
ចូលមកយកតាន់ចើនហោង ។ ឲ្យមើលអស់តំនូរឆង ដោយបទខំខន
ដំណើរនៃយាយនេះណា ។ ថាបើមើលហើយសោក ចូរយាយម៉ូម្ចា
រៀបច្រាំបអញកុំសង្ស័យឡើយ ។ នាងភ្លាំយាយមាលាហើយ ក្សត្រាណ
ត្រាណត្រើយ ទូរាជបុត្រាថ្លើមថ្លៃ ។ រីលក្ខាន្តច្រាសាទមាសមៃ ព្រួយ
ព្រះហឫទ័យ អំពាលនូរពោមនស្សា ។ ឯព្រះព្រហ្មទត្តពាដា ស្តេចពុំដឹង
ថា ជនខ័ន្ធឯងបុត្រាឡើយ ។ ស្តេចថាជាតរិយោហើយ ក្សត្រាត្រាណ
ត្រើយ ស្តែងស្តេចសោមនស្សា ។ យើងថ្ងៃឯនាងបពុមា កេសរ
ទត្តមា ចាំនជួបនឹងពាដបុត្រា ។ យើងសែងទុកក្សត្រាវិញណា ហើយរយើង
ចរបា ឯនាយសាំរាមួយរៀន ។ ដៃលរសែងហន្ទយន្តមាសមៃ ចូលមក
ជួញ្ញ នគរពាណាសី ។ ។ ពាដរបេត្តិ(ទៅមាន)ពេញបេ្ញ

គតិបណ្ឌិតរបស់ព្រះបាទ ម៉ាក៌-អូរែល ព្រះអធិរាជរ៉ូម៉ុំង

លោក រ៉ាយ-ភ៊ុក ជាស្រែងរៀបរៀង

១- គេលក្រោកតាំព្រឹក ចូរអ្នកនិយាយនឹងខ្លួនអ្នកថា "អញមុខជាជួបប្រទះនឹងមនុស្សដែលធ្វើឲ្យអញធុញគ្រាន់, មនុស្សអកតញ្ញូ, មនុស្សត្រហឹងកោងកាច, មនុស្សគាលទុច្ចរិត, មនុស្សលោភលន់ពន់ប្រមាណ ដែលអញមិនចូលចិត្ត; បើជួបនឹងមនុស្សមានគុណវិបត្តិដូច្នេះ អញត្រូវគិតថា ព្រោះគ្នាមិនស្គាល់ល្អអាក្រក់" ។

២- គ្រប់តែមោឍ, ចូរអ្នកព្យាយាមធ្វើទូកិច្ចការទាំងឡាយដែលមានក្នុងបច្ចុប្បន្នយ៉ាងម៉ឺងម៉ាត់ ដោយចិត្តស្មោះស្ម័គ្រ ដោយតែកាយនឹងដោយយុត្តិធម៌ ។

៣- អ្នកកុំបំពេញសកម្មភាព ដោយមិនបានគិតជាមុន ។

៤- បើអ្នកធ្វើទូកិច្ចការទាំងឡាយ ប្រកបដោយវិចារណញ្ញាណហើយ មិនបានលទ្ធផលដ៏ប្រសើរទេ ចូរអ្នកកុំស្អប់ខ្ពើម កុំលះបង់ព្យាយាម កុំលែងធ្វើកិច្ចការទាំងនោះទៀយ, បើអ្នកជួលហើយ ត្រូវតែក្រោកដើរទៅទៀត, ចូរអ្នកមានចិត្តតែកាយចុះ បើសកម្មភាពរបស់អ្នកមានសភាពថ្លៃថ្នូរគួរពេញចិត្ត ។

៥- អ្នកអាចរស់នៅបានដោយសុខកាយសប្បាយចិត្ត ព្រោះអ្នកចេះគ្រាច់ទៅតាមផ្លូវល្អហើយ, កិច្ចការទាំងឡាយអ្នកអាចបំពេញបាន

ទៅតាមមាត្រាច្បាប់ដែលគួរធ្វើ ។

៦- ចូរអ្នកយកចិត្តអ្នកទៅពិចារណាគ្នរឹងគ្នាំងឲ្យយ, ចំពោះ
វត្ថុមួយៗ ចូរអ្នកពិចារណាខ្លួនវត្ថុណាសម្បត្តិនឹងតម្លៃនៃវត្ថុនោះៗ ដោយ
មិនត់ចង់ កុំឲ្យភាន់ច្រឡំ ។

៧- ចូរអ្នកលៃលកឲ្យចំនួនស្រួលបួលចំពោះវត្ថុគ្នាំងឲ្យយ ដែល
មានជាប់នឹងសេចក្តីប្រាថ្នា ប្រកបដោយហេតុបច្ច័យគាប់ចិត្ត នឹងជាប់នឹងសេចក្តី
ប្រាថ្នារបស់អ្នក ។

៨- ចូរអ្នកស្រឡាញ់មនុស្ស ដែលស្ថិតនៅជុំវិញអ្នក តែការ
ស្រឡាញ់នោះឲ្យមានសេចក្តីស្មោះត្រង់ជាង ។

៩- ចូរអ្នកទម្លាប់ផ្លូវចិត្តឲ្យកសាងអ្នកជាខ្លួនឯងឲ្យយ ដោយការ
ឆ្លៀតឆ្លង់ ហើយចូរអ្នកតាមពិនិត្យមើលគុណវិបត្តិរបស់អ្នកនិយាយ ។

១០- ចូរអ្នកត្រឡប់មើលខ្លួនអ្នក នេះជាប្រកបល្អ ហើយ
ប្រកបល្អនេះ អាចនឹងចេញពីតែមកបាន បើអ្នកចេះដឹកនាំយ៉ាងខ្លាំង ។

១១- ជីវិតជាការតស៊ូ មិនមែនជារបាំរបែរ ឬយើងត្រូវមានវិចារ-
ណញ្ញាណថា បើគាត់គេចូលមកច្បាំងជាស្តេចមកយើងដោយមិនដឹងខ្លួន
យើងត្រូវត្រៀមឈរតស៊ូនឹងគេដោយមុឺងម៉ាត់ ។

១២- បើអ្នកត្រូវការធ្វើកិច្ចការអ្វី ត្រូវអ្នកគិតគូរ ជ្រៀងជ្រៀតរក
ហេតុផលឲ្យច្រើនឲ្យសព្វគ្រប់ទៅក្នុងកិច្ចការទាំងនោះសិន ។

១៣- បើអ្នកបំបាត់បោលខ្លួនយោបល់បែបនេះ ចំពោះកិច្ចការទាំងឡាយដែលទាំងឱ្យវិនាស អ្នកនឹងបានសេចក្តីសុខជាក់ប្រាកដ ។

១៤- ចូរអ្នកកុំកំហុសរបស់បុគ្គលដទៃតាមកន្ទិះនេះឡើយ ។

១៥- ពិភពលោកមានការចលនាជានិច្ចនោះ ពីសតវត្សមួយទៅសតវត្សមួយ ។

១៦- វត្ថុដែលធម្មជាតិចែកមកឱ្យចំពោះជីវសត្វមួយៗ តែងមានប្រយោជន៍ដល់ជីវសត្វនោះៗ ។

១៧- អ្នកមិនត្រូវបង្អាក់បង្រៀនបុគ្គលដទៃឱ្យអានសៀវភៅ ឬសរសេរ មុនខ្លួនឯងចេះអាន ឬសរសេរឡើយ ។

១៨- មនុស្សដែលកើតមកជាភាសាតែ គ្មានសំឡេងទេ ។

១៩- វត្ថុទាំងឡាយដែលអ្នកមានបំណងចង់បានកន្លងទៅអនាគត បើអ្នកចង់បានកន្លងថ្ងៃនេះ លុះត្រាតែខ្លួនអ្នកជាសត្រូវនឹងខ្លួនឯង ទើបបានសម្រេច ។

២០- ចូរអ្នកមើលដោយមិនសង្កេតវត្ថុទាំងឡាយ ឱ្យឃើញថាមានសភាពយ៉ាងណាខ្លះ ហើយចូរចំបែកដោយបញ្ញាចក្ខុវិតានោះៗតាមរូបលក្ខណៈខ្លួនឯង ទើបវត្ថុចំណងបែរជាឱ្យប្លាស់លាស់ ។

២១- បើចង់ហាមឃាត់មនុស្សកាចកុំឱ្យប្រព្រឹត្តអាក្រក់ អ្នកត្រូវហាមកុំឱ្យដើមជ្រៃមានទឹកនៅកន្លែងផ្លែជ្រៃ កុំឱ្យពាក្យ កុំឱ្យសេះស្រែកជាមុន។

រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

(តមក)

លោក ភិយ-ប៊ុក រៀបរៀង

ថ្ងៃមួយ លោកបានចូលទៅក្នុងព្រះវិហារក្នុងទីក្រុងមួយ បាន ប្រទះព្រះនាងកិស្ហ៊ូមីជិន ជាជព្រះនាងក្មានន ។ ព្រះនាងកិស្ហ៊ូមីជិន នេះ គេបានជារូបស្រីមួយយ៉ាងស្អាត ព្រះហស្តមួយដាក់ដៃក្មេង ព្រះ ហស្តមួយទៀតកាន់គ្រាប់បែក ។ ព្រះនាងជាបិសាច ត្រូវខ្មោចម្ន ក្នុងមួយថ្ងៃស៊ីក្មេនរបស់ខ្លួនមួយ ក្នុងបណ្តាក្មេនចាំង ៩០០ ។ មាន សេចក្តីដំណាលថា ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់បានទេសនាទូន្មានព្រះនាង ឡែនតបានតែការស៊ីក្មេននោះ ដោយទ្រង់ព្រះពរជាន់គ្រាប់បែក មាន សភាពដូចដុំសាច់ឡែបរកោនវិញ ។

ក្រៅពីនេះ លោកម៉ាត់ស៊ូដា មានសេចក្តីពេញចិត្តចំពោះសាវក របស់ព្រះសម្ពុទ្ធមួយព្រះអង្គព្រះនាម ចិនហ្សូ ។

មានសេចក្តីដំណាលថា ព្រះសាវកចិនហ្សូនេះ ជាអ្នកមានពាង កាយពុំសូវសភាព ជាអ្នកមានសំដីច្រើន, ដោយគុណវិបត្តិចាំងនេះ ទ្បានជាតូចសាវកដូចគ្នា ទ្បានបណ្តេញចេញពីគណៈសង្ឃ ។ ព្រោះ ហេតុនោះ ទ្បានជាគេបានរូបរបស់លោកដំកល់ទៅខាងក្រៅបូជនីយដ្ឋាន

តែមុខភ្នាក់ព្រះវិហារ ។ ប៉ុន្តែ ព្រះសោតអង្គនេះ មានគុណវិសេសមួយដែរ គួរឲ្យពេញចិត្តជាខ្លាំងពេក តែលោកអាចធ្វើពេទ្យជាងឲ្យសះស្បើយបាន ។ ពួកជនខ្លះ បានយកកន្ទៃដ៏ឈឺរបស់ខ្លួនទៅដាក់ចុះឡើងលើព្រះរូបនោះ, លុះជម្ងឺរបស់ខ្លួនជាសះស្បើយហើយ អ្នកខ្លះថ្វាយគ្រឿងបូជាដោយដៃមួកចំពាក់ ខ្លះយកកំណាត់ព្រៃ ធ្វើជាលំអព្រះស្ពាន់ ។ ព្រោះហេតុនោះ ទៅខាងភ្នាក់ព្រះវិហារ, ព្រះរូបចិនហ្នឹងតែងមានវត្ថុផ្សេងៗ ជាគ្រឿងបូជា ដោយគ្រួសារទីមួយៗ យកមកតាក់តែងលំអគួរឲ្យសើច តែគួរឲ្យមានសមាធិចិត្តចំពោះគុណវិសេសនៃព្រះរូបនោះដែរ ។

លោកម៉ាត់ស៊ីជា លោកមិនចាន់តោរពបូជា ព្រះចិនហ្នឹងនេះទេ លោកតែងតែគោរពកាន់តាមព្រះដ៏ហ្នឹងវិញ ។

ព្រះដ៏ហ្នឹងជាមិត្តរបស់កូនក្មេង ជួយជកក្មេងដែលឈឺ ។ កាលណាមានកេរ្តិ៍ទៅក្នុងផ្ទះម្នាក់ឯង, ព្រះដ៏ហ្នឹងតែងមកលួងលោមបង្គាស់ក្មេងនោះ ។ ម្យ៉ាងទៀត ព្រះដ៏ហ្នឹងជាអ្នកជួយបំពេញកិច្ចចំពោះក្មេងដែលខ្ចួលមរភាព, កាលបើមានចិត្តក្មេងនោះត្រួយចិត្ត ដោយកូនខ្លួនខ្ចួលមរណភាពដូច្នោះ ហើយចុះបង់ចោលការងារចាំផឹងឡាយ ចេះតែទៅយំកន្ទក់កន្ទេញនៅក្បែរផ្នូរនោះ ។ ព្រះអាចារ្យពេទ្យដ៏ជាក់ខ្លាំងក្នុងចំពោះកូននោះ តម្រូវឲ្យដញ្ជូនដុំថ្ម មកតម្កល់នៅក្បែរមាត់ខ្នើមួយ

នៃស្ថានទេវតា ។ ព្រះឯដ៏ហ្មត់នេះ ទៅដួយជញ្ជូនដុំថ្មក្រួនដោយសេចក្តីអន្ទះគ្រោះ ។ ដូច្នោះ មាតាចិការបស់ក្មួនខ្ញុំលួមរណភាព, ដើម្បីនឹងបន្ទោបន្ថយសេចក្តីសោកស្តាយរបស់ខ្លួន ក៏ជញ្ជូនដុំថ្មយកមកជង់ចំពោះព្រះកន្ត្រក្រព្រះដ៏ហ្មត់ ជាគ្រឿងតបស្នង ។

លោកម៉ាត់ស៊ុដា លោកមានចិត្តពោរពេញ ហើយលោកពេញចិត្តក្នុងការគោរពកាន់តាមព្រះដ៏ហ្មត់នេះបំផុត ។

រីឯព្រះដ៏ហ្មត់នេះ មានទ្រង់ទ្រាយជាព្រះសង្ឃ ព្រះកេសកោរលើង ព្រះកន្ត្រញញឹម ព្រះហស្តម្ខាងកាន់គ្រឿងអលង្ការ ព្រះហស្តម្ខាងទៀតកាន់ដំបង ។

ថ្ងៃមួយ លោកបានអញ្ជើញទៅកាន់ទីក្រុងមួយ ដើម្បីទិញរូបព្រះដ៏ហ្មត់ធ្វើពីថ្ម លុះចូលទៅដល់ទីក្រុង ក៏ចូលទៅកាន់ផ្ទះតាណិជម្នាក់ដែលលក់រូបចម្លាក់ឈ្មោះ តាកីហ្សាក់ ហើយឲ្យតាណិជនោះធ្វើរូបព្រះដ៏ហ្មត់ចំនួន ៦ អង្គ ។ នាយតាណិជបានធ្វើកិច្ចសន្យាជាមួយលោកម៉ាត់ស៊ុដាថា នឹងបាត់ឲ្យជាឯចម្លាក់ម្នាក់ធ្វើរូបព្រះដ៏ហ្មត់ ៦អង្គនោះ ឲ្យបានកន្លះឆ្នាំ ៦ ខែ ។

មុននឹងយកហ៊ាបទៅដាក់រូបព្រះដ៏ហ្មត់នោះមួយថ្ងៃ, លោកម៉ាត់ស៊ុដាមានចំណិតចិត្តឃើញរូបនោះយ៉ាងក្រៃលែង លោកក៏អញ្ជើញទៅកាន់ផ្ទះលោកតាកីហ្សាក់ ។ ខណៈនោះ លោកតាកីហ្សាក់

មិនទាន់យកព្រះជីហ្វូភាំង ៦ នោះមកដល់ផ្ទះនៅឡើយទេ លោក
មានចិត្តព្រួយកមិនចង់ដាក់បង្ហាញសេចក្តីពិតទៅលោកម៉ាត់ស៊ុជាសោះ ដោយ
ហេតុយល់ថា ក្រែងលោកម៉ាត់ស៊ុជាអាក់អន់ចិត្ត ព្រោះលោកអញ្ជើញ
មកតាំងត្រឡាយបំណងយើញព្រះជីហ្វូភាំង ៦ នោះណាប់ ។ លោក
តាកីហ្វូកំពុងតែរកគ្រប់ជាមួយនឹងរកមធ្យោបាយផ្សេងៗ សម្រួលដល់
ព្រះនេះ ឲ្យបានសម្រេចដូចបំណង, ក្នុងមួយរំពេចនោះ ចិញ្ចើម
លោកញាក់ត្រើតៗ លោកគំនិចញញឹមដោយយល់ថា ក្បែរបង់
លោកម៉ាត់ស៊ុជាឯងនឹងមើលមិនស្រួលភ្លាស់ ។ ម្យ៉ាងទៀតលោកតាកីហ្វូកំ
មានមិត្តម្នាក់ ឈ្មោះមនុស្សដំបូយតាខាក់ លោកកំបង្គាប់មនុស្សភាំង ៣
នេះឲ្យក្លែងខ្លួនធ្វើជារូបព្រះជីហ្វូ តាំយកស្បង់ចំពាក់លោកសង្ឃមកគ្រងឲ្យ
ដៃម្ខាងកាន់គ្រឿងអលង្ការ ដៃម្ខាងទៀតកាន់ដំបង ហើយបង្គាប់
អ្នកទាំង ៣ ថា បើគាលណាលោកម៉ាត់ស៊ុជាអញ្ជើញមកមើល ត្រូវ
កុំសើច កុំកំរើកដៃជើងឲ្យសោះ ។ លោកតាកីហ្វូកំ លុះរៀប
ចំយ៉ាងនេះរួចហើយ ក៏និយាយទៅលោកម៉ាត់ស៊ុជាថា ខ្ញុំទើបភ្លាញខ្លួ
រូបព្រះជីហ្វូ ៣ ព្រះអង្គសិន រួចហើយខ្លួនឯងក៏តែ តទៅយើង
ទើមើលត្រូវរូបព្រះជីហ្វូ ៣ ទៀត ដែលទៅបន្ទប់ផ្សេងគ្នា ។

លោកតាកីហ្វូកំ ក៏នាំលោកម៉ាត់ស៊ុជាទៅទស្សនារូបព្រះជីហ្វូ
ដែលដំកល់ទៅក្នុងបន្ទប់ដែរនោះ ។ ចំពោះព្រះរូបមួយៗ លោកបាន

ខ្ញុំនឹងសាលនោះពេយាំងស្មោះចំពោះ ហើយសូត្រធម៌ផង លោកពិនិត្យ
ដោយការហ្មត់ចត់ណាស់ ឃើញថាសាសនាយាំងរក្សាលទ្ធចំពោះ
រូបព្រះដ៏ហ្មឺងឯ ។ ល ។ ល ។

ដោយហេតុនៃលោកមានសេចក្តីពេញចិត្ត ចំពោះរូបព្រះដ៏ហ្មឺ
នោះពន់ពេក ទើបលោកមិនមានអាល្ហឺញឮទៅកាន់គេហដ្ឋានវិញទេ . . .
រតីលោករងាំចាំអ្នកខ្មៅ . . . . គ្រានោះ លោកម៉ាត់ស៊ុដា ក៏
ពោលទៅកាន់លោកតាកីហ្សាក់ថា ខ្ញុំចង់ឃើញរូបព្រះដ៏ហ្មឺឯង្រ្គាំមួយ
ជាមួយគ្នាបានឬទេ ? ដើម្បីនឹងប្រៀបធៀបគ្នា ។

បានជាលោកម៉ាត់ស៊ុដា ចង់ឃើញរូបព្រះដ៏ហ្មឺក្នុងគេលជាមួយ
គ្នាដូច្នោះ មកពីលោកសង្កេតឃើញព្រះដ៏ហ្មឺមួយនោះញញឹម . . .
ខ្លាំងព្រះដ៏ហ្មឺមួយទៀត បានបញ្ចេញសំណើចក្អួរស្រាល មិនស្ងៀ
ច្បាស់ . . . . ។

ឯនាយភាណាជតិះដៀលក្បាល ហើយនិយាយទៅកាន់លោកម៉ាត់-
ស៊ុដាថា បន្ទប់ផ្ទះរបស់ខ្ញុំតូចពេក មិនអាចនឹងនាំយករូបព្រះដ៏ហ្មឺ
ទាំង ៦ ជាក់ឱ្យសណ្ឋិតជាជួរជាមួយគ្នាបាន , ដូច្នោះ ខ្ញុំនឹងនាំ
លោកទៅទស្សនាក្នុងបន្ទប់មួយទៀត ដែលមានព្រះដ៏ហ្មឺ ៣ អង្គទៅ
ក្នុងនោះ ។

លោកម៉ាត់ស៊ុដាយល់ព្រម ក៏អញ្ជើញចូលទៅក្នុងបន្ទប់មួយទៀត,

តែមានសត្វស្លាបមួយមែក ដែលនាំឲ្យលោកបែរមុខត្រឡប់ទៅក្រោយ
មួយរំពេចនោះ" តើលោកបានឃើញអ្វី ? . . . ។

ព្រះរូបជីហ្វូដែលតាំងជាជួរនៅកន្លែងមុនមុនោះ បានរត់ចេញ
ដោយធាប់ហ័សតិចតួចផង . . . ។

លោកម៉ាត់ស៊ូជា ពិតមែនតែលោកមានក្អែកឆ្លាតមើលមិនស្រួល
ច្បាស់ ប៉ុន្តែ លោកសំគាល់ប្រហាក់ប្រហែលថា ដូចជាព្រះរូបនោះ
ចេះដើរទៅ . . . ឬជាសភាពពិតមែន ឬយ៉ាងណាមិនមានច្បាស់
ច្បាសផង . . . ។

កន្លងពេលដែលគំនិតលោកម៉ាត់ស៊ូជាកំពុងរំជួលខ្វាំងនោះ
លោកបានដើរត្រឡប់ទៅក្រោយ , ស្រាប់តែព្រះជីហ្វូ ១ អង្គរត់មកប៉ះ
កែងជើងលោក តែមិនមែនព្រះរូបទេ ជាមនុស្សមានសាច់ឈាម
ទ្រង់ត្រាយជាមនុស្សជាតិពិត ។ ។ លោកម៉ាត់ស៊ូជា កំរលប់ច្បាស់
ដោយបញ្ជាចក្ខុថា តាណាជនាតីហ្វូកំពុងបង្ហោនលោកពិតច្បាស
ណាស់ ចិត្តរបស់លោកក្តៅក្រហាយជាខ្លាំង ដោយលោកគិតឃើញ
ថា មិនសមបើលោកនាគីហ្វូក៏ ហ៊ានបោកបាញ្ឆោតមនុស្សស្មូតត្រង់
មិនកោតញ៉ែតសោះ សំគាល់ឯងជាមនុស្សមានក្អែកខ្វាក់ ឥតមាន
សត្វជ្រះថ្លាកន្លងព្រះពុទ្ធសាសនា ។

ប៉ុន្តែ លោកម៉ាត់ស៊ូជា ចប់កំហឹងនោះបាន ដោយលោកនឹក

ដល់ព្រះពុទ្ធាវាទថា «ត្រូវបំបាត់សេចក្តីក្រោធ ដោយមិនក្រោធ» ។

លោកម៉ាត់ស៊ុជា តំអត់ទោសឲ្យលោកតាកហ្វាភ៉ាំក្នុងពេលនោះ ។

ចប់រឿងព្រះដីហ្សូតាំង ៦ ។

៣-រឿងបិសាចលោភសង្ឃ

ឆមោ អមិតា ប៊ុតស្ស! ឆមោ អមិតា ប៊ុតស្ស! ខ្ញុំសូមគោរពព្រះសម្មាសម្ពុទ្ធជាម្ចាស់! ។

មានសេចក្តីដំណាលថា មានលោកសង្ឃមួយអង្គ សូត្រធម៌តាមប្រពៃណីឈរភៅមុខគោដន៏ឃង្គាន ១ ដងតំក្រុងណាគូយ៉ា ។ លោកបានឈប់នៅទីនោះ ដើម្បីនឹងសូមចង្ហាន់បិណ្ឌបាត ។ តែគ្មានអ្នកណាម្នាក់អើពើនឹងព្រះសង្ឃនេះសោះឡើយ ។ លោកបានរង់ចាំដោយសេចក្តីស្ងប់ស្ងៀម គ្មានកំរើកព្រះអង្គសោះ ។

លោកសង្ឃនេះ ពន្លឺចស្តើង ព្រះកេសាក៏រ ព្រះភក្ត្រពណ៌លឿងស្គមហើយញាញឹម ព្រះទ័យពេញភៅដោយឥច្ឆាសន្តុដ្ឋ ចំពោះព្រះពុទ្ធសាសនាយ៉ាងក្រៃលែង ។

នៅជិតលោក, មានបុរសអនាថាម្នាក់ដែលជាមនុស្សឥតទីពំនាក់តែងគ្រាច់ភៅតាមនិគមជនបទ ក្នុងប្រទេសជុំនាំងមួល ។ បុរសនេះមានមាឌធំ ស្គម សាច់លឿង សែ្បកជ្រួញជ្រីវ ។ តែបើសង្កេតមើលបុរសនេះដោយជាក់ច្បាស់ភៅ មិនមែនជាមនុស្សក្នុងសាធារណកម្មជ្ឈន្តរទេ ។

ហេតុដែលធ្វើឲ្យបុរសមានលក្ខណៈយ៉ាងនេះ មកពីការលំបាកតោក យ៉ាកអត់ឃ្លានេះឯងជាដើមហេតុ ដែលបានបាចនាពុកស្នាមលើថ្ងាសមុខ មាត់តាត់ ។ បុរសអនាថានេះ មកកាន់កោដនីយដ្ឋានដើម្បីសុំភាហារបរិភោគ ។ ដល់មិនឃើញអ្នកណាមកសួរ, បុរសនេះក៏លះដៃខ្លួនដើម្បីស្រែកហៅនាងទាសីម្នាក់ដែលឈរនៅទីនោះ ។ ទាសីនោះ ក៏ដើរចូលមក តែនាងមានសេចក្តីញាក់ញ៉ីតញាញើម ព្រោះមិនដឹងជាចំពោះអ្នកណា ចំពោះលោកសង្ឃ ឬគ្រហស្ថ ។

ឯលោកសង្ឃនោះ មានពុទ្ធដីកាថា ចូរនាងចំពោះបុរសនេះ ដែលជាមេរោគចុះ ព្រោះគាត់អញ្ជើញមកកាន់ទីនេះមុនគាត្មា ប្រហែលជាគាត់ប្រញាប់ទៅកាន់ទីដទៃទៀត ។

បុរសនោះតបទៅវិញថា ទេ ! ចូរនាងចំពោះព្រះសង្ឃមុនខ្ញុំចុះ ព្រោះព្រះសង្ឃជាបុរសតិសិដ្ឋគួរគោរពបូជា តាំងជាបុគ្គលមានកិត្តិយស ។

អ្នកទាំងពីរពោលធ្វើយឆ្លងគ្នាទៅវិញទៅមកដោយពាក្យកាត ។

បុរសក៏ពិតពុទ្ធដីកាព្រះសង្ឃថា ខ្លួនឈ្មោះ តាជិមាស៊ូម (Tajima Shume) ។

ចំណែកនាងទាសី ក៏ចាត់ចែងយកបាយសាយទៅដោយទំពាំងនឹងក្រវ៉ាល់ មកប្រគេនព្រះសង្ឃនាន់នឹងជូនបុរសតិសាំ ។ អ្នកទាំងពីរកើសាកសួរគ្នាទៅវិញទៅមក ទើបដឹងថា ចំណងនៃមន្តនឹងដើរទៅកាន់ក្រុង

គីយ៉ូតូ (Kyôto) តាមផ្លូវមានតំបន់សម្បូរខ្ទាងកើត, គេឲ្យឈ្មោះទីក្រុងនេះ ថា តូកៃដូ ។

លោកសង្ឃនីនិងបុរស ក៏ចេះតែត្រាច់ទៅជាមួយគ្នា, ទៅ៩៣ រយៈផ្លូវទៀតទើបដល់ទីក្រុងគីយ៉ូតូ ។

អ្នកទាំងពីរគ្មានវត្ថុអ្វីច្រើនទៅជាមួយទេ, បុរសមានតែជាវសាម៉ូរៃ ២, ឯលោកសង្ឃមានកាន់កញ្ចប់តូចមួយប៉ុន្តែឯកូនកន្ទែងពណ៌លឿង ។

លោកសង្ឃនិមន្តបណ្តើរដៃគជាមួយបុរសនោះបណ្តើរ លោកមានពុទ្ធដីកាអំពីសព្វនីយភាពនៃសត្វលោកទាំងមូល, ឯតាជម៉ាស្អុម បានតណ្ហាអំពីជីវភាព ហើយចេះនិយាយពីរឿងនេះរឿងនោះយ៉ាងក្បោះក្បាយគួរឲ្យចង់ស្តាប់តន់ពេក ។ នៅតាមផ្លូវ, មានទេសភាពគួរឲ្យពិតពិលមើលមើលគឺ: មានព្រះសង្ឃនិមន្តតាមថ្នល់ គ្រហស្ថត្រាច់តាមក្រោយ, មានពួកជូជនីយេសក៍ ដើរត្រួសឯទៅកាន់ព្រះវិហារ ដែលឋិតនៅទីក្រុងតូកៃដូ, មានអ្នករបៀង, អ្នកថ្នឹងរឿងត្រង់ ស្ទូមយោបកជារច្រើន ត្រាច់ទៅមកមិនដាច់ . - ។ ហួសពីនេះបន្តិចទៅ ឃើញពួកព្រះអ្នកម្ចាស់ ភាសាជប៉ុនហៅថា ដៃម៉ីយ៉ូ (Daimyô) ជ្រុំព្រះតស្តែព្រះភូសាជាកិត្តិយស តន់លើព្រះខ័ន្ធាន អស្សតរ ឬរាមស, មានពួកយោធាសាម៉ូរៃដើរអមសងខាង ។ កាលបើព្រះអង្គម្ចាស់ស្តេចយាងទៅដល់ទីណា, ទីនោះ តែងមានពួកពលរដ្ឋធ្វើតាវ៉ៃក្តួ. តែនក្បាល

ខ្ពង់ខ្ពស់ ។ តាំងនេះមានភ្នាក់កំពុងដើរទេស្សនាទូទៅឯណេះ។ ទីដែលពួក
ជាដែនទូកំពុងគួរប្រកាសជាច្រើន ។

(សត្វថ្មៃ ថ្នល់ពីរជាន់តូចក្បែរជាន់ទីក្រុងតែយ៉ាងតូច ចម្ងាយប្រាំរយ
តែឡូម៉ែត្រ មានក្រាលថ្ម ចាក់កៅស៊ូ ដាំដើមស្រល់ ទីដើមសែដ្រ
(Cèdres) តាមមាត់ថ្នល់ . .) ។

ថ្ងៃមួយតមក លោកតាជំទាវ ក៏ផ្តើមនិទានរឿងដ៏កាតព័អតីត
កាលបេះដូងតិតពុទ្ធដីកាចំពោះព្រះសង្ឃនោះ ។ ឯព្រះសង្ឃតបាន
ដឹងថា សកម្មភាពដែលបុរសមោះបំពេញក្នុងការធ្វើសង្គ្រាម ឬសម្លាប់
មនុស្សទេ ។ ប៉ុន្តែ លោកតែងមានពុទ្ធដីកាថា យើងមិនត្រូវប្រហារ
ជីវិតសត្វដទៃឬធ្វើទារុណកម្មចំពោះមនុស្សជាតិទេ បុគ្គលទីមួយ។ រមែង
ប្រព្រឹត្តទៅតាមជោគវាសនាសត្វ ។ ខ្លួន ក្រោយដែលខ្លួនធ្វើមរណភាព
បុគ្គលខ្លះ កំត្រឡប់មកចាប់ជាតិជាសត្វតិរច្ឆាន ខ្លះទៀតជាមនុស្ស
បុគ្គលទីមួយ ។ ត្រូវកើតស្លាប់ ។ រៀរល់ទៅក្នុងវដ្តសង្សារជាច្រើនជាតិ
បើគេត្បាយមកសាងខ្លួនទៅក្នុងអំពើជាកុសល គេនឹងទៅតបួលទៅជិត
ព្រះនិព្វានដែលជាទីរំលត់បង់នូវសង្សារវដ្ត, កាលបើដូច្នេះសត្វលោក
ទាំងអស់ រមែងបួលទៅកាន់ព្រះនិព្វានជួបជាព្រះសម្មាសម្ពុទ្ធដូច្នោះ ។
ព្រះសង្ឃនេះ មានពុទ្ធដីកាបណ្តើរ សូត្រធម៌បណ្តើរថា ឧមោ
អមិតា ម៉ិតស៊ី! ឧមោ អមិតា ម៉ិតស៊ី! ហើយលោក

ចាន់បញ្ចេញនូវសេចក្តីសង្វឹមរបស់លោក ចំពោះអនាគតនៃព្រះពុទ្ធសាសនាឲ្យតាជាម៉ាស្លុមស្តាប់ ព្រោះលោកជឿថា បុរសតាជាម៉ាស្លុមមានសន្ធានចិត្តស្លូតបូតគួរសម មិនដែលពោលវាចាផ្តួយនឹងលោកឡើយ ។

ការដែលជួបគ្នាកន្លះម៉ោ ២-៣ ថ្ងៃ ប៉ុណ្ណោះ ធ្វើឲ្យអ្នកទាំងពីរទៅជាមិត្តភក្តីនឹងគ្នាយ៉ាងជិតស្និទ្ធ មិនមានការលាក់កំបាំងអ្វីនឹងគ្នាឡើយ ។

ចំណែកព្រះសង្ឃលោកមានពុទ្ធដីកាដោយព្រះទ័យស្មោះត្រង់ថា លោកជ្រះបាទ ! តើក្នុងកញ្ចប់ដែលអាត្មាកាន់នោះមានអ្វី ? ។

បុរសនោះ ពោលតបថា ខ្ញុំព្រះករុណាមិនដឹងទេ, ហើយបុរសនេះ ត្រឡប់សួរព្រះសង្ឃវិញថា របស់មានសារៈសំខាន់ឬ ? ។

ព្រះសង្ឃមានពុទ្ធដីកាថា កញ្ចប់នេះ មានសារៈសំខាន់ណាស់ ។

បុរសតិតពុទ្ធដីកាថា ប្រហែលជាវ៉ែ្លផ្កាំ ដែលលោកម្ចាស់ជួនខ្ចប់ នៅពេលដែលទិមន្តទៅតាន់ថ្ងូជនីយដ្ឋានទេដឹង ! ។

– មិនមែន !

– ប្រហែលជាសៀវភៅដែលមានពុទ្ធភាសិតយ៉ាងពីពោះផ្លែម្លូសំកង់មានពុទ្ធដីកាទៅកាន់មនុស្សខ្លួនទៅឬ ? ។

– មិនមែនសោះឡើយ ។

បុរសនេះ តែងតែតមមែកនឹងចិត្តថា ប្រហែលជាព្រះចង្ក្រានកែវ

ព្រះសង្ឃសម្ពុទ្ធខេដ្ឋ ! តែបុរសនោះមិនហ៊ានសួរ បិតនៅស្ងៀមស្ងាត់ឥតឆ្លើយអ្វីតទៅទៀត ។

ចំណែកព្រះសង្ឃនោះ ក៏ឆ្លើយបន្តមទៀតថា នៅក្នុងកញ្ចប់នេះមានប្រាក់ ២០០ ដុល្លឹង ។

បុរសនោះ ស៊ើចយ៉ាងខ្លាំង ហើយក៏ឆ្លើយថា ព្រះតេជព្រះគុណមានព្រះពុទ្ធដីកាលេងខេដ្ឋ , បើព្រះតេជព្រះគុណ មានប្រាក់ដល់ចំនួនប៉ុណ្ណោះ មិនមែនត្រាប់តែគ្នាត់តាមផ្លូវដូច្នេះ ប្រាកដជាត្រូវចំពីរល្អជាងនេះ ហើយមិនមែនទៅសងតាមគោជនាគារ ដំរាំតែឡើយដូច្នេះទេ ប្រហែលជាហៅខ្ញុំព្រះករុណាទៅបរិភោគអាហារនៅគោជនាគារដើរតែឯងពុំខាន ។

ព្រះសង្ឃក៏ឆ្លើយតបទៅវិញទៅមកទៀតថា : ទេ ! អាត្មាមិនឱនិយាយលេងទេ អាត្មាមានប្រាក់ ២០០ ដុល្លឹងពិតមែន , តែប្រាក់នេះ មិនមែនសម្រាប់យកមកបាយក៏យជាប្រយោជន៍ផ្ទាល់ខ្លួនអាត្មាទេ, បើលោកចង់ដឹងការស្ងាត់កំបាំងរបស់អាត្មា, គួរលោកចាំស្តាប់ អាត្មានឹងពណ៌នាអំពីរឿងនេះ ៖

ថ្ងៃមួយ អាត្មាបានដើរទៅតាន់ក្រុង អូម៉ូរ៉ា ហើយចូលទៅក្នុងព្រះវិហារឈ្មោះអ៊ីតាម៉ូ ប្រហែលជាលោកធ្លាប់ស្គាល់ទីនោះដែរ ។ បុរសនោះ ក៏បង្ហាញកាយវិការជាសញ្ញាថា ខ្លួនធ្លាប់ស្គាល់ដែរ ។ ពេល

នោះ ជាពេលដែលមានធម្មជាតិចាំងភ្លាយស្រស់បំព្រង គឺមានមេឃ
ស្រឡះ ស្មឹក-ផ្កាឈើស្រស់ល្អ ។ ក្នុងពេលមួយរំពេចនោះ នៅឱ
ព្រះវិហារអឹតគាម៉ុ គេបានឮយួជួនប្រមូលភិក្ខុសង្ឃនឹងគ្រហស្ថឱ្យចូល
ទៅក្នុងព្រះវិហារ ដើម្បីធ្វើសមាធិនិងសូត្រធម៌, ពេលនោះ អាត្មាក៏
បានចូលទៅដែរ ស្រាប់តែមានបរិតសោមនស្សកើតឡើងក្នុងចិត្តរបស់
អាត្មាចំពោះព្រះសម្ងាសម្ពុទ្ធ ហើយបានប្តេជ្ញាក្នុងចិត្តថា « ក្នុងមួយជាតិ
នេះនឹងព្យាយាមកសាងព្រះពុទ្ធរូប ១ ព្រះអង្គធ្វើពីសំរិទ្ធិយ៉ាំងល្អថ្លែក” ,
បន្ទាប់ពីនោះមក អាត្មាក៏ចំណេរយោសនាបច្ចយគ្រប់គ្រាន់ នៃត្រ ស្រុក
ក្នុងប្រទេសជុំនេះ, ពេលនេះ អាត្មាប្រុងទៅកាន់គ្រឹងតាយ៉ូតូ រក
ជាងចម្លាក់ម្នាក់ ដើម្បីសម្រេចវត្ថុបំណងរបស់អាត្មា ។

ពេលនោះ ព្រះនេត្រដ៏តូចនៃព្រះសង្ឃនោះ កំបញ្ចេញនូវអាការៈ
ជាសញ្ញាឱ្យដឹងថា លោកមានព្រះទ័យជាប់ស្និតចំពោះការចេតាព្រះពុទ្ធរូប
នោះ ហើយព្រះសង្ឃនេះ កំមានពុទ្ធដីកាទៅតាមសេចក្តីបំណងថា :

ព្រះពុទ្ធរូបនោះត្រូវចេតាដូច្នេះតឹ ទ្រង់តង់លើថ្ងាឈូក ព្រះបាទ
ទ្រង់ព្រះភ្នែន ព្រះហស្តស្តាំទ្រង់លើកឡើងស្ទើនឹងព្រះអង្សា (ស្មា)
ឯបាតព្រះហស្តប្រែចេញក្រៅ ដើម្បីជូនពរសត្តសាធុការចំពោះសត្វលោក
ទូទៅ, នៅព្រះនលាដ (ថ្ងាស) មានគំនូរជាសញ្ញានៃតតិយលក្ខិត ព្រះ
កេសាទ្រង់ញញឹមស្រស់ស្រាយ ។ បន្ទាប់ពីនេះ ព្រះសង្ឃនោះបាន

គោលជាតាក្យសុភាសិតមួយ ដើម្បីឲ្យបុរសនោះស្តាប់ថា: «មនុស្ស ដែលមានតេនៈសម្បត្តិជាប់ខ្ជិលតែងមានគ្រោះថ្នាក់" តែអាត្មាអាត្ម លោកនៅដឹងនេះទើបអាត្មាពុំមានព្រួយបារម្ភ ។

ចំណែកបុរសនោះ កំពុងក្បាលសំដែងសេចក្តីគោរព, ប៉ុន្តែ អាកប្បកិរិយារបស់បុរសនេះ មិនសមរៀតាមអធ្យាស្រ័យរបស់ព្រះសង្ឃ នោះសោះ, ក្នុងមួយរំពេច ស្រាប់តែបុរសនោះ ដើរឃ្លាតឆ្ងាយពី ព្រះសង្ឃ មានចិត្តរំជួលយ៉ាងខ្លាំង ហើយដើរចុះ-ឡើងដោយវែង មុខជ្រួញខ្លាំង មានឆ្នត់ពីរជ្រួញពាក់កណ្តាលថ្ងាស ហើយគិតក្នុងចិត្តថា:

អញបានយកដីវិតរៀបប្តូនឯងហ្វាយនាយ ច្រើនលើកច្រើនសា ណាស់ហើយ សូម្បីតែជនមានគាយទុតូលកាតក៏អញជួយដែរ តែអញ មិនដែលមានប្រាក់សូម្បី ១ កាត ១០ នៃព្រះសង្ឃនេះសោះឡើយ, ឥឡូវអញកំពុងជាប់ចុះក្នុងភ្លើងភ្លក់ភ្លើង លំបាកសែនលំបាក អញចាស់ អាយុជិត ៤០ ឆ្នាំហើយ ។

តាមទំនៀមទម្លាប់នៃប្រទេសជប៉ុនថា: មនុស្សដែលមានអាយុ ៤០ ឆ្នាំ ឈ្មោះថា ចូលកន្លងដកាគ, គឺកន្លងវ័យនេះឯងដែលជនជាតិជប៉ុន ត្រូវលះបង់ការងារគ្រប់យ៉ាង ដើម្បីស្វែងរកធម៌ ការសាជប៉ុនហៅថា អិនតីយ៉ូ (Inkyo) ។

បុរសនោះឮត្រូញត្រែជាខ្លាំង ហើយគោលចំពោះខ្លួនឯងថា អញ

គ្មានថៅហ្វាយនាយទេ អញមិនអាចមានភ័ព្វសំណាងរកថៅហ្វាយនាយ
ថ្មីបានទៀតឡើយ, ប្រាក់ដែលព្រះសង្ឃនេះកាន់នៅព្រះហស្តលោក.
មួយចំណែក អាចឲ្យគុណូបការៈដ៏ធំធេងក្រៃលែង តែព្រះសង្ឃនេះ
មិនអាចឲ្យប្រាក់នេះមកអញទេ ។ គ្រានោះ សេចក្តីលោភលន់
ទាំបណ្តាលឲ្យឈាមក្នុងបេះដូងបុរសនោះកកស្អុកជាខ្លាំង, ដួងគាល
បុរសនោះចង់ឲ្យព្រះសង្ឃមានគ្រោះថ្នាក់ដល់អនិច្ចធម្ម ឬក្មេងខុសប្រាក់
នេះនៅតាំនឹងណាមួយ ខ្លួនឯងបានប្រាក់នោះ រត់ទៅទីឆ្ងាយជាន់ទៅ,
ដួងគាលបុរសនោះ មានចិត្តជាបអកុសលចូលមកលុកលុយកាន់តែខ្លាំង
ឡើង ប្រាថ្នាចង់ជាន់ប្រាក់ភ្លាម ។ ក៏គិតក្នុងចិត្តថា មិនជាអ្វីទេ!...
ចិត្តរបស់មនុស្សតែងមានកុសល ទំនងអកុសលផ្ទាស់វេនគ្នាទៅវិញទៅមក
យើងត្រូវតែឆ្លៀតឱកាសនេះ ដើម្បីកុំឲ្យចិត្តជាបកើតឡើងបាន ។

លោភតាជាមាស្លូវ ប្រឹងតស៊ូនឹងចិត្តជាបយ៉ាងអស់ទំហឹង, បន្តិច
មកចិត្តជាបនេះ ខំសង្កត់លើចិត្តបុណ្យ បុរសនេះខំរកមធ្យោបាយ
ដើម្បីនឹងលួចប្រាក់ព្រះសង្ឃនោះ មិនឲ្យលោកដឹង ឬជាច់ភ័ស្តុតាងបាន,
តែបុរសនេះ, នៅតែសំដែងអាកប្បកិរិយាស្និទ្ធស្នាលចំពោះព្រះសង្ឃ
ដដែរ ។

ឯព្រះសង្ឃមិនបានឃើញសេចក្តីប្រែចិត្តនៃបុរសនោះសោះ លោក
ក៏មិនអាចមានសេចក្តីសង្ស័យចំពោះបុរសនោះ ដែលខុសជាកល្យាណមិត្ត

វេលាលោក ។

ឯព្រះសង្ឃទាំងពីរនោះក៏ចាន់ទៅដល់ទីក្រុងកុមារណា ។ នៅទីនោះ មានដំណាក់មួយ ដែលត្រូវនឹងពួកបើកក្តោងទើបទៅដល់ត្រើយម្ខាង, ឯអ្នកចម្ងាំលុះរៀបចំមនុស្សបានចំនួន ៣០ នាក់ហើយ ក៏ចេញពួកទៅ។

លុះព្រះសង្ឃនេះ ឡើងគង់លើពួកហើយ លោកភ្ញាត់ព្រះចាន់ទៀបនឹងភ្ជាក់ទៅក្នុងទឹក តែមិនមានគ្រោះថ្នាក់អ្វីទេ ។ ពេលនោះ បុរសក៏ទឹកឃើញនូវមេធ្យាចាយមួយ ដែលទឹងធ្វើឲ្យព្រះសង្ឃនោះភ្ជាក់ទៅក្នុងទឹក ។

ព្រះសង្ឃទាំងបុរសនោះ បិតនៅកន្លែងឆ្ងាយពីអ្នកឯទៀត កញ្ជប់ប្រាក់នៅកណ្តាល ។ បុរសនោះបង្ហាញលោកសង្ឃនូវត្រីមួយមានពណ៌ក្រហមកំពុងលែលទឹកជិតពួក ។ ឯព្រះសង្ឃក៏ទូន្មានព្រះកេសាមើលត្រីក្នុងទឹក ។

ខណៈនោះ បុរសក៏ច្រានព្រះសង្ឃឲ្យភ្ជាក់ទៅក្នុងទឹកទៅ ។ រួចហើយរន៏ចាំមួយស្របក់ ក៏ស្រែកយ៉ាងខ្លាំងថា សូមឈប់ពួកសិន ព្រះសង្ឃដែលនិមន្តមកជាមួយខ្ញុំលោកភ្ជាក់ទៅក្នុងទឹកទៅហើយ ។

តែកន្លងគេលនោះមានវាយោបក់ចោកមកខ្លាំងបំផុតខ្លាំងក្តៅងពួក, ធ្វើពួកនោះឲ្យអណ្តែលឿនទៅឆ្ងាយ, ព្រះសង្ឃនោះក៏លិចលង់កណ្តាលសមុទ្រនោះទៅ ។ (នៅមានត)

រឿងស្រីគ្រប់ល័ក្ខណ៍

(តទៅ)

លោក ឃុក-វិធីរ រៀបរៀង លោក ផេង-គ្រីវ កែតម្រា

សិរីវឌ្ឍន៍ញញឹម។ ហើយធ្វើយទៅខ្លួនដោយគោរពថា:

- ចាស! សូមអរគុណច្រើន សំឡាញ់!

នៅថ្ងៃដែលស្វាមីតវិលាថ្មី សុំលាឪពុកម្តាយចេញទៅនៅភូមិថ្មី ជនសេដ្ឋីឥតមានចែកទ្រព្យសម្បត្តិអ្វីឲ្យសោះ។ ឪពុកសោភណាធ្វើដូច្នេះ មិនមែនស្អប់កូនស្រីខ្លួនទេ គឺដើម្បីផ្តាញ់ផ្តាសំឡាញ់តាត់តែប៉ុណ្ណោះ។

សិរីវឌ្ឍន៍ទីនាសោភណាទៅកាប់តាស់ដីនឹងពលត្រៃ ហើយសង់ខ្ទមមួយគ្រាន់ជាទីសំណាក់អាស្រ័យ។ ឯប្រជាប់សម្រាប់តាស់ពនេះ នាងទៅសូមខ្ចីពីអ្នកស្រុកដែលនៅជិតខាង។ ប៉ុន្តែនាងបានលាក់ប្រាក់កាសខ្លះជារបស់នាង ហើយឆ្ពោះកំលួចឲ្យខ្លះយកទៅផង ដើម្បីទិញអង្ករបន្តពេលខ្វះប្តីប្រកបការងារបាន។

រៀងរាល់ថ្ងៃ ប្តីតែងទៅកាប់ទុស ខុកឲ្យប្រពន្ធនៅមើលរក្សាខ្ទម។ ដោយសោភណាជាស្ត្រីមិនចេះប្រកាន់ខ្ជួនតាំងពីដើមមក នាងបានសំគាតផ្ទះដោនិច្ច។ ត្រង់ដីនៅជិតខាងខ្ទមដែលប្តីនាងបានកាប់តាស់យកកូនឈើចោលអស់ហើយនោះ នាងរៀបចំធ្វើជាកន្លែងដាំស្ពឹក

ត្រៃ ជាថ្នាលជាំជើរ ខ្ចឹម ទីបំផុតទៅដល់ទៀបផ្សារទន្លាមានត្រប់ ម្ចេស តែស្ពឹងជើម
ដែលនាងទៅសុំពួជពីផ្ទះជិតខាងមក ។ ទុសដែលប្តីកាប់ចានមក នាង
យកទៅហាលថ្ងៃ ។ កាលណាប្តីទៅត្រៃ នាងទៅផ្ទះ ខ្ចូលទុស
ស្លូតយកទៅលក់ ។ ក្នុងការចិញ្ចឹមជីវិត នាងមិនចេះអៀនខ្មាសទេ
ឲ្យតែកិច្ចការនោះប្រកបដោយធម៌ហើយចំរើនផង ។ ប៉ុន្តែ សោកណា
មានសេចក្តីអៀនខ្មាសបំផុត ចំពោះតែការខុសត្រូវ នឹងអំពើរំលោភ ។
ម្ល៉ោះហើយ ដោយការស្រុះចិត្តគំនិតគ្នា គូស្វាមីភរិយាទោះបីមិនបានកើត
ពីផ្ទៃពុកម្តាយឲ្យក៏ដោយ ក៏គង់អាចញ៉ាំងជីវភាពឲ្យប្រព្រឹត្តទៅបានស្រួល
គ្រាន់តែមិនអាចធ្វើជាអ្នកមានទ្រព្យបានតែប៉ុណ្ណោះ ។ នាងតែងសង្ឃឹម
ពុកជាខ្លាំងថា ទៅតាទីដ៏មានមើលចំណាំចំពោះមនុស្សសុចរិតឡើយ ។

ចាប់តាំងពីពេលដែលសំរាវខ្ពន្ធ័ទីដ៏សោកណា ទៅតាំងចិត្តនៅ។ ទី
នោះ អ្នកភូមិជិតខាងបានខ្ចូលសេចក្តីសុខក្នុងការធ្វើដំណើរទៅមក
ត្រង់ភូមិចាស់នោះ ។ ពោះយ៉ាប់ក្តី ថ្ងៃក្តី គេលែងដែលប្រទះឃ្លោចលង
ប្លន់ចុះប្រកប្រហែកគ្នាដែលជាហេតុនាំឲ្យសេចក្តីតក់ស្លុត ។ ក្នុងពេលត្រីកាល
គេលែងក្រឡេកឃើញត្រាយហោះដូចមុនទៀតហើយ ។ ឥឡូវសូម្បី
តែការចម្ការជ្រុយជ្រាក់ ក៏គេមិនគាំងដែលឃើញផង ។

ដូច្នេះអ្នកភូមិគាំងឮយមានសេចក្តីស្ញើចនឹងទុកចូលថា គ្រួសារ
នេះប្រហែលចេះមន្តវិជ្ជាអ្វីខ្លាំងពូកែណាស់ បានជាខ្មោចមិនហ៊ានធ្វើទុក្ខ ។

មិនតែប៉ុណ្ណោះ ការសរសើរអំពីសេចក្តីសុខក្នុងគ្រួសារ ក៏មានស្ទើរតែគ្រប់មាត់ថែមទៀត គឺថាគេមិនដែលភ្ជាប់ប្រពន្ធមានពាក្យតូចពាក្យធំជាក់ឡើយ ។ កាលណាឃើញនាងខូលៗសលក់ គេតែងនាំគ្នាអាណិត ព្រោះគេជឿនាងជាធាតនៃសេដ្ឋី ម្តេចឡើយអត់ឮ មកយកប៉ាក្រឡុតដូច្នេះ ។ ចំណែកសេ.កណាវិញមានមុខស្រស់ជាងទៅ ព្រោះនាងយល់ថា: "សេចក្តីសុខរបស់មនុស្សពុំមែននៅត្រង់មានទ្រព្យឬក្រឡុតទេ គឺនៅត្រង់មានការធ្វើ ហើយនឹងគេញ៉ាំចិត្តចំពោះវាសនារបស់អាត្មា" ។

នៅជំនាន់នោះ មានមាណពម្នាក់ឈ្មោះ "រូបសិរី" ជាបុត្រនៃឋូណ្ណសេដ្ឋី ។

រូបសិរីតែងតែទទួលនូវការជ្មាក់ជ្មួលពីសំណាក់នៃមាតាបិតា ហើយពុំដែលធ្វើការហត្ថកម្ម មានការជ្មាសសំអាតទីលំនៅជាដើមម្តងសោះឡើយ ។ គេមានសិទ្ធិតែងការដើរលេងតាមអំពើចិត្ត បើមានប្រព្រឹត្តខុសឆ្គាំឆ្គងត្រង់ចំណាមួយ មាតាបិតាតែងអធ្យាស្រ័យឧត់ធេសឲ្យជាធម្មតា ។ ម្ល៉ោះហើយរូបសិរីមានចិត្តភ្លើតភ្លើន រហូតដល់ទៅហ៊ានប្រព្រឹត្តអបាយមុខគ្រប់យ៉ាង ហើយជាពិសេស ខ្លួវអំពើមាតុគ្រាម ។ អ្នកស្រុកពាំងឡាយដែលមានសីលធម៌តឹងខ្លួន មានសេចក្តីធុញទ្រាន់ពន់ពេក ខឹងការប្រព្រឹត្តមិនតប្រៀនៃសេដ្ឋីបុត្រនេះ ។

ថ្ងៃមួយ សោភណាខូលទស្សៅលក់តាមផ្ទះអ្នកស្រុក ហើយចូលទៅដល់លំនៅរបស់រាជាលើចំនួនយើញនាងកាលណា ស្រាប់តែមានចិត្តច្រដិតច្រឌយ៉ាងសាហាវស្ទើរវង្វេងពុំបាន ។ ក្រោយដែលនាងដើរហួសទៅ សេដ្ឋីបុត្រដណ្តឹងសួរអ្នកជិតខាងថា នាងដែលខូលទស្សលក់នេះជាកូនអ្នកណា ឬជាប្រពន្ធឈ្មោះណា ? ហេតុអ្វីក្នុងពេលមុនគ្មានដែលយើញ? ។ គេប្រាប់ថានាងជាសេដ្ឋីធនាគារដូចលោកដែរ ប៉ុន្តែមិនដឹងហេតុម្តេចបានជាមានចិត្តជាក់ទុកឲ្យមកអ្នកក្រឡត់ដូច្នេះ ។ សព្វថ្ងៃតាមការសង្កេតយើញថា នាងមានការខឿយហត់គួរអាណិតពេក ។ រាល់ថ្ងៃ តែកាលណាថ្ពេញទៅក្រៃ ខ្លួនត្រូវតែខូលទស្សដើរលក់ជានិច្ច ។ បងប៉ីនឹកថា នាងនេះជាកូនសេដ្ឋីដូចអញដែរ ។ ធម្មតាមនុស្សមែនតែគេពេញចិត្តចំពោះទ្រព្យសម្បត្តិ តែដែលនាងថ្លង់ធ្លាយធ្លាក់ខ្លួនមកជាស្រីកំសត់ ប្រហែលជាមានការណ៍សំងាត់អ្វីមួយជាអនិដ្ឋារម្មណ៍ដែលយើងមិនអាចដឹងបាន ហើយដែលសេដ្ឋីធានាធ្វើការសព្វថ្ងៃនេះគឺតាជាធ្វើទាំងចិត្តខ្លាំង ។ បើអញនិយាយចែចង់នាង ដោយប្រើមធ្យោបាយណាមួយទាក់ទងនឹងដើម នោះប្រាកដជានាងនឹងយល់ព្រមតាមមិនខានបើការណ៍នេះបានសម្រេចដូចសេចក្តីប្រាថ្នា ហើយ អញនឹងដំកល់នាងជាភរិយាពេញទី អញមិនបោកបញ្ឆោតដូចស្ត្រីដែលអញបានតភ្ជាប់ក្នុងពេលមុនទេ ប្លើយ អញមិនឲ្យនាងធ្វើការអ្វីទាំងអស់ រកទាស

ជាប្អូនខាត់ឲ្យទៅចំរើនដើរធ្វើការជួស ថ្នាក់ថ្នមជាត្រកងជាបាស្រអង្អែលមិនឲ្យ
ខានខ្វក់ចិត្តត្រង់បន្តិចណាសោះឡើយ ។

ចាប់ពីថ្ងៃនោះមក រសជាតិឆ្ងាញ់នៃអាហារនឹងដំណេកលក់ស៊ប់ លះ
បង់រួចស៊ីរ៉ៃ ព្រោះភេតភេតជុតពេលខ្លួនឯងសន្លាន ។ ចំណែកសោភណា
ឥតដឹងខ្លួនបន្តិចសោះ ។ តួឲ្យអនិច្ចា ខានតែងតែសំដែងចិត្តមុខញញឹម
ជាធម្មតាចំពោះជនខានាដែលខានជួបប្រទះ ហើយខានពុំដឹងថាចំពោះខ្លួន
ខាង ទឹងមានជនពាលសាខាឲ្យចំណងប្រព្រឹត្តអំពើអយុត្តធម៌ឡើយ ។

នៅភូមិនោះ មិនឆ្ងាយពីផ្ទះរួចស៊ីរ៉ៃប៉ុន្មាន មានស្ត្រីម្នាក់ឈ្មោះ
"យ៉ាំស្មា" ។ ខានេះជាអ្នកចេះខាយលក្ខណៈនឹងឫក្សជាមនុស្ស
ហើយមានស្ត្រីម្នាក់ទៀតឈ្មោះ "ខាំស្យា" ដែលតែងរកទទួលទានដោយ
អំពើណាមកម្យ៉ាង ហៅថា "ធ្លាមេអណ្តើក" ។

ដើម្បីញុំាងចំណងស្នេហាគាត្មាឲ្យសម្រេចឆាប់ ហើយដោយសង្ខឹងពីខាង
ផងនោះ រួចស៊ីរ៉ៃកំចួលទៅតិតការណ៍យ៉ាងស្ងាត់ជាមួយស្ត្រីពាលពីខាង
លើ ។ ដើម្បីឲ្យគេយកចិត្តទុកដាក់ជាមិត្តចាត់ចំពោះរឿងខ្លួន សេដ្ឋប្តូ
ត្រូវលួចប្រាក់អាពុក ចំនួនពីរយកហាបណៈយកទៅឲ្យមួយរយម្នាក់
រួចហើយនិយាយដោយទឹកមុខក្រៀមក្រំនឹងស្ត្រីម្នាក់ថា:

- សូមលោកម៉ងមេត្តាអាណិតកូយ សព្វថ្ងៃកូយស្ទើររលេះលួយថ្នមប្រមាត់អស់ហើយ ព្រោះតែចង់បានរូបខាងនោះមកផ្គត់ផ្គង់ ធ្វើជាពន្ធិតា

លោកម៉ងដែលចេះកលល្បិចខាងការយាំចំណាខ្លះ សូមយកមកប្រើឲ្យខានក្នុងពេលនេះណា លោកម៉ង !

ម៉ងយ៉ាំស្នា មុនដំបូងនៅស្ងៀម ធ្វើទឹកមុខជាអ្នកមធ្យឹត ប្តេចេីបធ្វើយដោយសំដីមួយៗថា:

-កុំព្រួយកុយៗមកពីងម៉ងម្តង ម៉ងនឹងចំប្រឹងជួយដោយពេញសមត្ថភាព សូមកុយខុកចិត្តចុះ ។

បន្ទាប់ពីនោះមក រួចសិរីនៅនិយាយទឹងម៉ងម៉ាស្បាទៀត ។ អ្នកអង្វរស្តីនេះសុំឲ្យជួយថ្នាក់ថ្នមលួងលោម ទឹងពន្យល់សោកស្តាយដោយប្រការយ៉ាងណា ដើម្បីឲ្យខាងឃ្លាតទឹងបែកចិត្តចេញពីប្តី ហើយឲ្យបាក់ចិត្តមកលើខ្លួន ប្រសិនបេីការណ៍នេះបានសម្រេចហើយ ម៉ងម៉ាស្បាទឹងត្រូវខួលរង្គាន់ថែមទៀត ។ ចុំន្តែសេដ្ឋីបុត្រប្រាប់ថែមទៀតថា មុនទឹងចាត់ការនេះ សូមលោកម៉ងអញ្ជេីញទៅប្រឹក្សាជាមួយម៉ងយ៉ាំស្នាផង ដេីម្បីកុំឲ្យខ្វែងយោបល់គ្នា ព្រោះខ្ញុំបានបានតឹងតាត់ឲ្យជួយក្នុងរឿងនេះដែរ ។

ថ្ងៃក្រោយមក គេឃេីញម៉ងម៉ាស្បា នៅឯផ្ទះម៉ងយ៉ាំស្នាដេីម្បីពិភាក្សាគ្នា ។

ម៉ងម៉ាស្បាសួរទាំងទឹកមុខញឹមញែមចំពោះម៉ងយ៉ាំស្នាថា :

-ជូបម្តេចទៅអ្នកបង ឮថារូបសិរីជាកូនបុណ្ណេះសេដ្ឋីបានសុំឲ្យជួយគិតការអ្វីឬ ?

មីងយ៉ាស្មាយកដៃទៅចិទមាត់មីងម៉ាស្សាហើយធ្ងាប់ថា:

-កុំនិយាយឮពេក ! ចុះដូចម្តេចក៏អូនដឹងរឿងនេះ ? ការណ៍នេះមានទោស ត្រូវប្រយ័ត !

មីងម៉ាស្សាយកដៃទាំងពីរខ្ទប់មាត់សើច ហើយឆ្លើយតប ។ ថា:

-គេបានទៅពឹងឲ្យខ្ញុំជួយដែរ ហើយបង្គាប់ខ្ញុំឲ្យមកជួបមីងអ្នកបង្កុនធ្វើការ ។ ម្យ៉ាងទៀត គេឲ្យអ្នកបង្កុនប៉ុន្មាន ?

-មួយរយកហាបណៈ, ចុះអូនឯង គេឲ្យប៉ុន្មានដែរ ?

-មួយរយដូចគ្នា ។

មីងម៉ាស្សាសើចទៀតថា:

-អ្នកក្រខ្សត់ម៉ែបនេះ ឥតពីបាកអ្វីទេអ្នកបង្កុន លុយនេះស៊ីទ្វាញ់ណាស់ ។ អម្បាលពេលមុនៗ សុទ្ធតែប្រពន្ធអ្នកមានយសសក្តិ ខំឆ្ងល់ក្លាន អ្នកមានសម្បត្តិធំ ម៉ែចតង់ខ្ញុំតិតការកើត ឥតមានផលរាស់អ្វី ដូចជាប្រពន្ធលោក «សាយ៉ា» ទៅខូចជាមួយអ្នកកំសោយមិនតឹស្មាដៃខ្ញុំ ! ក្លាន់ក្រមុំលោក "ប៉ុន្តែ" ទៅស្រឡាញ់ "អាម៉ូវតូរ" ហើយបានជាប់គ្នាជាប្តីប្រពន្ធរហូតដល់សព្វថ្ងៃ មិនតឹស្មាដៃខ្ញុំ អ្នកបង្កុនឃើញថ្នាក់ទេ សុទ្ធតែអ្នកមានលុយ ។

មីងយ៉ាស្មានិយាយកាត់ថា:

-បំណាច់ខ្លួលលុយគេហើយ យើងត្រូវធ្វើការម៉ាត់ចត់ឲ្យគេ មែន

ឬទេអូន ? ដូច្នេះអូនឯងនឹងចាំបងធ្វើការមុនសិន ។

ព្រឹកស្អែកប្រហែលម៉ោងប្រាំបី សោភណាតែងតែខ្លួនៗសៅលក់ជាធម្មតា ។ លុះមកដល់ផ្ទះមីងយ៉ាស្មា ។ ស្រែកហៅនាងឲ្យចូលដើម្បីទិញៗស ។ គាត់សំដែងទឹកមុខរីករាយនឹងពាក់ព័ន្ធនាងថ្លែតជាធម្មតា ។ ក្រោយដែលបានទិញៗសរួចហើយ គាត់ធ្វើជាចាប់ដៃអង្អែលស្មានាង ព្រមភាំងសរសើរចំពោះសាច់ឈាមនឹងទឹកមុខប្រឹមប្រើយដោយសំដីរាន់ផ្អែម រួចនិយាយសុំទោសថា :

-នែកូន ! ម្តាយសុំទោស សូមសួរបន្តិច !

សោភណាជំពប់ទៅវិញដោយពាក្យសុភាពថា :

-ចាស ! លោកមីង ! មានការណ៍អ្វី អញ្ជើញសួរចុះ ឥតមានទោសនៃរេ លោកមីងកំដូចជាម្តាយខ្ញុំដែរ ។

-ម្តាយឃើញកូនមានរូបល្អ មើលទៅទឹកមុខកំស្រស់ សាច់ឈាមកំស្អាត សមជាអ្នកស្រណុក ម្តេចឡើយទៅជាក្រ ខ្លួនៗសលក់យ៉ាងនេះ ម្តាយចង់សុំពិនិត្យលក្ខណៈបន្តិច តាមវិជ្ជាហោរដែលម្តាយបានបេះខ្លះនោះ ។

ចំណុចនេះត្រូវនឹងចំណង់សោភណាដែរ ទើបនាងហុចដៃឲ្យមីងយ៉ាស្មាពិនិត្យ ។ លុះពិនិត្យដៃចាំងពីរសព្វគ្រប់ហើយ មីងយ៉ាស្មានិយាយដោយសំដីមុងមាត់ថា :

-កូនឯង បើតាមលក្ខណៈនឹងឋិតជាតិជាអ្នកមានសម្បត្តិសុភ
ហើយឥតខ្សោយលំបាកឡើយ ប៉ុន្តែត្រង់បាតដៃស្តាំ ឥស់មានខ្សែ
មកជាំជាប់ខ្លះ តែពេះជាជួយជ្នះក៏ដោយ ព្រះចន្ទនឹងរបួតតាមិនដ
មិនឆាប់ ។

ឮដូច្នោះ សោកណាគតអរក្រៃ ដោយយល់ថាថ្ងៃណាមួយ ត
ព្រមចាំនឹងបានជួសជុលមុខជានឹងបានរដោះតាការក្រលំបាកជាមិនខាន
មីងយ៉ាស្មាច្រាបថាបញ្ជាក់ថា :

-ខំនាយប៉ុន្មានម៉ាត់នេះ មានការបកស្រាយវែងបន្តិច តែក្រែង
ប្រញាប់ពេលគត់ទស ចូរពេលគត់ចុះ ។

ដោយចង់ដឹងរឿងឲ្យបានច្បាស់លាស់ សោកណាក៏អង្វរមីងយ៉ា
សុំបកស្រាយឲ្យស្តាប់ ។

គាត់ចាប់ពាក្យមួងវែត ខ្ទរដៃចាំនឹងគូនៃសោកណា មកជាក់
នៅលើក្តារគាត់ធ្វើជាសំឡឹងតិចិត្យដោយស្ងៀមស្ងាត់ រួចពើបនិយាយ
-ដៃលម្ខាយថា មានខ្សែពហ៊ុចាំនឹងបន្តិចនោះ ពហ៊ុជាសត្រូ
លោកវែ រាមនឹងតែរកចាប់ព្រះចន្ទ្រលេច ប៉ុន្តែរលេចមិនយូរប
ព្រះចន្ទ្រនឹងរបួតពីកណ្តាប់ដៃ ដោយសារកម្លាំងបុណ្យ តែជាកូនសត្វ
បីតែនៅក្នុងកណ្តាប់ដៃពហ៊ុ ក៏ជាកូនមានរសចក្តីខ្សែហត់ដូច្នេះ
តាមនិយាយ បើម្តាយថាហើយ សូមកូនកុំសង្ស័យអនិច្ចតា